

ប្រវត្តិសាស្ត្រ គឺជាចំណេះដឹងពីអតីតកាលដែលជួយឱ្យកូនខ្មែរចេះវិភាគ ដើម្បីស្គាល់ប្រទេសខ្លួនឯងពីអតីតកាល យល់ពីបច្ចុប្បន្នកាល និងសម្លឹងទៅរកអនាគតកាលដោយភាពជឿជាក់។ ប្រវត្តិសាស្ត្រខ្មែរបង្ហាញពីកត្តា«ភូមិសាស្ត្រនយោបាយ» ដែលមានឥទ្ធិពលយ៉ាងខ្លាំងក្លាលើវាសនាកម្ពុជា។ ដូច្នេះ កូនខ្មែរជំនាន់ក្រោយត្រូវចេះប្រវត្តិសាស្ត្រ ដើម្បីខិតខំប្រឹងប្រែងរៀបចំផែនការកសាងជាតិឱ្យថ្កុំថ្កើងរុងរឿងនាពេលអនាគត។


ISBN: 978 99243 40 69 0

អបអរសាទរទិវាប្រវត្តិសាស្ត្រជាតិ ថ្ងៃទី៩ វិច្ឆិកា





ប្រវត្តិសាស្ត្រកម្ពុជា
ក្នុងបរិបទសកលលោក



ដោយ បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

សហការជាមួយគ្រឹះស្ថានបោះពុម្ពផ្សាយស៊ីប៉ា
Sipar
២០១៩

ប្រវត្តិសាស្ត្រកម្ពុជា
ក្នុងបរិបទសកលលោក

ប្រវត្តិសាស្ត្រកម្ពុជា
ក្នុងបរិបទសកលលោក

ដោយ បណ្ឌិតសភាចារ្យ ហាច់ ជួន ណារ៉ុន

២០១៩

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

រចនាទំព័រ និងសម្រួលអត្ថបទដោយអង្គការSipar
© ហង់ជួន ណារ៉ុន
រក្សាសិទ្ធិគ្រប់យ៉ាង

បោះពុម្ពនៅកម្ពុជាដោយពោធិ៍ពុម្ព អេស អេច

មាតិកា

អារម្ភកថា xi

ជំពូក១-ប្រវត្តិសាស្ត្រខ្មែរសម័យមុនអង្គរ ១

១-ការកកើតអារ្យធម៌ខ្មែរ ១

២-ប្រវត្តិសាស្ត្រខ្មែរពីសតវត្សទី១ដល់ចុងសតវត្សទី៨ ..... ១០

ជំពូក២-សម័យអង្គរុងរឿង ២៧

១-តើព្រះមហាក្សត្រអង្គណាជាអ្នកកសាងរាជវង្សអង្គរ? ២៧

២-មហាវីរក្សត្រសម័យអង្គរ ៣៣

៣-មូលហេតុអ្វីបានជាអារ្យធម៌ខ្មែរឈានដល់កំពូលនៅសម័យអង្គរ? ៥១

៤-ហេតុអ្វីបានជាអង្គរធ្លាក់ចុះ? ៥៤

៥-អ្នកប្រាជ្ញនៅសម័យអង្គរ ៥៩

ជំពូក៣-ការកកើតរដ្ឋតូចៗក្រោយការធ្លាក់ចុះនៃចក្រភពអង្គរ ៦៥

ជំពូក៤-ការចាកចោលអង្គរ ៦៩

១-តើប្រវត្តិសាស្ត្រ ខ្មែរសម័យក្រោយអង្គរអាចចែកចេញជាដំណាក់កាលអ្វីខ្លះ? ៦៩

២-មូលហេតុអ្វីបានជាកម្ពុជាត្រូវបែកចែកជាបីនៅសតវត្សទី១៥? ៧១

ជំពូក៥-សម័យលង្វែក ៧៥
១-ព្រឹត្តិការណ៍សំខាន់ៗនៅដើមសម័យលង្វែក ៧៦
២-ការខិតខំប្រឹងប្រែងដើមបីកសាងវិញរបស់ខ្មែរក្រោយសម័យអង្គរ ... ៧៩
៣-មូលហេតុអ្វីបានជាលង្វែកបែកបាក់? ៧៩

ជំពូក៦-សម័យឧដុង្គ ៨៥
១-តើមូលហេតុអ្វីបានកម្ពុជាមិនអាចដើរឡើងវិញបាន នៅសម័យឧដុង្គ? ៨៦
២-តើមូលហេតុអ្វីបានកម្ពុជាបាត់បង់ទឹកដីកម្ពុជាក្រោម? ៨៨
៣-តើមូលហេតុអ្វីបានខ្មែរចំណុះឱ្យសៀមនៅសតវត្សទី១៨? ... ៩២
៤-តើមូលហេតុអ្វីបានជាកម្ពុជាធ្លាក់នៅក្រោមការគ្រប់គ្រង និងត្រួតត្រារបស់សៀម និងវៀតណាមនៅក្នុងសតវត្សទី១៩? ... ៩៤
៥-អក្សរសិល្ប៍ខ្មែរសម័យឧដុង្គ ៩៨

ជំពូក៧-ការកសាងជាតិឡើងវិញក្នុងរជ្ជកាលអង្គដួង ១០៣
១-តើមូលហេតុអ្វីបានជាមន្ត្រីខ្មែរយោងព្រះបាទអង្គដួងឱ្យឡើងសោយរាជ្យ? ១០៣
២-តើព្រះបាទអង្គដួងបានបន្សល់មត៌កអ្វីខ្លះសម្រាប់កម្ពុជា? ១០៥

ជំពូក៨-អាណាព្យាបាលបារាំង ១០៩
១-តើមូលហេតុអ្វីបានជាបារាំងចូលមកកាន់កាប់កម្ពុជា? ... ១០៩
២-តើអាណាព្យាបាលបារាំងនៅកម្ពុជាអាចចែកចេញជាប៉ុន្មានដំណាក់កាល? ១១១
៣-តើរជ្ជកាលព្រះបាទនរោត្តមបានបន្សល់ទុកសមិទ្ធផលអ្វីខ្លះ? ១១៥

៤-ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនៃសតវត្សទី២០ ..... ១១៧
៥-តើអ្វីទៅជាព្រឹត្តិការណ៍ធំៗក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ? ១១៩
៦-តើអ្វីបានជាចាំបាច់បង្កើតនូវអត្តសញ្ញាណជាតិខ្មែរ
ឡើងវិញ? ១២៣
៧-តើអ្វីទៅជាចតុស្តម្ភព្រះពុទ្ធសាសនានៅសតវត្សទី២០? ... ១២៧
៨-សង្គ្រាមលោកលើកទី២ និងការបែកចែក
ពិភពលោកជាពីរ..... ១២៩
៩-តើកម្ពុជាទទួលបានឯករាជ្យពីបារាំងដោយវិធីណា? ១៣១
១០-អក្សរសិល្ប៍ខ្មែរនៅសតវត្សទី១៩ និងដើមសតវត្សទី២០ ..... ១៣៤

ជំពូក៩-សង្គមរាស្ត្រនិយម (១៩៥៣-១៩៧០) ១៣៧
១-តើអង្គការនយោបាយសង្គមរាស្ត្រនិយមដែលបង្កើតឡើង
ដោយ សម្តេចនរោត្តម សីហនុអាចបង្រួបបង្រួម
អ្នកនយោបាយខ្មែរគ្រប់និន្នាការ និងមហាជនជុំវិញ
ព្រះមហាក្សត្រ ដើម្បីកសាងប្រទេសជាតិដែរឬទេ? ១៣៩
២-តើកម្ពុជាដឹកនាំដោយសម្តេចនរោត្តម សីហនុអាចប្រកាន់
យកនយោបាយការបរទេសអព្យាក្រឹតបានឬទេ? ១៤៥
៣-សមិទ្ធផល និងការធ្លាក់ចុះនៃរបបសង្គមរាស្ត្រនិយម..... ១៥១
៤-ស្នាដៃអក្សរសិល្ប៍ខេមរនិយមសម័យឯករាជ្យ..... ១៥៦

ជំពូក១០-សាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)..... ១៦៣
១-ហេតុអ្វីបានជាព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរីមតៈ
និងឧត្តមសេនីយ លន់ នល់ធ្វើរដ្ឋប្រហារទម្លាក់
សម្តេចនរោត្តម សីហនុពីតំណែង? ១៦៣
២-សង្គ្រាមក្នុងស្រុក និងការធ្វើអន្តរាគមន៍យោធាបរទេស.... ១៦៥

៣-ផលវិបាកនៃរដ្ឋប្រហារផ្តួលរំលំសម្តេចសីហនុ
សម្រាប់កម្ពុជា ១៧២
៤-ការពង្រឹងចលនាឆ្វេងនិយម និងកុម្មុយនីស្តនៅកម្ពុជា ១៧៤

ជំពូក១១-កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ១៨៩
១-មូលហេតុអ្វីបានជាខ្មែរក្រហមធ្វើបដិវត្តន៍? ១៩០
២-ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្ស? ១៩៨
៣-មូលហេតុអ្វីបានជារបបកម្ពុជាប្រជាធិបតេយ្យដួលរលំ? ២០៤

ជំពូក១២-សាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩) ... ២១១
១-ការកសាងជាតិឡើងវិញក្នុងរបបសាធារណរដ្ឋ
ប្រជាមានិតកម្ពុជា ២១១
២-ការស្តារនិងកសាងជាតិឡើងវិញលើគ្រប់វិស័យ ២២១
៣-ការប្រយុទ្ធតស៊ូប្រឆាំងនឹងការរំលៃត្រលប់នៃ
របបប៉ុល ពត ២៣៤

ជំពូក១៣-រដ្ឋកម្ពុជា និងដំណើរការស្វែងរកសន្តិភាព
នៅកម្ពុជា (១៩៨៩-១៩៩២) ២៣៧
១-ការរកដំណោះស្រាយបញ្ហាកម្ពុជា ដោយសន្តិវិធី ២៣៧
២-របត់នយោបាយក្នុងប្រទេស ដើម្បីបង្រួបបង្រួមជាតិ ២៦០
៣-ដំណើរការចរចាដើម្បីដោះស្រាយបញ្ហាកម្ពុជា ២៦៤
៤-ការសម្រេចបានកិច្ចព្រមព្រាងសន្តិភាពទីក្រុងប៉ារីស ២៥៥
៥-កម្ពុជាក្នុងដំណាក់កាលអន្តរកាលក្រោមការដឹកនាំ
របស់អ៊ុនតាក់ ២៥៧

ជំពូក១៤-ការបង្កើតព្រះរាជាណាចក្រកម្ពុជាទី២ (១៩៩៣-២០០៤) ២៦៣
១-ការបង្កើតឡើងវិញនៃរបបរាជានិយមនៅកម្ពុជា ២៦៣
២-នយោបាយឈ្នះ-ឈ្នះរបស់សម្តេចហ៊ុន សែន ដើម្បីកសាងសន្តិភាពឡើងវិញនៅកម្ពុជា ២៦៥
៣-ការកាត់ទោសមេដឹកនាំខ្មែរក្រហម និងការបិទទំព័រប្រវត្តិសាស្ត្រខ្មៅងងឹត ២៦៩

ជំពូក១៥-ការបើកសកលរាជធ្មី និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា ២៧៣
១-ការសម្រេចបាននូវសុខសន្តិភាពទូទាំងប្រទេស ២៧៣
២-ការឡើងសោយរាជ្យរបស់ព្រះករុណា នរោត្តម សីហមុនី ២៧៥
៣-យុទ្ធសាស្ត្រអភិវឌ្ឍកម្ពុជាក្នុងគ្រប់វិស័យ ២៧៦
៤-សមិទ្ធផលនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា នៅក្នុងឆ្នាំ ១៩៨៩-២០១៨ ..... ២៧៩

ឯកសារយោង ២៩៣

អារម្ភកថា

គោលបំណងនៃការសរសេរសៀវភៅ«ប្រវត្តិសាស្ត្រប្រទេសកម្ពុជា» គឺដើម្បី៖

ទីមួយ- *ជួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក្នុងការអនុវត្តកម្មវិធីសិក្សាតាមបែបបញ្ជត្តិ ជាពិសេសក្នុងការបង្រៀន និងការរៀនតាមបែបរិះរក (Enquiry-Based Learning or IBL) ដោយផ្តល់នូវឯកសារបង្រៀនកាន់តែសម្បូរណ៍បែបជាខេមរភាសា។*

ទីពីរ- *លើកកម្ពស់ការសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រ និងការចោះពុម្ពផ្សព្វផ្សាយវណ្ណកម្មប្រវត្តិសាស្ត្រ ដោយអ្នកស្រាវជ្រាវកម្ពុជា។ សៀវភៅប្រវត្តិសាស្ត្រកម្ពុជាជំពូកច្រើនលើសលប់ត្រូវបានសរសេរ និងចោះពុម្ពផ្សាយភាគច្រើនជាភាសាអង់គ្លេស និងជាភាសាបារាំង។*

ទីបី- *ចូលរួមវិភាគទានដ៏តិចតួចស្តួចស្តើង ក្នុងការសិក្សាប្រវត្តិសាស្ត្រកម្ពុជា។*

ការសិក្សាប្រវត្តិសាស្ត្រអាចឱ្យយើងស្គាល់ពីអតីតកាល និងអាចប្រមើលមើលអនាគតកាល។ ចំណេះដឹងខាងផ្នែកប្រវត្តិសាស្ត្រជួយឱ្យកូនខ្មែរចេះវិភាគ ដើម្បីយល់ពីអតីតកាល ស្គាល់បច្ចុប្បន្នកាល និងសម្លឹងទៅរកអនាគតកាល។

ខ្ញុំចាប់ផ្តើមសរសេរសៀវភៅ «ប្រវត្តិសាស្ត្រប្រទេសកម្ពុជា» ពីការកសាងនិងបង្រួបបង្រួមជាតិឱ្យក្លាយទៅជាមហានគរ និងការបែកបាក់ជាតិខ្មែរសម័យឧដុង្គ និងបញ្ចប់សៀវភៅនេះត្រង់ការបែកបាក់ និងការបង្រួបបង្រួមជាតិ និងការកសាងជាតិឡើងវិញ។ វដ្តនេះមានរយៈពេលជាង១០០០ឆ្នាំ។

ប្រវត្តិសាស្ត្រខ្មែរបង្ហាញពីកត្តា «ភូមិសាស្ត្រនយោបាយ» ដែលមាន

ឥទ្ធិពលយ៉ាងខ្លាំងក្លាមកលើវិសាលភាពកម្ពុជា ពោលគឺស្ថានភាពភូមិសាស្ត្រ កំណត់នយោបាយក្នុងប្រទេសកម្ពុជា និងកំណត់ការវិវត្តនៃប្រវត្តិសាស្ត្ររបស់កម្ពុជា។ ស្ថានភាពភូមិសាស្ត្រអនុញ្ញាតឱ្យអាណាចក្រខ្មែរដើរតួនាទីកំណត់នៅអាស៊ីអាគ្នេយ៍ពីសតវត្សទី១ដល់សតវត្សទី១៣។ ថ្វីត្បិតតែឥណ្ឌា និងចិនជាប្រទេសធំ ដែលមានអារ្យធម៌ខ្ពស់ក្នុងតំបន់ ប្រទេសទាំងពីរមានឥទ្ធិពលលើអាណាចក្រខ្មែរ តាមរយៈការហូរចូលនៃវប្បធម៌ ប្បាប់ និងទ្រឹស្តីក្នុងការគ្រប់គ្រងរដ្ឋតែប៉ុណ្ណោះ តាមរយៈសាសនា និងពាណិជ្ជកម្ម។ ការពង្រឹងរដ្ឋសៀមបានធ្វើឱ្យអាណាចក្រខ្មែរស្ថិតនៅចន្លោះប្រទេសធំពីរ ហើយស្ថានភាពត្របដណ្តប់នេះចាប់ផ្តើមរង្គោះរង្គើបន្តិចម្តងៗ។ ក៏ប៉ុន្តែ កម្ពុជានៅរក្សាបានទូវតួនាទីខ្លះនៅជ្រោយឥណ្ឌាចិនរហូតដល់ចុងសម័យលង្វែក។

តួនាទីរបស់កម្ពុជានៅអាស៊ីអាគ្នេយ៍បានធ្លាក់ចុះបន្តិចម្តង។ ចាប់ពីសតវត្សទី១៦ដល់សតវត្សទី១៩។ នៅសតវត្សទី១៦ ពេលខ្លះកម្ពុជាត្រូវបង្ខំចិត្តចំណុះឱ្យសៀម។ ក៏ប៉ុន្តែ ចាប់ពីពាក់កណ្តាលសតវត្សទី១៧ទៅ កម្ពុជាចាប់ផ្តើមងាកទៅរកជំនួយពីវៀតណាម ដើម្បីយកវៀតណាម ធ្វើជាកូនជញ្ជីងទប់ទល់នឹងសៀម។ គោលនយោបាយនេះបានធ្វើឱ្យដីខ្មែរត្រូវបានបាត់បង់ជាបណ្តើរៗ ហើយនៅចុងសតវត្សទី១៨ និងនៅដើមសតវត្សទី១៩កម្ពុជាស្ថិតនៅក្រោមការត្រួតត្រារបស់សៀម និងវៀតណាមតែម្តង។

នៅក្នុងសៀវភៅ«ប្រវត្តិសាស្ត្រប្រទេសកម្ពុជា» យើងអាចចែកប្រវត្តិ-សាស្ត្រខ្មែរជាដំណាក់កាលសំខាន់ៗ ដូចជា៖

ទី១-ដំណាក់កាលបង្រួបបង្រួមប្រទេស ដោយឈរលើកត្តាដូចតទៅ ៖ (១) ព្រហ្មញ្ញសាសនា និងការកសាងស្ថាប័នជាតិ (២) ការពង្រឹងគ្រប់គ្រងប្រទេស (៣) ការអភិវឌ្ឍសេដ្ឋកិច្ច និងវប្បធម៌ តាមរយៈការបង្កើតអត្តសញ្ញាណជាតិ និងដែលបង្រួបបង្រួមជាតិខ្មែរជុំវិញព្រះមហាក្សត្រ និង (៤) ការកសាងប្រព័ន្ធអប់រំ និងការអភិវឌ្ឍធនធានមនុស្ស សម្រាប់ការកសាងជាតិ។

ទី២-ដំណាក់កាលបែកបាក់ជាតិ ក្រោយសម័យអង្គរ ដោយសារកត្តាដូចតទៅ ៖ (១) សង្គ្រាមហែកហួរជាតិ ដណ្តើមអាជ្ញ និងសង្គ្រាមជាមួយប្រទេសជិតខាង (២) ការគ្រប់គ្រងបែបបុរាណ ដោយមិនគិតពីរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ច្បាប់ និងការអភិវឌ្ឍស្ថាប័ន (៣) វិបត្តិសេដ្ឋកិច្ច និងការគ្រប់គ្រងតាមបែបបុរាណ (៤) គ្មានគោលការណ៍ច្បាស់លាស់ក្នុងការស្នងរាជ្យ និងការឡើងសោយរាជ្យដោយប្រើកម្លាំងកងទ័ព (៥) ការមិនគិតគូពីការអភិវឌ្ឍធនធានមនុស្ស។

គឺក្នុងគោលដៅនេះហើយ ទើបខ្ញុំសម្រេចចិត្តសរសេរសៀវភៅប្រវត្តិសាស្ត្រនេះ ក្នុងគោលដៅផ្តល់នូវគំនិតដ៏តិចតួចស្តួចស្តើង ដើម្បីឱ្យកូនខ្មែរជំនាន់ក្រោយចេះប្រើកូមិសាស្ត្រនយោបាយកម្ពុជា ដើម្បីរកឯកភាពជាតិ និងកសាងជាតិឱ្យថ្កុំថ្កើងរុងរឿងបាន ជាពិសេសក្នុងយុគសម័យនៃបដិវត្តន៍ឧស្សាហកម្មលើកទី៤។

ថ្ងៃចន្ទ ១៤កេីត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩
បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

ជំពូក១
ប្រវត្តិសាស្ត្រ ខ្មែរសម័យមុនអង្គរ

១-ការកកើតអារ្យធម៌ខ្មែរ

ក-ពិភពលោកនៅសម័យមុនគ្រិស្តសករាជ

បុរេប្រវត្តិ គឺជាសម័យកាល ដែលគេគិតចាប់ពីមនុស្សចេះដើរដោយជើងក្រោយទាំងពីរ ហើយចាប់ប្រើដៃសម្រាប់ប្រើប្រាស់។ ប្រវត្តិសាស្ត្រមនុស្សជាតិចាប់ផ្តើមប្រមាណជា៦លានឆ្នាំមុន នៅពេលដែលសត្វស្វា Ape ចាប់ផ្តើមដើរត្រង់ខ្លួន។ ពូជមួយ គឺ Homo erectus រៀនប្រើប្រាស់ភ្លើង និងប្រើថ្មជាឧបករណ៍។ សម័យបុរេប្រវត្តិសាស្ត្រ គឺចាប់ពីរយៈពេលប្រមាណ ៣លានឆ្នាំរហូតដល់៣ ៦០០ឆ្នាំមុនគ.ស. ដែលជាឆ្នាំកំណើតអក្សរនៅមជ្ឈិមបូព៌ា។ សម័យបុរេប្រវត្តិសាស្ត្រចែកចេញជាយុគចំនួន៣គឺ ៖ (១) យុគថ្មបំបែក (Paléolithique) ចាប់ពីពេលមានមនុស្សរហូតដល់ឆ្នាំ៦ ០០០ មុនគ.ស. (២) យុគថ្មរំលីង (Néolithique) ពី៦ ០០០ឆ្នាំមុនគ.ស.ដល់ ២ ០០០ ឆ្នាំមុនគ.ស. និង (៣) យុគប្រើប្រដាប់ប្រដាធ្វើពីលោហធាតុ ពី ២ ០០០ ឆ្នាំមុនគ.ស.។

កំណាយបុរាណវិទ្យាបានរកឃើញថា នៅអាស៊ីអាគ្នេយ៍មានអំបូរមនុស្ស Homo erectus រស់នៅប្រមាណជា១,៩លានឆ្នាំមុន ហើយពូជអំបូរ

ម៉ឺងហ្គោលខ្ពអីត និងអូស្ត្រូឡូអីតមានវត្តមាននៅក្នុងតំបន់ជាយូរយោណាស់មកហើយ។ នៅឆ្នាំ២០០ ០០០មុនពួជសាសន៍មនុស្ស Homo sapiens បានលេចរូបរាងឡើង។ មនុស្សនេះរស់នៅជាអ្នកបរបាញ់ និងប្រមូលផល ហើយរស់នៅគ្រប់ទិសទីកន្លែងលើកពផែនដី។ វប្បធម៌ហាវបីញ (Hoabinh) គឺជាមូលដ្ឋានគ្រឹះនៃការវិវត្តសង្គម និងសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ ដោយពួកគេរស់នៅមុនយុគថ្មរំលីងពី១៣ ០០០ឆ្នាំដល់៤ ០០០ឆ្នាំមុនគ.ស.។ ពួកគេរស់នៅដោយបរបាញ់សត្វ ប្រមូលអាហារ និងនេសាទ។ ប្រមាណជា ៥ ៥០០ឆ្នាំមុនគ.ស. ប្រជាជននៅអេហ្ស៊ីបចាប់ផ្តើមចេះធ្វើស្រែចម្ការ ដែលនាំមនុស្សឱ្យរស់នៅតាមរបៀបថ្មី។ គេហៅយុគនេះថាយុគថ្មបំបែក។ តំបន់មេសូប៉ូតាមីបានក្លាយទៅជាវាលស្រែដ៏ធំល្វឹងល្វើយ តាមដងទន្លេនីលទីហ្គ្រីស និងអឺហ្វ្រាត។ ស្តេចហ្សាវ៉ាអុង Djoser ដែលគ្រងរាជ្យនៅ ២៦៣០-២ ៦៥១ឆ្នាំមុនគ.ស. បានសាងសង់ពីរ៉ាមីដទី១។ នៅពេលដែលអារ្យធម៌កាន់តែមានភាពសម្បូរណ៍បែបឡើង មនុស្សចាប់ផ្តើមសរសេរ ហើយពួកអេហ្ស៊ីបបានបង្កើតអក្សរមុនគេ ដើម្បីកត់ត្រាទុកនូវការធ្វើពាណិជ្ជកម្ម អក្សរសាស្ត្រ សាសនា ច្បាប់ និងកត់ត្រាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមនុស្សជាតិ។ ពួកអេហ្ស៊ីបប្រើប្រាស់រូបភាពនៃរបស់របរប្រើប្រាស់ប្រចាំថ្ងៃ ដើម្បីកត់ត្រាគំនិត និងសំឡេង។

នៅអំឡុងជាង១ ៥០០ឆ្នាំមុនគ.ស. ជនជាតិអារ្យាន (Aryans) បានមកតាំងទីលំនៅនៅឥណ្ឌាភាគពាយ័ព្យ ដោយនាំមកនូវព្រហ្មញ្ញសាសនាមកផងដែរ ដែលមានគម្ពីរវេទជាមូលដ្ឋាន និងភាសាសំស្ក្រឹតជាភាសាយាន។ ចាប់ពីសតវត្សទី៩មុនគ.ស. ពួកអាស៊ីរី (Assyrians) នៅភាគខាងជើងម៉េសូប៉ូតាមី បានបង្កើតជាអាណាចក្រអាស៊ីរីដ៏ធំមួយ ដែលមានព្រំដែនលាតសន្ធឹងពីអេហ្ស៊ីបដល់អ៊ីរ៉ាក់។ តែក្រោយមក ពួកបាប៊ីឡូនបានកម្ទេចអាណាចក្រនេះចោលទៅ។

នៅប្រមាណឆ្នាំ៦២៣មុនគ.ស. ព្រះសមណ គោតម (Gautama)

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បានប្រសូតជាព្រះរាជបុត្រនៅឥណ្ឌាខាងជើង។ ព្រះអង្គសុខចិត្តលះបង់នូវជីវិតស្តេច ហើយរស់នៅក្នុងជីវភាពសាមញ្ញក្រោមដើមឈើ ក្នុងរយៈពេល ៦ឆ្នាំមុនទីងត្រាស់ដឹង ដែលមានព្រះនាមថា ជាព្រះពុទ្ធ។ នៅឆ្នាំ៥៥០មុន គ.ស. ខុងជឺ ក៏បានចាប់កំណើតផងដែរ ហើយក្រោយមកបានក្លាយជាទស្សនវិទូចិនដ៏ល្បីល្បាញ ដែលមានឥទ្ធិពលលើនយោបាយ និងគំនិត។ អាណាចក្រពែរ្សក៏ចាប់បដិសន្ធិ និងមានអត្តភាពក្នុងរយៈពេល៣០ឆ្នាំ ពី៥៥៨ដល់ ៥៣០ឆ្នាំមុនគ.ស.។ នៅឆ្នាំ៥០៩មុនគ.ស. សាធារណរដ្ឋរ៉ូមក៏ចាប់ផ្តើមលេចរូបរាងឡើង។ នៅអំឡុង៥០០ឆ្នាំមុនគ.ស. អារ្យធម៌ក្រិកបានឈានដល់កំពូលខាងផ្នែកស្ថាបត្យកម្ម និងទស្សនវិជ្ជា។ ទស្សនវិទូក្រិកមានឥទ្ធិពលយ៉ាងខ្លាំងក្លាលើអារ្យធម៌បស្ចិមប្រទេស ក្នុងរយៈពេលរាប់សតវត្ស។ ឧត្តមសេនីយដ៏ល្បីល្បាញរបស់ក្រិកម្នាក់គឺ អាឡិចសង់ (៣៥៦-៣២៣ឆ្នាំមុនគ.ស.) (Alexander the Great) បានក្លាយជាស្តេចនៃម៉ាសេដូន នៅភាគខាងជើងក្រិក ហើយបានបង្កើតអាណាចក្រដ៏ធំមួយ ដែលលាតសន្ធឹងពីក្រិកដល់ឥណ្ឌាភាគខាងជើង។

នៅឆ្នាំ២៦២មុនគ.ស. ព្រះចៅអធិរាជអសោក ដែលគ្រងរាជ្យពីឆ្នាំ២៦៨ដល់២៣២ឆ្នាំមុនគ.ស. បានក្លាយជាពុទ្ធសាសនិក ហើយបានសាងសង់ចេតិយដ៏ធំមួយនៅសាន់ឈី ដើម្បីជាក់អដ្ឋិធាតុព្រះពុទ្ធ។ ព្រះចៅអធិរាជអសោកបានបញ្ជូនសាមណទូតទៅកាន់តំបន់នានា ដើម្បីផ្សព្វផ្សាយព្រះពុទ្ធសាសនា។ ទន្ទឹមនឹងនេះ នៅ២២១ឆ្នាំមុនគ.ស. ស្តេចចិនព្រះនាមហ្សេងនៃរាជាណាចក្រឈីន បានវាយយករដ្ឋចិន៦ផ្សេងទៀត ហើយបានប្រកាសខ្លួនជាព្រះចៅអធិរាជ។ នៅពេលព្រះអង្គចូលទិវង្គត ប្រជាជនប្រមាណជា៧សែននាក់ត្រូវបានកែនមកធ្វើផ្នូរព្រះអង្គ ហើយសពព្រះអង្គកប់ជាមួយទាហានដីលើភ្នំឡាំងយ៉ា ខេត្តអានហឺ។ នៅឆ្នាំ១១០មុនគ.ស. ចិនបានបង្កើតផ្លូវសូត្រ ដែលជាផ្លូវពាណិជ្ជកម្មពីចិន ឆ្លងកាត់តាមដងភ្នំនៃអាស៊ីកណ្តាល ទៅដល់សមុទ្រម៉េឌីទែរ៉ាណេ។ នៅពេលនោះមានតែជនជាតិ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ចិនទេ ដែលចេះត្បាញសូត្រដែលពេញនិយមយ៉ាងខ្លាំងនៅទីក្រុងរ៉ូម។

ចាប់ពីឆ្នាំ១០៥មុនគ.ស.មក សាធារណរដ្ឋរ៉ូមក៏ចាប់ផ្តើមបង្កើតកងទ័ពថ្មី ដែលធ្វើសង្គ្រាមវាយយកទ្វីបអាហ្វ្រិកខាងកើត និងអ៊ីតាលីខាងជើង។ អាណាចក្ររ៉ូម៉ាំងចាប់ផ្តើមរីកលាតសន្ធឹងនៅទ្វីបអឺរ៉ុប។ អ្នកនយោបាយនិងមេទ័ពរ៉ូមដ៏ល្បីល្បាញ សេហ្សា (Caesar) (១០០-៤៤ឆ្នាំមុនគ.ស.) វាយយកបានបារាំង (Gaul) ហើយត្រលប់មករ៉ូមដើម្បីប្រកាសខ្លួនឯងជាអ្នកគ្រប់គ្រងផ្តាច់ការមួយជីវិត តែត្រូវគេសម្លាប់នៅឆ្នាំ៤៤មុនគ.ស.។ ព្រះក្សត្រីយានី ក្លេអូប៉ាត្រា (Cleopatra) ជាស្តេចចុងក្រោយនៃសន្តតិវង្សម៉ាសេដូនដែលគ្រប់គ្រងអេហ្ស៊ីបពីឆ្នាំ៥១ដល់ឆ្នាំ៣០មុនគ.ស. ហើយក្រោយពីព្រះនាងចូលទិវង្គត អេហ្ស៊ីបបានក្លាយជាខេត្តមួយនៃចក្រភពរ៉ូម៉ាំង។ ចក្រភពរ៉ូម៉ាំង ដែលចាប់ផ្តើមពីទីក្រុមតូចមួយនៃរ៉ូមនៅឆ្នាំ៥០០មុនគ.ស. បានវាតទីបន្តិចម្តងៗ។ ហើយបានប្រែក្លាយទៅជាចក្រភពដ៏ធំមួយនៅឆ្នាំទី១នៃគ.ស. ដែលមានព្រំប្រទល់ពីប្រទេសអេស្ប៉ាញដល់ប្រទេសស៊ីរី ដែលមានប្រជាជនរស់នៅជាង៦០លាននាក់។

នៅឆ្នាំ៤មុនគ.ស. យេស៊ូ គ្រិស្ត បានចាប់កំណើតឡើង។ នៅឆ្នាំ៣៣នៃគ.ស. យេស៊ូ គ្រិស្ត ដែលជាមេដឹកនាំសាសនាជនជាតិជ្វីបដ៏មានប្រជាប្រិយម្នាក់ ត្រូវបានគេយកទៅប្រហារជីវិត។ អ្នកជឿលើយេស៊ូ គ្រិស្ត បានបង្កើតសាសនាថ្មីមួយឈ្មោះថា សាសនាគ្រិស្ត (Christianity) ដែលរីកសាយភាយនៅក្នុងចក្រភពរ៉ូម៉ាំង។

ខ-តើវប្បធម៌ខ្មែរមានមូលដ្ឋានមកពីណា?

ខ្មែរជាជនជាតិចំណាស់ជាងគេនៅអាស៊ីអាគ្នេយ៍ ៖ អំបូរខ្មែរមនបានមករស់នៅអាស៊ីអាគ្នេយ៍ដ៏គោក តាំងពីយុគថ្មរំលីងមកម្ល៉េះ ពោលគឺមនុស្សចេះចិញ្ចឹមសត្វ ប្រើប្រាស់សត្វ និងចេះរំលីងថ្ម ដើម្បីប្រើប្រាស់សម្រាប់ផលិតអាវុធ និងប្រដាប់ប្រដាផ្សេងៗ។ កំណាយបុរាណវត្ថុនៅ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សំរោងសែន (ខេត្តកំពង់ឆ្នាំង) នៅអន្ទង់ផ្តៅ (៣០គមពីសំរោងសែន) និង
នៅម្ខាងព្រៃ (ស្រុកគូលែនព្រហ្មទេព ខេត្តព្រះវិហារ) បានរកឃើញប្រជាប់
ប្រើប្រាស់ធ្វើពីដែក ស្ពាន់ លង្ហិន និងថ្មរំលីង ព្រមទាំងគ្រឿងអលង្ការ
ធ្នើងសត្វ និងមនុស្សផងដែរ។ នៅលើទឹកដីភាគខាងកើតនៃប្រទេសកម្ពុជា
មានការតាំងទីលំនៅតាំងពីសម័យយុគថ្មមកម្ល៉េះ។ កំណាយដោយលោកស្រី
Mourer នៅស្ថានីយល្អាងស្ពាន ខេត្តបាត់ដំបង ក្នុងអំឡុងទសវត្សរ៍ទី៦០
បានបញ្ជាក់ពីវត្តមានរបស់មនុស្សនៅលើទឹកដីដ៏បុរាណនេះតាំងតែពីឆ្នាំ
៤២៩០មុនគ.ស. ពោលគឺនៅក្នុងយុគថ្មរំលីង។ តាមឯកសាររបស់លោក
David Chandler នៅសំរោងសែន គេបានជីកដីឃើញលលាដ៍ក្បាល ដែល
បញ្ជាក់ថាមានមនុស្សមករស់នៅតាំងពីជិត១ ៥០០ឆ្នាំមុនគ.ស.។

ម្យ៉ាងវិញទៀត កំណាយនៅស្ថានីយអូរកែវ (Oc Eo) ក៏បានបង្ហាញ
ថា អរិយធម៌ និងសម្ភារសំរោងសែនមាននៅលាយឡំជាមួយសម្ភារមក
ពីឥណ្ឌាផងដែរ ដែលបង្ហាញនូវអំណះអំណាងថាវប្បធម៌ខ្មែរ គឺជាវប្បធម៌
ដែលស្ទេចេញពីវប្បធម៌ជូនតាខ្មែរ ជាមួយនឹងវប្បធម៌ឥណ្ឌា ហើយមុនការ
មកដល់នៃជនជាតិឥណ្ឌា ខ្មែរមានវប្បធម៌ និងអរិយធម៌របស់ខ្លួនរួចហើយ។

វប្បធម៌ខ្មែរមុនការហូរចូលនៃវប្បធម៌ឥណ្ឌា ៖ មុនការហូរចូលនៃ
វប្បធម៌ឥណ្ឌា ខ្មែរមានវប្បធម៌ និងអរិយធម៌របស់ខ្លួនរួចមកហើយ។ កម្ពុជា
គឺជាប្រទេសបុរាណ ដែលមានវប្បធម៌ និងអរិយធម៌របស់ខ្លួន។ មុន
ការទទួលយកការគោរពប្រតិបត្តិពីសាសនាមកពីប្រទេសឥណ្ឌា ពលរដ្ឋខ្មែរ
គោរពប្រតិបត្តិអ្នកតា ដែលមានរូបភាពជាដុំថ្មផ្សេងៗ។ បន្ទាប់មក វប្បធម៌
និងអរិយធម៌នេះទទួលរងនូវឥទ្ធិពលពីលទ្ធិនៃព្រហ្មញ្ញសាសនា និងពុទ្ធ
សាសនា។ ដូច្នេះ អរិយធម៌ខ្មែរ គឺជាលទ្ធផលនៃការស្ទ និងច្របាច់បញ្ចូល
គ្នាក្នុងរយៈពេលជាច្រើនសតវត្សរ៍រវាងអរិយធម៌ខ្មែរបុរាណ និងអរិយធម៌
បរទេស ដែលមានដើមប្រភពពីឥណ្ឌា បស្ចិមប្រទេស និងចិន។ យើងឃើញ
ថា ក្នុងការវិភាគពីអរិយធម៌ខ្មែរ គេឃើញមានទស្សនៈពីរខុសគ្នា ៖ ទស្សនៈ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទីមួយ គឺអរិយធម៌ខ្មែរមានឥទ្ធិពលពីឥណ្ឌា ហើយទស្សនៈទីពីរ គឺខ្មែរបានយកវប្បធម៌ពីឥណ្ឌា ដើម្បីយកមកសូឱ្យទៅជារបស់ខ្មែរ។

អ្នកស្រាវជ្រាវដែលប្រកាន់យកទស្សនៈទី១ យល់ឃើញថា ៖ មូលដ្ឋាននៃអរិយធម៌ខ្មែរស្ថិតនៅក្នុងទស្សនវិជ្ជានៃសាសនា ដែលជនជាតិខ្មែរទទួលយកជាបន្តបន្ទាប់ ឬក្នុងពេលតែមួយ ដូចជាវេទនិយម ព្រាហ្មណ៍និយម ហិណ្ឌូនិយម និងពុទ្ធនិយម។ មូលដ្ឋាននេះតែងតែវិវត្តជាលំដាប់ទៅតាមដំណាក់កាលនៃប្រវត្តិសាស្ត្រកម្ពុជា។ ដូច្នេះការសិក្សាវប្បធម៌ និងអរិយធម៌ខ្មែរទាមទារឱ្យយល់ពីព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ដែលខ្មែរទទួលពីឥណ្ឌាផងដែរ។

លោកសាស្ត្រាចារ្យ កេង វ៉ាន់សាក់ ជាអ្នកប្រកាន់យកទស្សនៈទី២។ នៅក្នុងនិក្ខេបបទដែលមានចំណងជើងថា «ការស្រាវជ្រាវនៃឫសគល់វប្បធម៌ខ្មែរ» លោកសាស្ត្រាចារ្យ កេង វ៉ាន់សាក់ បានលើកឡើងពីសម្មតិកម្មថា ៖ «វប្បធម៌ខ្មែរ គឺជាវប្បធម៌ចម្រុះ ដែលច្របាច់បញ្ចូលនូវមូលដ្ឋានក្នុងស្រុក (វប្បធម៌ខ្មែរ-មន ដែលមានសមាសធាតុនៃវប្បធម៌អូស្ត្រូអាស៊ី) និងវិភាគទានពីបរទេស ជាពិសេសពីឥណ្ឌា បស្ចិមប្រទេស និងចិន»។ លោកបន្តទៀតថា ៖ «[អក្សរសិល្ប៍ខ្មែរ-ឥណ្ឌា] បានអនុញ្ញាតឱ្យខ្ញុំយល់យ៉ាងច្បាស់ពីទំនាក់ទំនងពិត។ ដែលមានលក្ខណៈមិនត្រឹមតែខុសគ្នាទេ តែផ្ទុយគ្នារវាងអក្សរសិល្ប៍ឥណ្ឌា និងខ្មែរ។ អ្វីដែលអង្រួនខ្ញុំឱ្យភ្ញាក់ពីដំណេក គឺខ្ញុំតែងតែជឿថា ឥណ្ឌា និងខ្មែរអាចប្រៀបប្រដូចទៅនឹងការរៀបអាពាហ៍-ពិពាហ៍នឹងគ្នា។ ខ្ញុំចាប់ផ្តើមភ្ញាក់ខ្លួនបន្តិចម្តង។ រហូតដល់ពេលមួយ ដែលខ្ញុំរកឃើញរចនាសម្ព័ន្ធនៃភាសាខ្មែរ ដែលធ្វើឱ្យខ្ញុំលែងស្រមើស្រមៃទៀតហើយចាប់ផ្តើមមើលឃើញនូវការផ្ទុយគ្នា និងការខុសគ្នាជាមូលដ្ឋានរវាងវប្បធម៌ទាំងពីរ ៖ គឺឥណ្ឌា និងខ្មែរ»។ ពោល សាស្ត្រាចារ្យ កេង វ៉ាន់សាក់ បានទាត់ចោលសម្មតិកម្មរបស់លោក George Coedès ដែលថា ៖ «ខ្មែរគឺជាជនជាតិក្លួយ ដែលទទួលយកវប្បធម៌ឥណ្ឌា»។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ក៏ប៉ុន្តែ សាស្ត្រាចារ្យ កេង វ៉ាន់សាក់ មិនបានទាត់ចោលនូវការចូលរួមនៃវប្បធម៌ឥណ្ឌាក្នុងការបង្កើតវប្បធម៌ខ្មែរឡើយ។ លោកចែកវប្បធម៌ជាពីរផ្នែក ៖ វប្បធម៌ខាងផ្នែកសម្ភារ និងវប្បធម៌ខាងផ្នែកគំនិតស្មារតី។ លោកលើកឡើងថា លោក Jean Delvert (*Le paysan cambodgien*) និងលោកស្រី Éveline Porée-Maspero (*Étude sur les Rites agraires des Cambodgiens*) បានសិក្សាវប្បធម៌ខ្មែរខាងផ្នែកសម្ភារយ៉ាងល្អិតល្អន់ហើយ។ ដោយឡែកចំពោះវប្បធម៌ខាងផ្នែកគំនិតស្មារតី លោកបានចែកចេញជាពីរផ្នែកគឺ ៖ ទី១-វិភាគទានឥណ្ឌាក្នុងវប្បធម៌ និងអរិយធម៌ខ្មែរ តាមរយៈសាសនាព្រាហ្មណ៍ និងពុទ្ធសាសនាមហាយាន និងភាសាសំស្ក្រឹត និងពុទ្ធសាសនាថេរវាទ និងភាសាបាលី និងទី២-វប្បធម៌ខ្មែរសុទ្ធសាធ ដែលមានតាំងតែពីជំនាន់ហ្វូណន ហើយដែលស្ថិតជាមួយវប្បធម៌ឥណ្ឌា ដែលជំរុញឱ្យខ្មែរអាចឈានដល់ភាពរីកចម្រើនដូចជំនាន់អង្គរ។

បណ្ឌិត មីសែល ត្រាណេ បានយកសម្មតិកម្មរបស់សាស្ត្រាចារ្យ កេង វ៉ាន់សាក់ ទៅធ្វើការស្រាវជ្រាវបន្ថែម និងបានធ្វើសេចក្តីសន្និដ្ឋានថា ៖ «វប្បធម៌ខ្មែរដែលបានប្រសូតឡើងនាដើមសម័យប្រវត្តិសាស្ត្រក្រោមឥទ្ធិពលឥណ្ឌានោះ គឺជាវប្បធម៌មួយដែលប្រកបដោយលក្ខណៈសំយោគរវាងសមាសធាតុមន-ខ្មែរ និងឥណ្ឌា។ មុនមានលំហូរវប្បធម៌បរទេស អ្នកស្រុកនៃជ្រោយសុវណ្ណភូមិមានវប្បធម៌ដើមរបស់ខ្លួនរួចហើយ ដូចយើងឃើញតាមរយៈកំណាយនៃស្ពានីយល្អាងស្ពានៅខេត្តបាត់ដំបង សំរោងសែននៅខេត្តកំពង់ឆ្នាំង ស្ពានីយយុគថ្ម ក្រួសបំបែក នៅខេត្តក្រចេះ និងស្ទឹងត្រែងជាដើម។ នៅលើមូលដ្ឋានគ្រឹះដ៏រឹងមាំរបស់ជូនតាទាំងនោះ ដែលមានអាយុកាលរាប់ពាន់សែនឆ្នាំមុនគ.ស. ទើបជាតុឥណ្ឌាបានចាប់ពន្លកពីលើ ចាប់តាំងពីស.វ.ទី១ដល់ស.វ.ទី១៦ ដោយបាននាំមកនូវការអភិវឌ្ឍដ៏ឧត្តុង្គឧត្តមគ្រប់វិស័យ។ ក៏ប៉ុន្តែ នៅពេលដែលឥទ្ធិពលឥណ្ឌាមកដល់ប្រជាជនខ្មែរពុំទាន់មានអក្សរនៅឡើយទេ។ សំណេរប្រវត្តិសាស្ត្រខ្មែរចាប់បដិសន្ធិឡើង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅដើមស.វ.ទី១ ដោយទទួលនូវឥទ្ធិពលរបស់ឥណ្ឌា ហើយបង្កើតបានអក្សរជាតិតាមលំនាំឥណ្ឌា។ ឥទ្ធិពលឥណ្ឌាក៏បាននាំមកនូវរបបនយោបាយរាជាធិបតេយ្យដូចឥណ្ឌា។

គ-តើនៅអាស៊ីអាគ្នេយ៍មានជនជាតិណាខ្លះរស់នៅ?

នៅបុរេសម័យ មានតែជនជាតិធំៗចំនួនបីប៉ុណ្ណោះ ដែលតាំងទីលំនៅនៅអាស៊ីអាគ្នេយ៍ គឺជនជាតិខ្មែរ ជនជាតិមន និងជនជាតិចាម។

ជនជាតិខ្មែរ គឺជាជនជាតិដើមនៃអាស៊ីអាគ្នេយ៍ ដែលតាំងទីលំនៅនៅក្នុងជ្រលងនៃទន្លេមេគង្គភាគកណ្តាល និងភាគខាងក្រោម។ ប្រទេសមនមានឈ្មោះថា អាណាចក្រទ្វារវតី និងមានព្រំប្រទល់ជាប់នឹងអាណាចក្រខ្មែរ ហើយលាតសន្ធឹងតាមជង់ទន្លេមេណាម ឬចៅប្រាយ៉ា។ ជនជាតិមនរស់នៅផ្នែកខាងជើង និងខាងលិចទន្លេមេគង្គ គឺនៅចំកូមិភាគកណ្តាលនៃប្រទេសថៃបច្ចុប្បន្ន និងនៅតាមខ្ពង់រាបភ្នំផ្នែកខាងជើងជួរភ្នំដងរែក។ អាណាចក្រទ្វារវតីទទួលឥទ្ធិពលពីសិល្បៈឥណ្ឌាដំបូងគេដូចអាណាចក្រខ្មែរ និងចម្ប៉ាដែរ។ បើនិយ័យទៅតាមសិល្បៈទ្វារវតី ដែលជាសិល្បៈរីកចម្រើនជាពិសេសព្រះពុទ្ធរូបនៅវត្តប្រាមេន ខេត្តអយុធ្យាដែលមានកាលបរិច្ឆេទនៅស.វ.ទី៨នៃគ.ស. បញ្ជាក់ថាជនជាតិមនទំនង់ជាគោរពព្រះពុទ្ធសាសនានិកាយថេរវាទ។

យើងឃើញថា អាណាចក្រទាំងពីរមានទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុត ជាពិសេសខាងវិស័យវប្បធម៌ ដោយសារភាសាខ្មែរ និងភាសាមនស្ថិតនៅក្នុងគ្រួសារខ្មែរ-មនតែមួយ ហើយភាសាទាំងពីរនេះបានចារនៅក្នុងសិលាចារឹករបស់ខ្មែរ។ បើតាមមតិរបស់លោក Thierry Zephir សាស្ត្រាចារ្យនៃសាលាលូវ័របានឱ្យដឹងថា ព្រះពុទ្ធបដិមា <ទ្វារវតី> ក្នុងកាយវិការបង្រៀន (វិតក៌មុទ្រ) និងរូបពោធិសត្វដែលគេបានរកឃើញនៅក្នុងតំបន់បានហៀ ឬតំបន់ព្រះនគរជ័យ(បច្ចុប្បន្ននៅក្នុងទឹកដីថៃ) មានលក្ខណៈជាខ្មែរសុទ្ធសាធ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

និងស្ថិតនៅក្នុងរចនាបថព្រៃក្មេង ឬកំពង់ព្រះ ពោលព្រះពុទ្ធបដិមានេះមានសិល្បៈនៃដួងព្រលឹងខ្មែរ និងបង្ហាញពីសិល្បៈទ្វារវតីផងដែរ(កេរដំណែលខ្មែរ លេខ១០១)។

ដោយសារតែវប្បធម៌ខ្មែរ និងវប្បធម៌មនមានលក្ខណៈស្រដៀងគ្នា និងមានប្រភពតែមួយពីឥណ្ឌាសម័យដំបូង ជាពិសេសភាសាដែលស្ថិតនៅក្នុងគ្រួសារខ្មែរ-មនតែមួយ ដែលមានប្រភពពីភាសាសំស្ក្រឹតនេះហើយទើបមានប្រវត្តិវិទូមួយចំនួនបានលើកឡើងពីអំណះអំណាងនៃអារ្យធម៌ខ្មែរ-មនថា ហាក់បីដូចជាអារ្យធម៌តែមួយ ដោយសារសិល្បៈទ្វារវតីនៅមុនសម័យអង្គរបានទទួលឥទ្ធិពលពីគ្នាទៅវិញទៅមក។ ឧទាហរណ៍ ស្ថានីយបុរាណវិទ្យាស៊ីទេព ដែលជាស្ថានីយខ្មែរនៅក្នុងទឹកដីថៃ ដែលជាបេះដូងនៃអាណាចក្រទ្វារវតីគឺជាតឹកតាងស្រាប់។

តាមរយៈការសិក្សាពីទិដ្ឋភាពរួមនៃអាណាចក្របុរាណនៅអាស៊ីអាគ្នេយ៍ ការគ្រប់គ្រងមានលក្ខណៈជា « Center of power » ហើយការបែងចែកព្រំដែនរវាងអាណាចក្រពីរគឺជារឿងស្មុគស្មាញនិងអាស្រ័យតាមពេលវេលា។ ឧទាហរណ៍ តាមប្រភពរបស់លោក David Snellgrove នៅស្ថានីយមឿងសីមា ដែលស្ថិតនៅខាងលិចនៃនគរាជសីមា នៅលើខ្ពង់រាបក្រាំត គេឃើញមានផ្នូរខ្មោចអាយុជាង៦ ០០០ឆ្នាំ និងឃើញមានទូរសំណាល់ប្រាសាទមន និងប្រាសាទខ្មែរផងដែរ។

ជនជាតិខ្មែរ និងជនជាតិមន គឺជាជនជាតិដែលភាគច្រើនរស់នៅតាមតំបន់ព្រៃភ្នំ ហើយភាគតិចរស់នៅតាមមាត់សមុទ្រ។ នៅតាមមាត់សមុទ្រនៃឧបទ្វីបឥណ្ឌូចិន ភាគច្រើនជនជាតិដែលរស់នៅទីនោះគឺជនជាតិចាម ដែលមានដើមកំណើតមកពីឧបទ្វីបម៉ាឡេ និងឥណ្ឌូណេស៊ី។ ជនជាតិខ្មែរទទួលទូវឥទ្ធិពលខាងផ្នែកភាសា វប្បធម៌ និងសាសនាផ្ទាល់ពីឥណ្ឌា ជាពិសេសតាមរយៈមជ្ឈមណ្ឌលពាណិជ្ជកម្ម អូរកែវ នៃអាណាចក្រភ្នំ ឬហ្វូណន។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

២-ប្រវត្តិសាស្ត្រខ្មែរពីសតវត្សទី១ដល់ចុងសតវត្សទី៨

ក-ទំនាក់ទំនងប្រវត្តិសាស្ត្ររវាងហ្វូណន និងចេនឡា

តាមមតិលោក Coedès និងអ្នកប្រាជ្ញឯទៀត ពួកគេសន្និដ្ឋានថា ហ្វូណន មានមជ្ឈមណ្ឌលនយោបាយ និងសេដ្ឋកិច្ចនៅម្តុំដីសណ្តោនទន្លេមេគង្គ ហើយប្រហែលមានរាជធានីតែមួយនៅអង្គរបុរី ដែលមានទំនាក់ទំនងពាណិជ្ជកម្មយ៉ាងជិតស្និទ្ធជាមួយឥណ្ឌា និងចិន។

ឯកសារចិន History of the Liang Dynasty បានបញ្ជាក់ថា នៅពេលដែលស្តេចគ្រប់គ្រងហ្វូណនចូលទិវង្គតនៅឆ្នាំ៥៥០ ចលាចលបានកើតឡើង។ នៅពេលនោះ ស្តេចចេនឡា ដែលជាសាមន្តរដ្ឋនៅខាងជើងប្រទេស បានឆក់យកឱកាស ដើម្បីវាយយកហ្វូណន ជាសាមន្តរដ្ឋវិញ។ នៅពាក់កណ្តាលទី២នៃស.វ.ទី៦ ចេនឡាមានអានុភាពកាន់តែខ្លាំងឡើង។ ហើយចាប់ផ្តើមវាយលុកប្រទាំងនឹងអាណាចក្រភ្នំ។ អាណាចក្រចេនឡាក៏លាតសន្ធឹងតាមដងទន្លេមេគង្គ ពីសម្បុរណ៍ទៅដល់កំពង់ចាម រួចហើយក៏ឆ្ពោះទៅដល់យកអាណាចក្រភ្នំជាចំណុះនៅឆ្នាំ៥៥០។ តាមមតិលោក Coedès រដ្ឋដ៏មហិមានេះលាតសន្ធឹងជិតស្មើនឹងអាណាចក្រខ្មែរ ហើយចែកជាចេនឡាដីគោក ដែលគ្របដណ្តប់ទឹកដីកម្ពុជាបច្ចុប្បន្ន និងខ្ពង់រាបកូរ៉ាត និងចេនឡាទឹក ដែលគ្របដណ្តប់ដីសណ្តោនទន្លេមេគង្គ។

គេបានលើកឡើងថា ទំនាស់រាជបល្ល័ង្ក ទំនាស់ខាងសាសនា និងមហន្តរាយធម្មជាតិ គឺជាបុព្វហេតុបង្ក្រាប់ទៅវិញទៅមកក្នុងចម្បាំងរវាងចេនឡា និងអាណាចក្រភ្នំ។ អ្នកប្រាជ្ញបារាំងលោក Bernard Philippe Groslier បានសរសេរថា ៖«មហន្តរាយដែលបណ្តាលមកពីទឹកជំនន់បានបំផ្លាញទីក្រុង និងប្រព័ន្ធបញ្ចូលទឹកក្នុងស្រែ ហើយបង្ខំឱ្យប្រជារាស្ត្រកៀសខ្លួនទៅរស់នៅត្រង់ដីខ្ពស់នៅភាគខាងជើង ពេលនោះកូសាំងស៊ីនក៏ក្លាយទៅជាវាលល្បប់មួយស្ងាត់ជ្រងំ។ នៅពាក់កណ្តាលទី២នៃស.វ.ទី៦ ព្រះបាទភវវរ្ម័ន និងប្អូនជីដូនមួយរបស់ព្រះអង្គព្រះនាម ចិត្រសេន បានវាយលុក

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យកអាណាចក្រភ្នំ ចាប់តាំងពីខេត្តក្រចេះដល់បុរីម្យនៅចន្លោះទន្លេមូល និងជួរភ្នំដងរែក និងដល់មង្គលបុរី។ អាណាចក្រភ្នំក៏លើកពាជធានីចេញពីព្រៃធបុរៈទៅតាំងនៅទិសខាងត្បូង គឺនៅត្រង់នរាយនគរ គឺនៅត្រង់អង្គរបុរីក្នុងខេត្តតាកែវ។ បន្ទាប់ពីព្រះបាទភវរ្ម័ន សោយទិវង្គត ព្រះបាទចិត្រសេន បានឡើងសោយរាជ្យនៅឆ្នាំ៦០០ ដោយយកព្រះនាមថា មហេន្ទ្រវរ្ម័ន។ បុត្ររបស់ព្រះអង្គគឺព្រះបាទឥសានវរ្ម័ន បានឡើងសោយរាជ្យនៅឆ្នាំ៦១៦។ ព្រះអង្គបានបញ្ចប់សង្គ្រាមជាមួយអាណាចក្រភ្នំ ដោយវាយយកពាជធានីនរាយនគរ (អង្គរបុរី) ប្រមាណនៅឆ្នាំ៦៣០។ មតិនេះបានលើកឡើងថា ឥសានបុរៈ បានក្លាយទៅជាពាជធានីនៃចេនឡានៅក្រោមរជ្ជកាលនៃព្រះបាទឥសានវរ្ម័នទី១ គឺនៅសតវត្សទី៧។

នៅដើមស.វ.ទី៨ (៧០៦) អាណាចក្រចេនឡាត្រូវបែងចែកជាពីរ ដោយសារតែអំណាចកណ្តាលចុះខ្សោយ ៖ ភាគខាងជើងហៅថា ចេនឡាដីគោក ជាតំបន់ភ្នំ និងជ្រលងភ្នំ (ប្រទេសឡាវភាគកណ្តាល) និងភាគខាងត្បូងហៅថា ចេនឡាទឹកលិច ដែលមានតំបន់សម្បូរដោយបឹង និងមានសមុទ្រព័ទ្ធជុំវិញ (ពីអាងទន្លេមេគង្គត្រង់ល្បាក់ខោនដល់សមុទ្រ) ហើយដែលក្រោយមកប្រហែលជាបែកជារដ្ឋតូចៗជាច្រើន។ របបចេនឡាបានបែកបាក់ខ្លាយទៅជារដ្ឋតូចៗគ្មានលំនឹង។

ក៏ប៉ុន្តែ ប្រវត្តិវិទូក្រោយៗមានលោក Claude Jacques និងលោក Michael Vickery បានបដិសេធសេចក្តីសន្និដ្ឋានមួយចំនួនរបស់អ្នកប្រាជ្ញមុនៗ។ លោក Claude Jacques មានមតិថា អ្នកប្រាជ្ញមុនៗសិក្សាប្រវត្តិសាស្ត្រខ្មែរមុនអង្គរតាមរយៈប្រភពឯកសារចិន ហើយមិនបានសិក្សាពីសិលាចារឹកឡើយ។ លោក Michael Vickery បានចាត់ទុកថា មិនត្រឹមតែ «ចេនឡាដីគោក» និង «ចេនឡាទឹក» មិនដែលមានពិតទេ ការចែកដំណាក់កាលជាពីរនៅក្នុងពាជពង្សវាតាពីប្រភពចិនជា «ហ្វូណន» និង «ចេនឡា» គឺជារឿងដែលគ្មានន័យ ដោយសារតែតាមសក្ខីភាពជាក់ស្តែង មកទល់ឆ្នាំ៨០២

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នៅលើទឹកដីខ្មែរមិនដែលមានរដ្ឋឯកភាពតែមួយឡើយ តែគឺជាបណ្តុំនៃរដ្ឋតូចៗជាច្រើនៗ បើយោងតាមមតិនេះ ហ្វូណន និងចេនឡា គឺជារដ្ឋពីរដាច់ពីគ្នា ហើយការធ្លាក់ចុះនៃហ្វូណនមិនមែនបណ្តាលមកពីការឈ្លានពានរបស់ចេនឡាឡើយ គឺដោយសារការធ្លាក់ចុះនៃតួនាទីនៃកំពង់ផែអូរកែវ និងការកើនឡើងនៃការដាំដុះស្រូវ នៅតាមតំបន់វាលរាប និងនៅតាមតំបន់បឹងទន្លេសាបៗ

ខ-អាណាចក្រហ្វូណននៅអាស៊ីអាគ្នេយ៍

ហ្វូណនអភិវឌ្ឍឡើង ដោយឈរលើមូលដ្ឋានពីរ គឺ ៖ (១) មជ្ឈមណ្ឌលពាណិជ្ជកម្មនៅអាស៊ីអាគ្នេយ៍ និង (២) ការបង្កើតឡើងនូវវប្បធម៌ឥណ្ឌា-ខ្មែរៗ ការទទួលវប្បធម៌ឥណ្ឌាមានប្រភពចំនួនពីរសំខាន់ គឺពាណិជ្ជកម្ម និងសាសនាៗ

នៅខាងដើមគ្រិស្តសករាជ អាណាចក្រភ្នំ ដែលជាភាសាចិនហៅថា ហ្វូណន គឺជារដ្ឋសំខាន់ជាងគេនៅអាស៊ីអាគ្នេយ៍ៗ ប្រភពឯកសារស្តីពីហ្វូណន បានមកពីពង្សាវតានៃប្រទេសចិន ដោយសារស្តេចចិនបុកណាបានបញ្ជូនបេសកជនមកកាន់ហ្វូណន និងផ្លាស់ប្តូរពាណិជ្ជកម្មជាមួយរដ្ឋចំណាស់មួយនេះៗ ពង្សាវតាចិនបានបញ្ជាក់ពីទីតាំងហ្វូណន ថា៖ «អាណាចក្រហ្វូណនស្ថិតនៅភាគខាងត្បូងនៃទឹកដី រីណាន (អាណាចក្របុកណា Nan Yue) នៅក្នុងឈូងសមុទ្រខាងលិចនៃមហាសមុទ្រ (ឈូងសមុទ្រថៃ)ៗ នៅទីនោះមានទន្លេធំមួយ (ទន្លេមេគង្គ) ដែលហូរពីទិសខាងលិច ចាក់ចូលក្នុងសមុទ្រៗ ទឹកដីហ្វូណនមានទំហំ៣០០០លីកាវ៉ែ (រង្វាស់ចិន)ៗ គេអាចទៅដល់ទីនោះ តាមផ្លូវដីក៏បាន ផ្លូវទឹកក៏បាន»ៗ

តាមឯកសារប្រវត្តិសាស្ត្រឡាង់បានឱ្យដឹងថា ៖ «ទីប្រជុំជន (រាជធានី?)នៃហ្វូណនស្ថិតនៅចូលខាងក្នុងជ្រោះប្រមាណ៥០០លី (៦០០គម) ពីសមុទ្រ»ៗ ប្រភពមួយទៀតបង្ហាញថា៖ «រាជធានីហ្វូណនមានឈ្មោះថា

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

Te Mu (វ៉ាធបុរៈ)។ ក៏ប៉ុន្តែ បន្ទាប់ពីទីក្រុងនេះត្រូវបានចេនឡាចូលកាន់កាប់ នៅឆ្នាំ ៥៣៥ រាជធានីត្រូវបានរើទៅនៅឯ Nafuna។ ប្រវត្តិវិទូ Coedès (១៩៦៨:៦៥) បកស្រាយថា រាជធានីរបស់អាណាចក្រភ្នំ គឺ វ៉ាធបុរៈ (បុរីនៃស្តេចទាក់ដំរី) ដែលស្ថិតនៅម្តុំបាភ្នំ ក្នុងខេត្តព្រៃវែងសព្វថ្ងៃនេះ។ ក៏ប៉ុន្តែ លោក Vickery (១៩៩៨:២៩) បដិសេធអំណះអំណាងនេះ ដោយយោងលើសិលាចារឹកបាភ្នំ ដែលមានកាលបរិច្ឆេទក្រោយសម័យហ្វូណន (ឆ្នាំ ៦៥៥) ហើយតំបន់នេះមានឈ្មោះថា បន្ទាយព្រៃនគរ គឺមិនអាចជារាជធានីរបស់ហ្វូណនបានឡើយ។ លោក Claude Jacques បានអះអាងថា រាជធានីរបស់ហ្វូណនគួរតែជាអង្គរបុរី (៩០គមពីសមុទ្រ) ឬភ្នំជា ហើយមិនមែនបាភ្នំឡើយ ដោយសារតែបាភ្នំស្ថិតនៅឆ្ងាយពីអូរកែវ (Oc Eo) ដែលជាទីក្រុងផែដ៏សំខាន់នៅសម័យហ្វូណន។ ហ្វូណនលាតសន្ធឹងពីតំបន់មេគង្គខាងក្រោមដល់ទន្លេសាប។ ប្រជាជនហ្វូណនសាងសង់ប្រព័ន្ធប្រឡាយទឹកខ្នាត់ខ្នែង ដែលប្រើប្រាស់សម្រាប់នាវាចរណ៍។ អ្នកស្រុកហ្វូណនប្រើប្រាស់ប្រព័ន្ធប្រឡាយ ដើម្បីតភ្ជាប់ប្រាសាទសាសនាទាំងឡាយនៅក្នុងសម័យនោះ ព្រមទាំងភ្ជាប់អូរកែវទៅនឹងមាត់សមុទ្រ ដែលមានប្រវែង១១គីឡូម៉ែត្រ។ ការធ្លាក់ចុះនៃហ្វូណន គឺបណ្តាលមកពីប្រជាជនចាប់ផ្តើមចាកចេញពីតំបន់មាត់សមុទ្រនៅដើមសតវត្សទី៧ ដើម្បីទៅប្រកបរបរធ្វើស្រែចម្ការនៅក្នុងតំបន់វាលទំនាបជិតបឹងទន្លេសាប។ ប្រការនេះធ្វើឱ្យតួនាទីរបស់អូរកែវធ្លាក់ចុះ ហើយមជ្ឈមណ្ឌលនយោបាយ និងទីប្រជុំជនបានរើចូលទៅកាតខាងក្នុងប្រទេសជិតបឹងទន្លេសាប។

អង្គរបុរី ៖ នៅអង្គរបុរី គេឃើញមានប្រឡាយទឹកយ៉ាងវែង ដែលភ្ជាប់ទៅដល់អូរកែវ ដែលជាកំពង់ផែអន្តរជាតិរបស់ហ្វូណន។ រហូតដល់ដើមសតវត្សទី៧ អង្គរបុរីបានក្លាយទៅជាមជ្ឈមណ្ឌលនយោបាយ និងសាសនាមួយយ៉ាងធំ។ នៅទីនោះ គេឃើញមានរូបបដិមាទាំងព្រះពុទ្ធសាសនា ទាំងព្រហ្មញ្ញសាសនា។ នៅក្បែរអង្គរបុរី យើងមានប្រាសាទភ្នំដា

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលជាច្រាសាទបុរាណរបស់ខ្មែរដែរ។ ដូច្នេះ នៅជំនាន់ហ្វូណន ប្រជាជនប្រណិបត្តិព្រះពុទ្ធសាសនា ទាំងថេរវាទ ទាំងមហាយាន និងព្រហ្មញ្ញសាសនា ព្រមៗគ្នាប្រកបដោយភាពសុខដុមរមនា។

អាណាចក្រភ្នំបានទទួលឥទ្ធិពលអរិយធម៌ឥណ្ឌាយ៉ាងខ្លាំងក្នុងចំនួនពីរលើក គឺលើកទីមួយនៅដើមគ.ស.ទី១ និងមួយលើកទៀតនៅដើមគ.ស.ទី៥។ នៅឆ្នាំ ១៩២នៃគ.ស. អាណាចក្រចម្ប៉ាត្រូវបានបង្កើតឡើងនៅត្រង់វៀតណាមភាគកណ្តាល។ ជនជាតិចាមមានមុខរបរធ្វើជាអ្នកនេសាទសមុទ្រ និងបានធ្វើដំណើរទៅជួញជាមួយឥណ្ឌា ហើយបានទទួលយកព្រហ្មញ្ញសាសនា។ វប្បធម៌ឥណ្ឌា និងចិនចូលកម្ពុជាចាប់តាំងពីសតវត្សទី១នៃគ.ស. ហើយលើកទី២ នៅសតវត្សទី៣នៃគ.ស.។ នៅអាស៊ីអាគ្នេយ៍នៅពេលនោះមានអាណាចក្រធំៗពីរគឺ ហ្វូណន និងចម្ប៉ា ដែលទទួលយកព្រហ្មញ្ញសាសនា។

បើតាមការស្រាវជ្រាវរបស់បណ្ឌិត មីសែល ត្រាណេ វប្បធម៌ និងអារ្យធម៌ខ្មែរមានតាំងពីសម័យបុរេប្រវត្តិ ហើយបានជួបនឹងវប្បធម៌ចិន មុននឹងមានការហូរចូលនៃវប្បធម៌ឥណ្ឌានាដើមស.វ.ទី១នៃគ.ស.។ ទំនាក់ទំនងខ្មែរ និងចិនឆ្លុះបញ្ចាំងតាមរយៈស្តរមហោធិក ឬស្តរអារក្សហៅទឹកភ្លៀងដែលគេបានរកឃើញនៅក្នុងចក្រភពបុរេអង្គរ ក៏ដូចជាក្បាច់ក្បូរលម្អលើវត្ថុសិល្បៈមួយចំនួន ដូចជាជួង កាំបិត កងដៃ កងជើងជាដើម។ ការផ្សព្វផ្សាយវប្បធម៌ឥណ្ឌាប្រព្រឹត្តទៅតាមពីរផ្លូវ ៖ (១) គឺតាមរយៈពួកឈ្មួញដែលខិតខំរៀនសូត្រភាសាអ្នកស្រុកដើម ហើយខ្លះក៏បានរៀបមង្គលការជាមួយជនជាតិដើម និង (២) គឺតាមរយៈសាសនា និងពួកបញ្ញវន្តខ្មែរក្នុងវណ្ណៈខ្ពស់។

ឥណ្ឌាការូបនីយកម្ម ឬការទទួលជាតុផ្សេងៗនៃវប្បធម៌ឥណ្ឌាបានកើតមានឡើងចាប់តាំងពីស.វ.ទី១ មុនគ.ស.មកម្ល៉េះ ពោលគឺក្នុងពេលជាមួយគ្នានឹងពាណិជ្ជកម្មជាមួយចិនដែរ ដោយឈរលើមូលដ្ឋាននៃការ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិភាគវត្ថុសិល្បៈបុរាណ ដូចជាអង្គាំ កុលាលភាជន៍ និងកំណត់ហេតុផ្សេងៗ។ នរវិទូបានបែងចែកឥណ្ឌាការូបនីយកម្មជាពីរប្រភេទ ៖ ប្រភេទទី១ គឺតាមរយៈការប្រើប្រាស់ភាសាសំស្ក្រឹត ប្បាប់ និងព្រហ្មញ្ញសាសនា និងប្រភេទទី២ គឺតាមរយៈស្រុកភូមិ ទំនៀមទម្លាប់ និងជំនឿអ្នកស្រុក។

តួនាទីពាណិជ្ជកម្មនៃឥណ្ឌាការូបនីយកម្ម ៖ ពាណិជ្ជកម្មដើរតួនាទីយ៉ាងសំខាន់ក្នុងការហូរចូលនៃវប្បធម៌ឥណ្ឌា។ អាណាចក្រភ្នំ គឺជាអាណាចក្រតូចមួយ តែជាមជ្ឈមណ្ឌលពាណិជ្ជកម្មមួយដ៏សំខាន់នៅអាស៊ីអាគ្នេយ៍ ហើយកំពង់ផែអូរកែវដើរតួនាទីយ៉ាងសំខាន់នៅក្នុងពាណិជ្ជកម្មនេះ។ កំពង់ផែអូរកែវ គឺជាកំពង់ផែដ៏សំខាន់របស់អាណាចក្រហ្វូណន ហើយគឺជាផែអន្តរជាតិដ៏ធំមួយនៅអាស៊ីអាគ្នេយ៍។ កំណាយនៅអូរកែវបានរកឃើញទូវសម្ភារមកពីឥណ្ឌា ដែលជាចំណុចចាប់ផ្តើមនៃឥណ្ឌានីយកម្ម។ ជនជាតិឥណ្ឌាដែលមកកាន់អាណាចក្រហ្វូណន មានជនភៀសខ្លួន ក៏ដូចជាឈ្មួញដែលមករក ទិញមាស គ្រឿងប្រណីត និងគ្រឿងទេស។

អារ្យធម៌ហ្វូណនមានលក្ខណៈផ្សេងពីឥណ្ឌា ទោះបីជាចាប់ផ្តើមមានឥណ្ឌានីយកម្មក្តី។ ដូច្នេះហើយ ទើបគេហៅអារ្យធម៌នេះថា ជាអារ្យធម៌ខ្មែរ-ឥណ្ឌា។ ហ្វូណនមានប្រព័ន្ធប្រមូលពន្ធ ប្រព័ន្ធតុលាការ បណ្ណាល័យ សម្ងៀកបំពាក់ កសិកម្ម សិប្បកម្ម និងពាណិជ្ជកម្ម។ អ្នកស្រុកហ្វូណនគោរពបូជាព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា។

អាណាចក្រភ្នំមានការរៀបចំផ្នែកនយោបាយតាមបែបឥណ្ឌា។ ព្រះរាជាមានឋានន្តរនាមជា ក្រុងវ្នំ ព្រោះយកតាមភ្នំ ដែលព្រះអង្គគង់ឃាងឡើងទៅធ្វើសក្ការៈចំពោះព្រះ មហេស្វរៈ និងមានតម្កល់លិង្គព្រះ គិរិស គឺឈ្មោះព្រះឥសូរដែលសណ្ឋិតនៅលើភ្នំនោះ។ នៅក្នុងវិស័យនយោបាយក្រៅប្រទេស អាណាចក្រភ្នំបានចងស្ពានមេត្រីជាមួយប្រទេសធំៗ ដូចជាប្រទេសឥណ្ឌា និងប្រទេសចិន។ អ្នកប្រាជ្ញបារាំង លោក Louis Malleret បានធ្វើកំណាយនៅស្ថានីយអូរកែវ ហើយរកឃើញខឿនសំណង់ផ្សេងៗ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រមទាំងវត្ថុផ្សេងច្រើនទៀត មកពីចក្រភពរ៉ូម និងឥណ្ឌា។

តួនាទីសាសនានៃឥណ្ឌាការបន្ទាយកម្ម ៖ នៅសម័យអាណាចក្រភ្នំ ប្រជាជនខ្មែរខ្លះគោរពបូជាព្រហ្មញ្ញសាសនា និងខ្លះទៀតព្រះពុទ្ធសាសនា។ នៅក្នុងព្រហ្មញ្ញសាសនា អ្នកខ្លះគោរពព្រះឥសូរ អ្នកខ្លះគោរពព្រះវិស្ណុ។ ដល់ក្រោយស.វ.ទី៨ ប្រជាជនខ្មែរគោរពព្រះហរិហរៈ ដែលម្ខាងជាឥសូរ និងម្ខាងទៀតជាវិស្ណុ ដែលរូបចម្ងាក់ច្រើនធ្វើពីសំរឹទ្ធិ និងថ្ម។

នៅសម័យអាណាចក្រភ្នំ ព្រះពុទ្ធសាសនាមានការរុងរឿងក្រៃលែង ហើយអ្នកស្រុកច្រើនគោរពនិកាយថេរវាទ។ គេបានរកឃើញពុទ្ធរូបជាច្រើនអង្គធ្វើពីសំរឹទ្ធិ ពីថ្ម ឬពីឈើ ជារចនាបថភ្នំជានៅអង្គរបុរី ដែលជាមជ្ឈ-មណ្ឌលផលិតបដិមាទាំងនោះ។ ព្រះពុទ្ធរូបសម័យនោះដែលរកឃើញ គឺព្រះពុទ្ធរូបថ្មនៅវត្តរំលកស្រុកព្រៃកប្បាស ខេត្តតាកែវ ព្រះពុទ្ធរូបសំរឹទ្ធិនៅបាណន់ ខេត្តបាត់ដំបង និងព្រះពុទ្ធរូបនៅទួលព្រះធាតុ ខេត្តកំពង់ស្ពឺ។

អាណាចក្រភ្នំប្រើប្រាស់ភាសាសំស្ក្រឹតជាភាសាផ្លូវការ ក៏ប៉ុន្តែ ភាសាខ្មែរក៏ត្រូវបានគេប្រើប្រាស់ទន្ទឹមនឹងភាសាសំស្ក្រឹតដែរ។ ក្នុងវិស័យជំនឿសាសនា ប្រជាជននៅអាណាចក្រភ្នំបានកាន់សាសនាធំៗទាំងពីររបស់ឥណ្ឌា គឺសាសនាព្រាហ្មណ៍ និងពុទ្ធសាសនា។ ព្រះពុទ្ធសាសនាដែលនាំចូលមកកាន់អាណាចក្រភ្នំដំបូង គឺព្រះពុទ្ធសាសនាមហាយាន ដែលប្រើប្រាស់ភាសាសំស្ក្រឹត។ ចំណែកខាងសាសនាព្រាហ្មណ៍ គេឃើញមានការគោរពចំពោះព្រះឥសូរ ព្រះវិស្ណុ ព្រះហរិហរៈ (វិស្ណុ និងឥសូរ រួមគ្នា) និងព្រះព្រហ្ម។

នៅក្នុងវិស័យស្ថាបត្យកម្ម ប្រាសាទបុពណត្រូវបានសាងសង់ពីដីឥដ្ឋ។ ខឿនសំណង់ផ្សេង។ ដែលគេបានរកឃើញនៅកំពង់ផែអូរកែវ និងនៅអង្គរបុរីក៏ជាសំណង់ពីឥដ្ឋ។ នៅផ្នែកសិល្បៈបដិមា គេបានរកឃើញព្រះពុទ្ធរូប និងទេវរូបជាច្រើននៅតំបន់ភ្នំដា ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចជាពុទ្ធរូបវត្តរំលក រូបព្រះវិស្ណុ ព្រះពលរាម ព្រះកល្កិន និងព្រះគ្រឹស្ណ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

គោរជំនជាដើម។ ស្នាដៃទាំងនេះមានលក្ខណៈជាឥណ្ឌានៅឡើយ។

តាមប្រភពឯកសាររបស់លោក Bernard Philippe Groslier អាណាចក្រភ្នំមិនគ្រាន់តែមានអំណាចសមុទ្រ និងជំនួញប៉ុណ្ណោះទេ ប្រទេសនេះបានជានាឱ្យមានធនធាន កសិកម្មរបស់គេយ៉ាងច្រើនបំផុត ដោយរៀបចំទឹកដីរបស់គេបានប្រសើរ ដោយឈរលើការប្រឹងប្រែងដ៏មហិមា តាមរយៈការបង្កើតនូវប្រព័ន្ធព្រែកជីកសម្រាប់បង្ហូរទឹក និងធ្វើការស្រោចស្រពយ៉ាងប្រទាក់គ្នាចម្រុះ ប្រកបដោយប្រសិទ្ធភាពខ្ពស់សម្រាប់ដំណាំស្រូវ។ ប្រព័ន្ធព្រែកជីកទាំងនេះប្រទាក់ក្រឡាគ្នាពីមួយទៅមួយ រួចហើយក៏បត់បែនទៅនឹងបុរី ហើយក៏បម្រើដល់ការដឹកជញ្ជូននានា ជាពិសេសសម្រាប់នាវាធំៗ ដែលអាចចូលដល់ទៅខាងក្នុងទីក្រុង។ ជាការពិតណាស់ នៅតាមដងផ្លូវទាំងនេះហើយ ដែលឥទ្ធិពលឥណ្ឌាបានជ្រាបចូលទៅតំបន់ខាងក្នុងបានយ៉ាងងាយ។

នៅអំឡុងឆ្នាំ២៦៣-២៨៧ ហ្វូណានមានទំនាក់ទំនងការទូតជាមួយសន្តតិវង្សជិននៃប្រទេសចិន។ ក្នុងសតវត្សទី២ និងទី៣ ទំនាក់ទំនងការទូតជាមួយឥណ្ឌា និងចិនជានានាវាចរណ៍ខាងផ្នែកសមុទ្រ។ ព្រះរាជាណាចក្រហ្វូណានជាប្រទេសល្បីល្បាញនៅអាស៊ី អាគ្នេយ៍រហូតដល់ពាក់កណ្តាលសតវត្សទី៦ទើបធ្លាក់ចុះ។

នៅទ្វីបអាមេរិកឡាទីន អារ្យធម៌ ម៉ាយ៉ា (Maya) បានលេចរូបរាងឡើងនៅឆ្នាំ២៩០នៃគ.ស. នៅតំបន់ដីជ្រលងភ្នំនៃគ្វាតេម៉ាឡា (Guatemala) ហើយចាប់ផ្តើមសាងសង់ប្រាសាទ និងសរសេរសិលាចារឹក ដើម្បីកត់ត្រាប្រវត្តិសាស្ត្រ។ ជនជាតិម៉ាយ៉ាជាជនជាតិដែលរស់នៅទ្វីបអាមេរិកណ្តាល និងបានបង្កើតបានជាទីក្រុងជាច្រើន ដែលគ្រប់គ្រងដោយទេវរាជ។ ទីក្រុងម៉ាយ៉ារីកដុះដាលរហូតដល់ដើមសតវត្សទី៩ ទើបដួលរលំ។

ចំណែកឯនៅឯទ្វីបអឺរ៉ុបវិញ មេដឹកនាំជនជាតិហ៊ុន (Huns) ម្នាក់ឈ្មោះអាទីឡា (Attila) បានបង្រួបបង្រួមជនជាតិហ៊ុន ដែលជាពូជអ្នកចម្បាំង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មកពីអាស៊ីកណ្តាលពួកគែជិះសេះ ហើយដែលមកតាំងទីលំនៅនៅក្នុងប្រទេសហុងគ្រីបច្ចុប្បន្ន និងចាប់ផ្តើមធ្វើសង្គ្រាមវាយយកខេត្តភាគខាងកើតនៃចក្រភពរ៉ូម៉ាំង។ នៅឆ្នាំ៤៧៦នៃគ.ស. ចក្រភពរ៉ូម៉ាំងបានដួលរលំ។ ចក្រភពថ្មីមួយទៀតឈ្មោះ ប៊ីហ្សង់ទីន (Byzantine) ឬចក្រភពខាងកើតត្រូវបានបង្កើតឡើង និងបន្តអត្ថិភាពរហូតដល់ឆ្នាំ១៤៥៣។ ចាប់ពីឆ្នាំ៥០០ដល់ឆ្នាំ១៤៥០ គេចាត់ទុកថាជាមជ្ឈិមសម័យនៃប្រវត្តិសាស្ត្រមនុស្សជាតិ។ ចាប់ពីការដួលរលំនៃចក្រភពរ៉ូម៉ាំងមក ទ្វីបអឺរ៉ុបបានធ្លាក់ចូលក្នុងយុគសម័យងងឹតរហូតដល់ដើមសតវត្សទី១១ ទើបព្រះរាជាណាចក្រដ៏មានឥទ្ធិពលត្រូវបានបង្កើតឡើង។

នៅឆ្នាំ៥៧០ មូហាម៉ាត់ (Muhammad) បានចាប់កំណើតនៅក្រុងម៉ែក្កា (Mecca)។ នៅពេលនោះ ប្រជាជនអារ៉ាប៊ី សាអ៊ូឌីតជឿសាសនាជាច្រើន។ នៅពេលមានអាយុ៤០ឆ្នាំ មូហាម៉ាត់ចាប់ផ្តើមទទួលសារពីព្រះជាម្ចាស់ ហើយផ្សព្វផ្សាយសារទាំងនេះ ដែលមានសរសេរនៅក្នុងគម្ពីរកូរ៉ាន់ (Qur'an)។ សាសនាថ្មីនេះមានឈ្មោះថា អ៊ីស្លាម ដែលមានន័យថាការថ្វាយខ្លួនជូនព្រះ។ ចាប់ពីពេលដែលមូហាម៉ាត់ទទួលមរណភាពនៅឆ្នាំ៦៣២ ជនជាតិអារ៉ាប់ ដែលរួបរួមគ្នាដោយសាសនាអ៊ីស្លាមជាសាសនាបានចាប់-ផ្តើមយុទ្ធនាការវាយលុកយកយេរូសាឡិម និងដាម៉ាសពីចក្រភពប៊ីហ្សង់ទីន និងវាយយកចក្រភពពែរ្សទាំងមូលតែម្តង។ បន្ទាប់មកពួកអារ៉ាប់បានវាយយកបានប្រទេសស៊ីរី ប៉ាឡេស្ទីន និងប្រទេសអេហ្ស៊ីប។ នៅឆ្នាំ៦៩៨ ជនជាតិអារ៉ាប់បានគ្រប់គ្រងទ្វីបអាហ្វ្រិកខាងជើងទាំងស្រុងតែម្តង។

គ-អាណាចក្រចេនឡា

ចេនឡា គឺជាដំណាក់កាលអន្តរកាលនៃការយកវប្បធម៌ និងអារ្យធម៌ឥណ្ឌា ដើម្បីយកមកសូឱ្យទៅជាវប្បធម៌ និងអារ្យធម៌ខ្មែរ តាមរយៈការពង្រីកឥទ្ធិពលនៃព្រហ្មញ្ញសាសនា ការសាងសង់ប្រាសាទ និងការកសាង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មូលដ្ឋានគ្រឹះសម្រាប់ការបង្រួបបង្រួមរដ្ឋឱ្យទៅជាអាណាចក្រអង្គរនាពេលអនាគត។

ឯកសារចិន History of the Sui បានបញ្ជាក់ថា ចេនឡាលាតសន្ធឹងនៅខាងត្បូងឈាងខាងលិចនៃលីនយី ប្រហែលនៅចន្លោះចម្ប៉ា និងវៀតណាម ដែលមានរាជធានីនៅបាសាក់ ស្ថិតនៅចំកណ្តាលទន្លេមេគង្គ នៅលើខ្នងភ្នំ ដែលមានប្រាសាទមួយស្ថិតនៅចំកំពូលភ្នំ។ Coedès បានសន្និដ្ឋានថា រាជធានីរបស់ចេនឡាស្ថិតនៅត្រង់វត្តភូ ដែលបែរមុខទៅទន្លេបាសាក់ ហើយនៅលើកំពូលភ្នំនេះមានលិង្គឥសូរ កទ្រេស្វរៈ (Bhadresvara) ដែលអ្នកស្រុកគោរពបូជា។ ថ្វីត្បិតតែសម័យចេនឡាចាប់ផ្តើមពីចុងសតវត្សទី៦ រហូតដល់សតវត្សទី៨ ក៏ប៉ុន្តែ ចេនឡា គឺជារដ្ឋដែលមានអត្តិភាពតាំងតែពីសម័យហ្វូណានមកម៉្លេះ ហើយពីពេលមុន ចេនឡា គឺជាសាមន្តរដ្ឋរបស់ហ្វូណាន (Coedès, 1968:65-67)។

អាណាចក្រអំណាចអង្គរលើកដំបូងចាប់ផ្តើមឡើង នៅទិសឦសាននៃប្រទេសសៀមសព្វថ្ងៃ តាមដងទន្លេសេម៉ួន។ អាណាចក្រចេនឡាដំបូងខាងកើតមានព្រំប្រទល់ជាប់នឹងទន្លេមេគង្គកណ្តាលក្នុងតំបន់ចំប៉ាសាក់ក្នុងប្រទេសឡាវសព្វថ្ងៃ និងក្រចេះ និងទល់នឹងប្រទេសចាម ដែលបានទទួលឥទ្ធិពលឥណ្ឌា។ អាណាចក្រហ្វូណានត្រូវបានឈ្លានពានដោយរដ្ឋចំណុះជិតខាងគឺចេនឡា។

ព្រះពុទ្ធសាសនាមហាយានៅសម័យចេនឡារុងរឿងណាស់ តែគេពុំសូវឃើញមានបដិមាពោធិសត្វអវលោកេស្វរៈទេ មានមួយនៅខេត្តក្រមួនស និងមួយទៀតនៅប្រាសាទសាកៀម ខេត្តសៀមរាប។ ចំណែកលទ្ធិហីនយានក៏មិនសាបសូន្យដែរ។ រូបព្រះពុទ្ធនៃរជ្ជកាលចេនឡាត្រូវបានប្រទះឃើញនៅខេត្តត្រាវិញ ហើយតំបន់ចម្ងាក់ថ្មកក់តាមបែបសាសនាព្រាហ្មណ៍នៃអាស្រមមហាឫស្សីត្រូវបានគេរកឃើញនៅភ្នំដា នៅក្បែរតំបន់អង្គរបុរី។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

រចនាបថភ្នំដា ៖ សិល្បៈខ្មែរនៃរចនាបថភ្នំដា គឺជាសិល្បៈនៅក្មេងខ្ចី នៅឡើយ នៅក្នុងចន្លោះសតវត្សទី៦ និងទី៧។ ប្រាសាទភ្នំដា គឺជាប្រាសាទឥដ្ឋ ដែលសង់លើកំពូលភ្នំក្នុងខេត្តតាកែវ លើខឿនថ្មបាយក្រៀមដែលបន្តុបលើខឿនប្រាសាទបុរាណ ហើយមានប្រអប់ទ្វារធ្វើពីថ្ម។ រូបចម្លាក់នៃរចនាបថភ្នំដា មានលក្ខណៈធម្មជាតិនិយម និងពិសិដ្ឋនិយម គឺ ៖ ព្រះវិស្ណុដៃ៨ មានវង្វង់ជាជ្វានៅខាងក្រោយសម្រាប់ទ្រទ្រង់រូប និងពុទ្ធបដិមា២អង្គទៀត ដែលមានស្វាកស្នាមវប្បធម៌ឥណ្ឌា-ក្រិក។

ចំណែកឯនៅអាស៊ីអាគ្នេយ៍ដែនកោះវិញ ចាប់តាំងពីស.វ.ទី៦ មានអាណាចក្រចំនួនពីរដែលដើរតួនាទីសំខាន់ក្នុងតំបន់ គឺអាណាចក្រស្រីវិជ័យ (Srivijay) ដែលស្ថិតនៅមាត់សមុទ្រប៉ែកអាគ្នេយ៍នៃកោះ ស៊ូម៉ាត្រា ដែលបានក្លាយទៅជាមហាអំណាចជើងទឹកមួយនៃអាស៊ីភាគអាគ្នេយ៍។ ប្រការនេះក៏ជាមូលហេតុមួយផងដែរនៃការធ្លាក់ចុះនៃអាណាចក្រភ្នំ។ ចាប់ពីសតវត្សទី៨ អាណាចក្រថ្មីមួយទៀតត្រូវបានបង្កើតឡើងនៅលើកោះជ្វា (Java) ដែលគ្រប់គ្រងដោយសន្តតិវង្ស សិលិន្ទ្រា (លិលា+ឥន្ទ្រា) (Sailendras) មានន័យថា ស្តេចភ្នំដែលគោរពព្រះពុទ្ធសាសនា។ ព្រះរាជវង្សសិលិន្ទ្រា គឺជាស្ថាបនិកប្រាសាទបូរូបូឌួ (Borobudur) ប្រាសាទចន្ឌី សេវ៉ូ (Candi Sewu) និងប្រាសាទជាច្រើនទៀត។

ឃ-ឡង្គាសានបុរៈ និងសម័យមុនអង្គរ

ប្រាសាទសំបូរព្រៃគុក ដែលមានប្រាសាទនិងសំណង់តូចៗចំនួន ២៥០ ត្រូវបានបញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូនៅឆ្នាំ២០១៧។ ឡង្គាសានបុរៈ គឺជារាជធានីនៅសតវត្សទី៧របស់ព្រះបាទឡង្គាសានវរ្ម័នទី១ (៦១៦-៦៣៥)។ ព្រះបាទឡង្គាសានវរ្ម័នបានតាំងរាជធានីនៅឡង្គាសានបុរៈ គឺសំបូរព្រៃគុក នៅក្នុងខេត្តកំពង់ធំ ហើយដែលលេចធ្លោឡើងនៅស.វ.ទី៧ តាមដងស្ទឹងសែន។ ឡង្គាសានបុរៈ គឺជារាជធានី

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលបានសាងសង់ឡើងជាច្រើនឆ្នាំណាស់មកហើយ មិនមែនជាចលនាវប្បធម៌ ដែលងាកពីតំបន់ឆ្នេរ ហើយចូលទៅតំបន់ខាងក្នុងប្រទេសទេ ដោយសារតែមានរបកគំហើញថ្មីៗ ដែលបង្ហាញថា ទីតាំងនេះមានមនុស្សរស់នៅតាំងតែពីសម័យសំរឹទ្ធិមកម្ល៉ះ ហើយបន្តរីកចម្រើនខ្លាំងនៅសម័យចេនឡាពីសតវត្សទី៦ដល់៨ ហើយនៅសម័យអង្គរទៀតសោត ក៏មានឃើញការប្រើប្រាស់កុលភាជន៍ផងដែរ។

ក្រោយពេលព្រះបាទវ៉ីសានវ៉ារ្ម័នចូលទិវង្គត ព្រះបាទភវវ៉ារ្ម័នទី២ បានឡើងសោយរាជ្យនៅឆ្នាំ៦៣៥។ ដំណាក់កាលនេះ គឺជាសតវត្សដែលអាណាចក្រចេនឡាកំពុងរីកចម្រើន ទ្រុះបញ្ចាំងតាមរយៈការខិតខំប្រឹងប្រែងរបស់សិល្បករ ក្នុងការស្វែងរកសុក្រឹតភាពនៃសមាមាត្រ និងសមតានៃស្នាដៃស្ថាបត្យកម្ម ហើយបង្កើតបានជារចនាបថព្រៃក្មេង។ ប្រាសាទនៃរចនាបថព្រៃក្មេងមាន ប្រាសាទព្រៃក្មេង ដែលជាប្រាសាទតូចមួយនៅក្នុងតំបន់អង្គរ ប្រាសាទស្វាយព្រាម ប្រាសាទបាសិត ប្រាសាទព្រៃប្រាសាទ និងប្រាសាទភ្នំបាយ័ង។ ផ្នែរទ្វារនៃរចនាបថព្រៃក្មេងមានក្បាច់មូលនៅចំកណ្តាល និងរំលេចទៅដោយរំយោលផ្កាវល្លិ៍ព្យួរចុះក្រោម ដែលគេហៅថា «ចលនានៅមួយកន្លែង»។

តាមប្រភពឯកសាររបស់លោក Adhémar Leclère នៅចុងស.វ. ទី៧នៃគ.ស. ប្រទេសឥណ្ឌាមានឥទ្ធិពលយ៉ាងខ្លាំងមកលើអាណាចក្រខ្មែរ ដោយសារបណ្តាក្រុមឧបនិវេសន៍ ដែលនាំយកអារ្យធម៌មកផ្សព្វផ្សាយនៅទីនេះបន្តិចម្តងៗ។ គឺក្រុមឧបនិវេសន៍ហិណ្ឌូ ហើយរាជវង្សស្តេច ដែលសោយរាជ្យនៅអាណាចក្រខ្មែរសុទ្ធតែជាប់អម្បូរក្សត្រិយ៍ ឬព្រាហ្មណ៍ និងម្ចាងទៀតសាសនាដែលគេគោរព គឺព្រហ្មញ្ញសាសនាឬព្រះពុទ្ធសាសនា។ ច្បាប់ទម្លាប់ប្រពៃណី ដែលគេអនុវត្តសុទ្ធតែមានប្រភពចេញមកពីឥណ្ឌា។ គេគោរពបូជាអាទិទេពរបស់ឥណ្ឌា គេអានសៀវភៅឥណ្ឌា។ ពួកព្រាហ្មណ៍មកតាំងទីលំនៅក្នុងឥណ្ឌូចិនដោយស្ម័គ្រចិត្ត ព្រោះអ្នកស្រុកអនុវត្តតាមទ្រឹស្តីរបស់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គេ ហើយលើកកូនក្រមុំឱ្យគេទៀតផង។ នៅសម័យចេនឡា លទ្ធិព្រហ្មញ្ញ សាសនាមានការរីកវិត្ត ដោយសារប្រជាជនគោរពទូរទេវរូបទាំងបីគឺ ព្រះឥសូរ ព្រះវិស្ណុ និងព្រះហរិហរៈ។

ខ្មែរចាប់ផ្តើមសាងសង់ប្រាសាទធ្វើពីឥដ្ឋ និងលម្អដោយក្បាច់ធ្វើពីថ្មកក់ដែលបង្ហាញពីរចនាបថដ៏ស្រស់ប្រិមប្រិយនិងចាប់ផ្តើមបង្កើតសិលាចារឹកជាភាសាខ្មែរផងដែរ។ ព្រហ្មញ្ញសាសនាកាន់តែចាក់ឫសចូលជ្រៅក្នុងសង្គមខ្មែរ ជាពិសេស គឺសិវនិយម វិស្ណុនិយម និងហរិហរៈ (ម្ខាងជាព្រះសិវៈ និងម្ខាងទៀតជាព្រះវិស្ណុ)។

ព្រះបាទជ័យវរ្ម័នទី១ (៦៥៧-៦៨១) ដែលជាបុត្រព្រះបាទភវវរ្ម័នទី២ បានឡើងសោយរាជ្យនៅឆ្នាំ៦៥៧ ហើយបានពង្រីក និងពង្រឹងអំណាចរបស់ព្រះអង្គនៅឥណ្ឌូចិនភាគខាងត្បូង និងបានសាងសង់ប្រាសាទនៅតំបន់វ៉ាធបុរៈ និងនៅវត្តភូផងដែរ។ គេឃើញមានសិលាចារឹក និងប្រាសាទជាច្រើនដែលត្រូវបានសាងសង់នៅក្នុងរជ្ជកាលនេះ។ យើងមិនដឹងច្បាស់ពីរាជធានីនៅសម័យនោះឡើយ តែប្រវត្តិវិទូខ្លះបានសន្និដ្ឋានថា រាជធានីនេះគឺ អមរេន្ទ្របុរៈ ប្រហែលស្ថិតនៅម្តុំអង្គរ ដែលមានប្រាសាទអកយំ នៅចំកណ្តាល។ បន្ទាប់មក ប្រហែលជារាជធានីត្រូវបានលើកយកមកកាន់តំបន់នៃប្រាសាទត្រពាំងផុង ដែលត្រូវបានព្រះបាទជ័យវរ្ម័នទី៦កែលម្អថែមទៀត។ ក្នុងរជ្ជកាលនៃព្រះបាទជ័យវរ្ម័នទី១ ព្រហ្មញ្ញសាសនាសិវនិយមកំពុងរីកចម្រើន ជាពិសេសការគោរពបូជាលិង្គព្រះឥសូរ។ ចំណែកឯការគោរពបូជាព្រះពុទ្ធសាសនាមហាយានកាន់តែធ្លាក់ចុះ ដោយសារតែគេមិនសូវឃើញមានរូបចម្លាក់ព្រះពុទ្ធរូប នៅក្នុងសម័យកាលនេះទេ។ ស្ថាបត្យកម្មនៃដំណាក់កាលនេះមានលក្ខណៈបន្តពីរចនាបថព្រៃក្មេង ហើយត្រូវបានគេចាត់ទុកថាជាដំណាក់កាលទីពីរនៃរចនាបថព្រៃក្មេង ថែមទៀតផងដែលមានឈ្មោះថា រចនាបថប្រាសាទអណ្តែត ដែលមានរយៈកាលជំនាន់រចនាបថព្រៃក្មេងដែរ។ ស្នាដៃវិចិត្រដែលធ្ងុះបញ្ចាំងជាងគេនៃរចនាបថ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រាសាទអណ្តែត គឺរូបចម្លាក់ហរិហរៈនៃប្រាសាទអណ្តែត ដែលស្ថិតនៅក្នុងសារៈមន្ទីរជាតិនៃទីក្រុងភ្នំពេញ។

នៅក្នុងឆ្នាំ១៨៩១ លោក Adhémard Leclère បានរកឃើញសិលាចារឹកមួយផ្ទាំងនៅប្រាសាទត្រពាំងព្រៃ ស្រុកសំបូរ ខេត្តក្រចេះ ដែលសាងសង់ឡើងក្នុងស.វ.ទី៧។ ការស្រាវជ្រាវរបស់លោក Coedès តាមរយៈការសិក្សាសិលាចារឹកស.វ.ទី៧ K-127 ដែល នាពេលបច្ចុប្បន្នស្ថិតនៅក្នុងអភិរក្សអង្គរ និងបញ្ជាក់ដោយលោក Amir Aczel បានរកឃើញថា ជូនតាខ្មែរគឺជាអ្នកបង្កើតលេខសូន្យមុនគេលើពិភពលោក។ ក្នុងឆ្នាំ១៩៣១ លោក Coedès បានបកប្រែអត្ថបទលើសិលាចារឹកK-127នេះ មកជាភាសាបារាំង និងបានកត់សម្គាល់ថា លេខជាភាសាខ្មែរ៦០៥នេះ គឺជាលេខសូន្យចាស់ជាងគេលើសិលាចារឹក ដែលគាត់បានរកឃើញ។ លោក Coedès បានសរសេរអត្ថបទមួយក្នុងឆ្នាំ១៩៣១។

សតវត្សទី៨ គឺជាសម័យកាលនៃការធ្លាក់ចុះនៃអំណាចកណ្តាលរបស់ចេនឡា ដែលអាចបណ្តាលមកពីកលិយុគ ឬសត្រូវពីខាងក្រៅចូលមកឈ្លានពាន។ តាមសំណេររបស់អ្នកនិពន្ធអារ៉ាប់ក្នុងសតវត្សទី១០ ឈ្មោះ ស៊ូឡាយម៉ាន់ នៅក្នុងឆ្នាំ៧៨០ ស្តេចជ្វានៃរាជវង្សសៃលិន្ទ្រាបានរៀបចំកងទ័ពជើងទឹកមកឈ្លានពាន ហើយលើកស្តេចថ្មីឱ្យឡើងសោយរាជ្យ។ ព្រះនាងជ័យទេវី គឺជាស្តេចសោយរាជ្យនៅដើមសតវត្សទី៨។ ស្ថានភាពនយោបាយតានតឹងនេះមានឥទ្ធិពលទៅលើសិល្បៈផងដែរ។ ប្រាសាទភូមិប្រាសាទ និងប្រាសាទកំពង់ព្រះ ដែលជាតំណាងនៃរចនាបថកំពង់ព្រះ គឺជាប្រាសាទសាងសង់ពីឥដ្ឋ នៅសតវត្សទី៨ នៅពេលដែលចេនឡាជួបវិបត្តិកលិយុគ។ សិល្បៈខ្មែរធ្ងន់បញ្ជាំងនូវការរលត់បាត់បង់អស់វិញ្ញាណ ហើយនៅសល់តែភាពសាមញ្ញប៉ុណ្ណោះ ដោយសារតែខ្វះភាពច្នៃប្រឌិត។ ផ្នែរទ្វារនៃរចនាបថកំពង់ព្រះមានលក្ខណៈសាមញ្ញ ហើយចម្លាក់បិទភ្ជាប់បន្តបន្ទាប់គ្នា មានរាងជាស្លឹកឈើមួយសំណុំជាក់ផ្តេកគងលើគ្នា ជាបន្ត

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បន្ទាប់។ នៅចំកណ្តាល គេក៏ឃើញមានស្វ៊ីកឈើ ដែលមានរាងដូចភាហ៊ូ ឬ កល។ រចនាបថកំពង់ព្រះបង្ហាញពីធម្មជាតិនិយម ដែលលម្អដោយស្វ៊ីក ឈើ និងមែកឈើទាំងស្រុង។ សសរពេជ្រនៅរក្សាភាងមូលដដែល តែលម្អ ដោយក្បាច់ចិញ្ចៀនកង៏បន្តបន្ទាប់គ្នា បីដូចជាទង់ផ្កា។ ចំណែកឯហោជាង វិញមានរាងជាអក្សរ ប ផ្កាប់ ហើយនៅលើផ្ទៃហោជាងមានរូបតូច។ ប្រាសាទនៃរចនាបថកំពង់ព្រះគឺ ៖ ប្រាសាទកំពង់ព្រះ (ខេត្តកំពង់ឆ្នាំង) ប្រាសាទអកយំប្រាសាទត្រពាំងផុងប្រាសាទបាសិតប្រាសាទភូមិប្រាសាទ (ខេត្តកំពង់ធំ)។

នៅពេលដែលមានខ្មាំងពីក្រៅមកឈ្លានពានត្រួតត្រាកម្ពុជា ព្រះ បាទជ័យវរ្ម័នទី៦ បានកេណ្ឌទ័ពធ្វើសង្គ្រាមរំដោះចេនឡា បង្រួបបង្រួម នគរតូច។ ដើម្បីបង្កើតអាណាចក្រអង្គរជំរុំវៀងចាប់ពីឆ្នាំ៨០៦។

នៅប្រទេសចិនវិញ សន្តតិវង្សតាំង (៦១៨-៩០៧) បានបង្រួបបង្រួម និងគ្រប់គ្រងប្រទេសឱ្យស្គាល់នូវការរីកចម្រើនខាងផ្នែកសិល្បៈនិងបច្ចេក វិទ្យា ហើយឥទ្ធិពលចិនបានលាតសន្ធឹងដល់អាស៊ីកណ្តាល ហើយដំណាក់ កាលនេះ គឺជាយុគសម័យមាសនៃប្រទេសចិន។ បន្ទាប់ពីមានការបែកបាក់ ក្នុងរយៈពេលដ៏ខ្លី សន្តតិវង្សសុង (៩៦០-១២៧៩) បានដឹកនាំប្រទេសចិន ឱ្យស្គាល់វិបុលភាពរហូតដល់ពួកម៉ុងហ្គោលចូលមកឈ្លានពាន។

ចាប់ពីសតវត្សទី៥ និងទី៦មក ចក្រភពគុប្តៈនៅឥណ្ឌាបានបង្កើត សាកលវិទ្យាល័យនលន្ទា (Nalanda) ដែលស្ថិតនៅក្នុងអាណាចក្រមគធៈ (រដ្ឋបីហារបច្ចុប្បន្ន) ដើម្បីបណ្តុះអ្នកប្រាជ្ញខាងផ្នែកព្រះពុទ្ធសាសនា។ និស្សិតសិក្សាពុទ្ធសាសនាមហាយាន និងថេរវាទ ព្រមទាំង ឯកសារស្តីពីពុទ្ធសាសនាថេរវាទ គម្ពីរវេទ តក្កវិទ្យា វេយ្យាករណ៍ និង ទស្សនវិជ្ជា វិជ្ជាពេទ្យ។ល។ នៅសតវត្សទី៧ សាកលវិទ្យាល័យនលន្ទាមាន សាស្ត្រាចារ្យចំនួនជាង១ ៥១០នាក់។

នៅអាស៊ីអាគ្នេយ៍ មានរដ្ឋមួយទៀតដែលរីកចម្រើននៅចន្លោះ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សតវត្សទី៥ និងទី៩ គឺ «ទ្វារវតី» (Dvaravati) ហើយអារ្យធម៌ទ្វារវតីនេះរីកចម្រើននៅជុំវិញទីក្រុងព័ទ្ធដោយទឹក នៅតំបន់អ៊ូ ថុង (បច្ចុប្បន្នខេត្ត សុផាន់បុរី) នគរបធម ផុងទុក ស៊ីទេព និងស៊ីមហោសថ ជាដើម។ គេដឹងពី«ទ្វារវតី» តាមរយៈសិលាចារឹកជាភាសាមន ហើយរដ្ឋនេះរីកលូតលាស់ ដោយសារជំនួញ និងទទួលវប្បធម៌ពុទ្ធសាសនាថេរវាទ តាមរយៈទំនាក់ទំនងជាមួយឥណ្ឌា និងតាមរយៈព្រះសង្ឃ។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំពូក២
សម័យអង្គរដើម

សម័យអង្គរ គឺជាដំណាក់នៃការបង្រួបបង្រួមរដ្ឋតូចៗ តាមរយៈការធ្វើសឹកសង្គ្រាមឱ្យទៅជាអាណាចក្រដ៏ធំជាងគេនៅអាស៊ីអាគ្នេយ៍។ អង្គរកើតចម្រើនដោយពឹងផ្អែកលើវិស័យកសិកម្ម ដែលមានប្រព័ន្ធស្រោចស្រពលាតសន្ធឹងលើផ្ទៃដីដ៏ធំល្វឹងល្វើយ មានប្រជាជនជាង១លាននាក់ មានប្រព័ន្ធអប់រំឈានមុខឈរលើមូលដ្ឋានគ្រឹះនៃលទ្ធិព្រហ្មញ្ញសាសនា ការគ្រប់គ្រងរដ្ឋតាមបែបឥណ្ឌា និងបានបង្កើតឡើងនូវប្បធម៌ និងអារ្យធម៌អង្គរដ៏រុងរឿង ល្បីល្បាញសុសសាយនៅក្នុងពិភពលោក តាមរយៈការសាងសង់ប្រាសាទ សិល្បៈ តន្ត្រី កុលាលភាជន៍ និងរបាំជាដើម។

១-តើព្រះមហាក្សត្រអង្គណាជាអ្នកកសាងរាជវង្សអង្គរ?

ព្រះបាទជ័យវរ្ម័នទី២ជាស្តេចបង្រួបបង្រួមជាតិ ៖ សិលាចារឹកស្តុកកក់ធំ គឺជាប្រភពព័ត៌មានប្រវត្តិសាស្ត្រកម្ពុជាសម័យមុនអង្គរ និងសម័យអង្គរ។ តាមសិលាចារឹកនេះ ចក្រភពអង្គរត្រូវបានចាប់ផ្តើមកសាងឡើងដោយព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៥០)។ ព្រះបាទជ័យវរ្ម័នទី២ទ្រង់យាងមកពីប្រទេសជ្វា ដើម្បីរំដោះប្រទេសជាតិឱ្យមានឥស្សរភាព និងបង្រួបបង្រួមកម្ពុជាឱ្យមានឯកភាពជាតិឡើងវិញ។ ព្រះបាទជ័យវរ្ម័នទី២បានរៀបចំមូលដ្ឋានគ្រឹះខាងផ្នែកនយោបាយ សាសនា និងស្ថាបត្យកម្មនៃ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

អំណាចសម័យអង្គរ ដោយប្រមូលផ្តុំរដ្ឋចេនឡា ដែលបែកបាក់ ហើយបង្កើតជាអាណាចក្រមួយយ៉ាងធំ ដែលយកព្រហ្មញ្ញសាសនា ជាមូលដ្ឋានគ្រឹះនៃការគសាងរដ្ឋ។ ព្រះអង្គបានផ្ទាស់ប្តូររាជធានីញឹកញាប់ ដើម្បីបង្រួបបង្រួមទឹកដី។ រជ្ជកាលអង្គរចាប់ផ្តើមពីការបង្រួបបង្រួមទឹកដីនៃរដ្ឋចេនឡា ដែលបែកបាក់ ដោយព្រះបាទជ័យវរ្ម័នទី២បានបង្កើតរាជធានីនៅឥន្ទ្របុរៈ (កំពង់ចាម) បន្ទាប់មករើមកនៅហរិហរាល័យ (រលួស សៀមរាប) បន្ទាប់មករើមកនៅស្រីមហេន្ទ្របុរៈ បន្ទាប់មករើមកនៅអមរេន្ទ្របុរៈ (ប្រាសាទអកយំ បាភយណ៍) និងចុងក្រោយបំផុត ព្រះអង្គរៀបចំរាជធានីនៅ មហេន្ទ្របព៌ត (ភ្នំគូលែន)។ ភ្នំគូលែន គឺជាតំណាងភ្នំសុមេរុ។ នៅលើកំពូលភ្នំគូលែន ព្រះបាទជ័យវរ្ម័នទី២បញ្ជាឱ្យព្រាហ្មណ៍ឈ្មោះ ហិរណ្យទាម ដែលជាអ្នកប្រាជ្ញមកប្រារព្ធ «ពិធីទេវរាជ» ដើម្បីប្រកាសឯករាជ្យរបស់ប្រទេសខ្មែរឱ្យរួចពីចំណុះប្រទេសជ្វា ហើយអភិសេកព្រះអង្គឱ្យមានឋានៈជាចក្រវាទីន (ស្តេចចក្រវាល) នៅគ.ស.៨០២។ ចុងបញ្ចប់ ព្រះអង្គសុគតនៅក្រុងហរិហរាល័យ។

លទ្ធិទេវរាជជានិមិត្តរូបនៃអំណាចខ្មែរ ៖ យើងបានដឹងយ៉ាងច្បាស់ពីលទ្ធិទេវរាជពីសិលាចារឹកស្តុកកក់ធំ ដែលអ្នកប្រាជ្ញជាតិបារាំងឈ្មោះ George Coedès និង Dupont បានសិក្សាយ៉ាងលម្អិតនៅក្នុងអត្ថបទមួយក្រោមចំណងជើងថា «សិលាចារឹកស្តុកកក់ធំ ភ្នំសណ្តាក និងព្រះវិហារ»។ ព្រះបាទជ័យវរ្ម័នទី២ បញ្ជាឱ្យព្រាហ្មណ៍ហិរណ្យទាម បង្រៀនព្រាហ្មណ៍ម្នាក់ទៀតឈ្មោះថា សិវកៃវល្យ ដែលជាវាជបុរោហិតនូវគម្ពីរបួនគឺ ព្រះវិនាសិក្ខ-ព្រះនយោត្តរ-ព្រះសម្មោហៈ និងព្រះសិរសច្ឆេទៈ ដែលជាលទ្ធិព្រះឥសូរ។ ពិធីទេវរាជនេះត្រូវមានព្រាហ្មណ៍ជាអ្នករៀបចំ។ ទ្រង់បានប្រកាសយកព្រហ្មញ្ញសាសនាជាសាសនារបស់កម្ពុជា។ បន្ទាប់ពីប្រសិទ្ធីហើយ ព្រះសិវលិង្គនេះក៏ក្លាយទៅជាទេវរូប ដែលមានឋានៈជាកម្រតេង៍អញ ជគតតាជ។ ព្រះបាទជ័យវរ្ម័នទី២ និងព្រាហ្មណ៍ហរិណ្យទាមបានសច្ចាថា

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មានតែសមាជិកគ្រួសារព្រាហ្មណ៍សិវកៃវល្យទេ ដែលអាចប្រារព្ធធ្វើពិធីទេវរាជបាន។ បន្ទាប់ពីរៀបចំពិធីទេវរាជ ព្រះសិវលិង្គទទួលប្រសិទ្ធិ ហើយក្លាយទៅជាទេវរូប ដែលគេពាល់គ្នាត្រូវគោរពបូជា។ ព្រះសិវលិង្គនេះមានតែមួយទេ ហើយអាចយកទៅតម្កល់ទុកនៅកន្លែងជាទីសក្ការៈ និងអាចយកពីមួយកន្លែងទៅតម្កល់នៅមួយកន្លែងទៀត ដើម្បីការពារនិងរក្សានគរ។ ចាប់តាំងពីស.វ.ទី៩មក ពិធីនេះត្រូវបានរៀបចំឡើងនៅលើភ្នំ ឬប្រាសាទភ្នំ ដើម្បីគោរពដល់បុព្វបុរសមហាក្សត្រខ្មែរ ដែលទើបឡើងសោយរាជ្យថ្មី និងដើម្បីអភិសេកមហាក្សត្រថ្មីនេះឱ្យមានឫទ្ធានុភាពស្មើនឹងអាទិទេពផង។ ជារួម លទ្ធិទេវរាជ គឺជាការរៀបអភិសេកសិវលិង្គ ដែលគេសន្មតថា បានមកពីព្រះឥសូរ តាមរយៈព្រាហ្មណ៍ ដោយមានគោលដៅដូចតទៅ៖

- ដើម្បីឱ្យអាស្ថិនពិសិដ្ឋរបស់ព្រះរាជាបានទៅសណ្ឋិតនៅក្នុងសិវលិង្គនោះ និងបានក្លាយជានិមិត្តរូបនៃទេវរាជ។ សិវលិង្គដែលក្លាយជានិមិត្តរូបរបស់ជាតិជួយការពារអាណាចក្រខ្មែរឱ្យរួចផុតពីគ្រោះចង្រៃផ្សេងៗ ក៏ដូចជាពីសត្រូវដែលមកឈ្លានពាន។

- ធ្វើឱ្យព្រះរាជាក្លាយទៅជាព្រះឥសូរ។ ក្រោយពីការធ្វើពិធីអភិសេក «ពិធីទេវរាជ»នេះហើយ ព្រះរាជាក៏មានឋានៈជាចក្រវាទីន (ស្តេចចក្រវាល) ដែលជាព្រះឥសូរបែងកាត ដែលមានអំណាចអាចគ្រប់គ្រងទៅលើសព្វសត្វ ហើយបញ្ជារបស់ព្រះរាជាគឺជាបញ្ជារបស់អាទិទេព។ ប្រការនេះមានន័យថា ព្រះរាជាទទួលបញ្ជាដោយផ្ទាល់ពីអាទិទេព ដើម្បីគ្រប់គ្រងផែនដី។

- ដោយព្រះឥសូរមានលំនៅនៅលើ ភ្នំកៃលាស សិវលិង្គដែលជាតំណាងព្រះឥសូរផង និងជាតំណាងព្រះរាជាផងក៏ត្រូវយកទៅតម្កល់នៅលើភ្នំដែរ។ ប្រសិនបើគ្មានភ្នំធម្មជាតិទេ គេត្រូវសាងប្រាសាទដែលមានខឿនច្រើនជាន់ ឱ្យមានកម្ពស់ដូចភ្នំ ហើយដែលគេហៅថា ប្រាសាទភ្នំ។ ប្រាសាទភ្នំនេះត្រូវស្ថិតនៅចំកណ្តាលរាជធានី ដែលគេចាត់ទុកថា នៅចំស្នូលនៃចក្រវាល។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

តួនាទីព្រះរាជគ្រូក្នុងការកសាងធនធានមនុស្សសម័យអង្គរ ៖ រាជបុរោហិត ឬរាជគ្រូរបស់ព្រះមហាក្សត្រដែលជាព្រាហ្មណ៍ ឬបណ្ឌិតដើរតួនាទីយ៉ាងសំខាន់នៅក្នុងសាសនា និងនយោបាយរបស់អាណាចក្រខ្មែរ។ ព្រាហ្មណ៍ខ្លះមានដើមកំណើតពីប្រទេសឥណ្ឌា តែខ្លះទៀតគឺជាខ្មែរដែលបានសិក្សានៅប្រទេសឥណ្ឌា ហើយបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការពារប្រពៃណីហិណ្ឌូ និងវប្បធម៌សំស្ក្រឹតនៅក្នុងអាណាចក្រខ្មែរ។ រាជបុរោហិតជួរៀបចំវប្បកម្មខ្មែរ ជាអ្នកបង្រៀនកម្មវិធីខ្មែរ រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ ជួយជីកទាំកសាងប្រាសាទ តែងនិពន្ធកាន់បាប់ គម្ពីរសាស្ត្រាធំៗ ចារឹកសិលាចារឹក កសាងស្រុកភូមិ និងធានាការគោរពសាសនា។ ពួកព្រាហ្មណ៍ទាំងនោះក៏បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការចូលរួមវិភាគទានក្នុងការអភិវឌ្ឍសិល្បៈខ្មែរផងដែរ។

ការតែងតាំងរាជបុរោហិតមានលក្ខណៈតពូជពង្សវង្សត្រកូលតែម្តង។ តាមប្រភពឯកសាររបស់លោក ឡេអ៊ែនស៍ ប៉ាលម័រ ប្រ៊ីគ្តស៍ គ្រួសារប្រាណវត្ថ៌ន មានសិទ្ធិតពូជក្នុងការតែងតាំងអាចារ្យព្រាហ្មណ៍ (Hotar) ឬ រាជបុរោហិត។ គ្រួសារហរិបុរមានសិទ្ធិតពូជជាព្រះសង្ឃសម្រាប់ពិធីបូជាសពជាដើម។

នៅសម័យអង្គរ អាណាចក្រខ្មែរសម្បូរអ្នកប្រាជ្ញនិងអ្នកនិពន្ធមានទេពកោសល្យខ្ពស់ជាច្រើន។ ភាសាសំស្ក្រឹតជាមូលដ្ឋាននៃព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាមហាយាន និងជាភាសាផ្លូវការសម្រាប់កិច្ចការរដ្ឋ-សម័យអង្គរ។ ដូច្នេះហើយ អក្សរសាស្ត្រខ្មែរសម័យអង្គរមានលាយឡំអក្សរខ្មែរបុរាណ និងភាសាសំស្ក្រឹត។ អក្សរសិល្បខ្មែរជំនាន់អង្គរក៏បានឡើងដល់កម្រិតកំពូលដែរ តែយើងឃើញនៅសល់តែអក្សរសិល្បដែលបានសរសេរលើសិលាចារឹកតាមប្រាង្គប្រាសាទនានាជាភាសាខ្មែរបុរាណ និងជាភាសាសំស្ក្រឹតប៉ុណ្ណោះ។ អ្នកប្រាជ្ញជំនាន់នោះនិយមសរសេរជាភាសាសំស្ក្រឹត ដែលជាភាសាជាន់ខ្ពស់របស់អ្នកប្រាជ្ញ។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅអំឡុងឆ្នាំ ៨២៥ សន្តតិវង្សសៃលិន្ទ្រា (Sailendra) ដែលមានដើមកំណើតនៅកាលិង្គៈនៃឥណ្ឌាភាគខាងជើង បានសាងសង់ប្រាសាទបូរ៉ូបូឌួរ (Borobudur) ដែលជាបូជនីយដ្ឋានព្រះពុទ្ធសាសនាធំជាងគេនៅប្រទេសឥណ្ឌូណេស៊ី ដែលមានរូបបដិមាព្រះពុទ្ធចំនួន៥០៤អង្គ។ ចំណែកឯនៅអឺរ៉ុប ជនជាតិវ៉ាយគីង (Viking) បានចាប់ផ្តើមវាយលុកតាមឆ្នេរសមុទ្រអាត្លង់ទិក ហើយបានតាំងទីលំនៅនៅក្នុងប្រទេសអង់គ្លេស អៀកឡង់ និងបារាំងដែលគេវាយយកបាន។

នៅក្នុងសតវត្សទី១០ ក្នុងឆ្នាំ៩៣៩ វៀតណាមបានទទួលឯករាជ្យពីចិន។ នៅពេលនោះ វៀតណាមនៅខ្សោយនៅឡើយ។ សង្គ្រាមនៅពេលនោះ គឺជាសង្គ្រាមរវាងអាណាចក្រខ្មែរ និងចម្ប៉ាតែប៉ុណ្ណោះ។ ក៏ប៉ុន្តែ ចាប់ពីសតវត្សទី១៧មក ហើយជាពិសេសបន្ទាប់ពីវៀតណាមបានលេបយកចម្ប៉ាក្នុងសតវត្សទី១៨រួចមក វៀតណាមបានចាប់ផ្តើមធ្វើសង្គ្រាមជាមួយកម្ពុជាដើម្បីពង្រីកដែនដីរបស់ខ្លួន។

នៅក្នុងអាណាចក្រភូមាវិញ ព្រះបាទអនវរ៉ាធ៌: (Anawrahta) បានឡើងសោយរាជ្យជាស្តេចនៃបាហ្គាន់ ដែលជាអាណាចក្រពុទ្ធសាសនានៅតាមដងទន្លេអ៊ីរ៉ាវ៉ឌី ដែលមានឈ្មោះថា អាណាចក្របាហ្គាន់ (១០៤៤–១២៨៧)។ ព្រះអង្គបានសាងសង់ប្រាសាទស្វេហ្សីហ្គន (Shwezigon) ដើម្បីរក្សាទុកនូវព្រះសារីរិកធាតុ។

អារ្យធម៌ខ្មែរបានឈានដល់កម្រិតកំពូល ៖ ចាប់ពីស.វ.ទី១១ដល់ស.វ.ទី១៣ អារ្យធម៌ខ្មែរបានឈានដល់កម្រិតកំពូល។ នៅពេលនោះ ព្រះមហាក្សត្រខ្មែរបានកសាងប្រាង្គប្រាសាទជាច្រើន ដើម្បីឧទ្ទិសដល់ព្រះអាទិទេព ឬបុព្វការីជនរបស់ព្រះអង្គ និងដើម្បីជានាឱ្យបាននូវវិបុលភាព និងឯកភាពជាតិខ្មែរ។ ការសាងសង់ប្រាសាទបុរាណខ្មែរមានការវិវត្ត និងកែលម្អជាប្រចាំ ដែលឆ្លុះបញ្ចាំងពីដំណាក់កាល យុវវ័យ ភាពចាស់ទុំ និងជរាភាព។ អ្នកដែលសិក្សាសិល្បៈខ្មែរបានបែងចែកប្រាសាទបុរាណខ្មែរ ជា

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ស្ថាបត្យកម្មមុនសម័យបុរាណ (ពីស.វ.ទី១ដល់ស.វ.ទី៨) ស្ថាបត្យកម្មសម័យអង្គរ (ពីស.វ.ទី៩ដល់ស.វ.ទី១៣) និងស្ថាបត្យកម្មក្រោយសម័យអង្គរ (ពីស.វ.ទី១៤ដល់សព្វថ្ងៃនេះ)។ លោក Claude Jacques បានគូសបញ្ជាក់ថា សិល្បៈខ្មែរបានវិវត្តទៅតាមវិធីសាស្ត្របួនយ៉ាង គឺ ៖

ទីមួយ-តក្កកម្ម មានន័យថា ការបង្កើតអ្វីៗថ្មីទាំងស្រុង។

ទីពីរ-ការចូលរួមវិភាគទានពីសិល្បៈបរទេស (គឺពីសិល្បៈឥណ្ឌាតែក៏មានសារជាតុខ្លះនៃសិល្បៈជ្វា និងសិល្បៈចាមដែរ)។

ទីបី-ការខ្ចីនូវរចនាបថពីអតីតកាល តែមិនបានចម្លងទាំងស្រុងនូវរចនាបថទេ ដោយគ្រាន់តែស្វែងរកប្រធានបទចាស់ៗ ដើម្បីបញ្ចូលសាជាថ្មី ដោយមានធ្វើវិសោធនកម្មនៅលើអ្វីដែលមានចាស់។

ទីបួន-ការចម្លងតាមនូវបច្ចេកទេសផ្សេងៗ ហើយអ្វីដែលគេច្រើនជួបប្រទះ គឺការចម្លងតាមនូវក្បាច់រចនានៃសំណង់ឈើតូចតាចៗ។

ដោយឈរលើមូលដ្ឋាននៃការសិក្សានូវលក្ខណៈពិសេសខាងផ្នែកស្ថាបត្យកម្ម ឬក្បាច់រចនាផ្សេងៗ លោក Philippe Stern និង Gilbert de Coral-Rémusat បានបង្កើតបានជាបញ្ជីរចនាបថចំនួន១៣ ដោយដាក់ឈ្មោះតាមប្រាសាទសំខាន់ៗនិងមានលក្ខណៈពិសេស ហើយដែលតំណាងឱ្យរចនាបថសម័យនោះ។ តាមរយៈការសិក្សារួបចម្លាក់ លោក Jean Boisselier និង Pierre Dupont បានបន្ថែមនូវរចនាបថពីរទៀត គឺរចនាបថភ្នំដា និងរចនាបថប្រាសាទអណ្តែត។ ដូច្នេះ សិល្បៈខ្មែរបានវិវត្តទៅតាមរចនាបថចំនួន ១៥។ យើងឃើញថា សិល្បៈខ្មែរក្នុងដំណាក់កាលដំបូងស្ថិតនៅក្នុងសភាពក្មេងខ្ចីនៅឡើយ ហើយខ្ចីពីសិល្បៈឥណ្ឌាយ៉ាងច្រើន ដោយពុំទាន់សូន្យឱ្យចេញជាអត្តសញ្ញាណជាតិខ្មែរឱ្យបានទាំងស្រុងនៅឡើយ។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

២-មហាវីរក្សត្រសម័យអង្គរ

តាមប្រភពសិលាចារឹក ស្តុកកក់ធំ ព្រះមហាក្សត្រនៅសម័យអង្គរ មាន ៖

(១) ព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៥០) ដែលមានព្រាហ្មណ៍ សិវកៃវល្យ ជាបុរោហិត។ សិលាចារឹកបាពួន (K583) រៀបរាប់ថា ព្រះបាទជ័យវរ្ម័នទី២ជាអាទិទេពនៃក្សត្រលើគ្រប់ទ្វីប ដែលគ្រប់គ្រងប្រទេសប្រកបដោយទសពិធរាជធម៌ និងការពារប្រជាជនរបស់ព្រះអង្គ។ ព្រះរាជបុត្រព្រះអង្គព្រះនាម ស្រីឥន្ទ្រាយុទ្ធ មានឋាមពលខ្លាំងក្លាតាំងពីវ័យក្មេង ដោយច្បាំងឈ្នះស្តេចចម្ប៉ា។ ព្រះអង្គបានយាងទៅធ្វើធម៌នៅលិង្គបុរី (វត្តភូ)។ តាមបញ្ជារបស់ព្រះសិវៈ ព្រះអង្គបានសាងលិង្គមួយពីបំណែកលិង្គធំមួយទៀតឈ្មោះ លិង្គនិសកល ហើយព្រះអង្គបានតម្កល់លិង្គនេះនៅវត្តសន្ទុ ដោយប្រគេនថ្វាយព្រះចៅលិង្គបុរីនូវទេវរូប ស្រីសិខរិស្វរៈ ហើយបន្ទាប់មកព្រះអង្គបានយកលិង្គនេះមកទុកនៅប្រាសាទព្រះវិហារ។

រចនាបថគូលែន ៖ រចនាបថគូលែនធ្លុះបញ្ចាំងនូវស្ថិរភាពនយោបាយ និងសង្គមនៃរជ្ជកាលព្រះបាទជ័យវរ្ម័នទី២ ដែលបានរំដោះប្រទេសឱ្យមានឥស្សរភាពឡើងវិញ និងបង្រួបបង្រួមប្រទេសជាតិឱ្យមានឯកភាព។ រចនាបថនេះមានទិដ្ឋភាពបន្ត្រប់គ្នាបីយ៉ាង ៖ (១) សសរពេជ្រមានរចនាបថឯកភាពគ្នា ដែលបង្ហាញពីភាពសម្បូរណ៍បែប និងការច្នៃប្រឌិតយ៉ាងប៉ិនប្រសប់។ សសរពេជ្រទាំងនេះមានច្រាំជ្រុង ឬបួនជ្រុងស្មើ (៦) ផ្នែរមានលក្ខណៈកែលម្អយ៉ាងវិចិត្រ និងមានការច្នៃប្រឌិតរស់រវើក ដោយច្របាច់បញ្ចូលសិល្បៈខ្មែរដើម ជាមួយសិល្បៈខ្ចីពីបរទេស និងបង្ហាញពីនិមិត្តរូបនៃកម្លាំងទ័ពរបស់ព្រះបាទជ័យវរ្ម័នទី២ ក្នុងការប្រយុទ្ធជាមួយទ័ពជ្វា តាមរយៈក្បាច់ត្របកឈូក និងក្បាច់ផ្កាព្រលិត ដែលជានិមិត្តរូបនៃកម្លាំងទ័ព កម្លាំងធម្មជាតិ និងកសិកម្ម និងការបំផ្លែងក្បាច់រចនា និងជីវភាពដែលរក្សាបាននូវតុល្យភាពយ៉ាងសុក្រឹត និង (៣) រូបបដិមាដែលធ្លុះ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បញ្ចាំងពីសម័យអន្តរកាល នៅចន្លោះរចនាបថដែលកន្ធង់ផុតទៅ និង
រចនាបថដែលនឹងមកដល់។ ព្រះបាទជ័យវរ្ម័នទី២ បានសាងសង់ប្រាសាទ
ជាច្រើននៃរចនាបថគូលែន ដូចជាប្រាង្គ (សេ១) នៅសំបូរព្រៃគុក ប្រាសាទ
នៅបន្ទាយព្រៃនគរ ប្រាង្គខាងជើងនៃប្រាសាទព្រៃប្រាសាទ ប្រាសាទដំរី
ក្រាប ប្រាសាទអូផ្ដង ប្រាសាទខ្វិងស្ទាប់ ប្រាសាទរូបអារក្ស ប្រាសាទថ្មដាប់
ប្រាសាទគគីរ ប្រាសាទក្រហម ប្រាសាទអ្នកតា និងប្រាសាទត្រពាំងផុង។

(២) ព្រះបាទជ័យវរ្ម័នទី៣ (៨៥៦-៨៧៧) ជាព្រះរាជបុត្ររបស់
ព្រះបាទជ័យវរ្ម័នទី២ បានឡើងសោយរាជ្យស្នង ដែលមានព្រាហ្មណ៍ សូក្សម
វិន្ទុជាបុរោហិត និងដោយគង់នៅហរិហរាល័យរហូតដល់គ.ស.៨៧៧។
ព្រះអង្គបានសាងប្រាសាទមួយចំនួននៅហរិហរាល័យ (រលួស)។

(៣) ព្រះបាទឥន្ទ្រវរ្ម័នទី១ (៨៧៧-៨៨៩) ប្អូនជីដូនមួយរបស់ព្រះ
បាទជ័យវរ្ម័នទី៣បានឡើងគ្រងរាជសម្បត្តិនៅឆ្នាំ៨៧៧។ នៅក្នុងរជ្ជកាល
ព្រះបាទឥន្ទ្រវរ្ម័នទី១ រលួសបានក្លាយជាទីក្រុងមួយយ៉ាងល្អឯក ដែលមាន
ប្រជាជនរស់នៅតាមមាត់បឹងទន្លេសាប និងប្រកបរបរកសិកម្ម ដើម្បីចិញ្ចឹម
ជីវិត។ ព្រះអង្គបានជីកបារាយណ៍ឥន្ទ្រតដាក (សមុទ្រព្រះឥន្ទ) នៅខាង
ជើងរាជធានី ដែលមានប្រវែង៣៨០០ម៉ែត្រ និងទទឹង៨០០ម៉ែត្រ ដើម្បីបម្រើ
ឱ្យសាសនាផង និងជាប្រព័ន្ធស្រោចស្រពផង (អាចផ្ទុកទឹកបានជិត៨លាន
ម៉ែត្រគូប)។ នៅឆ្នាំ៨៧៩ ព្រះអង្គបានកសាងប្រាសាទព្រះគោ ដើម្បីឧទ្ទិស
ថ្វាយចំពោះព្រះមាតា ព្រះបិតា និងជីដូនជីតា។ នៅឆ្នាំ៨៨១ ទ្រង់បាន
កសាងប្រាសាទបាគង ដែលជាប្រាសាទរដ្ឋ (សម្រាប់តម្កល់ទេវលិង្គ) និង
ប្រាសាទភ្នំទីមួយ សាងពីថ្មកក់សម្រាប់តម្កល់ទេវលិង្គឥន្ទ្រេស្វរៈ។ ក្បាច់
រចនាលើផ្ដែរនៃប្រាសាទទាំងនេះបានឈានទៅដល់កម្រិតគុណភាពមួយ
ដែលមិនទាន់មានប្រាសាទណាល្អដូចឡើយ ដែលបង្កើតបានជារចនាបថ
ព្រះគោ។ ប្រាសាទដែលសាងសង់ដោយព្រះបាទឥន្ទ្រវរ្ម័នទី១ បង្កើតបាន
ជាស្តង់ដា ដែលមានសមាសធាតុទាំងអស់នៃប្រាសាទខ្មែរនៅសម័យអង្គរ ៖

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រាសាទអាបស្មើ និងប្រាសាទភ្នំ ដែលមានរបងព័ទ្ធជុំវិញដោយមានគោបុរៈ ឬខ្នោងទ្វារចូល បណ្ណាល័យ សាលាងងឹតទ្រវែង ដែលបន្ទាប់មកក្លាយជាកំពែងថែវ គូទឹកព័ទ្ធជុំវិញប្រាសាទ ផ្តែរ សសរពេជ្រ សសរទ្រ ហោជាងទេវតា ហើយថែមទាំងមានចម្ងាក់លិបធំៗទៀតផង។

ផ្តែរនៃប្រាសាទព្រះគោ គឺជាផ្តែរដ៏ល្អបំផុត និងមានលក្ខណៈពេញលេញបំផុតនៃសិល្បៈខ្មែរ។ ចាប់ពីរចនាបថព្រះគោនេះទៅ ផ្តែរទ្វារនៃរចនាបថក្រោយៗចាប់ផ្តើមបាត់បន្តិចម្តងៗនូវសមាសធាតុបង្កើតនៃផ្តែរទ្វារប្រាសាទខ្មែរ។ សមាសធាតុនៃផ្តែរមាន ៖ ក្បាច់ផ្តេក ក្បាច់កណ្តាល ក្បាច់តែមសងខាង ក្បាច់ពុះកាត់ជាបួនផ្នែក ក្បាច់ខាងលើក្បាច់ផ្តេក ក្បាច់ខាងក្រោមក្បាច់ផ្តេក ក្បាច់ទម្រក្បាច់តែម ក្បាច់តែមខាងក្រោម និងក្បាច់តែមខាងលើ។ លោក ហ្សីលប៊ែត ដឺ កូវ៉ាល់-ម៉ែមុយហ្សាត បានពិពណ៌នាយ៉ាងល្អិតល្អន់ពីផ្តែរនៃប្រាសាទបាគោថា ៖ «ក្បាច់ផ្តេកជាសំណុំស្លឹកឈើដែលពេលខ្លះត្រង់ ហើយពេលខ្លះពត់ពេនត្រូវបានបង្កើតឡើងជាំនួសផ្នូរ។ បន្ទាប់មកក្បាច់ផ្តេកជាមែកឈើ បែកចេញជាក្បាច់តែមសងខាង ជាក្បាលសត្វមករ ជាក្បាលនាគរាជ ជាស្លឹកឈើវេញត្របាញ់ ឬទៅតាមការស្រមើស្រមៃរបស់សិល្បករ។ នៅខាងក្រោមក្បាច់ផ្តេក គេឃើញមាននៅសល់តែក្បាច់ជាស្លឹកឈើវេញត្របាញ់ប៉ុណ្ណោះ ហើយសិល្បករខ្មែរលែងប្រើក្បាច់រំយោល និងបន្តោងរយ៉ាងទៀតហើយ»។ ចំពោះក្បាច់នៅកណ្តាលនៃផ្តែទ្វារចនាបថព្រះគោ បង្ហាញពីតួអង្គរាហូ គ្រុឌ ព្រឥន្ទជិះដំរីក្បាលបី ទេវរូប ឬផ្កាឈូក។ រាហូ គឺជាតំណាងភាពអមតៈនៃសង្គមខ្មែរ ដែលខ្ជាក់ធម្មជាតិពីប្រអប់មាត់។ សសរពេជ្រនៃរចនាបថព្រះគោ នៅតែមានរាងមូលដដែលហើយហោជាងមានរាងជា ប ផ្កាប់ចុះ។

(៤) បន្ទាប់ពីព្រះបាទឥន្ទ្រវរ្ម័នទី១ចូលទិវង្គត ជម្លោះដណ្តើមរាជ្យបានកើតឡើង ប្រហែលជារវាងបុត្រទាំងពីររបស់ព្រះអង្គ។ ព្រះបាទយសោវរ្ម័នទី១ (៨៨៩-៩០០) ជាអ្នកឈ្នះ ហើយឡើងសោយរាជ្យ ដែល

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មានព្រាហ្មណ៍វាមសិវៈជាបុរោហិត។ ព្រះអង្គបានសាងសង់អាស្រមជាច្រើន ដើម្បីឧទ្ទិសដល់និកាយផ្សេងៗនៃព្រហ្មញ្ញសាសនា ជាពិសេសព្រះសិវៈ និងព្រះវិស្ណុ។ តាមរយៈអាស្រមទាំងនេះ គេអាចដឹងបានថា ផ្ទៃដីនៃអាណាចក្រខ្មែរលាតសន្ធឹងពីតំបន់ខាងជើងភ្នំវ៉ែន នៅខ្ពង់រាបកូរ៉ាតដល់តំបន់វត្តភូ នៅចម្ប៉ាសាក់។ ព្រះអង្គបានសង់ប្រាសាទលលៃនៅចំកណ្តាលបាកាយណ៍ឥន្ទ្រតជាក ដើម្បីឧទ្ទិសជូនដល់ព្រះមាតាបិតារបស់ព្រះអង្គ។ បន្ទាប់មក ព្រះអង្គបានរើរាជធានីពីហរិហរាល័យមកដាក់នៅយសោធរបុរៈ (អង្គរទី១) ដែលក្លាយជារាជធានីនៃអាណាចក្រខ្មែរក្នុងរយៈពេលជាង៥០០ឆ្នាំ។ ព្រះអង្គបានជ្រើសរើសយកភ្នំមួយ ដើម្បីសាងសង់ប្រាសាទភ្នំបាខែង មានភាសាជីជាខឿនច្រើនថ្នាក់ ដែលស្ថិតនៅចំកណ្តាលរាជធានី សម្រាប់តម្កល់សិវលិង្គយសោធរេស្វរៈ (គ.ស.៨៩៣)។ ព្រះអង្គបានជីកបាកាយណ៍យសោធរតដាក មានប្រវែង៧,៥គម និងមានទទឹង១,៨គម។

ព្រះអង្គបានកសាងប្រាសាទពីរ ដើម្បីឧទ្ទិសចំពោះព្រះឥសូរ គឺបន្តសាងសង់ប្រាសាទសិខរិស្វរៈ ដែលជាប្រាសាទព្រះវិហារ និងប្រាសាទកេទ្រស្វរៈ នៅសិវបុរៈ (ភ្នំសណ្តាក)។ ចំណែកនៅឯភ្នំបូក និងភ្នំក្រោម ព្រះអង្គបានសាងប្រាសាទមានប្រាង្គ៣ សម្រាប់ឧទ្ទិសចំពោះត្រីមូរ្តិ (ព្រះព្រហ្ម-ព្រះវិស្ណុ-ព្រះឥសូរ)។ សិលាចារឹកកាសាសំស្ក្រឹត K382 ដែលប្រកាសខ្លះហៅថាសិលាចារឹកសិវសត្តិ បានលើកឡើងពីបញ្ជារបស់ព្រះសិវៈ ដើម្បីតម្កល់ទេវរូបនៅយសោធរគិរី (ភ្នំបាខែង)។ រចនាបថបាខែងបន្តនូវប្រពៃណីនៃរចនាបថព្រះគោ ប៉ុន្តែបានបោះបង់ចោលឥដ្ឋ ដោយយកថ្មកក់ និងថ្មបាយក្រៀមទៅសាងប្រាសាទវិញ។ រចនាបថនេះបានប្រឌិតសម្លៀកបំពាក់ចាប់ក្លីជាលើកដំបូង។ ចំពោះផ្នែរវិញ រចនាបថបាខែងមិនសូវស្អាតដូចផ្នែរនៃរចនាបថព្រះគោឡើយ។ ប្រាសាទនៃរចនាបថបាខែងមាន ៖ ប្រាសាទភ្នំបាខែង ប្រាសាទភ្នំក្រោម និងប្រាសាទភ្នំបូក។ ទឹកដីខ្មែរនៅពេលនោះ ខាងលិចទល់នឹងដែនសូត្រកម្រាតាស (ភូមា) ខាងត្បូងទល់នឹងសមុទ្រ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ខាងកើតទល់នឹងចម្ប៉ា ខាងជើងទល់នឹងប្រទេសចិន។

(៥) ក្រោយពីព្រះបាទយសោវរ្ម័នទី១ចូលទិវង្គតមក ព្រះបាទហស៌វរ្ម័នទី១ ដែលជាបុត្របានឡើងសោយរាជ្យ (៩០០-៩៦២?) នៅរាជធានីនៅយសោធរបុរៈ។ នៅក្នុងរជ្ជកាលរបស់ព្រះបាទហស៌វរ្ម័នទី១ ព្រះអង្គបានសាងសង់ប្រាសាទពីរ គឺប្រាសាទបក្សីចាំក្រួងនៅជិតប្រាសាទភ្នំបាខែង និងប្រាសាទក្រវ៉ាន់ ដែលមានបីជាន់ ដើម្បីឧទ្ទិសដល់ព្រះវិស្ណុ។ ព្រះបាទហស៌វរ្ម័នទី១មានព្រះអនុជមួយអង្គទៀត ព្រះនាម ឥសានវរ្ម័នទី២។

(៦) ព្រះបាទឥសានវរ្ម័នទី២ (៩២៥-?) បានឡើងសោយរាជ្យបន្តពីព្រះអនុជប្រហែលជានៅឆ្នាំ៩២៥ ដែលមានព្រាហ្មណ៍កុមារស្វាមិនជាបុរោហិត និងមានរាជធានីនៅយសោធរបុរៈ។

(៧) ព្រះបាទជ័យវរ្ម័នទី៤ (គ.ស ៩២៨-៩៤១) បានជ្រែករាជ្យពីក្មួយព្រះអង្គព្រះនាម ឥសានវរ្ម័នទី២ ហើយឡើងសោយរាជ្យនៅឆ្នាំ៩២៨។ ព្រះអង្គបានលើករាជធានីពីយសោធរបុរៈទៅកាន់ឆោកគគីរ (កោះកេរ) វិញ។ ក្នុងគោលបំណងពង្រីករាជានុភាព និងមហិទ្ធិឫទ្ធិ ព្រះអង្គបានកសាងទីក្រុងថ្មីកោះកេរនេះ និងបានកសាងប្រាសាទជាច្រើន ដូចជាប្រាសាទធំ ដែលជាប្រាសាទភ្នំដែលមានខឿន៧ជាន់ សម្រាប់តម្កល់រាជលិង្គត្រកូវនេស្វរ។ ឫង្គប្រាសាទនៃរចនាបថកោះកេរ គឺអនុវត្តយកខ្សែបន្ទាត់មេជ្រាទីរជាមេនៅលើវាលរាបៗ ប្រាសាទកោះកេរមានរូបបដិមាធំៗ ដែលជាតួអង្គនៃរឿងមហាភារតៈ និងរឿងរាមកេរ្តិ៍ ហើយចាប់ផ្តើមបង្ហាញរូបមានចលនាដូចជា រូបព្រះសិវៈកាំ រូបគ្រុឌជើរ រូបចំបាប់រវាងសុគ្រីព និងពាលី រូបចំបាប់រវាងយក្ខ និងទេវតា។ ផ្នែរទ្វារនៃរចនាបថកោះកេរលុបចោលក្បាច់ត្របកឈូក ហើយជាក់រូបទេពប្រណម្យជំនួសវិញ ដែលជានិមិត្តរូបនៃការស្វាគមន៍ចំពោះព្រះបាទជ័យវរ្ម័នទី៤ និងការកាត់ផ្តាច់ទំនាក់ទំនងជាមួយ យសោធរបុរៈ។ សសរពេជ្រនៃរចនាបថកោះកេរនៅមានធ្នាក់ក្បាច់ចិញ្ចៀន និងស្លឹកឈើជាច្រើន។ ហោជាង់មានរាង់ជាអក្សរ ប ផ្កាប់ចុះ តែមានច្រើនជាន់។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រាសាទនៃរចនាបថកោះកេរមានដូចតទៅ ៖ ប្រាសាទធំ ប្រាង្គប្រាសាទ នាងខ្មៅ ប្រាសាទដំរី ប្រាសាទក្រហម ប្រាសាទចិន ប្រាសាទបួក និង ប្រាសាទប្រាំ។

(៨) ក្រោយពីព្រះបាទជ័យវរ្ម័នទី៦បានចូលទិវង្គតនៅឆ្នាំ៨៦១ រិបត្តិ ស្នងរាជ្យបានកើតឡើង ហើយព្រះបាទឥន្ទ្រវរ្ម័ន ដែលជាបុត្ររបស់ប្អូន ស្រីព្រះបាទយសោវរ្ម័នទី១ ព្រះនាមមហេន្ទ្រទេវី និងព្រះអង្គមហេន្ទ្រវរ្ម័ន បានឡើងសោយរាជ្យ ដោយមានការគាំទ្រពីសំណាក់ព្រាហ្មណ៍ដែលរស់នៅ យសោធរបុរៈ។ ដូច្នេះ ព្រះបាទឥន្ទ្រវរ្ម័នបានលើករាជធានីពីកោះកេរមក យសោធរបុរៈវិញ ហើយបង្កើតជា«អង្គរទី២»ដែលមានព្រាហ្មណ៍សិវាចារ្យ ជាហោតរ កវិន្ទ្រារមថន ជាស្ថាបត្យករ និងព្រាហ្មណ៍យជ្ញវរាហៈជាព្រះ រាជគ្រូ។ ព្រះអង្គបានកសាងប្រាសាទមេបុណ្យខាងកើត និងប្រាសាទប្រែ រូប ដែលជាប្រាសាទសំខាន់នៃរចនាបថប្រែរូប។ មជ្ឈមណ្ឌលនយោបាយ ស្ថិតនៅត្រង់ប្រាសាទប្រែរូប ដែលជាប្រាសាទរដ្ឋសម្រាប់តម្កល់សិវលិង្គ។ ព្រះបាទឥន្ទ្រវរ្ម័នក៏ជាអ្នកកសាងប្រាសាទពុទ្ធសាសនាមួយដែរ គឺប្រាសាទ បាទជុំ។

រចនាបថប្រែរូបធ្លុះបញ្ចាំងការត្រលប់ទៅរកអតីតកាល ក្នុងវិស័យ ស្ថាបត្យកម្ម និងក្បួរក្បាច់រចនាប្រាសាទ។ ការលិត្រលប់ទៅរកអតីតកាល គឺការចម្លងតាមផ្នែរនៃប្រាសាទក្រុមរលួស ដូចជាប្រាសាទព្រះគោ ប្រាសាទ បាគង និងប្រាសាទលលៃ។ ជាពិសេស គឺប្រាង្គប្រាសាទមេបុណ្យខាងកើត និងប្រាសាទប្រែរូបត្រូវបានសាងសង់ដោយប្រើឥដ្ឋ ហើយក្បាច់រចនាមាន ស្រោបបាយអ និងក្នុងទ្រង់ទ្រាយជាប្រាសាទភ្នំ ដែលមានខឿនសាងអំពី ថ្មដែលទ្រប្រាសាទធំៗចំនួនប្រាំ ដែលធ្វើពីឥដ្ឋ។ ប្រាសាទប្រែរូប គឺជា ស្នាដៃដ៏ធំធេង និងមានសមាមាត្រល្អបំផុត សាងសង់ពីថ្មបាយក្រៀម និង ឥដ្ឋ។ រចនាបថនេះធ្លុះបញ្ចាំងពីការសាងសង់ប្រាសាទភ្នំដោយគ្មានថែវ តែ មានបន្ទប់វែងព័ទ្ធជុំវិញសាជីស្ទើរតែជាប់នឹងរបងទី១របស់ប្រាសាទ។ ផ្នែរ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទ្វារនៃប្រាសាទមេបុណ្យខាងកើតបង្ហាញពីព្រះឥន្ទ្រជិះលើដំរីក្បាលបី ដែលជាម្ចាស់លើសត្វលោក ទឹក និងធម្មជាតិ។ ទន្ទឹមនឹងនេះ ស្ថាបត្យករ លម្ហផ្តែរដោយសត្វមករ សត្វនាគ តំណាងឱ្យទឹក និងរាហូដំណាងឱ្យ ព្រលឹងអមតៈ។

ប្រាសាទបន្ទាយស្រី (ត្រកូវនមហេស្វរ) ដំល្បីល្បាញត្រូវបានកសាង ឡើងនៅក្នុងឆ្នាំ៩៦៧ ដោយព្រះរាជគ្រូរបស់ព្រះបាទរាជេន្ទ្រវរ្ម័នឈ្មោះ ព្រាហ្មណ៍យជ្ញវរាហៈនៅទិសខាងជើងនៃយសោធរបុរៈ។ ប្រាសាទនេះ សាងសង់ក្នុងរជ្ជកាលស្តេចពីរអង្គ ដោយសារនៅក្នុងឆ្នាំ៩៦៧ ព្រះបាទ រាជេន្ទ្រវរ្ម័ន សោយទិវង្គតទៅ បុត្ររបស់ព្រះអង្គព្រះនាមជ័យវរ្ម័នទី៥បាន ឡើងសោយរាជ្យ។ ប្រាសាទបន្ទាយស្រី គឺជាប្រាសាទសង់ពីថ្មកក់ពណ៌ ផ្កាឈូក ប្រកបដោយចម្លាក់យ៉ាងល្អពាសពេញតួប្រាសាទ។ រចនាបថ បន្ទាយស្រី គឺជារចនាបថឯក ដែលល្អយ៉ាងវិសេសវិសាល ដែលទុះបញ្ចាំង ពីសម្រស់ដ៏ឧត្តុង្គឧត្តម និងសុក្រឹតភាពនៃក្បួរក្បាច់រចនា និងស្ថាបត្យកម្ម នៃប្រាសាទនេះ។ ផ្តែរនៃប្រាសាទបន្ទាយស្រីបង្ហាញពីការបន្តរចនាបថនៃ ប្រាសាទប្រែរូប និងមេបុណ្យខាងកើត និងការចម្លងតាមផ្តែរនៃប្រាសាទ លលៃ ប្រាសាទព្រះគោ និងប្រាសាទបាគង។ ផ្តែរនៃប្រាសាទបន្ទាយស្រី មានក្បាច់ផ្តេក ដែលកាត់ផ្តែរជាបួនកង ដែលមានលក្ខណៈដូចរចនាបថ សំបូរព្រៃគុក និងរចនាបថព្រៃក្មេង។

ចំពោះសសរពេជ្រវិញ យើងឃើញមានប្រើឡើងវិញនូវសសរពេជ្រ មូលជាលើកចុងក្រោយនៃប្រាសាទបុរាណខ្មែរ ដោយប្រើប្រាស់លាយឡំ ជាមួយនឹងសសរពេជ្រវាងអដ្ឋកោណ។ ចំណែកឯក្បួរក្បាច់កម្រងផ្កា និង ភីផ្កាវិញត្រូវបានប្រើប្រាស់ទាំងនៅផ្នែកខាងលើ និងផ្នែកខាងក្រោមនៃសសរ ពេជ្រ។ ហោជាង គឺជាសមាសធាតុដ៏សំខាន់បំផុតនៃរចនាបថបន្ទាយស្រី។ ដូចហោជាងនៃរចនាបថកោះកេរ ហោជាងនៃប្រាសាទបន្ទាយស្រីមានបី ប្រភេទ ៖ (១) មានរាងជាអក្សរ ប ផ្កាប់ចុះ មានបីជាន់ និងមានរាងធ្មេញ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

រណា (២) ហោជាងខ្មែរមានច្រើនជាន់ និង (៣) ហោជាងត្រីកោណ។ ចំណែកឯក្បួរក្បាច់រចនាលើផ្ទៃហោជាងវិញ មានលម្អដោយស្លឹកឈើព័ទ្ធជុំវិញទេវរូប ឬរឿងដែលដកស្រង់ពីទេវកថាឥណ្ឌា។ គែមខាងក្រៅនៃហោជាង ពត់ពេនចេញជាក្បាលនាគពាជយ៉ាងវិសេសវិសាល។ ចំណែកឯសសរជ្រាសាទបន្ទាយស្រីមានលម្អដោយក្បួរក្បាច់រចនា និងការកែច្នៃរូបរាហូ មករូបសិង្ហ និងនាគពាជ ហើយជាពិសេសគឺ ផ្កាឈូក។

(៩) ព្រះបាទជ័យវរ្ម័នទី៥ (៩៦៨-១០០០) បានឡើងសោយរាជ្យក្រោយពីព្រះបិតាព្រះអង្គព្រះបាទរាជេន្ទ្រវរ្ម័នចូលទិវង្គតនៅឆ្នាំ៩៦៨។ ព្រះបាទជ័យវរ្ម័នទី៥ជាស្តេចដែលគោរពបូជាព្រហ្មញ្ញសាសនា (ព្រះសិវៈ និងវិស្ណុ) ផង និងព្រះពុទ្ធសាសនាមហាយានផង ដូចព្រះបិតាព្រះអង្គ។ ព្រះអង្គបានសាងសង់ជ្រាសាទតាកែវ សម្រាប់តម្កល់ព្រះសិវលិង្គ។ ព្រះបាទជ័យវរ្ម័នទី៥មានព្រាហ្មណ៍អាត្មសិវៈជាបុរោហិត និងមានរាជធានីនៅយសោធរបុរៈ។

ស្ថាបត្យកម្មនៃរចនាបថឃ្លាំងត្រូវបានចាប់ផ្តើមសាងសង់នៅចុងសតវត្សទី១០ និងដើមសតវត្សទី១១ តាមរយៈការសាងសង់ជ្រាសាទតាកែវ ជ្រាសាទវិមានអាកាស ជ្រាសាទឃ្លាំង និងជ្រាសាទព្រះវិហារ។ ស្ថាបត្យកម្មនៃរចនាបថឃ្លាំងមានការរីកចម្រើន ក្នុងការសាងសង់ជ្រាសាទភ្នំ ដែលមានលក្ខណៈពេញលេញ ដោយដកស្រង់នូវបទពិសោធក្នុងការសាងសង់សាលវែងនៅក្នុងរចនាបថ ដើម្បីច្នៃឱ្យក្លាយទៅជាកំពែងថែវមានដំបូលជាប្រក់ឥដ្ឋ ឬថ្មកក់ រត់ពីលើព្រលានខ្នើនព័ទ្ធជុំវិញជ្រាផ្តកណ្តាល។ នៅជ្រាសាទតាកែវ ស្ថាបត្យករបុរាណខ្មែរសង់ជាលើកដំបូង នូវថែវព័ទ្ធជុំវិញនៅលើខ្នើនរាងសាជី ដែលមានដំបូលប្រក់ឥដ្ឋ។ តែឥដ្ឋទាំងនេះបែកបាក់ខូចអស់ហើយ។ នៅជ្រាសាទវិមានអាកាស ស្ថាបត្យករបុរាណបានសង់ថែវព័ទ្ធជុំវិញ លើខ្នើនខ្ពស់ជាងគេនៃសាជី។ នេះជាជ្រាសាទខ្មែរទី១ ដែលមានថែវមានដំបូលប្រក់ថ្មកក់។ ជ្រាសាទតាកែវ និងជ្រាសាទព្រះវិហារ គឺជា

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្នាដៃកំពូលក្នុងចំណោមប្រាសាទបុរាណខ្មែរ។ ចំពោះផ្នែរទ្វារវិញ មិនមានការប្រែប្រួលផ្នែកអ្វីឡើយ។ នៅចំកណ្តាលផ្នែរ គេឃើញមានរាហូខ្លាក់ស្វឹកឈើ ដែលធ្លាប់បានជួបប្រទះ នៅលើប្រាសាទបន្ទាយស្រីរួចមកហើយ។ ផ្នែរនៃរចនាបថឃ្លាំងផ្តោតការយកចិត្តទុកដាក់លើមនុស្ស ជាពិសេសលម្អស្ត្រី ជីវិតក្នុងគ្រួសារ និងធម្មជាតិ ដូចជាចម្ងាក់សត្វស្រុក ស្វឹកឈើ ទង់ឈើ និងសត្វស្វាប។ រូបបដិមាទទួលឥទ្ធិពលពីរចនាបថប្រែរូប និងបន្ទាយស្រីមានដងខ្លួនស្រឡូន និងទឹកមុខស្នូតបូត ហើយមានសំពត់មានហោប៉ៅពីរនៅលើភ្លៅទាំងពីរ។ ហោជាងនៃរចនាបថឃ្លាំង ដូចហោជាងនៃប្រាសាទព្រះវិហារដែរ មានរាងត្រីកោណ ដែលជាហោជាងដែលឃើញមានចុងក្រោយគេបង្អស់នៃរចនាបថខ្មែរ។

(១០)ក្រោយពីព្រះបាទជ័យវរ្ម័នទី៥សោយទិវង្គតនៅឆ្នាំ១០០០ ក្មួយរបស់ព្រះអង្គ គឺព្រះបាទឧទយាទិត្យវរ្ម័នទី១ (១០០១-១០០៦) ដែលមានព្រាហ្មណ៍សទាសិវៈជាបុរោហិត បានឡើងសោយរាជ្យនៅឆ្នាំ១០០១ នៅយសោធរបុរៈ។ ព្រះអង្គសោយរាជ្យបានតែមួយឆ្នាំប៉ុណ្ណោះ ដោយសារមានកលិយុគ និងសង្គ្រាមដណ្តើមរាជ្យបានកើតមានឡើងរវាងព្រះបាទឧទយាទិត្យវរ្ម័នទី១ និងព្រះអង្គម្ចាស់ពីរព្រះអង្គ គឺ ជ័យវីរវរ្ម័ន និងសូរ្យវរ្ម័ន។ ព្រះបាទជ័យវីរវរ្ម័នត្រួតត្រានៅតំបន់អង្គរ ហើយព្រះបាទសូរ្យវរ្ម័ន គ្រប់គ្រងរាជ្យនៅខេត្តខាងកើត។ ព្រះបាទសូរ្យវរ្ម័នបានទទួលជោគជ័យក្នុងការបង្ក្រាបគូបដិបក្ខ និងគ្រប់គ្រងទូទាំងអាណាចក្ររួចមកព្រះអង្គបានឡើងសោយរាជ្យ។

(១១)ព្រះបាទសូរ្យវរ្ម័នទី១ (១០១១-១០៦៩) បានទទួលរាជាភិសេកជាចក្រវាទីន និងមានរាជធានីនៅអង្គរនៅឆ្នាំ១០១១។ សិលាចារឹកបានបង្ហាញថា ព្រះអង្គមានព្រះគោរម្យងារច្រើនខុសៗគ្នា ប្រហែលជាគោរម្យងារទាំងនេះចារឹកឡើងមុនពេលព្រះអង្គឈ្នះសង្គ្រាម និងមុនពេលព្រះអង្គឡើងគ្រងរាជ្យជាស្តេចកំពូល គឺមិនមែនកំណត់ហេតុពីព្រះអង្គ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្ទាល់ទេ។ សិលាចារឹក K153 នៅក្នុងឆ្នាំ១០០១ ព្រះអង្គមានគោរម្យងារជា ព្រះករុណាជ្រាសាទ ត ធូលី ព្រះបាទកម្រតេង អញ ស្រី សូរ្យបរមទេព។ សិលាចារឹក K125 នៅជិតក្រចេះបញ្ជាក់ថាព្រះអង្គមានគោរម្យងារជា ធូលី ជ្រះបាទធូលី ជើង ជ្រះ កម្រតេង អញ ត បរមវិត្រ តែនៅឃ្លាមួយទៀត សិលាចារឹកនេះហៅព្រះអង្គថា កម្រតេង កំតួន អញ។ សិលាចារឹក K292 បញ្ជាក់ថា ព្រះអង្គមានព្រះគោរម្យងារជា ជ្រះបាទ កម្រតេង អញ កំតួន អញ ស្រី សូរ្យវម៌ាទេវត សកលស្វេយ ជ្រះ ធម៌រាជ្យ។

សិលាចារឹកស្តុកកក់ធំបានបញ្ជាក់ថា នៅក្នុងឆ្នាំ១០០២ ព្រះបាទសូរ្យវរ្ម័នទី១ ដែលមានទីតាំងនៅភូមិភាគពាយព្យនៃប្រទេសកម្ពុជា ប្រហែលជានៅម្តុំដងទន្លេមេណាំផ្នែកកណ្តាល បានចាប់ផ្តើមប្រតិបត្តិការសឹកប្រឆាំងនឹងគូបដិបក្ខរបស់ព្រះអង្គ។ នៅឆ្នាំ១០០៤ ព្រះអង្គបានកាន់កាប់នូវទឹកដីផ្នែកខាងជើងនៃភ្នំដងរែក។ នៅពេលនោះ ព្រះបាទជ័យវរ្ម័ននៅសោយរាជ្យនៅអង្គរនៅឡើយ។ បន្ទាប់ពីបានពង្រឹងមូលដ្ឋាននៅទីនោះហើយ នៅចន្លោះឆ្នាំ១០០៥ និង១០០៧ ព្រះបាទសូរ្យវរ្ម័នទី១បានលើកទ័ពវាយចូលអង្គរ ហើយបានទទួលជោគជ័យជាស្ថាពរនៅឆ្នាំ១០១០។ បន្ទាប់មកព្រះអង្គខិតខំពង្រឹងសណ្តាប់ធ្នាប់សង្គម និងស្តារព្រះរាជាណាចក្រ ពង្រឹងក្បាលម៉ាស៊ីនរដ្ឋបាល និងកសាងប្រាសាទឡើងវិញ ដើម្បីឱ្យប្រជាពលរដ្ឋអាចរស់នៅក្នុងសុខសន្តិភាព។ ព្រះបាទសូរ្យវរ្ម័នទី១បានសោយរាជ្យរហូតដល់ឆ្នាំ១០៤៩។ ព្រះអង្គគឺជាយុទ្ធវិទូ និងជាមេដឹកនាំសឹកដ៏ចំណានមួយអង្គ ដែលបានពង្រីកទឹកដីនៃអាណាចក្រអង្គរ ដល់ត្រើយខាងស្តាំនៃទន្លេមេណាម និងបន្ទាប់មកដល់ម៉ាឡេស៊ីភាគកណ្តាល។

នៅពេលដែលស្រុកកើតសង្គ្រាមក្នុងស្រុក មន្ត្រីជាន់ខ្ពស់ខ្លះបានគាំទ្រដល់ពួកបះបោរ ដើម្បីចាក់ឱ្យក្នុងគោលដៅរក្សាទ្រព្យសម្បត្តិរបស់ពួកគេ។ បន្ទាប់ពីឡើងសោយរាជ្យនៅឆ្នាំ១០១១ ព្រះបាទសូរ្យវរ្ម័នទី១បានកោះនាហ្មឺនសព្វមុខមន្ត្រីទាំងអស់ឱ្យចូលស្បថចំពោះព្រះភក្ត្រព្រះអង្គ ដើម្បី

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឱ្យពួកគេសម្តែងនូវភាពស្មោះត្រង់ចំពោះព្រះអង្គ។ នៅលើសិលាចារឹកនៃគោបុរៈនៃព្រះបរមរាជវាំង ព្រះអង្គបានចារឹកនូវសម្បថ ដែលមន្ត្រីគ្រប់ជាន់ថ្នាក់ត្រូវធ្វើសច្ចាប្រណិធាន ដើម្បីបញ្ជាក់ពីភាពស្មោះត្រង់របស់ពួកគេចំពោះព្រះអង្គ។

នៅក្នុងរាជ្យរបស់ព្រះបាទសូរ្យវរ្ម័នទី១ ព្រាហ្មណ៍សទាសិវត្រូវបានតែងតាំងជាជយេន្ទ្របណ្ឌិត និងបានរៀបអភិសេកជាមួយប្អូនស្រីរបស់ព្រះមហាក្សត្រីយ៍វិរលក្ស្មី ដែលជាប្អូនថ្លៃរបស់ព្រះអង្គ។ បន្ទាប់មក សទាសិវត្រូវបានព្រះបាទឧទយាទិត្យវរ្ម័នទី៦តែងតាំងជារាជគ្រូ និងមានឋានៈជាធូលីជើង។

អាទិភាពរបស់ព្រះបាទសូរ្យវរ្ម័នទី១ គឺការផ្សះផ្សាជាតិ និងការពង្រឹងសន្តិភាពនៅក្នុងអាណាចក្រខ្មែរ បន្ទាប់ពីសង្គ្រាមក្នុងស្រុកអស់រយៈពេល៩ឆ្នាំមក។ ដើម្បីពង្រឹងអំណាចរបស់ព្រះរាជានៅតាមខេត្ត ព្រះអង្គបានផ្តោតជាសំខាន់លើការសាងសង់ប្រាសាទបុរាណនៅក្រៅអង្គរផងដែរ។ ដូច្នេះហើយ ទើបព្រះអង្គបានបញ្ជាឱ្យព្រាហ្មណ៍និងមន្ត្រីជាន់ខ្ពស់សាងប្រាសាទភ្នំជីសូរ ប្រាសាទព្រះវិហារ និងប្រាសាទព្រះខ័នកំពង់ស្វាយ។ សិលាចារឹក K381 ដែលឆ្លាក់លើសសរក្លោងទ្វារខាងត្បូងនៃថែវខាងត្បូងដែលស្ថិតនៅខាងកើតគោបុរៈទី៣នៃប្រាសាទព្រះវិហារ បានបញ្ជាក់ពីការឡើងសោយរាជ្យរបស់ព្រះបាទសូរ្យវរ្ម័នទី១។ សិលាចារឹក K380 ដែលឆ្លាក់លើសសរក្លោងទ្វារខាងត្បូងនៃគោបុរៈទី៦ បានបញ្ជាក់ថា នៅក្នុងរជ្ជកាលរបស់ព្រះបាទសូរ្យវរ្ម័នទី១ មានការគោរពយ៉ាងខ្លាំងក្លាចំពោះលទ្ធិសិវៈនិយមនៅលើកំពូលភ្នំព្រះវិហារ។ ព្រះអង្គបានបញ្ជាឱ្យតម្កល់ព្រះសិវលិង្គឈ្មោះសូរ្យវរមេស្វរ ដំបូងនៅជ័យក្សេត្រ (បាសិត) ហើយបន្ទាប់មកនៅក្នុងឆ្នាំ១០១៨ ព្រះអង្គបានបញ្ជាឱ្យយកព្រះសិវលិង្គឈ្មោះ សូរ្យវរមេស្វរនេះទៅតម្កល់នៅទីសក្ការៈបីទៀត គឺនៅសិខរិស្វរ (ព្រះវិហារ) ឥសានន្តធំត និងសូរ្យខ្មៅ (ភ្នំជីសូរ)។ សិវលិង្គសូរ្យវរមេស្វរនេះត្រូវបានគេតម្កល់នៅក្នុង

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

គោបុរៈទី៦នៃប្រាសាទព្រះវិហារ។ សិលាចារឹកនេះបានរំឭក ថាទេវរូប កន្ទ្រស្វរ ត្រូវបានយកមកពី លិង្គបុរី (វត្តភូ) ដើម្បីតម្កល់នៅក្នុងព្រះវិហារ។

ប្រាសាទព្រះវិហារត្រូវបានសាងសង់ឡើង ដោយមហាក្សត្រជាច្រើនអង្គ។ ដូច្នេះហើយទើបយើងឃើញថា ប្រាសាទព្រះវិហារសាងសង់ឡើងតាមរចនាបថខុសៗគ្នា ដែលឆ្លុះបញ្ចាំងពីដំណាក់កាលសាងសង់ផ្សេងៗគ្នា។ ជារួម ប្រាសាទព្រះវិហារត្រូវបានសាងសង់ឡើងជាបីដំណាក់កាល ៖ (១) ជំនាន់ព្រះអង្គម្ចាស់ ឥន្ទ្រាយុទ្ធ និងព្រះបាទយសោវរ្ម័នទី១ (២) ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ នៅពេលដែលប្រាសាទត្រូវបានស្ថាបនាឡើងជាថ្ម និង (៣) ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២។ ដូច្នេះ គឺនៅក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ហើយដែលមានការសាងសង់នូវប្រាសាទជាច្រើនធ្វើពីថ្មកក់ នៅតាមគោបុរៈផ្សេងៗនៃប្រាសាទព្រះវិហារ។ ប្រាង្គកណ្តាល គឺជានិវេសនដ្ឋាននៃអាទិទេព ដែលតំណាងដោយសិវលិង្គ។

សិលាចារឹក K381 បានបញ្ជាក់ថា ព្រះបាទសូរ្យវរ្ម័នទី១បានប្រទានដល់ឥសីឈ្មោះវិទ្យាបណ្ឌិតនូវកូសំមាសមួយ និងវិរស្រម (រាជវាំង) ដើម្បីតបស្នងសងគុណក្នុងការថែរក្សាលិង្គសិខរិស្វរ។ ដូច្នេះហើយ ទើបឥសីនេះបានដាក់ឈ្មោះអាស្រមនេះថាជាតាបសវិទ្យាបណ្ឌិតអាស្រម។ សិលាចារឹកនេះបញ្ជាក់ថា តាបសវិទ្យាបណ្ឌិតអាស្រមមានសិទ្ធិផ្តាច់មុខលើខ្ទុំបម្រើ និងរបស់របរសព្វសារពើនៅក្នុងប្រាសាទព្រះវិហារ។ សិលាចារឹក K381 បានពិពណ៌នាថា នៅក្នុងឆ្នាំ១០៦៦ តាបសវិទ្យាបណ្ឌិតអាស្រមបានធ្វើអំណោយដល់ស្រី សិខរិស្វរ នៅពេលបុណ្យចូលឆ្នាំនូវគ្រឿងអលង្ការ វត្ថុសម្រាប់រៀបចំពិធីផ្សេងៗ គោ ក្របី ដំរី ភូមិ ដីធ្លី និងខ្ទុំបម្រើជាដើម។

ប្រាសាទព្រះវិហារត្រូវបានពង្រីកជាបន្តបន្ទាប់។ សិលាចារឹក K380 បានបញ្ជាក់ថា នៅក្នុងឆ្នាំ១០៣៧ ព្រះបាទសូរ្យវរ្ម័នទី១បានផ្តល់អំណោយដល់ព្រាហ្មណ៍សុកាម៉ា ដែលមានដើមកំណើតនៅគុរុក្សេត្រ ដើម្បីតបស្នងសងគុណចំពោះការគ្រប់គ្រងប្រាសាទព្រះវិហារ។ ព្រាហ្មណ៍សុកាម៉ាជា

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

អ្នកកត់ត្រាប្រវត្តិប្រាសាទព្រះវិហារ និងអ្នកកាន់បណ្ណសារជាតិ។ ព្រាហ្មណ៍សុកាម៉ាបានពង្រីកប្រាសាទព្រះវិហារឱ្យកាន់តែធំជាងមុន។ អត្ថបទជាភាសាខ្មែរបានលើកឡើងថា មន្ត្រីជាន់ខ្ពស់បានទទួលពាក្យសម្បថស្វាមីភក្តិចំពោះព្រះបាទសូរ្យវរ្ម័នទី១នៅក្នុងប្រាសាទព្រះវិហារ ជាពិសេសស្វាមីភក្តិចំពោះព្រះអាទិទេព កម្រេស្វរនៃលិង្គបុរី ដែលបានមកចាប់ជាតិជាថ្មីជាសិខរិស្វរ។ ពាក្យសម្បថរួមមាន កាតព្វកិច្ចក្នុងការថែរក្សា ជួសជុល និងការពារប្រាសាទព្រះវិហារ ដើម្បីទប់ទល់នឹងខ្មាំងសត្រូវឈ្លានពាន និងពួកបះបោរ។

ព្រះបាទសូរ្យវរ្ម័នទី១មានបុត្រពីរអង្គ គឺព្រះបាទឧទយាទិត្យវរ្ម័នទី២ និង ព្រះបាទហស៌វរ្ម័នទី៣ជាបុត្រពៅ។

(១២) ក្រោយពីព្រះបាទសូរ្យវរ្ម័នទី១ចូលទិវង្គត ព្រះបាទឧទយាទិត្យវរ្ម័នទី២ (១០៦៩-១០៦៦) បានឡើងសោយរាជ្យបន្តឆ្នាំ១០៦៩។ ព្រះអង្គបានតែងតាំងព្រាហ្មណ៍សទាសិវ យេទ្រុបណ្ឌិតជាបុរោហិត។ ព្រះអង្គបានសាងប្រាសាទបាពួន ដែលស្ថិតនៅចំកណ្តាលក្រុងអង្គរ។

ស្តាបត្យកម្មខ្មែរចនាបថបាពួននៅពាក់កណ្តាល និងចុងសតវត្សទី១១ បានឈានដល់កម្រិតកំពូលនៃការសាងសង់ប្រាសាទភ្នំ ដែលខ្ពស់ចោត។ ប្រាសាទបាពួនមានថែវធ្វើពីថ្មកក់ព័ទ្ធជុំវិញប្រាង្គកណ្តាល មានកំផែង និងមានគោបុរៈជាច្រើន និងមានវិមាន ដែលសង់នៅតាមជ្រុង។ យើងសង្កេតឃើញថា មិនសូវមានការវិវត្តនៃក្បាច់រចនាប៉ុន្មានទេ។ ហោជាងនៃប្រាសាទបាពួនមានពីរជាន់។ ជាន់ខាងមុខលម្អដោយនាគរាជក្បាលប្រាំ ដែលទ្វាក់នៅតែមហោជាង ដែលមានកន្ទុយជាប់គ្នានៅត្រង់កំពូលជ្រុងលើនៃហោជាង។ នៅលើខ្លួននាគរាជមានលម្អដោយក្បាច់រុក្ខជាតិរាងស្រួចៗ។ នៅកណ្តាលហោជាងមានលម្អដោយក្បាចក្បីរុក្ខជាតិដ៏ស្រស់បំព្រង។ ហោជាងជាន់ទីពីរលម្អដោយនាគរាជដែរ ហើយនៅលើខ្លួននាគរាជមានលម្អដោយក្បាច់រុក្ខជាតិរាងស្រួចៗផងដែរ។ ប្រាសាទនៅក្នុងគោបុរៈទី៤ នៃប្រាសាទព្រះវិហារត្រូវបានសាងសង់ឡើង តាមរចនាបថ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បាពួននេះ។ នៅលើជញ្ជាំងប្រាសាទមានចម្ងាក់លីប លើផ្ទាំងថ្មតម្រួតលើគ្នា។

ក្នុងរាជ្យព្រះអង្គ ព្រះបាទឧទយាទិត្យវរ្ម័នទី២បានសាងប្រាសាទភីមៃ ដែលស្ថិតនៅខាងលើនៃទន្លេមន ក្នុងប្រទេសថៃ។

នៅឆ្នាំ១០៥២ ព្រះបាទឧទយាទិត្យវរ្ម័នទី២បានសាងប្រាសាទស្តុកកក់ធំ ដែលស្ថិតនៅស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ។ ប្រាសាទស្តុកកក់ធំនេះហើយ ដែលមានសិលាចារឹកជាភាសាខ្មែរបុរាណ និងភាសាសំស្ក្រឹតច្រើនជាងគេបង្អស់ ដែលរៀបរាប់ពីការសោយរាជ្យរបស់ព្រះមហាក្សត្រខ្មែរ ចាប់តាំងពីព្រះបាទជ័យវរ្ម័នទី៦រហូតមកដល់ជំនាន់ព្រះអង្គតែម្តង។

លើសពីនេះទៀតព្រះអង្គបានកសាងបារាយខាងលិច ឬបារាយទឹកថ្លា ដែលមានបណ្តោយប្រវែង៨គីឡូម៉ែត្រ និងទទឹង២,២គីឡូម៉ែត្រ អាចផ្ទុកទឹកបាន៦០លានគូប។ ដូច្នេះយើងឃើញថា នេះជាបារាយដែលធំជាងបារាយមុនៗទាំងអស់។ នៅកណ្តាលបារាយនោះ ព្រះអង្គក៏បានកសាងប្រាសាទ មេបុណ្យខាងលិច។ ក្នុងប្រាសាទនោះព្រះអង្គបានសាងរូបបដិមាព្រះវិស្ណុផ្ទុំមួយអង្គដែលធ្វើពីលង្ហិនតម្កល់នៅទីនោះ។ ចំណែកឯសិល្បៈស្ថិតរបស់ខ្មែរធ្វើពីសំរឹទ្ធបានឈានដល់កម្រិតកំពូលនៅចុងសតវត្សទី១១នេះ ដូចមានតឹកតាងរូបបដិមាព្រះវិស្ណុផ្ទុំមួយអង្គដែលធ្វើពីលង្ហិនតម្កល់នៅសារមន្ទីរជាតិស្រាប់។ ប្រាសាទនៃរចនាបថបាពួនមាន ៖ ប្រាសាទបាពួន ប្រាសាទមេបុណ្យខាងលិច និងប្រាសាទខ្នាសែនកែវ។

នៅក្នុងរជ្ជកាលនៃព្រះបាទឧទយាទិត្យវរ្ម័នទី២មានការបះបោរចំនួនបីលើក តែត្រូវបានបង្ក្រាបវិញ ដោយមេទ័ពរបស់ព្រះអង្គឈ្មោះសង្គ្រាម។ ព្រះបាទឧទយាទិត្យវរ្ម័នទី២សោយទិវង្គតនៅឆ្នាំ១០៦៦។

(១៣) ព្រះបាទហស៌វរ្ម័នទី៣ (គ.ស១០៦៦-១០៨០) ដែលជាព្រះអនុជរបស់ព្រះបាទឧទយាទិត្យវរ្ម័នទី២បានឡើងសោយរាជ្យនៅគ.ស.

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

១០៦៦ ក្រោយពីពេលដែលព្រះអង្គចូលទិវង្គត ហើយព្រាហ្មណ៍ទិវាករបណ្ឌិតបានបំពេញតួនាទីជាអាចារ្យប្រធាននៅប្រាសាទព្រះវិហារ។ រាជកិច្ចរបស់ព្រះអង្គផ្តោតលើការជួសជុលប្រាសាទ និងការរៀបចំប្រទេសឱ្យមានសណ្តាប់ធ្នាប់ និងវិបុលភាព។ នៅចុងរជ្ជកាលរបស់ព្រះអង្គ ចម្ប៉ាបានវាយចូលមកដល់ក្រុងសម្ពុបុរៈនៅរវាងឆ្នាំ១០៧៤ និង១០៨០ ហើយកេណ្ឌារាស្ត្រខ្មែរជាឈ្លើយសឹកទៀតផង។ នៅឆ្នាំ១០៨០ សង្គ្រាមដណ្តើមរាជ្យបានផ្ទុះឡើង ជាមួយអតិជនម្នាក់ដែលបានប្រកាសខ្លួនជាស្តេចផែនដីនៅក្រុងមហិធរបុរៈត្រង់តំបន់ទន្លេមូលដោយមានព្រះនាមថាព្រះបាទជ័យវរ្ម័នទី៦។

(១៤) ព្រះបាទជ័យវរ្ម័នទី៦ (គ.ស. ១០៨០-១១០៧) បានតែងតាំងព្រាហ្មណ៍ទិវាករបណ្ឌិតជាព្រះគ្រូ ដើម្បីអភិសេកព្រះអង្គ ហើយបានបម្រើព្រះអង្គក្នុងរយៈពេល៤០ឆ្នាំ។ ព្រះបាទជ័យវរ្ម័នទី៦បានផ្តល់គោរមងារដល់ព្រាហ្មណ៍ទិវាករបណ្ឌិតជាកតវតបាទកម្រតេង‌អញតគរុ ស្រី ទិវាករបណ្ឌិត។ ព្រាហ្មណ៍នេះមានតួនាទីជាអ្នកជួសជុល និងសាងសង់ប្រាសាទ និងចែកអំណោយដល់ប្រាសាទជាទីសក្ការៈនានា។ ព្រះបាទជ័យវរ្ម័នទី៦ បន្តកសាងប្រាសាទព្រះវិហារ និងប្រាសាទដទៃទៀត ដូចជាប្រាសាទភ្នំសណ្តាក វត្តភូ និងកម៉ែ (ខាងព្រះពុទ្ធសាសនា)។

(១៥) ព្រះបាទធរណីន្ទ្រវរ្ម័នទី១ឡើងសោយរាជ្យ ក្រោយពីព្រះរៀមប្អូនព្រះអង្គព្រះបាទជ័យវរ្ម័នទី៦បានសោយទិវង្គត។ ព្រះបាទធរណីន្ទ្រវរ្ម័នទី១បានបញ្ជាឱ្យព្រាហ្មណ៍ទិវាករបណ្ឌិតចែកអំណោយទៅតាមបណ្តាប្រាសាទនានា។

(១៦) ព្រះបាទសូរ្យវរ្ម័នទី៦ឡើងសោយរាជ្យដោយបង្ក្រាបបង្រួមអាណាចក្រពីរគឺ ៖ (១) អាណាចក្ររបស់ព្រះបាទធរណីន្ទ្រវរ្ម័នទី១ និង (២) អាណាចក្ររបស់ព្រះបាទឧបតីន្ទ្រវរ្ម័ន ដែលបានសោយរាជ្យនៅអង្គរតាំងតែពីគ.ស.១០៨០មកម្ល៉េះ។ ព្រះបាទសូរ្យវរ្ម័នទី៦ត្រូវបានរៀបចំអភិសេក ដោយព្រាហ្មណ៍ទិវាករបណ្ឌិតនៅឆ្នាំ១១១៣។ ស្តេចពីព្រះអង្គ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដែលមានកិត្តិនាមល្បីសុសសាយរន្ទឺនៅក្នុងរជ្ជកាលអង្គរ គឺ ៖ ព្រះបាទសូរ្យវរ្ម័នទី២ និង ព្រះបាទជ័យវរ្ម័នទី៧។ ព្រះបាទសូរ្យវរ្ម័នទី២បានបន្តការស្ថាបនាប្រាសាទព្រះវិហារ ប្រាសាទភ្នំជីសូរ ប្រាសាទភ្នំសណ្តាក និងប្រាសាទវត្តភូ។ ចំណែកសំណង់ថ្មី ព្រះអង្គបានកសាងប្រាសាទព្រះពិធូរ ប្រាសាទចៅសាយទេវតា ប្រាសាទធម្មានន្ទ ប្រាសាទបន្ទាយសំរែ និងប្រាសាទអង្គរវត្ត ដែលជាស្នាដៃស្ថាបត្យកម្មខ្មែរ សម្រាប់តម្កល់ព្រះវិស្ណុបដិមា ដែលមានព្រះបរមនាមថា បរមវិស្ណុលោក។ នេះជាលើកដំបូងហើយដែលសាសនាព្រាហ្មណ៍គណៈវិស្ណុត្រូវបានលើកតម្កើងជាសាសនារដ្ឋ ហើយបដិមាតំណាងព្រះរាជាលែងជាសិវលិង្គទៀតហើយ តែជាវិស្ណុបដិមាវិញ។

ព្រាហ្មណ៍ទិវាករបណ្ឌិតដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យសាសនានៅក្នុងសតវត្សទី១១ និងផ្នែកទី១នៃសតវត្សទី១២។ ព្រាហ្មណ៍ទិវាករបណ្ឌិតបានបម្រើព្រះមហាក្សត្រខ្មែរចំនួនប្រាំអង្គ គឺព្រះបាទឧទយាទិត្យវរ្ម័នទី២ ព្រះបាទហស៌វរ្ម័នទី៣ ព្រះបាទជ័យវរ្ម័នទី៦ ព្រះបាទធរណីន្ទ្រវរ្ម័នទី១ និងព្រះបាទសូរ្យវរ្ម័នទី៦។ សិលាចារឹកលេខ K383 ដែលចម្លងទាំងស្រុងពីសិលាចារឹកភ្នំសណ្តាក បញ្ជាក់ថា ទិវាករបណ្ឌិតបានដឹកនាំការធ្វើតម្រាងដ៏ច្រើននៅប្រាសាទព្រះវិហារ។ នៅគ.ស.១១១៩ ព្រះបាទសូរ្យវរ្ម័នទី២ បានត្រាស់បង្គាប់ឱ្យយកសិលាចារឹកនេះមកតម្កល់ទុកនៅប្រាសាទព្រះវិហារ។ ព្រាហ្មណ៍ទិវាករបណ្ឌិតបានជីកស្រះ និងជីកប្រឡាយទឹក ដោយចំណាយទ្រព្យធនរបស់លោកផ្ទាល់ និងបានធ្វើអំណោយជាវត្ថុមានតម្លៃទៅប្រាសាទព្រះវិហារ តាមព្រះរាជបញ្ជារបស់ព្រះបាទសូរ្យវរ្ម័នទី២។ សិលាចារឹកភ្នំសណ្តាក K194 បានរៀបរាប់ថា ៖ «នៅក្នុងគ.ស.១១១៩ ព្រះបាទសូរ្យវរ្ម័នទី២ បានបញ្ជាឱ្យគេកត់ត្រាលើសិលាចារឹកនេះនូវប្រវត្តិរូបរបស់ព្រាហ្មណ៍ទិវាករបណ្ឌិត ដែលមានគោរម្យងារជាកគវត្តិបត្តិ កម្រតេង អញ ជា គ្រូដែលព្រះបាទជ័យវរ្ម័នទី៦បានថ្វាយជូន នៅពេលព្រះអង្គឡើងសោយរាជ្យតែត្រូវបានប្តូរទៅជាគោរម្យងារមួយទៀតដែលខ្ពស់ជាង គឺ ធូលីជើង កម្រ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

តេង អញ។

នៅចុងស.វ.ទី១១ និងពាក់កណ្តាលទីមួយនៃស.វ.ទី១២ ស្ថាបត្យកម្មខ្មែរបានឈានដល់កម្រិតកំពូលហើយ។ យើងឃើញថា បន្ទាប់ពីមានការវិវត្តក្នុងរយៈពេល៥០០ឆ្នាំមក ទើបសិល្បៈ និងស្ថាបត្យកម្មខ្មែរ ជាពិសេសក្បូរក្បាច់រចនានៅលើប្រាសាទ បានឈានដល់កម្រិតកំពូលយ៉ាងសុក្រឹតមួយដ៏ល្អស្អាប់ស្ងែ។ ប្រាសាទទាំងអស់នៃរចនាបថអង្គរវត្តសុទ្ធសឹងតែសាងសង់ឡើង ដោយប្រើថ្មកក់ទាំងអស់ពីឆ្នាំ១១០០ដល់១១៧៥។ ប្រាសាទអង្គរវត្តត្រូវបានសាងសង់ដោយព្រះបាទសូរ្យវរ្ម័នទី២ នៅដើមសតវត្សទី១១ ដែលជានិមិត្តរូបនៃអារ្យធម៌ខ្មែរ ដែលឈានដល់កម្រិតកំពូល។

សសរពេជ្រនៃរចនាបថអង្គរវត្តបានវិវត្តទៅមុខ ដោយមានធ្នាក់ក្បាច់ចិញ្ចៀនរហូតដល់១០ ឬ១២។ ហោជាងនៃរចនាបថអង្គរវត្តរក្សាទូរវាងធ្ងន់ប៉ោងដូចរចនាបថមុនដែរ តែលើផ្នែកហោជាង ក្បាច់ក្បូរស្លឹកឈើត្រូវបានជំនួសដោយរឿងទេវកថា មហាភារតៈ និងរាមកេរ្តិ៍វិញ។ ម្យ៉ាងវិញទៀត នៅលើជញ្ជាំងប្រាសាទអង្គរវត្តបានទ្វាក់ចម្លាក់លីប (Bas-relief) លើផ្ទាំងថ្មយ៉ាងច្រើនសន្ធឹកសន្ធាប់ ជាពិសេសនៅលើជញ្ជាំងនៃថែវប្រាសាទដែលដកស្រង់ពីឈុតល្បីៗនៃទេវកថា មហាភារតៈ និងរាមកេរ្តិ៍ ដូចជាកូរសមុទ្រទឹកដោះជាដើម។

ចំណែកឯនៅទ្វីបអឺរ៉ុបវិញ នៅឆ្នាំ១០៦៦ ស្តេច វីលីយ៉ាំ (William) នៃន័រម៉ង់ឌី (Normandy) នៃបារាំងបានវាយយកបានប្រទេសអង់គ្លេស ហើយបានចែកដីឱ្យស្តេចត្រាញ់របស់ខ្លួន ដើម្បីកសាងប្រាសាទធំៗ (castles) ធ្វើពីថ្ម។ សាកលវិទ្យាល័យទី១នៅអឺរ៉ុប គឺសាកលវិទ្យាល័យបូឡូញ៉ា (Bologna) ត្រូវបានបង្កើតឡើងនៅអីតាលីនៅឆ្នាំ១០៨៨។ ៦៦ឆ្នាំក្រោយមក គឺនៅឆ្នាំ១១៥០ ទើបសាកលវិទ្យាល័យប៉ារីសត្រូវបានបង្កើតឡើង។ សាកលវិទ្យាល័យទាំងនេះត្រូវបានបង្កើតឡើងចេញពីសាលាវត្តកាតូលិក។

នៅឆ្នាំ១០៩៥ សម្តេចប៉ាប Urban II បានអំពាវនាវឱ្យស្តេចកាតូលិក

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅអឺរ៉ុបធ្វើដំណើរទៅទីក្រុងយេរូសាឡិម ដើម្បីរំដោះទីក្រុងនេះពីពួកអារ៉ាប់។ សាសនិកគ្រិស្តបានចាប់ផ្តើមធ្វើសង្គ្រាមសាសនា (Crusades) ប្រឆាំងសាសនិកអ៊ិស្លាមក្នុងរយៈពេល២០០ឆ្នាំ ដើម្បីរំដោះទីក្រុងយេរូសាឡិម ដែលជាទីក្រុងស័ក្តិសិទ្ធិ សម្រាប់សាសនាទាំងពីរ។

(១៧) ព្រះបាទជ័យវរ្ម័នទី៧ ៖ នៅគ.ស.១១៧៧ ចាមបានលើកទ័ពជើងទឹកវាយចូលអាណាចក្រខ្មែរចូលតាមដងទន្លេមេគង្គ ឡើងរហូតដល់បឹងទន្លេសាប និងវាយយករាជធានីអង្គរបាន។ ព្រះបាទជ័យវរ្ម័នទី៧ គឺជាព្រះរាជាដែលបានរំដោះអាណាចក្រខ្មែរទុកឱ្យមានឥស្សរភាពឡើងវិញ។ ព្រះអង្គទទួលរាជាភិសេក និងឡើងសោយរាជ្យនៅយសោធរបុរៈនៅគ.ស.១១៨១ នៅពេលដែលព្រះអង្គមានព្រះជន្មាយុ៥០ព្រះវស្សា។ បន្ទាប់ពីឡើងសោយរាជ្យ ព្រះអង្គបានចាត់ចែងឱ្យសាងសង់អង្គរទី៣ ដែលមានកំពែងថ្មបាយក្រៀម និងគូទឹកព័ទ្ធជុំវិញ មានគោបុរៈចំនួន៥ និងមានប្រាសាទបាយ័ននៃព្រះពុទ្ធសាសនាមហាយានៅចំកណ្តាល។ ព្រះអង្គមានព្រះមហេសីពីរអង្គ ដោយព្រះបាទជ័យវរ្ម័នទី៧បានរៀបអភិសេកជាមួយព្រះនាងឥន្ទ្រទេវី ដែលជាបងបង្កើតរបស់ព្រះនាងជ័យរាជទេវី ដែលបានសោយព្រះពិរាល័យទៅនោះ។ ព្រះអង្គជាព្រះមហាក្សត្រជំនាន់អង្គរទី១ ដែលគោរពព្រះពុទ្ធសាសនាមហាយាន។

ព្រះអង្គបានជីកបារាយណ៍ជ័យតដាក (សមុទ្រជ័យជម្ពុ) មានប្រវែង៣,៩គម និងមានទទឹង០,៨គម។ នៅចំកណ្តាលបារាយណ៍នេះ ព្រះអង្គសាងប្រាសាទនាគព័ទ្ធ ដើម្បីឧទ្ទិសដល់ព្រះពោធិសត្វអវលោកិស្វរ។ នៅខាងត្បូងបារាយណ៍ខាងកើត ព្រះអង្គបានសាងសង់ស្រះស្រង់ដ៏ល្អប្រណីតនៅមុខប្រាសាទរបស់ព្រះអង្គ។

ព្រះបាទជ័យវរ្ម័នទី៧បានសាងសង់ប្រាសាទជាច្រើនសន្ធឹកសន្ធាប់ដែលមានរចនាបថបាយ័ន។ ប្រាសាទទាំងនោះមានប្រាសាទបាយ័ន តាព្រហ្មតាសោម បន្ទាយក្តី ព្រះខ័ន នាគព័ទ្ធ បន្ទាយឆ្មារ ប្រាសាទជ្រុង ប្រាសាទ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រជល់ដំរី តាព្រហ្មបាទី ប្រាសាទបាណន់ វត្តនគរ តាណី ក្រោលគោ បន្ទាយព្រៃ ប្រាសាទព្រៃ និងព្រះថ្កុលៗលៅ ដែលជាប្រាសាទនៃរចនាបថបាយ័ន សាងសង់ឡើងពីគ.ស.១១៧៧ដល់គ.ស.១២៣០។ ក្រៅពីនេះ ព្រះអង្គបានសាងសង់ធម្មសាលាចំនួន១២១ និងមន្ទីរពេទ្យចំនួន១០២។ អ្នកស្រាវជ្រាវខ្លះសឹងតែមិនជឿថា ក្នុងរយៈពេលនេះ មានប្រាសាទដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានសាងសង់ឡើងនៅក្នុងអាណាចក្រខ្មែរ។ ដើម្បីសម្រេចបាននូវសមិទ្ធផលដ៏ច្រើនលើសលប់នេះ ស្តាបត្យករបុរាណខ្មែរបានកៀរគរប្រជាពលរដ្ឋប្រុស-ស្រី ទោះមាន ឬគ្មានជំនាញក្តី ដើម្បីចូលរួមសាងសង់ប្រាសាទ។ ដោយសារតែបញ្ហានេះ និងគួបផ្សំជាមួយនឹងការប្រើប្រាស់ថ្មចម្រុះគុណភាព និងការសាងសង់ដោយប្រញាប់ប្រញាល់នេះហើយ ទើបប្រាសាទមួយចំនួនធាប់បាក់បែកទ្រុឌទ្រោមជាងប្រាសាទនៃរចនាបថមុនៗ។

៣-មូលហេតុអ្វីបានជាអារ្យធម៌ខ្មែរឈានដល់កំពូលនៅសម័យអង្គរ?

ការលើកស្ទួយវិស័យអប់រំធ្វើឱ្យខ្មែរខ្លាំង ៖ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២១៨) ព្រះពុទ្ធសាសនាមហាយានត្រូវបានចាត់ជាសាសនារដ្ឋ។ ព្រះបាទជ័យវរ្ម័នទី៧បានកសាងធម្មសាលាចំនួន១២១ (អាស្រម) នៅតាមបណ្តោយផ្លូវសំខាន់ៗនានានៃចក្រភពរបស់ទ្រង់។ អ្នកសិក្សាចំនួនជិត៣ពាន់នាក់បានសិក្សានៅ«វិទ្យាល័យ»ទាំងនេះ ក្រោមការត្រួតពិនិត្យដោយផ្ទាល់ពីសម្តេចព្រះគ្រូ និងក្រុមសាស្ត្រាចារ្យ។ សាលារៀនទាំងនេះត្រូវបានសម្របសម្រួលដោយព្រាហ្មណ៍នៅប្រាសាទព្រះខ័ន។ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ប្រាសាទព្រះខ័ន គឺជាសាកលវិទ្យាល័យសម្រាប់បណ្តុះបណ្តាលថ្នាក់អាណាចក្រ ហើយព្រះនាងឥន្ទ្រទេវី ដែលជាអគ្គមហេសីទី៦នៃព្រះបាទជ័យវរ្ម័នទី៧ ជាសាកលវិទ្យាធិការតែម្តង ដោយព្រះនាងមានព្រះបញ្ញាញាណ និងចំណេះដឹងយ៉ាងខ្ពង់ខ្ពស់។

យោងតាមសិលាចារឹក មុនពេលក្លាយជាព្រះមហាក្សត្រិយានី

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ព្រះអង្គម្ចាស់ក្សត្រីឥន្ទ្រទេវី ដែលត្រូវបានគេចាត់ទុកជាព្រះអាទិទេពនៃចំណេះដឹងមកចាប់កំណើតនោះ ត្រូវបានតែងតាំងដោយព្រះរាជា ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យជំនាន់អង្គរ គឺប្រាសាទព្រះខ័ន។ ព្រះនាង ឥន្ទ្រទេវី ទ្រង់បានណែនាំព្រះរាជាឱ្យមានព្រះទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា និងការកសាងវប្បធម៌ជាតិ ដូចជាការបង្កើតឱ្យមានសាលាជាន់ខ្ពស់សម្រាប់បង្រៀនកូនចៅខ្មែរ និងបង្កើតវង់ល្ខោនសម្រាប់សម្តែងសិល្បៈខ្មែរជាដើម។ កម្មវិធីសិក្សាត្រូវផ្តោតទៅលើការអប់រំខាងផ្នែកសាសនា ភាសាសំស្ក្រឹត តារាសាស្ត្រ វិទ្យាសាស្ត្រសំណង់ ស្ថាបត្យកម្ម បច្ចេកទេសធ្វើសង្គ្រាម។ល។ ទន្ទឹមនឹងនេះ ប្រាសាទគឺជាកន្លែងសម្រាប់បណ្តុះជំនាញជាច្រើនប្រភេទ និងជាងធ្វើការតាមការដ្ឋានសំណង់ ហើយជំនាញទាំងនេះអាចត្រូវបានផ្ទេរពីឪពុកទៅកូន ពីមនុស្សជំនាន់មួយទៅជំនាន់មួយទៀត។

ចំណែកឯនៅអឺរ៉ុបវិញ នៅឆ្នាំ១១៦៧ ជម្លោះរវាងស្តេចអង់គ្លេសព្រះបាទហង់រីទី២ (Henry II) និងស្តេចសង្ឃនៅ Canterbury ឈ្មោះ Thomas Becket បានផ្ទុះឡើង ដោយសារតែបញ្ហាសិទ្ធិ និងអត្ថិយឯកសិទ្ធិនៃព្រះវិហារកាតូលិក។ ព្រះបាទហង់រីទី២ (Henry II) បានហាមឃាត់មិនឱ្យអ្នកប្រាជ្ញអង់គ្លេសទៅរៀននៅប្រទេសបារាំង។ នៅពេលនោះ អ្នកប្រាជ្ញ និងសាស្ត្រាចារ្យអង់គ្លេសចំនួន៥០នាក់បានជួបប្រជុំគ្នានៅ Oxford ដើម្បីបង្កើតសាកលវិទ្យាល័យ Oxford នៅឆ្នាំ១១៦៧។ នៅឆ្នាំ១២០៩ ចំនួននិស្សិតដែលរៀននៅសាកលវិទ្យាល័យ Oxford បានកើនឡើងដល់៣ ០០០នាក់។ នៅឆ្នាំ១២០៩ បន្ទាប់ពីមានជម្លោះរវាងសិស្ស និងប្រជាជននៅ Oxford សាស្ត្រាចារ្យមួយក្រុមបានចាកចេញពី Oxford ដើម្បីទៅបង្កើតសាកលវិទ្យាល័យថ្មីមួយទៀតនៅ Cambridge ដែលក្លាយទៅជាសាកលវិទ្យាល័យភាសាអង់គ្លេសចាស់ជាងគេទី២លើពិភពលោក។

ព្រះពុទ្ធសាសនាសម័យអង្គរ ៖ ព្រះពុទ្ធសាសនាបែបមហាយានត្រូវបាននាំចូលមកក្នុងអាណាចក្រខ្មែរដោយព្រះបាទជ័យវរ្ម័នទី៧ (១១៨១-

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១២១៨)។ បន្ទាប់ពីការចូលទិវង្គតរបស់ព្រះអង្គ ប្រទេសកម្ពុជាវិលទៅរក ព្រហ្មញ្ញសាសនាវិញក្នុងរយៈពេល៥០ឆ្នាំ។ នៅក្នុងរជ្ជកាលរបស់ព្រះអង្គ ចុងស.វ.ទី១២-ដើមស.វ.ទី១៣ ទាំងព្រហ្មញ្ញសាសនា ទាំងព្រះពុទ្ធសាសនា (មហាយាន និងហីនយាន) មានពណ្ណរាយជាមួយគ្នា ដោយស្នាព្រះហស្ត របស់ព្រះអង្គ។ លទ្ធិ «ថេរវាទ» ដែលចូលកម្ពុជាពីប្រទេសមនកាត់តាម សៀម កាន់តែរាលដាលបន្តិចម្តងៗក្នុងសង្គមខ្មែរ ហើយព្រះពុទ្ធសាសនា ហីនយានត្រូវបានលើកតម្កើងជាលើកដំបូង ជាសាសនាផ្លូវការរបស់អាណា ចក្រខ្មែរនៅក្នុងឆ្នាំ១៣៣៦។ គេសន្និដ្ឋានថា ព្រះពុទ្ធសាសនាតាមបែប ហីនយាននៅប្រទេសកម្ពុជារង្គតទ្ធិពលជាលើកដំបូង តាមរយៈវប្បធម៌ ទ្វារវតីរបស់ជនជាតិមន (Boisselier 1967)។ ការអប់រំក៏ត្រូវបានធ្វើតាម រយៈការគោរពប្រតិបត្តិពិធីសាសនាផ្សេង។ ចម្លាក់ប្រាសាទ និងសិលាចារឹក ជាភាសាសំស្ក្រឹតផង។

នៅឆ្នាំ១២០៦ មេកន្ទ្រាញវាលស្មៅនៃប្រទេសម៉ុងហ្គោលីបានបង្រួប បង្រួមកុលសម្ព័ន្ធម៉ុងហ្គោលីទាំងអស់ ហើយប្រកាសខ្លួនឯងថាជាហ្សង់ហ្ស៊ីស ខាន់ (Genghis Khan) ឬអ្នកគ្រប់គ្រងចក្រវាឡ ហើយចាប់ផ្តើមធ្វើសង្គ្រាម ដណ្តើមយកទ្វីបអាស៊ីទាំងមូល។

នៅអង់គ្លេស ពួកអភិជន (Baron) បានដើរបះបោរប្រឆាំងព្រះបាទ ចន (King John) នៅឆ្នាំ១២១៥ និងបានបង្ខំស្តេចអង្គនេះឱ្យចុះហត្ថលេខា លើធម្មនុញ្ញ ដែលមានឈ្មោះថា Magna Carta ដែលជាធម្មនុញ្ញ ដែល កំណត់ព្រំដែននៃអំណាចព្រះរាជា។ ធម្មនុញ្ញនេះប្រកាសថា ព្រះរាជា មិនមែនស្ថិតនៅលើច្បាប់ឡើយ។ ការប្រយុទ្ធប្រឆាំងនឹងអំណាចព្រះរាជា នេះបានឈានទៅដល់ការបង្កើតរដ្ឋសភា (Parlement ដែលន័យថា ការ ពិភាក្សា) ដែលប្រជាជនសាមញ្ញ និងពួកអភិជនអាចក្លាយជាសមាជិកបាន ដើម្បីផ្តល់យោបល់ដល់ស្តេច ក្នុងការគ្រប់គ្រងរដ្ឋ។ ទីក្រុងចាប់ផ្តើមរីកលូត-លាស់នៅទ្វីបអឺរ៉ុប ពាណិជ្ជកម្មផ្តល់ឱកាសដល់ក្រុមសិប្បករបង្កើតជាពោធ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាង ក្នុងការផលិតទំនិញ និងផ្តល់សេវានានា។ ពាណិជ្ជាង គឺជាកន្លែងដែលបណ្តុះបណ្តាលជំនាញដល់យុវជនវ័យក្មេងនៅអឺរ៉ុប។ នៅដើមសតវត្សទី ១៤ អឺរ៉ុបចាប់ផ្តើមមានកវីនិពន្ធ ដែលតែងនូវស្នាដៃអក្សរសិល្ប៍។

នៅចុងសម័យអង្គរ ក្នុងឆ្នាំ១៣៣៦ មានការរីកលូតលាស់ព្រះពុទ្ធសាសនាថេរវាទជំនួសឱ្យព្រះពុទ្ធសាសនាមហាយាន និងព្រហ្មញ្ញសាសនា។ ព្រះពុទ្ធសាសនាមហាយានគឺជាសាសនាដែលប្រើប្រាស់ភាសាសំស្ក្រឹតជាភាសាយាន។ ដូច្នេះហើយ ទើបនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ នៅចុងស.វ.ទី១២ និងដើមស.វ.ទី១៣ យើងឃើញថាសិលាចារឹក និងប្រាង្គប្រាសាទដែលសាងសង់ដោយព្រះអង្គសុទ្ធសឹងតែចារឹកជាភាសាសំស្ក្រឹត។ ការរីកដុះដាលនៃព្រះពុទ្ធសាសនាហីនយានបានធ្វើឱ្យខ្មែរបោះបង់ចោលការសិក្សាភាសាសំស្ក្រឹតបន្តិចម្តងៗ ហើយចាប់យកភាសាបាលីជាភាសាយានវិញ។

នៅក្នុងបរិបទតំបន់វិញ រជ្ជកាលម៉ែង (១៣៦៨-១៦៦៤) បានចាប់ផ្តើមជួសជុលមហាកំពែង ដែលចាប់ផ្តើមសាងសង់តាំងពី២៦១ឆ្នាំមុន គ.ស. ហើយបានសាងសង់មហាកំពែងនេះបន្ថែមទៀត ដើម្បីការពារព្រំដែនខាងជើងពីការឈ្លានពានរបស់ពួកម៉ុងហ្គោលី។

៤-ហេតុអ្វីបានជាអង្គរធ្លាក់ចុះ?

សម័យក្រោយរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ៖ ក្រោយពីព្រះបាទជ័យវរ្ម័នទី៧ចូលទិវង្គតនៅគ.ស.១២១៨ អាណាចក្រខ្មែរចាប់ផ្តើមធ្លាក់ចុះពីខាងក្រៅ។ ប្រទេសចម្ប៉ាចាប់សម្ពាធពីប្រទេសវៀតណាម។ ចំណែកឯជនជាតិថៃបានមកតាំងទីលំនៅនៅខ្ពង់រាបកូរ៉ាត និងក្នុងជ្រលងនៃទន្លេចៅប្រ៉ាយ៉ា។ នៅសតវត្សទី១៣ គឺជាសតវត្សនៃសង្គ្រាមសាសនានៅកម្ពុជា ដោយសារក្រោយគ.ស.១២១៨ នៅក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី២ និងព្រះបាទជ័យវរ្ម័នទី៨ (១២៦៣-៩៥) អាណាចក្រខ្មែរដាក់ទៅប្រកាន់យក

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ព្រហ្មញ្ញសាសនាជាសាសនារបស់រដ្ឋ។ ម្យ៉ាងវិញទៀត នៅសង្គ្រាមសាសនា គេបានកម្ទេច ឬធ្វាក់ឡើងវិញរូបព្រះពុទ្ធបដិមានៅប្រាសាទអង្គរធំ ប្រាសាទព្រះខ័ន ប្រាសាទតាព្រហ្ម និងប្រាសាទបន្ទាយក្តី ការធ្វាក់ឡើងវិញរូបព្រះពុទ្ធឱ្យទៅជាឥសី ឬព្រះលិង្គ។ នៅឆ្នាំ២០០១ អ្នកស្រាវជ្រាវដឹកនាំដោយលោកសាស្ត្រាចារ្យ Ishizawa បានរកឃើញនូវក្បាលព្រះពុទ្ធកប់ក្នុងដីចំនួន២៧២នៅប្រាសាទបន្ទាយក្តី។ នៅឆ្នាំ១២៩៦ ព្រះបាទឥន្ទ្រវរ្ម័នទី៣ ដែលត្រូវជាបុត្រសន្និសារ (ប្រសារ) របស់ព្រះបាទជ័យវរ្ម័នទី៨ (១២៤៣-១៣៩៥) បានឡើងសោយរាជ្យ។ ព្រះអង្គជាស្តេចដែលគោរពប្រណិបត្តិព្រះពុទ្ធសាសនាថេរវាទ។ នៅឆ្នាំ១២៩៦នោះ ចិនបានបញ្ជូនលេខកកម្មខាងផ្នែកពាណិជ្ជកម្ម ហើយបន្សល់ទុកនូវកំណត់ហេតុរបស់ជីវ តាខាន់ ដែលក្លាយជាប្រភពដ៏សំខាន់នៃប្រវត្តិសាស្ត្រខ្មែរសម័យអង្គរ។ បន្ទាប់ពីព្រះបាទឥន្ទ្រវរ្ម័នទី៣បានដាក់រាជ្យនៅឆ្នាំ១៣០៨ ព្រះបាទស្រីន្ទ្រជ័យវរ្ម័ន (១៣០៨-១៣២៧) បានឡើងសោយរាជ្យ ហើយចាប់ពីពេលនោះមកខ្មែរចាប់ផ្តើមសរសេរសិលាចារឹកជាភាសាបាលី ដែលបញ្ជាក់យ៉ាងច្បាស់ថាព្រះពុទ្ធសាសនាថេរវាទ គឺជាសាសនារដ្ឋ។

មូលហេតុនៃការធ្លាក់ចុះនៃសម័យអង្គរ ៖ អ្នកស្រាវជ្រាវបានលើកឡើងនូវមូលហេតុនៃការធ្លាក់ចុះនៃសម័យអង្គរ ៖ (១) សង្គ្រាមជាមួយសៀម និងចម្ប៉ា (២) ការទទួលយកព្រះពុទ្ធសាសនាថេរវាទ (៣) ការរីងស្ងួតហួតហែងនៃបាយណ៍ និងប្រព័ន្ធធារាសាស្ត្រនៃតំបន់អង្គរ និង (៤) ការរីកដុះដាលពាណិជ្ជកម្មនៅតំបន់ចតុមុខជាដើម។

ខុសពីព្រហ្មញ្ញសាសនាដែលជាសាសនារបស់នាហ្មឺនមន្ត្រី ព្រះពុទ្ធសាសនាថេរវាទគឺជាសាសនា ដែលប្រជាជនសាមញ្ញគោរពបូជានៅតាមតំបន់ជនបទ។ ពុទ្ធសាសនាថេរវាទ និងភាសាបាលី ដែលបាននាំចូលមកនៅស.វ.ទី១២ ក៏បានរីកដុះដាលបន្តិចម្តងៗ។ ចាប់ពីពេលដែលព្រះពុទ្ធសាសនាថេរវាទត្រូវបានប្រកាសជាសាសនារបស់រដ្ឋ ក្រុមបូជាចារ្យព្រាហ្មណ៍

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាច្រើន ដែលមានការអប់រំខ្ពង់ខ្ពស់បានភៀសខ្លួនចេញពីអាណាចក្រខ្មែរ ហើយមួយចំនួនបានរត់ភៀសខ្លួនទៅកាន់ប្រទេសសៀម និងត្រូវបានទទួលការយកចិត្តទុកដាក់ជាខ្លាំងដោយស្តេចសៀម។ ចាប់ពីពេលនោះមក អាស្រមនានា (មជ្ឈមណ្ឌលសាសនា) ត្រូវបានកាន់កាប់ដោយព្រះសង្ឃពុទ្ធសាសនា។ «គម្ពីរព្រហ្មញ្ញសាសនា ព្រមទាំងសាលារៀនត្រូវបានបំផ្លាញក៏ព្រោះតែគ្រូទាំងនោះ គឺជាអ្នកគោរពបូជាព្រហ្មញ្ញសាសនាទាំងអស់»។ ការទទួលយកនូវពុទ្ធសាសនាថេរវាទ និងការធ្លាក់ចុះសេដ្ឋកិច្ចធ្វើឱ្យជនជាតិខ្មែរឈប់សាងសង់ប្រាង្គប្រាសាទជាថ្ម ដែលបន្សល់ទុកនូវកសិ្តតាងជាច្រើន ហើយចាប់ផ្តើមសាងសង់វត្តអារាម និងសំណង់ជាឈើវិញ។ ការចាកចេញនៃអ្នកប្រាជ្ញខាងសាសនាព្រាហ្មណ៍ និងខាងផ្នែកភាសាសំស្ក្រឹតពីអាណាចក្រខ្មែរអាចឱ្យយើងធ្វើសេចក្តីសន្និដ្ឋានបានថា ការទទួលយកព្រះពុទ្ធសាសនាថេរវាទបានធ្វើឱ្យភាសាសំស្ក្រឹតត្រូវបានជំនួសដោយភាសាបាលី ដែលជាភាសានៃពុទ្ធសាសនាថេរវាទ។ បើតាមលោក Coedès ដែលបានស្រាវជ្រាវអត្ថបទសិលាចារឹក ភាសាបាលីដែលជាភាសាសក្ការៈនៃព្រះពុទ្ធសាសនាថេរវាទ ត្រូវបានចាប់ប្រើប្រាស់នៅកម្ពុជានៅដើមស.វ.ទី១៤។

យើងឃើញថា ចាប់ពីពេលដែលព្រះពុទ្ធសាសនាហីនយានត្រូវបានលើកតម្កើងជាសាសនារដ្ឋនៃអាណាចក្រខ្មែរនៅក្នុងឆ្នាំ១៣៣៦រហូតដល់ពេលចាកចោលអង្គរនៅឆ្នាំ១៤៣២ គឺមានរយៈពេលជិត១០០ឆ្នាំ។ ដូច្នេះ ការធ្លាក់ចុះជាបណ្តើរៗនៅក្នុងស.វ.ទី១៤នេះ គឺបណ្តាលមកពីការបាត់បង់បញ្ជាវន្ត និងធនធានមនុស្សខ្មែរ ដែលធ្លាប់រៀនសូត្រជាភាសាសំស្ក្រឹត។ ទន្ទឹមនឹងនេះប្រវត្តិវិទូក៏បានលើកពីសម្មតិកម្មដទៃទៀត ដូចជា ផលវិបាកនៃការចាញ់សង្គ្រាមជាមួយសៀម និងបញ្ហាផ្លាស់ប្តូរបរិស្ថានជាដើម។ ជាពិសេស ការរកឃើញរបស់ក្រុមស្រាវជ្រាវនៃសាលាបារាំងចុងបូព៌ា តាមរយៈការគូរដោយបច្ចេកវិទ្យាស្កេនឡាស៊ែរពីលើអាកាស(LIDAR) នៅឆ្នាំ២០១៥ បានរកឃើញនូវទីក្រុងបុរាណខ្មែរ មហេន្ទ្របរ៉ែតទាំងមូល ដែលមានទំហំ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៥០គីឡូម៉ែត្របួនជ្រុងជុំវិញភ្នំគូលែន ដែលលាតសន្ធឹងដល់ប្រាសាទព្រះខ័នកំពង់ស្វាយ។ ក្នុងបរិវេណទីក្រុងដ៏ធំនេះ មានប្រាសាទថ្ម ការដ្ឋានស្ថែក ព្រមទាំងប្រព័ន្ធផ្លូវទឹកសម្រាប់ស្រោចស្រព និងចរាចរណ៍។ របកគំហើញនេះបញ្ជាក់ពីមូលហេតុនៃការធ្លាក់ចុះសម័យអង្គរ ដែលបណ្តាលមកពីការបាត់បង់ប្រជាជន។ ប្រវត្តិវិទូក៏បានលើកឡើងពីការកើនឡើងនៃពាណិជ្ជកម្មនៅតំបន់ទន្លេចតុមុខនៃរាជធានីភ្នំពេញ ដែលអាចជាមូលហេតុនៃការផ្លាស់ប្តូររាជធានីផងដែរ។ របកគំហើញមួយទៀតរបស់បុរាណវិទូអំពីមូលហេតុនៃការធ្លាក់ចុះនៃអារ្យធម៌អង្គរ គឺការរីងស្ងួតហួតហែងនៃបាយណ៍ និងប្រព័ន្ធធារាសាស្ត្រនៃតំបន់អង្គរ។

ថ្វីត្បិតតែព្រះពុទ្ធសាសនាថេរវាទ ត្រូវលើកតម្កើងជាសាសនារដ្ឋនៃអាណាចក្រខ្មែរនៅក្នុងឆ្នាំ១៣៣៦ ក៏ប៉ុន្តែការទទួលយកព្រះពុទ្ធសាសនាថេរវាទនេះអាចជាដំណើរការសន្សឹមៗ ដោយត្រូវឆ្លងកាត់ដំណាក់កាលអន្តរកាល ដែលមានដំណាក់កាលមួយនោះ ប្រជាជនកម្ពុជាគោរពបូជាក្នុងពេលតែមួយនូវព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនាមហាយាន និងព្រះពុទ្ធសាសនាថេរវាទ។ លោកបណ្ឌិតសភាចារ្យ ឃីង ហុកឌី បានលើកឡើងថា ៖ «ចាប់ពីស.វ.ទី១៣មក យុវជនបានទទួលការអប់រំពីវត្តអារាម ដែលមានព្រះសង្ឃជាគ្រូអាចារ្យ ឬឧបជ្ឈាយ៍»។ សម្មតិកម្មនេះធ្វើឡើងដោយឈរលើមូលដ្ឋានកំណត់ត្រារបស់បេសកជនចិន ជីវ តាក្វាន់ នៅពេលមកទស្សនាអង្គរនៅឆ្នាំ១២៩៥-១២៩៦ ដោយបញ្ជាក់ថា «បុត្រគ្រហស្ថនានាទៅសាលាដោយមានព្រះសង្ឃជាអ្នកបង្រៀនអប់រំ។ ដល់ធំចាកសិក្ខាបទមកកាន់ជីវិតគ្រហស្ថវិញ»។

រជ្ជកាលអង្គរ គឺជានិមិត្តរូបនៃភាពថ្កុំថ្កើងរុងរឿងនៃអាណាចក្រខ្មែរពីសតវត្សទី៩ដល់សតវត្សទី១៣។ ចាប់ពីពាក់កណ្តាលសតវត្សទី១៣មក ឥទ្ធិពលនៃអាណាចក្រខ្មែរចាប់ផ្តើមថមថយចុះបន្តិចម្តងៗ ហើយអានុភាពរបស់សៀមចេះតែរីកដុះដាលខ្លាំងឡើងៗរហូតដល់នៅឆ្នាំ១៤៣១ (ឯកសារ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្លះថាឆ្នាំ១៤៣៣) ដែលស្តេចខ្មែរសម្រេចចិត្តចាកចោលអង្គរ ដើម្បីលើក រាជធានីមកចតុមុខវិញ។

នៅក្នុងរជ្ជកាលអង្គរមានសង្គ្រាមធំៗចំនួនពីររវាងខ្មែរ និងសៀម។ នៅឆ្នាំ១៣៩២ ស្តេចសៀមព្រះចៅរាមាធិបតីទី១ ដែលគ្រងរាជ្យនៅក្រុង ស្រីអយុធ្យាបានលើកទ័ពមកឈ្លានពានអង្គរ តែត្រូវព្រះបាទស្រីសុរិយោ-ទ័យវាយកម្ទេចចោលអស់។ ក៏ប៉ុន្តែ ស្តេចសៀមបានលើកទ័ពមកវាយអង្គរ ជាលើកទី២ ហើយចូលមកព័ទ្ធអង្គរក្នុងរយៈពេលជាងកន្ទុះឆ្នាំ និងគ្រប់គ្រង អង្គរបានពីរឆ្នាំ។ បន្ទាប់មក ព្រះបាទស្រីសុរិយោទ័យបានកេណ្ឌទ័ព ហើយ រំដោះអង្គរបានក្នុងឆ្នាំ១៣៩៤។

នៅឆ្នាំ១៤១៧ សង្គ្រាមខ្មែរសៀមលើកទីពីរបានកើតឡើង ហើយ ទ័ពសៀមបានចូលមកហ៊ឹមព័ទ្ធរាជធានីអង្គរម្តងទៀត ហើយបានសោយ រាជ្យនៅអង្គរ។ មិនដល់មួយឆ្នាំផង ព្រះបាទពញាយ៉ាត ដែលជាព្រះរាជ្យ បុត្ររបស់ព្រះបាទសុរិយោវង្ស បានភៀសព្រះអង្គទៅតាំងមូលដ្ឋាននិង កេណ្ឌទ័ពនៅទួលបាសាន ក្នុងខេត្តស្រីសន្ធរ ជាទីដែលព្រះបិតារបស់ព្រះ អង្គធ្លាប់យកមកកេណ្ឌទ័ពដើម្បីកម្ចាត់សៀម។ ចលនារំដោះជាតិរបស់ ព្រះអង្គមានការរីកចម្រើនយ៉ាងឆាប់រហ័ស គឺរយៈពេលតែ៩ខែ ទ័ពខ្មែរអាច មានសមត្ថភាពវាយយករាជ្យជានីអង្គរមកវិញបាន។ ព្រះបាទពញាយ៉ាត ទ្រង់លើកយកអ្នកម្នាងស៊ីសាងាម ជាបងប្អូនជីដូនមួយផង និងជាព្រះ ម្នាងរបស់ស្តេចសៀមឥន្ទ្រាជាផងទុកជាព្រះស្នំឯក។

នៅទ្វីបអឺរ៉ុប សង្គ្រាមរវាងបារាំង និងអង់គ្លេស ដែលចាប់ផ្តើមតាំង ពីឆ្នាំ១៣៣៧ នៅបន្តរហូតដល់ឆ្នាំ១៤១៩ទើបចប់។ តែនៅឆ្នាំ១៤១៩ ស្តេច ហង់រីទី៣នៃអង់គ្លេសបានប្រកាសសង្គ្រាមជាមួយបារាំងជាថ្មី និងបាន ឈ្លានពាន ហើយកាន់កាប់ប្រទេសបារាំងបានទាំងស្រុង។ វីរនារីបារាំង Jeanne d'Arc បានបង្រួបបង្រួមចលនាតស៊ូបារាំង ហើយកងទ័ពបារាំង បណ្តេញកងទ័ពអង់គ្លេសចេញបាននៅឆ្នាំ១៤៥៣។ ដំណាក់កាលនេះ គឺ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាដំណាក់កាលដែលខ្មែរចាកចោលទីក្រុងអង្គរ បន្ទាប់ពីសៀមវាយលុកចូលអង្គរ។

ចាប់ពីដើមសតវត្សទី១៥មក នៅពេលដែលចក្រភពអង្គរធ្លាក់ចុះនូវឥទ្ធិពលរបស់ខ្លួនក្នុងតំបន់ ទ្វីបអឺរ៉ុបស្គាល់នូវដំណាក់កាលនៃការរស់ឡើងវិញ (Renaissance) ជាដំណាក់កាល ដែលសិល្បករ និងស្ថាបត្យករអ៊ីតាលីបានបង្កើតនូវស្នាដៃថ្មី ដែលរំឭកពីវប្បធម៌ក្រិកបុរាណនិងរ៉ូមបុរាណ។ អ្នកប្រាជ្ញអឺរ៉ុបចាប់ផ្តើមរៀនពីស្នាដៃនៃទស្សនវិទូក្រិកបុរាណឡើងវិញ។ សិល្បករល្បីល្បាញជំនាន់នោះមាន Leonardo da Vinci និង Michelangelo ជាដើម។ អ្នកប្រាជ្ញហូឡង់ឈ្មោះ Erasmus បានបោះពុម្ពស្នាដៃនិពន្ធដែលល្បីល្បាញពេញអឺរ៉ុប។ ទស្សនវិទូ Machiavelli បានបោះពុម្ពសៀវភៅដ៏ល្បីរបស់គាត់ ដែលមានចំណងជើងថា ព្រះអង្គម្ចាស់។ អឺរ៉ុបបានចូលដល់យុគសម័យនៃការធ្វើដំណើរស្វែងរកពិភពថ្មី។ លោក Christopher Columbus បានធ្វើដំណើរទៅទ្វីបអាមេរិកចំនួន៤ដង ពីឆ្នាំ១៤៩២ដល់ឆ្នាំ១៥០៤។ ជនជាតិព័រទុយហ្គេ Magellan បានធ្វើដំណើរដោយនាវាពីមហាសមុទ្រអាត្លង់ទិកដល់មហាសមុទ្រប៉ាស៊ីហ្វិកនៅឆ្នាំ១៥២១។

៥-អ្នកប្រាជ្ញនៅសម័យអង្គរ

អ្នកប្រាជ្ញល្បីៗនៅដំណាក់កាលដំបូងនៃសម័យអង្គរមានដូចជា ៖

(១) បណ្ឌិត សិវសោម[1] ដែលរស់នៅក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី១ (គ.ស.៨៧៧–៨៨៩) ដែលបាននិពន្ធរឿងមហាការតៈ ក្បួនវេយ្យាករណ៍និងសិលាចារឹកប្រាសាទកណ្តាលដើម ដែលជាអត្ថបទថ្លែងសរសើរព្រះរាជបារមីនៃព្រះបាទឥន្ទ្រវរ្ម័នទី១ ដែលមានឫទ្ធានុភាពនាំឱ្យរាជសត្រូវនៅ

---

1 លី ជាមតេង (១៩៦០) «អក្សរសាស្ត្រខ្មែរ» ទំព័រ ៦៣ និង ម៉ឺញ សារី (២០១១) *វចនានុក្រមសិល្បៈខ្មែរ (Encyclopedia of Khmer Literature)* មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាកម្ពុជា ទំព័រ៤៣៨។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

គ្រប់ទិសទីខ្ជបខ្ជាចព្រះចេស្តាព្រះអង្គ។ ព្រះអង្គបានសាងប្រាសាទព្រះគោ និងបាគង ដែលជាបុពណដ្ឋានដ៏ល្អវិសេស។

(២) បណ្ឌិតយតិអមរភារៈ[2] ជាអ្នកប្រាជ្ញដ៏សំខាន់ក្នុងរជ្ជកាល ព្រះបាទយសោវរ្ម័ន (គ.ស.៨៩៩-៩០៨)។ លោកជាអធិបតីនៃបណ្ឌិតទាំងឡាយ និងមានឋានន្តរសក្តិជាសង្ឃរាជលើវត្តឥន្ទ្រាស្រមផ្នែកសាសនាព្រាហ្មណ៍ និងជាអ្នកតែងសិលាចារឹកភ្នំបាយ័ង ក្នុងខេត្តតាកែវ។ តាមរយៈសិលាចារឹកដែលកើតឡើងដោយព្រះរាជូបត្ថម្ភនៃព្រះបាទយសោវរ្ម័នដែលជាព្រះមហាក្សត្រភ្លៀវភ្លាមួយអង្គក្នុងស.វ.ទី៩បណ្ឌិតយតិអមរភារៈបានអួតសរសើរព្រះឥសូរ និងបានសុំបួងសួងសុំឱ្យព្រះឥសូរថែរក្សាប្រជានុរាស្ត្រឱ្យប្រកបដោយសេចក្តីសុខ។

(១) បណ្ឌិតសិវាចារ្យជាអធិការត្រួតត្រាខាងសីលធម៌ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥ (គ.ស.១០០២-១០៦៩) ដែលបានតែងសិលាចារឹកជាភាសាសំស្ក្រឹតនៅប្រាសាទតាកែវ។

(២) បណ្ឌិតកវិន្ទ្រៈ[4] ជាអ្នកប្រាជ្ញយ៉ាងធំ និងជាអ្នកនិពន្ធយ៉ាងឆើតក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២-១០៥០) និងមានតួនាទីជាព្រះរាជគ្រូ។ លោកបានតែងនិពន្ធសិលាចារឹកប្រាសាទខ្នា[5] ជាភាសាសំស្ក្រឹត ដើម្បីសរសើរតេជៈបារមីរបស់ព្រះបាទសូរ្យវរ្ម័នទី១ ដែលមានសេចក្តីភ្ញាហានមោះមុតក្នុងការធ្វើសឹក។

(៣) បណ្ឌិតសទាសិវត្រូវជាក្មួយរបស់បណ្ឌិតសិវាចារ្យ។ លោកជាកវីនិពន្ធ ដែលតែងសិលាចារឹកប្រវត្តិសាស្ត្រស្កុកកក់ធំ (K-235D)។ នៅក្នុងរាជ្យរបស់ព្រះបាទសូរ្យវរ្ម័នទី១ ព្រាហ្មណ៍សទាសិវត្រូវបានតែងតាំងជាជយេន្ទ្របណ្ឌិត និងបានរៀបអភិសេកជាមួយប្អូនស្រីរបស់ព្រះមហាក្សត្រីយ៍

---

2 លី ជាមតេង (១៩៦០) «អក្សរសាស្ត្រខ្មែរ» ទំព័រ៦៤។

3 Coedès, G, *Inscription du Cambodge*, T. 1, p. 256-260.

4 លី ជាមតេង (១៩៦០) «អក្សរសាស្ត្រខ្មែរ» ទំព័រ៦៥។

5 Coedès, G, *Inscription du Cambodge*, T. 1, p. 195-219.

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

វិលក្បី ដែលជាប្អូនថ្លៃរបស់ព្រះអង្គ។ បន្ទាប់មក សទាសិវ ត្រូវបានព្រះបាទឧទយាទិត្យវរ្ម័នទី២ ដែលឡើងសោយរាជ្យនៅឆ្នាំ១០៥០ តែងតាំងជារាជគ្រូ និងមានឋានៈជាជូលីជេងព្រះកម្រតេង។ សិលាចារឹកស្តុកកក់ធំ (K-235D) អាចចាត់ទុកថា ជាស្នាដៃអក្សរសិល្ប៍បែបប្រវត្តិសាស្ត្រដ៏សំខាន់ជាងគេ[6]។

(៤) ព្រាហ្មណ៍ទិវាករបណ្ឌិត ដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យសាសនានៅក្នុងស.វ.ទី១១ និងផ្នែកទី១ នៃស.វ.ទី១២។ ទិវាករបណ្ឌិត គឺរាជគ្រូនៃព្រះមហាក្សត្រខ្មែរចំនួនប្រាំអង្គគឺព្រះបាទរាជេន្ទ្រវរ្ម័ន (៩៤៤-៩៦៨) ព្រះបាទឧទយាទិត្យវរ្ម័នទី១ ព្រះបាទហស៌វរ្ម័នទី៣ ព្រះបាទជ័យវរ្ម័នទី៦ និងព្រះបាទសូរ្យវរ្ម័នទី២ (១១១២-១១៥២)។ បណ្ឌិតទិវាករ[7] គឺជាអ្នកប្រាជ្ញឯក ក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន ដែលចេះចាំគម្ពីរត្រៃវេទយ៉ាងស្ទាត់ជំនាញ។ លោកបាននិពន្ធសិលាចារឹកជាភាសាខ្មែរ និងជាភាសាសំស្ក្រឹត នៅប្រាសាទកំកឹស ដែលស្ថិតនៅឃុំយាង ខេត្តម្លូព្រៃ ចម្ងាយ១៦គីឡូម៉ែត្រខាងត្បូងភ្នំសណ្តាក និង២៥គីឡូម៉ែត្រពីប្រាសាទកោះកេរ។ សិលាចារឹកនេះថ្លែងសរសើរព្រះបារមីនៃព្រះបាទជ័យវរ្ម័នទី៥ (៩៦៨-១០០២) ដែលត្រូវជាព្រះរាជបុត្រនៃព្រះបាទរាជេន្ទ្រវរ្ម័ន។ នៅក្នុងរាជ្យរបស់ព្រះបាទហស៌វរ្ម័នទី៣ ដែលជាព្រះរៀមរបស់ព្រះបាទឧទយាទិត្យវរ្ម័នទី២ ព្រាហ្មណ៍ទិវាករបណ្ឌិតបានបំពេញតួនាទីជាអាចារ្យប្រធាននៅប្រាសាទព្រះវិហារ។ ព្រាហ្មណ៍ទិវាករបណ្ឌិតត្រូវបានព្រះបាទជ័យវរ្ម័នទី៦ជ្រើសរើសជាព្រះគ្រូដើម្បីអភិសេកព្រះអង្គ។ ព្រាហ្មណ៍ទិវាករបណ្ឌិតបានផ្សារភ្ជាប់ជាមួយសន្តតិវង្សថ្មីនេះ ហើយបានក្លាយជាទីប្រឹក្សាក្នុងរយៈពេល៦០ឆ្នាំ។ បន្ទាប់ពីព្រះបាទជ័យវរ្ម័នទី៦បានសោយទិវង្គត ព្រះរៀមប្អូនរបស់ព្រះអង្គ គឺព្រះបាទធរណីន្ទ្រវរ្ម័នទី១ បានឡើងសោយរាជ្យ។ ព្រះបាទធរណីន្ទ្រវរ្ម័នទី១ បានបញ្ជាឱ្យព្រាហ្មណ៍ទិវាករបណ្ឌិតចែកអំណោយនៅតាមបណ្តាប្រាសាទ

---

6 Burgess, J, (2010), *Stories in Stone : The Sdok Kok Thom Inscription & the Enigma of Khmer History*, River Books, Bangkok.

7 *លី ជាមតេង (១៩៦០) «អក្សរសាស្ត្រខ្មែរ» ទំព័រ៦៤-៦៥។*

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នានា។ ព្រាហ្មណ៍ទិវាករបណ្ឌិតត្រូវបានគេជ្រើសរើស ដើម្បីអភិសេកព្រះមហាក្សត្រថ្មី ដោយយកព្រះបរមនាមថាព្រះបាទសូរ្យវរ្ម័នទី៦។ សិលាចារឹកលេខ K383 ដែលចម្លងទាំងស្រុងពីសិលាចារឹក ភ្នំសណ្តាក បញ្ជាក់ថា ទិវាករបណ្ឌិត បានដឹកនាំការធ្វើគម្រោងដ៏ច្រើននៅប្រាសាទ ព្រះវិហារ។

(៥) បណ្ឌិតកូបន្ទ្រៈ[8] គឺជាអ្នកប្រាជ្ញល្បីល្បាញក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (១១៨០-១២២០) ជាអធិបតីលើគណៈអ្នកប្រាជ្ញ និងមានតួនាទីជាចៅក្រមល្បីខាងចំណេះនីតិសាស្ត្រ។ លោកបាននិពន្ធសិលាចារឹកប្រាសាទទេវ ដែលស្ថិតនៅក្នុងតំបន់វត្តភូ ប្រទេសឡាវ ដើម្បីថ្លែងសរសើរព្រះកិត្តិគុណរបស់ព្រះបាទជ័យវរ្ម័នទី៧ ដែលមានព្រះមេត្តាធម៌ក្រៃលែង ព្រមទាំងសមិទ្ធិធំៗ ដែលជាស្នាព្រះហស្តនៃព្រះមហាវីរក្សត្រអង្គនេះ។

នៅសម័យអង្គរ អាណាចក្រខ្មែរសម្បូរអ្នកប្រាជ្ញនិងអ្នកនិពន្ធមានទេពកោសល្យខ្ពស់ជាច្រើន។ ភាសាសំស្ក្រឹតជាមូលដ្ឋាននៃព្រហ្មញ្ញាសាសនា និងព្រះពុទ្ធសាសនាមហាយាន និងជាភាសាផ្លូវការសម្រាប់កិច្ចការរដ្ឋសម័យអង្គរ។ ដូច្នេះហើយ អក្សរសាស្ត្រខ្មែរសម័យអង្គរមានលាយឡំអក្សរខ្មែរបុរាណ និងភាសាសំស្ក្រឹត។ អក្សរសិល្ប៍ខ្មែរជំនាន់អង្គរក៏បានឡើងដល់កម្រិតកំពូលដែរ តែយើងឃើញនៅសល់តែអក្សរសិល្ប៍ដែលបានសរសេរលើសិលាចារឹកតាមប្រាង្គប្រាសាទនានាជាភាសាខ្មែរបុរាណ និងជាភាសាសំស្ក្រឹតប៉ុណ្ណោះ។ អ្នកប្រាជ្ញជំនាន់នោះនិយមសរសេរជាភាសាសំស្ក្រឹតដែលជាភាសាជាន់ខ្ពស់របស់អ្នកប្រាជ្ញ។ អត្ថបទអក្សរសិល្ប៍ជាភាសាសំស្ក្រឹតភាគច្រើនជាពាក្យកាព្យ ដែលនិយាយអំពីកំណត់ហេតុនៃប្រវត្តិរជ្ជកាល និងដើម្បីថ្លែងសរសើរស្តេច ឬមន្ត្រី។ ចំណែកឯអត្ថបទជាភាសាខ្មែរបុរាណវិញ ច្រើនជាពាក្យឧទ្ទិស ឬជាបញ្ជីរាប់ពលរេហ៍ រាប់វត្ថុដែលគេបូជាសម្រាប់បូជនីយដ្ឋានទាំងនោះ។ ស្នាដៃអក្សរសិល្ប៍ដ៏ល្បីល្បាញ គឺរឿងរាមកេរ្តិ៍

---

8 លី ជាមតេង (១៩៦០) «*អក្សរសាស្ត្រខ្មែរ*» ទំព័រ ៦៦។

9 Coedès, G, *Inscription du Cambodge*, T. 1, p. 227-249.

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

និងរឿងមហាការតៈ ដែលគេសរសេរជាភាសាខ្មែរបុរាណ លាយចម្រុះភាសាសំស្ក្រឹត។ រឿងរាមកេរ្តិ៍គឺជារឿងទីមួយរបស់ខ្មែរ។ រឿងរាមកេរ្តិ៍ខ្មែរមិនមែនប្រែត្រង់ៗពីរឿងរាមាយណៈឥណ្ឌាសុទ្ធសាធទេ។ ខ្មែរគ្រាន់តែប្រឌិតតាមប៉ុណ្ណោះ មានវគ្គខ្លះក៏ឃ្លាតចាកពីរឿងដើម មានវគ្គខ្លះក៏ប្រហាក់ប្រហែលគ្នា[10]។

ព្រះវិហារសាសនាព្រាហ្មណ៍ត្រូវបានចាត់ទុកជាមជ្ឈមណ្ឌលសិក្សារៀនសូត្រនៅក្នុងអាណាចក្រខ្មែរ។ ព្រាហ្មណ៍ដែលជាឧត្តមមន្ត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងអាណាចក្រខ្មែរ។ នៅស.វ.ទី១០ក្នុងរាជ្យព្រះបាទកជេន្ទ្រវរ្ម័ន ព្រាហ្មណ៍សិវាចារ្យជាហោតរ កវិន្ទ្រារីមថន ជាស្ថាបត្យករកសាងរាជវាំង និងប្រាសាទមេបុណ្យខាងកើត និងព្រាហ្មណ៍យជ្ញវរាហៈជាព្រះរាជគ្រូ[11]។ ប្រាសាទបន្ទាយស្រី (ត្រកូវនមហេស្វរ) ដ៏ល្បីល្បាញត្រូវបានកសាងឡើងនៅក្នុងឆ្នាំ៩៦៧ ដោយព្រាហ្មណ៍យជ្ញវរាហៈ។ ទន្ទឹមនឹងនេះ គេក៏ឃើញវត្តមាននៃព្រះពុទ្ធសាសនាមហាយាន នៅដើមសម័យអង្គរផងដែរ[12]។

ដូច្នេះ ប្រព័ន្ធអប់រំនៃអាណាចក្រខ្មែរសម័យមហានគរ គឺជាប្រព័ន្ធអប់រំតាមបែបសាសនា ដែលផ្សារភ្ជាប់ជាមួយនឹងព្រហ្មញ្ញសាសនា ហើយសម្រាប់តែកូនស្តេច និងកូនចៅនៃមន្ត្រីធំៗតែប៉ុណ្ណោះ[13] ពោល គឺជាប្រព័ន្ធអប់រំសម្រាប់អភិជន[14]។ ការសិក្សាត្រូវធ្វើឡើងជាភាសាសំស្ក្រឹត ដែលជាភាសានៃព្រហ្មញ្ញសាសនានិងជាភាសាខ្ពង់ខ្ពស់។ អាស្រមសាសនាព្រាហ្មណ៍ឬជម្មសាលា មានតួនាទីបីយ៉ាងគឺ ៖ លំនៅស្ថានរបស់ក្រមព្រាហ្មណ៍បុរោ-

---

10 លី ជាមតេង (១៩៦០) «*អក្សរសាស្ត្រខ្មែរ*» ទំព័រ ៥៩។

11 ត្រឹង ងា (១៩៧៦) «*ប្រវត្តិសាស្ត្រខ្មែរ*» ភាគ១ Editions Angkor ទំព័រ ៩៦។

12 Harris (2005) *Cambodian Buddhism : History and Practice*, Silkwom Books, p. 15.

13 Chou Ta-kuan, *Customs of Cambodia*. p. 9; see also Edwards, P. (2007), *Cambodge: The Cultivation of a Nation*, 1860-1945, University of Hawaii Press, Honolulu, p. 71.

14 Elitist education system

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហិត មជ្ឈមណ្ឌលអប់រំ និងជាកន្លែងស្នាក់អាស្រ័យសម្រាប់អ្នកពនេចរ[15]។ មុខងារចម្បងរបស់ក្រុមព្រាហ្មណ៍បុរោហិតគឺរៀន និងបង្រៀនគម្ពីរវេទ (ចំណេះដឹង)។ ព្រាហ្មណ៍បុរោហិត មានងារជារាជគ្រូ ឬព្រះគ្រូ ទទួលបន្ទុកក្នុងការអប់រំដល់ក្រុមរាជបុត្រ។ រាជគ្រូមានតួនាទីជាទីប្រឹក្សាពិសេស និងជាមហាឧបរាជ។ បណ្ណាល័យ (pustakasram[16]) សម្រាប់រក្សាទុកអត្ថបទពិសិដ្ឋត្រូវបានសាងសង់ជាទូទៅនៅសងខាងនៃទីសក្ការៈសំខាន់ៗ លោក Dagens បានបង្ហាញថាមនុស្សបួននាក់ធ្វើការនៅក្នុងបណ្ណាល័យនេះ ៖ «បណ្ណារក្សម្នាក់ និងកម្មករបីនាក់ ដើម្បីរៀបសាស្ត្រាស្ងឹករឹត សម្រាប់រយៈពេលពីរសប្តាហ៍»[17]។

15 Thach Toan (2012), *Les Khmers à l'ère de l'hindouisme* (50-1336 apr. J.-C.). *Les secrets d'Angkor.* L'Harmattan. Paris. p. 95.

16 Pustaka មានន័យថាសៀវភៅ។

17 Bruno Dagens (2005), *Les Khmers. Les belles lettres.* Paris. p. 284.

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំពូក៣
ការកកើតរដ្ឋតូចៗក្រោយការធ្លាក់ចុះនៃចក្រភពអង្គរ

អាស៊ីអាគ្នេយ៍ គឺជាតំបន់ដែលមានប្រជាជនចម្រុះជាតិសាសន៍រស់នៅ។ ពួកគេប្រមូលផ្តុំគ្នានៅក្នុងរដ្ឋតូចៗ។ ក្នុងចំណោមរដ្ឋទាំងអស់ មានតែចក្រភពអង្គរទេ ដែលរីកចម្រើនយ៉ាងធាប់រហ័ស ដោយសារព្រះបាទជ័យវរ្ម័នទី២ និងស្តេចខ្មែរជំនាន់អង្គរដទៃទៀតបានរៀបចំនូវប្រព័ន្ធគ្រប់គ្រងរដ្ឋ ដែលឈរលើមូលដ្ឋាននៃចំណេះដឹង និងច្បាប់ទម្លាប់។ រាជបុរោហិត ឬរាជគ្រូរបស់ព្រះមហាក្សត្រមានតួនាទីក្នុងការអភិវឌ្ឍធនធានមនុស្ស ដែលចាំបាច់សម្រាប់គ្រប់គ្រងអាណាចក្រដ៏ធំល្វឹងល្វើយ រៀបចំរបាក្សត្រិយ៍ និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ ជួយដឹកនាំកសាងប្រាសាទ តែងនិពន្ធក្នុងច្បាប់អក្សរសិល្ប៍ គម្ពីរ សាស្ត្រា ចារឹកសិលាចារឹក កសាងស្រុកភូមិ និងធានាការគោរពសាសនា។

ការបង្កើតប្រទេសសៀម ៖ ជនជាតិតៃ (ថៃ) បានធ្វើចំណាកស្រុកពីប៉ែកខាងត្បូងនៃប្រទេសចិន នៅក្នុងដំណើរទៅទិសខាងត្បូង។ ពួកគេរស់នៅក្នុងក្រុង (មឿង) តូចៗ ហើយនៅសតវត្សទី១១ និងទី១២ ពួកគេបានទិតរំបង្កើតរដ្ឋថ្មី ដោយរៀបចំរដ្ឋបាលគ្រប់គ្រងថ្នាក់កណ្តាល តែនៅមិនទាន់អាចពង្រីកការគ្រប់គ្រងទៅលើរដ្ឋជិតខាងឡើយ។ នៅចុងសតវត្ស

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទី១៣ បន្ទាប់ពីពួកម៉ុងហ្គោលបានចូលមកកាន់កាប់ណាន់ចៅ នៅយូណាន់ ពួកតៃធ្វើដំណើរចុះមកភាគខាងក្រោម ហើយបានបង្កើតជារដ្ឋតូចៗ ដែលស្ថិតនៅលើដែនដីដែលខ្មែរគ្រប់គ្រង។ នៅពេលនោះ នៅពេលដែលចក្រភពចាហ្គាន និងចក្រភពអង្គរចាប់ចុះខ្សោយ អំណាចនៅតំបន់អាស៊ីអាគ្នេយ៍ចាប់ផ្តើមបែកខ្ញែក រដ្ឋតូចៗដែលធ្លាប់ស្ថិតនៅក្រោមការគ្រប់គ្រងនៃអាណាចក្រអង្គរចាប់ផ្តើមពង្រឹងអំណាច តាមរយៈការគ្រប់គ្រងដោយស្វ័យភាព និងមានជំនឿសាសនា និងវប្បធម៌ជាប់ដោយខ្លួន ដោយប្រតិបត្តិព្រះពុទ្ធសាសនាថេរវាទ។ បន្ទាប់ពីព្រះចាទជ័យវ៊ីនទី៧ បានចូលទិវង្គត រដ្ឋសុខោទ័យ ដែលធ្លាប់តែជារដ្ឋចំណុះអាណាចក្រខ្មែរបានប្រកាសឯករាជ្យក្នុងឆ្នាំ១២១៩។ ស្តេចមួយអង្គមកពីឈ្មៀងសែនព្រះនាម ម៉ាងរ៉ៃ បានប្រមូលផ្តុំរដ្ឋតៃតូចៗនៅតំបន់ឈ្មៀងម៉ៃ ហើយបង្កើតរាជាណាចក្រឡានណា។ បន្ទាប់ពីពួកម៉ុងហ្គោលបានវាយកម្ទេចអាណាចក្រ ចាហ្គាន ក្នុងឆ្នាំ១២៨៧ ជនជាតិថៃលៃង់មានឧបសគ្គរាំងពួកគេ ក្នុងដំណើរឆ្ពោះទៅទិសខាងត្បូងទៀតហើយ។ ក្នុងរយៈពេល៦០ឆ្នាំ ព្រះចាទម៉ាងរ៉ៃបានប្រែក្លាយរដ្ឋមៀងតូចមួយឱ្យទៅជារាជាណាចក្រដ៏ធំមួយ។ ចាប់ពីពេលនោះមក ព្រះចាទរាមកំហែង (Rama Khamheng) ដែលជាស្តេចក្រាញ់នៅសុខោទ័យបានវាតយកទឹកដីរបស់ពួកមន ដោយខ្ចីសិល្បៈ ការគ្រប់គ្រងនយោបាយ និងរដ្ឋបាលពីខ្មែរ និងទទួលយកប្រពៃណីផ្នែកច្បាប់ និងព្រះពុទ្ធសាសនាថេរវាទពីពួកមន ហើយបានបង្កើតភាសាថៃដោយយកភាសាខ្មែរជាមូលដ្ឋាន។ នៅដើមសតវត្សទី១៤ រាជាណាចក្រសុខោទ័យបានបែកបាក់ ហើយទឹកដីនៅតាមវាលទំនាបចៅប្រ៉ាយ៉ាស្ថិតនៅក្នុងភាពចលាចល។ ដូច្នេះ អំណាចនៃតំបន់តៃបានដាក់មកភូមិភាគកណ្តាល ដោយសារអ្នកដឹកនាំម្នាក់ឈ្មោះអ៊ូថង បានច្របាច់រដ្ឋពីរបញ្ចូលគ្នា តាមរយៈការរៀបការ គឺរដ្ឋសោភ័ណបុរីជាមួយនឹងរដ្ឋលពបុរីនៃអាណាចក្រអង្គរ ហើយបានបង្កើតអាណាចក្រថ្មីមួយទៀតនៅអយុធ្យា ហើយគ្រងរាជ្យជាព្រះចាទ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

រាមាធិបតី (១៣៥០-១៣៦៩)។ លពបុរីធ្លាប់ជាមជ្ឈមណ្ឌលនៃអារ្យធម៌ទ្វារវតី ដែលព្រះបាទសូរ្យវរ្ម័នទី១ (១០០៧-១០៥០) ដណ្តើមបាន និងដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ចក្រភពអង្គរ។ អយុធ្យាបានប្រណាំងប្រជែងជាមួយរដ្ឋតែដទៃទៀតក្នុងការពង្រីង និងវាតទីយកអំណាចនៅក្នុងដែនដីតែ។

នៅឆ្នាំ១៣៩៣ ព្រះអង្គម្ចាស់ហ្វាងុំម នៅហួងព្រះបាង បានបង្កើតរដ្ឋឡានសាង ដោយបង្រួបបង្រួមរដ្ឋតូច។ ដែលមានជនជាតិលាវរស់នៅពីវាលទំនាបវៀងចន្ទន៍ដល់សុវណ្ណភូមិ តាមដងទន្លេមេគង្គ។

ការពង្រីងរដ្ឋសៀមនៅបន្តក្នុងរជ្ជកាលព្រះបាទត្រៃលោក (១៤៦៨-១៤៨៨) ដែលបានធ្វើមជ្ឈការនៃការគ្រប់គ្រងអំណាច ដោយបង្កើតការគ្រប់គ្រងរដ្ឋបាលខេត្ត បង្កើតរដ្ឋបាលគ្រប់គ្រង និងកងទ័ព និងប្រព័ន្ធតុលាការ ការគ្រប់គ្រងសេដ្ឋកិច្ចនិងសង្គម ជាពិសេស របៀបរបបក្នុងការតែងតាំងព្រះរាជា ដែលបំបាត់បានទូវជម្លោះផ្ទៃក្នុងរាជវង្សានុវង្ស។ កត្តាទាំងនេះហើយ ដែលធ្វើឱ្យសៀមអាចវាតយកទឹកដីខ្មែរបន្តិចម្តងៗ។

នៅចុងសតវត្សទី១៦ អយុធ្យាបានក្លាយជាមជ្ឈមណ្ឌលផលិតស្រូវយ៉ាងធំនៅអាស៊ីអាគ្នេយ៍ ហើយចូលរួមក្នុងពាណិជ្ជកម្មអន្តរជាតិ តាមរយៈការនាំស្រូវចេញតាមកំពង់ផែអន្តរជាតិនៅម៉ាឡាកា ហើយនាំចូលមកវិញនូវទំនិញផ្សេងៗពីក្រៅប្រទេស។ ការចូលរួមក្នុងពាណិជ្ជកម្មអន្តរជាតិបានធ្វើឱ្យអយុធ្យាមានការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ច ហើយជួយរដ្ឋសៀមក្នុងការពង្រីងកងទ័ព និងរៀបចំប្រព័ន្ធរដ្ឋបាលគ្រប់គ្រងប្រទេស។ នៅពេលដែលពួកព័រទុយហ្គាល់ចូលមកអាស៊ីអាគ្នេយ៍ នៅដើមសតវត្សទី១៦ សៀមបានទិញគ្រឿងសព្វាវុធជាច្រើន មានជាអាទិ៍កាំភ្លើងតូច និងកាំភ្លើងធំ និងគ្រាប់រំសេវជាដើម ដែលកងទ័ពសៀមប្រើប្រាស់ ក្នុងការធ្វើសង្គ្រាមជាមួយភូមា និងរាជាណាចក្រលង្វែករបស់ខ្មែរ។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជំពូក ៤
ការចាកចោលអង្គរ

១-តើប្រវត្តិសាស្ត្រខ្មែរសម័យក្រោយអង្គរអាចចែកចេញជាដំណាក់កាលអ្វីខ្លះ?

ជនជាតិខ្មែរបានចាប់ផ្តើមចាកចោលអង្គរ ដោយសារមូលហេតុច្រើនយ៉ាង ៖

(១) ការចាញ់សង្គ្រាមជាមួយសៀម ដែលធ្វើឱ្យប្រជារាស្ត្រវេទនាទុក្ខវេទនា

(២) ការហូរចេញនូវអ្នកប្រាជ្ញ អ្នកចេះដឹង និងជនជាន់មនុស្ស ដោយសារការផ្លាស់ប្តូរសាសនាពីព្រហ្មញ្ញសាសនាទៅព្រះពុទ្ធសាសនាថេរវាទ និងភាសាពីភាសាសំស្ក្រឹតទៅភាសាបាលី

(៣) ការធ្លាក់ចុះនូវផលិតភាពកសិកម្ម ដោយសារបន្ទាស់ទីរបស់ប្រជាជន

(៤) ការកើនឡើងនៃពាណិជ្ជកម្មនៅតំបន់ចតុមុខ ដោយសារការកែចម្រើននៃនាវាចរណ៍សមុទ្រ។

នៅឆ្នាំ១៤៣២ ព្រះបាទពញាយ៉ាតផ្លាស់ប្តូររាជធានីពីអង្គរមកទួលបាសាន ហើយក្រោយមកក៏រើរាជធានីមកភ្នំពេញនៅឆ្នាំ១៤៣៤រហូតដល់ចុងស.វ.ទី១៩។ ប្រវត្តិសាស្ត្រខ្មែរសម័យក្រោយអង្គរ អាចចែកចេញជាពីរដំណាក់កាលធំៗ ៖

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដំណាក់កាលទី១ ពីឆ្នាំ១៨៣១ដល់១៩៥៥ ៖ គឺជាដំណាក់កាលចតុមុខ-លង្វែក។ ក្នុងរយៈពេលជាង១៥០ឆ្នាំក្រោយការចាកចោលអង្គរ ខ្មែរនៅរក្សាបានតួនាទីសំខាន់នៅក្រោយឥណ្ឌូចិន និងនៅអាស៊ីអាគ្នេយ៍។ នៅសម័យចតុមុខ កម្ពុជាត្រូវបានបែងចែកជាបីម្តង និងជាពីរម្តង។ បន្ទាប់មក រាជធានីត្រូវបានលើកទៅលង្វែក។ នៅក្នុងសម័យលង្វែក ខ្មែរបានខិតខំប្រឹងប្រែងពង្រឹងខ្លួនឡើងវិញតាមរយៈការកសាងរដ្ឋ និងការជួសជុលប្រាសាទអង្គរ។ តែការបែកបាក់ក្នុងរាជវង្សបានធ្វើឱ្យខ្មែរបាត់បង់នូវភាពធន់ចំពោះការគំរាមកំហែងពីខាងក្រៅ និងចាញ់សង្គ្រាមជាមួយសៀម ហើយកម្ពុជាដើរលៃលួចតែម្តង។

នៅសម័យក្រោយអង្គរ គេលែងប្រើពាក្យ«ភ្នំ» ដើម្បីសម្គាល់ព្រះនាមស្តេចហើយ។ ដើម្បីសម្គាល់ស្តេច គេប្រើពាក្យ«ពញា»ជំនួសវិញ។ លុះក្រោមមកទៀត គេឈប់ប្រើពាក្យ«ពញា» ហើយប្រើពាក្យ«ស្រី» និង«អង្គ» ដូចជា ស្រីរាជា និងអង្គដួងជំនួសវិញ ដើម្បីភ្ជាប់ទៅនឹងព្រះនាមស្តេច។ សម័យកាលក្រោយអង្គរ ចាប់ពីសតវត្សទី១៥ គឺជាសម័យកាលកណ្តាលនៃប្រវត្តិសាស្ត្រកម្ពុជា។ ថ្វីត្បិតតែសម័យក្រោយអង្គរកម្ពុជាជួបនឹងកលិយុគយ៉ាងខ្លាំងក្លាក៏ដោយ អក្សរសាស្ត្រខ្មែរមានការរីកចម្រើនយ៉ាងខ្លាំង អត្ថបទអក្សរសិល្ប៍រឿងរាមកេរ្តិ៍ជាច្រើនរឿង ច្បាប់សុភាសិត គម្ពីរធម៌ និងរឿងល្បែងផ្សេងៗត្រូវបានសរសេរនៅក្នុងសម័យកណ្តាលនេះ។

នៅឆ្នាំ១៨៣៦ ព្រះបាទពញាយ៉ាតផ្ទាស់ប្តូររាជធានីពីអង្គរមកទួលបាសាន ហើយក្រោយមកក៏រើរាជធានីមកភ្នំពេញនៅឆ្នាំ១៨៣៧រហូតដល់ចុងស.វ.ទី១៩។ ភ្នំពេញនៅជារាជធានីនៃព្រះរាជាណាចក្រកម្ពុជាជិបតីអស់រយៈពេល៣០ឆ្នាំ។ ក្រោយមក រាជធានីបានលើកទៅស្រីសន្ធរ និងទៅលង្វែក។ នៅក្នុងដំណាក់កាលនេះ ស្តេចបីអង្គ គឺស្រីរាជា បរមរាជា និងអង្គចន្ទបានខិតខំពង្រឹងសន្តិភាព និងស្ថិរភាព ដោយធ្វើការទប់ទល់ជាមួយប្រទេសសៀម។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សម័យក្រោយអង្គរគឺជាសម័យកាល ដែលខ្មែរចុះដុនជាបខាងផ្នែកសេដ្ឋកិច្ច ដោយសារអស្ថិរភាពនយោបាយ ដែលបង្កើតឡើងដោយសារទំនាស់ផ្ទៃក្នុងរាជវង្សខ្មែរ ជាពិសេសបញ្ហាស្នងរាជ្យសម្បត្តិ ការឃុបឃិតនិងទំនាស់រវាងមន្ត្រីជាន់ខ្ពស់ និងសង្គ្រាមជាមួយប្រទេសជិតខាង។

២-មូលហេតុអ្វីបានជាកម្ពុជាត្រូវបែកចែកជាបីនៅសតវត្សទី១៥?

នៅឆ្នាំ១៤៣១ (ឯកសារខ្លះថាឆ្នាំ១៤៣៣) ពញាយ៉ាត លើកព្រះរាជធានីពីអង្គរទៅតាំងនៅឯចួលបាសាន។ ប៉ុន្តែ ដោយមានទឹកជំនន់ធំ ព្រះអង្គក៏លើករាជធានីពីទីនោះមកតាំងនៅចតុមុខវិញ។ លុះសម្រេចការកសាងហើយ ព្រះរាជាទ្រង់តាំងប្រទានានាមព្រះនគរថ្មីនេះថា ជាក្រុងចតុមុខមង្គលសកលកម្ពុជាធិបតីខត្តិយាមហានគរ។ ឯទីប្រជុំទន្លេទាំង៤ ដែលស្ថិតនៅមុខរាជធានីនេះ ក៏ទ្រង់បានប្រសិទ្ធិនាមថ្មីថា ទន្លេចតុមុខ។ ព្រះអង្គមានបុត្របីព្រះអង្គ ៖ (១) ព្រះបាទនរាយរាជា (២) ស្រីរាជា និង (៣) ធម្មរាជា (ជាមួយព្រះស្នំឯកអ្នកម្នាង ស៊ីសាងាម)។

សង្គ្រាមដណ្តើមរាជ្យ ៖ នៅឆ្នាំ១៤៦៣ ព្រះបាទពញាយ៉ាតបានបង្វែររាជ្យសម្បត្តិទៅព្រះរាជបុត្រច្បងរបស់ព្រះអង្គ ព្រះនាមនរាយរាជា។ ក្នុងឆ្នាំ១៤៦៦ ព្រះបាទពញាយ៉ាតសោយទិវង្គតទៅក្នុងជន្មាយុជាង៧០ ព្រះវស្សា ដោយព្រះបរមអដ្ឋិធាតុរបស់ព្រះអង្គត្រូវបានបញ្ចុះនៅក្នុងចេតីយនៅចង្កេះវត្តភ្នំ។ បន្ទាប់ពីរជ្ជកាលព្រះបាទនរាយរាជា ព្រះអនុជព្រះបាទស្រីរាជាឡើងស្នងរាជ្យពីឆ្នាំ១៤៦៨ដល់១៤៨៥។ នៅឆ្នាំ១៤៧៥ ព្រះអង្គបានប្រកាសធ្វើចម្បាំងរំដោះយកទឹកដីខ្មែរ ដែលសៀមយកក្នុងរជ្ជកាលព្រះរាជាមុនៗមកវិញ។ ទ្រង់បានដឹកនាំទ័ពដោយព្រះអង្គឯង ហើយចាត់តាំងព្រះស្រីសុរិយោទ័យ ជាក្មួយ ឱ្យកម្ចាំងទ័ព និងប្រមូលស្បៀងឧបត្ថម្ភសមរភូមិមុខ រីឯព្រះធម្មរាជា ជាឧបរាជនៅថែរក្សារាជធានីចតុមុខ។

នៅពេលនោះសង្គ្រាមដណ្តើមរាជ្យបានចាប់ផ្តើមឡើង ដែលបង្ហាញ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ពីការចាប់ផ្តើមបែកបាក់ក្នុងរាជវង្សខ្មែរលើកដំបូង ហើយដែលបង្កើតឱ្យមានគំរូឡើងសោយរាជ្យដោយប្រើប្រាស់កម្លាំង។ នៅពេលដែលព្រះបាទស្រីរាជាជាប់ដៃប្រយុទ្ធនៅសមរភូមិ ព្រះអង្គម្ចាស់ស្រីសុរិយោទ័យទី២ (បុត្រព្រះនរាយរាជា) មានគំនិតក្បត់ និងបានបង្កើតជាតំបន់អបគមន៍មួយ ដែលមានរាជធានីនៅស្រីសន្ធរ។ ព្រះបាទស្រីរាជាក៏លើកទ័ពមកវាយបណ្តេញទ័ពបះបោររំដោះអាណាខេត្តខាងជើង។ ដោយមានបំណងចង់សោយរាជ្យតែម្នាក់ឯង នៅឆ្នាំ១៤៩៥ ព្រះធម្មរាជាបានលបលួចទាក់ទងជាសម្ងាត់ជាមួយស្តេចសៀម ដើម្បីស្នើសុំជំនួយកម្លាំងយោធា។ ស្តេចសៀមបានបញ្ជូនកម្លាំងទ័ពសៀមមកក្នុងកម្ពុជាក្នុងន័យចូលមកសម្រុះសម្រួលព្រះរាជាខ្មែរទាំងបីអង្គដែលកំពុងទាស់គ្នា។

ការបែកបាក់កម្ពុជាជាអាណាចក្របី ៖ នៅក្នុងពាក់កណ្តាលទី២នៃសតវត្សទី១៥ ដោយសារជម្លោះផ្ទៃក្នុងរាជវង្ស ទឹកដីកម្ពុជាត្រូវបានចែកជាបីផ្នែក ៖ (១) អាណាចក្រខាងជើង មានរាជធានីនៅកំពង់សៀម គ្រប់គ្រងដោយព្រះបាទស្រីរាជា (ពីកំពង់សៀម ជើងព្រៃ និងស្ទឹងត្រង់នៅផ្នែកខាងកើតដល់រលោផ្អៀ ខេត្តពោធិ៍សាត់នៅផ្នែកខាងលិច និងដល់កំពង់ស្វាយ និងសុរិន្ទ និងព្រំដែនលាវនៅផ្នែកខាងជើង) (២) អាណាចក្រខាងកើត មានរាជធានីនៅស្រីសន្ធរ គ្រប់គ្រងដោយព្រះបាទស្រីសុរិយោទ័យ ពីឆ្នាំ១៤៧៧ (ពីស្រីសន្ធរដល់សំបូណ៌ ត្បូងឃ្មុំ បាភ្នំ ដល់ខេត្តដូងណាយ) និង (៣) អាណាចក្រខាងត្បូង មានរាជធានីនៅចតុមុខ គ្រប់គ្រងដោយព្រះបាទធម្មរាជា ពីឆ្នាំ១៤៧៨ (ពីចតុមុខដល់កំពង់សោម កំពត បាសាក់ ព្រះត្រពាំង និងក្រមួនសរហូតដល់មាត់សមុទ្រ។

បន្ទាប់ពីបែងចែកកម្ពុជាជាបីផ្នែកក្នុងរយៈពេលជាង១០ឆ្នាំរួចមក ស្តេចទាំងបីអង្គបានចាប់ផ្តើមចរចា ដើម្បីបង្រួមបង្រួមប្រទេសឡើងវិញ។ ស្តេចទាំងបីអង្គបានលើកពេលមកតាំងនៅឧដុង្គ ដើម្បីរួមពិភាក្សាបញ្ចប់សង្គ្រាមផ្ទៃក្នុងនេះ។ ក្នុងឱកាសបើកកិច្ចចរចាជាដំបូង ព្រះធម្មរាជាបាន

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្នើសុំឱ្យព្រះចៅសៀមធ្វើជាចៅក្រមផ្សះផ្សារទំនាស់ក្នុងព្រះរាជវង្សខ្មែរ។ ស្តេចសៀមក៏បានយល់ព្រម ហើយសម្រេចយកព្រះបាទស្រីរាជា និងស្រីសុរិយោទ័យទៅគង់នៅឯក្រុងអយុធ្យា។ ព្រះបាទធម្មរាជាត្រូវបានស្តេចសៀមរៀបចំអភិសេកជាព្រះមហាក្សត្រក្រុងកម្ពុជាក្នុងឆ្នាំ១៤៨៦ នៅរាជធានីចតុមុខ។ ក្រោយពីបានជួយធ្វើអន្តរាគមន៍ផ្សះផ្សារទំនាស់ក្នុងរាជវង្សខ្មែរមក ស្តេចសៀមបានទាមទារយកខេត្ត ដែលព្រះបាទស្រីរាជាទើបរំដោះបាននោះទៅវិញទាំងអស់។

ការបែកបាក់កម្ពុជាជាអាណាចក្រពីរម្តងទៀត ៖ នៅដើមសតវត្សទី១៦ ដោយសារចម្បាំងជ្រែករាជ្យ ទឹកដីកម្ពុជាត្រូវបានចែកជាពីរផ្នែក ៖ មួយផ្នែកគ្រប់គ្រងដោយស្តេចកន និងមួយផ្នែកទៀតគ្រប់គ្រងដោយព្រះបាទចន្ទរាជា (១៥១៦-១៥២៥)។

នៅពេលព្រះរាជបុត្រច្បងព្រះបាទធម្មរាជា គឺព្រះបាទស្រីសុគន្ធបទឡើងគ្រងរាជ្យ (១៥០៦-១៥១៦) ព្រះអង្គទ្រង់តាំងនាងពៅ កូនស្រីពិជ័យនាគនិងមេបាន ចៅហ្វាយស្រុកបាសាន ជាអ្នកព្រះម្នាងកេសរបុប្ផា ព្រះស្នំឯក។ ព្រះអង្គដូរឈ្មោះខេត្តនេះទៅជាស្រីសឈរវិញ ហើយក៏ប្រែក្លាយជាខេត្តស្រីសន្ធរហូតមកដល់សព្វថ្ងៃនេះ។ ព្រះអង្គតែងតាំងប្អូនប្រុសព្រះស្នំឯក នាយកន ដែលមានចំណេះវិជ្ជា ប្រាជ្ញាខ្លាំងពូកែ ជាមហាតលិក ហើយក្រោមមក ជាឃុនលួងព្រះស្តេចត្រួតលើពលព្រះរតនត្រៃទាំងអស់។

នៅគ.ស.១៥០៧ ព្រះបាទស្រីសុគន្ធបទ ទ្រង់តាំងព្រះអនុជចៅពញាចន្ទរាជា ជាមហាឧបរាជ ទៅគង់នៅក្នុងក្រុងចតុមុខ ដើម្បីគ្រប់គ្រងខេត្តនៅត្រើយខាងលិចឱ្យបានក្សេមក្សាន្ត។

នៅគ.ស.១៥០៩ ព្រះបាទស្រីសុគន្ធបទ ទ្រង់ព្រះសុបិននិមិត្តឃើញនាគមួយធំមានឫទ្ធិមហិមាមកដេញព្រះអង្គចេញពីព្រះរាជវាំង ហើយព្រួសភ្លើងឆេះអស់ព្រះនគរ។ ហោរាទាយទៅចំលើនាយកន ដែលកើតឆ្នាំពោធ៍។ ស្តេចតើយក៏រៀបចំឧបាយកលភ្លែងទៅបង់សំណាញ់ ហើយភ្លែងធ្វើជា

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សំណាញ់ជាប់គល់ រួចហើយបង្ហាប់ឱ្យកនមុជចុះទៅដោះ រួចសម្លាប់ចោល។ ព្រះស្នំឯកលបស្តាប់ឮ ក៏លួចប្រាប់ប្អូន។ ដោយដឹងឧបាយកលមុន កនបានគេចរួចផុតពីសេចក្តីស្លាប់ ហើយរត់ទៅប្រមូលទ័ពក្នុងខេត្តនៅត្រើយខាងកើត ក្នុងគោលដៅសងសឹកវិញ។

នាយកនប្រើល្បិចបញ្ឆោតចៅហ្វាយខេត្តនានាថា ព្រះបាទស្រីសុគន្ធបទបញ្ជាឱ្យកេណ្ឌទ័ពទៅកម្ចាត់មហាឧបរាជចន្ទរាជា ដែលក្បត់ហើយមានបំណងឡើងសោយរាជ្យនៅក្រុងចតុមុខ។ ព្រះចន្ទរាជាភ័យខ្លួនក៏រត់ទៅគង់ប្រថាប់នៅប្រទេសសៀម។ នាយកនប្រមូលបានកងទ័ពវាយលុកយកខេត្តជុំវិញរាជធានីទួលបាសាន។ ព្រះបាទស្រីសុគន្ធបទក៏ដកថយទៅតាំងទីនៅស្ទឹងសែន ហើយនាយកនដេញតាមដល់ក្តុំសន្ទុក។ ព្រះបាទស្រីសុគន្ធបទត្រូវពួកបះបោរធ្វើគត់នៅបន្ទាយស្ទឹងសែនក្នុងឆ្នាំ១៥១៦។ បន្ទាប់មក នាយកនបានប្រកាសខ្លួនជាស្តេចកន ដោយមានរាជនាមថា ស្រីជេដ្ឋាធិរាជរាមាធិបតី លើករាជធានីទៅតាំងទីនៅភូមិស្រឡប់ ខេត្តត្បូងឃ្មុំ ហើយបានបោះប្រាក់ស្ទឹងប្រើប្រាស់ ដោយមានរូបនាគជាសញ្ញា។

ក្នុងឆ្នាំ១៥១៦ ព្រះចន្ទរាជាត្រលប់ពីសៀមចូលមកកម្ពុជាវិញ ហើយកេណ្ឌទ័ពវាយដណ្តើមបានខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ស្វាយ និងខេត្តទាំងអស់ដែលស្ថិតនៅត្រើយខាងលិចទន្លេមេគង្គ។ ព្រះអង្គចន្ទមានការគាំទ្រយ៉ាងប្តូរផ្តាច់ពីគ្រួសារតាពេជ្រ គឺឃ្លាំងមឿង ដែលបានធ្វើពលិកម្មបូជាជីវិត ដើម្បីរំដោះទឹកដី។ នៅឆ្នាំ១៥១៩ ស្តេចកនបានលើកទ័ពមកវាយខេត្តកំពង់សៀម តែមិនបានសម្រេច។ ស្តេចទាំងពីរក៏សម្រេចចិត្តចែកកម្ពុជាជាពីរ ដើម្បីគ្រប់គ្រងក្នុងរយៈពេល៦ឆ្នាំ គឺពីឆ្នាំ១៥១៩ដល់១៥២៥។ ក្នុងឆ្នាំ១៥២៥ ព្រះចន្ទរាជាលើកទ័ពទៅវាយលុកក្រុងស្រឡប់ទទួលបានជោគជ័យ ហើយចាប់ និងសម្លាប់ស្តេចកនតែម្តង។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំពូក៥
សម័យលង្វែក

នៅដើមសតវត្សទី១៦ សន្តតិវង្សតូងហ្គូ (Taungoo, ១៥១០-១៧៥២) នៅភូមាបានបង្រួបបង្រួមប្រទេស ហើយបង្កើតនូវអាណាចក្រដ៏ធំមួយនៅអាស៊ីអាគ្នេយ៍។ ស្តេច Tabinshwehti បានពង្រីកឥទ្ធិពលខ្លួនដល់បាហ្កាន់នៅឆ្នាំ១៥៤៦។ ព្រះចៅ Bayinnaung ដែលឡើងសោយរាជ្យបន្ទាប់បានបន្តនយោបាយវាតទីនិយម ហើយវាយយកវរជ្ជាច្រើននៅភូមា រួមទាំងប្រទេសសៀមនៅឆ្នាំ១៥៦៤ និងឆ្នាំ១៥៦៨ផងដែរ។ កងទ័ពព្រះចៅ Bayinnaung របស់ភូមា (ហុងសាវឌី) បានដឹកនាំកងទ័ពវាយលុកពញ្ញាលោក ក្នុងឆ្នាំ ១៥៦៣-១៥៦៤។ ស្តេចពញ្ញាលោក ព្រះបាទធម្មារាជាធិរាជ្យបានចុះចាញ់ដោយសារខ្វះស្បៀងនិងដោយសារការរាតត្បាតនៃជំងឺអុតស្វាយ។ ស្តេច Bayinnaung បានជាក់ពញ្ញាលោក និងអយុធ្យាជារដ្ឋចំណុះ ហើយចាប់ព្រះរាជបុត្រ អង្គនរ៉ាសួនជាឈ្លើយដើម្បីធានានូវការស្មោះត្រង់។

ក្រោយពីព្រះចៅ Bayinnaung ចូលទិវង្គតនៅឆ្នាំ១៥៦១ ចក្រភពភូមាចាប់ផ្តើមបែកបាក់ ដោយសាររដ្ឋចំណុះទាមទារឯករាជ្យ។ ព្រះចៅនរ៉ាសួនបានឡើងសោយរាជ្យនៅអយុធ្យា ហើយបានរំដោះអយុធ្យាពីការគ្រប់គ្រងរបស់ភូមា ហើយឡើងសោយរាជ្យពីឆ្នាំ១៥៩០ដល់១៦០៦។

នៅដើមសតវត្សទី១៦ ជនជាតិព័រទុយហ្គាល់បានចាប់ផ្តើមមកដល់អាស៊ីអាគ្នេយ៍ ហើយបានធ្វើសង្គ្រាមដណ្តើមបានម៉ាឡាកាក្នុងឆ្នាំ១៥១១

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

និងកាន់កាប់ទីក្រុងនេះក្នុងរយៈពេល១៣០ឆ្នាំដើម្បីធ្វើជំនួញគ្រឿងទេស និងផ្សព្វផ្សាយសាសនាគ្រិស្ត។ ហើយនៅចុងទសវត្សរ៍ទី១៦ ប្រទេសហូឡង់ និងអង់គ្លេសបានមកបង្កើតក្រុមហ៊ុនធ្វើពាណិជ្ជកម្មគ្រឿងទេសនៅអាស៊ីអាគ្នេយ៍។ នៅពាក់កណ្តាលសតវត្សទី១៦ សង្ឃកាតូលិកចាប់ផ្តើមបញ្ជូនបេសកកម្មទៅកម្ពុជា ដើម្បីផ្សព្វផ្សាយសាសនាគ្រិស្ត។ ជនជាតិព័រទុយហ្គាល់បាននាំមកជាមួយនូវកាំភ្លើងធំ កាំភ្លើងតូច និងគ្រាប់រំសេវ ដែលជួយដល់កងទ័ពនៃព្រះចៅនរ៉ាសួនក្នុងការធ្វើសង្គ្រាមសឹកជាមួយប្រទេសជិតខាង។

១-ព្រឹត្តិការណ៍សំខាន់ៗនៅដើមសម័យលង្វែក

នៅស.វ.ទី១៦ ខ្មែរបានខិតខំប្រឹងប្រែងងើបឡើងវិញពីអន្ធការ។ ព្រះបាទអង្គចន្ទបានចាត់ចែងឱ្យមន្ត្រីធ្វើការជួសជុលអង្គរ និងឱ្យបណ្ឌិតជ័យនន្ទនិពន្ធសិលាចារឹកអង្គរវត្ត។

នៅឆ្នាំ១៥៦៩ ព្រះបាទអង្គចន្ទរាជបានលើករាជធានីទៅលង្វែក។ សម័យលង្វែកមានស្តេចពីរអង្គសំខាន់ គឺ៖ ព្រះបាទអង្គចន្ទរាជា ដែលធ្វើឱ្យកម្ពុជារឹងមាំ និងព្រះបាទសត្ថា ដែលធ្វើឱ្យលង្វែកបែកបាក់។ សម័យលង្វែកបង្ហាញពីការខិតខំប្រឹងប្រែងងើបឡើងវិញរបស់កម្ពុជា ក្នុងរាជ្យព្រះបាទអង្គចន្ទរាជា ដែលបានបញ្ជាឱ្យនាហ្មឺនសព្វមុខមន្ត្រីទៅជួសជុលប្រាសាទអង្គរវត្ត។

សម័យលង្វែក គឺជាសម័យកាលមួយ ដែលខ្មែរនៅមានឥទ្ធិពលនៅឡើយនៅលើជ្រោយឥណ្ឌូចិន។ លង្វែកជាទីតាំងប្រវត្តិសាស្ត្រខ្មែរដែលស្ថិតនៅក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង និងជាកន្លែងយុទ្ធសាស្ត្រមួយមានទន្លេ បឹង ជាពិសេសព្រែក។ ព្រះចន្ទរាជាបញ្ជាឱ្យមន្ត្រីឧកញ៉ាសេនាបតីឱ្យកេណ្ឌពស្ត្រកាប់ឈើ ជញ្ជូនថ្ម វែកដី ដើម្បីសង់បន្ទាយ និងរាជវាំង ដែលមានកំពែងការពារថជាន់ព្រមទាំងដាំរបងឫស្សីយ៉ាងក្រាស់ មានគូទឹក មានទ្វារ៨ ខាងក្នុងបន្ទាយទាំង៥ជាន់ ដាក់សុទ្ធតែទាហានកាំភ្លើង

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

វែង។ ក្នុងកំពែង មានរាជវាំង ហើយមានតម្កល់វត្ថុស័ក្តិសិទ្ធិគឺ ព្រះកែវ ឬ ព្រះត្រឡែងកែង និងព្រះគោចំនួន១២ និងមានក្សាន្ទូគម្ពីរក្បួនសាស្ត្រាដ៏មានតម្លៃលើសលប់។ ម្យ៉ាងទៀត តាមជំនឿរបស់ខ្មែរ ព្រះគោ និងព្រះកែវជាបងប្អូនបង្កើតនឹងគ្នា ដែលអ្នកស្រុកតែងតែគោរពបូជាទុកជាវត្ថុស័ក្តិសិទ្ធិ ដោយសារនៅក្នុងបន្ទាយលង្វែកមានរូបព្រះគោព្រះកែវ គេមានជំនឿថា នេះជាបន្ទាយមួយយ៉ាងមាំសម្រាប់ការពារសត្រូវផង និងឃ្លាំងវប្បធម៌ជាតិផង។

ព្រះបាទអង្គចន្ទជាព្រះមហាក្សត្រដ៏មានមហិទ្ធិឫទ្ធិខ្លាំងពូកែ និងប្រកបដោយទសពិធរាជធម៌។ ព្រះអង្គទ្រង់បានប្រមូលអ្នកប្រាជ្ញរាជបណ្ឌិត ព្រះសង្ឃ ព្រមទាំងគម្ពីរដីកា ក្រាំង សាស្ត្រា ឯកសារទាំងអស់ទុកជាគ្រឹះព្រះនគរ។ ទ្រង់បានទំនុកបម្រុងអ្នកមានចំណេះវិជ្ជា មេទ័ពមានថ្វីអាវុធយុទ្ធសាស្ត្រ រក្សាទុកជាកម្លាំងការពារជាតិមាតុភូមិ ទំនុកបម្រុងព្រះពុទ្ធសាសនា សាងសង់វត្តអារាម លើកតម្កើងវប្បធម៌ជាតិ មានល្ខោន និងតូរ្យតន្ត្រីសព្វបែបយ៉ាង។ ព្រះអង្គចាត់ចែងកសាងសិលាចារឹកមួយចំនួនទៅកន្លែងព្រះពាន់ និងនៅថែវខាងក្រោមនៃប្រាសាទអង្គរវត្ត ពីគ.ស១៥៦៥ ដល់១៧៦៦។

ម្យ៉ាងទៀត ទឹកដីកម្ពុជាក៏រក្សាបាននៅគង់វង្ស។ ដោយសារព្រះអង្គមិនព្រមបញ្ជូនសួយទៅថ្វាយស្តេចសៀម ដែលបានចាត់ទុកនគរខ្មែរថាជានគរចំណុះតាំងពីរាជ្យព្រះធម្មរាជាមក នៅឆ្នាំ១៥៣០ និងនៅឆ្នាំ១៥៤០ ព្រះចៅស្តេចសៀមបានលើកទ័ពមកលុកលុយខេត្តអង្គរ តែត្រូវទ័ពព្រះចន្ទរាជាវាយឱ្យបែកខ្ចាត់ខ្ចាយបរាជ័យនៅត្រង់ស្ទឹងអង្គរ ត្រង់ភូមិមួយដែលជាប់ឈ្មោះថា "សៀមរាប" ខេត្តសៀមរាបរហូតមកដល់សព្វថ្ងៃនេះ។ នៅឆ្នាំ១៥៣១ ព្រះចន្ទរាជាទ្រង់លើកទ័ពទៅវាយរំដោះយកខេត្តបស្ចិមបុរីមកវិញបាន។

នៅឆ្នាំ១៥៥១ ព្រះបាទតាបឹនស្វេជីនៃប្រទេសកូមាត្រូវបានមន្ត្រី

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជនជាតិមនលួចធ្វើគត ហើយព្រះរាមម្តាយទីទៃរបស់ព្រះអង្គ ព្រះនាមបាយីនណោង (១៥៥១-១៥៨១) ឡើងសោយរាជ្យ ហើយបានវាយយករដ្ឋភូមាទាំងអស់ ដែលស្ថិតនៅក្នុងអាណាចក្រទុនហ្គោ (Toungoo)។ ព្រះអង្គបានយកប៉េហ្គូធ្វើជារាជធានីថ្មី។ នៅឆ្នាំ១៥៥៥ ព្រះអង្គវាយយករាជធានីចាស់ អាវ៉ា និងភូមាភាគខាងលើ និងវាយយករដ្ឋហ្សាន់ ហើយបន្ទាប់មកវាយយកបានឈៀងម៉ៃ។ ក្នុងរយៈពេល៣១ឆ្នាំនៃរជ្ជកាលព្រះអង្គ ព្រះបាទបាយីនណោងបានបង្កើតអាណាចក្រដ៏ធំជាងគេនៅអាស៊ីអាគ្នេយ៍ ដែលមានភូមា រដ្ឋហ្សាន់ចិន ឡាន់ណា ឡាន់សាង មានីពួរ និងសៀម។ នៅឆ្នាំ១៥៦៣ ព្រះអង្គវាយចូលទឹកដីសៀម កាត់តាមកំផែងពេជ្រ ដើម្បីវាយយកសុខោទ័យ ពិស្ណុលោក និងសុវណ្ណភូមិ។ នៅខែកុម្ភៈ ឆ្នាំ១៥៦៨ កងទ័ពភូមាវាយចូលអយុធ្យា ហើយស្តេចសៀមបានចុះចាញ់។ ព្រះបាទបាយីនណោងបានតែងតាំងព្រះបាទមហិន្ទ្រាធិរាជ បុត្រព្រះបាទមហាចក្រព័ទ្ធនៃស្តេចថៃ។

ឱកាសដែលសៀមជាប់ដៃច្បាំងនឹងភូមា ព្រះបាទចន្ទរាជា ទ្រង់លើកទ័ពទៅវាយសៀមនៅឆ្នាំ១៥៥៩ម្តង និងឆ្នាំ១៥៦២ម្តងទៀត ហើយរំដោះយកខេត្តចន្ទបុរី និងខេត្តផ្សេងទៀតនៅជិតនោះបានមកវិញ។ ព្រះចន្ទរាជាបានសោយទិវង្គតនៅក្រុងលង្វែកនៅគ.ស១៥៦៦។ ព្រះបាទចន្ទរាជា គឺជាព្រះមហាក្សត្រដែលបានសោយរាជ្យយូរជាងគេ ក្នុងរយៈពេលកន្លះសតវត្ស។ ដើម្បីទប់ទល់នឹងខ្មែរ ស្តេចថៃ មហាចក្រព័ទ្ធបានសុំព្រះបាទបាយីនណោងឱ្យនាំនរ៉ាសួនជាបុត្រត្រលប់មកសៀមវិញនៅឆ្នាំ១៥៧១។

ក្នុងឆ្នាំ១៥៩៣ ជនជាតិព័រទុយហ្គាល់ឈ្មោះ លូ៉ី ការដូសូ (Louis Cardoso) និង ហួន ម៉ាឌេយ៉ា (Juan Madeira) បានទៅដល់លង្វែក និងបានគូសផែនទីទីក្រុងលង្វែក។ ក្នុងឆ្នាំ១៥៦០ សង្ឃមួយអង្គព្រះនាមឌីឡាគ្រុយ (Boapar de la Gruy) បានមកកម្ពុជាចំនួនមួយឆ្នាំ តែមិនអាចទាក់ទាញខ្មែរឱ្យជឿសាសនាគ្រិស្តបាន។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

២-ការខិតខំប្រឹងប្រែងងើបមកវិញរបស់ខ្មែរក្រោយសម័យអង្គរ

នៅក្នុងសតវត្សទី១៥ និងទី១៦ ខ្មែរបានខិតខំប្រឹងប្រែងកសាងជាតិឡើងវិញ នៅក្នុងគ្រប់វិស័យ ជាពិសេសក្នុងការលើកកម្ពស់អក្សរសិល្ប៍ខ្មែរសម័យកណ្តាល។ អ្នកនិពន្ធខ្មែរបានតែងនិពន្ធរឿងរាមកេរ្តិ៍ ដោយប្រើប្រាស់ពាក្យពេចន៍នៃភាសាខ្មែរកណ្តាល នៅសតវត្សទី១៥ និងទី១៦ ពោលគឺនៅសម័យមុនលង្វែក និងនៅសម័យលង្វែក។ អត្ថបទសរសេរជាពាក្យកាព្យដ៏អស្ចារ្យនេះមិនបានបញ្ជាក់ពីពេលវេលានៃការតែងនិពន្ធ និងឈ្មោះរបស់កវីនិពន្ធឡើយ។ រឿងរាមកេរ្តិ៍ គឺជាវណ្ណកម្មឯក ដែលធ្លុះបញ្ចាំងនូវទេពកោសល្យនៃកវីនិពន្ធខ្មែរ ហើយដែលត្រូវបានចាត់ទុកជាវណ្ណកម្មអក្សរសិល្ប៍ព្រាហ្មណ៍និយម។ រឿងរាមកេរ្តិ៍ជាស្នាដៃអក្សរសិល្ប៍សម័យក្រោយអង្គរដ៏អស្ចារ្យ ដែលជាឥតិកណ្ឌជាតិខាងផ្នែកអក្សរសាស្ត្រ។ រឿងរាមកេរ្តិ៍មានលំនាំប្រហាក់ប្រហែលនឹងរឿងរាមាយណៈ ដែលជារឿងកថា (épopée) របស់ឥណ្ឌាក៏ពិតមែន តែកវីនិពន្ធខ្មែរបានយករឿងនោះមកសូកែច្នៃសាច់រឿងនិងថែមគ្រឿង ដោយប្រើប្រាស់វិធីសាស្ត្រ និងសិល្ប៍វិធីតែងនិពន្ធ ថែមថយពាក្យពេចន៍ បញ្ចូលទស្សនៈ និងខ្ចីមសារឱ្យធ្លុះបញ្ចាំងពីឥថភាពក្នុងសង្គមខ្មែរ ប្រើប្រាស់រោងារសាស្ត្រខ្មែរ ដើម្បីឱ្យសាច់រឿងនេះក្លាយជារបស់ខ្មែរសុទ្ធសាធ។ អក្សរសិល្ប៍កំណាព្យខ្មែរ ជាពិសេសអក្សរសិល្ប៍ព្រាហ្មណ៍និយមសម័យក្រោយអង្គរ ពិតជាកំណប់វិជ្ជាមហាសាលរបស់ខ្មែរពិតមែន។

៣-មូលហេតុអ្វីបានជាលង្វែកបែកបាក់?

បុត្រច្បងរបស់ព្រះចន្ទរាជាគឺព្រះបាទបរមរាជា (១៥៦៦-១៥៧៦) បានបន្តធ្វើចម្បាំងជាមួយសៀមដើម្បីដណ្តើមយកអាណាខែត្រខ្មែរ ដែលសៀមបានយកទៅ។ នៅឆ្នាំ១៥៧០ ព្រះអង្គបានយាងទៅគង់នៅរាជធានីអង្គរដើម្បីប្រមូលទ័ពទៅរំដោះយកខែត្រនគរាជសីមា ហើយដាក់មន្ត្រីខ្មែរឱ្យនៅត្រួតត្រាទីនោះ។ នៅឆ្នាំ១៥៧៤ ដោយទ័ពភូមា និងទ័ពខ្មែរវាយគាប

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សៀមខ្លាំងពេក ស្តេចសៀមបង្ខំចិត្តចុះសន្ធិសញ្ញាចង់ស្គានមេត្រីជាមួយខ្មែរ ហើយព្រមប្រគល់ខែត្រនគរាជសីមា ខេត្តចន្ទបុរី និងខេត្តបស្ចិមបុរីឱ្យមហាក្សត្រខ្មែរវិញ។ ព្រះបាទបរមរាជាទ្រង់សោយទិវង្គតនៅគ.ស.១៥៧៦។

នៅឆ្នាំ១៥៨១ ព្រះបាទចាយីនណោង៉ចូលទិវង្គត បុត្រព្រះអង្គនន្ទចាយីនឡើងគ្រងរាជ្យតែព្រះបិតុលាព្រះអង្គបានបះបោរនៅឆ្នាំ១៥៨៣។ ព្រះបាទនន្ទចាយីនបានសុំជំនួយពីសមន្តរដ្ឋ។ ព្រះអង្គនរ៉ែសួនបានលើកទ័ពទៅជួយនៅខែកុម្ភៈ ឆ្នាំ១៥៨៤ តែមានការយឺតយ៉ាវ ធ្វើឱ្យស្តេចភូមាមានការសង្ស័យ ហើយបញ្ជាឱ្យកូនលើកទ័ពមកសម្លាប់ទ្រង់។ បន្ទាប់ពីបានទទួលដំណឹងនេះ ព្រះអង្គនរ៉ែសួនបានផ្តាច់ទំនាក់ទំនងជាមួយភូមា ហើយប្រមូលទ័ពដើម្បីវាយភូមាវិញ ហើយប្រកាសឯករាជ្យនៃអយុធ្យានៅឆ្នាំ១៥៨៦។

មូលហេតុនៃការបែកបន្ទាយលង្វែក ៖ លង្វែកបែកបាក់ដោយសារមូលហេតុពីរយ៉ាង ៖ (១) ការបែកបាក់ផ្ទៃក្នុង និងការគ្រប់គ្រងខ្សោយ និង (២) សង្គ្រាមជាមួយសៀម។

ព្រះបាទសត្ថាទី១ (១៥៧៦-១៥៨៦) ជាបុត្រាទី៦របស់ព្រះបរមរាជា ត្រូវបានសោយរាជសម្បត្តិបន្ត ឯបុត្រាប្អូន ព្រះបាទស្រីសុរិយោពណ៌ជាឧបរាជ។ ក្នុងរជ្ជកាលព្រះបាទសត្ថាទី១ ប្រទេសកម្ពុជាបាត់បង់ឥទ្ធិពលនិងសិទ្ធិអំណាចស្ទើរតែអស់ទាំងស្រុងពីអាស៊ីអាគ្នេយ៍។ មូលហេតុដែលធ្វើឱ្យលង្វែកបែកបាក់ គឺដោយសារតែព្រះបាទសត្ថាទី១ ភ័យនឹងព្រះអនុជខ្លួន គឺព្រះបាទស្រីសុរិយោពណ៌ ដែលជាស្តេចមានប្រាជ្ញាឈ្លាសវៃ និងមានប្រជាប្រិយភាព ហើយខ្លាចថា ថ្ងៃក្រោយបុត្ររបស់ព្រះអង្គមិនអាចស្នងរាជបល្ល័ង្កបាន។ នៅឆ្នាំ១៥៨៦ ព្រះបាទសត្ថាទី១ជាក់រាជសម្បត្តិឱ្យបុត្រាប្អូនព្រះនាមជ័យជេដ្ឋាទី១ (១៥៨៦ -១៥៩៣) ឡើងគ្រងរាជសម្បត្តិក្នុងព្រះជន្មទើបតែ១១ព្រះវស្សា ឯបុត្រាទី២ព្រះនាមពញាតន់ មានព្រះជន្ម ៦ព្រះវស្សាជាមហាឧបរាជ។ ចំណែកព្រះបាទស្រីសុរិយោពណ៌ ជាមហា

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឧកញ៉ាពាជ។ ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី១ ប្រទេសជាតិចុះទន់ខ្សោយ យ៉ាងខ្លាំង ដែលបណ្តាលមកពីវិបត្តិរាជវង្សានុវង្ស មន្ត្រីសេនាបតី និងប្រជារាស្ត្រគ្មានជំនឿទីគោរពព្រះរាជាវ័យក្មេង គ្មានព្រះរាជតម្រិះបន្តិចសោះ ធ្វើឱ្យប្រទេសជិតខាង ជាពិសេសប្រទេសសៀមលើកទ័ពមកវាយលុកចូលប្រទេសខ្មែរជាច្រើនលើកច្រើនសា។

នៅឆ្នាំ១៥៨០ ភូមាបានវាយលុកចូលប្រទេសសៀមយ៉ាងខ្លាំង ពេលនោះស្តេចសៀម មហាធម្មរាជាបានផ្ញើរាជសារសុំជំនួយពីស្តេចខ្មែរ ហើយបានចុះកិច្ចព្រមព្រៀងសន្តិភាព។ ព្រះបាទសត្ថាទី១ក៏បញ្ជូឱ្យព្រះបាទស្រីសុរិយោពណ៌នាំទ័ពទៅជួយច្បាំងសៀមរហូតទទួលបានជ័យជម្នះលើទ័ពភូមា ហើយបានបណ្តេញទ័ពភូមាចេញពីទឹកដីសៀមទៀត។ នៅឆ្នាំ១៥៨៦ ព្រះអង្គនរ៉ាសួនបានវាយយកបានឈាងម៉ែ ហើយប្រមូលបានទ័ពនិងអាវុធយុទ្ធភ័ណ្ឌជាច្រើន។ នៅឆ្នាំ១៥៨៦ ព្រះបាទនន្ទបាយីនបានលើកទ័ពមកវាយនិងហ៊ុមព័ទ្ធអយុធ្យាដោយផ្ទាល់ តែមិនបានជោគជ័យ។ ក្រោយពីកម្ទេចភូមាហើយ សៀមលើកទ័ពមកវាយកម្ពុជាម្តងៗ។ នៅឆ្នាំ១៥៨៨ សៀមវាយយកបានបន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ រហូតដល់ស្រុកបរិបូរណ៌ ព្រមទាំងហ៊ុមព័ទ្ធបន្ទាយលង្វែកទៀតផង។ ពួកវាព័ទ្ធបន្ទាយលង្វែកអស់រយៈពេល៣ខែតែត្រូវបាក់ទ័ពរត់ខ្ចាត់ខ្ចាយទៅវិញ ដោយសារខ្វះស្បៀងនិងកើតជំងឺឆ្លង។ នៅឆ្នាំ១៥៩០ ព្រះបាទមហិន្ទ្រាធិរាជចូលទិវង្គត ហើយព្រះអង្គនរ៉ាសួនបានអភិសេកជាព្រះចៅក្រុងអយុធ្យា សាន់កិតទី២។

នៅឆ្នាំ១៥៩២ ភូមាបានលើកទ័ពមកវាយសៀមម្តងទៀត។ ព្រះអង្គនរ៉ាសួនប្រុងនឹងលើកទ័ពមកវាយលុកកម្ពុជា តែក៏បង្វែរទិសទៅទប់ទល់នឹងភូមាវិញ។ នៅឆ្នាំ១៥៩៤ ស្តេចសៀម នរ៉ាសួន បានលើកទ័ពមកវាយខ្មែរជាលើកទីពីរ ដោយមានកងទ័ពច្រើនជាងមុន និងមានអាវុធទំនើបជាងមុន តាមជើងគោកផង និងតាមជើងទឹកផង។ សៀមវាយបែកបន្ទាយលង្វែក

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នៅឆ្នាំ១៥៩៥។ ព្រះបាទសត្ថាទី១ និងព្រះបាទជ័យជេដ្ឋាទី១កៀសព្រះកាយទៅនៅជែនដីលាវ ហើយក៏សោយទិវង្គតនៅទីនោះទៅ ក្នុងឆ្នាំ១៥៩៦។ ចំណែកឯព្រះបាទស្រីសុរិយោពណ៌ត្រូវសៀមចាប់បាននាំយកទៅស្រុកសៀម។

នៅក្នុងរជ្ជកាលព្រះបាទសត្ថាទី១ មានជនជាតិអេស្ប៉ាញម្នាក់ឈ្មោះ Ruiz de Hernan Gonsalez ដែលឈ្មោះខ្មែរហៅថា «ញ» ចូលមកបម្រើស្តេចខ្មែរជាអង្គរក្ស(ពញាញ)។ គាត់មានមិត្តស្និទ្ធស្នាលម្នាក់ឈ្មោះ Diogo Veloso ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយក្សត្រិយ៍ ដែលជាបងប្អូនជីដូនមួយរបស់ព្រះបាទសត្ថា។ ពេលបុត្រាទី២របស់ព្រះបាទសត្ថា ព្រះនាមពញាតន់ឡើងសោយរាជ្យ ព្រះអង្គបានតែងតាំងវេឡូសូជាចៅហ្វាយខេត្តបាភ្នំ និងហ្គុនសាលែសជាចៅហ្វាយខេត្តទ្រាំង (តាកែវ)។

ក្រោយពីបែកបន្ទាយលង្វែកមក ប្រទេសកម្ពុជាអស់ឫទ្ធានុភាព ហើយធ្លាក់ទៅជារដ្ឋទន់ខ្សោយមួយទៅតំបន់អាស៊ីអាគ្នេយ៍។ ពួកសៀមបានប្រមូលយកព្រះគោព្រះកែវ ទ្រព្យសម្បត្តិ ក្បួនខ្នាត និងឯកសារផ្សេងៗជាច្រើនយកទៅស្រុកសៀម។ ខ្មែរបានបាត់បង់កេតនកណ្ឌជាតិ ក្បួនច្បាប់។ អ្នកប្រាជ្ញ និងបណ្ឌិតជាច្រើនត្រូវកៀសខ្លួនទៅស្រុកសៀម។ ម្យ៉ាងវិញទៀត ក្រាំង និងសាស្ត្រាស្វីករឹតតែកំរិនាសខ្ទេចខ្ទីដោយសារសង្គ្រាមផងដែរ មិនបានបន្សល់ទុកដល់ជនជំនាន់ក្រោយ។ សាស្ត្រាជំនាន់អង្គរជាច្រើនត្រូវបានបាត់បង់ផងដែរនៅក្នុងសង្គ្រាម ខ្លះទៀតត្រូវគេប្រមូលយកទៅទីក្រុងអយុធ្យា ហើយត្រូវភ្លើងឆេះអស់នៅពេលដែលភូមាដុតក្រុងអយុធ្យាក្នុងឆ្នាំ១៧៦៧។ ដូច្នេះហើយទើបយើងមិនមានអក្សរសិល្ប៍អ្វីដែលនៅសេសសល់ពីដំណាក់កាលលង្វែកឡើយ លើកលែងតែរឿងរាមកេរ្តិ៍។ ប្រទេសកម្ពុជាបានបាត់បង់អាណាខ្ទែត្រខាងលិច និងពាយព្យ ដូចជា ខ្ទែត្រចន្ទបុរី បស្ចិមបុរី នគរាជសីមា ចាត់ដំបង សៀមរាប ពោធិសាត់...។ ប្រទេសជាតិធ្លាក់ទៅក្នុងភាពអនាធិបតេយ្យ ហើយគ្រោះទុរ្ភិក្សបានចូលមកយាយីប្រជារាស្ត្រខ្មែរពេញ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ផ្នែប្រទេស។ ដូច្នេះ ការបែកបាក់លផ្នែកកើតឡើងដោយសារ ៖ (១) ការមិនទុកចិត្តគ្នា និងការបែកបាក់ក្នុងជួរព្រះរាជវង្សានុវង្ស និង (២) ប្រព័ន្ធគ្រប់គ្រងរដ្ឋមិនបានកំណត់ពីគោលការឡើងស្នងរាជ្យច្បាស់លាស់។

នៅសតវត្សទី១៦ នៅពេលដែលកម្ពុជាធ្លាក់ចុះទៅក្នុងកលិយុគ ទ្វីបអឺរ៉ុបស្គាល់នូវសេចក្តីរុងរឿង។ អ្នកនិពន្ធដ៏ល្បីល្បាញរបស់អង់គ្លេស សេកស្ពៀរ (Shakespeare, ១៥៦៤-១៦១៦) បានតែងរឿងដ៏ល្បីល្បាញ គឺ Hamlet, Romeo and Juliet និង Macbeth។ នៅអឺរ៉ុបសង្គ្រាមសាសនារវាងពួកកាតូលិក និងពួកប្រូតេស្តង់ក៏ចាប់ផ្តើមដែរ។ សង្គ្រាម៣០ឆ្នាំត្រូវបានបញ្ចប់ដោយការចុះកិច្ចព្រមព្រៀងសន្តិភាព Westphalia ដែលទទួលស្គាល់អំណាចនៃរដ្ឋអធិបតេយ្យ។ ប្រជាពលរដ្ឋអឺរ៉ុបដែលជឿសាសនាប្រូតេស្តង់ បានធ្វើដំណើរទៅកាន់ទ្វីបអាមេរិក ដើម្បីស្វែងរកសេរីភាពជំនឿសាសនា។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំពូក៦
សម័យឧដុង្គ

ដំណាក់កាលទី២នៃសម័យក្រោយអង្គរ គឺដំណាក់កាលឧដុង្គ ៖ នៅ ស.វ.ទី១៧ និង១៨ នៅពេលដែលស្ថានភាពនយោបាយនៅកម្ពុជាកាន់ តែមានសភាពយ៉ាប់យ៉ឺនទៅៗ។ ក្នុងរយៈពេល៣៥០ឆ្នាំ ជាពិសេសគឺពី ឆ្នាំ១៧៧៦ដល់១៨៦០ កម្ពុជាបានបាត់បង់ទាំងស្រុងនូវតួនាទីនៅក្រោយ កូសាំងស៊ីន។ កម្ពុជាធ្លាក់ចុះបន្តិចម្តងៗទៅក្នុងកលិយុគ។

ដំណាក់កាលទី២ ពីឆ្នាំ១៥៨៦ដល់១៨៦៣ ៖ ឧដុង្គគឺជាសម័យកាល ដែលខ្មែរចុះដុនជាបខាងផ្នែកសេដ្ឋកិច្ច ដោយសារអស្ថិរភាពនយោបាយ ដែលបង្កើតឡើងដោយសារទំនាស់ផ្ទៃក្នុងរាជវង្សខ្មែរ ជាពិសេសបញ្ហាស្នង រាជ្យសម្បត្តិ ការឃុបឃិតនិងទំនាស់រវាងមន្ត្រីជាន់ខ្ពស់ និងសង្គ្រាមជាមួយ ប្រទេសជិតខាង។ ក្នុងរយៈពេលជាង២៥០ឆ្នាំនេះ ខ្មែរបានធ្លាក់ចុះពីប្រទេស មួយ ដែលមានវប្បធម៌ និងអារ្យធម៌ខ្ពង់ខ្ពស់ដល់កម្រិតមួយជិតស្មើសូន្យ។ នៅក្នុងសម័យនេះ ស្តេចខ្មែរក៏បានខិតខំធ្វើទំនើបកម្មប្រព័ន្ធប្បាប់ និងពង្រឹង ស្ថាប័នដែរ តែដោយសារមូលដ្ឋានសេដ្ឋកិច្ច និងការគ្រប់គ្រងតាមបែប ប្រពៃណី ទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសខាងក្រៅតិចតួច ធ្វើឱ្យ កម្ពុជាមិនអាចប្រណាំងប្រជែងជាមួយប្រទេសជិតខាងបាន ហើយថែមទាំង ធ្លាក់ចូលក្រោមការត្រួតត្រារួមរបស់ សៀម និងវៀតណាមទៀតផង។

សតវត្សទី១៧ គឺជាសតវត្សនៃបដិវត្តន៍វិទ្យាសាស្ត្រនៅទ្វីបអឺរ៉ុប ៖

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

អ្នកប្រាជ្ញជំាបានរកឃើញទ្រឹស្តីខាងផ្នែកគណិតវិទ្យា រូបវិទ្យា និងបានបង្កើតអគ្គិសនី និងបច្ចេកទេសនាវាចរណ៍។ ញូតុន (១៦៤២-១៧២៧) បានរកឃើញទំនាញផែនដី នៅក្នុងស្នាដៃរបស់គាត់ឈ្មោះ គោលការណ៍នៃគណិតវិទ្យា។ សតវត្សទី១៧ គឺជាសតវត្ស ដែលទ្វីបអឺរ៉ុបធ្វើអាណានិគមលើទ្វីបអាមេរិក។ ទ្វីបអឺរ៉ុបចាប់ផ្តើមធ្វើអាណានិគមនៅអាស៊ីអាគ្នេយ៍ផងដែរ។ នៅពាក់កណ្តាលទី១នៃសតវត្សទី១៧ ក្រុមហ៊ុនហូឡង់ និងអង់គ្លេសបានប្រណាំងប្រជែងគ្នាជាមួយប្រទេសព័រទុយហ្គាល់នៅក្នុងពាណិជ្ជកម្មគ្រឿងទេស។ ក្នុងឆ្នាំ១៦៦១ កងទ័ពហូឡង់បានដណ្តើមបានក្រោយម៉ាឡាកាពីព័រទុយហ្គាល់។ អេស្ប៉ាញក៏បានចូលមកធ្វើអាណានិគមលើប្រទេសហ្វីលីពីនពីឆ្នាំ១៥៧១ដល់១៨៩៨។

នៅឆ្នាំ១៦៦៤ កងទ័ពម៉ាន់ជូរីនៃភាគខាងជើងនៃប្រទេសចិនបានផ្តួលរំលំរាជវង្សម៉ីង ហើយបង្កើតជារាជវង្សឆេង។ ពួកគេបាននាំមកនូវភាសា និងវប្បធម៌របស់ខ្លួន តែសហការជាមួយពួកហាន ដើម្បីបង្កើតអាណាចក្រមួយដ៏ធំ និងមានជាងគេក្នុងពិភពលោកនៅសតវត្សទី១៨។ ស្តេចឈានឡុង (១៧៣៥-១៧៩៦) បានបង្កើតបណ្ណាល័យធំជាងគេនៅក្នុងប្រវត្តិសាស្ត្រប្រទេសចិន។

១-តើមូលហេតុអ្វីបានកម្ពុជាមិនអាចងើបឡើងវិញបាននៅសម័យឧដុង្គ?

សម័យឧដុង្គ នៅស.វ.ទី១៧ និង១៨ គឺជាដំណាក់កាល ដែលស្ថានភាពនយោបាយនៅកម្ពុជាកាន់តែមានសភាពយ៉ាប់យ៉ឺនទៅៗ។ ក្នុងរយៈពេល ៦៣ឆ្នាំនៃសម័យឧដុង្គ គឺពីឆ្នាំ១៦៦០ដល់ឆ្នាំ១៨៦៣ កម្ពុជាធ្លាក់ចុះបន្តិចម្តងៗទៅក្នុងកលិយុគរហូតដល់បាត់តួនាទីទាំងស្រុង នៅក្រោយកូសាំង-ស៊ីន។ នៅដំណាក់កាលទី១នៃសម័យឧតុង្គ វិបត្តិដណ្តើមអាជ្ញក្នុងរាជវង្ស-នុវង្សបានជំរុញឱ្យប្រទេសជិតខាងលេបត្របាក់ទឹកដីខ្មែរបន្តិចម្តងៗ ទាំងពីខាងលិច ទាំងពីខាងកើត។ នៅដើមសម័យឧដុង្គ កម្ពុជាបានខិតខំដក

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ខ្លួនពីឥទ្ធិពលរបស់សៀម ដោយយកវៀតណាមជាជញ្ជីងតុល្យភាព។ យុទ្ធសាស្ត្រនេះផ្តល់ឱកាសឱ្យវៀតណាមពង្រីកទឹកដី និងឥទ្ធិពលរបស់ខ្លួនមកលើកម្ពុជាទៅវិញ។ សតវត្សទី១៧ គឺជាសតវត្សនៃការចាប់ផ្តើមបាត់បង់ទឹកដីកម្ពុជាក្រោម។

វិបត្តិនៅឧដុង្គ ៖ បណ្តាលពីកត្តាដូចតទៅ ៖ (១) ការគ្រប់គ្រងរដ្ឋតាមបែបបុរាណ (២) សេដ្ឋកិច្ចកម្ពុជាមិនពឹងផ្អែកលើពាណិជ្ជកម្មជាមួយបរទេស (៣) កម្ពុជាគ្មានទំនាក់ទំនងសំខាន់ជាមួយប្រទេសខាងក្រៅ ជាហេតុធ្វើឱ្យការអភិវឌ្ឍធនធានមនុស្សនៅអន់ថយ និង(៤) មន្ត្រីធំៗមិនសូវគិតដល់ប្រយោជន៍ជាតិ។

នៅឆ្នាំ១៦០១ ស្តេចសៀមបានបញ្ជូនព្រះបាទស្រីសុរិយោពណ៌ ដែលជាព្រះអនុជរបស់ព្រះបាទសត្ថាទី១ឱ្យមកសោយរាជ្យចំណុះឱ្យសៀម។ ព្រះអង្គបានចាកចេញពីទីក្រុងអយុធ្យា ប្រទេសសៀម ដើម្បីធ្វើមាតុភូមិនិវត្តិមកកម្ពុជាវិញ ដោយចូលតាមច្រកកំពត មកគង់នៅកោះស្លាកែតជិតភូមិកៀនស្វាយសព្វថ្ងៃ។ ព្រះអង្គបង្ក្រាបចលនាបះបោរស្រួល ហើយបានបញ្ជាឱ្យគេសង់ព្រះរាជវាំងនៅអរិយក្សត្រសព្វថ្ងៃ ហើយក៏គ្រងរាជ្យនៅទីនោះពីឆ្នាំ១៦០៣ដល់១៦១៣ ក្នុងព្រះជន្មាយុ៦០វស្សា។ ទ្រង់ទទួលរាជាភិសេកជាស្តេចផែនដីនៅឆ្នាំ១៦១៣។ ព្រះស្រីសុរិយោពណ៌មានរាជបុត្រពីរអង្គគឺ ជ័យជេដ្ឋា និងឧទ័យ។

ខ្មែរយកវៀតណាមធ្វើជាជញ្ជីងដើម្បីទប់ទល់នឹងសៀម ៖ ព្រះបាទស្រីសុរិយោពណ៌យល់ថា ដើម្បីឱ្យមានតុល្យភាព ព្រះអង្គបានធ្វើការសាកល្បងចងសម្ព័ន្ធភាពជាមួយវៀតណាម ដោយផ្សំផ្គុំបុត្រព្រះអង្គព្រះបាទជ័យជេដ្ឋាទី២ជាមួយនឹងបុត្រីស្តេចត្រាញ់វៀតណាម ក្នុងគោលដៅយកឥទ្ធិពលរបស់វៀតណាមទប់ទល់នឹងការលុកលុយទន្ទ្រានរបស់សៀម។ ប៉ុន្តែសម្ព័ន្ធថ្មីនេះមិនបានសម្រេចតាមបំណង ហើយធ្វើឱ្យប្រទេសខ្មែររស់នៅដោយសុខដុមរមនាឡើយ។ ផ្ទុយទៅវិញ វាបានក្លាយជាទម្ងន់មួយយ៉ាង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ធ្ងន់បន្ថែមទៀតមកលើខ្មែរ។

ការរៀបចំក្រមច្បាប់ថ្មី ៖ ព្រះរាជកិច្ចដំបូងគឺ កំណែទម្រង់ច្បាប់នៅក្នុងប្រព័ន្ធតុលាការខ្មែរ ដោយក្រមមួយចំនួនមិនទាន់មានភាពយុត្តិធម៌នៅឡើយ។ ព្រះបាទជ័យជេដ្ឋាទី៦បានឱ្យអ្នកប្រាជ្ញស្រាវជ្រាវច្បាប់ សម្រាប់ប្រើក្នុងព្រះរាជនគរ ដោយពិនិត្យឡើងវិញនូវច្បាប់ដែលវិនាស នៅពេលបាក់បែកក្រុងលង្វែក (ច្បាប់ព្រះជ័យចេស្តា)។ កំណែទម្រង់ច្បាប់ និងរដ្ឋបាលប្រព្រឹត្តទៅពីឆ្នាំ១៦០១ដល់១៧៦៣។

២-តើមូលហេតុអ្វីបានកម្ពុជាបាត់បង់ទឹកដីកម្ពុជាក្រោម?

ដំណើរឆ្ពោះទៅទិសខាងត្បូង ៖ ព្រះបាទជ័យជេដ្ឋាទី៦សោយរាជ្យចាប់ពីឆ្នាំ១៦១៨ដល់ឆ្នាំ១៦៦៨។ នៅឆ្នាំ១៦២០ រាជធានីកម្ពុជាត្រូវបានបង្កើតឡើងនៅឧត្តុង្គ។ ដោយព្រះអង្គមានមហេសីនាមអង្គចូវ ជាបុត្រីស្តេចវៀតណាម ព្រះបាទជ័យជេដ្ឋាទី៦បានអនុញ្ញាតឱ្យជនជាតិវៀតណាមមកតាំងទីលំនៅនៅជាយខាងត្បូងព្រៃនគរ (គ.ស.១៦៦៣) និងបង្កើតគ្រឹះស្ថានជំនួញនៅប៉ែកខាងត្បូងប្រទេសខ្មែរពីរ មានខេត្តព្រៃនគរ និងកំពង់ក្របី ព្រមទាំងសុំអនុញ្ញាតឱ្យមានសិទ្ធិកាន់កាប់ក្រសួងគយនៅទីនោះផង។ ប្រការនេះ គឺជាការចាប់ផ្តើមនៃនយោបាយវាតទីរបស់វៀតណាម ដើម្បីដណ្តើមយកទឹកដីកម្ពុជា ៖

- នៅឆ្នាំ១៦៩៩ ៖ ខេត្តបារៀ (បាភាយ) លៀងហ្វា និងយ៉ាឌិញ (ព្រៃនគរ) បានទៅវៀតណាម
- នៅឆ្នាំ១៧៣៣ ៖ ខេត្តវិញឡុង (លង់ហោរ) និងមិថរ (មេ-ស) បានទៅវៀតណាម
- នៅឆ្នាំ១៧៥៨-១៧៧៥ ៖ ខេត្តស្រុកទ្រាំង (ស្រុកឃ្លាំង) ត្រាវិញ (ព្រះត្រពាំង) សាដែក (ផ្សារដែក) គូឡៅយ៉ាង (កោះតែង) និងចូដុក (មាត់ជ្រូក) បានទៅវៀតណាម។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ស្តេចឡើងគ្រងរាជ្យដោយប្រើប្រាស់កម្លាំងទ័ព ៖ នៅក្នុងសតវត្សទី១៧ និងទី១៨ ការបាត់បង់ទឹកដី គឺបណ្តាលមកពីស្តេចខ្មែរឈ្លោះគ្នារត់ទៅពឹងវៀតណាមឱ្យជួយ។ បញ្ហាសំខាន់ដែលធ្វើឱ្យរាជវង្សបែកបាក់គ្នា គឺការប្រជែងរាជ្យរវាងរាជវង្សានុវង្ស ដោយសារតែគ្មានទំនៀមទំលាប់ច្បាស់លាស់ក្នុងការឡើងគ្រងរាជ្យ ៖

• ជម្លោះរវាងព្រះពញ្ញាសូរ និងព្រះអង្គតន់ ជាមួយព្រះបាទកមាធិបតីចន្ទនៅឆ្នាំ១៦៥៨

• ជម្លោះរវាងព្រះអង្គនន់ទី២ និងព្រះបាទជ័យជេដ្ឋាទី៤ នៅឆ្នាំ ១៦៩១។

ដំណាក់កាលទី៦នៃសម័យឧដុង្គ ៖ នៅក្នុងដំណាក់កាលទី៦នៃសម័យឧដុង្គ ក្នុងសតវត្សទី១៨ និងទី១៩នេះ កម្ពុជាបានបាត់ទ្វារភាពម្ចាស់ការ ដោយសារជម្លោះដណ្តើមរាជ្យជាប្រចាំ និងការរត់ទៅពឹងពាក់ប្រទេសជិតខាង ដើម្បីជួយឱ្យឡើងសោយរាជ្យ។ ការពង្រឹងអំណាចនៅប្រទេសសៀមក្នុងរជ្ជកាលចក្រី និងនៅប្រទេសវៀតណាមក្នុងរជ្ជកាលព្រះចៅអធិរាជង្វៀង បានធ្វើឱ្យកម្ពុជាស្ថិតនៅចន្លោះជង្គើបពីរ ដែលគាបខ្មែរបាត់អស់ទឹកដី។ ព្រះមហាក្សត្រខ្មែរពេលនោះច្រើនមានវ័យក្មេង គ្មានបទពិសោធ ហើយការគ្រប់គ្រងរដ្ឋស្ថិតនៅក្នុងកណ្តាប់ដៃរបស់មន្ត្រីជាន់ខ្ពស់ ដែលឈ្លោះគ្នាដណ្តើមអំណាច។ ប្រជាពលរដ្ឋខ្មែររងទុក្ខវេទនាដោយសារភាពចលាចល និងអសន្តិសុខ។

យុគសម័យពន្លឺ ៖ សតវត្សទី១៧ និងទី១៨ នៅអឺរ៉ុប គឺជាយុគសម័យពន្លឺ (Enlightenment) ឬ «សតវត្សទស្សនវិជ្ជា» ដោយសារទស្សនវិទូបានផ្សព្វផ្សាយគំនិតថ្មី។ តាមរយៈការប្រជុំតាមបណ្តាវិទ្យាសាស្ត្រសាខ្លាំងអក្សរសិល្ប៍ ហាង់ការ៉ា និងសៀវភៅ។ ទស្សនវិទូធំៗនៃយុគសម័យពន្លឺគឺ ៖ Bacon, Descartes, Locke, Spinoza, Diderot, Hume, Kant, Montesquieu, Rousseau, Adam Smith, និង Voltaire។ គំនិត និងទស្សន

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

វិទ្យាសាស្ត្រទាំងនេះកាត់បន្ថយឥទ្ធិពលនៃរបបពាណិជ្ជកម្ម និងសាសនាគ្រិស្ត ហើយនាំមកនូវការផ្លាស់ប្តូរខាងផ្នែកនយោបាយក្នុងសតវត្សទី១៨ និងទី ១៩។ អ្នកវិទ្យាសាស្ត្រ និងទស្សវិទូជាង១៥០នាក់បានចងក្រងសៀវភៅសព្វ មុខវិជ្ជា (Encyclopaedia) ដើម្បីផ្សព្វផ្សាយចំណេះដឹងវិទ្យាសាស្ត្រ និង ទស្សវិជ្ជាថ្មី។

បដិវត្តន៍ឧស្សាហកម្មលើកទី១ ៖ ចុងសតវត្សទី១៨ គឺជាដំណាក់កាល នៃបដិវត្តន៍ឧស្សាហកម្មនៅអឺរ៉ុប ជាពិសេសនៅអង់គ្លេស។ ចាប់តាំងពីឆ្នាំ ១៧៥០ដល់១៨៥០ ទ្វីបអឺរ៉ុបបានប្រែមុខមាត់យ៉ាងខ្លាំង។ ប្រជាជនបាន ចាកចេញពីស្រែចម្ការ ដើម្បីទៅធ្វើការនៅតាមរោងចក្រ។ របកគំហើញថ្មី ខាងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថ្មីបានជំរុញបដិវត្តន៍ឧស្សាហកម្ម។ បញ្ហា-វន្តចាប់ផ្តើមគិតគូរខុសពីមុន ដោយឈរលើមូលដ្ឋាននៃវិទ្យាសាស្ត្រ។ លោក James Watt បានកែលម្អម៉ាស៊ីនដើរដោយចំហាយទឹក ដែលក្លាយជាក្បាលរទេះភ្លើងនៃបដិវត្តន៍ឧស្សាហកម្មលើកទី១ ដែលចាប់ផ្តើមនៅប្រទេសអង់គ្លេស ហើយដែលបង្កើនផលិតភាពពលកម្មបានយ៉ាងខ្លាំងក្លា។ អង់គ្លេសបាន ក្លាយទៅជាមជ្ឈមណ្ឌលឧស្សាហកម្ម ដែលផលិតផលិតផលវាយនភ័ណ្ឌ សេរ៉ាមិក ឧបករណ៍ធ្វើពីដែក ម៉ាស៊ីន ស៊ីម៉ងត៍ និងសាប៊ូជាដើម។ នៅទ្វីបអឺរ៉ុប អំណាចនៃវិទ្យាសាស្ត្រ ឧស្សាហកម្ម និងបច្ចេកវិទ្យាបានបង្កើតនូវគម្លាតដ៏ ធំរវាងទ្វីបអឺរ៉ុប និងអាស៊ីអាគ្នេយ៍។

អឺរ៉ុបអាចផលិតទំនិញបានយ៉ាងច្រើន ដែលទាមទារនូវទីផ្សារសម្រាប់ លក់ផលិតផល និងប្រភពនៃវត្ថុធាតុដើម។ ដូច្នេះហើយ នយោបាយនៃ ប្រទេសអឺរ៉ុបគឺ ការប្រណាំងប្រជែងគ្នា ដើម្បីដណ្តើមអាណានិគម និង កាន់កាប់កំពង់ផែធំៗ ដែលស្ថិតនៅតាមផ្លូវពាណិជ្ជកម្មសំខាន់ៗ និងការ ការពារតំបន់ផលប្រយោជន៍របស់ខ្លួន ក្នុងគោលដៅត្រួតត្រាប្រភពនៃវត្ថុ ធាតុដើមសំខាន់ៗ។ ដើម្បីរកទីផ្សារលក់ផលិតផលឧស្សាហកម្ម អង់គ្លេស ចាប់ផ្តើមវាតទីយកអាណានិគម ដើម្បីបង្កើតទីផ្សារនៅទ្វីបផ្សេងទៀតនៅ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាស៊ី អាហ្វ្រិក និងអាមេរិក។ នៅឆ្នាំ១៧៧៦ អាណានិគមអាមេរិកបានដើរបះបោរប្រឆាំងនឹងអង់គ្លេស ហើយបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ស្តីពីឯករាជ្យ។ នៅឆ្នាំ១៧៨៣ អង់គ្លេសទទួលស្គាល់សហរដ្ឋអាមេរិក ជារដ្ឋឯករាជ្យ។ ប្រទេសអឺរ៉ុបពីរ គឺព័រទុយហ្គាល់ និងហូឡង់ ដែលជាមហាអំណាចសមុទ្រនៅបន្តដើរតួនាទីសំខាន់ក្នុងការរាតទីធ្វើអាណានិគម នៅអាស៊ីអាគ្នេយ៍។

ដំណើរឆ្ពោះទៅទិសខាងត្បូងនៃប្រទេសវៀតណាម ៖ នៅសតវត្សទី១៥ អាណាចក្រជាយវៀតមានដែនដីតូចនៅឡើយ។ នៅចុងសតវត្សទី១៦ វៀតណាមចែកចេញជាពីរផ្នែក ៖ តុងកឹង គ្រប់គ្រងដោយសន្តតិវង្សជិញ (Trinh) មានរាជធានីនៅហាណូយ និងអាណ្ណាមគ្រប់គ្រងដោយសន្តតិវង្សង្វៀង (Nguyen) មានរាជធានីនៅវ៉ៃ (Hue)។ បន្ទាប់ពីលេបយកចម្ប៉ាអស់ក្នុងឆ្នាំ១៧២០ ពួកសន្តតិវង្សង្វៀងចាប់ផ្តើមធ្វើដំណើរឆ្ពោះទៅទិសខាងត្បូង ដើម្បីកាន់កាប់តំបន់កូសាំងស៊ីន ឬកម្ពុជាក្រោម។ នៅក្នុងពាក់កណ្តាលសតវត្សទី១៨ វៀតណាមបានបង្រួបបង្រួមគ្នា ដោយសារបងប្អូនបីនាក់ពីស្រុកតាយសុន (Tayson) បានដើរបះបោរហើយដណ្តើមបានការគ្រប់គ្រងវៀតណាមទាំងមូល ៖ Nguyen Van Hue បានប្រកាសខ្លួនជាព្រះចៅអធិរាជនៅតុងកឹង Nguyen Van Nhac បានប្រកាសខ្លួនជាព្រះចៅអធិរាជនៅអាណ្ណាម និង Nguyen Van Lu បានប្រកាសខ្លួនជាព្រះចៅអធិរាជនៅតំបន់ដីសណ្តទន្លេមេគង្គ។ ក៏ប៉ុន្តែ កូនស្តេចនៃរាជវង្សង្វៀងឈ្មោះ ង្វៀង អាញ់បានរត់រួច ហើយទៅកេណ្ឌទ័ពនៅតំបន់ដីឧបទ្វីបកាម៉ៅ ហើយវាយយកព្រៃនគរបានក្នុងឆ្នាំ១៧៨៨ បន្ទាប់មកវាយយកក្រុងវ៉ៃបានក្នុងឆ្នាំ១៨០១ និងហាណូយបានក្នុងឆ្នាំ១៨០៦។ ក្នុងឆ្នាំ១៨០៦ ង្វៀង អាញ់ បានប្រកាសខ្លួនជាព្រះចៅអធិរាជយ៉ាឡុង។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

៣-តើមូលហេតុអ្វីបានខ្មែរចំណុះឱ្យសៀមនៅសតវត្សទី១៨?

សន្តតិវង្សចក្រីនិងឥទ្ធិពលលើកម្ពុជា ៖ នៅក្នុងរាជ្យព្រះបាទឧទ័យអង្គតន់ ក្នុងឆ្នាំ១៧៦៥ បន្ទាប់ពីភូមាបានចូលឈ្លានពាន និងដុតស្រីអយុធ្យា ចៅហ្វាយខេត្តមេទីពកូនកាត់ចិនម្នាក់ ឈ្មោះពញាតាក់ បានកេណ្ឌទីពរំដោះប្រទេសសៀមពីភូមាបាន ហើយផ្ទាស់ព្រះរាជធានីពីស្រីអយុធ្យាមកបាងកក រួចឡើងសោយរាជ្យជាស្តេច។ ពញាតាក់បានបញ្ជាឱ្យព្រះបាទឧទ័យអង្គតន់លើកសួយសារអាករទៅថ្វាយ តែទ្រង់មិនព្រម។ ក្នុងឆ្នាំ១៧៦៩ ពញាតាក់បានញុះញង់ព្រះអង្គនន់ ដែលរត់ទៅជ្រកនៅជាយដែនសៀម លើកទីពមកច្បាំងនឹងខ្មែរ តាមសមុទ្រផង និងតាមជើងគោកផង។ សៀមបានច្បាំងឈ្នះហើយរៀបចំព្រះរាជពិធីអភិសេកថ្វាយព្រះបាទអង្គនន់ឡើងសោយរាជ្យក្នុងឆ្នាំ១៧៧៥។ ក្នុងឆ្នាំ១៧៧៩ ចៅហ្វាយខេត្តទ្រាំង ចៅហ្វាមូបានកេណ្ឌទីពវាយចូលក្រុងឧដុង្គ សម្លាប់ព្រះអង្គនន់ ហើយលើកព្រះអង្គអេង ព្រះជន្ម៦វស្សា ឡើងគ្រងរាជសម្បត្តិ។ ព្រះចៅក្រុងធនបូរី ពញាតាក់បានបញ្ជាឱ្យឧកញ៉ាយោមរាជបែនចូលគាល់ រួចបញ្ជាឱ្យចៅពញាមហាក្សត្រសឹក ជួងលើកទីពមកឧដុង្គ ជាមួយបែន ដើម្បីសងសឹក។ ចៅហ្វាមូ និងនាហ្មឺនជាបក្សពួកត្រូវបានសម្លាប់ក្នុងសង្គ្រាម។ ក៏ប៉ុន្តែ នៅពេលដែលព្រះចៅក្រុងធនបូរីបែកកម្មដ្ឋាន រួចចេញទៅបួស ចៅពញាមហាក្សត្រសឹក ជួងវិលត្រលប់មកប្រទេសសៀមវិញ ដើម្បីសោយរាជសម្បត្តិជាម្ចាស់ផែនដីក្រុងសៀមក្នុងឆ្នាំ១៧៨២ រួចហើយបញ្ជាឱ្យចាប់ផ្សឹកពញាតាក់ រួចដាក់ទោសប្រហារជីវិត។ នេះគឺជាដំណាក់កាលថ្មីនៃសម័យកាលរាជវង្សចក្រីនៅប្រទេសសៀម ដែលព្រះចៅស្តេចសៀមយកព្រះនាមជាព្រះរាមទី១។

ការបែកបាក់ក្នុងជួរឧត្តមមន្ត្រីខ្មែរ ខេត្តបាត់ដំបងនិងសៀមរាបក្រោមការត្រួតត្រាសៀម ៖ ក្រោយពីបានសម្លាប់ចៅហ្វាមូ រួចយោមរាជបែនតាំងខ្លួនជាសម្តេចចៅហ្វាវិញ។ កម្ពុជាកើតចលាចលម្តងទៀត ដោយចៅហ្វាយ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ខេត្តស្តេចត្រាញ់ត្បូងឃ្មុំលើកទ័ពមកចូលចាប់ចៅហ្វាំបែន និងក្រឡាហោម ប៉ុក ដែលជាព្រះធម្មបិតានៃព្រះបាទអង្គអេង។ ចៅហ្វាំបែន និងក្រឡាហោម ប៉ុកបាននាំព្រះបាទអង្គអេងវត់ (ព្រះជន្ម១០វស្សា) ទៅសៀម។ ស្តេចសៀម ឃាត់ព្រះអង្គទុករហូតដល់អាយុ២២វស្សា។ ក្នុងឆ្នាំ១៧៩៤ ព្រះអង្គអេង បានរៀបអភិសេកនៅក្នុងព្រះជន្ម២២វស្សានៅទីក្រុងបាងកក។ គ្រឿងបញ្ជាក្សត្រជាពិសេស គឺព្រះខ័នរាជ្យ ដែលចៅហ្វាំបែនបានលួចយកទៅឱ្យសៀម ក៏ត្រូវបង្វិលមកឱ្យខ្មែរវិញនៅដើមខែមីនា ១៧៩៤។ ប្រទេសកម្ពុជាពេលនោះបានបាត់បង់ពួកមន្ត្រីដែលមានសមត្ថភាព និងស្មោះត្រង់ ចំណែកឯវិស័យការពារប្រទេស យើងក៏គ្មានទ័ពសម្រាប់ការពារខ្លួនទប់ទល់នឹងការវាយលុកណាមួយពីខាងក្រៅ។ ចំណែកឯវិស័យសេដ្ឋកិច្ចទៀតសោតបានធ្លាក់ចុះដុនជាបដោយសង្គ្រាមក្នុងស្រុក។ ស្តេចសៀមក៏សុំយកខេត្តបាត់ដំបង និងសៀមរាប។ នៅឆ្នាំ១៧៩៣ ស្តេចវាមាទី១តែងតាំងនាហ្មឺនខ្មែរបីរូប គឺ ចៅពញាអភ័យភូបៃស បែនឱ្យត្រួតខេត្តបាត់ដំបង កែបជាចៅហ្វាយខេត្តសៀមរាប និងកនជាចៅហ្វាយខេត្តពោធិ៍សាត់ ហើយត្រូវរាយការណ៍រាល់កិច្ចការទាំងឡាយ ដោយផ្ទាល់ឱ្យស្តេចក្រុងសៀម។ ព្រះអង្គអេងមានព្រះរាជបុត្រា៥ព្រះអង្គ គឺ៖ ព្រះអង្គចន្ទ ព្រះអង្គកឹម ព្រះអង្គស្ងួន ព្រះអង្គអិម និងព្រះអង្គឌួង។

សតវត្សទី១៨ ដែលជាសតវត្សចំណោះដឹងនៅទ្វីបអឺរ៉ុប តែសម្រាប់កម្ពុជា គឺជាសតវត្សនៃការធ្លាក់ចុះ ការបាត់បង់ឯករាជ្យ សង្គ្រាមដណ្តើមអំណាច និងសង្គ្រាមវាតទីនៃប្រទេសជិតខាង។ កម្ពុជានៅបន្តជាប្រទេសដែលមានសេដ្ឋកិច្ច និងរចនាសម្ព័ន្ធសង្គមបែបបុរាណ ស្ថាប័ននយោបាយទន់ខ្សោយ និងកង្វះខាតធនធានមនុស្ស ខ្វះនាហ្មឺនស្មោះត្រង់ មានសមត្ថភាពដែលអាចដឹកនាំប្រទេសជាតិបាន។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

៤-តើមូលហេតុអ្វីបានជាកម្ពុជាធ្លាក់នៅក្រោមការគ្រប់គ្រង និងត្រួតត្រារបស់សៀម និងវៀតណាមនៅក្នុងសតវត្សទី១៩?

នៅក្នុងបរិបទសាកលលោក សតវត្សទី១៩គឺជាសតវត្សឧស្សាហូប-នីកម្មនៅអង់គ្លេស ដែលផ្សព្វផ្សាយទៅប្រទេសផ្សេងទៀតនៅអឺរ៉ុប។ បន្ទាប់ពីសង្គ្រាមក្នុងស្រុក (១៨៦១-១៨៦៥) សហរដ្ឋអាមេរិកបានចាប់ផ្តើមអភិវឌ្ឍវិស័យឧស្សាហកម្ម ហើយជប៉ុនបានចាប់ផ្តើមយុគសម័យ«មេអ៊ីយិ» (Meiji) ដោយបើកទ្វារទទួលយកវិធីសាស្ត្រឧស្សាហកម្ម និងបច្ចេកវិទ្យាពីបស្ចិមប្រទេស ដោយផ្តោតជាសំខាន់លើផ្លូវដែក វាយនភ័ណ្ឌ និងពាណិជ្ជកម្ម។ ការអភិវឌ្ឍផ្តោតជាសំខាន់លើការវិនិយោគក្នុងវិស័យអប់រំ ជាពិសេសការអប់រំកម្រិតបឋមសិក្សា និងការអប់រំបច្ចេកទេស និងវិស្វកម្ម។

នៅសតវត្សទី១៩ អង់គ្លេស និងបារាំងបានចូលខ្លួនមកជំនួសព័រទុយហ្គាល់ និងហូឡង់នៅអាស៊ី។ អង់គ្លេសបានដាក់អាណានិគមលើឥណ្ឌានៅឆ្នាំ១៨៥៨ ហើយបារាំងបានចូលមកឧបទ្វីបឥណ្ឌូចិន នៅទសវត្សរ៍ឆ្នាំ១៨៦០។ ប្រទេសអឺរ៉ុបបានរៀបចំសន្ធិសីទនៅទីក្រុងប៊ែឡាំង នៅឆ្នាំ១៨៨៤-១៨៨៥ ដើម្បីបែងចែកទ្វីបអាហ្វ្រិក។ បារាំង និងអង់គ្លេសទទួលបានប្រទេសអាណានិគមច្រើនជាងគេ។

នៅក្នុងបរិបទកម្ពុជា សតវត្សទី១៩ គឺជាសតវត្សដែលកម្ពុជាបាត់បង់នូវឥស្សរភាព ជាប្រទេសឯករាជ្យ។ កម្ពុជាស្ទើរតែបាត់បង់ឈ្មោះពីផែនទីពិភពលោក។ សង្គ្រាមបានបំផ្លាញដល់ឫសគល់នូវវត្តអារាម ដែលជាកន្លែងបណ្តុះបណ្តាលធនធានមនុស្សដ៏តិចតួចស្ទួចស្តើងរបស់កម្ពុជា។ ក៏ប៉ុន្តែអក្សរសិល្ប៍ពុទ្ធនិយមខ្មែរបានឈានឡើងដល់កម្រិតកំពូល ដោយសារប្រជាជនត្រូវការស្នាដៃអក្សរសិល្ប៍ សម្រាប់កម្សាន្តរំដាប់ទុក្ខព្រួយ។

អំណាចក្នុងដែនាហ្មឺនធំ៖ ចាប់ពីឆ្នាំ១៧៩៦ដល់១៨០៥មក កិច្ចការប្រទេសស្ថិតនៅក្នុងដៃចៅហ្វាប៉ុក។ ពេលព្រះអង្គអេងចូលទិវង្គត ព្រះអង្គចន្ទជាព្រះរាជបុត្រទើបតែមានព្រះជន្មបាន៦វស្សា។ ដូចនេះកិច្ចការប្រទេស

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាតិត្រូវហៅហ្វ៊ីប៉ុកជាអ្នកទទួលបន្ទុក។ ព្រះអង្គចន្ទ (១៨០៦-១៨៣៦) ជាបុត្រអង្គអេង បានរៀបអភិសេកនៅឆ្នាំ១៨០៦ នៅទីក្រុងបាងកក ក្រោមអធិបតីភាពព្រះចៅរាមាទី២ ក្នុងព្រះជន្ម១៦ព្រះវស្សា ហើយស្តេចសៀមតែងតាំងអង្គស្វនជាមហាឧកញ៉ារាជ និងអង្គអិមជាមហាឧបរាជ។ ព្រះរាជវង្សានុវង្សជិតស្និទ្ធនឹងព្រះរាជាត្រូវឃាត់ទុកនៅបាងកក ដើម្បីឱ្យសៀមមានឥទ្ធិពលលើស្តេចខ្មែរ។ តែតេជោមឿង ចៅហ្វាយខេត្តកំពង់ស្វាយបដិសេធមិនព្រមបម្រើនៅក្រោមព្រះអង្គចន្ទ។ នៅក្នុងរជ្ជកាលនេះ វៀតណាមជ្រៀតជ្រែកចូលកម្ពុជាកាន់តែខ្លាំងឡើង។

ស្តេចខ្មែរពឹងសៀម និងវៀតណាមដើម្បីបានសោយរាជ្យ ៖ ចាប់ពីឆ្នាំ១៨១០ ការតស៊ូដណ្តើមអំណាចនៅក្នុងរាជវង្សានុវង្សកាន់តែខ្លាំងក្លា។ នៅខែកញ្ញា ឆ្នាំ១៨១០ ព្រះបាទអង្គចន្ទបានកាត់ទោសប្រហារជីវិតក្រឡាហោមមឿង និងចក្រីកែប ដែលប៉ុនប៉ងធ្វើឃាតព្រះអង្គ។ នៅឆ្នាំ១៨១១ ព្រះរាជបញ្ជូនទ័ពឱ្យទៅកម្ចាត់ចៅហ្វាយខេត្តកំពង់ស្វាយ មឿង។ មឿងក៏រត់ទៅប្រទេសសៀមបាត់។ នៅឆ្នាំ១៨១២ ជម្លោះដណ្តើមរាជ្យរវាងអង្គចន្ទ និងអង្គស្វនបានកើតឡើង។ អង្គស្វនបានទាំព្រះរាជវង្សានុវង្សទៅរស់នៅខេត្តពោធិ៍សាត់។ ដោយសង្ឃឹមថា ជាឧបាយកលរបស់សៀម ព្រះអង្គចន្ទបានសុំទ័ពពីវៀតណាម ៥០០នាក់មកការពារ។ ស្តេចសៀមក៏លើកទ័ពមកខេត្តពោធិ៍សាត់ ដើម្បីបញ្ជាក់ច្រាប់អង្គស្វនថា សៀមគាំទ្រព្រះអង្គ។ ទ័ពសៀមច្បាំងទ័ពវៀតណាមលើទឹកដីខ្មែរ ដើម្បីឱ្យស្តេចខ្មែរបានសោយរាជ្យរៀងៗខ្លួន។ ស្តេចអង្គចន្ទសុខចិត្តលើកសួយសារអាករថ្វាយស្តេចសៀមព្រះបាទព្រះរាមទី២ ទើបសៀមព្រមដកទ័ពចេញពីប្រទេសកម្ពុជា។ ថ្វីត្បិតតែស្តេចខ្មែរសុខចិត្តចំណុះឱ្យសៀម នៅឆ្នាំ១៨១៦ សៀមបានបញ្ជូនទ័ពមកកាន់កាប់ខេត្តកំពង់ស្វាយ។ ដូច្នេះ ពាក់កណ្តាលប្រទេសស្ថិតនៅក្រោមឥទ្ធិពលសៀម ហើយម្ខាងទៀតនៅក្រោមឥទ្ធិពលវៀតណាម។ ក្នុងរយៈពេល៦៩ឆ្នាំ សៀម និងវៀតណាមមិនបានច្បាំងគ្នាលើទឹកដីខ្មែរទៀត

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទេ។ ចាប់ពីពេលនោះមក ខ្មែរក្វាយខ្លួនជាចំណុះវៀតណាម ហើយនាំ
សួយសារអាករថ្វាយស្តេចយួនចំនួនបីឆ្នាំជាប់គ្នា។ ក្នុងរជ្ជកាលព្រះអង្គចន្ទ
កម្ពុជាកាន់តែចូលស៊ប់ក្នុងដង្ហើបរបស់វៀតណាម។ គេបានកេណ្ឌខ្មែរឱ្យ
ជីកព្រែកពីរនៅឆ្នាំ១៨១៣ ព្រែកវិញតេ ខ្មែរហៅថាព្រែកជីក ឬព្រែកយួន
ដែលភ្ជាប់ពីមាត់ជ្រូកទៅពាម ទម្លាក់ទៅក្នុងសមុទ្រចិនមានប្រវែង៥៣
គីឡូម៉ែត្រ ទទឹង៣៣ម៉ែត្រ។ ព្រែកជីកមួយទៀត ឈ្មោះព្រែកវិញអាន ខ្មែរ
ហៅថាឡុងសែន ភ្ជាប់ពីទន្លេបាសាក់ទៅមេគង្គមានប្រវែង១៤គីឡូម៉ែត្រ។
នៅពេលនោះហើយ ដែលគេហៅថា សម័យតែអុង។ ព្រះឧទ័យរាជាអង្គ
ចន្ទទ្រង់សុគតនៅឆ្នាំ១៨៣៤ ដោយរោគាពាធក្នុងព្រះជន្ម៦៤វស្សានៅ
ក្រុងឧដុង្គ។

ព្រះអង្គចន្ទមានបុត្រ៤អង្គ គឺក្សត្រីអង្គប៉ែន អង្គម៉ី អង្គពៅ និងអង្គ
សួន។ ព្រះអនុជរបស់ព្រះអង្គមានព្រះឧបរាជអង្គឯម អ្នកអង្គម្ចាស់អង្គឌួង
និងអង្គសួនវិញ អាណ្ណាមមិនយល់ព្រមឱ្យឡើងសោយរាជ្យទេ ព្រោះចូល
ដៃជាមួយសៀម និងរស់នៅស្រុកសៀម។ ក្រុមប្រឹក្សាព្រះរាជបល្ល័ង្កមិន
យល់ព្រមប្រគល់ព្រះរាជបល្ល័ង្កទៅឱ្យព្រះរាជបុត្រីច្បងរបស់ព្រះអង្គចន្ទ
ព្រះនាមប៉ែនឡើយ ព្រោះព្រះនាងត្រូវជាចៅរបស់ចៅហ្វាបែន ដែលបាន
លើកកូនស្រីថ្វាយព្រះរាជា ក្រោយពីបានប្រគល់ដីបាត់ដំបងឱ្យទៅសៀម
រួច។ គេបានឯកភាពគ្នាលើកព្រះអង្គម្ចាស់ក្សត្រីអង្គម៉ីឡើងសោយរាជ្យវិញ។
ព្រះអនុជក្សត្រីរបស់ព្រះនាង គឺព្រះអង្គពៅ ត្រូវបានលើកឱ្យឡើងធ្វើជា
ព្រះឧបរាជ។

កម្ពុជាក្រោមការត្រួតត្រាសៀម និងវៀតណាម ៖ ក្រោយពេលអង្គ
ចន្ទចូលទិវង្គតនៅឆ្នាំ១៨៣៤ វៀតណាមបានលើកក្សត្រីអង្គម៉ីឱ្យឡើងសោយ
រាជ្យ ដើម្បីកុំឱ្យគេយាងព្រះរាជ្យបុត្រពីសៀមមកសោយរាជ្យ។ សង្គ្រាម
រវាងវៀតណាម និងសៀមលើទឹកដីខ្មែរនៅតែបន្ត។ កម្ពុជាត្រូវបែងចែកជា
ពីរផ្នែក ដោយផ្នែកខាងក្រុងឧដុង្គស្ថិតនៅក្រោមការត្រួតត្រារបស់សៀម

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ហើយផ្នែកខាងត្បូងចតុមុខស្ថិតក្រោមការត្រួតត្រារបស់វៀតណាម។ ក្នុងរជ្ជកាលក្សត្រីអង្គម៊ី (១៨៣៤ - ១៨៤១) កិច្ចការប្រទេសជាតិត្រូវធ្លាក់ទៅក្នុងដៃឧត្តមសេនីយ ត្រឿងមិញយ៉ាង។ កម្ពុជាបន្តបាត់បង់ខេត្តខាងកើតជាបន្តបន្ទាប់ ដោយសារវៀតណាមដណ្តើមយក ចំណែកសៀមនៅទិសខាងលិចបានលេបយកខេត្តមហានគរ និងម្ហូព្រៃថែមទៀត។ ដើម្បីបញ្ចប់ទុក្ខវេទនារបស់ប្រជាជនខ្មែរ នាហ្មឺនអស់មុខមន្ត្រីក៏សម្រេចចិត្តទៅយាងព្រះបាទអង្គដួងពីប្រទេសសៀមមកឡើងសោយរាជ្យ។

សេដ្ឋកិច្ចចំណុះប្រទេសជិតខាង ៖ កម្ពុជាជាប្រទេសក្រីក្រខ្លាំង ដោយសារសេដ្ឋកិច្ចពឹងផ្អែកលើវិស័យកសិកម្មបែបបុរាណ សម្រាប់គ្រប់-គ្រាន់តែបរិភោគក្នុងស្រុក។ កម្ពុជាជាប្រទេស ដែលបិទទ្វារមិនទទួលឥទ្ធិ-ពលពីខាងក្រៅ។ ពាណិជ្ជកម្មក្រៅប្រទេសមានទំហំតិចតួច ដោយកម្ពុជានាំចេញតែភ្នុកដំរី ម្រេច ក្រវាញ ស្បែក និងខ្វឹមចន្ទន៍។ កម្ពុជាខ្ចីប្រមុះគេដកដង្ហើម ដោយពឹងផ្អែកទាំងស្រុងលើសេដ្ឋកិច្ចសៀម និងវៀតណាម។ ស្តេចខ្មែរមិនអាចជួបបរទេសបានទេ ប្រសិនបើគ្មានការអនុញ្ញាតពីសៀម និងវៀតណាម។

វប្បធម៌ជុនជាប ៖ ក្នុងអំឡុងស.វ.ទី១៩ នៅពេលដែលមានជម្លោះរវាងពួកសៀម និងពួកវៀតណាម ក្នុងការកាន់កាប់ត្រួតត្រាកម្ពុជា វប្បធម៌ខ្មែរគឺសឹងផុតរលត់ក៏ព្រោះថាវត្តអារាមត្រូវបានកម្ទេច និងបំផ្លាញចោល។

រដ្ឋបាលទន់ខ្សោយ ៖ ចតុស្តម្ភនៃរដ្ឋបាលសាធារណៈ គឺឧកញ៉ាយមរាជ ឧកញ៉ាវាំង ឧកញ៉ាក្រឡាហោម និងឧកញ៉ាចក្រី ក៏អាចជាអ្នកប្រាជ្ញបានដែរ។ ជានិច្ចជាកាល ព្រះមហាក្សត្រតែងតែជ្រើសរើសមន្ត្រី និងឧត្តមមន្ត្រី ក្នុងចំណោមអ្នកចេះដឹង និងកវីនិពន្ធ។ ឧត្តមមន្ត្រីគឺជាប្រកព និងជាសសរស្តម្ភនៃអំណាច និងភាពស្មោះត្រង់ ហើយកិច្ចដំណើរការរបស់រដ្ឋត្រូវប្រព្រឹត្តទៅតាមរយៈទំនាក់ទំនងជាបុគ្គល។ នៅពេលដែលធនធានមនុស្សទាំងនោះបាត់បង់ទៅប្រទេសជាតិក៏ថមថយដែរ។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រព័ន្ធអប់រំខ្មែរចុងក្រោយ ៖ ប្រព័ន្ធអប់រំនៃប្រទេសខ្មែរនៅដើមស.វ.ទី១៩ ត្រូវបានបំផ្លាញដល់ឫសគល់។ កម្ពុជានៅពេលនោះខ្វះអ្នកប្រាជ្ញ និងឧត្តមមន្ត្រីដែលមានប្រាជ្ញា ឋាមពល និងសមត្ថភាពដែលអាចជួយសង្គ្រោះប្រទេសជាតិឱ្យរួចចាកផុតពីគ្រោះមហន្តរាយបាន។

តាមការពិត ប្រព័ន្ធអប់រំនៅកម្ពុជាមុនស.វ.ទី២០ជាប្រព័ន្ធមួយ ដែលឈរលើមូលដ្ឋាននៃវចនាសម្ព័ន្ធសង្គម ដែលមិនមែនស្ថាប័នទេ តែគឺបុគ្គលជាអ្នកដើរតួនាទីឈានមុខនៅក្នុងរដ្ឋបាល។ ក្នុងប្រព័ន្ធអប់រំបែបប្រពៃណីនេះ ព្រះសង្ឃរាជ បព្វជិតព្រាហ្មណ៍ អ្នកប្រាជ្ញ ភរិនិពន្ធ គឺជាសសរស្តម្ភនៃប្រព័ន្ធអប់រំតាមបែបប្រពៃណី។ ព្រះបាទអង្គឌួងបានខិតខំប្រឹងប្រែងក្នុងការស្តារ និងកសាងប្រព័ន្ធអប់រំខ្មែរឡើងវិញ នៅក្នុងរជ្ជកាលរបស់ទ្រង់ ដោយស្តារឡើងវិញនូវព្រះពុទ្ធសាសនា និងសាលាវត្ត។

៥-អក្សរសិល្ប៍ខ្មែរសម័យឧដុង្គ

នៅដំណាក់កាលឧដុង្គ នៅស.វ.ទី១៧ និងទី១៨ នៅពេលដែលស្ថានភាពនយោបាយនៅកម្ពុជាកាន់តែមានសភាពយ៉ាប់យ៉ឺនទៅៗ ភរិនិពន្ធខ្មែរនៅបន្តខិតខំប្រឹងប្រែងបង្កើតស្នាដៃអក្សរសិល្ប៍ដែលល្អឥតខ្ចោះ។ ស្នាដៃអក្សរសិល្ប៍ត្រូវបានកត់ត្រាទុកលើក្រាំង ដែលជាសន្ធឹកក្រដាសស្ថាប់បត់ជាផ្នត់ និងលើស្លឹករឹត ដែលហៅថាសាស្ត្រា ដែលសរសេរជាពាក្យកាព្យ។ អក្សរសិល្ប៍សម័យកណ្តាលមានដូចជាសិលាចារឹក (សិលាចារឹកជ័យនន្ទ) របាក្សត្រ ឬព្រះរាជពង្សាវតារ ក្រម-ក្បួន-តម្រា (Les codes cambodgiens) ច្បាប់-សុភាសិត រឿងព្រេង រឿងល្បែង និងរឿកថា។

«ច្បាប់» គឺជាកំណាព្យទូន្មានប្រៀនប្រដៅ ដែលមានលក្ខណៈជាក្រមសីលធម៌ សម្រាប់ត្រង់ត្រាប់ តែគ្មានលក្ខណៈចាប់បង្ខំឡើយ។ ច្បាប់ទាំងនេះត្រូវបានតែងជាពាក្យកាព្យ ដើម្បីទាក់ទាញ និងឱ្យងាយទន្ទេញចាំមាត់។ ច្បាប់ខ្មែរមាន«ច្បាប់ពាក្យចាស់» «ច្បាប់មហាបដ្ឋាន «ច្បាប់ហៃ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មហាជន» «ច្បាប់សុភាសិត» «ច្បាប់បណ្តាំបិតា» «ច្បាប់ស្រី» «ច្បាប់អរិយសត្តា» «ច្បាប់វិធូបណ្ឌិត» «ច្បាប់ធម្មបាល»ជាដើម។

«សាស្ត្រាល្បែង» គឺជាអត្ថបទអក្សរសិល្ប៍ដែលពេញនិយមនៅសម័យឧដុង្គ។ រឿងល្បែងគឺជាស្នាដៃអក្សរសិល្ប៍ ដែលច្នៃប្រឌិតសម្រាប់ប្រលោមលួងលោមអារម្មណ៍អ្នកអានក្នុងកម្រងភាសាកំណាព្យដ៏ប្រណីត ពោលគឺជាកម្រងអត្ថបទរឿងរ៉ាវបែបប្រពៃណី ដែលតាក់តែងជាភាព្យឃ្លោងឡើងនៅរវាងស.វ.ទី១៨-១៩។ អ្នកនិពន្ធបំបែរគោលដៅទៅរកការអប់រំ ការសម្រាលទុក្ខសោកពោគភ័យមួយចំណែកធំរបស់មនុស្សជាតិ។ «សាស្ត្រាល្បែង» គឺសាស្ត្រាដែលអានសម្រាប់បន្ធូរចិត្តទុក្ខព្រួយ ចិត្តលំបាកតឹងតែងឱ្យធូរស្រាល។

«រឿងព្រេង» គឺជាការនិទាន សេចក្តីតំណាលតាមលំដាប់លំដោយដែលជូនតាយើងនិទានពីមាត់មួយទៅមាត់មួយជាយូរលង់ណាស់មកហើយ និងដែលឆ្លុះបញ្ចាំងឱ្យឃើញពីទំនៀមទម្លាប់ និងប្រពៃណីរបស់ជនជាតិខ្មែរយើង។ រឿងព្រេងទាំងអស់នេះត្រូវបានកត់ត្រាទុកដោយកវីបណ្ឌិតខ្មែរជាសំណេរលើស្លឹករឹត ឬលើក្រដាស ដើម្បីទុកជាកេរឱ្យខ្មែរជំនាន់ក្រោយ។ រឿងព្រេងភាគច្រើនត្រូវបានសរសេរជាពាក្យរាយ ហើយគ្មានកាលបរិច្ឆេទទេ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានចងក្រងរឿងព្រេងខ្មែរ និងបានបោះពុម្ពផ្សាយរហូតដល់ឆ្នាំ១៩៧២ ជា«ប្រជុំរឿងព្រេងខ្មែរ» ដែលមាន៨ភាគ និងមានរឿងទាំងអស់ចំនួន២១៦។

អ្នកនិពន្ធខ្មែរល្បីៗសម័យឧត្តុង្គមានដូចតទៅ៖

(១) អ្នក ប៉ាង តាត[18] គឺជាអ្នកនិពន្ធ ដែលសរសេរកំណាព្យ«ល្បើកអង្គរ» ជាបទព្រហ្មគីតិ បទកាកគតិ និងបទពំនោល ដែលអ្នកគ្រូ ពៅ សារវេស បានបកស្រាយតាមវិទ្យាសាស្ត្រនៃភាសាវិទ្យាថា សរសេរ

---

18 ម៉ុញ សារី (២០១១) *វចនានុក្រមអក្សរសិល្ប៍ខ្មែរ (Encyclopedia of Khmer Literature)* មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាកម្ពុជា ទំព័រ ១៦៦។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នៅឆ្នាំ១៦៦០[19]។ កំណាព្យនេះ ដែលសរសេរឡើងនៅពេលដែលប្រជាជនកម្ពុជាមានជំនឿលើព្រះពុទ្ធសាសនាថេរវាទ បានឆ្លុះបញ្ចាំងពីលទ្ធិសុខដុមនីយកម្មរវាងសាសនាព្រាហ្មណ៍ និងសាសនាព្រះពុទ្ធ[20]។

(២) ព្រះរាជសម្ភារ ដែលជារាជកវី ក្នុងស.វ.ទី១៧ (គ.ស.១៦០១-១៦៣១)។ ព្រះអង្គជាព្រះរាជបុត្រច្បងរបស់ព្រះបាទជ័យជេដ្ឋា និងអ្នកម្នាងសុន ដែលមានព្រះនាមថា ព្រះអង្គតូ ក្រោយមកជាព្រះស្រីធម្មរាជា។ ដោយមានវិបត្តិស្នេហាជាមួយព្រះនាងអង្គវតី ដែលជាមហេសីរបស់ស្តេចមា ព្រះបាទឧទ័យ ព្រះអង្គបានគៀសព្រះកាយទៅខេត្តក្រចេះ ហើយត្រូវបានទ័ពព័រទុយហ្គាល់ចាញ់សុគត។ ស្នាព្រះហស្តរបស់ព្រះអង្គមាន ច្បាប់រាជនីតិ កំណាព្យ«ច្បាប់រាជសម្ភារ» (ឆ្នាំ១៦៦២) លិខិតផ្ញើទៅថ្វាយព្រះម៉ែយូវត្តី ពាក្យកាព្យសរសេរលើចុងភ្នោត មុនពេលសុគតដោយទាហានព័រទុយហ្គាល់ចាញ់ កំណាព្យសរសើរហេមន្តមាស កំណាព្យ«កន្ទង់មាសមង្គលថ្លៃ» កំណាព្យ«ព្រលឹងមាសអើយ» ច្បាប់ក្រម និងច្បាប់ហោរាធជន ឬច្បាប់ត្រីនេត្រ[21]។

(៣) បណ្ឌិត ជ័យនន្ទ ជាកវី និងមន្ត្រីមួយរូប ដែលនិពន្ធកំណាព្យ (សិលាចារឹកទំនើបអង្គវត្ត K-34, K-38 ចំនួនប្រមាណ៤០ផ្ទាំង) នៅឆ្នាំ ១៧០១ ចុងរាជ្យព្រះរាជសម្ភារ។ លោកបានតែងសិលាចារឹកមួយ ដែលប្រកបដោយសម្ផស្សជើងកាព្យ ដែលអាចយកជាគំរូមេកាព្យបាន និងដែលអធិប្បាយជីវប្រវត្តិ និងសកម្មភាពរបស់ឧត្តមមន្ត្រីនៃព្រះមហាក្សត្រព្រះបាទជ័យជេដ្ឋាទី៣[22]។

---

19 *ល្បើកអង្គវត្ត* អារម្ភកថាដោយ *ឃីង ហុកឌី* (២០០៦) Editions Angkor *ទំព័រxi*។

20 Edwards, P. (2007), Cambodge: *The Cultivation of a Nation, 1860-1945*, University of Hawaii Press, Honolulu, p. 23.

21 *លាង ហាប់អាន (១៩៦៧) «ប្រវត្តិអក្សរសាស្ត្រ ខ្មែរៈ សម័យនគរភ្នំដល់សម័យឧដុង្គ (ស.វ.ទី១ដល់ទី១៩ទី៩)» ទំព័រ ២១៩-២៣០*។

22 V. Pou, Saveros, « Inscriptions Modernes d'Angkor Vat », (IMA34-38), BEFEO., t. LXII, Paris 1975:293…

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

(៤) ឧកញ៉ាកោសាធិបតី កៅ ជាកវីឯកក្នុងរជ្ជកាលព្រះបាទអង្គចន្ទទី៦។ លោកត្រូវបានតែងតាំងជាចៅហ្វាយឃ្វាំងមណីរតន៍ក្នុងព្រះបរមរាជវាំង និងជាទីប្រឹក្សាច្បាប់របស់ព្រះមហាក្សត្រ។ លោកបានសរសេររឿង «ក្រែងសុភមិត្រ» នៅឆ្នាំ១៧៩៨។

(៥) ឧកញ៉ាព្រះឃ្វាំង នង ជាប្អូនបង្កើតរបស់ព្រះមាតានៃព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម។ លោកបានបួសរៀន និងបានធ្វើជាចៅអធិការនៅវត្តចតុទិសនៃក្រុងឧដុង្គដោយបានទទួលសមណសក្តិជាមហាព្រហ្មមុនី។ ឧកញ៉ាព្រះឃ្វាំង នង ជាកវីឯកនៅក្នុងរាជ្យព្រះបាទអង្គអេង និងព្រះបាទអង្គចន្ទ។ លោកបានសរសេរស្នាដៃខាងអក្សរសាស្ត្រជាច្រើនរហូតដល់បានឡើងជារាជឧកញ៉ាព្រះឃ្វាំង ជាងារចាងហ្វាងក្រុមព្រះរាជបណ្ឌិត និងជាព្រះរាជនិពន្ធរបស់ព្រះរាជាទៀតផង។ ស្នាដៃរបស់លោកមាន ៖ ច្បាប់សុភាសិត(១៧៩០) លោកនយបករណ៍(១៧៩៦) បុញ្ញសារសិរសា (១៧៩៧) រឿង«កោគកុលកុមារ»(១៨០៦) វរនុជវរនេត្រ(១៨០៦) ព្រះសមុទ្រ(១៨០៨) និងពង្សាវតារ(១៨១៨)។

នៅមានកវីបណ្ឌិតជាច្រើនទៀត ដែលបាននិពន្ធស្នាដៃនៅក្នុងស.វ. ទី១៨-១៩ តែមិនបានដាក់ឈ្មោះនៅលើស្នាដៃអក្សរសិល្ប៍របស់ខ្លួន ដូចជារឿងពុទ្ធិសែន ព្រះសុជន ទិព្វសង្វារ ហង្សរុយន្ត រាជកុល រតនាវង្ស សង្ខសិល្ប៍ជ័យជាដើម។

នៅពេលដែលស្ថានភាពនយោបាយនៅកម្ពុជាកាន់តែអាក្រក់ទៅ កវីនិពន្ធនៅក្នុងសម័យឧដុង្គបានបង្កើតអក្សរសិល្ប៍ពុទ្ធនិយម គឺជាប្រភេទអក្សរសិល្ប៍ដែលតែងជាពាក្យកាព្យ តាមលំនាំសាច់រឿងនៃទសជាតក និងបញ្ញាសជាតកនៅក្នុងអំឡុងសតវត្សរ៍ទី១៨-១៩។ អក្សរសិល្ប៍កំណាព្យខ្មែរជាពិសេសអក្សរសិល្ប៍ពុទ្ធនិយមសម័យក្រោយអង្គរ ពិតជាកំណប់វិញ្ញាមហាសាលរបស់ខ្មែរពិតមែនៗ ការវិវត្តនៃអក្សរសិល្ប៍កំណាព្យខ្មែរឆ្ទុះបញ្ចាំងពីការវិវត្តនៃអក្សរសាស្ត្រខ្មែរជារួម ពីការសរសេរជាភាសាបាលី សំស្ក្រឹត និង

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ខ្មែរបុរាណ និងខ្មែរកណ្តាលមកសរសេរជាភាសាខ្មែរក្នុងចុងសតវត្សរ៍ទី១៩ និងដើមសតវត្សរ៍ទី២០ ទាំងការវិវត្តខាងផ្នែកក្បួនវេយ្យាករណ៍ ការសរសេរពាក្យជំសម្បុរណ៍បែប ដែលអាចចាត់ទុកជាបេតិកភណ្ឌអរូបីនៃជាតិខ្មែរយើង ការតែងកំណាព្យជាបទជំពូកនិងសទ្ទឹកសទ្ទាប់ ដែលឆ្លុះបញ្ចាំងពីភាពរស់រវើក និងការចេះច្នៃប្រឌិតរបស់កវីនិពន្ធខ្មែរ។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំពូក៧
ការកសាងជាតិឡើងវិញ ក្នុងរជ្ជកាលអង្គដួង

១-តើមូលហេតុអ្វីបានជាមន្ត្រីខ្មែរយាងព្រះចាទអង្គដួង ឱ្យឡើងសោយរាជ្យ?

ក្នុងអំឡុងស.វ.ទី១៨ នៅពេលដែលមានជម្លោះរវាងពួកសៀម និងពួកវៀតណាម ក្នុងការកាន់កាប់ត្រួតត្រាកម្ពុជា វប្បធម៌ខ្មែរគឺសឹងផុតរលត់ក៏ព្រោះថាវត្តអារាមត្រូវបានកម្ទេច និងបំផ្លាញចោល។ កម្ពុជានៅពេលនោះខ្វះអ្នកប្រាជ្ញ និងឧត្តមមន្ត្រីដែលមានប្រាជ្ញា ជាមពល និងសមត្ថភាពដែលអាចជួយសង្គ្រោះប្រទេសជាតិឱ្យរួចចាកផុតពីគ្រោះមហន្តរាយបាន។

កម្ពុជាក្នុងភាពអន្ទាក់៖ នៅដើមស.វ.ទី១៩ កម្ពុជាស្ទើរតែធ្លាក់ដល់ចំណុចសូន្យ ដោយសារតែសង្គ្រាមជាមួយសៀម និងវៀតណាម ព្រមទាំងការបះបោរនៅក្នុងស្រុកជាច្រើនទសវត្សរ៍។ នាម៉ឺនខ្មែរធំៗព្រមព្រៀងគ្នាទៅយាងព្រះចាទអង្គដួងពីប្រទេសសៀមឱ្យស្តេចយាងមកគ្រងរាជ្យស្រោចស្រង់ប្រទេសជាតិ។ ព្រះចៅសៀមទ្រង់យល់ព្រម និងបានចាត់ចៅពញាបឌិនដែលជាមេទ័ពឱ្យដង្ហែទ្រង់ត្រលប់មកវិញនៅឆ្នាំ១៨៦១។ ព្រះបាទអង្គដួងជាព្រះរាជបុត្រពៅនៃព្រះបាទអង្គអេង (គ.ស. ១៧៧៩-១៧៩៦) ដែលសៀមលើកឱ្យឡើងគ្រងរាជ្យពេលព្រះអង្គនៅមានជន្មាយុ៧ឆ្នាំក្រោមការ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឃុំគ្រងរបស់សៀម ហើយសៀមបានយកបុត្រព្រះអង្គទៅរស់នៅបាងកក ដើម្បីបន្តមានឥទ្ធិពលលើកម្ពុជា។ ដូច្នេះហើយទើបព្រះបាទអង្គឌួងបានក្លាយជាបុត្រចិញ្ចឹមរបស់ព្រះចៅរាមាទី១ ដែលជាអ្នកបង្កើតសន្តតិវង្សចក្រី (១៧៨២-១៨០៩)។ ក្រោយពីព្រះបាទអង្គអេងចូលទិវង្គត ព្រះបាទអង្គចន្ទទី២ (១៨០៦-១៨៣៤) ឡើងសោយរាជ្យ ហើយក៏ចាប់ផ្តើមប្រឆាំងនឹងសៀម ដោយសុំជំនួយពីវៀតណាម។ នៅពេលនោះហើយដែលវៀតណាមបានផ្តាច់យកទឹកដីខ្មែរនៅតំបន់ដីសណ្តទន្លេមេគង្គទាំងមូលតែម្តង។ នៅដើមទសវត្សរ៍ឆ្នាំ១៨៣០ សៀមចាប់ផ្តើមបង្កើនឥទ្ធិពលមកលើកម្ពុជា ហើយបានបញ្ជូនកងទ័ពមកបណ្តេញទ័ពវៀតណាម និងព្រះបាទអង្គចន្ទទី២ ចេញពីកម្ពុជា។ សៀមបានលើកបន្តុបព្រះរាមរបស់ព្រះបាទអង្គចន្ទទី២ ទាំងពីរដែលរស់នៅបាងកកឱ្យឡើងសោយរាជ្យ តែមិនទទួលបានទូវាការគាំទ្រពីប្រជាជនឡើយ។ បីឆ្នាំក្រោយមក វៀតណាមនាំព្រះបាទអង្គចន្ទទី២មកសោយរាជ្យនៅកម្ពុជាវិញ។ នៅពេលព្រះអង្គចូលទិវង្គត វៀតណាមបានលើកក្សត្រីអង្គម៉ី ដែលជាបុត្រីរបស់ព្រះបាទអង្គចន្ទទី២ ឱ្យឡើងសោយរាជ្យ។ នៅក្នុងរជ្ជកាលស្តេចអង្គម៉ី ប្រជាជនកម្ពុជាបានដើរបះបោរប្រឆាំងនឹងការធ្វើវៀតណាមការូបនីយកម្មនៃប្រទេសកម្ពុជា ដូចជាការរៀបចំរដ្ឋបាលកម្ពុជាឱ្យដូចវៀតណាម និងការដូរឈ្មោះខេត្តខ្មែរឱ្យទៅជាវៀតណាមជាដើម។ សង្គ្រាមជាមួយនឹងវៀតណាមបន្តទៀតពីឆ្នាំ១៨៤១ដល់១៨៤៩ តែមិនឈ្នះមិនចាញ់។ ទីបំផុត មេទ័ពខ្មែរ និងវៀតណាមក៏យល់ព្រមឈប់ប្រាំង ហើយលើកសម្តេចព្រះអង្គដួងឡើងសោយរាជ្យ។ ប្រទេសសៀម និងវៀតណាមបានចុះសន្ធិសញ្ញានៅខែធ្នូ ឆ្នាំ១៨៤៩ ដើម្បីប្រគល់រាជបល្ល័ង្កខ្មែរមកព្រះអង្គឌួងវិញ។ ព្រះបាទសម្តេចព្រះហរិរក្សរាមាអង្គឌួងបានឡើងគ្រងរាជសម្បត្តិនៅក្រុងឧដុង្គនៅឆ្នាំ១៨៤៧ ដោយមានតំណាងសៀម និងវៀតណាមជាអធិបតី។ ចាប់តាំងពីពេលនោះមក ប្រទេសខ្មែរបានស្គាល់នូវសុខសន្តិភាពបរិបូណ៌ ជាហេតុឱ្យព្រះអង្គអាចដាក់ចេញនូវកំណែទម្រង់

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

រដ្ឋ និងបានកសាងឡើងវិញនូវប្រព័ន្ធអប់រំ។

២-តើព្រះបាទអង្គដួងបានបន្សល់មត៌កអ្វីខ្លះសម្រាប់កម្ពុជា?

ព្រះបាទហរិរក្សរាមាតស្សរាធិបតីអង្គដួង ជាព្រះរាជាដែលប្រកបដោយទសពិធរាជធម៌ ដែលយកព្រះទ័យទុកដាក់ដល់ការស្តារសន្តិភាពឡើងវិញ ការអភិវឌ្ឍកម្ពុជា និងបង្កើតនូវប្រព័ន្ធរាជការថ្មីមួយ។ សង្គ្រាមបាននាំមកនូវមហន្តរាយ ដោយសារភូមិស្រុកត្រូវបានដុតបំផ្លាញ ដីស្រែចម្ការត្រូវចោះបង់ចោល ផ្លូវថ្នល់ និងស្ពានរងការខូចខាតជាដំណាំ។ អសន្តិសុខកើតមានឡើងលើផ្ទៃប្រទេស ប្រជាជនជួបទុរភិក្ស។

កំណែទម្រង់ព្រះបាទអង្គដួង ៖ ការកសាងប្រទេសនៅក្នុងស.វ. ទី១៩បានចាប់ផ្តើមដំបូងដោយ ៖ (១) លើកតម្កើងជាថ្មីនូវព្រះពុទ្ធសាសនា ដោយស្តារឡើងវិញនូវព្រះពុទ្ធសាសនា និងសាលាវត្ត និងបង្រៀនព្រះត្រៃបិដក និងបញ្ជាឱ្យកុមារចូលរៀនសាលាវត្ត (២) សាងសង់សាលាទានសម្រាប់ធ្វើសង្ឃទាន និងធ្វើទានដល់ជនក្រីក្រ (៣) កែច្បាប់ និងតាក់តែងច្បាប់ថ្មី (៤) ជ្រើសតាំងជាមន្ត្រីអ្នកដែលមានចំណេះវិជ្ជាជ្រៅជ្រះ (៥) ដាក់ទណ្ឌកម្មដល់មន្ត្រីជក់អាភៀន និងទុច្ចរិត (៦) មិនយកពន្ធពីការស្ត្រី និងមិនយកការប្រាក់ធ្ងន់ពេក (៧) ចោះប្រាក់សម្រាប់ចាយ (៨) សាងសង់ផ្លូវពីឧដុង្គទៅកំពត កសាងកំពង់ផែសមុទ្រ និងសាងសង់សំពៅសម្រាប់ដឹកទំនិញទៅលក់នៅសិង្ហបុរី (៩) បញ្ជូននិស្សិតទៅរៀនភាសាបារាំង និងអង់គ្លេសនៅសិង្ហបុរី សម្រាប់បម្រើការងារក្នុងរាជការ។

ការកសាងព្រះពុទ្ធសាសនា ៖ ព្រះបាទអង្គដួងបានចាត់ទុកវិស័យព្រះពុទ្ធសាសនាជាផ្នែកមួយដ៏សំខាន់ក្នុងការធ្វើឱ្យមានសន្តិភាព និងការរស់ឡើងវិញនៃកម្ពុជា។ ព្រះអង្គមានព្រះរាជបញ្ជាឱ្យប្រមូលនូវពុទ្ធវចនៈទាំងឡាយ មានគម្ពីរព្រះត្រៃបិដកជាដើម។ ការលើកតម្កើងជាថ្មីនៃវិស័យព្រះពុទ្ធសាសនានៅកម្ពុជា និងជួយក្នុងការបង្កើតលក្ខណ្ឌចាំបាច់ក្នុងការ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កសាងឡើងវិញនូវវិស័យអប់រំ។

ការគ្រប់គ្រងប្រទេស ៖ ព្រះបាទអង្គដួងបានកែទម្រង់រដ្ឋបាលបុរាណ របស់ខ្មែរឱ្យមានលក្ខណៈទំនើប ពង្រឹងសណ្តាប់ធ្នាប់សង្គម និងសន្តិសុខ សង្គមលើផ្ទៃប្រទេស។ ព្រះអង្គរៀបចំឱ្យមានសវនាការយ៉ាងទៀងទាត់ ជាមួយនាហ្មឺនសព្វមុខមន្ត្រី ដើម្បីពិភាក្សា និងដោះស្រាយបញ្ហាធំៗរបស់ ប្រទេសជាតិ។ ព្រះអង្គតែងតែយកព្រះទ័យទុកដាក់ដោះស្រាយពាក្យ បណ្តឹងរបស់ប្រជាជន និងបានសុំឱ្យអ្នកប្រាជ្ញខ្មែរពិនិត្យច្បាប់ពីបរមបុរាណ ឡើងវិញ ជាពិសេសក្រមនីតិសាស្ត្ររបស់ព្រះបាទជ័យជេដ្ឋា ចាប់តាំង ពីសតវត្សទី១៧ និងដើមសតវត្សទី១៨ ហើយដែលបង្កើតបានជាកម្រង ច្បាប់ ដែលមានឈ្មោះថា ក្រមកម្ពុជា (Les codes cambodgiens) ដែល ក្លាយទៅជាមូលដ្ឋាននៃប្រព័ន្ធយុត្តិធម៌របស់កម្ពុជាមុនសម័យបារាំង។ កម្រង ច្បាប់កម្ពុជាមានចំនួន១៥០០ទំព័រត្រូវបានបោះពុម្ពនៅឆ្នាំ១៨៩១ ដែល ចែកចេញជា២៨ក្បាល។

កំណែទម្រង់សេដ្ឋកិច្ច ៖ ព្រះបាទអង្គដួងបានកែទម្រង់ការគ្រប់គ្រង សេដ្ឋកិច្ចរបស់កម្ពុជាឱ្យមានលក្ខណៈទំនើប លើកកម្ពស់ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស កាត់បន្ថយបន្ទុកពន្ធដារទៅលើប្រជាជនក្រីក្ររបស់ព្រះ អង្គ និងរៀបចំបោះកាក់ប្រាក់ ដែលមានរូបហង្សជាសញ្ញា ដើម្បីប្រើប្រាស់ ទូទាំងប្រទេស។ ព្រះអង្គបញ្ជាឱ្យសាងសង់ផ្លូវពីក្រុងឧដុង្គទៅកាន់កំពង់ផែ ទន្លេទៅកំពង់ហ្លួងនៅឆ្នាំ១៨៥៦ និងសាងសង់ផ្លូវស្តេចក្លាប់ឧដុង្គមានជ័យ ទៅនឹងកំពង់ផែសមុទ្រ ហើយនៅឆ្នាំ១៨៥៧ ព្រះអង្គបានសាងសង់ផ្លូវពី ឧដុង្គមានជ័យទៅភ្នំពេញ។

កិច្ចការបរទេស ៖ ព្រះបាទអង្គដួងមានការព្រួយបារម្ភថា ថ្ងៃណាមួយ កម្ពុជាអាចនឹងត្រូវប្រទេសជិតខាងលេបត្របាក់បាត់ពីផែនទីពិភពលោក។ ព្រះអង្គក៏បានធ្វើញត្តិមួយទៅកាន់ព្រះចៅណាប៉ូឡេអុងទី៣ ស្នើសុំបារាំង ជួយរំដោះប្រទេសខ្មែរចេញពីឥទ្ធិពលសៀម និងវៀតណាម តែមិនបាន

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទទួលចម្ងើយអ្វី។

ការដើបឡើងនៃវប្បធម៌ជាតិ ៖ អក្សរកម្មភាសាខ្មែរមានវិបុលភាពជាខ្លាំងក្នុងរជ្ជកាលព្រះបាទអង្គឌួង ហើយទ្រង់ព្រះអង្គឯងក៏ជាអ្នកនិពន្ធដ៏ល្បីល្បាញផងដែរ។ ស្នាព្រះហស្តរបស់ព្រះអង្គមាន ៖ រឿងចម្ប៉ាជោង (១៨១០) រឿងកាកី (១៨១៥-នៅពេលទ្រង់មានព្រះជន្ម១៨វស្សានៅឡើយ) និងច្បាប់ស្រី (១៨៣៧)។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំពូក៨
អាណាព្យាបាលបារាំង

១-តើមូលហេតុអ្វីបានជាបារាំងចូលមកកាន់កាប់កម្ពុជា?

បារាំងចូលមកកាន់កាប់ដែនកូសាំងស៊ីន ៖ នៅដើមសតវត្សទី១៩ ក្នុងរជ្ជកាលព្រះចៅអធិរាជមិញម៉ាង (Minh Mang) (១៨២០-១៨៤១) ធៀវត្រី (Thieu Tri) (១៨៤១-១៨៤៧) និងធូឌឹក (Tu Duc) (១៨៤៧-១៨៨៣) រាជការវៀតណាមបានធ្វើទុក្ខបុកម្នេញយ៉ាងខ្លាំងចំពោះសាសនិកសាសនាគ្រិស្តនៅវៀតណាម។ ដោយយកលេសពីការធ្វើទុក្ខបុកម្នេញនេះ បារាំងបានបញ្ជូនកងទ័ពមកប្រទេសវៀតណាមក្នុងឆ្នាំ១៨៥៨ ដោយសហការជាមួយប្រទេសអេស្ប៉ាញ ដើម្បីជួយសង្គ្រោះបេសកជនសាសនាគ្រិស្ត។ បន្ទាប់ពីធ្វើសង្គ្រាមជាមួយវៀតណាមក្នុងរយៈពេលបួនឆ្នាំ បារាំងបានចុះសន្ធិសញ្ញាជាមួយព្រះចៅអធិរាជធូឌឹក (Tu Duc) ក្នុងឆ្នាំ១៨៦២ ដែលមានលក្ខខណ្ឌដូចតទៅ ៖ (១) កាត់ខេត្តចំនួនបីនៃតំបន់យ៉ាឌីញ ដែលមានឈ្មោះថា កូសាំងស៊ីន (Cochinchine) រួមទាំងទីក្រុងព្រៃនគរផង ទៅឱ្យបារាំង (២) បើកសិទ្ធិឱ្យបារាំងប្រើប្រាស់កំពង់ផែវៀតណាមចំនួន៣ (៣) បង់សំណងឱ្យបារាំងចំនួន៤លានពីយ៉ាស្លេ (៤) មិនធ្វើទុក្ខបុកម្នេញដល់សាសនាគ្រិស្ត និង (៥) ផ្តល់សិទ្ធិដល់បារាំងក្នុងការធ្វើនាវាចរណ៍នៅតាមដងទន្លេមេគង្គ។

ការប្រណាំងប្រជែងជាមួយអង់គ្លេស និងដំណើរឆ្ពោះទៅរកចិនភាគ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ខាងត្បូង ៖ បំណងពិតរបស់បារាំងក្នុងការធ្វើសង្គ្រាមជាមួយវៀតណាម គឺដើម្បីគ្រប់គ្រងតំបន់កូសាំងស៊ីន និងទទួលសិទ្ធិក្នុងការធ្វើដំណើរលើដងទន្លេមេគង្គ ដែលពេលនោះបារាំងស្មានថា មានប្រភពមកពីប្រទេសចិនភាគនិរតី។ គោលដៅរបស់បារាំង គឺវាយចូលប្រទេសចិនតាមដងទន្លេមេគង្គ។ បារាំងបានបញ្ជូនទាហានកងទ័ពជើងទឹកពីរូប ដើម្បីធ្វើការស្រាវជ្រាវផ្លូវទឹកទន្លេមេគង្គ គឺ Francis Garnier និង Doudart de Lagrée។ ម្យ៉ាងវិញទៀត អង់គ្លេសបានបោះទីតាំងនៅប្រទេសសៀម ក្នុងគោលដៅពង្រីកឥទ្ធិពលនៅអាស៊ីអាគ្នេយ៍។ ដូច្នេះ បារាំងត្រូវកាត់ផ្តាច់កម្ពុជាចេញពីឥទ្ធិពលអង់គ្លេស។

មានតែប្រទេសចិន និងថៃប៉ុណ្ណោះដែលគេចផុតពីទឹមអាណានិគមនិយម។ បន្ទាប់ពីចាញ់សង្គ្រាមអាភៀនជាមួយអង់គ្លេសនៅឆ្នាំ១៨៣៩-៦២ និង១៨៥៦-៦០ (ដោយសារអង់គ្លេសចង់មានសេរីភាពក្នុងការធ្វើពាណិជ្ជកម្មអាភៀនដែលផ្តល់ប្រាក់ចំណេញខ្ពស់) ចិនត្រូវប្រគល់ហុងកុងឱ្យទៅអង់គ្លេសជាសំណង។

ការយកចិត្តទុកដាក់របស់បារាំងដល់វប្បធម៌ខ្មែរ ៖ នៅស.វ.ទី១៩ បារាំងបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើសម្បត្តិវប្បធម៌ ជាពិសេសសម្បត្តិវប្បធម៌នៅប្រទេសអាណានិគម។ នៅក្នុងសម័យអាណាព្យាបាលអ្នកស្រាវជ្រាវបារាំងជាច្រើនបានចូលរួមចំណែកក្នុងការស្រាវជ្រាវ និងអភិរក្សវប្បធម៌ និងអរិយធម៌ខ្មែរ។ ដូច្នេះហើយទើបមានអ្នកស្រាវជ្រាវបារាំងជាច្រើនបានមកដល់កម្ពុជា។ ជនជាតិបារាំងទី១ ដែលទៅទស្សនាអង្គរគឺលោក Henri Mouhot ដែលបានទៅដល់ទីនោះនៅឆ្នាំ១៨៦០ និងបានបោះពុម្ពផ្សាយពីដំណើររបស់លោកពីព្រៃនគរទៅអង្គរនៅក្នុង Revue Maritime et Coloniale ក្នុងឆ្នាំ១៨៦៣។ ក្នុងរយៈពេលបម្រើការងារនៅកម្ពុជា តំណាងជាន់ខ្ពស់បារាំងប្រចាំកម្ពុជាក្នុងឆ្នាំ១៨៦៦-១៨៦៥ លោក Doudart de Lagrée បានធ្វើដំណើរទៅអង្គរ ដើម្បីទៅសិក្សាពីប្រភពវប្បធម៌

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

និងអរិយធម៌ខ្មែរផងដែរ។ បន្ទាប់ពីបានសិក្សាស្រាវជ្រាវពីអង្គរអស់ជាច្រើនឆ្នាំ បុរាណវិទូបារាំងលោក Louis Delaporte បានប្រមូលនូវពុម្ពចម្លាក់អង្គរ ដើម្បីចូលរួមក្នុងពិព័រណ៍សកលលោក (Exposition universelle) ក្នុងឆ្នាំ ១៨៧៨ ដែលធ្វើឱ្យប្រាសាទអង្គរកាន់តែមានកិត្តិនាមល្បីរន្ទឺសុសសាយខ្លាំងឡើង។

២-តើអាណាព្យាបាលបារាំងនៅកម្ពុជាអាចចែកចេញជាប៉ុន្មានដំណាក់កាល?

ព្រះបាទនរោត្តម

ព្រះបាទនរោត្តមឡើងសោយរាជ្យនៅឆ្នាំ១៨៦០ នៅពេលដែលព្រះបាទអង្គដួងសោយទិវង្គត។ ព្រះបាទអង្គដួងមានបុត្របីអង្គ។ បុត្រទីបី អ្នកអង្គម្ចាស់ស៊ីវុត្ថា បានចាប់ផ្តើមបះបោរដណ្តើមរាជ្យ តែត្រូវបានសម្រប-សម្រួល។ ព្រះបាទនរោត្តមទទួលការអប់រំនៅបាងកក។ ព្រះអង្គយាងចេញពីឧដុង្គមានជ័យមកគង់នៅទីក្រុងភ្នំពេញ នៅឆ្នាំ១៨៦៦។ នៅពេលនោះបារាំងមានបំណងបង្កើតទំនាក់ទំនងពាណិជ្ជកម្មជាមួយកម្ពុជា និងយល់ថា អាចធ្វើដំណើរទៅប្រទេសចិនតាមដងទន្លេមេគង្គ។ កម្ពុជាគ្មានផែនទីសម្រាប់សម្គាល់ព្រំដែនឡើយ។ ប្រជាជនកម្ពុជានៅពេលនោះមានចំនួនប្រមាណជា១លាននាក់តែប៉ុណ្ណោះ។

ដំណាក់កាលទី១នៃអាណាព្យាបាលបារាំង ១៨៦៣-១៨៨៣ ៖ នៅឆ្នាំ១៨៦២ អគ្គទេសាភិបាលកូសាំងស៊ីនបានធ្វើដំណើរមកកម្ពុជា ដើម្បីជួបព្រះបាទនរោត្តម និងវាយតម្លៃពីស្ថានភាពកសិកម្ម ពាណិជ្ជកម្ម និងទំនាក់ទំនងរវាងកម្ពុជាជាមួយសៀម។ បន្ទាប់មក នៅក្នុងឆ្នាំ១៨៦៣ អគ្គទេសាភិបាលកូសាំងស៊ីនថ្មី ឧត្តមនាវី La Grandière បានសន្យាជាក់កម្ពុជាក្រោមកិច្ចការពាររបស់បារាំង។ ព្រះបាទនរោត្តមអល់អែក ដោយសារខ្លាចសៀមផង និងខ្លាចបារាំងមិនអាចការពារកម្ពុជាបាន បណ្តោយឱ្យវៀតណាម

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

លេបបាត់។ តែទីបំផុត ព្រះអង្គយល់ព្រមចុះសន្ធិសញ្ញាអាណាព្យាបាលបារាំង-កម្ពុជាចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣។ អាណាព្យាបាលនេះអនុញ្ញាតឱ្យប្រទេសបារាំងមកឈរជើងនៅប្រទេសកម្ពុជា ដើម្បីឡើងបន្តទៅកាន់ប្រទេសចិនតាមទន្លេមេគង្គ។ សន្ធិសញ្ញានេះអនុញ្ញាតឱ្យប្រទេសកម្ពុជារួចផុតពីការត្រួតត្រា (Suzerainteté) ត្រួតគ្នារបស់សៀម និងវៀតណាម។ អនុលោមតាមសន្ធិសញ្ញានេះ បារាំងសន្យាការពារកម្ពុជាពីចលាចលផ្ទៃក្នុង និងការវាយប្រហារពីខាងក្រៅ (មាត្រា១ និង១៦)។ ដូច្នេះ ការភ័យខ្លាចរបស់ព្រះបាទអង្គឌួង ដែលថានៅថ្ងៃណាមួយនាពេលអនាគត ប្រទេសកម្ពុជានឹងត្រូវលប់បាត់ចេញពីផែនទីនោះ នឹងលែងមានហើយ។ អនុលោមតាមសន្ធិសញ្ញាឆ្នាំ១៨៦៣នេះ បារាំងបានដើរតួជាអ្នកស្នងអធិរាជអាណ្ណាមហើយ«អធិរាជរបស់ជនជាតិបារាំងព្រមផ្តល់ការគាំពារដល់ព្រះមហាក្សត្រកម្ពុជា»។ បារាំង«យល់ព្រមប្រែក្លាយទៅជាអាណាព្យាបាលដើម្បីការពារសិទ្ធិក្នុងការត្រួតត្រា (Droits de Suzerainteté)» ដែលខ្លួនទទួលបានក្រោយស្នងបន្តនៅក្នុងបណ្តាខេត្តកូសាំងស៊ីនពីអធិរាជអាណ្ណាម ដែលក្សត្រកម្ពុជាធ្លាប់បង់សួយសារអាករជូនតាំងពីឆ្នាំ១៨០៧មក។ បារាំងមានអ្នកតំណាងម្នាក់នៅអមព្រះមហាក្សត្រកម្ពុជា ដែលជាវ៉ាស៊ីដង់ជាតិបារាំង ដែលដាក់«ឱ្យនៅក្រោមសមត្ថកិច្ចជាន់ខ្ពស់របស់ទេសាភិបាលកូសាំងស៊ីន» (មាត្រា២)។ តាមទស្សនៈគតិយុត្តិ គេអាចកត់សម្គាល់បានថា ចាប់ពីមានសន្ធិសញ្ញាឆ្នាំ១៨៦៣ និងសន្ធិសញ្ញាផ្សេងៗបន្តបន្ទាប់មក ទឹកដីកូសាំងស៊ីនបានត្រូវគេចាត់ទុកជាអាណានិគមបារាំង រីឯកម្ពុជា អាណ្ណាម និងតុងកឹងបិតក្រោមរបបអាណាព្យាបាល។

ក៏ប៉ុន្តែ បារាំងមិនបានផ្តល់សច្ចាប័នដល់សន្ធិសញ្ញាអាណាព្យាបាលនេះទាន់ពេលឡើយ។ ស្ថិតនៅក្នុងសភាពគំរាមកំហែងពីការបះបោររបស់អ្នកអង្គម្ចាស់ស៊ីវុត្ថា ព្រះបាទនរោត្តមក៏ចុះហត្ថលេខាលើសន្ធិសញ្ញាមួយទៀតជាមួយប្រទេសសៀម ដោយប្រគល់ឱ្យសៀមការកិច្ចបង្ក្រាបចលនា

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បះបោរ ស្តារស្ថានភាពក្នុងប្រទេសឱ្យសុខសាន្តត្រាណឡើងវិញ និង ដោះស្រាយរាល់វិវាទជាមួយមហាអំណាចបរទេស (មាត្រា១)។ ស្តេចសៀម ទទួលបានខ្លះអំណាចតែងតាំងអភិបាលលើទឹកដីកម្ពុជា (មាត្រា៦ និង៧)។ ខេត្តបាត់ដំបង និងអង្គរត្រូវបានកាត់ទៅឱ្យសៀម ហើយការប្រគល់ឱ្យខេត្ត ពោធិ៍សាត់ និងខេត្តកំពង់ស្វាយ ដែលពួកសៀមបានកាន់កាប់នាពេលស្តេច ស៊ីវុត្ថាបះបោរ ត្រូវភ្ជាប់លក្ខខណ្ឌទៅនឹង«ឥរិយាបថល្អ»របស់ក្សត្រកម្ពុជា។ ដូច្នេះ សន្ធិសញ្ញាសម្ងាត់នេះបង្ហាញទន្ទ:របស់ព្រះបាទ នរោត្តម ក្នុងការ ដឹកនាំនយោបាយរកតុល្យភាពរវាងបារាំង និងសៀមផងដែរ។

បារាំងបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាអាណាព្យាបាលបារាំង-ខ្មែរ នៅខែមីនា ឆ្នាំ១៨៦៤។ បន្ទាប់ពីដឹងពីសន្ធិសញ្ញាសម្ងាត់ខ្មែរ-សៀម បារាំង បានជាក់សម្ពាធលើសៀម ហើយចុះហត្ថលេខាលើសន្ធិសញ្ញាចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៦៧ ជាមួយសៀមនៅទីក្រុងបារីស ដែលតាមរយៈនោះ ស្តេចសៀមទទួលស្គាល់អាណាព្យាបាលបារាំងនៅកម្ពុជា (មាត្រា១) ហើយ សន្ធិសញ្ញាសម្ងាត់ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៨៦៣ ត្រូវបានប្រកាសថាជាមោឃៈ (មាត្រា២)។ ជាថ្នូរមកវិញ បារាំងទទួលស្គាល់ការត្រួតត្រារបស់សៀមលើ ទឹកដីបាត់ដំបង និងអង្គរ។ ជាក់ស្តែង ខេត្តបាត់ដំបួ (បាត់ដំបង) និងអង្គរ (សៀមរាប) នៅតែជាកម្មសិទ្ធិរបស់ព្រះរាជាណាចក្រសៀម (មាត្រា៤)។ សៀមនឹងប្តេជ្ញាមិនទន្ទ្រានយកទឹកដីកម្ពុជាឡើយ (មាត្រា៥)។ រដ្ឋមន្ត្រី ក្រសួងការបរទេសបារាំងបានរំពឹងថា វាមានប្រយោជន៍ណាស់សម្រាប់បារាំង ក្នុងការធ្វើសម្បទាន ដោយផ្ទាស់ប្តូរការទទួលស្គាល់អាណាព្យាបាលរបស់ បារាំងនៅកម្ពុជាជាមួយនឹងការកាត់ខេត្តទាំងពីរនេះទៅឱ្យសៀម។

ការបះបោរប្រឆាំងបារាំង ៖ បន្ទាប់ពីបារាំងចូលកាន់កាប់ស្រុកខ្មែរ មានចលនាបះបោរធំៗពីរប្រឆាំងបារាំង៖ (១) ការបះបោរបស់អាចារ្យស្វា ឬ សូរ (១៨៥៩-១៨៦៦) ដោយសារការបាត់បង់ខេត្តពីរបស់ខ្មែរផង និង (២) ការបះបោររបស់ ពោធិកំបោរ (១៨៦៥-១៨៦៧) នៅផ្នែកខាងកើត។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការបះបោរទាំងពីរត្រូវបានបាក់ទបង្ក្រាប។

ដំណាក់កាលទី៦នៃអាណាព្យាបាលបារាំង ១៨៨៤-១៩៥៣ ៖ នៅក្នុងឆ្នាំ១៨៨៤ ស្ថិតនៅក្រោមការគំរាមប្រើកម្លាំង បារាំងបានបង្ខំឱ្យកម្ពុជាចុះអនុសញ្ញាទី២មួយទៀត ដើម្បីបង្កើតសហភាពគយរវាងកម្ពុជា កូសាំងស៊ីន អាណ្ណាម និងតុងកឹង។ អនុសញ្ញានេះត្រូវបានព្រះមហាក្សត្រកម្ពុជាឡាយព្រះហស្តលេខានាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤។ យោងតាមខ្លឹមសារនៃអនុសញ្ញានេះ ៖ «មហាក្សត្រខ្មែរយល់ព្រមទទួលកំណែទម្រង់រដ្ឋបាលតុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្មគ្រប់រូបភាព ដែលរដ្ឋាភិបាលនៃសាធារណៈរដ្ឋបារាំងវិនិច្ឆ័យ ថាមានប្រយោជន៍ទៅថ្ងៃមុខ ដើម្បីសម្រួលដល់ការបំពេញអាណាព្យាបាលភាពរបស់ខ្លួន» (មាត្រា១)។ ផលវិបាកគតិយុត្តិនៃអនុសញ្ញានេះ គឺ ៖ (៦) ការដកអំណាចពីព្រះមហាក្សត្រ និងរាជវង្សានុវង្ស ដែលចែកគ្នាត្រួតត្រាលើខេត្ត ហើយបង្កើតប្រព័ន្ធរដ្ឋបាលទំនើប ស្ថិតក្រោមការគ្រប់គ្រងរបស់អ៊ើស៊ីដង់ជាន់ខ្ពស់បារាំង (៦) កំណែទម្រង់ការប្រមូលពន្ធពីប្រព័ន្ធប្រមូលពន្ធយកទៅប្រើក្នុងរាជរាំងទៅប្រព័ន្ធពន្ធសម្រាប់ចំណាយថវិកាជាតិ ជាពិសេសសម្រាប់សាងសង់ផ្លូវ (៣) ការបង្កើតកម្មសិទ្ធិដី ដែលពីមុនជាដីរបស់ព្រះរាជា មកជាកម្មសិទ្ធិរដ្ឋ និងកម្មសិទ្ធិឯកជន។ កំណែទម្រង់តុលាការផ្តោតទៅលើការបង្កើតតុលាការវិជ្ជាជីវៈ ហើយកំណែទម្រង់ពាណិជ្ជកម្ម មានគោលដៅកាត់ផ្តាច់សិទ្ធិផ្តាច់មុខរបស់រាជរាំងលើពាណិជ្ជកម្ម។

បន្ទាប់ពីបាត់បង់អំណាច ព្រះបាទនរោត្តម លែងសហការជាមួយបារាំង ហើយបានឱ្យព្រះអនុជស៊ីវុត្ថា បះបោរប្រឆាំងបារាំង។ ការបះបោរយ៉ាងខ្លាំងក្លាធ្វើឱ្យមានអសន្តិសុខកើតឡើងទូទាំងប្រទេស ធ្វើឱ្យព្រះបាទនរោត្តមព្រួយខ្លាចព្រះអនុជឡើងសោយរាជ្យ ក៏ចាប់សហការជាមួយបារាំងវិញ។ បារាំងក៏ចាប់ផ្តើមពង្រឹងអំណាចរបស់ព្រះបាទនរោត្តម ដើម្បីទប់ទល់នឹងព្រះអនុជ ដែលចូលទិវង្គតទៅព្រះជន្មាយុ៦០ឆ្នាំ។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កំណែទម្រង់ការគ្រប់គ្រងរដ្ឋ ៖ សន្ធិសញ្ញាបាំង-ខ្មែរឆ្នាំ១៨៨៦ បានប្រគល់អំណាចឱ្យបារាំងក្នុងការគ្រប់គ្រងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា រួមទាំងវិធានការកំណែទម្រង់រដ្ឋផងដែរ ដែលក្នុងនោះការរៀបចំប្រព័ន្ធរដ្ឋបាលគ្រប់គ្រង និងប្រព័ន្ធអប់រំបានទាំឱ្យមានការផ្លាស់ប្តូរជាច្រើន។ ក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រឹត្តិការណ៍សំខាន់គឺការបង្កើតសហព័ន្ធឥណ្ឌូចិននៅឆ្នាំ១៨៩៨ ដែលបង្រួបបង្រួមដែនដីអាណានិគម និងអាណាព្យាបាលបារាំងនៅឥណ្ឌូចិន ដូចជាកម្ពុជា តុងកឹង អាណ្ណាម កូសាំងស៊ីន និងឡាវឱ្យស្ថិតនៅក្នុងសហភាពរូបិយវត្ថុ និងរដ្ឋបាលតែមួយ។ ក៏ប៉ុន្តែមុននឹងបង្កើតសហព័ន្ធឥណ្ឌូចិន បារាំងក៏បានខិតខំកំណត់ព្រំប្រទល់ទឹកដីអាណានិគមរបស់ខ្លួនឱ្យបានច្បាស់លាស់ តាមរយៈការចុះកិច្ចព្រមព្រៀងឆ្នាំ១៨៧៣ ស្តីពីព្រំប្រទល់រវាងកម្ពុជា និងកូសាំងស៊ីន។ ចតុស្តម្ភនៃរដ្ឋបាលសាធារណៈ គឺឧកញ៉ាយមរាជ ឧកញ៉ាវាំង ឧកញ៉ាក្រឡាហោម និងឧកញ៉ាចក្រី នៅបន្តដើរតួនាទីសំខាន់នៅក្នុងប្រព័ន្ធរដ្ឋបាល។ បន្ទាប់មកបារាំងពង្រឹងអំណាចបន្ថែមទៀតតាមរយៈព្រះរាជប្រកាសឆ្នាំ១៨៩៧ ដោយដាក់រ៉េស៊ីដង់ជាន់ខ្ពស់បារាំង (Résident supérieur) មានអំណាចខ្ពស់ជាងព្រះមហាក្សត្រ និងគណៈរដ្ឋមន្ត្រីខ្មែរ។ រ៉េស៊ីដង់ជាន់ខ្ពស់ជាអ្នកត្រួតលើរ៉េស៊ីដង់ចំនួន១២នាក់ទៀត ដែលមើលការខុសត្រូវលើចៅហ្វាយស្រុកខ្មែរចំនួន៥១។

៣-តើរជ្ជកាលព្រះបាទនរោត្តមបានបន្សល់ទុកសមិទ្ធផលអ្វីខ្លះ?

សមិទ្ធផលក្នុងរជ្ជកាលព្រះបាទនរោត្តម ៖ នៅក្នុងរជ្ជកាលនេះ កម្ពុជាបានបង្កើតឡើងនូវប្រព័ន្ធរដ្ឋបាលសម័យទំនើប និងប្រព័ន្ធកម្មសិទ្ធិឯកជនលើដីធ្លី (១) កំណែទម្រង់រដ្ឋបាល ៖ ការកាត់បន្តយចំនួនខេត្តក្នុងគោលដៅកាត់បន្តយចំណាយថវិកាជាតិ ការលប់បំបាត់ការបែកចែកការទទួលខុសត្រូវតាមខេត្តរបស់ពាជវង្សានុវង្ស ហើយថវិកាត្រូវបានបង្វែរយកទៅសាងសង់ផ្លូវដើម្បីប្រយោជន៍របស់សាធារណៈ ការលប់បំបាត់ក្រមប្រឹក្សា

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មន្ត្រីដែលទទួលប្រាក់ខែរដ្ឋ ការបំបាត់ចោលឧកញ៉ាហួង ដែលកេងប្រវ័ញ្ច លើប្រជាពលរដ្ឋ ការផ្តល់សិទ្ធិឱ្យចៅហ្វាយខេត្ត (ព្រ័ស៊ីដង់) បាវ៉ាំងជាអ្នក តែងតាំងចៅហ្វាយស្រុក អភិបាលក្រុង មេឃុំ និងមេភូមិ (២) កំណែទម្រង់ តុលាការ ៖ ការលុបចោលវណ្ណៈខ្ញុំគេ ការកែលម្អលក្ខខណ្ឌរបស់អ្នកទោស ការកំណត់អំណាចតុលាការរដ្ឋបាលបុរាណខ្មែរ ការពង្រឹកអំណាចចៅក្រម ដែលប្រើប្រាស់ច្បាប់បាវ៉ាំងសម្រាប់កាត់ក្តី (៣) កំណែទម្រង់សេដ្ឋកិច្ច ៖ ការលុបបំបាត់ពាណិជ្ជកម្មផ្តាច់មុខ។ កំណែទម្រង់នេះ គឺជាការផ្លាស់ប្តូរ យ៉ាងខ្លាំងពីរបបគ្រប់គ្រងតាមបែបសក្តិភូមិ ទៅជារបបគ្រប់គ្រងតាមបែប ទំនើប។

ការអភិវឌ្ឍវិស័យអប់រំ ៖ អគ្គទេសាភិបាលកូសាំងស៊ីន Charles Thomson បានធ្វើការប្តេជ្ញាចិត្តលើកកម្ពស់ការអភិវឌ្ឍវិស័យអប់រំជាភាសា បាវ៉ាំងនៅកម្ពុជា ក្នុងគោលដៅលើកកម្ពស់ធនធានមនុស្សកម្ពុជាឱ្យបានឆាប់ រហ័ស ដើម្បីការងារក្នុងរដ្ឋបាលអាណានិគមនិយម។ គោលនយោបាយ នេះមានគោលដៅកាត់បន្ថយការប្រើប្រាស់មន្ត្រីពជការជាជនជាតិវៀត-ណាម និងធ្វើឱ្យខ្មែរកាន់តែទុកចិត្តបាវ៉ាំងកាន់តែខ្លាំងឡើង។

ការកំណត់ព្រំដែនជាមួយវៀតណាម ៖ ក្នុងគោលដៅកំណត់ព្រំដែន សម្រាប់ប្រមូលពន្ធ អគ្គទេសាភិបាលកូសាំងស៊ីន ឧត្តមនាវីឯក គ្រង់ឌីយែរ (Grandière) បានសម្រេចចិត្តលើកយកបញ្ហាព្រំដែនមកដោះស្រាយ ហើយ នៅក្នុងឆ្នាំ១៨៦៣ បានចាត់តាំងតំណាងអាណាព្យាបាលឈ្មោះ ឌូដា ដេ ឡាក្រេ (Doudart de Lagrée) ឱ្យយកចិត្តទុកដាក់សិក្សាទៅលើការកំណត់ ព្រំដែនរវាងកូសាំងស៊ីន និងកម្ពុជា។ វិធានការនេះជួយដល់ការការពារ ទឹកដីកម្ពុជា ថ្វីត្បិតតែកម្ពុជាបានទិតៀនបាវ៉ាំងថា បានកាត់ខេត្តខ្មែរនៅ កម្ពុជាក្រោមឱ្យទៅវៀតណាម ហើយនៅឆ្នាំ១៩៤៩ បានប្រគល់ខេត្តទាំង នេះឱ្យអាជ្ញាធរវៀតណាម។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៤-ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនៃសតវត្សទី២០

ពិភពលោកនៅដើមសតវត្សទី២០ មានលក្ខណៈដូចតទៅ ៖ (១) សម្ព័ន្ធភាពយោធារវាងប្រទេសនៅអឺរ៉ុប (២) អាណានិគមនិយម ដែលអនុញ្ញាតឱ្យប្រទេសអឺរ៉ុបផ្សព្វផ្សាញវប្បធម៌ និងបច្ចេកវិទ្យា (៣) និន្នាការឆ្ពោះទៅរកសាកលភាវូបនីយកម្ម ដែលឈរលើមូលដ្ឋាននៃទំនាក់ទំនងវិសមភាពរវាងប្រទេសធ្វើអាណានិគម ដែលធ្វើអាជីវកម្មលើវត្ថុធាតុដើម និងពលកម្មថោកនៃប្រទេសស្ថិតនៅក្រោមអាណានិគម (៤) អនុត្តរភាពនៃប្រទេសអឺរ៉ុប ដែលគ្រប់គ្រងនយោបាយ និងសេដ្ឋកិច្ចពិភពលោក។ ព្រឹត្តិការណ៍សំខាន់ៗនៃសតវត្សទី២០គឺ ៖ (១) សង្គ្រាមលោកលើកទី១ (២) ការដើរឡើងនៃលទ្ធិកុម្មុយនីស្ត (៣) បដិវត្តន៍រុស្ស៊ី (៤) បដិវត្តន៍ឧស្សាហកម្មលើកទី២ (៥) សង្គ្រាមលោកលើកទី២ (៦) ការបែងចែកពិភពលោកជាប្លុកលោកសេរី និងលោកកុម្មុយនីស្ត។ នៅដើមសតវត្សទី២០ បដិវត្តន៍ឧស្សាហកម្មនាំមកនូវផលប្រយោជន៍ សម្រាប់តែស្រទាប់ប្រជាជនមួយចំនួនតូចនៅបស្ចិមប្រទេសមួយចំនួនប៉ុណ្ណោះ។ ការរកឃើញនូវភ្លើងអគ្គិសនី រទេះភ្លើងដើរដោយចំហាយទឹក និងទូរស័ព្ទនៅសតវត្សទី១៩ បង្កើតបាននូវមូលដ្ឋានគ្រឹះ សម្រាប់ការអភិវឌ្ឍនៅសតវត្សទី២០។

សង្គ្រាមលោកលើកទី១ ៖ សង្គ្រាមលោកលើកទី១ផ្ទុះឡើង ដោយសារកត្តាសំខាន់ៗដូចតទៅ ៖ (១) ពិភពលោកបានចែកមហាអំណាចជាពីរក្រុមដែលប្រណាំងប្រជែងគ្នា ៖ ម្ខាងសម្ព័ន្ធមិត្តអាឡឺម៉ង អូទ្រីស-ហុងគ្រី និងអីតាលី និងម្ខាងទៀត រុស្ស៊ី អង់គ្លេស និងបារាំង។ បារាំង និងអាឡឺម៉ងប្រឈមមុខដាក់គ្នាខ្លាំង ជាពិសេសនៅក្នុងតំបន់បាល់កង់ចម្រុះជាតិសាសន៍។ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩១៤ នៅពេលដែលអ្នកជាតិនិយមសែបបានលួចសម្លាប់ស្តេច Ferdinand របស់អូទ្រីសនៅ Sarajevo អូទ្រីសបានប្រកាសសង្គ្រាមជាមួយប្រទេសសែបីរ។ សង្គ្រាមលោកលើកទី១បានចាប់ផ្តើមដោយសារ តែប្រទេសទាំងពីរក្រុមមានចងសម្ព័ន្ធយោធាជាមួយគ្នា។ ប្រជា-

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជនជាង២០លាននាក់បាត់បង់ជីវិតក្នុងសង្គ្រាមលោកលើកទី១។ នៅក្នុងខែ
សីហា ឆ្នាំ១៩១៨ កងទ័ពសម្ព័ន្ធមិត្តបានវាយចូលដល់ព្រំដែនអាឡឺម៉ង
ហើយនៅថ្ងៃទី ១១ វិច្ឆិកា ឆ្នាំ១៩១៨ កិច្ចព្រមព្រៀងឈប់បាញ់គ្នាត្រូវបាន
ចុះហត្ថលេខា។ សន្ធិសញ្ញាទីក្រុង Versailles ទាមទារឱ្យអាឡឺម៉ងសង
៣១ពាន់លានដុល្លារ។

ការរើបឡើងនៃលទ្ធិកុម្មុយនីស្ត ៖ បដិវត្តន៍ឧស្សាហកម្មបានកែប្រែ
សេដ្ឋកិច្ចកសិកម្មនៅអឺរ៉ុបឱ្យទៅជាសេដ្ឋកិច្ចឧស្សាហកម្ម តាមរយៈការប្រើ-
ប្រាស់ម៉ាស៊ីនដើរដោយចំហាយទឹក សម្រាប់នាវា និងរទេះភ្លើង ការផលិត
រថយន្ត និងការប្រើប្រាស់ម៉ាស៊ីន ដើម្បីផលិតវាយនភ័ណ្ឌ។ សតវត្សទី២០
គឺជាសតវត្សនៃការកើនឡើងពាណិជ្ជកម្មពិភពលោក។ ក៏ប៉ុន្តែ បដិវត្តន៍នេះ
ផ្តល់ផលប្រយោជន៍ឱ្យតែវណ្ណៈអភិជន និងវណ្ណៈកណ្តាលប៉ុណ្ណោះ។ កម្មករ
និងកសិករមានកម្រិតជីវភាពទាបជង្រៃ។ វិសមភាពសង្គម ផ្សារសេរី និង
លទ្ធិមូលធននិយមបានបង្កើតឱ្យកើតមានឡើងនូវលទ្ធិសង្គមនិយម សម្រាប់
ចលនាកម្មករ និងកសិករ។ កាល ម៉ាក្សអំពាវនាវឱ្យ«កម្មករទូទាំងពិភពលោក
រួបរួមគ្នាឡើង»។

ការបង្កើតរដ្ឋសង្គមនិយមទី១លើពិភពលោក ៖ ស្តេចត្សារ នីកូឡាយ
ទី២បានឡើងគ្រងរាជ្យនៅឆ្នាំ១៨៩៦។ កត្តាបីសំខាន់ៗដែលនាំឱ្យមាន
បដិវត្តន៍ផ្តួលរំលំស្តេចត្សារ ៖ (១) ឧស្សាហូបនីយកម្មយ៉ាងលឿនបានធ្វើ
ឱ្យកសិករបាត់បង់ដីធ្លី ហើយរត់មកធ្វើការនៅតាមរោងចក្រនៅទីក្រុង (២)
បរាជ័យរបស់រុស្សីក្នុងសង្គ្រាមជាមួយជប៉ុន (១៩០៤-០៥) ធ្វើឱ្យរុស្សី
បាត់បង់ដីកោះគូរិល (៣) ការចូលរួមនៃកងទ័ពរុស្សីក្នុងសង្គ្រាមលោកលើក
ទី១ (១៩១៤-១៩១៨) ធ្វើឱ្យជីវភាពប្រជាជនកាន់តែលំបាក។ កត្តានេះ
បានបង្កើតលក្ខខណ្ឌអំណោយផល សម្រាប់បដិវត្តន៍ប្រជាធិបតេយ្យ ដើម្បី
រំលំរបបសក្តិភូមិនៅខែកុម្ភៈ ឆ្នាំ១៩១៧ និងការបង្កើតរដ្ឋាភិបាលបណ្តោះ
អាសន្ន ដែលបម្រើផលប្រយោជន៍ឱ្យវណ្ណៈមូលធន និងអភិជន។ ដោយ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្ថានភាពក្នុងប្រទេសនៅមិនមានភាពល្អប្រសើរ ពួកបដិវត្តន៍បានដឹកនាំកម្មករ និងកងទ័ពផ្តួលរំលំរដ្ឋាភិបាលបណ្តោះអាសន្ន ដែលជាបដិវត្តន៍សង្គមនិយមនៅខែតុលា ឆ្នាំ១៩១៧ និងបង្កើតឡើងនូវអំណាចសូវៀត។ សង្គ្រាមស៊ីវិលរវាងពួក«ស» និងពួក«ក្រហម»បានចាប់ផ្តើមរហូតដល់ពួកកុម្មុយនីស្តទទួលជោគជ័យ។ បន្ទាប់មក សហភាពសូវៀតត្រូវបានបង្កើតឡើង ដែលជារដ្ឋសង្គមនិយមទី១លើសកលលោក។

បដិវត្តន៍ឧស្សាហកម្មលើកទី២ ៖ បដិវត្តន៍ឧស្សាហកម្មលើកទី២ គឺជាបដិវត្តន៍បច្ចេកវិទ្យា ដែលចាប់ផ្តើមនៅចុងសតវត្សទី១៩ និងបញ្ចប់មុនសង្គ្រាមលោកលើកទី២។ បដិវត្តន៍លើកទី២ គឺនវានុវត្តន៍ និងការបង្កើតម៉ាស៊ីនធំៗ ដូចជាគ្រឿងចក្រសម្រាប់រោងចក្រ ដំណើរការទំនើបសម្រាប់ផលិតដែកថែប ការផលិតអគ្គិសនី តេឡេក្រាប ខ្សែសង្វាក់ផលិតកម្មក្នុងរោងចក្រ និងប្រព័ន្ធផ្លូវដែកជាដើម ដែលបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ការផ្សព្វផ្សាយគំនិតវិទ្យាសាស្ត្រ។

៥-តើអ្វីទៅជាព្រឹត្តិការណ៍ធំៗក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ?

រជ្ជកាលព្រះបាទនរោត្តម ស៊ីសុវត្ថិ

ដំណាក់កាលកំណែទម្រង់នៅកម្ពុជា ៖ ព្រះបាទស៊ីសុវត្ថិ គឺជាព្រះមហាក្សត្រ ដែលសហការជាមួយបារាំងក្នុងការបង្ក្រាបការបះបោរប្រឆាំងបារាំង និងគាំទ្រការធ្វើកំណែទម្រង់ធ្វើទំនើបកម្មប្រព័ន្ធរដ្ឋបាល ថ្វីត្បិតតែព្រះអង្គធ្លាប់ទទួលការអប់រំនៅបាឋកកក៏ដោយ។ នៅពេលដែលព្រះបាទនរោត្តមចូលទិវង្គត បារាំងមិនចង់ឱ្យព្រះអង្គម្ចាស់យុគន្ធរ ដែលជាបុត្រឡើងសោយរាជ្យទេ ដោយសារព្រះអង្គប្រឆាំងគេ បារាំងក៏លើកព្រះបាទស៊ីសុវត្ថិឱ្យឡើងសោយរាជ្យ។

ការទាមទារមកវិញខេត្តបាត់ដំបង និងសៀមរាប ៖ ដើម្បីបញ្ចៀសការប្រណាំងប្រជែងផ្នែកអាណានិគម ប្រទេសបារាំង និងចក្រពត្តិអង់គ្លេស

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បានសម្រេចបែងចែកដែនឥទ្ធិពលរបស់ពួកគេ។ នៅចុងសតវត្សរ៍ទី១៩ បារាំងចង់បង្កើតរដ្ឋទ្រនាប់មួយនៅចន្លោះឥណ្ឌូចិន និងភូមា។ បារាំងបានសម្រេចចិត្តពង្រីកអាណាព្យាបាលរបស់ខ្លួន ដើម្បីវាតទីយកទឹកដីនៅក្នុងតំបន់។ ឧប្បត្តិហេតុជាច្រើនបានកើតឡើងជាមួយសៀម ដោយបារាំងប្រើប្រាស់នូវកម្លាំងយោធា ដើម្បីទាមទារទឹកដីពីសៀមវិញ។ នៅឆ្នាំ១៨៩៣ បារាំងបានទាមទារឱ្យព្រះចៅជូឡា ឡុងកនចុះសន្ធិសញ្ញាបារាំង-សៀមចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៨៩៣ សៀមបានលះបង់ការទាមទារទាំងអស់នៅលើទឹកដីត្រើយខាងឆ្វេងទន្លេមេគង្គ ហើយកាត់ទឹកដីទៅឱ្យអាណ្ណាម និងឡាវ។

សន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៦ ៖ ធ្វើឱ្យប្រទេសកម្ពុជាទទួលបានមកវិញនូវខេត្តម្លូព្រៃ និងទន្លេរពៅ ជាថ្នូរទឹងការលុបបំបាត់សិទ្ធិយុត្តាធិការ និងការការពារ ដែលផ្តល់ឱ្យបារាំងដោយអនុសញ្ញាឆ្នាំ១៨៩៣។ តាមរយៈសន្ធិសញ្ញាឆ្នាំ១៩០៦ ប្រទេសបារាំងបានកាត់ផ្តាច់ទឹកដីពីរកន្លែងនៅត្រើយខាងឆ្វេងទន្លេមេគង្គពីប្រទេសសៀម ៖ ខេត្តម្លូព្រៃ និងទន្លេរពៅរបស់កម្ពុជាដែលត្រូវប្រគល់ទៅឱ្យកម្ពុជាវិញ។ លើសពីនេះទៀត សន្ធិសញ្ញាឆ្នាំ១៩០៦ បានទទួលស្គាល់ថា ខ្សែបន្ទាត់ទ្រនុងកំពូលភ្នំ (Crête) ដងវែកគឺជាខ្សែបន្ទាត់ព្រំដែនកម្ពុជាជាមួយសៀម។

សន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៧ ៖ តាមរយៈសន្ធិសញ្ញាឆ្នាំ១៩០៧ រដ្ឋាភិបាលសៀមប្រគល់ឱ្យបារាំងនូវទឹកដីបាត់ដំបង សៀមរាប និងស៊ីសុផុន (ប្រការ១)។ ជាថ្នូរមកវិញ ប្រទេសសៀមទទួលបានទឹកដីត្រាត និងជានាសាយ។ ប្រទេសសៀមក៏យកមកវិញនូវកោះទាំងឡាយដែលស្ថិតនៅខាងត្បូងនៃជ្រោយឡែមលីង (Lem Ling) រួមទាំងកោះគុត (Koh Kut) ផងដែរ (ប្រការ៦)។

ការកសាងជនជាតិមនុស្ស ៖ លោកស្រី Penny Edwards បានសរសេរនិក្ខេបបទថ្នាក់បណ្ឌិតមួយ ដែលមានចំណងជើងថា៖ CAMBODGE: The

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Cultivation of a Nation, 1860-1945 , «ការកសាងជាតិកម្ពុជាឡើងវិញ»។ នៅក្នុងនិក្ខេបបទនេះ លោកស្រីបានធ្វើការសិក្សាពីតួនាទីរបស់អាជ្ញាធរអាណាព្យាបាលបារាំងក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីបម្រើការងារនៅក្នុងរដ្ឋបាលអាណានិគម និងការអភិរក្សវប្បធម៌ខ្មែរ។

ការអភិវឌ្ឍធនធានមនុស្សក្នុងសម័យអាណាព្យាបាលបារាំងត្រូវបានលើកកម្ពស់តាមរយៈការអនុវត្តវិធានការពីរសំខាន់ៗ ៖ ទីមួយ-ការបញ្ជូនិស្សិតកម្ពុជាឱ្យទៅរៀននៅតាមគ្រឹះស្ថានសិក្សានៅបារាំង និងនៅវៀតណាម និងទីពីរ-ការបង្កើតប្រព័ន្ធអប់រំផ្លូវការ តាមរយៈការបង្កើតសាលារដ្ឋខ្មែរ-បារាំងនៅកម្ពុជា។

ដើម្បីពង្រឹងរដ្ឋបាលអាណានិគម លោក August Pavie បានផ្តួចផ្តើមគំនិតបង្កើតសាលាកម្ពុជា (École Cambodgienne) នៅទីក្រុងប៉ារីស ហើយបានជ្រើសរើសកូនមន្ត្រីជាន់ខ្ពស់ខ្មែរចំនួន១៣នាក់ ដើម្បីយកទៅបណ្តុះបណ្តាល ដើម្បីប្រើប្រាស់ក្នុងរដ្ឋបាលអាណានិគម។ ក្នុងឆ្នាំ១៨៨៦ សាលាកម្ពុជាត្រូវបានបង្កើតឡើងនៅទីក្រុងប៉ារីស ហើយពីឆ្នាំ១៨៨៥ដល់១៨៨៩ សាលានេះបណ្តុះបណ្តាលតែនិស្សិតកម្ពុជាប៉ុណ្ណោះ។ ក្នុងចំណោមនិស្សិតដែលទទួលការបណ្តុះបណ្តាលដំបូង មានអនាគតសេនាបតីក្រសួងសិក្សាធិការ និងយុទ្ធនាធិការ ពេជ្រ ប៉ុណ្ណ ដែលជាកូនឧកញ៉ាមេត្រីភូតុន និងអនាគតនាយករដ្ឋមន្ត្រី ជួន សម្បត្តិ (១៨៦៦-១៩៥០) ផងដែរ។ ក្នុងឆ្នាំ១៨៨៩ សាលាកម្ពុជាត្រូវបានប្រែក្លាយទៅជាសាលាអាណានិគម (École Coloniale) សម្រាប់បណ្តុះបណ្តាលនិស្សិតមកពីបណ្តាប្រទេសអាណានិគមនិយមរបស់បារាំង និងជនជាតិបារាំងដែលមានបំណងធ្វើការជាមន្ត្រីនៅតាមប្រទេសអាណានិគមទាំងនោះ។ ក្រោយសង្គ្រាមលោកលើកទី២ លោកប្រធានាធិបតី Charles De Gaule បានប្រែក្លាយសាលាអាណានិគមនេះឱ្យទៅជាសាលារដ្ឋបាលជាតិ (École Nationale d'Administration) ក្នុងឆ្នាំ១៩៤៩ សម្រាប់បណ្តុះបណ្តាលនិស្សិត ដែលមានបំណងចង់បម្រើ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការងារនៅក្នុងរដ្ឋការបារាំង។

ការសាងសង់ផ្លូវគមនាគមន៍ ៖ កំណែទម្រង់ការគ្រប់គ្រងរដ្ឋជួយឱ្យបារាំងប្រមូលពន្ធ ដើម្បីយកមកកសាងផ្លូវគមនាគមន៍។ នៅឆ្នាំ១៩២៨ កម្ពុជាបានសាងសង់ផ្លូវជាតិបាន១១៧៣គីឡូម៉ែត្រ និងផ្លូវខេត្តបាន២២២០គីឡូម៉ែត្រ។ ការធ្វើដំណើរពីភ្នំពេញទៅសាយហ្គន ចំណាយពេលអស់តែប្រាំម៉ោងប៉ុណ្ណោះ។

វិស័យអប់រំ ៖ សមិទ្ធផលក្នុងវិស័យអប់រំនៅមានកម្រិតនៅឡើយ។ សាលារៀនមានគោលដៅសម្រាប់បង្រៀនតែកូនអ្នកធំ ដើម្បីធ្វើការក្នុងរាជការប៉ុណ្ណោះ។ នៅឆ្នាំ១៩២៤ រដ្ឋបាលបារាំងបានបង្កើតសាលាគរុកោសល្យមួយនៅកំពង់ចាម ដើម្បីបណ្តុះបណ្តាលគ្រូ។ សាលាភាគច្រើនជាសាលាវត្ត។ ចំនួនសាលាបឋមសិក្សាកើនឡើងពីជាង១ពាន់នៅឆ្នាំ១៩៣៦ ដល់ជិត៦ពាន់នៅឆ្នាំ១៩៥០ ហើយចំនួនសិស្សកើនឡើងពីជាង៥ម៉ឺនដល់ជិត៦សែននាក់។ វិទ្យាល័យកើនឡើងពី៣ដល់៤ ហើយសិស្សវិទ្យាល័យកើនឡើងពី៤០០នាក់ក្នុងឆ្នាំ១៩៣៦ ដល់១៥០០នាក់ក្នុងឆ្នាំ១៩៥០។

វិស័យសេដ្ឋកិច្ច ៖ សេដ្ឋកិច្ចកម្ពុជានៅដើមសតវត្សទី២០ គឺជាសេដ្ឋកិច្ចកសិកម្មបុរាណ សម្រាប់ត្រឹមតែមួយរស់ប៉ុណ្ណោះ។ កសិករត្រូវខ្ចីប្រាក់ពីឈ្មួញ ដល់រដូវច្រូតកាត់ ផលស្រូវត្រូវយកទៅសងបំណុល។ មានតែពាណិជ្ជករ និងឧកញ៉ាទេដែលទទួលប្រាក់ចំណេញពីពាណិជ្ជកម្មកសិផល ដោយសារពួកគេជាអ្នកកំណត់ថ្លៃ និងអត្រាការប្រាក់ដែលខ្ពស់លើសលប់។ ពួកបារាំងចាត់ទុកថា អំណាចរបស់ពួកឧកញ៉ា គឺជាឧបសគ្គដ៏សំខាន់នៃកំណើនសេដ្ឋកិច្ច។ ដោយសារអំណាចដ៏ខ្លាំងនេះ វិនិយោគិនបរទេសមិនហ៊ានដាក់ទុនរកទទួលទានៅកម្ពុជាឡើយ ប្រសិនបើគ្មានបង្អែករឹងមាំ។ មានតែពួកបារាំងប៉ុណ្ណោះដែលវិនិយោគលើចម្ការកៅស៊ូ។ ដំណាំសម្រាប់លក់ទៅក្រៅប្រទេសមានតែកៅស៊ូ និងស្រូវ។ ក៏ប៉ុន្តែ ថ្វីត្បិតតែផ្ទៃដីដាំដុះកើនឡើង តែទិន្នផលស្រូវធ្លាក់ចុះ ដោយសារតែការដាំដុះធ្វើ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមរបៀបប្រពៃណី។ ឧស្សាហកម្មគ្មានអ្វីជាដុំកំភួនឡើយ។ បាវ៉ង់មិនបានពង្រឹងផ្នែកស្ថាប័ន និងកម្មសិទ្ធិលើអចលនទ្រព្យ និងចលនទ្រព្យ ដែលជាមូលដ្ឋានគន្លឹះនៃការអភិវឌ្ឍសេដ្ឋកិច្ច ដូចនៅក្នុងប្រទេសក្រោមអាណានិគមអង់គ្លេសឡើយ។

បដិវត្តន៍ពីសៀមទៅថៃឡង់ដ៍ ៖ ដោយមិនសប្បាយចិត្តនឹងនយោបាយស្តេចថៃ អ្នកនយោបាយ បញ្ញវន្ត នាយទាហាន និងមន្ត្រីរដ្ឋការចំនួន ៥៣នាក់បង្កើតជាគណបក្សប្រជារាស្ត្រ ហើយបានធ្វើរដ្ឋប្រហារនៅឆ្នាំ ១៩៣២ ដើម្បីផ្តួលរំលំព្រះចៅក្រុងជាធិប៉ុក លុបបំបាត់អភ័យឯកសិទ្ធិរបស់ស្តេច បង្កើតរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងផ្លាស់ប្តូរឈ្មោះប្រទេសពីសៀមទៅថៃឡង់ដ៍។ កងទ័ពចាប់សមាជិកនៃព្រះរាជវង្សានុវង្សយកជាឈ្លើយសឹក។ ពួកធ្វើរដ្ឋប្រហាររៀបចំកម្មវិធីនយោបាយ៦ខ ៖ (១) សេរីភាព និងសមភាពប្រជារាស្ត្រក្នុងវិស័យនយោបាយ តុលាការ និងពាណិជ្ជកម្ម (២) សន្តិភាព និងសណ្តាប់ធ្នាប់សង្គមត្រូវជានា (៣) នយោបាយសេដ្ឋកិច្ចជាតិសុទ្ធសាធ (៤) បុគ្គលម្នាក់ៗត្រូវមានសិទ្ធិស្មើៗគ្នា (៥) ប្រជាពលរដ្ឋមានសេរីភាពពេញលេញ (៦) ប្រជាពលរដ្ឋទទួលនូវការអប់រំយ៉ាងពេញលេញ។ ព្រះមហាក្សត្រលែងមានអំណាចអ្វីទាំងអស់។

៦-តើអ្វីបានជាចាំបាច់បង្កើតនូវអត្តសញ្ញាណជាតិខ្មែរឡើងវិញ?

ការកសាងអត្តសញ្ញាណជាតិខ្មែរ ៖ អត្តសញ្ញាណខ្មែរច្រាស្រ័យភ្ជាប់គ្នា តាមរយៈមនោសញ្ចេតនា ជំនឿ សាសនា ភាសា ទំនៀមទម្លាប់ ប្រពៃណី សិល្បៈ សំណង់ សង្គម ការរស់នៅរបស់ជនជាតិខ្មែរៗលៅ។ ដូច្នេះហើយការស្រាវជ្រាវអំពីវប្បធម៌ និងអរិយធម៌ខ្មែរ គឺជាការបង្កើតនូវអត្តសញ្ញាណជាតិខ្មែរ ដើម្បីឱ្យឃើញថា ខ្មែរខុសពីជាតិសាសន៍ដទៃដូចម្តេចខ្លះ។ អរិយធម៌ គឺជា ៖ (១) វប្បធម៌ដែលមានជំនឿ សាសនា ភាសា អក្សរសាស្ត្រ សិល្បៈ តូរ្យតន្ត្រី ទំនៀមទម្លាប់ ប្រពៃណី ច្រាំង្គច្រាសាទ ការអប់រំ កីឡា

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ល្បែងកម្សាន្ត ច្បាប់ និង (២) សង្គមធម៌ ដែលមានលំនៅ ចំណីអាហារ សម្លៀកបំពាក់ សេដ្ឋកិច្ច សង្គមកិច្ច របៀបគ្រប់គ្រងរដ្ឋ វណ្ណៈសង្គម ស្ថាប័ន និងអង្គការសង្គមជាដើម។ លោក Paul Doumer ដែលត្រូវបានតែងតាំង ជាអគ្គទេសាភិបាលឥណ្ឌូចិនពីឆ្នាំ១៨៨៧ដល់១៨០២ គឺជាអ្នកយកចិត្ត ទុកដាក់ដល់ការអភិរក្ស និងការស្រាវជ្រាវពីបេតិកភណ្ឌ។ ក្នុងឆ្នាំ១៨០០ លោកបានចេញប្រកាសស្តីពីការអភិរក្សបេតិកភណ្ឌប្រវត្តិសាស្ត្រនៅឥណ្ឌូ-ចិន ហើយលោក Étienne Lunet de la Jonquière ត្រូវបានតែងតាំងឱ្យ ធ្វើការសិក្សា និងរៀបចំបញ្ជីប្រាសាទបុរាណខ្មែរ។ បេសកកម្មអចិន្ត្រៃយ៍ បុរាណវិទ្យានៅឥណ្ឌូចិនត្រូវបានបង្កើតឡើង ដោយក្រឹត្យចុះថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ១៨៩៨ ដែលស្ថិតនៅក្រោមឱវាទអគ្គទេសាភិបាលឥណ្ឌូចិន(មាត្រា ១) ក្នុងគោលដៅធ្វើការស្រាវជ្រាវបេតិកភណ្ឌបុរាណវិទ្យា និងអក្សរសាស្ត្រ ប្រវត្តិសាស្ត្រ និងចូលរួមចំណែកក្នុងការសិក្សាអរិយធម៌ឥណ្ឌា ចិន ម៉ាឡេ ។ល។ (មាត្រា៦)។ នៅក្នុងឆ្នាំ១៩០០ បេសកកម្មនេះត្រូវបានដូរឈ្មោះ ទៅជាសាលាបារាំងចុងបូព៌ា (EFEO) ហើយប្រធានាធិបតីបារាំង Émile Loubert បានចេញក្រឹត្យចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩០១ ដើម្បីទទួលស្គាល់ ស្ថាប័នស្រាវជ្រាវនេះ។ ដំបូងស្ថាប័ននេះមានទីតាំងនៅក្រុងហាណូយ ហើយ ក្រោយឆ្នាំ១៩៥៤ បានលើកទីតាំងមកទីក្រុងព្រៃនគរវិញ។ សាលាបារាំង ចុងបូព៌ាបានចូលរួមចំណែកក្នុងការសិក្សាស្រាវជ្រាវអំពីវប្បធម៌ និងអរិយ ធម៌ខ្មែរ ជាពិសេសប្រាសាទអង្គរ ដែលជាដួងព្រលឹងរបស់ជាតិខ្មែរ និង ដែលបង្កើតឡើងនូវស្មារតីស្នេហាជាតិ និងជាតិនិយម និងអត្តសញ្ញាណ ខ្មែរក្នុងចំណោមប្រជាជន និងបញ្ញវន្តខ្មែរ។ លោក Louis Finot (១៨៦៦-១៩៣៥) អ្នកឯកទេសបារាំងខាងផ្នែកវប្បធម៌ឥណ្ឌា ត្រូវបានតែងតាំងជា ប្រធានទី១នៃស្ថាប័នស្រាវជ្រាវនេះ។ លោក Louis Finot ក៏បានចូលរួមក្នុង ការបណ្តុះបណ្តាលជនជាមនុស្សនៅកម្ពុជា ដូចជាការនិមន្តសម្តេច ជួន ណាត និងសម្តេច ហួត តាត ឱ្យទៅរៀនភាសាសំស្ក្រឹតនៅហាណូយ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាដើម។ នៅក្នុងឆ្នាំ១៩៥១ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដើម្បីស្នើសុំឱ្យសាលាបារាំងចុងបូព៌ា បន្តបេសកកម្មបច្ចេកទេស លើការងារអភិរក្សប្រាង្គប្រាសាទចំនួន១៥០០ ដែលសាលានេះបានប្រគល់ឱ្យកម្ពុជា។ សាលាបារាំងចុងបូព៌ា បន្តបំពេញបេសកកម្មបច្ចេកទេសរហូតដល់ឆ្នាំ១៩៧៣ នៅខេត្តសៀមរាប និងដល់ឆ្នាំ១៩៧៥ នៅភ្នំពេញ។ ដើម្បីលើកកម្ពស់ការសិក្សាសិល្បៈ និងស្ថាបត្យកម្មខ្មែរ លោក George Groslier បានបង្កើតសាលារចនាឡើងនៅឆ្នាំ១៩១៧ ដែលក្រោយមកបានក្លាយទៅជាសាកលវិទ្យាល័យវិចិត្រសិល្បៈ។

នៅក្នុងឆ្នាំ១៩២៩ សាលាបារាំងចុងបូព៌ាបានរៀបចំបញ្ជីបេតិកភណ្ឌដែលត្រូវការពារ ដែលក្នុងនោះមានប្រាសាទចំនួន៦៧០នៅកម្ពុជា ហើយនៅក្នុងឆ្នាំ១៩៣៥ ចំនួនប្រាសាទកើនឡើងដល់៧៦១។ លោក Henri Marchal ដែលជាអភិរក្សអង្គរចំនួនបីអាណត្តិ ពីឆ្នាំ១៩១៦ដល់ឆ្នាំ១៩៥៣ បានជួសជុលប្រាសាទ ហើយរៀបចំឱ្យមានប្រាសាទរង្គតូច និងប្រាសាទរង្គធំ និងជាអ្នករៀបចំជួសជុលប្រាសាទអង្គរវត្ត ដោយប្រើប្រាស់បច្ចេកទេសរុះរើ ហើយកសាងឡើងវិញ (Anastylose)។ បន្ទាប់មកគឺលោក Georges Trouvé (១៩០២-១៩៣៥) និងលោក Maurice Glaize (១៩៨៦-១៩៦៤) ដែលត្រូវបានតែងតាំងជាអភិរក្សអង្គរដើម្បីបន្តការងារនេះ។ លោក Bernard Philippe Groslier ដែលជាអភិរក្សអង្គរពីឆ្នាំ១៩៥៩ដល់ឆ្នាំ១៩៧៣ បានកែលម្អបច្ចេកទេសរុះរើ ហើយកសាងឡើងវិញ (Anastylose) នេះឱ្យកាន់តែសុក្រឹតឡើងថែមទៀត។

ទន្ទឹមនឹងការសិក្សា និងការអភិរក្សប្រាង្គប្រាសាទបុរាណ សាលាបារាំងចុងបូព៌ា បានធ្វើការសិក្សាលើសិលាចារឹកខ្មែរ ដែលជាកេរដំណែលប្រវត្តិសាស្ត្រ និងជាប្រភពនៃចំណេះដឹងខាងផ្នែកប្រវត្តិសាស្ត្រកម្ពុជា។ អ្នកដែលចាប់ផ្តើមផ្តិតយកសិលាចារឹកខ្មែរដំបូង គឺលោក Doudart de Lagrée នៅពេលលោកធ្វើបេសកកម្មនៅប្រាសាទអង្គរនៅឆ្នាំ១៨៦៦ ហើយ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អ្នកដែលបានបកប្រែសិលាចារឹកសំស្ក្រឹតខ្មែរលើកទី១ គឺអ្នកប្រាជ្ញហូឡង់ លោក Hendrik Kern។ បន្ទាប់មក លោកបានផ្តិតសិលាចារឹកមួយចំនួន ហើយផ្ញើទៅទីក្រុងប៉ារីស ហើយលោក Abel Bergaigne និង លោក Auguste Barth បានធ្វើការសិក្សា ហើយបោះផ្សាយនូវស្នាដៃមួយនៅឆ្នាំ១៨៨៣ ដែលមានចំណងជើងថា ៖ «សិលាចារឹកសំស្ក្រឹតនៅចម្ប៉ា និងនៅកម្ពុជា»។ ក៏ប៉ុន្តែ គឺលោក George Coedès ដែលជានាយកសាលាបារាំងបុរាណវិទ្យាចាប់ពីឆ្នាំ១៩២៩ ដែលជាអ្នកបានចំណាយពេលស្ទើរតែពេញមួយជីវិតដើម្បីសិក្សាសិលាចារឹកខ្មែរ និងបានបោះពុម្ពសៀវភៅចំនួន៨ក្បាលដែលមានចំណងជើងថា «សិលាចារឹកនៃប្រទេសកម្ពុជា(១៩៣៧-១៩៦៦)» ដែលក្លាយជាប្រភពដ៏សំខាន់ សម្រាប់ការសិក្សាប្រវត្តិសាស្ត្រកម្ពុជា។ លោកបានសរសេរសៀវភៅ និងអត្ថបទជាច្រើនស្តីពីប្រវត្តិសាស្ត្រខ្មែរ។ កូនសិស្សរបស់លោក Coedès គឺលោក Claude Jacques និងលោក Kamalesvar Bhattacharya ដែលជាអ្នកឯកទេសភាសាសំស្ក្រឹតបានបន្តការសិក្សាសិលាចារឹក។ ទន្ទឹមនឹងនេះ លោកស្រីសាស្ត្រាចារ្យ៣ សារវរស៍ក៏បានចូលរួមធ្វើការសិក្សាសិលាចារឹកជាភាសាខ្មែរផងដែរ និងបានបោះពុម្ពផ្សាយសៀវភៅដែលមានចំណងជើងថា ៖ «Les inscriptions modernes d'Angkor»។

អ្នកប្រាជ្ញបារាំងផ្នែកភាសាបាលីក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការស្រាវជ្រាវពីកម្ពុជាដែរ។ ក្នុងនោះ តួឯកដ៏សំខាន់គឺលោកស្រី Suzanne Karpelès ដែលជាភាសាវិទូ ពុទ្ធសាសនវិទូ និងជាអ្នកឯកទេសខាងផ្នែកគម្ពីរស្ទឹករឹតជាភាសាបាលី និងជាភាសាខ្មែរ។ លោកស្រីបានចូលបម្រើការងារនៅក្នុងឆ្នាំ១៩២២ និងបានបង្កើតព្រះរាជបណ្ណាល័យភ្នំពេញនៅឆ្នាំ១៩២៩ ដើម្បីប្រមូល រៀបចំ និងអភិរក្សអក្សរសិល្ប៍ជាភាសាខ្មែរ និងបាលី។ លោកស្រីក៏បានផ្តួចផ្តើមគំនិតឱ្យខ្មែរយើងបង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិតឡើង ដើម្បីធ្វើការស្រាវជ្រាវខាងផ្នែកពុទ្ធសាសនា និងបោះពុម្ពផ្សាយ ព្រះត្រៃ-បិដក ដោយយកឯកសារពី Pali Text Society នៅទីក្រុងឡុងដ៏ជាគោល។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បន្ទាប់ពីការបង្កើតអាណាព្យាបាលបារាំងនៅកម្ពុជា អ្នកឯកទេសបារាំងបានចាប់ផ្តើមដើរប្រមូលអត្ថបទអក្សរសិល្ប៍ ចរិយាធម៌ និងសាស្ត្រាស្តីពីប្រវត្តិសាស្ត្រកម្ពុជា ដើម្បីធ្វើការសិក្សាពីកម្ពុជា។ ក៏ប៉ុន្តែ សាស្ត្រាទាំងនេះគឺជាអត្ថបទចម្លងដោយដៃ លើស្លឹករឹតហើយមិនសូវមានច្រើនទេ។ មន្ត្រីជាន់ខ្ពស់ បញ្ញវន្ត ព្រះសង្ឃរាជ និងព្រះញាតិវង្សានុវង្ស រក្សាទុកសាស្ត្រាទាំងនេះដោយប្រុងប្រយ័ត្ន ដោយចាត់ទុកសាស្ត្រាទាំងនេះជាវត្ថុមានតម្លៃ ហើយពេលខ្លះជាវត្ថុស័ក្តិសិទ្ធិទៀតផង។

៧-តើអ្វីទៅជាចតុស្តម្ភព្រះពុទ្ធសាសនានៅសតវត្សទី២០?

ការកសាងចតុស្តម្ភព្រះពុទ្ធសាសនា ៖ ស្ថាប័នអប់រំព្រះពុទ្ធសាសនាចំនួន៤ ដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាង និងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជាគឺ ៖ សាលាបាលីជាន់ខ្ពស់ ព្រះរាជបណ្ណាល័យកម្ពុជា វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងក្រុមជំនុំប្រែគម្ពីព្រះត្រៃបិដក។

សាលាបាលីជាន់ខ្ពស់ ៖ ក្នុងគោលបំណងដើម្បីកាត់បន្ថយឥទ្ធិពលរបស់សៀមមកលើព្រះសង្ឃកម្ពុជា ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ទ្រង់ព្រះរាជានុញ្ញាតឱ្យបង្កើតសាលាបាលីទី១ (សាលាបាលីជាន់ខ្ពស់អង្គវត្ត) ក្នុងឆ្នាំ១៩០៩ នៅក្រុងសៀមរាប។ សាលានេះបានបិទទ្វារនៅឆ្នាំ១៩១១ ដោយសារមានការលំបាកក្នុងការជ្រើសរើសសិស្សចូលរៀន។ តាមការទទូចស្នើសុំរបស់លោក George Coedès ដែលព្រួយបារម្ភអំពីការកើនឡើងនៃឥទ្ធិពលនិកាយធម្មយុត្តិ សាលាបាលីជាន់ខ្ពស់ថ្មីមួយទៀតត្រូវបានបង្កើតឡើងនៅរាជធានីភ្នំពេញក្នុងឆ្នាំ១៩១៩។ មេដឹកនាំអ្នកប្រាជ្ញខាងផ្នែកពុទ្ធសាសនាចំនួនពីរអង្គទៀតគឺ សម្តេចព្រះសង្ឃរាជ ជួន ណាត និងសម្តេចព្រះសង្ឃរាជ ហួត តាត ក៏ធ្លាប់ជាសិស្សភាសាបាលីដែរ។ ដូច្នេះ ការបង្កើតសាលាបាលីជាន់ខ្ពស់បានបណ្តុះបណ្តាលនូវបញ្ញវន្តខ្មែរឆ្នើមៗជាច្រើននាក់។ ដូចជំនាន់ព្រះបាទអង្គឌួងដែរ ខ្មែរបានលើកតម្កើងព្រះពុទ្ធសាសនា ជា

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ពិសេសការអប់រំជាភាសាបាលី ដែលជាមធ្យោបាយដ៏សំខ័ន្តិសិទ្ធិក្នុងការថែរក្សាវប្បធម៌ជាតិ។

ព្រះរាជបណ្ណាល័យជាតិ ៖ ការបង្កើតព្រះរាជបណ្ណាល័យកម្ពុជាក្នុងឆ្នាំ១៩២៩ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់មួយទៀត ក្នុងការលើកកម្ពស់ការរៀន និងការអានៅកម្ពុជា។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩២០ លោកស្រី Suzanne Karpelès ត្រូវបានចាត់តាំងឱ្យគ្រប់គ្រង និងចាត់ចែងបណ្ណាល័យ ព្រមទាំងក្នុងការលើកកម្ពស់ការបោះពុម្ពផ្សាយអត្ថបទព្រះពុទ្ធសាសនា។ ចំនួនអ្នកអានបានកើនឡើងពី៣ ៧៨២ ក្នុងឆ្នាំ១៩២៦ ទៅ៥ ២៣៧ ក្នុងឆ្នាំ១៩៣០។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ៖ ស្ថាប័នធំមួយទៀតនៅឧត្តមសិក្សានាដើមសតវត្សទី២០ គឺវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលត្រូវបានសម្ពោធនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៣០ ដោយមានការកិច្ចធ្វើយតបទៅនឹងតម្រូវការនៃសាលាបាលី បណ្ណាល័យ សារមន្ទីរជាដើម ដើម្បីលើកកម្ពស់ការសិក្សាស្រាវជ្រាវព្រះពុទ្ធសាសនាថេរវាទ។ ការកិច្ចសំខាន់របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យគឺត្រួតពិនិត្យ និងរៀបចំការងារកែសម្រួល ការបកប្រែ និងសរសេរគម្ពីរព្រះត្រៃបិដកជាភាសាបាលី-ខ្មែរ និងបោះពុម្ពផ្សព្វផ្សាយអត្ថបទស្រាវជ្រាវស្តីពីវប្បធម៌ និងអារ្យធម៌ខ្មែរ។

ក្រុមជំនុំព្រះត្រៃបិដក ៖ នៅក្នុងរាជ្យព្រះបាទសម្តេចមុនីវង្ស «ក្រុមជំនុំព្រះត្រៃបិដក» ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៣០ ដើម្បីបកប្រែ និងបោះពុម្ពផ្សាយព្រះត្រៃបិដកជាភាសាខ្មែរ ដើម្បីលើកស្ទួយព្រះពុទ្ធសាសនា កាត់បន្ថយជម្ងោះសាសនា និងទុកជាប្រទីបជ្វាលាបំភ្លឺផ្លូវសម្រាប់ពុទ្ធសាសនិកជន ដើម្បីឱ្យកម្ពុជាថ្កុំថ្កើងរុងរឿង មានកេរ្តិ៍ឈ្មោះក្រអូបសាយក្នុងសាកលលោក។ គម្ពីរព្រះត្រៃបិដកខ្មែរនេះត្រូវបានក្រុមជំនុំព្រះត្រៃបិដកបកប្រែពីភាសាបាលីមកជាភាសាខ្មែរក្នុងរយៈពេល៣៩ឆ្នាំ ពីឆ្នាំ១៩៣០ ដល់ឆ្នាំ១៩៦៨។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៩-សង្គ្រាមលោកលើកទី២ និងការបែកចែកពិភពលោកជាពីរ

សង្គ្រាមលោកលើកទី២ ៖ វិបត្តិសេដ្ឋកិច្ចឆ្នាំ១៩២៩បានរុញសេដ្ឋកិច្ច អាឡឺម៉ង់ចូលក្នុងវិបត្តិដ៏ជ្រៅ។ ម្យ៉ាងវិញទៀត អាឡឺម៉ង់ត្រូវសង្គ្រោះក្រមប្រទេស ក្រមសម្ព័ន្ធមិត្តដោយសារខ្លួនចាញ់សង្គ្រាម។ វិបត្តិនេះបានជួយឱ្យអ៊ីត្លែរ ដែលមាននិន្នាការប្រឆាំងពួកជ្វីប និងពួកកុម្មុយនីស្តឡើងកាន់អំណាចនៅ អាឡឺម៉ង់។ អ៊ីត្លែរឡើងកាន់អំណាចនៅឆ្នាំ១៩៣៤ ហើយប្រជាជនអាឡឺម៉ង់ សង្ឃឹមថា នឹងមានការផ្លាស់ប្តូរជាវិជ្ជមានក្នុងវិស័យសេដ្ឋកិច្ច។ តែផ្ទុយទៅ វិញ អ៊ីត្លែរចាប់ផ្តើមកសាងកម្លាំងទ័ព និងជណ្តើមទឹកដីអឺរ៉ុប ដែលមាន ប្រជាជននិយាយភាសាអាឡឺម៉ង់។ ប្រទេសអាឡឺម៉ង់បានចងសម្ព័ន្ធមិត្ត ជាមួយអ៊ីតាលី និងជប៉ុន។ ចំណែកឯប៉ូឡូញជាសម្ព័ន្ធមិត្តជាមួយបារាំង និងអង់គ្លេស។ នៅពេលដែលអាឡឺម៉ង់ឈ្លានពានប៉ូឡូញ នៅថ្ងៃទី១ កញ្ញា ឆ្នាំ១៩៣៩ អង់គ្លេសក៏ប្រកាសសង្គ្រាមជាមួយប្រទេសអាឡឺម៉ង់ភ្លាម។ ទ័ព អាឡឺម៉ង់ប្រើយុទ្ធសាស្ត្រសង្គ្រាម «វាយដូចផ្គេកបន្ទោរ» ដើម្បីដណ្តើមទឹកដី បែលហ្សិក ហូឡង់ លុចសំបួរ ដាណឺម៉ាក និងន័រវេ។ ក្នុងឆ្នាំ១៩៤១ អ៊ីត្លែរ បញ្ជូនទាហាន៤លាននាក់ទៅវាយយកសហភាពសូវៀត ហើយហ៊ុមព័ទ្ធ ទីក្រុងស្តាលីនក្រាដ និងទៅជិតដល់ទីក្រុងម៉ូស្គូ នៅពេលដែលរដូវត្រជាក់ បានដល់។ កងទ័ពក្រហមបានវាយបកយកជ័យជម្នះ និងរំដោះបានអឺរ៉ុប ខាងកើត។ នៅខែវិច្ឆិកា ឆ្នាំ១៩៤៣ ស្តាលីន Churchill និង Roosevelt បាន ជួបប្រជុំគ្នានៅទីក្រុងតេហេរង់ ដើម្បីពិភាក្សាពីយុទ្ធសាស្ត្រធ្វើសឹក។ ស្តាលីន សម្តែងការមិនសប្បាយចិត្ត ដោយសារអាមេរិក និងកងទ័ពសម្ព័ន្ធមិត្តពន្យា ពេលបើកសមរភូមិទី៦។ ទាល់តែនៅនិទាឃរដូវ ឆ្នាំ១៩៤៤ ទើបកងទ័ព អាមេរិកបញ្ជូនកងទ័ពមករំដោះអឺរ៉ុប នៅពេលដែលកងទ័ពសូវៀតចូលជិត ដល់ទីក្រុងប៊ែរឡាំង។ ទាហាន២៥លាននាក់ និងប្រជាជនពី៣០ដល់៦០ លាននាក់បាត់បង់ជីវិត។ ក្រោយសង្គ្រាមលោកលើកទី២ សហភាពសូវៀត ចាប់ផ្តើមគ្រប់គ្រងអឺរ៉ុបខាងកើត សហរដ្ឋអាមេរិកបានក្លាយជាមហាអំណាច

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សេដ្ឋកិច្ច ហើយឥទ្ធិពលអឺរ៉ុបខាងលិចចាប់ផ្តើមធ្លាក់ចុះ។

បដិវត្តន៍សង្គមនិយមនៅចិន ៖ លោក ស៊ុន យ៉ាតសេនបានដឹកនាំបដិវត្តន៍ជាតិនិយមនៅឆ្នាំ១៩១១-១២ និងបានផ្តួលរំលំរាជវង្សឈីង (១៦៤៤-១៩១២) ដែលរណបបរទេស និងបញ្ចប់ទាំងស្រុងនូវរបបរាជានិយមដែលមានអាយុជាង៤០០០ឆ្នាំនៅប្រទេសចិន។ ប្រទេសចិនបានក្លាយទៅជាសាធារណរដ្ឋចិន។ លោក ស៊ុន យ៉ាតសេនបានដឹកនាំគណបក្សជាតិនិយមដើម្បីប្រយុទ្ធនឹងពួកម្ចាស់ដី។ ជប៉ុនបានឈ្លានពានចិននៅឆ្នាំ១៩៣១ ដោយកាន់កាប់តំបន់ម៉ាន់ជូរី។ នៅឆ្នាំ១៩៣៤ លោក ម៉ៅ សេទុងបានរត់គេចពីការចាប់ខ្លួនរបស់ប្រធានាធិបតី ធាង កាយសៀក (Chiang Kai-shek) ដោយដឹកនាំពួកកុម្មុយនីស្តដើរយ៉ាងធ្ងាយចំនួន១៦ ៥០០គីឡូម៉ែត្រ ហើយបានធ្វើឱ្យម៉ៅ សេទុងក្លាយជាមេដឹកនាំកុម្មុយនីស្តរបស់ចិន។ ពួកជាតិនិយមនិងពួកកុម្មុយនីស្តចិនបានពួតដៃគ្នាប្រយុទ្ធប្រឆាំងទ័ពជប៉ុន។ ក្រោយសង្គ្រាមលោកលើកទី២ សង្គ្រាមក្នុងស្រុកនៅបន្តរហូតដល់ពួកកុម្មុយនីស្តទទួលជោគជ័យនៅឆ្នាំ១៩៤៩។

ការបែងចែកពិភពលោកជាប៉ូលពីរ និងសង្គ្រាមត្រជាក់ ៖ នៅក្នុងសង្គ្រាមលោកលើកទី២ (១៩៤០-១៩៤៥) សហភាពសូវៀតជួយរំដោះប្រទេសអឺរ៉ុបខាងកើតពីពួកហ្វាស៊ីស្ត និងបានបង្កើតនូវរបបសង្គមនិយមនៅក្នុងប្រទេសអឺរ៉ុបខាងកើត។ ចាប់ពីពេលនោះមកពិភពលោកបានបែក-ចែកជាប្លុកពីរ ៖ ប្លុកលោកសេរី ដឹកនាំដោយសហរដ្ឋអាមេរិក និងប្លុកសង្គមនិយម ដឹកនាំដោយសហភាពសូវៀត។ សង្គ្រាមត្រជាក់ និងការប្រណាំងសព្វាវុធបានចាប់ផ្តើមឡើងរវាងសហភាពសូវៀត និងសហរដ្ឋអាមេរិក ដើម្បីទាក់ទាញប្រទេសផ្សេងៗឱ្យដើរតាមខ្លួន។ ទន្ទឹមនឹងនេះ សង្គ្រាមក្តៅបានកើតមានឡើងនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍ ដោយមានការជួយគាំទ្រជាថវិកា និងជាសព្វាវុធពីមហាអំណាចទាំងពីរ។ នៅឆ្នាំ១៩៣០ លោក ហូ ជីមិញ និងអ្នកបដិវត្តន៍វៀតណាម កម្ពុជា និងឡាវ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បានបង្កើតបក្សកុម្មុយនីស្តឥណ្ឌូចិន។ នៅឆ្នាំ១៩៤១ ហូ ជីមិញត្រលប់ពី
និរទេសខ្លួន ដើម្បីដឹកនាំកងទ័ពបដិវត្តន៍វាយប្រហារកងទ័ពជប៉ុនរហូត
ទទួលបានជោគជ័យនៅខែ សីហា ឆ្នាំ១៩៤៥ ហើយហូ ជីមិញបានដឹកនាំ
ធ្វើបដិវត្តន៍ទាមទារឱ្យព្រះចៅអធិរាជបោជាយចុះពីតំណែង បង្កើតរដ្ឋាភិ-
បាលបណ្តោះអាសន្ន និងបង្កើតសាធារណរដ្ឋសង្គមនិយមវៀតណាម។
សង្គ្រាមត្រជាក់ចាប់ផ្តើមពីឆ្នាំ១៩៤៦ នៅពេលដែលសហរដ្ឋអាមេរិកប្រកាស
ពី«គោលនយោបាយហ៊ឹមព័ទ្ធសហភាពសូវៀត» និងបញ្ចប់នៅឆ្នាំ១៩៩១
នៅពេលដែលសហភាពសូវៀតដួលរលំ។ សង្គ្រាមត្រជាក់ គឺការកើនឡើង
នូវភាពតានតឹងរវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត ការរត់ប្រណាំង
សព្វាវុធ និងការប្រណាំងប្រជែងដណ្តើមឥទ្ធិពលលើប្រទេសតតិយលោក។

៩-តើកម្ពុជាទទួលបានឯករាជ្យពីបារាំងដោយវិធីណា?

សម្តេចសីហនុឡើងសោយរាជ្យ ៖ បន្ទាប់ពីព្រះបាទមុនីវង្សសោយ
ទិវង្គតនៅឆ្នាំ១៩៤១ ទេសាភិបាលបារាំង Decoux បានលើកសម្តេចសីហនុ
ឱ្យឡើងសោយរាជ្យ ដោយសារព្រះអង្គជាព្រះរាជបុត្រនៃអ្នកអង្គម្ចាស់
ស៊ីសុវត្ថិ កុសុមៈ និងព្រះអង្គម្ចាស់នរោត្តម សុភម្រឹត ពោលគឺជាព្រះតំណាង
ឱ្យខ្មែរទាំងពីរ។ ម្យ៉ាងវិញទៀត បារាំងយល់ថា ពួកគេស្រួលមានឥទ្ធិពល
លើព្រះអង្គ។ សម្តេចសីហនុបានប្រកាសឯករាជ្យពីបារាំង បន្ទាប់ពីកងទ័ព
ជប៉ុនបានចូលមកដល់កម្ពុជា នៅខែ សីហា ឆ្នាំ១៩៤១។ ព្រះអង្គបានលុប
ចោលក្រឹត្យរបស់ព័ស៊ីដង់ជាន់ខ្ពស់បារាំងស្តីពីការយកអក្សរឡាតាំងមក
ប្រើជំនួសអក្សរខ្មែរក្នុងគោលដៅអភិរក្សវប្បធម៌ជាតិ។ ក្រោយសង្គ្រាមលោក
លើកទី២ បារាំងបានផ្តល់ឱ្យកម្ពុជានូវ«ស្វ័យភាពពេញលេញ» ក្នុងសហភាព
បារាំង។ ច្បាប់ស្តីពីការបោះឆ្នោតត្រូវបានអនុម័តនៅឆ្នាំ១៩៤៦ ហើយរដ្ឋ
ធម្មនុញ្ញថ្មីត្រូវបានអនុម័តនៅឆ្នាំ១៩៤៧។ សម្តេចសីហនុបានខិតខំប្រឹងប្រែង
ដើម្បីសុំឱ្យបារាំងផ្តល់ឯករាជ្យពេញលេញដល់កម្ពុជា។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មុនការបង្កើតចលនាខ្មែរឥស្សរៈ ការតស៊ូដើម្បីឯករាជ្យពីបារាំងមានលក្ខណៈតូចតាច ជាពិសេសអ្នកស្នេហាជាតិខ្មែរតវ៉ាប្រឆាំងនឹងបំណងរបស់បារាំងក្នុងការផ្ទាស់ប្តូរភាសាខ្មែរ ដោយយកអក្ខរាវិរុទ្ធឡាតាំងមកប្រើជំនួសអក្ខរាវិរុទ្ធខ្មែរ។ ទស្សនៈជាតិនិយមកើតឡើងក្នុងចំណោមលោកសង្ឃ ដែលរៀនសូត្រនៅតាមសាលាបាលី ហើយនៅឆ្នាំ១៩៤២ អាចារ្យហែមចៀវ ដែលជាគ្រូសាលាបាលីជាមួយនឹងលោក ប៊ុន ចាន់ម៉ុល និងលោក ប៉ាច ឈឿន បានដឹកនាំបាតុកម្មលោកសង្ឃ ដែលគេឱ្យឈ្មោះថា «កុប្បកម្មធត្រ» (La révolte des ombrelles)។ បារាំងបានចាប់មេដឹកនាំបាតុកម្ម មានលោក ប៊ុន ចាន់ម៉ុល និងអាចារ្យហែមចៀវទៅជាក់គុកនៅលើកោះ។ លោក សឺង ង៉ុកថាញ់បានរត់ទៅនៅប្រទេសជប៉ុន ហើយនៅក្នុងសង្គ្រាមលោកលើកទី២ នៅពេលដែលជប៉ុនចូលមកកាន់កាប់ប្រទេសកម្ពុជា ត្រូវបានជប៉ុនលើកបន្តុបជានាយករដ្ឋមន្ត្រីរហូតដល់ពេលជប៉ុនចាញ់សង្គ្រាមលោកលើកទី២។

(១) ចលនាខ្មែរឥស្សរៈ៖ ចលនាខ្មែរឥស្សរៈ គឺជាចលនាដែលខ្មែរមាននិន្នាការប្រឆាំងបារាំងបង្កើតឡើង ក្នុងគោលដៅទាមទារឯករាជ្យពីបារាំង។ នៅក្នុងចលនានេះមានចរន្តបីសំខាន់ ៖ (១) ចរន្តខ្មែរសេរី ដែលដឹកនាំដោយលោក សឺង ង៉ុកថាញ់ (២) ចរន្តជាតិនិយមដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម ច័ន្ទរង្សី និង (៣) ចរន្តខ្មែរវៀតមិញ។ ចរន្តទាំងបីបានរួបរួមគ្នា ហើយបង្កើតបានជាចលនាខ្មែរឥស្សរៈឆ្នាំ១៩៤៧ នៅទីក្រុងបាងកក ប្រទេសថៃ ដើម្បីទាមទារឯករាជ្យពីបារាំង។ នៅក្នុងចលនាខ្មែរឥស្សរៈនេះ គេក៏បានចាត់តាំងឱ្យមានបញ្ជាការរួមគ្នា ៖ ខ្មែរឥស្សរៈ និងវៀតមិញផងដែរ។ មានឥស្សរជនខ្មែរមួយចំនួនចូលរួម ដូចជា ជាប ឈួន, សៀវ ហេង និងឌុង ប៊ុនរត (នួន ជា ដែលជានិស្សិតនៅសាកលវិទ្យាល័យធម្មសាស្ត្រ) ដែលសហការជាមួយវៀតមិញ។ លោក សឺង ង៉ុកថាញ់បានទៅលាក់ខ្លួននៅភ្នំដងរែក ដោយប្រមូលបក្សពួកខ្លួនដូចជាលោក ហង្ស ធុនហាក់ ហើយ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បង្កើតបានជាក្រុមភ្នំដងរែក មានមានន័ន្ទាការសេរីនិយម។

(៦) ព្រះរាជបូជនីយកិច្ចរបស់សម្តេចនរោត្តមសីហនុ ៖

ការផ្តល់ឯករាជ្យដល់កម្ពុជា ៖ បារាំងបានចូលមកគ្រប់គ្រងកម្ពុជាវិញ ក្រោយសង្គ្រាមលោកលើកទី២ ដោយផ្តល់សិទ្ធិកាន់តែច្រើនដល់ប្រជាពលរដ្ឋខ្មែរ។ នៅឆ្នាំ១៩៤៦ បារាំងផ្តល់«សិទ្ធិស្វ័យគ្រប់គ្រង»ដល់កម្ពុជាតាមរយៈការអនុម័តច្បាប់ស្តីពីគណបក្សនយោបាយ និងការរៀបចំការបោះឆ្នោតលើកទី១ នៅឆ្នាំ១៩៤៦។ គណបក្សដែលទទួលបានជោគជ័យគឺគណបក្សប្រជាធិបតេយ្យ ហើយរដ្ឋសភាកម្ពុជាត្រូវបានបង្កើតឡើង និងបានអនុម័តរដ្ឋធម្មនុញ្ញលើកទី១ ដែលយកតាមគំរូបារាំង និងប្រកាសឱ្យប្រើប្រាស់នៅឆ្នាំ១៩៤៧។ តាមសន្ធិសញ្ញាក្រុងបារីសឆ្នាំ១៩៤៩ បារាំងបានផ្តល់«ឯករាជ្យផ្នែកក្នុង»ដល់កម្ពុជា ក្នុងក្របខ័ណ្ឌសហព័ន្ធបារាំង និងបានលុបចោលរបបអាណាព្យាបាល។ កម្ពុជាទទួលសិទ្ធិក្នុងការគ្រប់គ្រងកងទ័ព ដែលស្ថិតក្រោមការត្រួតត្រាផ្ទាល់របស់ព្រះមហាក្សត្រ។ តែនៅពេលមានសង្គ្រាម កងទ័ពនេះត្រូវផ្ទេរឱ្យស្ថិតនៅក្រោមគណៈកម្មាធិការយោធាពិសេសនៅក្រោមទីបញ្ជាការរបស់បារាំង។ បារាំងនៅទទួលខុសត្រូវ ក្នុងការគ្រប់គ្រងប្រព័ន្ធតុលាការ និងការតែងតាំងអគ្គរាជទូតកម្ពុជានៅបរទេស។

នៅឆ្នាំ១៩៥៣ សម្តេចសីហនុបានចាប់ផ្តើម«ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យពីបារាំង» ដោយរំលាយរាជរដ្ឋាភិបាល ព្យួររដ្ឋធម្មនុញ្ញ រំលាយរដ្ឋសភា និងប្រកាសខ្លួនជានាយករដ្ឋមន្ត្រី ក្នុងគោលដៅទាមទារឯករាជ្យទាំងស្រុងពីបារាំង។ ព្រះអង្គបានយាងទៅប្រទេសបារាំង ដើម្បីបញ្ចុះបញ្ចូលរដ្ឋាភិបាលបារាំងឱ្យធាប់ប្រគល់ឯករាជ្យ ដោយខ្វាចប្រជាពលរដ្ឋខ្មែរងាកទៅរកសឹង ង៉ុកថាញ់ និងខ្មែរឥស្សរៈ។ ដោយបារាំងមិនយល់ព្រម ព្រះអង្គបានយាងទៅប្រទេសជប៉ុន សហរដ្ឋអាមេរិក និងកាណាដា។ នៅទីបញ្ចប់ ព្រះអង្គបានយាងទៅនិរទេសខ្លួននៅប្រទេសថៃនៅខែឧសភា

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឆ្នាំ ១៩៥៣ ហើយក៏សុខចិត្តត្រលប់មកវិញ នៅពេលបារាំងប្រគល់ឯករាជ្យ ដល់កម្ពុជានៅថ្ងៃ៩ វិច្ឆិកា ១៩៥៣។

សង្គ្រាមឥណ្ឌូចិនលើកទី១ និងសន្និសីទទីក្រុងហ្សឺណែវ ៖ នៅឆ្នាំ ១៩៣០ ពួកកុម្មុយនីស្តវៀតណាម ក្រោមការដឹកនាំរបស់លោក ហូ ជីមិញ បានបង្កើតបក្សកុម្មុយនីស្តឥណ្ឌូចិន ដើម្បីរំដោះឧបទ្វីបឥណ្ឌូចិនពីនឹម អាណានិគមនិយមបារាំង។ សង្គ្រាមឥណ្ឌូចិនលើកទី១បានផ្ទុះឡើងរវាង ចលនារំដោះវៀតណាម ឬវៀតមិញ និងរដ្ឋការអាណានិគមនិយមបារាំង។ នៅឆ្នាំ១៩៥០ សង្គ្រាមកូរ៉េបានផ្ទុះឡើង ដែលជាការចាប់ផ្តើមនៃសង្គ្រាម ត្រជាក់រវាងប្លុកលោកសេរី និងប្លុកកុម្មុយនីស្ត។ បន្ទាប់ពីសង្គ្រាមនៅកូរ៉េ បានចប់នៅឆ្នាំ១៩៥៣ ពួកកុម្មុយនីស្តបានដឹកកាំភ្លើងពីកូរ៉េកាត់ចិន ដើម្បី ផ្តល់ឱ្យទ័ពវៀតណាមវាយបារាំង ក្នុងសង្គ្រាមឥណ្ឌូចិនទី១។ កងទ័ពវៀត-ណាមខាងជើងបានលើកកាំភ្លើងធំទៅដំឡើងលើកំពូលភ្នំព័ទ្ធជុំវិញព្រលាន យន្តហោះ និងមូលដ្ឋានសឹកបារាំងនៅដៀនបៀនភូ ហើយបានវាយឈ្នះ កងទ័ពបារាំងនៅឆ្នាំ១៩៥៤។ បារាំងចាញ់សង្គ្រាមនៅដៀនបៀនភូ ហើយ សម្រេចចិត្តចាកចេញពីឥណ្ឌូចិន ហើយផ្ទេរតួនាទីប្រយុទ្ធនឹងការរាលដាល នៃលទ្ធិកុម្មុនិស្តឱ្យអាមេរិកវិញម្តង។ សម្រាប់សហរដ្ឋអាមេរិក សង្គ្រាមនៅ វៀតណាមបានចាប់ផ្តើមឡើង។ បារាំងបានកោះប្រជុំសន្និសីទនៅហ្សឺណែវ ដើម្បីផ្តល់ឯករាជ្យដល់កម្ពុជា វៀតណាម និងឡាវ។

១០-អក្សរសិល្ប៍ខ្មែរនៅសតវត្សទី១៩ និងដើមសតវត្សទី២០

កវីនិពន្ធ និងបញ្ហាវន្តខ្មែរនៅចុងសតវត្សទី១៩ និងនៅដើមសតវត្ស ទី២០មាន ៖

(១) ហ្មឺនកត្តីអក្សរ តន់ គឺជាមន្ត្រី និងជាអ្នកនិពន្ធ ដែលបានសរសេរ រឿង«សព្វសិទ្ធិ» នៅឆ្នាំ១៨៩៩ នៅក្នុងការិយាល័យរបស់លោកនៅក្នុង ព្រះបរមរាជវាំង។ លោកបានជំនុំប្រឹក្សាអំពីវិជ្ជាផ្សេង។ ដូចជាសាស្ត្រាវិមាន

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ចន្ទ ទិព្វសង្វារជាដើម[23]។

(២) ព្រះបទុមត្ថេរ សោម (១៨៥២-១៩៣២) គឺជាកវីដ៏ល្បី ដែលមានស្រុកកំណើតនៅខេត្តព្រៃវែង។ នៅពេលមានអាយុ២១ឆ្នាំ ព្រះអង្គបានបួសជាភិក្ខុ និងបានបន្តការសិក្សានៅភ្នំពេញអស់ជាច្រើនឆ្នាំ ហើយបានវិលទៅធ្វើជាចៅអធិការនៅវត្តកំព្រាខេត្តព្រៃវែងវិញ។ ព្រះអង្គបាននិពន្ធស្នាដៃដ៏ល្បីល្បាញគឺ៖ រឿងទុំទាវ (១៩១៥)។

(៣) ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ (១៨៥៩-១៩២៤) បានបួសរៀននៅតាមវត្តដល់មានអាយុបាន២០ឆ្នាំ បានបួសជាភិក្ខុនៅវត្តកែវ ហើយបានទៅរៀននៅទីក្រុងបាត់ដំបងអស់រយៈពេល៧ឆ្នាំ។ លោកបានលាចាកសិក្ខាបទនៅពេលមានជន្មាយុ៣៧ឆ្នាំ។ ដល់មានជន្មាយុ៥៥ឆ្នាំ លោកបានមកធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ ខាងតែងវចនានុក្រម និងផ្សៀងផ្ទាត់គម្ពីរដីកា។ លោកគឺជាអ្នកនិពន្ធខ្មែរដ៏ល្បីម្នាក់ ដែលបាននិពន្ធរឿង«គតិលោក» (១៩២០) ចំនួន១០ភាគ ដែលត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សាជាតិ «និវាសនគរវត្ត» (១៩២៦) ជាពាក្យកាព្យ រឿងអំបែងបែក បឋមសម្ពោធិ លោកនីតិបករណ៍ (ជាពាក្យកាព្យ) សុភាសិតប្បាប់ស្រី ក្បួនមេកាព្យ និងស្នាដៃឯទៀតចំនួន៤៤មុខ[24]។

(៤) ឧកញ៉ាសន្ធរវោហារ ម៉ុក[25] (១៨៨០-១៩៣០) មាននាមដើម ម៉ុក សំឱកជាភ្នាក់ងារនៅក្នុងព្រះបរមរាជវាំង និងជាអ្នកនិពន្ធដ៏ល្បីម្នាក់។ លោកបានប្រឡងជាប់សញ្ញាបត្របឋមសិក្សាបំពេញវិជ្ជាផុតថ្នាក់ ហើយបានចូលបម្រើជាគ្រូបង្រៀនចាប់តាំងពីអាយុ២៣ឆ្នាំ។ លោកត្រូវបានព្រះបាទសម្តេចព្រះនរោត្តមតែងតាំងឱ្យធ្វើជាចាងហ្វាងក្រមព្រះអាលក្ខណ៍ ហើយជាគ្រូលើនាម៉ឺនទាំងឡាយខាងការបង្ហាត់បង្រៀនពីប្បាប់រាជការ។

---

23 អត្ថបទលោករឹម គិន ក្នុងទស្សនាវដ្តីមិត្តសាលាចាលី ទំព័រ ១៦០ (ម៉ុញ សារី (២០១១) ទំព័រ ៣៦៧)។

24 ម៉ុញ សារី (២០១១) ទំព័រ៦៦៦។

25 លី ជាមតេង (១៩៦០) «អក្សរសាស្ត្រខ្មែរ» ទំព័រ៤៦។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

លោកបានសរសេរកំណាព្យជាច្រើន និងបានសរសេររឿង«ទេវន្ត» រឿង «ទុំទាវ» មុនរឿងទុំទាវរបស់កិក្តុសោម។

(៥) ឧកញ៉ាវិបុលរាជសេនា នួ កន (១៨៧៦-១៩៤៧) មានដើមកំណើតនៅឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ។ លោកបានបួសរៀននៅវត្ត រួចសឹកមកវិញដើម្បីចូលធ្វើការជាស្មៀនក្នុងរាជការ។ ក្នុងឆ្នាំ១៩០២ លោកបានប្រឡងជាប់លេខ១ខាងអក្សរសាស្ត្រខ្មែរ និងបានសញ្ញាបត្ររាជការ ហើយក៏ត្រូវបានតែងតាំងជាចៅហ្វាយខេត្តកំពង់សៀម។ បន្ទាប់មកលោកបានក្លាយជាជំនាញការខាងច្បាប់ និងត្រូវបានតែងតាំងជាចាង-ហ្វាងសាលាឧទ្ធរណ៍។ បន្ទាប់ពីបានទៅរៀនបំពេញវិជ្ជាខាងរបៀបរាជការនៅប្រទេសបារាំងអស់រយៈពេល៩ខែ លោកត្រូវបានតែងតាំងជាកូឈួយសេនាបតីក្រសួងក្សេត្រាធិការ មានគោរមងារជាឧកញ៉ាវិបុលរាជសេនា។ លោកបាននិពន្ធរឿងជាច្រើន ដូចជារឿងពិម្ពាទិព្វាន (១៩២០) និងរឿង «ទាវឯក» (១៩៦២ ជាប់រង្វាន់លេខ១ ក្នុងការប្រឡងអក្សរសាស្ត្រក្នុងឆ្នាំ ១៩៦៤) និងរឿងដទៃទៀត។

(៦) កិរម្យាសា អ៊ូ លៅ ង៉ុយ (១៨៦៥-១៩៣៦) បានបួសរៀននៅវត្តអង្គបីឯចក ភូមិបៃកស្ពរ ឃុំបៃកចាន។ លោកបានទៅស្វែងរៀននៅវត្តដទៃទៀតជាច្រើន ដើម្បីបំពេញចំណេះដឹងរបស់លោក។ ចេះដឹងល្មមហើយ លោកបានលាចាកសិក្ខាបទមកនិពន្ធស្នាដៃពាក្យកាព្យចំនួន៩គឺ ៖ ច្បាប់ល្បើកថ្មី (ឆ្នាំ១៩២២) ច្បាប់កេរកាលថ្មី (១៩២២) សេចក្តីរំឭកជាស់តឿន (ឆ្នាំ១៩៣១) ច្បាប់ប្រដៅទូន្មានជនប្រុសស្រី និងបណ្តាំ ក្រមង៉ុយ (ឆ្នាំ១៩៣៥)។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំពូក៩
សង្គមរាស្ត្រនិយម
(១៩៥៣-១៩៧០)

ការបង្កើតប្លុកយោធា ៖ លើឆាកអន្តរជាតិ ទសវត្សរ៍ឆ្នាំ១៩៥០ និង ១៩៦០ គឺជាដំណាក់កាលដំបូងនៃសង្គ្រាមត្រជាក់ និងការប្រណាំងប្រជែង រវាងមហាអំណាចនៃប្លុកទាំងពីរ -មូលធននិយម និងសង្គមនិយម- ដើម្បី ពង្រីកឥទ្ធិពលរបស់ខ្លួន។ សណ្តាប់ធ្នាប់ពិភពលោកចែកជាប៉ូលពីរក្រោយ សង្គ្រាមលោកលើកទី២។ សន្ធិសីទបាន់ឌុង នៅឆ្នាំ១៩៥៥ បង្កើតចលនា ថ្មីមួយ ដែលប្រកាន់ជំហរអព្យាក្រឹត គឺចលនាមិនចូលបក្សសម្ព័ន្ធនៅចន្លោះ មហាអំណាចធំៗទាំងពីរ។ ចិន និងឥណ្ឌាក៏បានបង្ហាញពីមហិច្ឆតាត្រួតត្រា ចលនានេះផងដែរ។ កម្ពុជាប្រៀបបាននឹងកូនក្រមុំ ដែលមានកំលោះៗ ជាច្រើនតាមចែចង់។

សណ្តាប់ធ្នាប់សកលលោកថ្មី ៖ ក្រោយសង្គ្រាមលោកលើកទី២ អង្គការសហប្រជាជាតិត្រូវបានបង្កើតឡើង ដើម្បីការពារសន្តិភាព និង បញ្ចៀសសង្គ្រាម ដោយហាមឃាត់ការធ្វើសង្គ្រាម ដើម្បីដោះស្រាយជម្លោះ រវាងប្រទេស។ សណ្តាប់ធ្នាប់ពាណិជ្ជកម្មត្រូវបានកំណត់ដោយកិច្ចព្រម-ព្រៀងទូទៅស្តីពីអត្រាពន្ធគយ និងពាណិជ្ជកម្ម (GATT) ហើយក្រោយ មកប្រែក្លាយទៅជាអង្គការពាណិជ្ជកម្មពិភពលោក (WTO)។ ក្នុងវិស័យ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

យោជា ប្រទេសលោកខាងលិចបង្កើតអង្គការ NATO ដើម្បីបង្កើតសម្ព័ន្ធមិត្តជួយការពារគ្នា ហើយប្រទេសសង្គមនិយមបង្កើតអង្គការសន្ធិសញ្ញាក្រុងវ៉ារស្សាវ៉ៃ។ ក្នុងវិស័យសេដ្ឋកិច្ច អឺរ៉ុបខាងលិចបង្កើតសហគមន៍អឺរ៉ុប ហើយប្រទេសអឺរ៉ុបខាងកើតបង្កើតក្រុមប្រឹក្សាជួយសេដ្ឋកិច្ចគ្នាទៅវិញទៅមក (COMECON)។

ចលនាផ្តល់ឯករាជ្យដល់ប្រទេសអាណានិគម ៖ របបអាណានិគមនិយមបានរង្គោះរង្គើក្រោយសង្គ្រាមលោកលើកទី២។ ឥណ្ឌាទទួលបានឯករាជ្យនៅឆ្នាំ១៩៤៧ពីចក្រភពអង់គ្លេស ហើយនៅអំឡុងទសវត្សរ៍ឆ្នាំ១៩៥០ និង១៩៦០ ប្រទេសអាណានិគមនិយមស្ទើរតែទាំងអស់ទទួលបាននូវឯករាជ្យភាពរបស់ខ្លួន។ ក្រោយសង្គ្រាមលោកលើកទី២ ប្រធានាធិបតី Truman ប្រកាសគោលនយោបាយហ៊ឹមព័ទ្ធការរាលដាលនៃលទ្ធិសង្គមនិយម ហើយអាមេរិកបានចូលមកដើរតួនាទីការពារតំបន់ ជំនួសឱ្យបារាំងនៅឥណ្ឌូចិន។

សង្គ្រាមឥណ្ឌូចិនលើកទី២ ៖ កត្តាភូមិសាស្ត្រនយោបាយបន្តមានឥទ្ធិពលយ៉ាងខ្លាំងក្លាមកលើស្ថានភាពនយោយក្នុងប្រទេសកម្ពុជា។ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ចែកចេញជាពីរផ្នែក ៖ ឥណ្ឌូចិនដែលទទួលរងឥទ្ធិពលយ៉ាងខ្លាំងក្លាពីចិន និងវៀតណាម និងអាស៊ីអាគ្នេយ៍ដែនកោះនិងថៃ ដែលទទួលរងនូវមនោគមវិជ្ជាសេរីនិយម។ បន្ទាប់ពីសន្និសីទទីក្រុងហ្សឺណែវនៅឆ្នាំ១៩៥៤ បារាំងបានដកថយចេញពីអាស៊ីអាគ្នេយ៍ ហើយផ្ទេរតួនាទីតំបន់ឱ្យទៅសហរដ្ឋអាមេរិកដើម្បីទប់ទល់ការរាលដាលនៃលទ្ធិសង្គមនិយម។ សហរដ្ឋអាមេរិកគាំទ្រវៀតណាមខាងត្បូង ហើយចិន និងសហភាពសូវៀតគាំទ្រវៀតណាមខាងជើង។ សង្គ្រាមឥណ្ឌូចិនលើកទី២បានផ្ទុះឡើងរវាងវៀតណាមខាងជើង និងវៀតណាមខាងត្បូង។ នៅឆ្នាំ១៩៦៥ វៀតណាមប្រកាសនយោបាយបង្រួបបង្រួមជាតិ និងបានបង្កើតផ្លូវលំហូជីមិញ ដើម្បីដឹកគ្រឿងសព្វាវុធនិងស្បៀងពីចិន និងសហភាពសូវៀតទៅកាន់វៀតណាមខាងត្បូង។ អ្នកនយោបាយខ្មែរបានបែកបាក់ជាច្រើនពួក ៖ ខ្មែរក្រហម

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្មែរស៊ីជំពូ ខ្មែរស ខ្មែរសីហនុនិយម និងខ្មែរខៀវៗលៅ ដំណាក់កាលនេះ គឺជាដំណាក់កាលនៃល្បែងលាបព័ណ៌ឱ្យគ្នា។ តើសង្គ្រាមត្រជាក់មានបច្ច័យអ្វីខ្លះមកលើកម្ពុជា?

គេអាចបែងចែកព្រឹត្តិការណ៍នៃសម័យសង្គមរាស្ត្រនិយមជាដំណាក់កាលសំខាន់ៗដូចតទៅ ៖ (១) ១៩៥៣-១៩៦៣ គឺជាដំណាក់កាលកសាងជាតិ (២) ១៩៦៤-១៩៦៧ គឺជាដំណាក់កាលងាកទៅឆ្វេង និង (៣) ១៩៦៨-១៩៧០ គឺជាដំណាក់កាលងាកទៅខាងស្តាំ។

១-តើអង្គការនយោបាយសង្គមរាស្ត្រនិយមដែលបង្កើតឡើងដោយសម្តេចនរោត្តម សីហនុអាចបង្រួបបង្រួមអ្នកនយោបាយខ្មែរគ្រប់និន្នាការ និងមហាជនជុំវិញព្រះមហាក្សត្រ ដើម្បីកសាងប្រទេសជាតិដែរឬទេ?

សម្តេចនរោត្តម សីហនុ គឺជាព្រះមហាក្សត្រ ដែលតែងតែធ្វើឱ្យគេឯងភ្ញាក់ផ្អើលគ្រប់គ្នា ដោយសារព្រះអង្គមានឧបនិស្ស័យធ្វើនយោបាយ។ ការទាមទារឯករាជ្យពីបារាំង ធ្វើឱ្យប្រជាប្រិយភាពរបស់ព្រះអង្គកើនឡើង ហើយដែលគេប្រសិទ្ធនាមថា ជាព្រះបិតាឯករាជ្យជាតិ។ ក៏ប៉ុន្តែ ព្រះអង្គនៅមិនទាន់មានគម្រោងច្បាស់លាស់ក្នុងការកសាងជាតិនៅឡើយ។ ផ្ទុយទៅវិញ គណបក្សប្រជាធិបតេយ្យបានប្រមូលផ្តុំបញ្ញវន្តពីគ្រប់ស្រទាប់ជាន់ថ្នាក់ និងបានរៀបចំជាកម្មវិធីនយោបាយយ៉ាងទាក់ទាញ ដែលធ្វើឱ្យគណបក្សនេះមានប្រជាប្រិយភាពយ៉ាងខ្លាំងក្លាលើឆាកនយោបាយជាតិ។ ម្យ៉ាងវិញទៀត គណបក្សប្រជាធិបតេយ្យដឹកនាំដោយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ដែលមានទិន្នាការប្រឆាំងបារាំង និងជាខ្សែស្តេចដូចព្រះអង្គផងដែរ។ ស្ថិតនៅក្នុងស្ថានភាពភូមិសាស្ត្រនយោបាយសង្គ្រាមត្រជាក់ និងការប្រយុទ្ធគ្នាយ៉ាងស្វិតស្វាញរវាងកម្លាំងបដិបក្សស្តាំ និងឆ្វេងនិយម សម្តេចសីហនុបានប្រើប្រាស់យុទ្ធសាស្ត្រ«បំបែកកម្លាំង ដើម្បីត្រួតត្រា» ក្នុងគោលដៅបង្កើត

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាឧត្រុនយោបាយមួយក្រោមស្លាក«សង្គមវាស្រ្តនិយម» ឬ«សង្គមនិយមព្រះពុទ្ធសាសនា» ដើម្បីធ្វើអព្យាក្រឹតភាវូបនីយកម្មកម្ទាំងនយោបាយ និងបង្រួបបង្រួមជាតិ កសាងប្រទេស។

ក-ការបំបែកគណបក្សប្រជាធិបតេយ្យ និងការបង្កើតចលនាសង្គមវាស្រ្តនិយម

ក្រោយសង្គ្រាមលោកលើកទី២ បារាំងបានបង្កើតប្រព័ន្ធនយោបាយនៅកម្ពុជា ដែលស្រដៀងនឹងប្រព័ន្ធបារាំងដែរ។ ដើម្បីជៀសវាងមិនឱ្យមានរដ្ឋប្រហារផ្តួលរំលំរបបវាជានិយមដូចនៅប្រទេសថៃ ជម្រើសដ៏សមស្របមួយ គឺការបង្កើតរបបវាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ ក្នុងន័យនេះ ថ្វីត្បិតតែបារាំងនៅរក្សារបបអាណាព្យាបាល តែបារាំងផ្តល់សិទ្ធិកាន់តែច្រើនមកឱ្យខ្មែរ។ ក្នុងបរិការណ៍នេះ គណបក្សប្រជាធិបតេយ្យត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៤៦ និងទទួលអាសនៈចំនួន៥០លើ៦៧ នៅក្នុងការបោះឆ្នោតឆ្នាំ១៩៤៦ និង៥៥ នៅឆ្នាំ១៩៥១។ គណបក្សនេះដឹកនាំដោយព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ដែលជាបណ្ឌិតខាងផ្នែកគណិតវិទ្យាពីប្រទេសបារាំង មាននិន្នាការនយោបាយប្រឆាំងបារាំង តែចង់ឱ្យកម្ពុជាអនុវត្តលទ្ធិប្រជាធិបតេយ្យបែបបារាំង និងមានទំនាក់ទំនងជាមួយខ្មែរឥស្សរៈ ដែលគាំទ្រដោយថៃ។ គណបក្សនេះគាំទ្រដោយសារព័ត៌មាននគរវត្តរបស់ប៉ាច ឈឺន និងសឺង ង៉ុកថាញ់ សង្ឃគណៈមហានិកាយ អ្នកនយោបាយវៀតណែង និងបញ្ញវន្តខ្មែរ។ គណបក្សនយោបាយពីរផ្សេងទៀតគឺ ៖ គណបក្សសេរីភាពដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត ដែលជាអ្នកអភិរក្សនិយម កុំឱ្យលឿនពេក និងគួរពីងបារាំងតទៅទៀត ដោយមានការគាំទ្រដោយវណ្ណៈអ្នកមាន និងក្តីម្តីធំៗ។ គណបក្សចម្រើនជាតិ ដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម ម៉ុងតាណា។

កោះសន្តិភាព ៖ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ និង១៩៦០ កម្ពុជា គឺជា

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កោះសន្តិភាពក្នុងភ្នក់ភ្លើងនៃសង្គ្រាមនៅវៀតណាម។ បន្ទាប់ពីបានឯករាជ្យ ពីបារាំងនៅឆ្នាំ១៩៥៣ កម្ពុជាបានខិតខំប្រឹងប្រែងកសាងជាតិក្នុងគ្រប់វិស័យ ដោយពឹងផ្អែកលើធនធានក្នុងស្រុកផង និងដោយពឹងផ្អែកលើជំនួយពីក្រៅប្រទេសផង។ នៅលើឆាកជាតិ ដំណាក់កាលនេះ គឺជាដំណាក់កាលតស៊ូនយោបាយរវាងកម្លាំងស្តាំនិយម និងកម្លាំងឆ្វេងនិយម ដើម្បីកសាងមូលដ្ឋានកសិកម្ម បង្កើតវោងចក្រឧស្សាហកម្ម និងការកសាងប្រព័ន្ធសេវាកម្ម ជាពិសេសប្រព័ន្ធធនាគារទំនើប និងការបណ្តុះបណ្តាលធនធានមនុស្ស។ វិស័យអប់រំបានក្លាយទៅជាវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ក្នុងការកសាងប្រទេសជាតិ។

ម្យ៉ាងវិញទៀត ដោយមានការគាំទ្រពីបារាំង សម្តេចសីហនុបានដាក់ចេញនូវនយោបាយធ្វើឱ្យគណបក្សប្រជាធិបតេយ្យចុះខ្សោយ តាមរយៈការអូសទាញកម្លាំង ការបំបែកបំបាក់ និងការប្រមូលកម្លាំងទាំងឆ្វេងនិយម និងទាំងស្តាំនិយមចូលក្នុងឆត្រនយោបាយរបស់ព្រះអង្គ។ ព្រះអង្គម្ចាស់យុត្តិវង្សសុគតដោយរបេងក្នុងឆ្នាំ១៩៤៧ ថ្នាក់ដឹកនាំជាន់ខ្ពស់មួយចំនួនត្រូវបានចាប់ខ្លួនក្រោមបទសហការជាមួយខ្មែរឥស្សរៈ លោកអៀវ តើសដែលស្នងតំណែងទ្រង់យុត្តិវង្ស ត្រូវបានគេធ្វើឃាតក្នុងឆ្នាំ១៩៥០។ សម័យក្រោយឯករាជ្យ សម្តេចសីហនុបានក្លាយទៅជាព្រះបិតាកសាងជាតិ ដោយព្រះអង្គចាប់ផ្តើមពីការអភិវឌ្ឍវិស័យអប់រំ ការកសាងទំនប់ប្រឡាយទឹក តាមរយៈការងារហត្ថកម្ម និងការបង្កើតវោងចក្រឧស្សាកម្មថ្មីៗ។ លើផ្នែកនយោបាយ បន្ទាប់ពីធ្វើឱ្យគូប្រណាំងប្រជែងចុះខ្សោយហើយ សម្តេចសីហនុបានបង្កើតចលនាសង្គមរាស្ត្រនិយម ជាជម្រកនយោបាយដល់គ្រប់និន្នាការទាំងអស់។ ព្រះអង្គបានជ្រើសរើសយក«សង្គមនិយមព្រះពុទ្ធសាសនា»ជាមនោគមវិជ្ជា។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ខ-ការបង្កើតចលនាខ្មែរក្រហម និងការពង្រឹងក្រុមស្តាំនិយម

កំណែទម្រង់សេដ្ឋកិច្ច ៖ ក្នុងគោលដៅពង្រឹងតួនាទីរបស់រដ្ឋ របប សង្គមវាស្ត្រនិយមបានអនុវត្តកំណែទម្រង់ធនាគារ និងពាណិជ្ជកម្មក្រៅប្រទេស។ រដ្ឋបានបង្កើតក្រុមហ៊ុនអាហរ័ណទីហរ័ណជាតិ ដែលមានឈ្មោះថា សូណិចស៊ីម (ទុនរដ្ឋ៦០% ទុនឯកជន៤០%) ដើម្បីធ្វើប្រតិបត្តិការនាំចូល និងនាំចេញជំនួសពាណិជ្ជករឯកជន និងបង្កើតធនាគារពាណិជ្ជរដ្ឋ ដែលមានឈ្មោះថា ឥណទានជាតិ ដែលមានតួនាទីផ្តល់ឥណទានជំនួសធនាគារបរទេស។ នៅឆ្នាំ១៩៦៤ រដ្ឋបានបង្កើតក្រុមហ៊ុនទិញកសិផល និងក្រុមហ៊ុនចែកចាយទំនិញនាំចូល ដើម្បីជួយដល់ក្រុមហ៊ុននាំចេញនាំចូល សូណិចស៊ីម។ ក៏ប៉ុន្តែ ក្រុមហ៊ុនរដ្ឋទាំងនេះដំណើរការគ្មានប្រសិទ្ធភាព ដោយសារតែអំពើពុករលួយ និងធ្វើឱ្យមានវិបត្តិសេដ្ឋកិច្ចទៅវិញ។

សង្គមវាស្ត្រនិយម ៖ «សង្គមវាស្ត្រនិយម»របស់សម្តេចសីហនុមិនបានដាក់ចេញកម្មវិធីកំណែទម្រង់ដោះស្រាយបញ្ហាសង្គមឡើយ ធ្វើឱ្យព្រះអង្គទទួលរងសម្ពាធយ៉ាងខ្លាំងពីពួកធ្វេងនិយម។ ម្យ៉ាងវិញទៀត ការអនុវត្តគោលនយោបាយសេដ្ឋកិច្ចបង្កើត«វិស័យសេដ្ឋកិច្ចរដ្ឋ» ដែលពេញនិយមនៅជំនាន់នោះ ធ្វើឱ្យការគ្រប់គ្រងសេដ្ឋកិច្ចគ្មានប្រសិទ្ធភាព ហើយ«វិស័យសេដ្ឋកិច្ចរដ្ឋ»បានក្លាយទៅជាប្រភពនៃអំពើពុករលួយ ដែលរុញគ្រូបង្រៀន និងបញ្ញវន្តវ័យក្មេង ដែលព្រះអង្គបណ្តុះបណ្តាលឱ្យជាកទៅរកនិន្នាការធ្វេងនិយម ដែលសម្តេចសីហនុប្រសិទ្ធនាមឱ្យថា «ខ្មែរក្រហម»។ អ្នកនយោបាយស្តាំនិយម និងពួកយោធាទទួលការគាំទ្រយ៉ាងខ្លាំងពីបស្ចិមប្រទេស ដែលបង្កើតយន្តការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលស៊ីវិល និងយោធាខ្មែរ។ ជំនួយយោធារបស់សហរដ្ឋអាមេរិកមានគោលដៅសំខាន់ គឺការពង្រឹងកម្លាំងស្តាំនិយម ដើម្បីទប់ទល់នឹងចលនាកុម្មុយនីស្តកម្ពុជា។

កត្តានយោបាយក្នុងប្រទេស ៖ (១) វិបត្តិរាជបល្ល័ង្ក (២) បញ្ហា

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្កើតឡើងដោយពួកស្តាំនិយមដូចជាសម សារី និងការប៉ុនប៉ងបង្កើតចលាចលរបស់ជាប ឈួន។

ជម្លោះរាជបល្ល័ង្ក ៖ រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ត្រូវបានរៀបចំឡើងតាមគំរូនៃរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែលមិនអនុញ្ញាតឱ្យព្រះមហាក្សត្រលូកដៃចូលទៅក្នុងការគ្រប់គ្រងកិច្ចការរដ្ឋ។ ដើម្បីបន្តការដឹកនាំប្រទេសដោយផ្ទាល់ សម្តេចសីហនុបានដាក់រាជ្យថ្វាយព្រះបិតារបស់ព្រះអង្គ ព្រះបាទនរោត្តម សុរាម្រិត ហើយបានប្រកាសខ្លួនជានាយករដ្ឋមន្ត្រី ក្នុងគោលដៅបន្តដឹកនាំប្រទេស និងប្រឡូកក្នុងកិច្ចការនយោបាយកម្ពុជា។ នៅពេលដែលព្រះបិតារបស់ព្រះអង្គ ព្រះបាទសុរាម្រិតចូលទិវង្គត ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីវ៉ង្ស ដែលជាព្រះបិតុលារបស់ព្រះអង្គ និងជាប្រធានក្រុមប្រឹក្សារាជសម្បត្តិ ចង់ឡើងសោយរាជ្យ ហើយមិនព្រមតែងតាំងសម្តេចសីហនុជាព្រះមហាក្សត្រកម្ពុជា។ នៅពេលនោះ វិបត្តិរាជបល្ល័ង្កបានផ្ទុះឡើង ហើយបង្ហាញពីការប្រកួតប្រជែងរវាងខ្សែនរោត្តម និងស៊ីសុវត្ថិ នៅក្នុងរាជវង្សខ្មែរ។ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីវ៉ង្ស ធ្លាប់ជាបេក្ខភាពដើម្បីក្លាយជាព្រះមហាក្សត្រម្តងរួចទៅហើយ នៅឆ្នាំ១៩៦១ នៅពេលព្រះបិតារបស់ព្រះអង្គ ព្រះបាទស៊ីសុវត្ថិ មុនីវង្សចូលទិវង្គត។ ក៏ប៉ុន្តែនៅពេលនោះ អាជ្ញាធរបារាំងយល់ឃើញថា ដើម្បីសម្រុះសម្រួលរវាងខ្សែនរោត្តម និងស៊ីសុវត្ថិ នៅក្នុងរាជវង្សខ្មែរ មានតែជ្រើសរើសសម្តេចនរោត្តម សីហនុ ដែលមានព្រះរាជមាតាជាខ្សែស៊ីសុវត្ថិ ហើយព្រះរាជបិតាជាខ្សែនរោត្តមទេ ទើបអាចផ្សះផ្សារការប្រណាំងប្រជែងនេះបាន។ ម្យ៉ាងទៀត អាជ្ញាធរបារាំងយល់ឃើញថា សម្តេចនរោត្តម សីហនុ ដែលមានព្រះជន្មក្មេង ងាយស្រួលក្នុងការគ្រប់គ្រងជាងព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីវ៉ង្ស។ ដើម្បីដោះស្រាយវិបត្តិរាជបល្ល័ង្កនេះ សម្តេចនរោត្តម សីហនុបានរៀបចំឱ្យមានប្រជាមតិមួយ ដើម្បីរកការគាំទ្ររបស់រាស្ត្រខ្មែរ ដើម្បីឱ្យព្រះអង្គបន្តតំណែងទៀត។ បន្ទាប់ពីមានលទ្ធផលប្រជាមតិគាំទ្រដល់ព្រះអង្គរួចមក សម្តេចនរោត្តម សីហនុបានបង្កើតរាជ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

រដ្ឋាភិបាលថ្មីមួយ ដែលមានព្រះអង្គជានាយករដ្ឋមន្ត្រី។ ជម្ងោះរវាងខ្សែ នពោត្តម និងស៊ីសុវត្ថិ នៅក្នុងរាជវង្សខ្មែរនៅបន្តរហូតដល់រដ្ឋប្រហារទម្លាក់ សម្តេចនពោត្តម សីហនុ ដោយព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរីមតៈ និងលោក ឧត្តមសេនីយ លន់ នល់នៅឆ្នាំ១៩៧០។

គម្រោងការសម្ងាត់របស់ពួកស្តាំនិយម ៖ បន្ទាប់ពីបានបញ្ចប់ការ សិក្សាផ្នែកវិទ្យាសាស្ត្រនយោបាយនៅប៉ារីស សម សារីបានចូលរួមក្នុង សន្និសីទហ្សឺណែវ ជួយសម្តេចសីហនុបង្កើតចលនាសង្គមរាស្ត្រនិយម និង ឃោសនាបោះឆ្នោតឆ្នាំ១៩៥៥។ បន្ទាប់ពីមានរឿងអាស្រូវមួយចំនួន លោក បានដាកមកចងប៉ងបង្កើតគណបក្សប្រឆាំងសម្តេចនពោត្តម សីហនុ។ ក្នុងខែ មករា ឆ្នាំ១៩៥៩ សម្តេចសីហនុបានលើកឡើងពី«គម្រោងការសម្ងាត់នៃ ទីក្រុងបាងកក» ដែលនាយករដ្ឋមន្ត្រីថ្មីថៃ ឧត្តមនាវីក សារិទ្ធ ថាណាភ័ត បានរៀបចំឡើង។ សម សារីបានរត់ទៅរស់នៅប្រទេសថៃ។ មួយខែក្រោយ មក លេចឡើងនូវរឿងភ័រដាប ឈួន ដែលមានទំនោរចង់ប្រឆាំងនយោបាយ អែបអបកុម្មុយនីស្តរបស់សម្តេចសីហនុ។ តួអង្គស្តាំនិយមសំខាន់មួយទៀត គឺ សឺង ង៉ុកថាញ់។

គ-ការពង្រឹងចលនាតស៊ូឆ្វេងនិយម

ការបង្កើតបក្សកុម្មុនិស្តខ្មែរ ៖ ព្រឹត្តិការណ៍ដ៏សំខាន់នៅក្នុងទសវត្សរ៍ ឆ្នាំ១៩៥០ គឺការសម្រេចចិត្តរបស់ហូ ជីមិញ ក្នុងការរំលាយបក្សកុម្មុយនីស្ត ឥណ្ឌូចិនក្នុងឆ្នាំ១៩៥១ ដើម្បីបង្កើតបក្សកុម្មុយនីស្តនៅក្នុងប្រទេសទាំងបី នៅឥណ្ឌូចិន។ ជនកុម្មុយនីស្តជាច្រើនមានគំនិតជាតិនិយមចង្អៀតចង្អល់ នៅឡើយ ហើយលទ្ធិអន្តរជាតិនិយមនៅមិនទាន់ជ្រួតជ្រាបនៅក្នុងស្រទាប់ ប្រជាជនឥណ្ឌូចិននៅឡើយ។ ដូច្នេះ ដើម្បីប្រយុទ្ធនឹងចលនាជាតិនិយម ក្នុងបក្ស មានតែការបង្កើតគណបក្សដាច់ដោយឡែកទេ ទើបធ្វើឱ្យការតស៊ូ នេះមានប្រសិទ្ធភាព។ ការបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរនៅថ្ងៃទី៦៩ ខែ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មិថុនា ឆ្នាំ១៩៥១ ដឹកនាំដោយខ្មែរវៀតមិញទូ សាមុត បង្កើតបានជាឧត្តនយោបាយថ្មីមួយ សម្រាប់ការតស៊ូជាសម្ងាត់របស់ពួកខ្មែរក្រហម។ ចាប់ពីឆ្នាំ១៩៦៣ដល់១៩៦៦ មេដឹកនាំកុម្មុយនីស្តខ្មែរបានទៅបោះទីតាំងនៅតាមព្រំដែនវៀតណាម ក្រោមកិច្ចការពាររបស់វៀតណាម។

ការបះបោរនៅសំឡូត ៖ កសិករខ្មែរបះបោរក្នុងឆ្នាំ១៩៦៧ ដោយសារតែវិបត្តិសេដ្ឋកិច្ចពិភពលោក ដែលធ្វើឱ្យថ្លៃកសិផលធ្លាក់ចុះ។ ប្រជាកសិករមិនពេញចិត្តនឹងក្រុមហ៊ុនទិញកសិផលរដ្ឋ ដែលទម្លាក់ថ្លៃទិញស្រូវឱ្យនៅយ៉ាងទាប។ កសិករខ្មែរនៅសំឡូតក៏បានបះបោរ ហើយកងទ័ពក៏បានបង្ក្រាបយ៉ាងព្រៃផ្សៃ។ កសិករដែលរួចផុតពីការបង្ក្រាបបានរត់ចូលព្រៃចូលរួមជាមួយចលនាតស៊ូប្រដាប់អាវុធ។ រាជរដ្ឋាភិបាលមានការសង្ស័យលើអ្នកនយោបាយឆ្វេងនិយម។ ចាប់ពីពេលនោះមក មេខ្មែរក្រហម ដូចជា ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹម ស្រាប់តែបាត់ខ្លួន ដោយរត់ចូលព្រៃ ដើម្បីចូលរួមក្នុងចលនាបដិវត្តន៍កម្ពុជា។ មេខ្មែរក្រហមបានរើទីបញ្ជាការរបស់ខ្លួនពីខេត្តកំពង់ចាមទៅកាន់ភូមិភាគឦសាន ដែលជាមូលដ្ឋានកងទ័ពវៀតកុង និងវៀតណាមខាងជើងនៅកម្ពុជា។ កងទ័ពវៀតណាមខាងជើងបានបង្កើតសាលានយោបាយ និងសាលាយោធា ដើម្បីជួយបណ្តុះបណ្តាលទ័ពខ្មែរក្រហមផងដែរ។ មូលដ្ឋានសឹកនៃកងទ័ពវៀតណាមខាងជើងត្រូវបានបង្កើតឡើងនៅតាមព្រំប្រទល់ខេត្តតាមព្រំដែនកម្ពុជា-វៀតណាម។

២-តើកម្ពុជាដឹកនាំដោយសម្តេចនរោត្តម សីហនុអាចប្រកាន់យកនយោបាយការបរទេសអព្យាក្រឹតបានឬទេ?

បន្ទាប់ពីសង្គ្រាមនៅកូរ៉ (១៩៥០-១៩៥៣) ត្រូវបានបញ្ចប់ ពួកកុម្មុយនីស្តចិន និងវៀតណាមបានដឹកសព្វាវុធពីកូរ៉ មកប្បាំងបាវាំងនៅវៀតណាម។ កងទ័ពវៀតណាមខាងជើងបានដោះកាំភ្លើងធំ ហើយលើកយកទៅដំឡើងលើកំពូលភ្នំជុំវិញមូលដ្ឋានសឹកបាវាំងនៅឌៀនបៀនភូ។ ការ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រយុទ្ធនៅឱ្យនៅលើដើមឆ្នាំ១៩៥៤ គឺជាដំណាក់ការចុងក្រោយនៃសង្គ្រាមឥណ្ឌូចិនលើកទី១។ បន្ទាប់ពីចាញ់សង្គ្រាម បារាំងយល់ព្រមរៀបចំសន្និសីទនៅហ្សឺណែវ ដើម្បីប្រគល់ឯករាជ្យដល់ប្រទេសកម្ពុជា វៀតណាម និងឡាវ។ ដើម្បីទប់ទល់នឹងការរាលដាលនៃលទ្ធិកុម្មុយនីស្ត អាមេរិកបានបង្កើតអង្គការសេអាតូ និងបង្កើតមូលដ្ឋានយោធានៅអាស៊ីអាគ្នេយ៍។ សន្និសីទហ្សឺណែវ ឆ្នាំ១៩៥៤ កំណត់ថា កម្ពុជាគឺជាប្រទេសអព្យាក្រឹតក្នុងគោលដៅកុំឱ្យសហរដ្ឋអាមេរិកដាក់មូលដ្ឋានយោធានៅកម្ពុជា។ ក៏ប៉ុន្តែ សភាពការណ៍នយោបាយពិភពលោក និងតំបន់បង្ហាញនូវនិន្នាការធំៗបីគឺ ៖

ក-សង្គ្រាមត្រជាក់រវាងអាមេរិក និង ប្លុកកុម្មុយនីស្ត

សង្គ្រាមត្រជាក់ គឺជាភាពតានតឹងក្នុងទំនាក់ទំនងអន្តរជាតិ ដែលបង្កើតឡើង ដោយសារសង្គ្រាមពាក្យសម្តី ការឃោសនា ការគំរាមកំហែង និងការរត់ប្រណាំងសព្វាវុធរវាងលោកខាងលិចដឹកនាំដោយសហរដ្ឋអាមេរិក និងប្លុកសង្គមនិយម ដឹកនាំសហភាពសូវៀតរវាងឆ្នាំ១៩៤៥ និង ១៩៩០។ សង្គ្រាមត្រជាក់ចាប់ផ្តើមពីគោលនយោបាយក្រៅប្រទេសរបស់សហរដ្ឋអាមេរិក ដែលមានគោលដៅហ៊ឹមព័ទ្ធ (containment) នយោបាយវាតទីនិយម (expansionism) របស់សហភាពសូវៀត។ ប្រទេសកំពុងអភិវឌ្ឍត្រូវបានចែកជាពីរ គឺ ៖ (១) ប្រទេសដែលរណបអាមេរិក និង (២) ប្រទេសដែលរណបសហភាពសូវៀត។ ក៏ប៉ុន្តែ ចលនាប្រទេសមិនចូលបក្សសម្ព័ន្ធត្រូវបានបង្កើតឡើង បន្ទាប់ពីសន្និសីទប្រទេសអាស៊ី និងអាហ្វ្រិក ដែលប្រព្រឹត្តទៅនៅបាន់ឌុង បានប្រកាសពីគោលការណ៍៦ខ ស្តីពីសន្តិសហវិជ្ជមាន។ ទំនាស់រវាងចិន និងសហភាពសូវៀតបានផ្ទុះឡើង ដោយសារចិនមានមហិច្ឆតាធ្វើជាមេដឹកនាំរបស់តតិយលោក។

នៅក្នុងបរិការណ៍នៃសង្គ្រាមត្រជាក់ សហរដ្ឋអាមេរិកបានចោះជំហានចូលឥណ្ឌូចិន ដោយផ្តល់ការគាំទ្រខាងផ្នែកយោធា និងហិរញ្ញវត្ថុដល់រដ្ឋ-

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កិបាលវៀតណាមខាងត្បូង និងទិតទំទាក់ទាញព្រះរាជាណាចក្រកម្ពុជាឱ្យ
ស្ថិតនៅរណបអាមេរិក។ ចិន និងសហភាពសូវៀតក៏ចាប់ផ្តើមផ្តល់ការគាំទ្រ
ខាងផ្នែកយោធា និងហិរញ្ញវត្ថុដល់វៀតណាមខាងជើង ហើយសង្គ្រាម
ឥណ្ឌូចិនលើកទី២បានផ្ទុះឡើង។ អាមេរិកបានបញ្ជូនកងទ័ពប្រមាណជា
កន្ទុះលាននាក់មកជួយច្បាំងនៅវៀតណាមខាងជើង។

ទសវត្សរ៍ឆ្នាំ១៩៦០ គឺជាដំណាក់កាលថ្មីមួយដែលនយោបាយក្រៅ
ប្រទេសរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវរេចុះរេឡើងដូចប៉ោលនាឡិកា
(The Swinging Sixties) ៖ ពីនយោបាយក្រៅប្រទេសអព្យាក្រឹតទៅនយោ-
បាយចងសម្ព័ន្ធមិត្តជាមួយចិន និងវៀតណាមក្នុងគោលដៅប្រើប្រាស់
កម្លាំងខាងក្រៅ ដើម្បីដាក់សម្ពាធលើកម្លាំងខាងក្នុង ជាពិសេសអ្នកនយោ-
បាយឆ្វេងនិយម។ ចាប់ពីឆ្នាំ១៩៦៥មក កងទ័ពវៀតកុង និងវៀតណាម
ខាងជើងបានរត់គេចពីការទម្លាក់គ្រាប់បែក ដើម្បីមកបង្កើតជំរំសម្ងាត់នៅ
តាមតំបន់ព្រំដែនកម្ពុជា-វៀតណាម។ បញ្ហាទំនាស់ព្រំដែនក៏បានផ្ទុះឡើង
ដោយសារសង្គ្រាមត្រជាក់នេះផងដែរ។ ប្រទេសថៃ និងវៀតណាមខាង
ត្បូងគាំទ្រដោយអាមេរិកប្រកាសមិនទទួលស្គាល់ព្រំដែនអន្តរជាតិរបស់
ប្រទេសកម្ពុជា។ ផ្ទុយទៅវិញ រដ្ឋាភិបាលវៀតណាមខាងជើងប្រកាសទទួល
ស្គាល់ព្រំដែនអន្តរជាតិរបស់កម្ពុជាជាថ្នូរនឹងការគាំទ្រខាងផ្នែកនយោបាយ
និងយោធា។ ប្រការនេះរុញសម្តេចសីហនុឱ្យផ្លាស់ប្តូរនយោបាយក្រៅប្រទេស
របស់ខ្លួន។

ខ-ការងាកពីនយោបាយអព្យាក្រឹតមកសហការជាមួយប្លុកកុម្មុយនីស្ត

ការពាំរបាំតង់ហ្គោជាមួយមហាអំណាច ៖ ដំបូងឡើយ សម្តេចសីហនុ
ដើរនយោបាយនៅកណ្តាល ដែលត្រូវបំពេញតាមសំណូមពររបស់មហា
អំណាចទាំងសងខាងនៃសង្គ្រាមត្រជាក់ គឺសហរដ្ឋអាមេរិកផង និងប្លុក
កុម្មុយនីស្ត ដឹកនាំដោយសហភាពសូវៀត និងចិនផងក្នុងគោលដៅជៀស

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កុំឱ្យកម្ពុជាធ្លាក់ចូលក្នុងបំពុកណាមួយ។ កម្ពុជាមានទំនាក់ទំនងការទូតជាមួយបំពុកទាំងពីរ ដោយប្រកាន់យកនយោបាយអព្យាក្រឹត។ ព្រឹត្តិការណ៍សំខាន់ៗដែលមានឥទ្ធិពលលើការរីវិត្តនៃស្ថានការណ៍នយោបាយក្នុង និងក្រៅប្រទេសរបស់កម្ពុជាគឺ ៖

ទីមួយ-រដ្ឋប្រហារនៅវៀតណាមខាងត្បូងរៀបចំដោយសហរដ្ឋអាមេរិក និងក្រុមឧត្តមសេនីយដែលអាមេរិកគាំទ្រ ដើម្បីទម្លាក់ និងសម្លាប់នាយករដ្ឋមន្ត្រី ង៉ោ ឌិនយៀម ក្នុងឆ្នាំ១៩៦៣

ទីពីរ-ការប្រកាសរបស់សហរដ្ឋអាមេរិក ដើម្បីគាំទ្រជំហរវៀតណាមខាងត្បូង និងថៃឡង់ដ៍ ដែលបដិសេធមិនទទួលស្គាល់ព្រំដែនអន្តរជាតិកម្ពុជា

ទីបី-ការប្រកាសដោយប្រទេសវៀតណាមខាងជើង ទទួលស្គាល់ព្រំដែនអន្តរជាតិរបស់កម្ពុជា

ទីបួន-គោលនយោបាយការបរទេសនៃសាធារណរដ្ឋប្រជាមានិតចិន និងបំពុកកុម្មុយនីស្តដឹកនាំដោយសហការសូវៀត ក្នុងការទាក់ទាញកម្ពុជាឱ្យដាកចេញពីសហរដ្ឋអាមេរិក

ការផ្តាច់ទំនាក់ទំនងការទូតជាមួយអាមេរិក ៖ បន្ទាប់ពីរដ្ឋប្រហារនៅវៀតណាមខាងត្បូងរៀបចំឡើងដោយឧត្តមសេនីយវៀតណាម និងគាំទ្រដោយអាមេរិក នៅថ្ងៃទី១ វិច្ឆិកាឆ្នាំ១៩៦៣ ដែលធ្វើប្រធានាធិបតី ង៉ោ ឌិនយៀម (Ngô Đình Diệm) ចាត់បង់ជីវិតនៅថ្ងៃទី១៩ វិច្ឆិកា ១៩៦៣ សម្តេចសីហនុប្រកាសឈប់យកជំនួយអាមេរិក ហើយបណ្តេញបុគ្គលិកទទួលបន្ទុកជំនួយចេញពីក្រៅប្រទេស។ ជំនួយនេះមានចំនួនប្រមាណ៦០លានដុល្លារក្នុងមួយឆ្នាំ និងមានចំណែកស្មើ១៥%នៃថវិកាជាតិ។ ទំនាស់ឈានទៅដល់ការកាត់ផ្តាច់ទំនាក់ទំនងការទូតនៅក្នុងឆ្នាំ១៩៦៥។ ការឈប់ទទួលជំនួយមានបច្ច័យមួយចំនួនដល់ស្ថានភាពសេដ្ឋកិច្ចក្នុងឆ្នាំបន្តបន្ទាប់ដោយសារពាជរដ្ឋាភិបាលត្រូវបោះផ្សាយក្រដាសប្រាក់ ដើម្បីបំពេញតម្រូវ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការនៃចំណាយសាធារណៈ។

សង្គ្រាមបង្ហូរបបង្ហូរវៀតណាម ៖ នៅឆ្នាំ១៩៦០ វៀតណាមខាងជើងបានប្រកាសបង្កើតចលនាតស៊ូបដិវត្តន៍នៅវៀតណាមខាងត្បូង ដើម្បីបង្ហូរបបង្ហូរវៀតណាមទាំងពីរ។ ឱ្យក្វើងសង្គ្រាមនៅវៀតណាមកាន់តែឆេះសន្ធោសន្ធៅឡើង ហើយរាលដាលជាបណ្តើរៗដល់ប្រទេសកម្ពុជា។ នៅឆ្នាំ១៩៦៤ និង១៩៦៥ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឱ្យមានបាតុកម្មប្រជាជន សិស្ស និងនិស្សិតប្រឆាំងស្ថានទូតអាមេរិក និងអង់គ្លេស។ ដើម្បីសម្តែងពីសាមគ្គីភាពជាមួយវៀតណាមខាងជើង សម្តេចសីហនុរៀបចំសន្និសីទប្រជាជនឥណ្ឌូចិននៅភ្នំពេញនៅឆ្នាំ១៩៦៥។ ទំនាក់ទំនងរវាងកម្ពុជា និងចិនកាន់តែមានភាពជិតស្និទ្ធឡើង តាមរយៈទស្សនកិច្ចយ៉ាងញឹកញាប់របស់សម្តេចសីហនុ ទៅប្រទេសចិន។

ផ្លូវលំហូជីមិញ ៖ ដើម្បីបញ្ជូនគ្រឿងសព្វាវុធ គ្រាប់រំសេវ ថ្នាំសង្កូវ និងគ្រឿងឧបភោគបរិភោគ ជាពិសេសអង្ករ ទៅផ្គត់ផ្គង់កងទ័ពធ្វើសង្គ្រាមនៅវៀតណាមខាងត្បូង និងនៅប្រទេសឡាវ ប្រទេសចិន និងសហភាពសូវៀតត្រូវមានផ្លូវពិសេសមួយ ដើម្បីផ្គត់ផ្គង់ចិញ្ចឹមចលនាបដិវត្តន៍ តាមផ្លូវដែលគេប្រសិទ្ធនាមថា ផ្លូវលំហូជីមិញ។ ចាប់តាំងពីឆ្នាំ១៩៦៧មក សហរដ្ឋអាមេរិកបានស្រាវជ្រាវរកផ្លូវលំនេះ។ នៅចុងឆ្នាំ១៩៦៨ មជ្ឈដ្ឋានមួយចំនួនក្នុងប្រទេសបានដឹងថា កងទ័ពកម្ពុជាបានចូលរួមក្នុងការដឹកអាវុធ និងអង្ករទៅកាន់វៀតណាមខាងត្បូង ដើម្បីប្រគល់ឱ្យទ័ពវៀតកុង និងវៀតណាមខាងជើងពីឆ្នាំ១៩៦៦ដល់ឆ្នាំ១៩៦៩ ដោយឆ្លងកាត់តាមកំពង់ផែក្រុងព្រះសីហនុទៅកាន់តំបន់ព្រំដែន។ ក៏ប៉ុន្តែ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ការដឹកជញ្ជូនសព្វាវុធតាមផ្លូវលំហូជីមិញ គឺដឹកចេញពីកំពង់ផែហាយហុងតាមផ្លូវជាតិលេខ១ពីហាណូយ តាមមាត់សមុទ្រហួតដល់ដា-ណាង និងឆ្ពោះទៅកាន់តំបន់ផ្នែកខាងត្បូងនៃប្រទេសវៀតណាមតែម្តង។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

គ-ការតម្រង់ទិសគោលនយោបាយក្រៅប្រទេសមកស្តារវិញ

មូលហេតុនៃការផ្ទាស់ប្តូរនយោបាយ ៖ ព្រឹត្តិការណ៍ធំៗមួយចំនួនបានរុញកម្ពុជារបស់សម្តេចសីហនុឱ្យងាកពីចិនមករកអាមេរិកវិញ ៖ (១) កុប្បកម្មនៃកសិកររនៅសំឡូត ដែលសម្តេចសីហនុយល់ថា គឺជាអំពើរបស់ពួកកុម្មុយនីស្ត (២) ស្ថានភាពសេដ្ឋកិច្ចកាន់តែដុនដាបឡើង ដោយសារអតិផរណា (ការបោះពុម្ពក្រដាសប្រាក់ចាយ) ការគ្រប់គ្រងវិស័យសេដ្ឋកិច្ចរដ្ឋគ្មានប្រសិទ្ធភាព ខ្វិនភាពថវិកាជាតិ ដោយសារគម្រោងសាងសង់លើសលទ្ធភាពថវិកា (៣) ការធ្លាក់ចុះប្រជាប្រិយភាពរបស់សម្តេចសីហនុ ដោយសារបញ្ហាគ្រប់គ្រងផ្ទៃក្នុង និងការរាលដាលនៃមូលដ្ឋានសឹករបស់ពួកវៀតកុង និងវៀតណាមខាងជើងលើទឹកដីកម្ពុជា។

ការបង្កើតឡើងវិញទំនាក់ទំនងការទូតជាមួយអាមេរិក ៖ ដើម្បីដោះស្រាយបញ្ហានេះ សម្តេចសីហនុបានចាប់ផ្តើមអនុវត្តនយោបាយក្រៅប្រទេសងាកទៅរកបស្ចិមប្រទេស។ ជាដំបូង គឺជាទស្សនកិច្ចរបស់អតីតស្ត្រីទី១ អាមេរិក ហ្សាក់គី កេណេឌី (Jackie Kennedy) នៅចុងឆ្នាំ១៩៦៧ និងការភ្ជាប់ទំនាក់ទំនងការទូតឡើងវិញក្នុងខែមេសា ឆ្នាំ១៩៦៩។

ការប្រគល់អំណាចឱ្យលន់ នល់ និងសិរីមត: ៖ ដោយសារស្ថានភាពសេដ្ឋកិច្ចក្នុងប្រទេសកាន់តែយ៉ាប់យឺនទៅ រដ្ឋាភិបាលស្រោចស្រង់ជាតិត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៩ ដោយមានលោកលន់ នល់ជាប្រមុខ និងអ្នកអង្គម្ចាស់ស៊ីសុវត្ថិ សិរីមត:ជាឧបនាយករដ្ឋមន្ត្រី។ នៅដើមឆ្នាំ១៩៧០ អ្នកអង្គម្ចាស់សិរីមត:ចាប់ផ្តើមធ្វើឯកជនភាវូបនីយកម្មធនាគារពាណិជ្ជ និងបិទកាស៊ីណូរដ្ឋវិញ។ ចលនាបាតុកម្មរបស់សិស្ស និងនិស្សិតបានចាប់ផ្តើមឡើង ដើម្បីបណ្តេញកងទ័ពវៀតកុង និងវៀតណាមខាងជើងចេញពីកម្ពុជា។ កម្ពុជារអិលជើងធ្លាក់ចូលបន្តិចម្តងៗទៅក្នុងភ្លើងសង្គ្រាម។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

៣-សមិទ្ធផល និងការធ្លាក់ចុះនៃរបបសង្គមរាស្ត្រនិយម

ទោះបីជាមានលទ្ធផលអវិជ្ជមានជាច្រើនក៏ដោយ កម្ពុជានៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ត្រូវបានសាជារណមតិចាត់ទុកថា ជា«កោះសន្តិភាព» និងជា«គុជនៅអាស៊ី»។ កម្រិតអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាសម្រេចបានខ្ពស់ជាងប្រទេសសិង្ហបុរីទៅទៀត។

ក-សមិទ្ធផលសេដ្ឋកិច្ច

គោលនយោបាយសេដ្ឋកិច្ច ៖ នៅដើមសម័យឯករាជ្យ សេដ្ឋកិច្ចកម្ពុជា ជាពិសេសការផលិតអគ្គិសនី និងការផ្គត់ផ្គង់ប្រេងឥន្ធនៈស្ថិតនៅក្នុងកណ្តាប់ដៃបរទេសគ្រប់គ្រង ដូចជាបារាំង និងអង់គ្លេស។ ដើម្បីអភិវឌ្ឍប្រទេសជាតិ រាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមបានដាក់ចេញនូវគោលនយោបាយបង្កើតក្រុមហ៊ុនចម្រុះរដ្ឋ និងវិស័យឯកជនជាពិសេសក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម តែរដ្ឋបន្តគ្រប់គ្រងជាចំបងលើវិស័យសំខាន់ៗ ដូចជាថាមពល គមនាគមន៍ និងរ៉ែជាដើម។ រាជរដ្ឋាភិបាលបានរៀបចំផែនការប្រាំឆ្នាំចំនួនពីរ ៖ (១) ផែនការប្រាំឆ្នាំលើកទី១ (១៩៦០-១៩៦៤) និងផែនការប្រាំឆ្នាំលើកទី២ (១៩៦៨-១៩៧២)។ ក៏ប៉ុន្តែ ផែនការទាំងនេះពឹងផ្អែកលើការវិនិយោគឯកជនប្រមាណជា៣០%នៃតម្រូវការវិនិយោគសរុប។

នយោបាយជាតូបនីយកម្ម ៖ ចាប់តាំងពីការទាត់ចោលជំនួយរបស់សហរដ្ឋអាមេរិកនៅឆ្នាំ១៩៦៣មក រាជរដ្ឋាភិបាលបានអនុវត្តនូវគោលនយោបាយជាតូបនីយកម្ម សេដ្ឋកិច្ច តាមរយៈការបង្កើតក្រុមហ៊ុនរដ្ឋ។ ក៏ប៉ុន្តែ ក្រុមហ៊ុនរដ្ឋទាំងនោះដំណើរការច្រើនតែខាត ដោយសារការគ្រប់គ្រងគ្មានប្រសិទ្ធភាព។ ម្យ៉ាងវិញទៀត ក្រុមហ៊ុននាំចេញ និងនាំចូលសូណិចស៊ីមបានក្លាយជាប្រភពនៃការពុករលួយ និងការបង្កើតឡើងនូវផ្សារងងឹតសម្រាប់រូបិយប័ណ្ណ។ ក្នុងបរិការនៃសង្គ្រាមត្រជាក់ វិទ្ធង្សនាសេដ្ឋកិច្ចក៏កើត

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មានឡើង ដោយប្រជានធនាគារជនជាតិថៃ រៀបលុយរត់ទៅបាងកក ដែលនាំឱ្យសាធារណជនបាត់ជំនឿលើប្រព័ន្ធធនាគារ។ ចាប់តាំងពីឆ្នាំ១៩៦៣ មក កំណើនសេដ្ឋកិច្ចក៏ចាប់ផ្តើមធ្លាក់ចុះហើយសកម្មភាពសេដ្ឋកិច្ចនៅទ្រឹងនៅឆ្នាំ១៩៦៦។

វិស័យកសិកម្ម ៖ កសិកម្មមានចំណែកជាង៤០%នៃផលិតផលសរុបក្នុងស្រុក។ ផ្ទៃដីដាំដុះមានចំនួន២,៣លានហិកតា។ ៨០%នៃកសិករកម្ពុជាមានដីស្រែតិចជាង២ហិកតា ហើយមានតែម្ចាស់ដីតែ១ ១៩១នាក់ប៉ុណ្ណោះដែលមានដីស្រែធំជាង២០ហិកតា។ ផលិតផលស្រូវកើនឡើងពីរដងដល់ជាង៣លានតោន។ កម្ពុជាបានដាក់ចេញនូវគោលនយោបាយធ្វើពិពិធកម្មកសិកម្ម ដោយពង្រីកផ្ទៃដីដាំដំណាំរួមផ្សំ ដូចជាកៅស៊ូ កប្បាស ពោតលួ។ ការចិញ្ចឹមសត្វ ដូចជាមាន់ ទា ជ្រូក គោ ក្របីក៏កើនឡើងជាលំដាប់។ ផលិតផលនេសាទ ទាំងនេសាទទឹកសាប និងនេសាទទឹកប្រៃបានក្លាយជាវិស័យថ្មីសម្រាប់បម្រើឱ្យការនាំចេញ ដែលមានចំណែកស្មើនឹង២,៤%នៃផលិតផលសរុបក្នុងស្រុក។ ផលិតផលនេសាទត្រីទឹកសាបសម្រេចបានចំនួនជាង១០០ ០០០តោនក្នុង១ឆ្នាំ ចំណែកផលិតផលត្រីសមុទ្រសម្រេចបានប្រមាណជា៦០ ០០០តោន។

វិស័យហេដ្ឋារចនាសម្ព័ន្ធ ៖ រាជរដ្ឋាភិបាលបានចាប់ផ្តើមសាងសង់កំពង់ផែទឹកជ្រៅនៅកំពង់សោម និងកំពង់ផែភ្នំពេញ សាងសង់ផ្លូវជាតិសំខាន់ៗតភ្ជាប់ភ្នំពេញទៅនឹងទីរួមខេត្ត ជាពិសេសការកសាងផ្លូវជាតិលេខ ៤ តភ្ជាប់ភ្នំពេញទៅនឹងក្រុងព្រះសីហនុ តាមរយៈជំនួយអាមេរិក ការសាងសង់អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង និងអាកាសយានដ្ឋាននៅតាមទីរួមខេត្ត និងសាងសង់ខ្សែរថភ្លើងពីរខ្សែតភ្ជាប់ភ្នំពេញទៅនឹងក្រុងព្រះសីហនុនិងខេត្តបាត់តំបង និងព្រំដែនថៃ។

វិស័យឧស្សាហកម្ម ៖ រាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមបានដាក់ចេញនូវគោលនយោបាយឧស្សាហូបនីយកម្ម តាមរយៈការសាងសង់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពោធិចក្រវាឃនភ័ណ្ឌ ពោធិចក្រក្តារបន្ទះ ពោធិចក្រកែវ ពោធិចក្រក្រជាស ពោធិចក្រស៊ីម៉ងត៍ ពោធិចក្រក្រចៅ ពោធិចក្រស្ករស ពោធិចក្រស្រាបៀរ និង ពោធិចក្រដំឡើងត្រាក់ទ័រ។ នៅឆ្នាំ១៩៦៨ ទូទាំងប្រទេសមានពោធិចក្រចម្រុះ រដ្ឋ-ឯកជនចំនួន២៩ សហគ្រាសរដ្ឋចំនួន២៨ និងសហគ្រាសតូច និងមធ្យម ឯកជនជិត៤ ០០០កន្លែង។

ខ-សមិទ្ធផលវិស័យអប់រំ

ទសវត្សរ៍ឆ្នាំ១៩៦០ គឺជាសម័យកាល ដែលត្រូវបានគេចាត់ទុកថា ជា សុវណ្ណសម័យនៃការអប់រំនៅកម្ពុជា។ ថវិកាជាតិប្រមាណជា២០%ចំណាយ លើវិស័យអប់រំ។ សាលារៀនជាច្រើនត្រូវបានចាត់ទុកថាជាថ្នាលបណ្តុះ-បញ្ជា ស្មារតី គំនិតស្នេហាជាតិ និងជាទីកន្លែងសម្រាប់អនុវត្តកម្មវិធីសិក្សា ជាតិ។

រាជរដ្ឋាភិបាលវិនិយោគខ្លាំងលើវិស័យអប់រំ។ សាលាបឋមសិក្សាកើន ឡើងជិតពីរដង ដល់ជិត៦ពាន់សាលា ដោយសារការសាងសង់សាលា បឋមសិក្សាថ្មីចំនួនជាង៦ ០០០ ដែលធ្វើឱ្យចំនួនសិស្សកម្រិតបឋមសិក្សា កើនឡើងពី៣សែននាក់ក្នុងឆ្នាំ១៩៥៥ដល់ជាង១លាននាក់ក្នុងឆ្នាំ១៩៦៨។ អនុវិទ្យាល័យ និងវិទ្យាល័យត្រូវបានពង្រីក និងពង្រឹង ហើយចំនួនកើនឡើង ពី១០ដល់២០០។ គ្រឹះស្ថានឧត្តមសិក្សា ដែលនៅជំនាន់បារាំងគ្មានទាល់ តែសោះ តែនៅចុងទសវត្សរ៍ឆ្នាំ១៩៦០ គ្រឹះស្ថានឧត្តមសិក្សាចំនួន៩ត្រូវបាន បង្កើត ដែលមានសិស្សចំនួន១១០០០នាក់សិក្សា ហើយសាស្ត្រាចារ្យឧត្តម សិក្សាកើនឡើងដល់ជិត៦ពាន់។ ក៏ប៉ុន្តែ តាមលទ្ធផលនៃការអង្កេតប្រជា-ជនឆ្នាំ១៩៦២ បញ្ហាប្រឈមដ៏ធំមួយរបស់កម្ពុជា គឺប្រជាជន៩០%មិនចេះ អក្សរ ជាពិសេសស្ត្រី ប្រជាជនកម្ពុជាតែ២%ប៉ុណ្ណោះរៀនចប់បឋមសិក្សា ហើយមានតែសិស្សចំនួន៣០០នាក់រៀនចប់វិទ្យាល័យ។

សាលាបឋមសិក្សា និងអនុវិទ្យាល័យនៅកម្ពុជាមានចំនួនប្រមាណ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាជាង៨០០ នៅពេលដែលកម្ពុជាទទួលបានឯករាជ្យក្នុងឆ្នាំ១៩៥៣។ បន្ទាប់ពីទទួលបាន រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយប្រែក្លាយសាលាវត្តឱ្យទៅជាសាលារដ្ឋ ហើយបានធ្វើឱ្យចំនួនសាលារដ្ឋកើនឡើងយ៉ាងធាប់រហ័សដល់១ ៦៥៣ ក្នុងឆ្នាំ១៩៥៨ ហើយបានកើនឡើងដល់ ៥ ០២៦ ក្នុងឆ្នាំ១៩៦៨/៦៩ ដែលក្នុងនោះ សាលាបឋមសិក្សាមានចំនួន ៤៨៥៧ ហើយអនុវិទ្យាល័យ និងវិទ្យាល័យមានចំនួនត្រឹមតែ១៧៩ប៉ុណ្ណោះ។ ចំនួនសិស្សដែលរៀននៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបានកើនឡើងពី៤៣ ៦៤៩នាក់នៅឆ្នាំ១៩៥៦ដល់១ ០១៨ ២៦៤នាក់ក្នុងឆ្នាំ១៩៦៨-៦៩។ ក្នុងនោះ សិស្សសាលាបឋមសិក្សាមានចំនួន៩១៩ ៤៥៦នាក់ស្មើនឹង ៩០,៣% សិស្សអនុវិទ្យាល័យមានចំនួន៦៣ ៦១៤នាក់ស្មើនឹង៦,២% ហើយសិស្សវិទ្យាល័យមានចំនួនតែ៣៥ ១៩៤នាក់ប៉ុណ្ណោះស្មើនឹង៣,៥%។ សិស្សទាំងនោះត្រូវបានបង្រៀនដោយគ្រូប្រមាណជា២១ ៣១៣នាក់នៅកម្រិតបឋមសិក្សា និងគ្រូប្រមាណជា៤ ៤៩១នាក់នៅកម្រិតមធ្យមសិក្សា។

ការអប់រំផ្តោតលើគុណភាពជាចម្បង។ ការប្រឡងថ្នាក់ជាតិ គឺជារបាំងមួយដើម្បីជ្រើសសិស្សឆ្នើមបំផុត ដើម្បីឱ្យពួកគេបន្តការសិក្សាទៅមុខទៀត និងដើម្បីជ្រើសរើសចូលបំពេញការងាររាជការ។ សិស្សដែលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិនៅក្នុងទសវត្សរ៍ទី៦០ មានចំនួនពី ១ ៥០០នាក់ (២៣%នៃសិស្សដែលចូលរួមប្រឡង) នៅក្នុងឆ្នាំ១៩៦០-៦១ ដល់៨ ៨០០នាក់ (៣៨%) នៅឆ្នាំ១៩៦៨-៦៩។ ប្រព័ន្ធសាលារៀនត្រូវបានប្រើប្រាស់ជាយន្តការមួយ ដើម្បីសម្រិតសម្រាំងឱ្យសិស្សទទួលបានទូវការអប់រំកម្រិតខ្ពស់ នៅពេលពួកគេបញ្ចប់ការសិក្សា។ សិស្សដែលពូកែបំផុតនឹងទទួលបានអាហារូបករណ៍ ដើម្បីបន្តការសិក្សារបស់ពួកគេនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាដែលមានកិត្យានុភាព ទាំងនៅក្នុងស្រុក ទាំងនៅបរទេស។ ដូច្នេះហើយ សិស្សប្រកួតប្រជែងគ្នាយ៉ាងខ្លាំង ដើម្បីទទួលបានពិន្ទុល្អ និងចំណាត់ថ្នាក់លេខ១នៅក្នុងថ្នាក់រៀន។ ចំនួនសិស្សនៅកម្រិត

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បឋមសិក្សា និងមធ្យមសិក្សានៅកម្ពុជាបានកើនឡើងពីប្រមាណជា៩០ ០០០ នាក់ទៅជាង១លាននាក់ក្នុងអំឡុងពេលប្រមាណជា១៥ឆ្នាំប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ប្រព័ន្ធអប់រំនៅកម្ពុជាត្រូវបានបង្កើតឡើងដើម្បីបណ្តុះបណ្តាលវិញ្ញូជន និងមន្ត្រី ដើម្បីឱ្យធ្វើការជាមន្ត្រីរាជការនៅក្នុងសេវាសាធារណៈ និងវិស័យឯកជន។

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងពិសេស ទៅលើការអប់រំឧត្តមសិក្សា តាមរយៈការបង្កើតគ្រឹះស្ថានឧត្តមសិក្សាចំនួន៦នៅទសវត្សរ៍ឆ្នាំ១៩៥០។ ដោយហេតុនេះហើយ ទើបការអប់រំឧត្តមសិក្សាត្រូវបានពង្រីកវិសាលភាពយ៉ាងធំធេងរហ័ស ចាប់ពីពាក់កណ្តាលនៃទសវត្សរ៍ឆ្នាំ១៩៥០ រហូតដល់ឆ្នាំ១៩៧០ នៅពេលដែលសង្គ្រាមក្នុងស្រុកបានផ្ទុះឡើង បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចសីហនុ។ ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានកើនឡើងពី១១នៅឆ្នាំ១៩៥៦ដល់ចំនួន១៨ ក្នុងឆ្នាំ១៩៥៨ និងដល់ចំនួន ២៩មកទល់នឹងឆ្នាំ១៩៧០។

ក្នុងឆ្នាំ១៩៦០ សាកលវិទ្យាល័យភូមិន្ទភ្នំពេញត្រូវបានបង្កើតឡើងដោយច្របាច់បញ្ចូលគ្នានូវគ្រឹះស្ថានឧត្តមសិក្សាមួយចំនួន។ ភាសាបារាំងត្រូវបានប្រើប្រាស់សម្រាប់ការបង្រៀន និងប្រើប្រាស់កម្មវិធីសិក្សានិងគរុកោសល្យបែបបារាំង។ សាកលវិទ្យាល័យភូមិន្ទជាឧត្តមួយដែលមានមហាវិទ្យាល័យចំនួន៧រួមមាន ៖ នីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច មនុស្សសាស្ត្រ វិទ្យាសាស្ត្រសុខាភិបាល និងប៉ារ៉ាមេឌីកាល់ ឱសថសាស្ត្រ ពាណិជ្ជ-សាស្ត្រ និងគរុវិជ្ជា។ នៅរវាងឆ្នាំ១៩៦៨ និង១៩៦៩ មាននិស្សិតសរុបចំនួន ៦ ៩៧១នាក់បានចុះឈ្មោះចូលរៀន និងមាននិស្សិត១៦%ជានារី។

នៅឆ្នាំ១៩៦៥ សាកលវិទ្យាល័យចំនួន៦ផ្សេងទៀតត្រូវបានបង្កើតឡើងរួមមាន ៖ សាកលវិទ្យាល័យភូមិន្ទបច្ចេកទេស សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សាកលវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម សាកលវិទ្យាល័យភូមិន្ទកំពង់ចាម សាកលវិទ្យាល័យបាត់ដំបង សាកលវិទ្យាល័យភូមិន្ទតាកែវ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កំពត និងសាកលវិទ្យាល័យប្រជាជន ហើយនៅចុងឆ្នាំ១៩៦៩ សាកលវិទ្យាល័យមានចំនួន៩ និងមាន៣៤មហាវិទ្យាល័យ និងមានសាលាជាន់ខ្ពស់ចំនួន៨។ នៅឆ្នាំ១៩៦៥ ក៏មានការបង្កើតពុទ្ធិកសាកលវិទ្យាល័យ ហើយមាននិស្សិតចំនួន១២៧នាក់។

គ-វិបត្តិសេដ្ឋកិច្ច ៖ ថវិកាចាក់តុល្យភាព

វិបត្តិសេដ្ឋកិច្ចនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០ មានមូលហេតុដូចតទៅ ៖ (១) ក្នុងឆ្នាំ១៩៦៣ ជំនួយអាមេរិកចំនួន៤០លានដុល្លារ ១៥% នៃថវិកាជាតិត្រូវបានកាត់ផ្តាច់ (២) ជាតួបទនិយកម្ម ៖ ក្រុមហ៊ុន និងធនាគារឯកជនត្រូវបិទទ្វារ តែមានសកម្មភាពរត់ពន្ធ និងផ្សារដឹង ទាំងឱ្យរដ្ឋបាត់ចំណូល តែចំណាយកើនឡើងច្រើន (៣) រដ្ឋាភិបាលចាប់ផ្តើមបោះពុម្ពលុយ ដើម្បីបំពេញកង្វះខាតសាច់ប្រាក់ ធ្វើឱ្យមានអតិផរណា ទំនិញឡើងថ្លៃ (៤) ការរត់ពន្ធអង្គរយកទៅលក់ឱ្យទីពវៀតណាមតាមព្រំដែន។

វិបត្តិសេដ្ឋកិច្ចបានកើតឡើងក្នុងឆ្នាំ១៩៦៧-១៩៦៨ ៖ ដែលជាមូលហេតុនៃបាតុកម្មនៅសំឡូត (ខ្វះថវិកាទិញស្រូវ និងស្រូវចុះថោក) បញ្ហាបំណុលរបស់កសិករ គុណភាពប្រព័ន្ធធារាសាស្ត្រ សេដ្ឋកិច្ចពិភពលោក ហើយសិស្ស និងនិស្សិតចេញពីសាកលវិទ្យាល័យអត់ការងារធ្វើ។ គ្រូបង្រៀនបានរត់ចូលព្រៃម៉ាគី ដើម្បីចូលរួមជាមួយចលនាបដិវត្តន៍។ នៅពេលនោះ មន្ត្រីធំៗចាប់ផ្តើមឃុបឃិតធ្វើផែនការក្បត់សម្តេចសីហនុ។

៤-ស្នាដៃអក្សរសិល្ប៍ខេមរនិយមសម័យឯករាជ្យ

ព្រឹត្តិការណ៍ដ៏សំខាន់បំផុតនៅសតវត្សទី២០ គឺការបង្កើតវចនានុក្រមភាសាខ្មែរ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការវិវត្តភាសាខ្មែរ អក្សរសិល្ប៍ខ្មែរ ការកសាងវប្បធម៌ និងជាតិខ្មែរឡើងវិញ។ ក្រុមជំនុំជាតិខ្មែរត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩១៩ ដែលមានសម្តេចចក្រីកុញ្ជរាជិបតី ពេជ្រ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប៉ុណ្ណ សេនាបតីក្រសួងសិក្សាធិការ និងយុទ្ធនាធិការជាអធិបតី និងមានសមាជិកសុទ្ធសឹងតែជាបញ្ញវន្ត ដូចជាព្រះមហាវិមលធម្ម ថោង ព្រះពុទ្ធឃោសាចារ្យ ជួន ណាត ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ ព្រះឧត្តមមុនី អ៊ុម ស៊ូ ព្រះសក្យវង្ស ហួត តាត និងឧកញ៉ាទេពពិទូ ឈឹម ក្រសេមជាដើម ដោយមានការទំនុកបម្រុងពីលោក Goerge Cordès ចាងហ្វាងសាលាបារាំងបុងបូពាំ ដើម្បីបង្កើតវចនានុក្រមខ្មែរ។

អ្នកប្រាជ្ញខ្មែរក្នុងសតវត្សទី២០ ខាងផ្នែកអក្សរសាស្ត្រខ្មែរមាន ៖

(១) សម្តេចព្រះមហាសុមេធាធិបតី ជួន ណាត (១៨៨៣-១៩៦៩) ៖ ជាសម្តេចព្រះសង្ឃរាជអគ្គទី៦នៃគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា។ សម្តេចសង្ឃ ជួន ណាតបានខិតខំប្រឹងប្រែងបំពេញការងារ រៀបចំឱ្យកើតជាវចនានុក្រមខ្មែរឡើងនៅឆ្នាំ១៩៣៨ និងចំណាយពេលពេញមួយជីវិត ដើម្បីពិនិត្យឡើងវិញរហូតដល់ការបោះពុម្ពលើកទី៥ ក្នុងឆ្នាំ១៩៦៧ បន្ទាប់ពីបានផ្ទៀងផ្ទាត់ឡើងវិញដោយអ្នកស្ទាត់ជំនាញខាងអក្សរសាស្ត្រខ្មែរផងដែរ។

(២) សម្តេចព្រះមហាសុមេធាធិបតី ហួត តាត (១៨៩២-១៩៣៩) គឺជាសម្តេចព្រះសង្ឃរាជអគ្គទី៥នៃគណៈមហានិកាយ។ សម្តេចទ្រង់ប្រសូតនៅភូមិផ្សារឧដុង្គ ខេត្តកំពង់ស្ពឺ។ នៅពេលព្រះជន្មាយុបាន១៣ឆ្នាំ សម្តេចបានបួសជាសាមណេរ និងបានសិក្សាព្រះបរិយត្តិធម៌ ក្នុងសំណាក់ព្រះធម្មលិខិតស៊ូ។ ព្រះជន្មាយុ២១វស្សា សម្តេចបានឧបសម្បទាក្នុងពទ្ធសីមាវត្តឧណ្ណាលោម ក្នុងសំណាក់សម្តេចព្រះសង្ឃរាជ និល ទៀង ជាព្រះឧបជ្ឈាយ៍។

(៣) ព្រះភិក្ខុ ប៉ាង ខាត់ (វីរិយបណ្ឌិតោ) គឺជាអតីតសិស្សសាលាបារាំងបុងបូពាំ និងជាសាស្ត្រាចារ្យខាងប្រវត្តិសាសនាសកលលោក នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងជាសាស្ត្រាចារ្យភាសាខ្មែរបុរាណ (សិលាចារឹក) នៅមហាវិទ្យាល័យអក្សរសាស្ត្រ-មនុស្សសាស្ត្រ។ ព្រះអង្គ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មានស្នាព្រះហស្តជាច្រើន ដូចជាពុទ្ធជីវប្រវត្តិ វចនានុក្រមសំស្ក្រឹត-ខ្មែរ ស្រីហិតោបទេស[26] (អត្ថបទបកប្រែ) ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ មគ្គុទ្ទេសក៍នគរ។

(៤) លោក កេង វ៉ាន់សាក់ (១៩២៥-២០០៩) បានប្រឡងជាប់បរិញ្ញាបត្រផ្នែកទស្សនវិជ្ជានៅសាកលវិទ្យាល័យសរ័ពោន ក្រុងប៉ារីស នៅឆ្នាំ១៩៥១។ នៅឆ្នាំ១៩៥២-១៩៥៤ លោកជាសាស្ត្រាចារ្យនៅវិទ្យាល័យស៊ីសុវត្ថិ។ លោកជាមេដឹកនាំគណបក្សប្រជាធិបតេយ្យនៅពេលបោះឆ្នោតឆ្នាំ១៩៥៥។ បន្ទាប់ពីបរាជ័យនៃគណបក្សប្រជាធិបតេយ្យរដ្ឋាភិបាលសង្គមរាស្ត្រនិយមបានបញ្ជូនឱ្យចាប់លោកដាក់គុកធំពីខែកញ្ញាដល់តុលាឆ្នាំ១៩៥៥។ ដល់ពេលចេញពីពន្ធនាគារ លោកបានបោះពុម្ពផ្សាយកម្រងកំណាព្យ ដែលមានឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើកវីនិពន្ធខ្មែរជំនាន់នោះ។ ពីឆ្នាំ១៩៥៨ដល់១៩៦២ លោកមានតំណែងជាព្រឹទ្ធបុរសមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ និងជាចាងហ្វាងវិទ្យាស្ថានជាតិគរុកោសល្យ (១៩៥៨-១៩៦០)។ លោកបានការពារនិក្ខេបបទថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យសរ័ពោន ដែលមានចំណងជើងថា «ការស្រាវជ្រាវឫសគល់នៃវប្បធម៌ខ្មែរ»។ លោកបានបង្កើតពុម្ពអក្សរខ្មែរ សម្រាប់ប្រើក្នុងម៉ាស៊ីនអង្គុលីលេខ។ លោកបាននិពន្ធស្នាដៃមួយចំនួន ដូចជាកំណាព្យចិត្តក្រមុំ (១៩៥៤) និងបាននិពន្ធសិក្សាស្តីពី«មូលភាពនៃការបង្កើតពាក្យថ្មី»(១៩៦៤) និង «សូរសព្ទខ្មែរ» (១៩៦៦)[27]។

(៥) លោក ឃួន សុខម្ហូ (១៩៣១-១៩៧៥) កើតនៅសង្កាត់ទូកមាសខេត្តកំពត។ លោកមានសញ្ញាបត្របណ្ឌិតអក្សរសាស្ត្រផ្នែកភាសាវិទ្យាពី

---

[26] ស្រីហិតោបទេស គឺជាស្នាដៃនិពន្ធភាសាសំស្ក្រឹតរបស់នារាយណបណ្ឌិត អ្នកច្រាជ្វតណ្ហា។

[27] ឃីង ហុកនី (ប្រមូលផ្តុំអត្ថបទដោយ) (២០០៦) «*សម្ភោគម្មអក្សរសាស្ត្រខ្មែរ (Mélanges littéraires offerts au Professeur KENG Vannsak)*» បណ្ណាគារអង្គរ ភ្នំពេញ។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សាកលវិទ្យាល័យ ហ៊ីម ប៊ុល អាល្លឺម៉ង់។ លោកបានពន្យល់ពីមូលដ្ឋាននៃអក្សរសាស្ត្រខ្មែរក្នុងស្នាដៃរបស់លោក ដែលជានិក្ខេបបទថ្នាក់បណ្ឌិតមានចំណងជើងថា «ទម្រង់សូរវិទ្យាខ្មែរ» (ឆ្នាំ ១៩៧១)។

នៅជំនាន់អាណាព្យាបាលបារាំង និងនៅជំនាន់ឯករាជ្យ យើងឃើញមានលេចឡើងនូវចលនាអក្សរសិល្ប៍ខេមរនិយម។ ចលនាអក្សរសិល្ប៍នេះបានលើកឡើងពីការរស់នៅរបស់ខ្មែរពិតៗ ហើយដែលក្រសួងអប់រំ និងសិក្សាធិការបានដាក់បញ្ចូលស្នាដៃអក្សរសិល្ប៍នេះទៅក្នុងកម្មវិធីសិក្សាជាតិ ដែលក្នុងនោះមានស្នាដៃរបស់លោក រឹម គិន លោក ញ៉ុក ថែម និងលោក នូ ហាច។

(១) លោក រឹម គិន (១៩១១-១៩៥៩) ជាសាស្ត្រាចារ្យនៅសាលាគរុវិជ្ជា និងជាអ្នកនិពន្ធខ្មែរសម័យទំនើបដ៏ល្បីល្បាញ ដែលបាននិពន្ធស្នាដៃនិពន្ធជាច្រើន ដែលក្នុងនោះរឿងសូផាត (ឆ្នាំ១៩៣៨) ដែលត្រូវបានដាក់ចូលបង្រៀនក្នុងកម្មវិធីសិក្សា។ លោកបានបង្កើតសមាគមអ្នកនិពន្ធខ្មែរនៅឆ្នាំ១៩៥៧។

(២) លោក ញ៉ុក ថែម កើតនៅឆ្នាំ១៩០៣ នៅឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។ កាលពីកុមារភាពលោករៀននៅវត្តពោធិវាល ស្រុកសង្កែ ដោយរៀនទាំងអក្សរជាតិ និងបានសិក្សាធម៌វិន័យ ហើយបន្ទាប់មកបានបួសជាសាមណេរ ដោយរៀនធម៌វិន័យ និងភាសាបាលីផងដែរ។ នៅឆ្នាំ១៩១៩ នៅពេលមានអាយុ១៩ឆ្នាំ លោកបានទៅបន្តវិជ្ជានៅបាងកក ហើយបានរៀនជាប់សញ្ញាបត្រធម្មវិន័យថ្នាក់ត្រីនៅឆ្នាំ១៩២១ និងថ្នាក់ទោនៅឆ្នាំ១៩២៧។ ខាងផ្នែកភាសាបាលី លោកបានជាប់សញ្ញាបត្រខ្ពស់បំផុតនៅឆ្នាំ១៩២៩ ហើយនៅឆ្នាំ១៩៣០ លោក ញ៉ុក ថែមបានត្រលប់មកភ្នំពេញវិញ ហើយបានចូលធ្វើជាសមាជិកគណៈកម្មការប្រែព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ។ នៅឆ្នាំ១៩៣៨ លោកធ្វើការនៅក្នុងព្រះរាជបណ្ណាល័យជាតិ។ ក្នុងឆ្នាំ១៩៥០ លោកបានចូលធ្វើការជាសាស្ត្រាចារ្យខ្មែរ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នៅវិទ្យាល័យព្រះព្រះស៊ីសុវត្ថិ បន្ទាប់មកធ្វើជាសាស្ត្រាចារ្យនៅវិទ្យាល័យព្រះមុនីវង្ស នៅវិទ្យាស្ថានគរុកោសល្យ និងនៅសាលាភូមិន្ទរដ្ឋបាល។ លោកបាននិពន្ធរឿងកុលាបប៉ៃលិនក្នុងឆ្នាំ១៩៣៦។ លោកជាអ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរ និងពុទ្ធសាសនាមួយរូប និងជាសាស្ត្រាចារ្យភាសាបាលីនៅមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ និងជានិពន្ធនាយកយ៉ាងឆ្នើមនៃទស្សនាវដ្តី«កម្ពុជសុរិយា»របស់ពុទ្ធសាសនបណ្ឌិត្យ។ ស្នាដៃដ៏សំខាន់មួយទៀតរបស់លោក គឺរឿងបញ្ញាសជាតក ដែលចោះពុម្ពបញ្ចូលគ្នារឿងទាំង៥០ ជាសៀវភៅតែមួយ។

(៣)លោក ទូ ហាច (១៩១៦-១៩៧៥) កើតនៅឆ្នាំ១៩១៦ នៅឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង។ កាលពីកុមារភាព លោកសិក្សានៅសាលាបឋមសិក្សាវត្តកំពង់ព្រះ ដែលមានគ្រូជាព្រះសង្ឃនៅសាលានេះ ហើយដែលលោកចេះអានសាស្ត្រាស្ទឹករឹតយ៉ាងស្ទាត់ជំនាញ។ ឆ្នាំ១៩៣២ លោកបានប្រលងជាប់ចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ហើយលោកឥស្សរៀនសូត្ររហូតបានទទួលសញ្ញាបត្រកម្រិតមធ្យមសិក្សា។ ហើយលោកចាប់ផ្តើមអាជីពរបស់លោកជាមេធាវីយុត្តិធម៌មួយរូប ដែលបំពេញការងារនៅក្នុងខេត្តសៀមរាប។ បន្ទាប់មក លោកបានចូលបម្រើការងារនៅក្រសួងឃោសនាការទទួលបន្ទុកខាងការផ្សាយកាសែតកម្ពុជានៅឆ្នាំ១៩៤៧។ នៅឆ្នាំ១៩៥២ បានទៅធ្វើការនៅក្រសួងការបរទេស ប្រធានផ្នែកកិច្ចការនយោបាយការបរទេស (Directeur en Direction des Affaires Politiques)។ ក្នុងការងារនេះ លោកត្រូវបានតែងតាំងឱ្យទៅបំពេញបេសកកម្មនៅបរទេសដូចជាទៅប្រទេសសៀម និងយូហ្គោស្លាវី។ ក្រោយមក រាជរដ្ឋាភិបាលបានដំឡើងឋានៈឱ្យលោកក្លាយជាឯកអគ្គរាជទូតខ្មែរប្រចាំនៅប្រទេសឥណ្ឌូនេស៊ី ប្រទេសវៀតណាម និងជាអ្នកតំណាងពិសេសប្រចាំអង្គការសហប្រជាជាតិផងដែរ។ លោកបាននិពន្ធប្រលោមលោកចំនួន៤រឿង ដែលក្នុងនោះរឿងចំនួនពីរត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សា គឺរឿងផ្កាស្រពោន

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

(១៩៦៩) និងរឿងមាលាដួងចិត្ត (១៩៧២)។ រឿងពីរទៀតគឺរឿងនារីជាទីស្នេហា (១៩៥៣) និងរឿងលាវណ្យ និងវិទ្ធ (១៩៥៦)។

ទស្សនវិជ្ជានៃអក្សរសិល្ប៍ខេមរនិយមមានគោលដៅពន្យល់ពីរឿងរ៉ាវក្នុងសង្គមខ្មែរនៅសម័យឯកភាជ្យ ដោយផ្តោតលើចំណុចសំខាន់ៗដូចតទៅ៖

១ ទ្រឹស្តីអត្តាហិអត្តនោ នាថោ គឺជាទ្រឹស្តីខ្លួនត្រូវទីពឹងខ្លួនតែប៉ុណ្ណោះ ពោលគឺតួអង្គត្រូវចេះខំប្រឹងប្រែងកសាងជីវភាពខ្លួន ឱ្យបានចម្រើន ឱ្យមានជំហររឹងប៉ឹងដោយវិជ្ជាសម្បត្តិ គុណសម្បត្តិ សមត្ថភាព ទ្រព្យសម្បត្តិ និងសុខភាព ទើបអាចរស់នៅក្នុងសង្គមមនុស្សបានថ្លៃថ្នូរ ហើយអាចផ្តល់បានន្លូវអត្ថប្រយោជន៍ដល់សង្គម ឱ្យបានចម្រើនឡើងទៀតផង។

២ ទ្រឹស្តីជាតិនិយមខ្មែរ គឺយើងម្នាក់ៗត្រូវខំបំពេញករណីយកិច្ចរបស់ខ្លួន ចំពោះខ្លួនឯង ចំពោះសង្គម ចំពោះជាតិ សាសនា ព្រះមហាក្សត្រ ដែលជាឧត្តមគតិរបស់ពលរដ្ឋជាតិខ្មែរ។

៣ ការតស៊ូគង់តែនឹងបានសម្រេច ៖ ការតស៊ូរបស់ចៅចិត្រ ជម្នះគ្រប់ឧបសគ្គបានធ្វើឱ្យចៅចិត្រអាចឈោងទៅបេះផ្កាកូលាបដ៏ស្រស់បំព្រងបីដូចជាបេះផ្កាយលើមេឃផងដែរ។

៤ ការអប់រំយុវជន ៖ អត្ថបទអក្សរសិល្ប៍ខេមរនិយមបង្ហាញពីគំនិតខ្មែរ ដែលអ្នកនិពន្ធត្រូវលើកយកប្រជានបទនៃសង្គមខ្មែរមកបកស្រាយ ក្នុងគោលដៅទូន្មានកូនចៅឱ្យចេះត្រៀមខ្លួនក្នុងជីវិត ៖ (១) យុវជនត្រូវមានសមត្ថភាពវិជ្ជាជីវៈ មានចំណេះដឹង និងមានបំណិន (២) យុវជនត្រូវចេះតស៊ូក្នុងជីវិត (៣) យុវជនត្រូវបំពេញភារកិច្ចរបស់ខ្លួនចំពោះសង្គម និងប្រទេសជាតិ (៤) យុវជនត្រូវចេះគិតពីប្រយោជន៍រួម (៥) យុវជនត្រូវមានភាពស្មោះត្រង់នឹងប្រទេសជាតិ និងស្មោះនឹងស្នេហា (៦) យុវជនត្រូវមានភាពរឹងប៉ឹង (៧) យុវជនត្រូវរក្សាភាពថ្លៃថ្នូរ និង (៨) យុវជនត្រូវមានសុខភាពល្អ។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំពូក១០
សាធារណរដ្ឋខ្មែរ
(១៩៧០-១៩៧៥)

១-ហេតុអ្វីបានជាព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរីមតៈ និងឧត្តមសេនីយ លន់ នល់ធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុពីតំណែង?

បដិវត្តន៍ឧស្សាហកម្មលើកទី៣ ៖ ដើមទសវត្សរ៍ឆ្នាំ១៩៧០ គឺជាការចាប់ផ្តើមនៃបដិវត្តន៍ឧស្សាហកម្មលើកទី៣ ដែលកើតឡើងចាប់ពីឆ្នាំ១៩៦៩ ជាមួយនឹងការប្រើប្រាស់នូវឧបករណ៍អេឡិចត្រូនិច កុំព្យូទ័រ ទូរគមនាគមន៍ និងថាមពលបរមាណូ។ បច្ចេកវិទ្យាទាំងនេះជួយដល់ការស្រាវជ្រាវអវកាស បច្ចេកវិទ្យាជីវសាស្ត្រ និងនាំមកនូវការធ្វើស្ងួយប្រវត្តិកម្ម ក្នុងដំណើរការផលិតកម្ម។ ការប្រើប្រាស់ទូរទស្សន៍ជួយឱ្យប្រជាជនលើសាកលលោកដឹងព្រឹត្តិការណ៍ ដែលកើតឡើងជុំវិញពិភពលោក ជាពិសេសសង្គ្រាមនៅឧបទ្វីបឥណ្ឌូចិន។

នៅចុងឆ្នាំ១៩៦៩ និងដើមឆ្នាំ១៩៧០ អ្នករស់នៅទីក្រុងភ្នំពេញតែងតែក្រោកឡើងពីព្រលឹមស្រាងៗ ដើម្បីមើលផ្កាយដុះកន្ទុយលេចឡើងរាល់ព្រឹកពីទិសបូព៌។ តាមជំនឿពីបុរាណ គេថាប្រទេសនឹងមានសង្គ្រាមហើយ។ ក៏ប៉ុន្តែ តាមពិតមូលហេតុដែលធ្វើឱ្យកើតសង្គ្រាមវៀតណាមនេះ រាលដាលយ៉ាងសន្ធោសន្ធៅមកលើកម្ពុជា គឺមានមូលហេតុភូមិសាស្ត្រនយោ-

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បាយទៅវិញទេ។

សង្គ្រាមនៅវៀតណាម និងវិបត្តិកម្ពុជា

កត្តាក្រៅប្រទេស ៖ នៅពេលដែលប្រធានាធិបតីនិចសុនឡើងកាន់តំណែងជាប្រធានាធិបតីទី៣៧របស់សហរដ្ឋអាមេរិកក្នុងខែមករា ឆ្នាំ១៩៦៩ កងទ័ពអាមេរិកស្ថាប់នៅវៀតណាមប្រមាណជា៣០០នាក់ក្នុងមួយសប្តាហ៍។ សង្គ្រាមនេះបង្កើតឱ្យប្រជាជនអាមេរិកមិនសប្បាយចិត្ត ហើយចេញធ្វើបាតុកម្មតវ៉ាជារៀងរាល់ថ្ងៃ។ និចសុនយល់ច្បាស់ថា អាមេរិកមិនអាចឈ្នះសង្គ្រាមវៀតណាមបានឡើយ តែលោកបានតាំងចិត្តថា ត្រូវបញ្ចប់សង្គ្រាមឱ្យបានឆាប់។ លោកបានរិះរកវិធី ដើម្បីអាចដកកងទ័ពអាមេរិកចេញពីវៀតណាម តែដោយរក្សាសន្តិសុខដល់កងទ័ពវៀតណាមខាងត្បូងផងដែរ។ ដូច្នេះហើយ ទើបនិចសុនអនុញ្ញាតឱ្យយន្តហោះB-52 ទម្លាក់គ្រាប់បែកដោយឥតរើសមុខ លើទីតាំងពួកវៀតកុង និងខ្មែរក្រហមលើទឹកដីកម្ពុជាក្នុងខែមីនា ឆ្នាំ១៩៦៩ ក្នុងប្រតិបត្តិការ Menu ដោយគ្មានការអនុញ្ញាតពីរដ្ឋាភិបាលកម្ពុជា។

ផ្លូវលំហូជីមិញ ៖ ដើម្បីឱ្យសហរដ្ឋអាមេរិកអាចដកទ័ពចេញពីឥណ្ឌូចិនបាន គេត្រូវកាត់បន្ថយកម្លាំងសត្រូវតាមរយៈការផ្តាច់នូវការផ្គត់ផ្គង់គ្រឿងសព្វាវុធ ថ្នាំពេទ្យ គ្រឿងឧបភោគបរិភោគ ជាពិសេសអង្ករនិងសម្ភារៈឯទៀត ដល់ពួកកងទ័ពវៀតណាមខាងជើង និងពួកវៀតកុងនៅវៀតណាមខាងត្បូងតាមផ្លូវលំហូជីមិញ។ ពីពេលដំបូង មានសម្មតកម្មពីរស្តីពីផ្លូវលំហូជីមិញ ៖ (១) ផ្លូវគោកពីវៀតណាមខាងជើងទៅវៀតណាមខាងត្បូងកាត់តាមប្រទេសឡាវនិង(២) ផ្លូវសមុទ្រ។ ក៏ប៉ុន្តែ នៅចុងឆ្នាំ១៩៦៨ គេបានដឹងថា ផ្លូវលំហូជីមិញនេះឆ្លងកាត់តាមកម្ពុជាពីកំពង់ផែក្រុងព្រះសីហនុដល់ព្រំដែនវៀតណាមខាងជើង។

កត្តាផ្ទៃក្នុងប្រទេស ៖ អ្នកស្រាវជ្រាវខ្លះបានលើកឡើងពីមូលហេតុ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នៃវិបត្តិសេដ្ឋកិច្ច និងការពង្រឹងអំណាចរបស់ពួកស្តាំនិយម ដែលជំរុញឱ្យមេដឹកនាំនយោបាយកម្ពុជាធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ។

រដ្ឋប្រហារទម្លាក់សម្តេចសីហនុ ៖ នៅដើមខែមករា ឆ្នាំ១៩៧០ សម្តេចសីហនុបានចេញពីកម្ពុជា ដើម្បីទៅព្យាបាលនៅប្រទេសបារាំង ដើម្បីទុកឱ្យអ្នកអង្គម្ចាស់សិរីមតៈអាចកែលម្អការគ្រប់គ្រងកិច្ចការសំខាន់ៗរបស់ប្រទេសជាតិ។ បន្ទាប់ពីចេញពីមន្ទីរពេទ្យ ព្រះអង្គមានផែនការធ្វើទស្សនកិច្ចផ្លូវការនៅសហភាពសូវៀត និងនៅប្រទេសចិន។ ដើម្បីទម្លាក់សម្តេចសីហនុពីតំណែង អ្នកអង្គម្ចាស់សិរីមតៈ និងបក្សពួកបានរៀបចំឱ្យប្រជាជនដែលរស់នៅក្នុងស្រុកតាមព្រំដែន ជាអាទិ៍ចន្ទ្រា កំពង់ភោរីរំដួល និងរមាសហែក ធ្វើបាតុកម្មនាដើមខែមីនា ឆ្នាំ១៩៧០ ប្រឆាំងនឹងវត្តមាន និងទាមទារឱ្យដកកងទ័ពវៀតកុង និងវៀតណាមខាងជើងពីទឹកដីកម្ពុជា។ នៅថ្ងៃទី ១១ ខែមីនា ឆ្នាំ១៩៧០ បាតុកម្មសិស្សនិស្សិតត្រូវបានរៀបចំឡើងនៅភ្នំពេញ ប្រឆាំងស្ថានទូតវៀតណាមខាងជើង និងការិយាល័យតំណាងរបស់រណសិរ្សរំដោះវៀតណាមខាងត្បូង។ បាតុកម្មនេះឈានដល់អំពើហិង្សា និងការដុតកម្ទេចស្ថានបេសកកម្មទាំងពីរ។ អ្នកនយោបាយស្តាំនិយម ដែលជិតស្និទ្ធនឹងអ្នកអង្គម្ចាស់សិរីមតៈចាប់ផ្តើមទិតៀន និងប្រកាសថា ការដែលសម្តេចសីហនុអនុញ្ញាតឱ្យមានវត្តមានកងទ័ពវៀតកុងលើទឹកដីកម្ពុជា គឺជាអំពើក្បត់ជាតិ។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ រដ្ឋសភាបានបោះឆ្នោតទម្លាក់សម្តេចសីហនុពីតំណែង និងតែងតាំងលោកឧត្តម លន់ ប្រធានរដ្ឋសភា ជាប្រមុខរដ្ឋជំនួសវិញ។ អ្នកនយោបាយបីរូប ដែលមានតួនាទីសំខាន់ក្នុងការធ្វើរដ្ឋប្រហារគឺ ឧត្តមសេនីយ លន់ នល់ នាយករដ្ឋមន្ត្រី អង្គម្ចាស់សិរីមតៈ ឧបនាយករដ្ឋមន្ត្រី និងលោក អ៊ិន តាំ ប្រធានរដ្ឋសភា។

២-សង្គ្រាមក្នុងស្រុក និងការធ្វើអន្តរាគមន៍យោធាបរទេស

រដ្ឋប្រហារទម្លាក់ព្រះបាទនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឆ្នាំ១៩៧០ បាននាំមកនូវផលវិបាកបីយ៉ាងសម្រាប់កម្ពុជា ៖ (១) ការផ្ទុះសង្គ្រាមក្នុងស្រុក (២) អន្តរាគមន៍យោធាបរទេស និងការទម្លាក់គ្រាប់បែកលើកម្ពុជា និង (៣) ការកសាងកម្លាំងខ្មែរក្រហមជាអង្គការចាត់តាំងយោធានិងនយោបាយ។

ក-ការផ្ទុះសង្គ្រាមក្នុងស្រុក និងអស្ថិរភាព

ជម្លោះខ្មែរនឹងខ្មែរ ដែលពីពេលមុន គឺជាជម្លោះពាក្យសម្តី និងការខ្វែងគំនិតគ្នាខាងផ្នែកទស្សនៈ និងមនោគមវិជ្ជា ឥឡូវបានប្រែក្លាយជាជម្លោះប្រដាប់អាវុធ ដែលមានប្រទេសជិតខាង និងមហាអំណាចគាំទ្រទាំងសងខាង។ ស្ថានភាពកូមិសាស្ត្រនយោបាយជាច្រើនសតវត្សបានចាប់ផ្តើមកើតមានឡើងវិញនៅកម្ពុជា។

ព័ត៌មានស្តីពីរដ្ឋប្រហារនេះត្រូវបាននាយករដ្ឋមន្ត្រីសហភាពសូវៀត កូសីហ្គីនទូលថ្វាយសម្តេចសីហនុ នៅពេលដែលព្រះអង្គចាកចេញពីទីក្រុងម៉ូស្គូទៅកាន់ប៉េកាំង។ នៅប៉េកាំង ចិនទទួលព្រះអង្គក្នុងឋានៈជាប្រមុខរដ្ឋជាដែល។ សម្តេចសីហនុមានបំណងសុំសិទ្ធិជ្រកកោនខាងផ្នែកនយោបាយនៅប្រទេសចាវ៉ាំង តែបន្ទាប់មកព្រះអង្គបានទទួលយកសំណើរបស់នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ និងនាយករដ្ឋមន្ត្រីវៀតណាមខាងជើង ផាំ វ៉ាន់ជុង ដើម្បីដឹកនាំរដ្ឋាភិបាលនិរទេសនៅប៉េកាំង ជាមួយខ្មែរក្រហម ដែលមានឈ្មោះថា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK) ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០។ ព្រះអង្គបានអំពាវនាវឱ្យប្រជាជនខ្មែរត់ចូលតំបន់រំដោះ ដើម្បីប្រយុទ្ធប្រឆាំងនឹងសាធារណរដ្ឋខ្មែរ។ សង្គ្រាមក្នុងស្រុកបានផ្ទុះឡើង។

ទ័ពលន់ នល់គ្រប់គ្រងបានតែទីប្រជុំជន ៖ នៅចុងខែមីនា ឆ្នាំ១៩៧០ កសិករដែលរស់នៅតាមតំបន់ព្រំដែនប្រទេស ជាពិសេសក្នុងខេត្តកំពង់ចាម បានងើបបះបោរប្រឆាំងនឹងការទម្លាក់សម្តេចសីហនុពីតំណែង។ យុវជន

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាច្រើនដែលរស់នៅតាមទីជនបទបានរត់ចូលព្រៃធ្វើជាកងទ័ពតាមការអំពាវនាវរបស់សម្តេចសីហនុ។ កងទ័ពរបស់លន់ នល់គ្រប់គ្រងបានតែទីរួមខេត្ត ទីប្រជុំជន និងតាមផ្លូវជាតិសំខាន់ៗតែប៉ុណ្ណោះ។ ថ្វីត្បិតតែសហរដ្ឋអាមេរិកបានផ្តល់ជំនួយយោធា និងហិរញ្ញវត្ថុយ៉ាងច្រើនសន្ធឹកសន្ធាប់ក៏ដោយ ក៏កងទ័ពជាតិខ្មែរ (Force Armée Nationale Khmère) ដែលមានការហ៊ឺកហាត់ខ្សោយ មានតែចំនួនលើក្រដាស គ្មានចំនួនទ័ពគ្រប់គ្រាន់បើកប្រាក់បៀវត្សមិនទៀងទាត់ និងបាក់ទឹកចិត្ត ហើយមិនអាចកម្ចាត់កងទ័ពរំដោះជាតិប្រជាជនកម្ពុជា និងកងកម្លាំងវៀតណាមបានឡើយ។ ដោយមានការគាំទ្រពីកងទ័ពវៀតណាមខាងជើង កងទ័ពរំដោះបានបិទផ្លូវសេដ្ឋកិច្ចសំខាន់ៗ ក្នុងគោលដៅកាត់ផ្តាច់ដង្ហើមសេដ្ឋកិច្ចរបស់របបលន់ នល់។ នៅចុងឆ្នាំ១៩៧០ និងឆ្នាំ១៩៧១ កងទ័ពលន់ នល់បានបើកប្រតិបត្តិការសឹកចេនឡាទី១ និងចេនឡាទី២ ដើម្បីបើកផ្លូវជាតិឡើងវិញ តែត្រូវបរាជ័យ។ រនុកក្នុងរបស់ខ្មែរក្រហមក្នុងកងទ័ពបានផ្តល់ការសម្ងាត់ទាំងអស់ឱ្យខ្មែរក្រហម។ ក្នុងកងទ័ពគ្រប់កងឯកភាពមានការលួចបំបាត់កូនទាហាន ហើយមេបញ្ជាការកឹបយកប្រាក់ខែកូនទាហាន និងខ្មោច ធ្វើជាសម្បត្តិខ្លួន។ កងទ័ពគ្មានវិន័យ ខ្វះទៅអុកឡុកហាងទំនិញ បរិភោគបាយឬគុយទាវមិនឱ្យប្រាក់។

ការបែកបាក់ផ្ទៃក្នុង និងបាតុកម្មសិស្ស-និស្សិត ៖ លោកសេនាប្រមុខ លន់ នល់ និងអ្នកអង្គម្ចាស់សិរីមតៈ គឺជាមិត្តជិតស្និទ្ធគ្នាតាំងពីកុមារភាព។ ក៏ប៉ុន្តែ បន្ទាប់ពីរដ្ឋប្រហារប្លន់ប្រុសរបស់លោក គឺលោក លន់ ណុន គឺជាគូប្រកួតប្រជែងដ៏ស្វិតស្វាញរបស់ទ្រង់សិរីមតៈ។ លន់ ណុនផ្តល់ថវិកាគាំទ្រដល់កាសែតក្នុងស្រុកមួយចំនួន និងបង្កើតគណៈកម្មការសាធារណរដ្ឋដែលប្រមូលផ្តុំបញ្ញវន្តស្តាំនិយម ក្នុងគោលដៅប្រឆាំងនឹងលទ្ធិជានិយមនិងអ្នកអង្គម្ចាស់សិរីមតៈ។ លន់ ណុនបានរៀបចំឱ្យមានបាតុកម្មសិស្សនិងនិស្សិតដើម្បីទាមទារឱ្យអ្នកអង្គម្ចាស់សិរីមតៈលាលែងពីតំណែង។ ខ្មែរ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ក្រហមក៏បានបញ្ចូលមុខសញ្ញារបស់ពួកគេចូលដឹកនាំចលនានិស្សិតៗ បាតុកម្មនិស្សិតបានបង្កើតនូវអស្ថិរភាពនយោបាយ និងការបាត់បង់ជំនឿរបស់ប្រជាពលរដ្ឋ និងទាហានមកលើរបបលន់ នល់។

នយោបាយក្រៅប្រទេស ៖ នយោបាយក្រៅប្រទេសនៃសាធារណរដ្ឋខ្មែរ គឺការរណបសហរដ្ឋអាមេរិក ដោយរដ្ឋាភិបាលនៃសាធារណរដ្ឋខ្មែរពឹងផ្អែកទាំងស្រុងលើជំនួយអាមេរិក។ ក៏ប៉ុន្តែ កម្ពុជានៅតែមានជម្លោះព្រំដែនជាមួយវៀតណាមខាងត្បូង និងជាមួយប្រទេសថៃ ទាំងព្រំដែនគោក ទាំងព្រំដែនទឹក។ សហរដ្ឋអាមេរិកបានបង្កើនជំនួយពី២០លានដុល្លារក្នុងមួយឆ្នាំដល់ជិត២០០លានដុល្លារ តែនៅតែមិនអាចស្រោចស្រង់របបសាធារណរដ្ឋខ្មែរ ដែលពោរពេញទៅដោយអំពើពុករលួយបានឡើយ។

នយោបាយក្នុងប្រទេស ៖ នៅក្នុងរបបសាធារណរដ្ឋខ្មែរ មានគណបក្សនយោបាយពីរគឺ ៖ (១) គណបក្សប្រជាធិបតេយ្យ ដែលដឹកនាំដោយអ៊ិន តាំ និងមានការចូលរួមពីពួកស្តាំនិយមដូចជា សឺង ង៉ុកថាញ់ និងមានការគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់ប្រជាពលរដ្ឋ ជាពិសេសក្នុងមជ្ឈដ្ឋានព្រះសង្ឃ និង (២) គណបក្សសាធារណរដ្ឋដឹកនាំដោយអ្នកអង្គម្ចាស់សិរីមតៈ។ លន់ នល់ស្ថិតនៅពីលើគណបក្សនយោបាយ។

របបលន់ នល់បានខិតខំប្រែក្លាយសង្គ្រាមផ្ទៃក្នុងឱ្យក្លាយជាសង្គ្រាមសាសនាប្រឆាំងនឹងរបបកុម្មុយនីស្តទមិឡឥតសាសនា ដោយសង្ឃឹមថាប្រជាជនខ្មែរភាគច្រើនជាអ្នកគោរពបូជាពុទ្ធសាសនា។ ដូច្នេះ ពួកគេសង្ឃឹមថា ការប្រែក្លាយសង្គ្រាមប្រឆាំងពួកខ្មែរក្រហមឱ្យទៅជាសង្គ្រាមសាសនាអាចនឹងជួយពង្រឹងប្រជាប្រិយភាពរបស់លន់ នល់ ដែលជាអ្នកនយោបាយដែលប្រជាកសិករខ្មែរភាគច្រើនមិនដែលបានស្គាល់។

អស្ថិរភាពនយោបាយ ៖ ក្រោយពីការធ្វើរដ្ឋប្រហារភ្លាម បន្ទាប់ពីមានការអំពាវនាវរបស់សម្តេចសីហនុ នៅចុងខែមីនា ឆ្នាំ១៩៧០ កសិករមកពីខេត្តកំពង់ចាមបានធ្វើបាតុកម្មបង្ខាំងនឹងរបបលន់ នល់។ បាតុកម្ម

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នេះត្រូវបានទាហានលន់ នល់បង្ក្រាបយ៉ាងព្រៃផ្សៃបំផុត។ កងទាហានលន់ នល់ចាប់សម្លាប់ប្រជាជនស្លូតត្រង់វៀតណាម ដែលរស់នៅកម្ពុជាបណ្តែតទឹក ជាហេតុធ្វើឱ្យសភាពការណ៍ផ្ទៃក្នុងប្រទេសចាប់ផ្តើមច្របូកច្របល់។ ម្យ៉ាងវិញទៀត ការដឹកនាំនៃរបបសាធារណរដ្ឋខ្មែរមានភាពរកាំរកូសនិងធូរលុង ដោយសារកត្តាដូចតទៅ ៖

(១) លន់ នល់ធ្លាក់ខ្លួនពិការមួយចំហៀងខ្លួន ដោយសារតែជំងឺលើសឈាម ចាប់ឆ្នាំ១៩៧១មក។ លន់ នល់ គឺជាអ្នកដឹកនាំប្រពៃណី និងមានជំនឿខ្លាំងលើអាគមអូមអាមជាជាងការបណ្តុះបណ្តាលនាយទាហាន នាយទាហានរង និងពលទាហាន និងការពង្រឹងកងទ័ព និងរដ្ឋបាលសាធារណៈ។

(២) ជម្លោះរវាងអ្នកអង្គម្ចាស់សិរីមតៈជាមួយលន់ ណុន ដែលជាប្អូនរបស់លន់ នល់ និងជាអ្នកកាច់ចង្កូត និងញាក់ខ្សែពីក្រោយវាំងននៗ។

(៣) ការប្រកួតប្រជែងរវាងលន់ នល់, អ្នកអង្គម្ចាស់សិរីមតៈ និងអ៊ិន តាំ។

(៤) បញ្ហាវន្តខ្មែរនៅតែបែកបាក់គ្នាជាច្រើនក្រុម និងច្រើនពួក។

(៥) បាតុកម្មសិស្ស និស្សិត និងសាស្ត្រាចារ្យ។

ចាប់ពីឆ្នាំ១៩៧២ ជម្លោះរវាងលន់ ណុន និងអ្នកអង្គម្ចាស់សិរីមតៈបានផ្ទុះឡើងជាសាធារណៈ។ លន់ ណុនបានរៀបចំបាតុកម្មសិស្ស និងនិស្សិតប្រឆាំងនឹងអ្នកអង្គម្ចាស់ ដោយទាមទារឱ្យអ្នកអង្គម្ចាស់សិរីមតៈលាលែងពីតំណែង។ ហើយបន្ទាប់ពីការទម្លាក់គ្រាប់បែកលើផ្ទះលន់ នល់ដោយសមាជិកវាជវង្សានុវង្ស ក្នុងខែមីនា ឆ្នាំ១៩៧៣រួចមក ផ្ទះរបស់អ្នកអង្គម្ចាស់សិរីមតៈត្រូវស្ថិតក្រោមការឃ្លាំមើល។ គ្រូចាប់ផ្តើមធ្វើបាតុកម្មប្រឆាំងរដ្ឋាភិបាល។ ក្រោយមកទើបគេដឹងថា ពួកខ្មែរក្រហមបានដាក់កម្លាំងបង្កប់ ដើម្បីរៀបចំបាតុកម្មផ្តួលរដ្ឋាភិបាលលន់ នល់។ ក្នុងរយៈពេលមិនដល់៥ឆ្នាំផង មានការដោះដូររដ្ឋាភិបាលជាច្រើនលើកច្រើនសា។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្ថានភាពសេដ្ឋកិច្ចដុនដាប ៖ បញ្ហាដ៏ធំនៃរបបលន់ នល់គឺ ៖ ទំនិញ ឡើងថ្លៃ ការខ្វះខាតស្បៀងអាហារ រូបិយវត្ថុបាត់តម្លៃ ការធ្លាក់ចុះនូវកម្រិតជីវភាពរបស់មន្ត្រីរាជការ គ្រូបង្រៀន និងប្រជាជនបើប្រៀបធៀបនឹងរបបសីហនុ អំពើពុករលួយ ការកិបកេងប្រាក់ខែមន្ត្រីរាជការ ទាហានខ្មោចការលក់អាវុធ អង្ករ និងគ្រឿងឧបភោគបរិភោគឱ្យខ្មែរក្រហម។ របបលន់ នល់រស់ដោយសារតែជំនួយរបស់សហរដ្ឋអាមេរិក។ មនុស្សភាគច្រើនដឹងច្បាស់ថា នៅពេលដែលអាមេរិកដកចេញពីឥណ្ឌូចិន របបលន់ នល់នឹងដួលរលំ។

ស្ថានភាពយោធាក្នុងប្រទេស ៖ ស្ថានភាពយោធា និងសមរភូមិកាន់តែដុនដាបទៅៗ ដោយសាកម្លាំងសាធារណរដ្ឋគ្រប់គ្រងបានតែនៅទីប្រជុំជន និងតាមដងផ្លូវជាតិមួយចំនួនប៉ុណ្ណោះ។ ផ្លូវជាតិគមនាគមន៍សំខាន់ៗ ត្រូវបានកាត់ផ្តាច់។ ប្រតិបត្តិការសឹកចេនឡាទី១ និងចេនឡាទី២ទទួលបរាជ័យ។ កងទ័ពបាត់បង់នូវស្មារតីប្រយុទ្ធ។ នៅឆ្នាំ ១៩៧៤ និង ១៩៧៥ កងទ័ពខ្មែរក្រហមបាញ់គ្រាប់ផ្លោងចូលមកភ្នំពេញ ក្នុងគោលដៅបំបាក់ស្មារតីប្រជាជនភ្នំពេញ និងកងទ័ពលន់ នល់។ គេបានប្រើសង្គ្រាមចិត្តសាស្ត្រក្នុងគ្រប់រូបភាព រួមទាំងការធ្វើវិទ្ធង្សនាខាងផ្នែកសេដ្ឋកិច្ចផងដែរ។ មនុស្សភាគច្រើនធ្លាក់ក្នុងភាពអស់សង្ឃឹមជុញច្រាន់នឹងសង្គ្រាម និងគាំទ្រឱ្យមានការចរចាជាមួយខ្មែរក្រហម ដើម្បីបញ្ចប់សង្គ្រាម។

ខ-អន្តរាគមន៍យោធាពីបរទេស

ការហូរចូលនៃកងទ័ពវៀតមិញ ៖ គោលដៅនៃរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ គឺដើម្បីដេញកងទ័ពវៀតកុង និងវៀតណាមខាងជើងចេញពីកម្ពុជា។ ផ្ទុយទៅវិញ ចាប់ពីចុងខែមីនា ឆ្នាំ១៩៧០ គេឃើញមានការហូរចូលនៃកងទ័ពវៀតណាមក្នុងទឹកដីកម្ពុជា ដើម្បីជួយប្លាំងខ្មែរក្រហម។ ម្យ៉ាងវិញទៀត រដ្ឋប្រហារនេះបើកផ្លូវឱ្យសហរដ្ឋអាមេរិកបញ្ជូន

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទ័ពរបស់ខ្លួនមកកម្ពុជា ដើម្បីបើកប្រតិបត្តិការបោសសម្អាតកងទ័ពខ្មែរក្រហម និងវៀតកុង ដោយមានការគាំទ្រពីកងទ័ពវៀតណាមខាងជើង និងមានការគាំទ្រពីកងទ័ពថៃផងដែរ។ រត្តមាននៃកងទ័ពវៀតណាមខាងជើងនៅបន្តរហូតដល់ចុងឆ្នាំ១៩៧២ ទើបកងទ័ពភាគច្រើនបានដកចេញ ដើម្បីត្រៀមអនុវត្តកិច្ចឈប់បាញ់គ្នាដែលចរចានៅហ្សឺណែវ និងតម្រូវឱ្យអាមេរិកដកទ័ពចេញពីវៀតណាមខាងត្បូង ហើយវៀតណាមខាងជើងដកទ័ពចេញពីកម្ពុជា។

ការទម្លាក់គ្រាប់បែកអាមេរិក ៖ ក្នុងខែមករា ឆ្នាំ១៩៧៣ សហរដ្ឋអាមេរិក និងវៀតណាមខាងជើងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបញ្ចប់សង្គ្រាមវៀតណាម។ នៅក្នុងគោលនយោបាយការបរទេស អាមេរិកផ្សារភ្ជាប់ជោគវាសនារបស់វៀតណាមខាងត្បូង ជាមួយនឹងកម្ពុជា។ ដូច្នេះដើម្បីទប់កុំឱ្យកម្លាំងកងទ័ពវៀតកុងលើទឹកដីកម្ពុជា ចូលទៅវាយលុកដណ្តើមយកទីតាំងយោធានៅវៀតណាមខាងត្បូងបាន កងទ័ពអាកាសរបស់អាមេរិកបានធ្វើការទម្លាក់គ្រាប់បែក B-52 ដោយឥតរើសមុខ នៅតាមទីជនបទកម្ពុជា។ ជនជាតិកម្ពុជាស្លូតត្រង់ជាច្រើនម៉ឺននាក់បានបាត់បង់ជីវិត។ ប្រជាជនដែលរស់នៅតាមទីជនបទភាគច្រើនបានបញ្ជូនកូនចៅឱ្យចូលបម្រើក្នុងកងទ័ពរំដោះ ហើយប្រជាជនមួយចំនួនទៀតភៀសខ្លួនមករស់នៅភ្នំពេញ។ ការទម្លាក់គ្រាប់បែកនេះក៏បានបង្កើតជាកំហឹងវណ្ណៈ ដែលក្រោយមកត្រូវបានខ្មែរក្រហមប្រើប្រាស់ ដើម្បីចាត់ការជាមួយកងទ័ពលន់ នល់ និងប្រជាជននៃទីក្រុងភ្នំពេញ។ ការទម្លាក់គ្រាប់បែកនេះបន្តរហូតដល់ខែសីហា ឆ្នាំ១៩៧៣ នៅពេលដែលសភាអាមេរិកទាមទារឱ្យឈប់។ តាមទិន្នន័យរបស់អ្នកស្រាវជ្រាវអាមេរិក Ben Kiernan យន្តហោះចម្បាំងរបស់សហរដ្ឋអាមេរិកបានចេញទៅធ្វើប្រតិបត្តិការចំនួន ២៣០ ៥៦១ដង ដោយទម្លាក់គ្រាប់បែកចំនួន ២,៧លានតោនលើទីតាំងទាំងអស់ចំនួន ១១៣ ៧១៦កន្លែង ដើម្បីកម្ទេចកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាមខាងជើង។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អន្តរាគមន៍នៃកងទ័ពវៀតណាមខាងត្បូង ៖ ដើម្បីទប់ទល់ជាមួយនឹងលំហូរចូលនៃកងទ័ពវៀតណាមខាងជើង អាមេរិកបានបញ្ជូនកងទ័ពរបស់ខ្លួន និងកងទ័ពវៀតណាមខាងត្បូងចូលធ្វើប្រតិបត្តិការសឹកនៅកម្ពុជា។

គ-ការពង្រឹងអង្គការចាត់តាំងយោធា និងនយោបាយខ្មែរក្រហម

ក្នុងបរិការណ៍នៃសង្គ្រាមនៅវៀតណាម និងការទម្លាក់គ្រាប់បែកឥតឈើសមុខនៅតាមទីជនបទកម្ពុជា ប្រជាកសិករជាច្រើនបានបញ្ជូនកូនចៅទៅបម្រើជាយោធានៃកងទ័ពរំដោះ។ នៅក្នុងដំណាក់កាលនេះ ពួកខ្មែរក្រហមចាត់ទុកថាជាបដិវត្តន៍ប្រជាជនប្រជាធិបតេយ្យ ដែលមានគ្រប់សមាសភាពទាំងអស់ចូលរួម (មិនមែនមានតែពួកកុម្មុយនីស្តទេ) ក្នុងគោលដៅរំដោះជាតិឱ្យរួចចាកផុតពីនឹមចក្រពត្តិនិយម។ ក្នុងន័យនេះ ទោះបីជាកងទ័ពវៀតកុង និងវៀតណាមខាងជើងមួយភាគធំត្រូវបានដកចេញពីកម្ពុជា ខ្មែរក្រហមមានលទ្ធភាពកេណ្ឌទ័ពបំពេញ ក្នុងចំណោមកូនចៅកសិករ ដែលរងគ្រោះដោយសារសង្គ្រាម និងការទម្លាក់គ្រាប់បែក។ ក្នុងបរិការណ៍នៃការកើនឡើងនៃអំពើពុករលួយក្នុងរដ្ឋាភិបាលលន់ នល់ និស្សិតបញ្ញវន្ត គ្រូបង្រៀន និងសាស្ត្រាចារ្យខ្លះមើលឃើញជម្រើសខ្មែរក្រហម ថាជាជម្រើសគោលនយោបាយជានានូវយុត្តិធម៌សង្គម និងការសាងសង់សង្គមមួយ ដែលស្អាតស្អំ និងដែលធ្វើយតបទៅតាមការស្រមើស្រមៃរបស់ពួកគេ។

៣-ផលវិបាកនៃរដ្ឋប្រហារផ្តួលរំលំសម្តេចសីហនុសម្រាប់កម្ពុជា

ក-ការបែកបាក់ជាតិកាន់តែធំ

សង្គ្រាមផ្ទៃក្នុងដែលផ្ទុះឡើង បានធ្វើឱ្យខ្មែរបែកបាក់គ្នាកាន់តែធំឡើងៗ។ បញ្ញវន្ត អ្នកពាក់ព័ន្ធ និងប្រជាជនដែលកាន់ជើងភាគីម្ខាងៗក្នុងសង្គ្រាមមិនត្រឹមតែមើលមុខគ្នាមិនត្រង់ទេ តែពួកគេប្រកាន់យកជំហរកាន់តែជាប់ខាតទៅ ដែលបង្កើតឱ្យសង្គមជាតិកម្ពុជាកាន់តែប្រេះស្រាំដូចកែវ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ហើយមិនងាយនឹងផ្សះផ្សា និងបង្រួបបង្រួមជាតិបានៗ ម្យ៉ាងវិញទៀត សង្គ្រាមបានធ្វើឱ្យជនជាតិកម្ពុជា ទាំងទាហាន ទាំងជនស៊ីវិលស្ងួតត្រង់ស្ងាប់អស់ជាងកន្ទុះលាននាក់។ សង្គ្រាមបង្កើតឱ្យមានមានអរិភាព និងកំហឹង ដែលពេលខ្លះក្លាយទៅជាកំហឹងវណ្ណៈ និងបង្កើតឱ្យមានការសងសឹកគ្នានៅពេលក្រោយទៀត។

ខ-សហរដ្ឋអាមេរិកជកថយពីឥណ្ឌូចិន

ចលនាប្រឆាំងសង្គ្រាមនៅវៀតណាម ៖ នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ អ្នកនយោបាយអាមេរិកបានយល់ច្បាស់ថា ពួកគេមិនអាចយកឈ្នះសង្គ្រាមនៅវៀតណាមបានឡើយ ដោយសារប្រជាជនវៀតណាមចង់បានទូរកំណែទម្រង់ខាងផ្នែកនយោបាយ និងសង្គម ដែលរដ្ឋាភិបាលវៀតណាមក្រោមការដឹកនាំរបស់ង៉ោ ឌិនយៀម និងធីវគឺ មិនអាចអនុវត្តបាន។ ម្យ៉ាងវិញទៀត ចលនាប្រឆាំងសង្គ្រាមនៅវៀតណាមបានរាលដាលក្នុងចំណោមនិស្សិត និងបញ្ញវន្ត ដែលទាមទារឱ្យបញ្ឈប់សង្គ្រាមនេះ។ ក្នុងយប់ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៦៨ ដែលជាថ្ងៃចូលឆ្នាំវៀតណាម កងទ័ពរំដោះ និងកងទ័ពវៀតណាមខាងជើងបានវាយចូលទីក្រុងសំខាន់ៗនៅវៀតណាមខាងត្បូង រួមទាំងទីក្រុងព្រៃនគរ និងស្ថានទូតសហរដ្ឋអាមេរិកផងដែរ។ សហរដ្ឋអាមេរិកក៏សម្រេចចិត្តដកទ័ពជាងកន្ទុះលាននាក់ ក្នុងកិត្តិយស។

ការទម្លាក់គ្រាប់បែកដើម្បីបញ្ចប់សង្គ្រាម ៖ លោក និចសុន បានជាប់ឆ្នោតជាប្រធានាធិបតីក្នុងឆ្នាំ១៩៦៨ ដោយសារលោកបានសន្យាថានឹងបញ្ចប់សង្គ្រាមនៅវៀតណាម។ ក៏ប៉ុន្តែ ក្នុងគោលដៅការពាររបប និងកងទ័ពនៅវៀតណាមខាងត្បូងអាមេរិកបានបើកយុទ្ធនាការទម្លាក់គ្រាប់បែកលើកំពង់ផែហាយហ្វុងរបស់វៀតណាម និងនៅតាមតំបន់ព្រំដែនរបស់កម្ពុជាជាមួយវៀតណាម ដែលរុញកម្ពុជាឱ្យចូលបន្តិចម្តងៗក្នុងភ្លើងសង្គ្រាម។

សន្និសិទទីក្រុងហ្សឺណែវ ៖ បន្ទាប់ពីការចរចាអស់រយៈពេលដ៏យូរ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងខែមករា ឆ្នាំ១៩៧៣ សហរដ្ឋអាមេរិក និងរដ្ឋាភិបាលវៀតណាមខាងត្បូងបានចុះកិច្ចព្រមព្រាង ជាមួយសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាមខាងជើង) និងរដ្ឋាភិបាលបណ្តោះអាសន្នវៀតណាមខាងត្បូង នៅទីក្រុងហ្សឺណែវ ដើម្បីប្រកាសឈប់បាញ់គ្នា ដកកងទ័ពអាមេរិកចេញពីវៀតណាម និងប្តូរឈ្លើយសឹកគ្នា។

គ-ការកសាងជាតិដែលចាប់ផ្តើមដោយព្រះបាទអង្គដួងត្រូវបានបំផ្លាញ

សង្គ្រាមដែលបានអូសបន្លាយក្នុងរយៈពេលមិនដល់ប្រាំឆ្នាំផងនោះ (១៩៧០-១៩៧៥) គឺជាសង្គ្រាមក្នុងស្រុកទ្រង់ទ្រាយធំជ្នាក់ជាតិលើកទីមួយ បន្ទាប់ពីសម័យព្រះបាទអង្គដួង ក្នុងឆ្នាំ១៨៦១។ ផ្លូវគមនាគមន៍ត្រូវបានបំផ្លាញខ្ទេចខ្ទី កម្ពុជាបានក្លាយទៅជាចម្ការមីន និងយោធភ័ណ្ឌមិនទាន់ផ្ទុះ។ មូលដ្ឋានឧស្សាហកម្ម និងកសិកម្ម និងសាលារៀន ដែលកសាងឡើងដោយរបបសង្គមរាស្ត្រនិយមត្រូវបានបំផ្លាញ។ ប្រជាពលរដ្ឋខ្មែររាប់សែននាក់បានបាត់បង់ជីវិត។ អ្នកមានទ្រព្យសម្បត្តិបានចាកចេញទៅរស់នៅឯបរទេស។ សមិទ្ធផលដែលសម្រេចបានក្នុងរយៈពេល១៣០ឆ្នាំក្រោយពីការងើបឡើងវិញរបស់កម្ពុជាចាប់តាំងពីសម័យអង្គដួង ត្រូវបានបំផ្ទិចបំផ្លាញដោយការសម្រេចចិត្តខុសជាយុទ្ធសាស្ត្ររបស់ចៅលួតរបស់ព្រះអង្គ គឺអ្នកអង្គម្ចាស់សិរីមតៈ។ កម្ពុជាបានប្រែក្លាយពីកោះសន្តិភាពទៅជាមូលដ្ឋានដែលអំណោយផល សម្រាប់ការធ្វើបដិវត្តន៍ក្រហម។

៤-ការពង្រឹងចលនាឆ្វេងនិយម និងកុម្មុយនីស្តនៅកម្ពុជា

ក-បញ្ញវន្ត និងយុវជនខកចិត្តនឹងបដិវត្តន៍ទទេរបស់លន់ នល់

នៅពេលដំបូង រដ្ឋប្រហាររបស់លោកលន់ នល់ និងព្រះអង្គម្ចាស់សិរីមតៈត្រូវបានគាំទ្រដោយបញ្ញវន្តខ្មែរ និងយុវជនទីក្រុង ដែលមិនពេញ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ចិត្តនឹងការដឹកនាំរបស់សម្តេចសីហនុ ហើយដែលចង់បានទូវសេរីភាព និង
លទ្ធិប្រជាធិបតេយ្យ។ ក៏ប៉ុន្តែ ក្រោយរដ្ឋប្រហារ ប្រព័ន្ធ និងវប្បធម៌នយោ-
បាយមានការផ្ទាស់ប្តូរតិចតួចណាស់ ហើយអំពើពុករលួយ និងបក្សពួក
និយមបានកើនឡើងយ៉ាងខ្លាំង ដែលធ្វើឱ្យបញ្ហាវន្ត និងយុវជនមានការ
ខកចិត្តយ៉ាងខ្លាំង។ លោកលន់ នល់បានអនុវត្តនយោបាយប្រជាភិថុត និង
ប្រកាសសង្គ្រាមសាសនាប្រឆាំងនឹងពួកទមិឡឥតសាសនា ដោយបង្កើត
ចលនាខ្មែរ-មន ក្នុងគោលដៅបង្រួបបង្រួមខ្មែរកណ្តាល ខ្មែរក្រោមនៅ
វៀតណាមខាងត្បូង ខ្មែរនៅប្រទេសថៃ និងមននៅភូមា។ គោលនយោ-
បាយនេះបានធ្វើឱ្យមានជម្លោះការទូតជាមួយប្រទេសថៃ និងវៀតណាម
ខាងត្បូង។ នៅពេលដែលសង្គ្រាមក្នុងស្រុកផ្ទុះឡើង ទាហានលន់ នល់
គ្រប់គ្រងបានតែទីក្រុងភ្នំពេញ និងទីរួមខេត្តមួយចំនួនប៉ុណ្ណោះ។ ផ្លូវគម-
នាគមន៍ត្រូវបានកាត់ផ្តាច់។ និស្សិត និងគ្រូបង្រៀនបានចាប់ផ្តើមធ្វើបាតុកម្ម
ដោយមានការគាំទ្រជាសម្ងាត់ពីពួកខ្មែរក្រហម ដែលបង្កប់ខ្លួនក្នុងចំណោម
គ្រូបង្រៀន និងប្រជាជនទីក្រុង។ គេបានលើកឡើងថា បដិវត្តន៍លន់ នល់
គឺជា«បដិវត្តន៍ទទេ»។

ខ-ការប្រយុទ្ធប្រឆាំងរបបលន់ នល់ដឹកនាំដោយពួកកុម្មុយនីស្ត

នៅឆ្នាំ១៩៧០ ពួកកុម្មុយនីស្តខ្មែរបានចាប់ផ្តើមពង្រឹងអំណាច ដោយ
បង្កើតរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា (Front uni national) ជាមួយ
សម្តេចសីហនុ នៅថ្ងៃទី៣-៤ ខែឧសភា ឆ្នាំ១៩៧០ នៅទីក្រុងប៉េកាំង។
គណៈកម្មការកណ្តាលដែលមានសមាជិកចំនួន៤៦នាក់ត្រូវបានបង្កើតឡើង
ដែលក្នុងនោះមានបញ្ជាវន្តកុម្មុយនីស្តចំនួន១៣រូបគឺ ៖ ហ៊ូ យន់, ហ៊ូ នឹម,
ខៀវ សំផន, ជួន មុំ, ជួន ប្រសិទ្ធ, ជូ ជេត, អៀង ជារិទ្ធ, កែវ មា, ប៊ុក
ឌីសកុមារ, សៀវ អាន, សុខ ធួក, ទីវ អុល និង គង់ សូឌីប។ មេកុម្មុយនីស្ត
ធំៗ ដូចជាប៉ុល ពត និងអៀង សារី គឺជាអ្នកចាំញាក់ខ្សែនៅក្រោយឆាក។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

រដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (Gouvernement Royal Uni National du Kampuchea-GRUNK) ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧០ ដែលមានសម្តេចប៉ែន នុត ជានាយករដ្ឋមន្ត្រី លោកខៀវ សំផន ជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ លោកគាត ឈន់ ជារដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រី លោកសារិន ឆាក ជារដ្ឋមន្ត្រីក្រសួងការបរទេស លោកហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងព័ត៌មាន លោកហ៊ូ យន់ ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោកជួន មុំ ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច លោកចៅ សេង ជារដ្ឋមន្ត្រីទទួលបន្ទុកការងារពិសេស លោកជួន ប្រសិទ្ធ ជារដ្ឋមន្ត្រីទទួលបន្ទុកការងារសម្របសម្រួល លោកចាន់ យូរ៉ាន់ ជារដ្ឋមន្ត្រីក្រសួងអប់រំ ឧត្តមសេនីយឆ្នង សំអុល ជារដ្ឋមន្ត្រីក្រសួងកងទ័ព លោកជា សានជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លោកហួត សម្បត្តិ ជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍សហគមន៍ និងគមនាគមន៍។ ថ្វីត្បិតតែនៅក្នុងសមាសភាពរដ្ឋាភិបាលភាគច្រើនជាអ្នកនយោបាយសីហនុនិយមនៅក្នុងប្រទេសកម្ពុជា ពួកកុម្មុយនីស្តខ្មែរ គឺជាអ្នកដឹកនាំការតស៊ូប្រយុទ្ធប្រឆាំងនឹងរបបលន់ នល់។

ចាប់ពីខែធ្នូ ឆ្នាំ១៩៧០ ទីក្រុងភ្នំពេញទាំងមូលត្រូវបានកាត់ផ្តាច់ពីទីជនបទ។ វិបត្តិនយោបាយ វិបត្តិសេដ្ឋកិច្ច និងវិបត្តិសង្គមកើតឡើងជាបន្តបន្ទាប់។ វិស័យកសិកម្មបានដួលរលំដោយសារតែប្រជាកសិករត្រូវរត់ចោលផ្ទះសម្បែង ដើម្បីទៅរស់នៅទីក្រុងភ្នំពេញ និងតាមទីរួមខេត្ត។ នៅឆ្នាំ១៩៧៣ ផលិតផលស្រូវសម្រេចបានត្រឹមតែប្រមាណ៣៥%នៃផលិតផលឆ្នាំ១៩៦៩។ អ្នករស់នៅទីក្រុងរស់នៅដោយពឹងផ្អែកលើជំនួយពីបរទេស ជាពិសេសការនាំចូលអង្ករដែលផ្គត់ផ្គង់ដោយអាមេរិក។ ផលិតផលឧស្សាហកម្មធ្លាក់ចុះចំនួន៦៦% ហើយពាណិជ្ជកម្មបានធ្លាក់ចុះជាង៧ដង។ ពាណិជ្ជកម្មក្រៅប្រទេសមានឱនភាពជិត១០០លានដុល្លារក្នុងមួយឆ្នាំ។ ថវិកាជាតិមានឱនភាពយ៉ាងខ្លាំង ដោយសារកំណើនចំណាយយោធា ហើយបានក្លាយជាប្រភពនៃអតិផរណាជាច់បង្គៀរ។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិបត្តិខាងលើនេះបានធ្វើឱ្យមានការផ្ទាស់ប្តូររដ្ឋាភិបាលនៃសាធារណរដ្ឋខ្មែរយ៉ាងញឹកញាប់ ៖

១-រដ្ឋាភិបាលដឹកនាំដោយលោកឧត្តមសេនីយលន់ នល់ ជានាយករដ្ឋមន្ត្រីត្រូវបានបង្កើតឡើងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដោយមានព្រះអង្គម្ចាស់សិរីមតៈ ជាឧបនាយករដ្ឋមន្ត្រីទី១ លោកយ៉ែម សំបូរ ជាឧបនាយករដ្ឋមន្ត្រីទី២ និងលោកអុប គឹមអាង ជាឧបនាយករដ្ឋមន្ត្រីទី៣។

២-រដ្ឋាភិបាលដឹកនាំដោយព្រះអង្គម្ចាស់សិរីមតៈ ជានាយករដ្ឋមន្ត្រីត្រូវបានបង្កើតឡើងនៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៧១ ដោយសារលោកលន់ នល់មានជំងឺយ៉ាងធ្ងន់រហូតដល់ពិការខ្លួន។

៣-រដ្ឋាភិបាលដឹកនាំដោយលោកសឺង ង៉ុកថាញ់ ជានាយករដ្ឋមន្ត្រីត្រូវបានបង្កើតឡើងនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧២។

៤-រដ្ឋាភិបាលដឹកនាំដោយលោកហង្ស ជុនហាក់ ជានាយករដ្ឋមន្ត្រីត្រូវបានបង្កើតឡើង នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧២។

៥-រដ្ឋាភិបាលដឹកនាំដោយលោកអ៊ិន តាំ ជានាយករដ្ឋមន្ត្រីត្រូវបានបង្កើតឡើង នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៣។

៦-រដ្ឋាភិបាលដឹកនាំដោយលោកឡុង បូរ៉ែត ជានាយករដ្ឋមន្ត្រីត្រូវបានបង្កើតឡើង នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៣។

៧-រដ្ឋាភិបាលដឹកនាំដោយលោកឡុង បូរ៉ែត ត្រូវបានបញ្ចប់ ដោយគណៈកម្មាធិការកំពូលដែលដឹកនាំដោយឧត្តមសេនីយ សាក់ ស៊ុតសាខន ជាប្រធានត្រូវបានបង្កើតឡើង នៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៥។

នៅក្នុងរយៈពេលពីរឆ្នាំក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ពួកកុម្មុយនីស្តខ្មែរពឹងផ្អែកលើកងទ័ពវៀតណាម ក្នុងការប្រយុទ្ធប្រឆាំងនឹងរបបលន់ នល់។ ក៏ប៉ុន្តែ ចាប់ពីឆ្នាំ១៩៧២មក ពួកកុម្មុយនីស្តខ្មែរបានចាប់ផ្តើមបានចាប់ផ្តើមពង្រឹងអំណាចយោធានៅក្នុងប្រទេស។ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧២ ពួកគេបានបង្កើតអគ្គបញ្ជាការជាន់ខ្ពស់នៃកងកម្លាំងរំដោះបដិវត្តន៍នៅក្នុង

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទ័ពរំដោះជាតិកម្ពុជា ដែលមានខៀវ សំផន ជាប្រធាន ប៉ុល ពត ជាអគ្គ បញ្ជាការ សោ វណ្ណា (សោ ភីម) ជាអគ្គបញ្ជាការរង ហួន ជា ជាស្នងការ នយោបាយ ឆៀន ឈិត (តាម៉ុក) ទទួលបន្ទុកកងសុការ និងសុន សេន ជាប្រធានសេនាធិការនៃកងទ័ព។

នៅក្នុងរយៈពេល៥ឆ្នាំ ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ប្រជាជនខ្មែរ ជាង១លាននាក់ត្រូវបានសម្លាប់ របួស ឬក្លាយជាជនពិការដោយសារ សង្គ្រាម។ សេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះដល់កម្រិតមួយយ៉ាងខ្លាំង។ ភោជនីយដ្ឋាន ប្រមាណជា៨០% ហើយផ្លូវជាតិនិងស្ពានប្រមាណជា៦០% ត្រូវបានកម្ទេច ដោយសារសង្គ្រាម។ កម្ពុជាបានចោះជំហានទៅរកយុគសម័យអន្ធការ ដែលគ្មាននរណាម្នាក់អាចប៉ាន់ស្មានបាន។

៥-ស្នាដៃអក្សរសិល្ប៍នៅសម័យសាធារណរដ្ឋខ្មែរ

សម័យសាធារណរដ្ឋខ្មែរ គឺជាសម័យកាលមួយដែលកម្ពុជាទទួល រងនូវឥទ្ធិពលពីរះបាវ៉ាំងនិងអាមេរិក។មុនរបបលន់ នល់កម្ពុជាឱ្យតម្លៃខ្ពស់ ដល់បញ្ជាវន្តដែលបានទៅសិក្សានៅប្រទេសបារាំង ដោយសារតែភាសា បារាំង គឺជាភាសាផ្លូវការក្នុងការងាររាជការ និងក្នុងវិស័យអប់រំ។ បញ្ជាវន្ត ដែលបានទៅសិក្សានៅសហរដ្ឋអាមេរិកបំពេញការងារក្នុងតំណែងបន្ទាប់ បន្សំប៉ុណ្ណោះនៅក្នុងរាជការ។ បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០មក គេចាប់ផ្តើម បើកទូលាយឱ្យមានការសិក្សាភាសាអង់គ្លេសនៅតាមវិទ្យាល័យ ចាប់ពីថ្នាក់ ទី៥ទំនើប (ថ្នាក់ទី៧បច្ចុប្បន្ន) ហើយបញ្ជាវន្តដែលបានទៅសិក្សានៅសហ-រដ្ឋអាមេរិកបានទទួលតំណែងធំៗនៅក្នុងរាជការ ហើយមួយចំនួនបាន ក្លាយជារដ្ឋមន្ត្រី។

ខាងផ្នែកគំនិតវិញ ចលនាទស្សនវិជ្ជាអត្ថិភាពនិយម (existentialisme) ដែលរីកដុះដាលនៅអឺរ៉ុបនៅសម័យក្រោយសង្គ្រាមលោកលើកទី២ នៅ បន្តមានឥទ្ធិពលយ៉ាងខ្លាំងក្លា នៅក្នុងចំណោមបញ្ជាវន្ត និងយុវជនខ្មែរ។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ខ្ញុំសូមលើកយកអ្នកនិពន្ធ និងទស្សនវិទូបីរូប ដែលមានឥទ្ធិពលខាងផ្នែកគំនិតមកលើបញ្ហាវន្ត និងយុវជនខ្មែរនៅសម័យសាធារណរដ្ឋ ហើយដែលបានសរសេរសៀវភៅទាក់ទងនឹងចរន្តទស្សនវិជ្ជាអត្ថិភាពនិយម គឺលោក វ៉ាន់ឌី កាអុន លោក សុទ្ធ ប៉ូលីន និងលោក ឃុន ស្រ៊ុនៗ ទន្ទឹមនឹងនោះ នៅសម័យសង្គ្រាម ក្រោមការគំរាមកំហែងនៃគ្រាប់ផ្លោង យុវជន សិស្ស និងនិស្សិតសម្ងំអានស្នាដៃ«ប្រលោមលោកកាប់ជាវ» បកប្រែពីភាសាចិន ដែលចេញផ្សាយជារឿងរាល់ថ្ងៃ។

ទី១-លោកវ៉ាន់ឌី កាអុន (Vandy Kaonn) កើតនៅឆ្នាំ១៩៤២នៅទីក្រុងភ្នំពេញ។ លោកគឺជាអ្នកវិភាគប្រវត្តិសាស្ត្រកម្ពុជា និងអក្សរសិល្ប៍ខ្មែរ ហើយលោកក៏ជាអ្នកនិពន្ធសៀវភៅមួយចំនួនទាក់ទងនឹង ទស្សនវិជ្ជា សង្គមវិទ្យា នយោបាយ និងប្រវត្តិសាស្ត្រ។ លោក វ៉ាន់ឌី កាអុន បានសិក្សាផ្នែកសង្គមវិទ្យានៅសិរបោន (Sorbonne) (សាកលវិទ្យាល័យប៉ារីស) ហើយបានបញ្ចប់នៅឆ្នាំ១៩៧០។ លោកបានសរសេរសៀវភៅយ៉ាងច្រើននៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ៖ (១) សង្គមសក្តិភូមិខ្មែរនៅក្នុងរឿងទុំទាវ (១៩៧១) (២) អាល់ប៊ែរត៍ កាមុស ៖ ទស្សនវិទូនៃការឥតន័យ (១៩៧៣) (៣) បញ្ហាវប្បធម៌និងអារ្យធម៌ (១៩៧៣) (៤) ក្បួនចិត្តសាស្ត្រ (១៩៧៣) (៥) វិភាគទាននៃការសិក្សាអក្សរសិល្ប៍ ៖ ប្រាកដនិយមនិងអណ្តែតអណ្តូងនិយម (១៩៧៣) (៦) វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរ ៖ ចលនាអក្សរសិល្ប៍ (១៩៧៣) (៧) សោកនាដកម្មនៃការអផ្សុករបស់អ្នកស្រីប៉ូវ៉ារី ៖ វិភាគប្រលោមលោក (១៩៧៤) និង (៨) ស្នេហាចុកឈាមរបស់កំលោះវ៉ែរទែរ ៖ វិភាគប្រលោមលោក (១៩៧៤)។

បន្ទាប់ពីថ្ងៃរំដោះ លោកវ៉ាន់ឌី កាអុន បានចូលមកធ្វើការនៅគណៈឃោសនាអប់រំមជ្ឈិម ដែលមានការកិច្ចធ្វើការស្រាវជ្រាវប្រវត្តិបក្សប្រជាជនកម្ពុជា និងផ្សព្វផ្សាយគោលនយោបាយរបស់គណបក្ស។ លោកក៏មានការកិច្ចបង្រៀននយោបាយដល់កម្មាភិបាលថ្នាក់កណ្តាលផងដែរ។ ក្រោយ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មក លោកវ៉ាន់ឌី កាអុន បានបង្កើត និងដឹកនាំវិទ្យាស្ថានស្រាវជ្រាវសង្គម នៅក្នុងគណៈឃោសនាអប់រំមជ្ឈិមផងដែរ។ លោកមាននិន្នាការនយោបាយ ប្រឆាំងរាជានិយម។ នៅឆ្នាំ១៩៨៩ នៅពេលដែលលោក ហ៊ុន សែន ចាប់ផ្តើមចរចាជាមួយសម្តេចសីហនុ លោកបានរត់ទៅប្រទេសបារាំង ហើយ ធ្វើការចិញ្ចឹមគ្រួសារយ៉ាងលំបាក មុននឹងក្លាយជាអ្នកកាសែតនៅវិទ្យុបារាំង អន្តរជាតិ នៅឆ្នាំ១៩៩៣។ នៅឆ្នាំ១៩៩៤ លោកបានបញ្ចប់និក្ខេបបទ បណ្ឌិតប្រវត្តិសាស្ត្រនៅទីក្រុងNice។ លោកបានធ្វើការនៅវិទ្យុបារាំងអន្តរ-ជាតិរហូតចូលនិវត្តន៍នៅឆ្នាំ២០០៧។ លោកត្រូវបានប្រជាជនខ្មែរស្គាល់ យ៉ាងទូលំទូលាយតាមរយៈកម្មវិធីប្រវត្តិសាស្ត្រខ្មែរ និង អក្សរសិល្ប៍ខ្មែរ របស់វិទ្យុបារាំងអន្តរជាតិផ្សាយជាខេមរភាសា។

លោក វ៉ាន់ឌី កាអុន បានចែកចលនាអក្សរសិល្ប៍ខេមរនិយម ជា ចរន្តដូចតទៅ ៖

ប្រាកជនិយម ៖ អក្សរសិល្ប៍ប្រាកជនិយម (Réalisme) គឺជាចរន្ត អក្សរសិល្ប៍ដែលមានលក្ខណៈស្របតាមធម្មជាតិ និងដែលយោងទៅតាម ច្បាប់ធម្មជាតិ។ អក្សរសិល្ប៍ប្រាកជនិយមពិពណ៌នា និងលាតត្រដាងការ ពិតនៃលក្ខណៈពិតប្រាកដនៃជីវិតមនុស្សលោក បង្ហាញការពិតក្នុងសង្គម និងលាតត្រដាងដោយត្រង់។ និយាយចំ។ អធិប្បាយរៀបរាប់អំពីចរិយា មាយាទនៃតួអង្គដែលអ្នកនិពន្ធធ្លាប់សង្កេតឃើញក្នុងសង្គម។ អក្សរសិល្ប៍ រឿង«សុភាទន្សាយ»ចូលក្នុងប្រភេទប្រាកជនិយម ដោយសារទន្សាយមិន ជឿតាមការអង្វរករបស់ក្រពើឱ្យស្រាយចំណងក្រពើឡើយ ដោយសារ ទន្សាយមិនជឿថា ក្រពើនឹងតបស្នងសងគុណទន្សាយវិញ ដូចពាក្យចាស់ លោកថា «ធ្វើល្អបានល្អ»នោះឡើយ។ ជាតិជាសត្វ ដែលបរិភោគសាច់ ក្រពើនឹងលេបត្របាក់ទន្សាយ តាមច្បាប់ធម្មជាតិជាក់ជាមិនខាន។ ទស្សន: ប្រាកជនិយមក៏បង្ហាញផងដែរពីភាពជាក់ស្តែងខ្លះដូចជា«ខ្លួនទាបកុំតោង ដៃខ្ពស់កុំឈោងស្រាវឱបភ្នំ»។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

អណ្តែតអណ្តូងនិយម ៖ អក្សរសិល្ប៍អណ្តែតអណ្តូងនិយម (Romantisme) គឺជាចរន្តអក្សរសិល្ប៍ដែលមានលក្ខណៈផុយពីការពិត ដែលមានតែនៅក្នុងការស្រមើស្រមៃ និងការរំពឹងរបស់អ្នកនិពន្ធ ហើយដែលមានតែក្នុងគំនិត (Idéal) តែប៉ុណ្ណោះ។ រឿងអណ្តែតអណ្តូងនិយមបង្ហាញថា នៅក្នុងលោកនេះគ្មានអ្វីដែលធំជាងស្នេហាឡើយ ហើយតួអង្គខិតខំស្វែងរកស្នេហាដែលបរិសុទ្ធ។ នៅពេលខ្លះដំណើរសាច់រឿងនៃអក្សរសិល្ប៍អណ្តែតអណ្តូងនិយម វាច្រាសចាកពីច្បាប់ធម្មជាតិ។ អណ្តែតអណ្តូងនិយមខ្លះមានលក្ខណៈឧត្តមគតិនិយម គឺថាអ្វីៗសុទ្ធសឹងតែល្អចំពោះមនុស្សលោកទាំងអស់។

ជីវិតនិយម ៖ អក្សរសិល្ប៍ជីវិតនិយមមានគោលដៅអប់រំឱ្យស្រឡាញ់ជីវិត ឱ្យចេះតស៊ូយ៉ាងអង់អាចក្លាហាន ដោយមិនឱ្យតម្លៃខ្លាំងពេកលើប្រព័ន្ធគំនិត។ តួអង្គសុខចិត្តក្រេបយកសុកមង្គល ថ្វីត្បិតតែវាជាសុកមង្គលបន្តិចបន្តួចក៏ដោយ។ ទស្សនវិជ្ជាជីវិតនិយម គឺជាទស្សនវិជ្ជាសុទិដ្ឋិនិយម ហើយមិនបង្រៀនមនុស្សឱ្យលះបង់ជីវិតលោកិយសុខៈ ដើម្បីស្វែងរកសេចក្តីសុខក្នុងបរលោកឡើយ។ រឿងសុភាទន្សាយអាចចាត់ទុកថាជាអក្សរសិល្ប៍ជីវិតនិយម ដោយទន្សាយប្រើប្រាស់តែប្រាជ្ញាដែលខ្លួនមាន ដើម្បីដោះស្រាយបញ្ហា។ ទន្សាយត្រូវរកគ្រប់កលល្បិច ដើម្បីប្រយុទ្ធតទល់នឹងអ្នកខ្លាំង។ សុភាទន្សាយជាតួអង្គមានសច្ចធម៌ ស្រឡាញ់យុត្តិធម៌ ចេះជួយយកអាសាអ្នកទន់ខ្សោយ និងអ្នកស្លូតត្រង់ប្រៀបបីដូចជាស្ថាប័នតុលាការដូច្នេះដែរ។

វិចារណនិយម ៖ អក្សរសិល្ប៍វិចារណនិយមទាត់ចោលទូរជំនឿ និងបុរេនិច្ឆ័យ ដែលគ្មានវិចារណញ្ញាណជាមូលដ្ឋាន ហើយយកប្រាជ្ញា និងតម្រិះវិជ្ជាធ្វើជាមធ្យោបាយ ដើម្បីដោះស្រាយបញ្ហា។ រឿងធនញ្ជ័យគឺជាវណ្ណកម្មអក្សរសិល្ប៍ ដែលឈរលើមូលដ្ឋាននៃតក្កវិជ្ជា និងការពិចារណា។ ធនញ្ជ័យបានយកចំណេះប្រាជ្ញារបស់ខ្លួនជាដើមទុន ដើម្បីប្រយុទ្ធនឹងសណ្តាប់ធ្នាប់សង្គមសក្តិភូមិ ក្នុងអំឡុងសតវត្សទី១៨ និង១៩។ ក្នុងរឿង

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ធនញ្ជ័យ អ្នកនិពន្ធចង់បង្ហាត់បង្ហាញពីរបៀបដោះស្រាយបញ្ហា ដោយត្រូវប្រើប្រាស់ប្រាជ្ញា និងតក្កវិជ្ជា ដើម្បីទប់ទល់នឹងកលល្បិចគ្រប់បែបយ៉ាង។ វណ្ណកម្មនេះបើមើលដំបូងហាក់បីដូចជារឿងកំប្លែង តែបង្កប់នូវវិធីត្រិះរិះពិចារណាយ៉ាងជ្រាលជ្រៅ ដែលយើងអាចឱ្យនិយមន័យថា គឺជាចរន្តអក្សរសិល្ប៍វិចារណនិយមក្នុងចលនាអក្សរសិល្ប៍ខេមរនិយម។

ទី២-លោក សុទ្ធ ប៉ូលីន (Soth Polin) កើតនៅឆ្នាំ១៩៤៣ នៅស្រុកកំពង់សៀម ខេត្តកំពង់ចាមនៅក្នុងគ្រួសារបញ្ញវន្ត (ជីតារបស់លោក គឺជាកវីនិពន្ធដ៏ល្បីល្បាញឈ្មោះ នូ កន ដែលនិពន្ធរឿងទាវឯក)។ នៅក្នុងយុវវ័យ លោកចូលចិត្តអានសៀវភៅខ្មែរ ស្នាដៃអក្សរសិល្ប៍បារាំង និងស្នាដៃទស្សនវិជ្ជានៃបស្ចិមប្រទេស។ លោកជាអ្នកនិពន្ធខ្មែរ ដែលប្រលោមលោកដំបូងរបស់លោកមានចំណងជើងថា «ជីវិតឥតន័យ» ហើយត្រូវបានចេញផ្សាយក្នុងឆ្នាំ១៩៦៤ នៅពេលដែលលោកមានអាយុ២២ឆ្នាំ។ លោកធ្លាប់ជាអ្នកសរសេរកាសែតឱ្យកាសែតខ្មែរឯកភាជ្យរបស់ពូលោក ស៊ឹម វ៉ា ហើយក៏បានបង្កើតកាសែតនគរធំ ដែលត្រូវបានបោះពុម្ពផ្សាយចាប់ពីចុងទសវត្សរ៍ឆ្នាំ១៩៦០រហូតដល់ឆ្នាំ១៩៧៦។ លោកបានផ្លាស់ទៅប្រទេសបារាំងនៅឆ្នាំ១៩៧៤ ហើយបន្ទាប់មកក៏ផ្លាស់ទៅសហរដ្ឋអាមេរិក។

រឿង«ជីវិតឥតន័យ»លាតត្រដាងនូវទំនាស់វណ្ណៈ ដែលអ្នកនិពន្ធមានបំណងធ្វើការស្រាវជ្រាវ និងធ្វើការវិនិច្ឆ័យពីព្រលឹង និងចិត្តថ្លើមរបស់មនុស្ស។ នៅក្នុងសាច់រឿងនេះ គេឃើញមានឥទ្ធិពលនៃចលនាទស្សនវិជ្ជាអត្ថិនិយម ជាពិសេសរឿង«មិនចុះសម្រុងនឹងជីវិត (l'Étranger)» របស់ Albert Camus និងរឿង «កំអួត» របស់ Jean-Paul Satre។ សាច់រឿងនេះបរិយាយពីលោកស្រីយ៉ាវ៉ុម ដែលនាំកូនស្រីឈ្មោះ រ័តនា អតីតសិស្សអនុវិទ្យាល័យនពោត្តម ដែលមានសម្រស់ល្អផ្តាច់គេ មកកោះលួង ក្នុងខេត្តកំពង់ចាម ដើម្បីរៀបមង្គលការកូនស្រីជាមួយអនាគតវេជ្ជបណ្ឌិតម្នាក់ ដែលនាងមិនដែលស្គាល់ និងមិនស្រឡាញ់។ ស្ថិតនៅក្រោមការគាបសង្កត់ពី

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ម្តាយ រ័តនាបានក្លាយជានារីម្នាក់ដែលបាត់សតិដូចជា «វត្តវរ» និង«រលួយ ស្មោះ»។ នាងឥតដឹងខ្លួនដោយសារតែនាងបានក្លាយជា«វត្តវរ»ទៅហើយ។ ព្រលឹងរបស់នាងនៅបិតនិត្យនៅជាប់សង្សាររបស់នាងនៅឯភ្នំពេញ ឈ្មោះ សាវ៉ាក់ទៅហើយ។ សតិវិញ្ញាណរបស់នាងត្រូវគ្របសង្កត់រឹតរួត ដោយដួង ព្រលឹងរបស់សង្សារនាង។ រ័តនាគឺជានារីដែលស្រេកឃ្លានសេរីភាព និង មានមហិច្ឆតាកៃច្នៃព្រងើយនានាងទៅតាមចំណង់ និងតាមចង្វាក់នៃ បេះដូង ហើយចង់រើបម្រាស់ពីសំណាញ់ប្រពៃណី និងទំនៀមទម្លាប់។ នាងចង់បានសុភមង្គលពិតៗ។ នាងមិនចង់ធ្វើតាមបំណងរបស់ឪពុកដែល ធ្លាប់ពោលថា ៖ «បើកូនឯងយកគ្នាជាប្តីប្រពន្ធទៅ ទុកជាមិនស្រឡាញ់គ្នា ក៏ដោយ យូរៗទៅគង់តែស្រឡាញ់គ្នាជាមិនខាន»។ រ័តនាជាកូនក្រមុំអ្នក មានស្តុកស្តម្ភម្នាក់ មានរូបសម្បត្តិលើសគេនៅភ្នំពេញ តែត្រូវបានឪពុក ម្តាយបង្ខំឱ្យរៀបការជាមួយកំលោះម្នាក់ឈ្មោះចម្រើន។ ថ្វីត្បិតតែចម្រើន មានរូបសម្បត្តិធើតធាយ តែចំពោះរ័តនា នាងគ្មានស្រឡាញ់បុរសនេះបន្តិច សោះ។

សេចក្តីស្នេហារបស់រ័តនាធំជាងសេចក្តីស្លាប់ទៅទៀត ដោយនាង ស្រឡាញ់សង្សារស្មើជីវិត។ ថ្វីត្បិតតែនាងជានារីនៅក្រមុំ តែបេះដូងរបស់ នាងមានចៅហ្វាយរួចទៅហើយ គឺនាងបានលួចស្រឡាញ់កំលោះសាវ៉ាក់។ ក៏ប៉ុន្តែ សាវ៉ាក់ជាកំពូលបុរសកម្សត់ម្នាក់ ដែលស្អប់ខ្ពើមទ្រព្យសម្បត្តិ បុណ្យសក្តិ កិត្តិយស ជាពិសេសគឺស្អប់ខ្ពើមកូនក្រមុំអ្នកមានតែម្តង។ ចំពោះ សាវ៉ាក់ ជីវិត គឺជាកំអួត ការឆ្កើមរអើមជីវិតឥតន័យ និងឥតខ្លឹមសារ។ ពេលវេលាសង្កត់សង្កិនមនុស្សគ្មានក្តីមេត្តា។ សោកស្តាយរបស់សាវ៉ាក់ គឺស្ថិត នៅលើការកម្សត់។ សាវ៉ាក់ជាអ្នកចូលចិត្តអានសៀវភៅ ហើយក៏ជាបញ្ញា-វន្តម្នាក់ដែរ។ តែរ័តនាបានតស៊ូទាក់ទាញសាវ៉ាក់ឱ្យចាប់ចិត្តប្រតិព័ទ្ធលើរូប នាង។ ស្នេហានេះគឺជាស្នេហាផ្កែកបន្ទោរ។ សោកស្តាយក្នុងដួងចិត្តរបស់ ស្រីក្រមុំ។ លុះបានសម្រេច នាងត្រូវប្រឈមមុខជាមួយម្តាយនាងម្តង។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សេចក្តីស្នេហាខ្លាំងកើតឡើងដោយសារមានឧបសគ្គមកពារាំង។ នាងសុខចិត្តធ្វើតាមបំណងឪពុកម្តាយ ដោយសារសេចក្តីអាណិតដល់ឪពុកម្តាយនាង។ ក៏ប៉ុន្តែ វែតនាបែរជាមានចិត្តប្រតិព័ទ្ធលើសាវ៉ាក់ ដែលមិនស្រឡាញ់នាង ហើយត្រូវជាបងប្អូនជីដូនមួយរបស់ចម្រើនទៅវិញ។ ចំណែកសាវ៉ាក់វិញ គេជាអ្នកក្រជាបុរសលេះដូងដែក បុរសគ្មានស្នេហា ជាតួកម្សត់ ស្អប់ខ្ពើមជីវិត ស្អប់ខ្ពើមការរស់នៅ មិនចុះសម្រុងនឹងជីវិត។ ជីវិតរបស់សាវ៉ាក់គឺជាជីវិតដែលឥតខ្វីមសារៗ តែសាវ៉ាក់ជាសិស្សម្នាក់ដែលរៀនពូកែ មានចរិយាថ្លៃថ្នូរ ចេះតស៊ូ។ ផ្ទុយទៅវិញ ចម្រើនជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ដែលមានឪពុកជាអ្នកពាជការធំ។ ជាទីបញ្ចប់ គួរស្នេហ៍ទាំងពីរសុខចិត្តសម្លាប់ខ្លួន ដើម្បីគេចឱ្យផុតពីជីវិតឥតន័យ។

ទី៣-លោក ឃុន ស្រ៊ុន កើតនៅក្នុងស្រុកសំពោធ ខេត្តតាកែវ នៅឆ្នាំ ១៩៦៥ ក្នុងគ្រួសារកូនចៅចិនក្រីក្រមួយ។ នៅពេលដែលលោកមានអាយុ ៨ឆ្នាំ បិតារបស់លោក ឃុន គឹមឆេង ដែលរត់មកពីប្រទេសចិន ដើម្បីគេចពីរបបកុម្មុយនីស្តបានទទួលមរណភាព ហើយលោកនិងបងប្អូន៦នាក់ទៀតស្ថិតនៅក្នុងបន្ទុករបស់ម្តាយលោកឈ្មោះ ជី អេង ដែលប្រកបរបរលក់ដូរបន្តិចបន្តួច។ ដោយលោកជាសិស្សពូកែម្នាក់ លោកទទួលអាហារូបករណ៍ ដើម្បីសិក្សានៅកម្រិតវិទ្យាល័យ និងនៅមហាវិទ្យាល័យ។ នៅក្នុងទសវត្សទី៦០ លោកបានក្លាយជាសាស្ត្រាចារ្យគណិតវិទ្យា និងជាអ្នកនិពន្ធកំណាព្យ និងសៀវភៅ។ លោកបានចូលរួមក្នុងគណៈកម្មការសរសេរសៀវភៅគណិតវិទ្យារបស់ក្រសួងអប់រំជាតិផងដែរ។ លោកបានបោះពុម្ពសៀវភៅជាច្រើនជាអាទិ៍ ៖ (១) គណិតវិទ្យាថ្នាក់ទី៣-៤-៥-៦-៧-៨ (១៩៧០) (២) សៀវភៅជំទង់អំពីចំណេះដឹង (១៩៧១) (៣) សំរស់ជីវិត (១៩៧១) (៤) ជំទង់អំពីស្នេហា (១៩៧១) (៥) ហ្សង់ប៉ូល សាត្រ និងអាល់បែរ កាមុស ១៩៧២ និង (៦) លំនៅចុងក្រោយ (១៩៧២)។

រឿង«លំនៅចុងក្រោយ»របស់លោក ឃុន ស្រ៊ុន គឺជាកម្រងរឿង

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

និទានចំនួន៥។ រឿងទីមួយមានចំណងជើងថា «ផ្នែកបន្ទោរមួយ» ដែលមានលំនាំរឿងប្រហាក់ប្រហែលនឹងរឿងខ្លី «Erostratus» ដែលអ្នកនិពន្ធបារាំង Jean-Paul Sartre បានតែងនៅក្នុងសៀវភៅរបស់លោក Le mur ឬជញ្ជាំង។ អ្នកនិទានរឿង ដែលជាអ្នកទោសម្នាក់ស្រាប់តែចង់ប្រាថនារីម្នាក់ឈ្មោះថា នាងញក់ អាយុប្រហែលសាមសិបឆ្នាំ រត់មកពីស្រែ ដែលចូលចិត្តនិយាយកវ ចូលចិត្តក្តេងក្តាង ហើយមានគំនិតអាត្មានិយមឱ្យធ្ងាក់ពីអគារបួនជាន់ នៅពេលដែលអ្នកទាំងពីរកំពុងដួតទឹក។ ទង្វើនេះពិតជាទង្វើមួយដែលប្លែកដែលអាចធ្វើឱ្យអ្នកនិទានមានឈ្មោះល្បីល្បាញ។ លោកប្រៀបប្រដូចទង្វើបែបនេះជាមួយទង្វើរបស់រដ្ឋាភិបាល ដែលចាប់មនុស្សសួតត្រង់ដូចរូបលោក ឃុន ស្រ៊ុន ទៅជាក់គុក។ បន្ទាប់ពីក្តីស្រមើ-ស្រមៃនេះ អ្នកនិពន្ធស្រាប់តែដឹងខ្លួនឡើងវិញ ហើយចាត់ទុកជីវិតថា ជារឿងមួយដែលអាចស្ងាប់ដោយគេមិនអាចនឹកស្មានដល់។

រឿងទីពីរមានចំណងជើងថា «កេទដែលគេជិន» ដែលលាតត្រដាងរឿងរបស់អ្នកគ្រូ សារឿន ដែលមានលក្ខណៈប្លែកពីគេឯង។ អ្នកគ្រូមានរូបរាងល្អលើសបន្តិច មានឫកពាស្រគត់ស្រគំ ចូលចិត្តសិក្សាស្រាវជ្រាវ មាននិស្ស័យជាមួយសិស្សនិងបុគ្គលិករួមការងារ តែមិនព្រមយកគ្រូសារដោយសារគាត់ស្អប់ប្រុស។ អ្នកគ្រូយល់ឃើញថា ប្រុសៗតែងតែជិះជាន់ស្ត្រី ហើយការរៀបអាពាហ៍ពិពាហ៍មិននាំមកនូវសុភមង្គលឡើយ។ ម្យ៉ាងវិញទៀត មនុស្សស្រីមានសិទ្ធិក្នុងការមិនបង្កើតកូន។ អ្នកគ្រូស្អប់មនុស្សប្រុសដោយសារនៅក្នុងសង្គមខ្មែរ មនុស្សប្រុសតែងតែធ្វើបាបមនុស្សស្រី។ រឿងនេះបង្ហាញពីការទាមទារសិទ្ធិរបស់ស្ត្រីនៅក្នុងសង្គមខ្មែរ ហើយតួអង្គអ្នកគ្រូសារឿនចង់រើបម្រាស់ឱ្យផុតពីសំណាញ់នៃប្រពៃណី និងទន្ទឹមទម្លាប់។ រឿងនេះឆ្លុះបញ្ចាំងពីទំនាស់រវាងតួអង្គ និងសង្គមបរិយាកាសនៅក្នុងសង្គមខ្មែរនាសម័យនោះ គឺជាការមិនចុះសម្រុងនឹងសង្គម។

រឿងទីបីមានចំណងជើងថា «ផ្ទះអទ្ទិតសុខ» ដែលតួអង្គឈ្មោះសុខ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បានរត់ពីភូមិកំណើតទៅរស់នៅភ្នំពេញ ហើយធ្វើការជាអ្នកបម្រើតាមផ្ទះ។ សុខ គឺជាមនុស្សម្នាក់ដែលមើលឃើញថា អ្នកភូមិគាត់តែងតែយកចង្ការមកវត្ត ដើម្បីប្រាថ្នាសុំឡើងឋានសួគ៌។ ពុទ្ធបរិស័ទខ្វះបុណ្យក៏សាង បាបក៏សាង ដោយសារតែគេជឿជាក់ថា ទោះបីជាយ៉ាងណា ព្រះអាចជួយយោងពួកគេដល់ឋានសួគ៌ទាំងអស់គ្នា។ សុខបានរៀបការជាមួយស្ត្រីម្នាក់ដែលខ្លួនលួចស្រឡាញ់ជាយូរមកហើយ។ នៅពេលដែលនាងមានផ្ទៃពោះ ស្រាប់តែមានចោរមកប្លន់ ហើយសម្លាប់ប្រពន្ធសុខបាត់ទៅ។ សុខក៏បានសម្លាប់ចោរទាំងនោះអស់ទៅ។ ចោរទាំងនោះគ្មាននរណាក្រៅពីជំទប់មេឃុំ និងអ្នកលេងនៅក្នុងភូមិទេ។ សុខត្រូវរត់ចោលស្រុកទៅរស់នៅភ្នំពេញ។ សុខក៏ទៅធ្វើជាជាងធ្វើផ្ទះនៅភ្នំពេញ ហើយស្នាក់នៅជាមួយគ្រួសារអ្នកមានម្នាក់។ សុខបានរៀនបើកឡាន ហើយប្រឡងបានប័ណ្ណបើកបរមួយ។ ថ្ងៃមួយសុខបានចាកចេញពីផ្ទះអ្នកមាននេះ ដើម្បីទៅស្វែងរកទ្រនំថ្មី។ សុខបានទៅរស់នៅជាមួយគ្រួសារថ្មី ដែលម្ចាស់ស្រីប្រកបរបរធ្វើជាគ្រូបង្រៀនតែប្តីលោកស្រីជាអ្នកលេងល្បែងបំផ្លាញអស់ទ្រព្យសម្បត្តិ។ លោកស្រីអស់សង្ឃឹមជាមួយប្រុសៗ។ ស្រាប់តែសុខមានចិត្តអាណិតលោកស្រី ហើយថែមតែលួចស្រឡាញ់លោកស្រីថែមទៀត។ សុខបានសរសេរសំបុត្រជូនលោកស្រី ដើម្បីលាតត្រដាងពីស្នេហារបស់ខ្លួនចំពោះលោកស្រី តែបានត្រឹមតែទទួលការស្តីបន្ទោសពីលោកស្រីប៉ុណ្ណោះ។ សុខក៏សម្រេចចិត្តចាកចោលផ្ទះនេះដោយក្តីអាល័យ។ ទីបំផុត សុខបានទៅរស់នៅផ្ទះគ្រូបង្រៀនម្នាក់។ លោកគ្រូបានណែនាំសុខឱ្យអាន និងសរសេរសៀវភៅ។ «ជីវិតជារឿង...គ្មាននរណាជៀសរឿងរួចទេ...ស្រុកគេ ពិសេសបារាំង គេមានអីៗ លឿន ព្រោះស្មេរគេហ៊ានរត់កាត់រឿងណា...តម្លៃស្មេរទូទៅ នៅត្រង់ប៉ុនវែករឿងនេះឯង»។ រឿងមនុស្សផ្ងាស់ប្តូរភាល់ពេល។ រឿងទីបួនឈ្មោះថា «សាលាខ្ញុំ» ហើយរឿងទីប្រាំមានចំណងជើងថា «គ្រូកឿន» ដែលបរិយាយពីអនុស្សាវរីយ៍របស់លោក ឃុន ស្រ៊ុន កាលនៅសិក្សា។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នៅឆ្នាំ ១៩៧៣ លោក ឃុន ស្រ៊ុន បានសរសេររឿង «ជនជាប់ចោទ» ដែលលាតត្រដាងពីជីវិតផ្ទាល់របស់លោក នៅពេលដែលរដ្ឋាភិបាលលន់ នល់ចាប់លោកជាក់គុក។ ស្នាដៃនិពន្ធរបស់លោក ឃុន ស្រ៊ុន ទទួល ឥទ្ធិពលពីចលនាទស្សនវិជ្ជាអត្ថិភាពនិយម (existentialisme) និងទស្សន-វិជ្ជាព្រះពុទ្ធសាសនា។ ក្រោយពីចេញពីគុកនៅឆ្នាំ១៩៧៣ លោក ឃុន ស្រ៊ុន បានរត់ទៅចុះចូលធ្វើបដិវត្តន៍ជាមួយពួកខ្មែរក្រហម។ បន្ទាប់ពីខ្មែរ ក្រហមវាយបែកភ្នំពេញ លោក ឃុន ស្រ៊ុន (ដែលឈ្មោះបដិវត្តន៍ហៅ ថាកឿន) ត្រូវបានអង្គការចាត់តាំងឱ្យទៅធ្វើការជាវិស្វកររទេះភ្លើង។ នៅ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៨ លោក ឃុន ស្រ៊ុន និងគ្រួសារត្រូវបានអង្គការ ចាប់យកទៅជាក់គុកទួលស្វែង ហើយសម្លាប់ចោល។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំពូក១១
កម្ពុជាប្រជាធិបតេយ្យ
(១៩៧៥-១៩៧៩)

របបកម្ពុជាប្រជាធិបតេយ្យបានកម្ទេចអស់ទាំងស្រុងនូវសមិទ្ធផលខាងផ្នែកអភិវឌ្ឍធនធានមនុស្ស ដែលសម្រេចបានក្នុងរយៈពេល១៣០ឆ្នាំនៃការអភិវឌ្ឍកម្ពុជា ដែលបញ្ជាវន្តខ្មែរបានខិតខំប្រឹងប្រែងកើបឡើងវិញឱ្យស្មើ ហើយថែមទាំងលើសប្រទេសក្នុងតំបន់ទៀតផង ដែលចាប់ផ្តើមឡើងតាំងពីសម័យអង្គដួងមកម្ល៉េះ។ កម្ពុជាបានធ្លាក់ចុះដល់កម្រិតសូន្យឡើងវិញ។ តើនេះជាវាសនា ជាបណ្តាសា ជាការសងសឹក ជាការសម្រេចចិត្តដ៏ឃោរឃៅគ្មានមនុស្សធម៌ ឬជាឧក្រិដ្ឋកម្មដើម្បីសម្រេចនូវមហិច្ឆតាឬក្តីស្រមើស្រមៃគ្មានវិចារណញ្ញាណ?

ការដួលរលំនៃរបបលន់ នល់នៅភ្នំពេញ និងរបបសាធារណរដ្ឋវៀតណាម នៅវៀតណាមខាងត្បូង នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ និងជោគជ័យរបស់ពួកកុម្មុយនីស្តនៅប្រទេសឡាវបានធ្វើឱ្យឧបទ្វីបឥណ្ឌូចិនទាំងមូលធ្លាក់ចុះទៅក្នុងជំរំកុម្មុយនីស្ត។ តំបន់អាស៊ីអាគ្នេយ៍បានបោះជំហានចូលក្នុងដំណាក់កាលថ្មីមួយទៀត ក្នុងការប្រឈមមុខរវាងលោកសេរី និងលោកកុម្មុយនីស្ត។ ប្រទេសសមាជិកអាស៊ានមានការព្រួយបារម្ភយ៉ាងខ្លាំងដោយសារពួកគេព្រួយបារម្ភពីការរាលដាលនៃលទ្ធិកុម្មុយនីស្តចូលប្រទេស

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ថៃ និងប្រទេសផ្សេងទៀត។

១-មូលហេតុអ្វីបានជាខ្មែរក្រហមធ្វើបដិវត្តន៍?

ការវិវត្តនយោបាយទ្វេនិយមនៅកម្ពុជាមានចំណុចបួនសំខាន់ៗ ៖

ក-ការបង្កើតបក្សប្រជាជនបដិវត្តន៍កម្ពុជា និងការតស៊ូ

ការប្រយុទ្ធផ្ទៃក្នុងបក្ស ៖ បន្ទាប់ពីបក្សកុម្មុយនីស្តឥណ្ឌូចិនត្រូវបានរំសាយ បក្សប្រជាជនបដិវត្តន៍ខ្មែរត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១ ដោយឈរលើមូលដ្ឋាននៃលទ្ធិម៉ាក្សឡេនីន។ អាចារ្យម៉ៀន (សឺង ង៉ឹកមិញ) ត្រូវបានតែងតាំងជាលេខាបក្សរហូតដល់ចុងទសវត្សរ៍៥០។ ក្រោយសន្ធិសីទទីក្រុងហ្សឺណែវ វៀតណាមបានបញ្ជូនខ្មែរដែលបណ្តុះ-បណ្តាលនៅភាគខាងជើងជាច្រើនពាន់នាក់ត្រលប់ទៅវិញ។ គណបក្សប្រជាជនក៏បានចូលរួមក្នុងការបោះឆ្នោតឆ្នាំ១៩៥៥ដែរ តែទទួលបានសំឡេងគាំទ្រតិចតួចណាស់។ នៅក្នុងបក្ស ចែកចេញជាខ្មែរវៀតមិញ និងខ្មែរឯករាជ្យពីវៀតណាម។ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ពួកបដិវត្តន៍មួយក្រុមបានកោះប្រជុំបក្សប្រជាជនបដិវត្តន៍កម្ពុជា ហើយបានដូរឈ្មោះទៅជាបក្សពលករកម្ពុជា ដែលជាបក្សលទ្ធិម៉ាក្សលេនីន មានលក្ខន្តិក: និងគណៈកម្មការកណ្តាល ហើយដែលទូ សាមុត ត្រូវបានតែងតាំងជាលេខាធិការបក្ស ហើយនួន ជាជាអនុលេខា ចំណែកឯសាឡុត ស (ប៉ុល ពត) ត្រូវបានតែងតាំងជាអនុលេខាទីពីនៅឆ្នាំ១៩៦១។ នៅខែកុម្ភៈ ឆ្នាំ១៩៦៣ ក្រោយពីលោកទូ សាមុតបាត់ខ្លួនគួរឱ្យសង្ស័យ និងបន្ទាប់ពីលោក សឺង ង៉ឹកមិញ ស្លាប់នៅប៉េកាំងមក មហាសន្និបាតបក្សជាបន្ទាន់មួយត្រូវបានប្រារព្ធឡើង ហើយបានជ្រើសតាំងប៉ុល ពតជាលេខាបក្ស។ មេដឹកនាំបក្សកុម្មុយនីស្តជាច្រើន ដែលក្នុងនោះមានប៉ុល ពត និងអៀង សារី ផងដែរបានរត់ចូលព្រៃ ដើម្បីធ្វើការតស៊ូបដិវត្តន៍។ ក្នុងឆ្នាំ១៩៦៧ បន្ទាប់ពីកុបកម្មនៅ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សំឡុត ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នីមក៏រត់ចូលព្រៃអស់ទៀត។

អង្គការ គឺជាស្ថាប័នកំពូលរបស់បក្ស ៖ នៅក្នុងរបបប៉ុល ពត អង្គការគឺជាស្ថាប័នខ្ពស់បំផុតរបស់បក្ស។ បើតាមលក្ខន្តិក: អង្គការគឺជាគណៈកម្មការកណ្តាលនៃបក្សកុម្មុយនីស្តកម្ពុជា។ ក៏ប៉ុន្តែ នៅចន្លោះការប្រជុំគណៈកម្មការកណ្តាល គឺការិយាល័យនយោបាយបក្ស ដែលធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗរបស់បក្ស។ អង្គការប្រៀបប្រដូចទៅនឹងអង្គការសម្ងាត់ ដែលមានអំណាចកំពូលរបស់ខ្មែរក្រហម ហើយដែលអាចសម្រេចលើអាយុជីវិតរបស់ជនកម្ពុជាគ្រប់រូបនៅសម័យនោះ។ «បើអង្គការឱ្យរស់ គឺរស់ បើអង្គការឱ្យស្លាប់ គឺស្លាប់»។ អ្នកដែលមានសិទ្ធិសម្រេចនៅពេលនោះ គឺជាសមាជិកគណៈកម្មាធិការបក្សកុម្មុយនីស្តកម្ពុជា ដែលមានសមាជិកចំនួន១០នាក់ ដែលមានប៉ុល ពតជាលេខាបក្ស និងនួន ជាជាអនុលេខាបក្ស។

ខ-បញ្ហាវន្តឆ្វេងនិយម និងមនោគមវិជ្ជាខ្មែរក្រហម

ប្រភពនៃបដិវត្តន៍កម្ពុជា ៖ បដិវត្តន៍កុម្មុយនីស្តនៅកម្ពុជាកើតឡើងដោយសារក្រុមពីរសំខាន់ ៖ (១) ក្រុមទី១ គឺជាខ្មែរវៀតមិញបណ្តុះបណ្តាលដោយវៀតណាម ដែលដំបូងចូលក្នុងចលនាខ្មែរឥស្សរៈ ដើម្បីរំដោះប្រទេសកម្ពុជាពីការគ្រប់គ្រងបារាំង ដែលដឹកនាំដោយសឺង ង៉ុកមិញ និងទូ សាមុត និង (២) ក្រុមបញ្ហាវន្តឆ្វេងនិយម ដែលបណ្តុះ បណ្តាលនៅប្រទេសបារាំង ដែលដឹកនាំដោយសាឡុត ស ហៅប៉ុល ពត។ ការប្រយុទ្ធរវាងក្រុមទាំងពីរបានធ្វើឱ្យមានការបង្ក្រាបផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជាក្នុងរយៈពេលជិតកន្លះសតវត្សៗ

មូលដ្ឋានទ្រឹស្តីខ្មែរក្រហម ៖ នៅអំឡុងទសវត្សរ៍ទី៥០ ក្រុមនិស្សិតខ្មែរមួយក្រុមដែលសិក្សានៅប្រទេសបារាំងបានបង្កើត «សមាគមនិស្សិតខ្មែរ (A.E.K)» ដែលមានមតិឆ្វេងជ្រុល ហើយនៅក្នុងនោះពួកគេបានបង្កើតក្លឹបម៉ាក្សនិយម ក្នុងគោលដៅពិភាក្សាស្តីពីមាគ៌ានៃការអភិវឌ្ឍប្រទេស ដោយ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រកាន់យកលទ្ធិសង្គមនិយម។ នៅទសវត្សរ៍ឆ្នាំ៥០ និង៦០ លទ្ធិកុម្មុយនីស្ត និងសង្គមនិយមកំពុងតែពេញនិយមក្នុងចំណោមយុវជន និងនិស្សិត។ សមាជិកក្លឹបនេះមានសាឡុត ស ហៅប៉ុល ពត ដែលរៀនមិនចប់បាន សញ្ញាបត្រវិស្វកម តែចូលចិត្តអានស្នាដៃរបស់ម៉ាក្ស អៀង សារី ដែលរៀននៅវិទ្យាស្ថានសិក្សានយោបាយនៅប៉ារីស ហ៊ូ យន់ ដែលទទួលបានសញ្ញាប័ត្របណ្ឌិតសេដ្ឋកិច្ច មកពីសាកលវិទ្យាល័យប៉ារីសនៅឆ្នាំ១៩៥៥ ខៀវ សំផន ដែលទទួលបានសញ្ញាប័ត្របណ្ឌិតសេដ្ឋកិច្ចមកពីសាកលវិទ្យាល័យប៉ារីស និងសុន សេន ដែលរៀនខាងផ្នែកអប់រំ និងអក្សរសិល្ប៍ និងហ៊ូ នឹម ដែលទទួលបានសញ្ញាប័ត្របណ្ឌិតនីតិសាស្ត្រនៅសាកលវិទ្យាល័យភ្នំពេញ ហើយបានសរសេរសៀវភៅស្តីពីសហករណ៍។

ហ៊ូ យន់ចូលចិត្តមនោគមវិជ្ជាម៉ាក្សតាំងពីយុវភាពម្ល៉េះ។ នៅប៉ារីសក្នុងទសវត្សរ៍៥០ គាត់សេពគប់តែជាមួយពួកធ្វេងនិយម។ នៅក្នុងនិក្ខេបបទបណ្ឌិតរបស់គាត់ «កសិករកម្ពុជា និងគម្រោងទំនើបកម្ម (La paysannerie du cambodge et ses projets de moderisation)» លោកបានសិក្សាពីការរៀបចំសហករណ៍ ដែលអាចធ្វើទំនើបកម្មវិស័យកសិកម្មនៅកម្ពុជាបាន។ ហ៊ូ យន់ជាបញ្ញវន្តខ្មែរក្រហមម្នាក់ ដែលប្រកាន់ទ្រឹស្តីវ៉ឺរូស និងមានទំនាស់ក្នុងជួរខ្មែរក្រហមដូចគ្នា។ ចំណែកឯខៀវ សំផនបានការពារនិក្ខេបបទបណ្ឌិតនៅក្នុងឆ្នាំ១៩៥៩ ដែលមានចំណងជើងថា «សេដ្ឋកិច្ចកម្ពុជា និងបញ្ហាឧស្សាហូបនីយកម្ម (L'économie du Cambodge et ses problèmes d'industrialisation) »។

គំនិតសំខាន់ៗនៅក្នុងនិក្ខេបបទបណ្ឌិតទាំងពីរនេះបានក្លាយទៅជាប្រធានបទនៃគោលនយោបាយសេដ្ឋកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ហ៊ូ យន់ចាត់ទុកកសិករជាវណ្ណៈ ដែលដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងទំនើបកម្ម ដោយទាត់ចោលមតិដែលថា ទីក្រុងនិងឧស្សាហូបនីយកម្ម គឺជាចំណុចចាប់ផ្តើមនៃការអភិវឌ្ឍ។ ចំណែកឯខៀវ សំផន

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

វិញយល់ឃើញថា ការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហូបនីយកម្មត្រូវចាប់ផ្តើមពីគោលនយោបាយខ្លួនទីពឹងខ្លួន និងការបញ្ចប់ជាស្ថាពរនូវការពឹងផ្អែកលើសេដ្ឋកិច្ចនៃប្រទេសរីកចម្រើន។ ម្យ៉ាងវិញទៀត ខៀវ សំផនចាត់ទុកការងារទីក្រុង ដូចជាមន្ត្រីរាជការ ពាណិជ្ជករ និងធនាគារិក សុទ្ធសឹងតែអ្នកដែលបំពេញការងារដែលគ្មានផលិតភាព។ លោកចាត់ទុកសកម្មភាពទាំងនេះមិនបានផ្តល់តម្លៃបន្ថែមអ្វីទាំងអស់ដល់សង្គម ហើយគឺជាអ្នកដែលកេងប្រវ័ញ្ចលើសកម្មភាពផលិតកម្មដទៃទៀត ដូចជាកសិកម្ម សិប្បកម្ម និងឧស្សាហកម្មធុនតូចជាដើម និងគ្មានផលប្រយោជន៍អ្វីដល់សង្គមឡើយ។

គ-នយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ

ដោយកម្ពុជា គឺជាប្រទេសកសិកម្ម ការធ្វើសមូហភាវូបនីយកម្ម (Collectivization) កសិកម្មបានក្លាយជាគោលនយោបាយស្នូលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានគោលដៅកសាងសង្គមកុម្មុយនីស្តមួយដែលគ្មានវណ្ណៈ គ្មានកម្មសិទ្ធឯកជន គ្មានទីផ្សារគ្មានការជិះជាន់ គ្មានគម្លាតរវាងអ្នកមាននិងអ្នកក្រ និងប្រជាជនរស់នៅដោយស្មើភាពគ្នា ដោយអនុត្តនូវគោលការណ៍«កាត់ក្បាលតម្រូវតាមមួក»។

គោលនយោបាយមហាលោតផ្លោះមហាអស្ចារ្យ៖ តាមទ្រឹស្តីកុម្មុយនីស្តបដិវត្តន៍ត្រូវចែកជាពីដំណាក់កាល ៖ (១) នៅដំណាក់កាលដំបូង ពួកប៉ុល ពតបានអនុវត្តនូវបដិវត្តន៍ប្រជាជនប្រជាធិបតេយ្យ (១៩៧០-១៩៧៥) ក្នុងគោលដៅប្រមូលកម្លាំងទាំងអស់ឱ្យជួយគាំទ្របុព្វហេតុបដិវត្តន៍ ដើម្បីផ្តួលរំលំរបបចាស់។ នៅក្នុងដំណាក់កាលនេះ ពួកប៉ុល ពតពឹងផ្អែកលើសម្តេចសីហនុ និងកងទ័ពវៀតណាមខាងជើង ក្នុងការកៀរគរកម្លាំងមហាជន ដើម្បីផ្តួលរំលំរបបលន់ នល់ (២) នៅក្នុងដំណាក់កាលទីពីរ (១៩៧៥-១៩៧៦) ពួកខ្មែរក្រហមបានកសាងកម្លាំងស្នូល សម្រាប់ការធ្វើបដិវត្តន៍សង្គមនិយម ពោលគឺការដណ្តើមអំណាចដឹកនាំពីសម្តេចសីហនុ ដើម្បី

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បក្សគ្រប់គ្រង។

ការកសាងសង្គមថ្មីត្រូវឆ្លងកាត់ពីរដំណាក់កាល ៖ ដំណាក់កាលសង្គមនិយម និងដំណាក់កាលកុម្មុយនីស្តនិយម។ សម្រាប់ប្រទេសខ្លះមុននឹងទៅដល់សង្គមនិយម គេត្រូវឆ្លងកាត់ដំណាក់កាលអន្តរកាលឈានទៅសង្គមនិយមសិន។ មុននឹងទៅដល់កុម្មុយនីស្ត គេត្រូវឆ្លងកាត់ដំណាក់កាលសង្គមនិយមសិន (សមូហភាវូបនីយកម្ម ឧស្សាហូបនីយកម្ម កម្មសិទ្ធិសង្គមនិយម (រដ្ឋ សហករណ៍ និងគ្រួសារ) តែនៅមានទីផ្សារ ការប្រើប្រាស់រូបិយវត្ថុ និងនៅមានរដ្ឋ និងវណ្ណៈ)។ គ្មានប្រទេសណាបានទៅដល់ដំណាក់កាលកុម្មុយនីស្តនិយមឡើយ ក៏ប៉ុន្តែតាមទ្រឹស្តីកុម្មុយនីស្ត គឺជាដំណាក់កាលដែលគ្មានរដ្ឋ គ្មានវណ្ណៈ គ្មានទីផ្សារ គ្មានរូបិយវត្ថុ ហើយផលិតភាពកើនឡើងដល់កំពូល ដែលប្រជាជនធ្វើការតាមសមត្ថភាព តែទទួលផលតាមតម្រូវការ។ ពួកប៉ុល ពតបានជាក់ចេញនូវគោលដៅឈានទៅដល់ដំណាក់កាលកុម្មុយនីស្តតែម្តង ដោយមិនចាំបាច់ឆ្លងកាត់សង្គមនិយម ដោយអនុវត្តតាមទ្រឹស្តី«មហាលោតផ្លោះមហាអស្ចារ្យ»។

នយោបាយសេដ្ឋកិច្ចឯករាជ្យម្ចាស់ការ ៖ នយោបាយសេដ្ឋកិច្ចខ្មែរក្រហមមានពីរដំណាក់កាល ៖ (១) ដកសេដ្ឋកិច្ចខ្មែរពីប្រព័ន្ធសេដ្ឋកិច្ចពិភពលោក ដែលមានការជិះជាន់ និងលុបបំបាត់ការពឹងពាក់ (dependency) ទាំងស្រុងនៃសេដ្ឋកិច្ចកម្ពុជាទៅលើសេដ្ឋកិច្ចពិភពលោក ដោយអនុវត្តនយោបាយឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន និងការធ្វើសមូហភាវូបនីយកម្ម កសិកម្ម និងជាតូបនីយកម្មឧស្សាហកម្ម និងសេវាកម្ម។ ដំណាក់កាលនេះគេត្រូវបង្កើតមូលដ្ឋានបច្ចេកទេស សម្រាប់ការផ្លាស់ប្តូរសេដ្ឋកិច្ច និងសង្គមស៊ីជម្រៅ ហើយសមូហភាវូបនីយកម្មកសិកម្មបង្កើតនូវលទ្ធខណ្ឌអំណោយផល សម្រាប់ការកសាងមូលដ្ឋានឧស្សាហកម្មនៅកម្ពុជា (២) នៅដំណាក់កាលទី២ នៅពេលដែលសេដ្ឋកិច្ចខ្មែរសម្រេចបាននូវឯករាជ្យម្ចាស់ការ (Independent) ហើយ ទើបត្រូវបញ្ចូលសេដ្ឋកិច្ចកម្ពុជាទៅក្នុងប្រព័ន្ធសេដ្ឋ-

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កិច្ចពិភពលោកវិញ។

ការធ្វើសមូហភាវូបនីយកម្មកសិកម្មនៅក្នុងបរិបទកម្ពុជា គឺដើម្បីរំដោះប្រជាកសិករឱ្យរួចផុតពីបំណុល ដែលកសិករក្រក្រីជំពាក់ម្ចាស់ដី។ បំណុលត្រូវបានលោក ហ៊ូ យន់ចាត់ទុកថាជាឧបសគ្គមួយយ៉ាងសំខាន់ក្នុងការធ្វើទំនើបកម្មកសិកម្ម ហើយការធ្វើសមូហភាវូបនីយកម្មកសិកម្មជួយរំដោះកសិករក្រីក្រពីការជិះជាន់របស់ម្ចាស់ដី។

ឃ-បដិវត្តន៍សង្គមនិយម

បដិវត្តន៍កសិករ ៖ ពួកខ្មែរក្រហមបានជ្រើសរើសបដិវត្តន៍សង្គមនិយមជាមាគ៌ាដើម្បីអភិវឌ្ឍកម្ពុជា។ តាមទ្រឹស្តីបដិវត្តន៍ម៉ាក្សឡេនីន វណ្ណៈកម្មករគឺជាវណ្ណៈបដិវត្តន៍។ ក៏ប៉ុន្តែ ពួកខ្មែរក្រហមយល់ថាក្នុងបរិបទកម្ពុជា កសិករ គឺជាប្រភពនៃថាមពលមិនចេះរីងស្ងួត ហើយបដិវត្តន៍កម្ពុជាមិនអាចធ្វើទៅបាន ដោយគ្មានកសិករឡើយ ហើយគេត្រូវប្រើកសិករ ដើម្បីលើកកម្ពស់ និងរក្សាសាមគ្គីភាពនៃវណ្ណៈពលករ។ កសិករ គឺជាវណ្ណៈឈានមុខរបស់បដិវត្តន៍។ បដិវត្តន៍កម្ពុជា គឺជាបដិវត្តន៍កសិករ។ នេះគឺជាចំណុចគន្លឹះនៃភាពខុសគ្នារវាងលទ្ធិឡេនីននិយម និងលទ្ធិម៉ៅនិយម។ ឡេនីនចាត់ទុកកម្មករជាវណ្ណៈឈានមុខ ដោយសារកម្មករគ្មានកម្មសិទ្ធិ ពោលគឺជាវណ្ណៈអធន ហើយកសិករដែលមានកម្មសិទ្ធិលើដីធ្លី និងមធ្យោបាយផលិតកម្ម គឺជាវណ្ណៈអតិជនតូចតាច។ ដោយឡែក លទ្ធិម៉ៅនិយមចាត់ទុកកសិករជាវណ្ណៈអធនឈានមុខ ដែលជាវណ្ណៈក្រីក្រដូចកម្មករដែរ។

ការធ្វើសមូហភាវូបនីយកម្មកសិកម្ម ៖ ចាប់ពីឆ្នាំ១៩៧៣មក គណៈកម្មការកណ្តាលនៃបក្សកុម្មុយនីស្តកម្ពុជាបានចេញគោលនយោបាយស្តីពីការធ្វើសមូហភាវូបនីយកម្មកសិកម្មនៅក្នុងតំបន់រំដោះ ដែលខ្មែរក្រហមគ្រប់គ្រង។ ដីស្រែត្រូវយកទៅដាក់រួម ហើយគេបង្កើតសហករណ៍សម្រាប់បង្កបង្កើនផល ដោយយកមធ្យោបាយផលិតកម្មទាំងអស់មានគោ ក្របី

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

និងឧបករណ៍ផ្សេងៗទៅជាក់ជាទ្រព្យសម្បត្តិរួមរបស់សហករណ៍។

ការជីកប្រឡាយលើកទំនប់ ៖ ដើម្បីធ្វើស្រែឱ្យបានបីដងក្នុងមួយឆ្នាំ របបប៉ុល ពតបានប្រែក្លាយកម្ពុជាឱ្យទៅជាការដ្ឋានជីកប្រឡាយនិងលើកទំនប់មួយយ៉ាងធំ ពាសពេញផ្ទៃប្រទេស។ ប្រព័ន្ធស្រោចស្រពនេះត្រូវបានបង្កើតឡើងតាមការស្រមើស្រមៃ ដោយមិនប្រើប្រាស់នូវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឡើយ។ ជាលទ្ធផល គោលនយោបាយនេះមិនត្រឹមតែមិនអាចបង្កើតលក្ខណសម្បត្តិសម្រាប់ការបង្កបង្កើនផលៗដងក្នុងមួយឆ្នាំប៉ុណ្ណោះទេ ថែមទាំងនាំឱ្យប្រជាជនធ្វើការលើសកម្លាំង មានជំងឺតម្កាត់ និងបាត់បង់ជីវិតទៀតផង។

ការបំបាត់កម្មសិទ្ធិឯកជន ៖ របបប៉ុល ពតបានបំបាត់ចោលកម្មសិទ្ធិឯកជន ដោយរក្សាទុកតែកម្មសិទ្ធិសមូហភាពតែប៉ុណ្ណោះ។ ដើម្បីលុបបំបាត់កម្មសិទ្ធិឯកជន ដែលជាប្រភពនៃការជិះជាន់កេងប្រវ័ញ្ចលើមនុស្ស ខ្មែរក្រហមបានបង្កើតនូវផ្ទះបាយរួម ការទទួលទានអាហាររួមគ្នា ការធ្វើការរួមគ្នាជាសហករណ៍ និងក្រុមចល័តរបស់យុវជន និងការរៀបអាពាហ៍ពិពាហ៍រួមគ្នា។

ការលុបបំបាត់រូបិយប័ណ្ណនិងពាណិជ្ជកម្ម ៖ នៅដើមខែមេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានសម្រេចចិត្តលុបបំបាត់រូបិយប័ណ្ណជាតិ ដែលជាមធ្យោបាយធ្វើពាណិជ្ជកម្មដែលពួកគេចាត់ទុកថាជាប្រភពនៃការជិះជាន់។ ការលុបបំបាត់ពាណិជ្ជកម្ម គឺជាផ្នែកមួយនៃនយោបាយប្រមូលកសិផលលើស ជាពិសេសស្រូវយកមកប្រើប្រាស់ សម្រាប់ការនាំចេញ និងជាប្រភពនៃការធ្វើឧស្សាហូបនីយកម្ម។ នៅក្នុងឆ្នាំ១៩៧៨ គេឃើញរបបខ្មែរក្រហមបោះពុម្ពក្រដាសប្រាក់។ តែប្រហែលជាមានមតិផ្ទុយគ្នាក្នុងជួរមជ្ឈិមបក្ស ទើបក្រដាសប្រាក់ទាំងនេះមិនត្រូវបានដាក់ឱ្យចរាចរឡើយ។

ការគ្រប់គ្រងបែបស្វយ័ត ៖ ការគ្រប់គ្រងប្រទេសរបស់ពួកខ្មែរក្រហមបែងចែកកម្ពុជាជា៦តំបន់យោធា (បូព៌ា និរតី ឧត្តរ (កណ្តាល) ពាយ័ព្យ បស្ចិម

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

និងឡាំសាន) និងជា៣៦តំបន់។ ភូមិភាគនីមួយៗដឹកនាំដោយមេខ្មែរក្រហមសំខាន់ៗ ដែលទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយរួម ដែលដាក់ចេញដោយមជ្ឈិមបក្ស តែមានស្វ័យភាពក្នុងការគ្រប់គ្រង។ ជាក់ស្តែងក្នុងការអនុវត្តគោលនយោបាយ យើងឃើញថា ភូមិភាគខ្លះធូរ តែភូមិភាគខ្លះតឹង។ ភូមិភាគខ្លះសម្លាប់មនុស្ស ចំណែកភូមិភាគខ្លះគ្មានការសម្លាប់រង្គាលឡើយ។ ភូមិភាគដែលសាហាវព្រៃផ្សៃជាងគេគឺភូមិភាគនិរតី ដឹកនាំដោយតាម៉ុក។ ភូមិភាគពាយព្យនៅបាត់ដំបង និងភូមិភាគឧត្តរក៏មានការសម្លាប់រង្គាលដែរច្រើនជាងគេដែរ។ ភូមិភាគចែកចេញជាតំបន់ ហើយតំបន់ចែកចេញជាស្រុក ស្រុកចែកចេញជាឃុំ និងភូមិ។

ការអនុវត្តគោលនយោបាយឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន ៖ នៅក្នុងពេលធ្វើសង្គ្រាមឈូបអង្គភាពទ័ពនីមួយៗមានភាពម្ចាស់ការរៀងៗខ្លួន ក្នុងការធ្វើប្រតិបត្តិការសឹក តាមគោលការណ៍ម្ចាស់ការ។ អង្គភាពនីមួយៗទទួលបញ្ជារួម តែចាត់តាំងអនុវត្តតាមវិធីសាស្ត្ររបស់ខ្លួនក្នុងគោលដៅរក្សាការសម្ងាត់របស់បក្ស។ អង្គភាពនីមួយៗស្គាល់ច្បាស់តែសមាសភាពរបស់អង្គភាពខ្លួនឯង ហើយពឹងពាក់លើកម្លាំងរបស់ខ្លួនក្នុងការរកស្បៀងចិញ្ចឹមកងទ័ព។ ប្រសិនបើខ្មាំងចាប់សមាជិកណាម្នាក់សួរចម្ងើយ គេអាចដឹងពីអង្គភាពនោះតែប៉ុណ្ណោះ។ ដូច្នេះ គោលការណ៍ឯករាជ្យម្ចាស់ការជួយឱ្យពួកខ្មែរក្រហមអាចរក្សាការសម្ងាត់បក្ស និងគ្រប់គ្រងកងទ័ពសម្រាប់សង្គ្រាមឈូបប្រកបដោយប្រសិទ្ធភាព។ គោលការណ៍នេះត្រូវបានបន្តយកមកប្រើប្រាស់ក្នុងការគ្រប់គ្រងប្រទេសក្រោយរំដោះ។ ភូមិ ឃុំ ស្រុក តំបន់ និងភូមិភាគនីមួយៗត្រូវមានឯករាជ្យម្ចាស់ការរៀងៗខ្លួន។ ស្រូវដែលនៅសេសសល់ត្រូវប្រមូលយកមកទុកនៅមជ្ឈិម សម្រាប់នាំចេញទៅបរទេស។ ការអនុវត្តគោលការណ៍នេះមិនទាមទារឱ្យមានពាណិជ្ជកម្មក្នុងប្រទេសឡើយ។

ការគ្រប់គ្រងតាមបែបផ្តាច់ការវណ្ណៈអធន ៖ នៅក្នុងដំណាក់កាលដំបូង នៅពេលដែលបដិវត្តន៍មិនទាន់គ្រប់គ្រងសភាពការណ៍ក្នុងប្រទេស

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បានល្អ អ្នកបដិវត្តន៍បានដាក់ចេញនូវគោលនយោបាយ«ផ្តាច់ការវណ្ណៈអធន»។ ពោលគឺការគ្រប់គ្រងតាមបែបផ្តាច់ការ ដែលមេដឹកនាំបក្ស ជាពិសេសការិយាល័យនយោបាយជាអ្នកសម្រេចលើកិច្ចការទាំងអស់ក្នុងបក្ស។ ផ្តាច់ការវណ្ណៈអធននេះក៏មានការប្រើប្រាស់នូវអំពើហិង្សា ការកម្ចាចោលកម្ទាំងសត្រូវ ដើម្បីពង្រឹងអំណាចបដិវត្តន៍។ បន្ទាប់មកនៅពេលដែលបក្សអាចគ្រប់គ្រងសភាពការណ៍បដិវត្តន៍បានល្អប្រសើរហើយ ទើបគេចាប់ផ្តើមអនុវត្តគោលនយោបាយ«ប្រជាធិបតេយ្យប្រមូលផ្តុំ» ពោលគឺការដឹកនាំត្រូវតាមមតិរបស់អង្គភាពបក្ស ដែលជ្រើសរើសតំណាងមានសិទ្ធិក្នុងការសម្រេចចិត្តលើគោលនយោបាយនៅតាមរចនាសម្ព័ន្ធពីក្រោមឡើងលើរបស់បក្ស។

*ការបង្កើតមនុស្សថ្មី ការទិតៀនទិដ្ឋស្ថីយទិតៀន ៖ គោលដៅសំខាន់*របស់បដិវត្តន៍ គឺការបង្កើតមនុស្សថ្មីបដិវត្តន៍ ដែលនឹងក្លាយទៅជាសសរទ្រូងសម្រាប់បដិវត្តន៍។ ការបង្កើតមនុស្សថ្មីធ្វើឡើងតាមពីរវិធី ៖ (១) ការទិតៀនទិដ្ឋស្ថីយទិតៀន ដើម្បីកែលម្អ និងកែប្រែមនុស្សចាស់ឱ្យក្លាយទៅជាមនុស្សថ្មីរបស់បដិវត្តន៍ និង(២) ការអប់រំក្មេង ដោយផ្តាច់ពួកគេចេញពីឥទ្ធិពលអាក្រក់របស់មាតាបិតា និងក្រុមគ្រួសារ ហើយដាក់ពួកគេឱ្យនៅជាប់ដោយឡែក រួចអប់រំពួកគេតាមមាគ៌ារបស់បក្ស និងឱ្យស្រឡាញ់បដិវត្តន៍ក្នុងគោលដៅប្រែក្លាយពួកគេឱ្យទៅជាកម្ទាំងពិតរបស់បដិវត្តន៍។ ពួកប៉ុលពតជឿលើភាពស្មោះត្រង់របស់ក្មេង ដែលមានភាពស្មោះត្រង់បរិសុទ្ធចំពោះបក្ស និងហ៊ានបកអាក្រាតទង្វើរបស់មនុស្សចាស់ ដែលអនុវត្តខុសពីមាគ៌ាបក្ស។

២-ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្ស?

*របបកម្ពុជាប្រជាធិបតេយ្យបានសម្លាប់ជនជាតិខ្មែរអស់ប្រមាណជា*ជិត២លាននាក់ ដោយសារតែ ៖ (១) ការអនុវត្តនយោបាយប្រល័យពូជ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាម (ការកាប់សម្លាប់សង្គសីកនីដ៏របបលន់ នល់ ការស្លប់ខ្ពើមប្រជាជនទីក្រុង) (២) ការអនុវត្តបដិវត្តន៍វប្បធម៌ (ការជន្ទៀសប្រជាជនទៅរស់នៅជនបទ ការតស៊ូវណ្ណៈ និងការបង្កើតគុក និងមណ្ឌលកែប្រែ) (៣) ការអនុវត្តគោលនយោបាយបន្សុទ្ធផ្ទៃក្នុងបក្ស និង(៤) ការអត់ឃ្លាន និងជំងឺតម្កាត់ផ្សេងៗ។

ក-ការអនុវត្តនយោបាយប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាម

មនោគមន៍វិជ្ជាខ្មែរក្រហម គឺជាការច្របាច់បញ្ចូលគ្នារវាងលទ្ធិជាតិនិយមជ្រុលរបស់ប៉ុល ពត និងលទ្ធិកុម្មុយនីស្តម៉ៅនិយម។ មនោគមវិជ្ជានេះនាំឱ្យមានការសងសឹក ការប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម បដិវត្តន៍វប្បធម៌ និងការធ្វើវិសុទ្ធកម្មផ្ទៃក្នុងបក្ស។

នយោបាយសងសឹកជាមួយកងទ័ពលន់ នល់ ៖ នៅក្នុងរបបសង្គមរាស្ត្រនិយម ពួកបដិវត្តន៍ខ្មែរត្រូវរងការគៀបសង្កត់ ការធ្វើបាប ធ្វើទុក្ខបុកម្នេញ និងត្រូវប៉ូលិសចាប់យកទៅធ្វើទារុណកម្មនៅក្នុងពន្ធនាគារ។ ម៉្យាងវិញទៀត ក្នុងសម័យសង្គ្រាម កងទ័ពអាកាសអាមេរិកបានទម្លាក់គ្រាប់បែកលើទីតាំងខ្មែរក្រហម និងធ្វើឱ្យពួកបដិវត្តន៍របួស និងស្លាប់ជាច្រើនឥតគណនា។ អំពើទាំងអស់នេះបង្កើតនូវកំហឹងបដិវត្តន៍ ដែលជំរុញឱ្យពួកគេធ្វើការលះបង់ និងហ៊ានពលីជីវិតដើម្បីបដិវត្តន៍។ នៅពេលដែលពួកខ្មែរក្រហមឡើងកាន់អំណាច ពួកគេចាប់ផ្តើមសងសឹក ចំពោះរាល់ទង្វើទាំងឡាយនោះ ដោយចាប់ផ្តើមសម្លាប់ដោយឥតពីរោះមុខ ប្រជាជនទីក្រុងដែលរស់នៅក្រោមការគ្រប់គ្រងរបស់លន់ នល់។ អំពើនេះ យើងអាចចាត់ទុកថា ជាអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

នយោបាយប្រល័យពូជសាសន៍ ៖ ខ្មែរក្រហមចាត់ទុកជនជាតិភាគតិច ដែលរស់នៅតំបន់ព្រំសានថា ជាជនជាតិដែលស្មោះត្រង់ខ្លាំងនឹងបដិវត្តន៍។ ពួកគេអនុវត្តនយោបាយស្នេហាជាតិនិយមជ្រុល (Chauvenism)

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដែលមានគោលដៅធ្វើការបន្សុទ្ធជាតិសាសន៍ (Ethnic cleansing) តាមរយៈ ការសម្លាប់ជនជាតិវៀតណាម និងជនជាតិចាម ដែលច្បាប់អន្តរជាតិចាត់ទុកថា ជាអំពើប្រល័យពូជសាសន៍។

នយោបាយវាតទីនិយមដណ្តើមទឹកដី ៖ បន្ទាប់ពីបញ្ចប់សង្គ្រាមក្នុងស្រុកមក ពួកប៉ុល ពតបានចាប់ផ្តើមពង្រឹងការគ្រប់គ្រងលើដែនកោះ និងព្រំដែនសមុទ្រ និងចាប់ផ្តើមពង្រីកដណ្តើមយកទឹកដី ដែលបានបាត់បង់នៅសម័យបារាំង ដោយធ្វើការវាយលុកវៀតណាម ដើម្បីដណ្តើមដីខ្មែរវិញ។ គោលនយោបាយនេះត្រូវបានអនុវត្ត ដោយមិនបានគិតគូរពីច្បាប់អន្តរជាតិ ហើយនាំមកនូវសង្គ្រាមជាមួយវៀតណាម ការកាប់សម្លាប់ប្រជាជនវៀតណាមសូតត្រង់ និងការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។

ខ-បដិវត្តន៍វប្បធម៌ និងការតស៊ូវណ្ណៈ

ការបង្កើតវប្បធម៌ថ្មី ៖ ពួកប៉ុល ពតយល់ថា វប្បធម៌បដិវត្តន៍ត្រូវឈរលើមូលដ្ឋានវប្បធម៌ថ្មី ដែលខុសពីវប្បធម៌ចាស់ប្រពៃណីរិយា។ បដិវត្តន៍វប្បធម៌ គឺជាការលប់បំបាត់ឱ្យអស់នូវកាកសំណល់សក្តិភូមិ ដូចជាចម្រៀង របាំ សិល្បៈនៃសង្គមចាស់ដែលបម្រើឱ្យវណ្ណៈជិះជាន់ និងការបង្កើតឡើងនូវចម្រៀង របាំ និងសិល្បៈបែបថ្មី ដើម្បីជារបស់វណ្ណៈអធន និងដើម្បីបម្រើវណ្ណៈអធន។

ការហាត់ពត់លត់ដំ ៖ បដិវត្តន៍វប្បធម៌ គឺជាការបញ្ជូនបញ្ជាវន្ត និងមន្ត្រីរាជការសក្តិភូមិ ដែលពួកគេចាត់ទុកថា ជាវណ្ណៈអភិជនតូចតាចឱ្យទៅហាត់ពត់លុតដំ និងរៀនសូត្រពីទីជនបទ និងកសិករ ដើម្បីឱ្យពួកគេយល់ច្បាស់ពីជំហរបដិវត្តន៍ ហើយធ្វើការងារបម្រើបដិវត្តន៍។

ការតស៊ូវណ្ណៈ ៖ ដោយឡែកការតស៊ូវណ្ណៈ គឺការកែប្រែសង្គមខ្មែរដែលមានវណ្ណៈកសិករ កម្មករ នាយទុន សក្តិភូមិ (អ្នកគាំទ្ររាជានិយម) ឱ្យក្លាយជាសង្គមបដិវត្តន៍ ដែលវណ្ណៈកសិកររដើរតួឈានមុខ ចំណែកវណ្ណៈ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កម្មករវិញមានតិចតួចប៉ុណ្ណោះនៅកម្ពុជា (នៅសហភាពសូវៀត វណ្ណៈកម្មករ គឺជាវណ្ណៈឈានមុខ)។ ជនបដិវត្តន៍មានប្រភពមកពីវណ្ណៈអជ្ញធរ ពោលគឺមានដើមកំណើតចេញពីគ្រួសារក្រីក្រតោកយ៉ាក គ្មានការអប់រំ និងមិនពុករលួយដោយវប្បធម៌សក្តិភូមិ។ នៅក្នុងរបបប៉ុល ពត ឋានៈក្នុងសង្គមបានក្រឡាប់ចាក់ ដូចសុភាសិតខ្មែរដែលពោលថា «ឃ្លោកលិច អំបែងអណ្តែង» ពោលគឺអ្នកមិនចេះជាអ្នកគ្រប់គ្រងអ្នកចេះ។

ការជន្លៀសប្រជាជនចេញពីភ្នំពេញ ៖ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ កងទ័ពខ្មែរក្រហមរាប់សែននាក់បានសម្រុកចូលទីក្រុងភ្នំពេញ តាមគ្រប់មុខព្រួញទាំងអស់។ ទាហានដែលដើរជាជួរៗបានស្រែកតាមឧឃោសនស័ព្ទ សុំឱ្យប្រជាជនទីក្រុងភ្នំពេញចាកចេញពីលំនៅដ្ឋានជាបណ្តោះអាសន្ន ចំនួនបីថ្ងៃ ឱ្យទៅរស់នៅតាមតំបន់ជាយក្រុង ដោយយកលេសថា ខ្លាចអាមេរិកទម្លាក់គ្រាប់បែក។ សន្និបាតគណបក្ស ដែលបានធ្វើឡើងពីរខែមុនខ្មែរក្រហមសម្រុកចូលកាន់កាប់ទីក្រុងភ្នំពេញ បានសម្រេចជន្លៀសប្រជាជនចេញពីទីក្រុង។ ហ៊ូ យន់ ដែលប្រធាននីតិវិធានការនេះត្រូវអង្គការយកទៅសម្លាប់ចោលក្នុងឆ្នាំ១៩៧៥។ តាមពិតទៅ មូលហេតុដែលខ្មែរក្រហមជន្លៀសប្រជាជនចេញពីទីក្រុងឱ្យទៅរស់នៅជនបទ គឺជាផ្នែកមួយនៃបដិវត្តន៍វប្បធម៌ ដើម្បីបង្ខំឱ្យប្រជាជនទីក្រុងដែលពួកគេយល់ថា ជាខ្មាំងដែលគាំទ្ររបបលន់ នល់ឱ្យទៅរៀនសូត្រហាត់ពត់លត់ដំ ដើម្បីប្រែក្លាយពួកគេពីវណ្ណៈអភិជនឱ្យទៅជាវណ្ណៈអជ្ញធរ ជាយស្រួលក្នុងការបែងចែកខ្មាំងនិងមិត្ត និងជួយដល់បដិវត្តន៍ក្នុងការគ្រប់គ្រង និងកាត់បន្ថយសកម្មភាពប្រឆាំងបដិវត្តន៍។

ការបែងចែកប្រជាជនជាប្រជាជនថ្មីនិងប្រជាជនចាស់ ៖ ប្រជាជនទីក្រុង ដែលរស់នៅក្រោមការគ្រប់គ្រងនៃរបបលន់ នល់ត្រូវបានពួកខ្មែរក្រហមចាត់ទុកថា ជាប្រជាជនថ្មី ដែលត្រូវបញ្ជូនឱ្យទៅរស់នៅក្រោមការឃ្លាំមើលពីប្រជាជនចាស់ ដែលជាប្រជាជនរស់នៅក្នុងតំបន់រំដោះ។ នៅ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពេលដំបូងប្រជាជនថ្មីភាគច្រើន ដែលរស់នៅក្នុងភូមិចាស់ ត្រូវសង់លំនៅដ្ឋានក្រោមសំយាបនៃផ្ទះរបស់ប្រជាជនចាស់ ដើម្បីសម្រួលដល់ការឃ្លាំមើលជំហរ។ អ្នកដែលពួកគេចាត់ទុកថាជាប្រតិកិរិយា ត្រូវបញ្ជូនទៅរៀនសូត្រ ពោលគឺត្រូវគេយកទៅឃុំឃាំងក្នុងពន្ធនាគារតាមស្រុក ឬមួយយកទៅសម្លាប់ចោល។ ប្រជាជនថ្មីទទួលនូវរបបម្ហូបអាហារតិចជាងប្រជាជនចាស់។ បន្ទាប់ពីអាជ្ញាធរជឿជាក់ពីជំហររបស់ប្រជាជនថ្មីចំពោះបដិវត្តន៍ហើយ ទើបពួកគេអាចសង់លំនៅដ្ឋានរស់នៅជាប់ដោយឡែកបាន។

ការបង្កើតសង្គមគ្មានវណ្ណៈ ៖ គោលដៅនៃសង្គមកុម្មុយនីស្ត គឺការបង្កើតសង្គមមួយ ដែលស្មើភាពគ្នាទាំងស្រុង គ្មានអ្នកមាន គ្មានអ្នកក្រ គ្មានការជិះជាន់កម្លាំងពលកម្ម និងគ្មានវណ្ណៈ ដែលពលរដ្ឋទាំងអស់ធ្វើការតាមសមត្ថភាព និងទទួលផលតាមសេចក្តីត្រូវការ។ ចំណុចសំខាន់នៃសង្គមនេះ គឺការបំបាត់ចោលនូវស្ថាប័នរដ្ឋ ដោយសារប្រជាពលរដ្ឋមានការយល់ដឹងអាចគ្រប់គ្រងខ្លួន ដោយខ្លួនឯងបាន។ លទ្ធិកុម្មុយនីស្តចាត់ទុករដ្ឋជាឧបករណ៍ផ្តាច់ការរបស់វណ្ណៈដឹកនាំ។ ក្នុងសង្គមសង្គមនិយម កម្មករគឺជាវណ្ណៈដឹកនាំ ដោយសារកម្មករខុសពីកសិករ ត្រង់ថាកម្មករគឺជាវណ្ណៈអធន ជាប់ខាត ធ្វើការដើម្បីយកប្រាក់ខែ ដែលជាថ្លៃឈ្នួលលក់ពលកម្ម។ នៅពេលដែលពលរដ្ឋក្នុងសង្គមស្មើភាពគ្នា នោះលែងមានវណ្ណៈ ហើយក៏លែងមានភាពចាំបាច់ក្នុងការមានស្ថាប័នរដ្ឋសម្រាប់គ្រប់គ្រងផងដែរ។

គ-ការអនុវត្តនយោបាយវិសុទ្ធកម្មផ្ទៃក្នុងបក្ស

គោលនយោបាយកម្ទេចចោលខ្មែរហាណូយ ៖ ប៉ុល ពតមានការសង្ស័យពីចំណងរបស់ពួកបដិវត្តន៍ខ្មែរ ដែលបណ្តុះបណ្តាលដោយវៀតណាមចាប់តាំពីឆ្នាំ១៩៥៤ ដែលវៀតណាមបានជ្រើសរើស ដើម្បីចូលរួមក្នុងចលនាបដិវត្តន៍ និងធ្វើការតស៊ូសិក្សានយោបាយនៅសាលាមិត្តភាពកម្ពុជា-វៀតណាមនៅទីក្រុងហាណូយ។ វៀតណាមយល់ថា បដិវត្តន៍កម្ពុជា

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មានភាពទន់ខ្សោយ ដូច្នេះវៀតណាមត្រូវជួយពង្រឹងកម្មាភិបាលបដិវត្តន៍តាមរយៈការបណ្តុះបណ្តាលនយោបាយឱ្យយល់ពីលទ្ធិម៉ាក្សឡេនីន។ អ្នកបដិវត្តន៍ជាច្រើន ដែលទទួលការបណ្តុះបណ្តាលនៅវៀតណាមត្រូវបានគេបញ្ជូនមកកាន់កម្ពុជានៅដើមទសវត្សរ៍ទី៧០។ ក្នុងគោលដៅធ្វើឱ្យបក្សកុម្មុយនីស្តកម្ពុជាសុទ្ធល្អ គ្មានបក្សពួកខាងក្នុង ប៉ុល ពតចាប់ផ្តើមអនុវត្តនយោបាយធ្វើវិសុទ្ធកម្មបក្ស ដោយដកអាវុធពីពួកនោះ និងកម្ទេចចោលនូវកម្លាំងដែលស្មោះត្រង់នឹងវៀតណាម។ នៅចុងឆ្នាំ១៩៧១ ពួកប៉ុល ពតចាប់ផ្តើមដកអ្នកបដិវត្តន៍ខ្មែរមកពីហាណូយ ផ្ទេរពួកគេទៅកាន់កន្លែងដែលមិនសំខាន់ និងយកទៅសម្លាប់ចោលជាបណ្តើរៗ។ ចាប់ពីឆ្នាំ១៩៧៦ ប៉ុល ពតចាប់ផ្តើមសម្រិតសម្រាំងកម្មាភិបាលយោធា ដោយចោសសម្គាតផ្ទៃក្នុងបក្ស និងបានអនុវត្តនយោបាយវិសុទ្ធកម្មផ្ទៃក្នុងបក្ស ដោយយកអ្នកដែលគេសង្ស័យយកទៅជាក់គុក ឬយកទៅសម្លាប់ចោល ដោយចោទថាជាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ជាគិញសម្លាត់វៀតណាម ជាសេអ៊ីអាអាមេរិក ឬជាកាហ្សេប៊ើរបស់សូវៀត។

នយោបាយជាតិនិយមជ្រុល និងសង្គ្រាមតាមព្រំដែនជាមួយវៀតណាម ៖ នៅអំឡុងពេលធ្វើសង្គ្រាមជាមួយរបបលន់ នល់ ទោះបីជាកងទ័ពវៀតណាមខាងជើងបានជួយបណ្តុះបណ្តាលកងទ័ព និងកម្មាភិបាលខ្មែរក្រហមក្តី ក៏មេដឹកនាំខ្មែរក្រហមមិនទទួលយកស្មារតីអន្តរជាតិនិយមវណ្ណៈអធន ហើយនៅតែប្រកាន់យកនូវស្មារតីជាតិនិយមជ្រុល ដោយជាស់តឿនកម្មាភិបាលរបស់ខ្លួនឱ្យមានការប្រុងប្រយ័ត្នទៅនឹងគោលដៅរបស់វៀតណាមចំពោះកម្ពុជា។ ម្យ៉ាងវិញទៀត ពួកខ្មែរក្រហមចង់ស្ថិតនៅក្នុងភាពឯករាជ្យ មិនចំណុះឱ្យវៀតណាម។ បន្ទាប់បានកាន់កាប់ទឹកដីកម្ពុជាទាំងស្រុងមក ខ្មែរក្រហមមានមហិច្ឆតាដណ្តើមពីវៀតណាម ដើម្បីកាន់កាប់ដែនកោះមួយចំនួន និងចាប់ផ្តើមធ្វើសង្គ្រាមវាយយកខេត្តវៀតណាមតាមព្រំដែនចាប់ពីឆ្នាំ១៩៧៧ ហើយបានកាប់សម្លាប់ប្រជាជនសូតត្រង់អស់

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាច្រើនៗ ប៉ុល ពតកាន់តែមិនទុកចិត្តកងពលភាគខាងកើតទន្ទេមេគង្គ ដែលធ្លាប់ត្រូវបានទំនុកបម្រុង និងបណ្តុះបណ្តាលដោយកងទ័ពវៀតណាមខាងជើង។ ចលនាបោសសម្អាតផ្ទៃក្នុងបានចាប់ផ្តើមឡើង ក្នុងជួរកម្មាភិបាលបក្ស និងនៅតាមជួរកងទ័ពៗ

៣-មូលហេតុអ្វីបានជារបបកម្ពុជាប្រជាធិបតេយ្យដួលរលំ?

របបកម្ពុជាប្រជាធិបតេយ្យដួលរលំ ដោយសារកត្តាសត្យានុម័ត និងអត្តនោម័តមួយចំនួន ថ្វីត្បិតតែរបបនេះមានកងទ័ពដល់ទៅ២៣កងពលធំ ដែលមានកម្លាំងទ័ពដល់ទៅ១៨០ពាន់នាក់ ដោយសារតែកត្តាដូចតទៅ៖ (១) ការងើបឡើងប្រឆាំងពីសំណាក់ប្រជាជនកម្ពុជាទូទាំងប្រទេស (២) ការគ្រប់គ្រងតាមបែបព្រៃផ្សៃ ការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងអំពើប្រល័យពូជសាសន៍ (៣) ការបង្កើតសង្គមមួយ ដែលដំណើរការដោយឈរលើមូលដ្ឋាននៃការភ័យខ្លាច មិនទុកចិត្តគ្នា និងគ្មានមូលធនសង្គម (៤) ការធ្លាក់ចុះនៃផលិតភាពការងារ ដោយសារតែការអនុវត្តគោលនយោបាយកម្ទេចចោលអ្នកចេះដឹង ការប្រើប្រាស់តែកម្លាំងពលកម្មមនុស្ស និងការមិនប្រើប្រាស់បច្ចេកវិទ្យានិងគ្រឿងចក្រក្នុងចង្វាក់ផលិតកម្ម និង (៥) អន្តរាគមន៍ខាងផ្នែកយោធា ដោយមានការចូលរួមពីកងទ័ពស្ម័គ្រចិត្តវៀតណាម និងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។

ក-ការងើបឡើងប្រឆាំងពីសំណាក់ប្រជាជនកម្ពុជាទូទាំងប្រទេស

ការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ រួមផ្សំនឹងការបង្ខំប្រជាជនឱ្យធ្វើការលើសកម្លាំង ការគាបសង្កត់ប្រជាជនឱ្យភ័យខ្លាច ការបែងចែកប្រជាជនជាច្រើនប្រភេទ ការរើសអើងសង្គម ការបង្ក្រាបផ្ទៃក្នុងបានបង្កើតនូវអយុត្តិធម៌សង្គម ការរើបម្រះ ការបះបោរ និងការងើបឈរក្រោកឡើងប្រឆាំងនឹងរបបប៉ុល ពតៗ ការងើបប្រឆាំងនេះមាន

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ពីប្រភេទ ៖ បែបសកម្ម ដោយរត់ចូលព្រៃ និងរត់ទៅរកវៀតណាមឱ្យជួយរំដោះ និងបែបអសកម្ម ដោយមិនជួយការពាររបបព្រៃផ្សៃនេះ។

ខ-ការគ្រប់គ្រងតាមបែបព្រៃផ្សៃ

ការគ្រប់គ្រងដោយឈរលើមូលដ្ឋាននៃការគំរាមកំហែង ការគាបសង្កត់ ការបង្ខិតបង្ខំ អំពើហិង្សា និងការកាប់សម្លាប់បានធ្វើឱ្យសង្គមខ្មែរធ្លាក់ដល់បាត កម្រិតសូន្យ។ កម្ពុជាបាត់បង់អស់នូវធនធានមនុស្សប្រកបដោយគុណភាព។ ប្រជាជនជិតពីរលាននាក់បាត់បង់ជីវិត ដោយសារការកាប់សម្លាប់ ការអត់ឃ្លាន ជំងឺតម្កាត់ និងការធ្វើការហួសកម្លាំង។ គ្រួប្រមាណជា៨០%បានបាត់បង់ជីវិត។ សង្គមខ្មែរបាត់បង់អស់នូវមូលធនសង្គម គឺការជឿទុកចិត្តគ្នា ការជួយយកអាស្រ័យគ្នា និងចេះឈឺធ្លាលគ្នា (ដោយសារខ្មែរក្រហមប្រកាន់យកគោលការណ៍«ក្បាលនរណា សក់អ្នកនោះ»)។ សង្គមបែបនេះមិនអាចធានាបាននូវប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការបង្កបង្កើនផលបានឡើយ។

គ-ការបង្កើតសង្គមគ្មានមូលធនសង្គម

សង្គមដែលគ្មានវណ្ណៈមានតែនៅក្នុងការស្រមើស្រមៃរបស់ពួកទ្រឹស្តីនិយម និងគម្ពីរនិយមតែប៉ុណ្ណោះ។ សង្គមខ្មែរបានបាត់អស់នូវព្រលឹងជាតិ។ បដិវត្តន៍បានបង្កើតឡើងនូវសង្គមទទេ។ បដិវត្តន៍កម្ពុជា គឺជាបដិវត្តន៍ទទេដែលគ្មានមូលដ្ឋានទ្រឹស្តីវិទ្យាសាស្ត្រពិតប្រាកដ។ បដិវត្តន៍កម្ពុជា គឺជាការធ្វើពិសោធយ៉ាងព្រៃផ្សៃ និងជាសោកនាដកម្មដ៏ល្ងីងជូរចត់ ដែលបន្សល់ទុកនូវការបែកបាក់សង្គមជាតិ ការបាត់ព្រលឹងជាតិ និងការហែកហួរជាតិឯងគ្មានទីបញ្ចប់។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឃ-ប្រសិទ្ធភាពសេដ្ឋកិច្ចធ្លាក់ចុះ

ការអនុវត្តគោលនយោបាយសេដ្ឋកិច្ចឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន មហាលោតផ្លោះមហាអស្ចារ្យ ការសម្លាប់អ្នកចេះ ការប្រើកម្លាំងពលកម្ម មនុស្សសុទ្ធសាធក្នុងវិស័យ កសិកម្ម ការធ្វើឧស្សាហូបនីយកម្មដោយមិនប្រើបច្ចេកទេស និងបច្ចេកវិទ្យា (មិនប្រើអ្នកចេះដឹង) និងការលុបបំបាត់នូវសេវាកម្ម (គ្មានពាណិជ្ជកម្ម គ្មានប្រាក់កាស) ការសម្លាប់ប្រជាជនខ្លួនឯងជិត៣០%នៃប្រជាជនសរុប បានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាធ្លាក់ចុះយ៉ាងគំហុក។ បដិវត្តន៍កម្ពុជាបានដាក់ចេញនូវគោលដៅកសាងសង្គមកម្ពុជាដែលសម្បូរណ៍រុងរឿងតាមរយៈការបង្កើនផលិតភាពពលកម្ម ការលុបបំបាត់វិសមភាព អំពើជិះជាន់ និងឧបសគ្គនានាដែលរារាំងការអភិវឌ្ឍ និងទំនើបកម្មនៃកម្ពុជា។ តែផ្ទុយទៅវិញ ការអនុវត្តរបស់ខ្មែរក្រហមបានធ្វើឱ្យកម្ពុជាដើរថយក្រោយជិតមួយសតវត្ស។ សមិទ្ធផលរបស់កម្ពុជា និងការងើបឡើងវិញរបស់ជាតិខ្មែរ ដែលចាប់ផ្តើមឡើងវិញនៅក្នុងរជ្ជកាលព្រះបាទអង្គដួងបានរលាយបាត់អស់ទាំងស្រុង នៅក្នុងសម័យកាលអន្ធកាលនៃរបបប៉ុល ពត។

វិស័យអប់រំនៅកម្ពុជាត្រូវបានកម្ទេចទាំងស្រុង ដោយសារសង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍ជាងបីទសវត្សរ៍។ គ្រឹះស្ថានសិក្សាទាំងអស់ត្រូវបិទទ្វារទាំងស្រុងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ហើយការរៀន និងការបង្រៀនត្រូវបានហាមឃាត់។ ចាប់ពីឆ្នាំ១៩៧៥ ដល់១៩៧៩ ពួកខ្មែរក្រហមបានបំផ្ទុះបំផ្លាញអគារសិក្សា បណ្ណាល័យ និងសម្ភារដែលបម្រើដល់ការសិក្សារៀនសូត្រអស់ប្រមាណជាជាង៩០%។ គ្រឹះស្ថានឧត្តមសិក្សាមួយចំនួនក្នុងចំណោម៩នៅក្នុងប្រទេសត្រូវបានបំផ្លាញខ្ទេចខ្ទី ហើយគ្រឹះស្ថានពីរទៀតក៏ត្រូវខូចខាតយ៉ាងធ្ងន់ធ្ងរ។ បញ្ហាវិន្តបានក្លាយជាគោលដៅនៃបដិវត្តន៍វប្បធម៌របស់ពួកខ្មែរក្រហម។ គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាចំនួន៧៥% សាស្ត្រាចារ្យនៅសាកលវិទ្យាល័យ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំនួន៩១% សិស្សរៀននៅបឋមសិក្សា និងមធ្យមសិក្សាចំនួន៦៧% និងនិស្សិតសាកលវិទ្យាល័យចំនួន៩៦% ត្រូវបានសម្លាប់ ឬស្លាប់ ដោយអត់អាហារ (ក្រសួងអប់រំ ១៩៩០ UNESCO 1991)។ ពួកគេបានប្រែក្លាយសាលារៀន និងសាកលវិទ្យាល័យឱ្យទៅជាមន្ទីរឃុំឃាំង ឬក៏ប្រើសម្រាប់ជាជង្រុកស្រូវទៅវិញ។ សៀវភៅសិក្សា និងឯកសារផ្សេងៗត្រូវបានដុតបំផ្លាញ និងកម្ទេចចោល។ របបកម្ពុជាប្រជាធិបតេយ្យបានធ្វើឱ្យប្រព័ន្ធអប់រំនៅកម្ពុជាថ្លាក់ដល់កម្រិតសូន្យ។ មានតែបញ្ជីវន្តប្រមាណជា១៥%តែប៉ុណ្ណោះដែលនៅរស់។ អ្នកចេះដឹងមួយចំនួនធំទៀតក៏សម្រេចចិត្តភៀសខ្លួនទៅនៅឯបរទេស។ យើងអាចនិយាយបានថា មូលដ្ឋានគ្រឹះនៃស្ថាប័ន និងធនធានមនុស្សរបស់កម្ពុជា ដែលបង្កើតឡើងតាមរយៈកំណែទម្រង់របស់ព្រះបាទអង្គឌួងចាប់តាំងពីឆ្នាំ១៨៦៨ នៅពេលដែលកម្ពុជាបានស្គាល់សុខសន្តិភាពបរិបូណ៌ បានត្រូវបំផ្ទិចបំផ្លាញអស់ដល់ឫសគល់ ចាប់តាំងពីឆ្នាំ១៩៧០ នៅពេលដែលសង្គ្រាមបានផ្ទុះឡើង បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ និងរបបប្រល័យពូជសាសន៍ប៉ុល ពត ឆ្នាំ ១៩៧៥-១៩៧៨។ កម្ពុជាបានស្គាល់សុខសន្តិភាពចំនួន១២២ឆ្នាំគត់។

ង-អន្តរាគមន៍ខាងផ្នែកយោធា

ការផ្តាច់ខ្លួនពីរបបប៉ុល ពត ៖ ក្រោយពីវៀតណាមវាយលុកចូល និងដកទ័ពចេញពីទីសបូព៌ានៃកម្ពុជា ក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមចាប់ផ្តើមសម្លាប់ប្រជាជន និងយកមេដឹកនាំគ្រប់លំដាប់ថ្នាក់របស់ខ្លួនទៅសម្លាប់ចោល។ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ លោក ហ៊ុន សែន ប្រធានសេនាធិការ និងជាអនុប្រធានកងវរៈសេនាធំតំបន់៧១នៃយោធភូមិភាគបូព៌ាបានផ្តាច់ខ្លួន ហើយធ្វើដំណើរទៅតំបន់ព្រំដែនកម្ពុជា-វៀតណាម ហើយនៅថ្ងៃទី ២១ ខែមិថុនា បានឆ្លងចូលទៅប្រទេសវៀតណាម និងបានសុំជំនួយយោធាពីវៀតណាម ដើម្បីផ្តួលរំលំរបបប៉ុល ពត។ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

លោក ហ៊ិន សែនបានជួបពិភាក្សាជាមួយអនុរដ្ឋមន្ត្រីការពារជាតិវៀតណាម ឧត្តមសេនីយឯក វ៉ាន់ ទៀនយ៉ុន នៅទីក្រុងហូជីមិញ។ នៅចុងឆ្នាំ១៩៧៧ វៀតណាមបានបើកយុទ្ធនាការទ្រង់ទ្រាយធំ (ពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៧ ដល់ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៨៨) ដើម្បីផ្តន្ទាទោសដល់កងទ័ពប៉ុល ពត ដែលបានឈ្លានពាន និងសម្លាប់ប្រជាជនស្នូតត្រង់វៀតណាមនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម។ ចលនាបះបោរប្រឆាំងនឹងខ្មែរក្រហមកើតឡើងជាច្រើនកន្លែង។ នៅឆ្នាំ១៩៧៨ មេបញ្ជាការកងពលធំលេខ៧ ប្រចាំភូមិភាគបូព៌ា ហេង សំរិនបានរត់ចូលទៅក្នុងប្រទេសវៀតណាម ហើយអំពាវនាវឱ្យប្រជាជនកម្ពុជាទាំងអស់គ្នាក្រោកឡើងប្រយុទ្ធប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នៃរបបកម្ពុជាប្រជាធិបតេយ្យ។ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាត្រូវបានបង្កើតឡើងនៅថ្ងៃទី២ ខែឧសភា ឆ្នាំ ១៩៧៨ នៅខេត្តដុងណាយ ប្រទេសវៀតណាម ដែលមានយុទ្ធជនជាង ២០០នាក់ មានលោក ញឹក ហួន ជាប្រធានអង្គភាព និងលោក ហ៊ិន សែន ជាប្រធានយោធា និងជាប្រធាននយោបាយ។

រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ៖ ដើម្បីត្រៀមរៀបចំបង្កើតរណសិរ្ស ភាគីវៀតណាមបានរៀបចំការជួបប្រជុំនៃកម្លាំងតស៊ូខ្មែរប្រឆាំងប៉ុល ពតទាំងអស់នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ៖ (១) ក្រុមយោធភូមិភាគបូព៌ា ដឹកនាំដោយលោក ហេង សំរិន និងលោក ជា ស៊ីម (២) ក្រុមភូមិភាគឦសាន ដឹកនាំដោយលោក ប៊ូ ថង, លោក ស៊ើយ ភៃវ និងលោក ប៊ិន មី (៣) ក្រុមរៀននៅហាណូយ ដឹកនាំដោយលោក ចាន់ ស៊ី, លោក ជា សុទ្ធ, លោក ប៉ែន សុវណ្ណ និង លោក រស់ សាម័យ (៤) ក្រុមយោធា ដឹកនាំដោយលោក ហ៊ិន សែន និង (៥) ក្រុមភៀសខ្លួនទៅប្រទេសថៃ ដឹកនាំដោយលោក សាយ ភូថង, លោក ទៀ បាញ់ និង លោក វ៉ង់ផ្វាម កៃសន (មិនអាចចូលរួមបាន)។

នៅថ្ងៃទី២៧-៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៨ មហាសន្និបាតរបស់អ្នកស្នេហា

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាតិត្រូវបានរៀបចំឡើងនៅទីក្រុងហូជីមិញ និងបានសម្រេចបង្កើតរណសិរ្ស
សាមគ្គីសង្គ្រោះជាតិកម្ពុជា ហើយបានបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការ
មជ្ឈិមរណសិរ្សដែលមានសមាជិក១៤រូប ក្នុងនោះមានលោក ហេង សំរិន
ជាប្រធាន និងលោក ជា ស៊ីម ជាអនុប្រធាន។ មហាសន្និបាតបានអនុម័ត
កម្មវិធីនយោបាយ ៖ (១) ផ្តួលរំលំរបបខ្មែរក្រហម ដើម្បីរំដោះប្រជាជនពី
ការកាប់សម្លាប់ (២) កសាងប្រទេសកម្ពុជាប្រកបដោយសន្តិភាព ឯករាជ្យ
ប្រជាធិបតេយ្យ អព្យាក្រឹត បូរណភាពទឹកដី និងសម្បុរវប្បធម៌។ នៅថ្ងៃទី
២ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាត្រូវបានប្រកាស
នៅក្នុងតំបន់រំដោះ នៅឃុំដើងឃ្លូ ស្រុកស្នួល ខេត្តក្រចេះ។

ការរំដោះកម្ពុជាដោយកងទ័ពស្ម័គ្រចិត្តវៀតណាម ៖ នៅខែកញ្ញា
១៩៧៧ កងពលធំទាំងប្រាំមួយនៃកងទ័ពបដិវត្តន៍កម្ពុជា ដោយមានការ
គាំទ្រពីកាំភ្លើងធំបានធ្វើសង្គ្រាមឈ្លានពានវៀតណាម តាមខេត្តដែលនៅ
ជាប់ព្រំដែន និងបានសម្លាប់ប្រជាជនវៀតណាមជាច្រើននាក់។ ក៏ប៉ុន្តែ
កងទ័ពប្រជាជនវៀតណាម ដោយមានការគាំទ្រពីកងកាំភ្លើងធំ និងកង
ទ័ពអាកាស បានវាយលុកចូលទឹកដីកម្ពុជាវិញក្នុងខែធ្នូ ឆ្នាំ១៩៧៧ ដើម្បី
សង្គ្រោះ និងព្រមាន។ ខ្មែរក្រហមបានផ្តាច់ទំនាក់ទំនងការទូតជាមួយ
វៀតណាម នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧។ បន្ទាប់ពីបានទទួលជោគជ័យ
កងទ័ពវៀតណាមបានដកចេញពីកម្ពុជា នៅក្នុងខែមករា ឆ្នាំ១៩៧៩។ ចិន
បានព្យាយាមសម្រុះសម្រួលរវាងកម្ពុជា និងវៀតណាមតែត្រូវបរាជ័យ។
នៅខែឧសភា ឆ្នាំ១៩៧៩ ចិនបានប្រកាសកាត់បន្ថយជំនួយដល់ប្រទេស
វៀតណាម។

*ប៉ុល ពត*ចាប់ផ្តើមសង្ស័យពីផែនការក្បត់ និងបានបញ្ជាអង្គភាព
យោធា ពីភូមិភាគនិរតី ដើម្បីទៅកាន់កាប់ភូមិភាគបូព៌ា និងពាយ័ព្យ ក្នុង
គោលដៅកម្ចាត់ពួកក្បត់។ មេដឹកនាំភូមិភាគបូព៌ា សោ ភឹមបានសម្លាប់ខ្លួន
ហើយចាប់ពីខែមេសា ឆ្នាំ១៩៧៩ នាយទាហាន និងពលទាហាននៃកងទ័ព

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ភូមិភាគបូព៌ាមួយចំនួនបានរត់ភៀសខ្លួនទៅវៀតណាម ដើម្បីគេចផុតពីការ
ស្លាប់ និងដើម្បីបង្កើតចលនាតស៊ូ ដែលនៅក្នុងនោះមានលោក ហោង សំរិន
លោក ជា ស៊ីម និងលោក ហ៊ុន សែនដែរ។

បន្ទាប់ពីមានសំណើរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា កងទ័ព
វៀតណាម ក្រោមការដឹកនាំរបស់ឧត្តមសេនីយ៍ថ្នាក់ទីមួយ ឡេឌឹកអាញ
បានបើកប្រតិបត្តិការវាយលុកចូលមកក្នុងទឹកដីកម្ពុជា នៅថ្ងៃទី ២៣ ខែធ្នូ
ឆ្នាំ១៩៧៨ ដោយប្រើ១៣កងពលធំ មានទាហានប្រមាណ១៥០០០០នាក់
គាំទ្រដោយកាំភ្លើងធំធុនធ្ងន់ និងកម្លាំងអាកាស។ ក្នុងរយៈពេលតែពីរសប្តាហ៍
កងទ័ពខ្មែរក្រហមទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរ ដោយបាត់បង់កម្លាំងប្រយុទ្ធ
ជាងពាក់កណ្តាល។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាម
រំដោះបានភ្នំពេញ ហើយសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានបង្កើត
ឡើង ដោយមានលោក ហោង សំរិន ជាប្រធានរដ្ឋ និងលោក ប៉ែន សុវណ្ណ
ជាលេខានៃបក្សបដិវត្តន៍ប្រជាជនកម្ពុជា។ ប្រតិបត្តិការរំដោះកម្ពុជាពីរបប
ប៉ុល ពតចំណាយពេលវេលាចំនួន១៩ថ្ងៃគត់។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំពូក១២
សាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩)

១-ការកសាងជាតិឡើងវិញក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ថ្ងៃរំដោះជាតិបានចូលមកដល់ ជាថ្ងៃដែលរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដោយមានកងកម្លាំងវៀតណាមជួយរំដោះប្រជាជនកម្ពុជាឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមទាំងស្រុង។ ប្រជាជនកម្ពុជាជាច្រើននាំគ្នាប្រារព្ធទិវានេះ ថាជាថ្ងៃកំណើតទីពីររបស់កម្ពុជា។ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានប្រកាសអំពីការចាប់បដិសន្ធិនៃរបប សាធារណរដ្ឋប្រជាមានិតកម្ពុជា។ ប្រជាជនកម្ពុជាបានខិតខំប្រឹងប្រែងទ្វេរដង ដើម្បីស្តារប្រទេសជាតិឡើងវិញ រៀបចំសេដ្ឋកិច្ចបង្កើតប្រព័ន្ធសិក្សាធិការ បើកមន្ទីរពេទ្យ និងបណ្តុះបណ្តាលបុគ្គលិកកម្រិតគ្រប់គ្រង។ សាធារណរដ្ឋប្រជាមានិតកម្ពុជាមានការគាំទ្រពីវៀតណាម សហភាពសូវៀត ប្រទេសកុម្មុយនីស្តនៅអឺរ៉ុប ប្រទេសឥណ្ឌា និងប្រទេសកំពុងអភិវឌ្ឍ ដែលគាំទ្រដោយសហភាពសូវៀត។

ពួកខ្មែរក្រហមដែលនៅសេសសល់បានរត់ភៀសខ្លួនទៅរស់នៅតាមតំបន់ព្រំដែនជាមួយប្រទេសថៃ។ សម្តេចសីហនុត្រូវបានរំដោះចេញពីភ្នំពេញ ដើម្បីទៅរស់នៅប្រទេសចិនវិញ។ ប្រជាជនខ្មែរមួយចំនួនបានរត់

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទៅរស់នៅតាមជំរំនៅប្រទេសថៃ ក្នុងគោលដៅស្វែងរកសិទ្ធិជ្រកកោននៅប្រទេសបស្ចិមប្រទេសទីបី។ ជំរំជនភៀសខ្លួនត្រូវបានបង្កើតឡើងនៅតាមតំបន់ព្រំដែន ដែលគ្រប់គ្រងដោយភាគីខ្មែរចំនួនបីគឺ ៖ ពួកខ្មែរក្រហមសម្តេចសីហនុ និងសម្តេចសឺន សាន។ នៅពេលនោះ ប្រទេសកម្ពុជាមានតំបន់ត្រួតត្រាចំនួន៤ផ្សេងគ្នា។

ស្ថានភាពសេដ្ឋកិច្ច-សង្គមក្រោយរំដោះ ៖ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ប្រជាជនកម្ពុជាទូទាំងប្រទេសបានធ្វើដំណើរពីកន្លែង ដែលពួកគេត្រូវបានខ្មែរក្រហមជន្ទៀសទៅនៅបណ្តោះអាសន្ន ហើយត្រលប់មកស្រុកកំណើតវិញ។ ប្រជាជនភ្នំពេញដែលសល់ពីស្លាប់បានចូលមកភ្នំពេញវិញ ដើម្បីចុះឈ្មោះចូលបម្រើការងារតាមក្រសួង និងស្ថាប័ន ដែលទើបនឹងបង្កើតថ្មី។ ការជំរឿនស្ថិតិជាបឋមបានបង្ហាញឱ្យឃើញថា ប្រជាជនកម្ពុជាជិត៦លាននាក់បានបាត់បង់ជីវិតក្នុងជំនាន់ប៉ុល ពត។ សង្គ្រាមជាង ប្រាំឆ្នាំ និងរបបប្រល័យពូជសាសន៍ចំនួន៣ឆ្នាំ ៨ខែ និង២០ថ្ងៃបានបន្សល់ទុកនូវស្ត្រីមេម៉ាយ កុមារកំព្រា និងគ្រួសារបែកបាក់ជាច្រើនឥតគណនា។ ប្រជាជនកម្ពុជាមួយចំនួនធំនៅមិនទាន់មានទីលំនៅអចិន្ត្រៃយ៍នៅឡើយ ដែលបង្កើតឱ្យមានទុរភិក្សនៅតាមតំបន់មួយចំនួន ដោយសារគ្មានសត្វពាហនៈ និងឧករណ៍ដើម្បីធ្វើស្រែចម្ការ និងប្រកបរបរចិញ្ចឹមជីវិត។ ប្រទេសវៀតណាម សហភាពសូវៀត ប្រទេសអឺរ៉ុបខាងកើត និងអង្គការមនុស្សធម៌មួយចំនួនបានផ្តល់នូវគ្រឿងឧបភោគបរិភោគដល់កម្ពុជា ដើម្បីបញ្ចៀសនូវគ្រោះទុរភិក្សនេះ។ ដូច្នេះហើយ ទើបរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានដាក់ចេញនូវគោលនយោបាយបង្កើតក្រុមសាមគ្គីបង្កបង្កើនផល ដែលដំបូងគេគិតថា ជាក្រុមប្រវាស់ដៃ ដើម្បីជួយគ្នាក្នុងការធ្វើស្រែចម្ការតែប៉ុណ្ណោះ។

នយោបាយអន្តរជាតិ ៖ លើឆាកអន្តរជាតិ ការប្រឈមមុខដាក់គ្នារវាងសហភាពសូវៀត និងសហរដ្ឋអាមេរិកនៅតែបន្ត។ ការរត់ប្រណាំង

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សព្វាវុធរវាងមហាអំណាចទាំងពីរនៅតែបន្តយ៉ាងស្វិតស្វាញ។ ពិភពលោកស្ថិតនៅក្នុងសភាពនៃប៉ូលពីរ ៖ (១) ពិភពបស្ចិមប្រទេស ដែលដឹកនាំដោយសហរដ្ឋអាមេរិក និងមានអង្គការអូតង់ជាឫកយោធា និង(២) ឫកលោកខាងកើតដឹកនាំដោយសហភាពសូវៀត ដែលមានអង្គការសន្ធិសញ្ញាវ៉ាសូវីជាឫកយោធា។ ប្រទេសតតិយលោកបានចែកជាពីរដែរ ៖ (១) ប្រទេសកំពុងអភិវឌ្ឍន្លោះទៅកាន់មូលធននិយម និង(២) ប្រទេសកំពុងអភិវឌ្ឍន្លោះទៅកាន់សង្គមនិយម។ កម្ពុជាបានចូលជាសមាជិកនៃប្រទេសកំពុងអភិវឌ្ឍន្លោះទៅកាន់សង្គមនិយម។ ទន្ទឹមនឹងនេះ នៅមានសាធារណរដ្ឋប្រជាមានិតចិន ដែលមាននិន្នាការប្រឆាំងនឹងសហភាពសូវៀត ហើយដែលបានចងសម្ព័ន្ធមិត្តជួរលុងជាមួយនឹងសហរដ្ឋអាមេរិក ប្រឆាំងនឹងសហភាពសូវៀត។

ក-ការកសាងស្ថាបនរដ្ឋឡើងវិញ

ការកសាងបក្សឡើងវិញ ៖ សន្និបាតកម្មាភិបាលទូទាំងប្រទេសរបស់គណបក្សប្រជាជនបដិវត្តកម្ពុជាត្រូវបានប្រារព្ធឡើងនៅទីក្រុងហូជីមិញ ពីថ្ងៃទី៥ដល់៨ ខែមករា ឆ្នាំ១៩៧៩ ដោយមានតំណាងចូលរួម៦២រូប។ អង្គសន្និបាតបានសម្រេចលើបញ្ហាសំខាន់បីគឺ ៖ (១) អនុម័តកម្មវិធីនយោបាយ និងលក្ខន្តិក:បក្ស ដោយដាក់ចេញនូវភារកិច្ចផ្លូវរំលំរបបប៉ុល ពតបង្កើតរបបប្រជាធិបតេយ្យប្រជាជន រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង មានទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការជាមួយបណ្តាប្រទេសសង្គមនិយម (២) បង្កើតគណៈកសាងបក្សឡើងវិញ (៣) កំណត់ឈ្មោះបក្សគឺ បក្សប្រជាជនបដិវត្តកម្ពុជា ដែលកើតនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ១៩៥១។ មហាសន្និបាតតំណាងទូទាំងប្រទេសលើកទី៤ របស់បក្ស (២៦-២៩ ខែឧសភា ឆ្នាំ១៩៨១) បានយល់ព្រមទទួលស្គាល់ការសម្រេចនេះ និងបានបង្កើតការិយាល័យនយោបាយ ដែលមានសមាស

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ភាពចំនួន៨រូប ៖ (១) លោក ប៉ែន សុវណ្ណ (២) លោក ហេង សំរិន (៣) លោក ជា ស៊ីម (៤) លោក សាយ ភូថង (៥) លោក ប៊ូ ថង (៦) លោក ហ៊ុន សែន (៧) លោក ជា សុទ្ធ និង (៨) លោក ចាន់ ស៊ី និងបង្កើតគណៈលេខាមជ្ឈិមបក្ស ដែលមាន៧រូប ៖ (១) លោក ប៉ែន សុវណ្ណ ជាអគ្គលេខាបក្ស (២) លោក សាយ ភូថង (៣) លោក ប៊ូ ថង (៤) លោក ហ៊ុន សែន (៥) លោក ជា សុទ្ធ (៦) លោក ចាន់ ស៊ី និង (៧) លោក ចាន់ កិន។

ការបង្កើតស្ថាប័នរដ្ឋ ៖ នៅថ្ងៃ៧ មករា ១៩៧៩ កងទ័ពវៀតណាមរំដោះបានភ្នំពេញ ហើយសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានបង្កើតឡើងដោយមានលោក ហេង សំរិន ជាប្រធានរដ្ឋ និងលោកប៉ែន សុវណ្ណ ជាលេខានៃបក្សបដិវត្តន៍ប្រជាជនកម្ពុជា។ មេដឹកនាំខ្មែរក្រហម និងកងទ័ពដែលនៅសេសសល់បានរត់ទៅជ្រកនៅតាមព្រំដែនកម្ពុជា-ថៃ។

ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា (ក្រុមប្រឹក្សារដ្ឋមន្ត្រី) ត្រូវបានបង្កើតឡើងនៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៩។ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា គឺជាស្ថាប័ននីតិប្រតិបត្តិ ដែលមានតួនាទីដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ដែលមានសមាសភាពដូចតទៅ ៖ (១) លោក ហេង សំរិន ប្រធាន (២) លោក ប៉ែន សុវណ្ណ អនុប្រធាន និងជារដ្ឋមន្ត្រីការពារជាតិ (៣) លោក ជា ស៊ីម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (៤) លោក ហ៊ុន សែន រដ្ឋមន្ត្រីក្រសួងការបរទេស (៥) លោក ចាន់ វ៉ែន រដ្ឋមន្ត្រីក្រសួងអប់រំ (៦) លោក កែវ ចិន្តា រដ្ឋមន្ត្រីក្រសួងឃោសនាការ និងវប្បធម៌ (៧) លោក នូ សេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងសង្គមកិច្ច (៨) លោក ម៉ុក សាគុណ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងជីវភាព និង (៩) លោក អ៊ិង ផន ប្រធានមន្ទីរក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា។

រដ្ឋសភាជាតិ ដែលមានសមាជិកចំនួន១១៧រូបត្រូវបានបង្កើតឡើងបន្ទាប់ពីការបោះឆ្នោតនៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៨១ ដើម្បី ៖ (១) ជ្រើស-

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ពីសលោក ជា ស៊ីម ជាប្រធានរដ្ឋសភា (២) អនុម័តលើសមាសភាពក្រុមប្រឹក្សារដ្ឋ (៧ រូប) ដែលមានលោក ហេង សំរិន ជាប្រធាន និង (៣) អនុម័តសមាសភាពក្រុមប្រឹក្សារដ្ឋមន្ត្រី (១៧រូប) ដែលមានលោក ប៉ែន សុវណ្ណ ជាប្រធាន លោក ហ៊ុន សែន លោក ជា សុទ្ធ និង លោក ចាន់ ស៊ី ជាអនុប្រធាន។

ក្រុមប្រឹក្សារដ្ឋ ដែលមានលោក ហេង សំរិន ជាប្រធាន មានតួនាទីត្រួតពិនិត្យការតាក់តែងច្បាប់ រដ្ឋសភាបានជ្រើសពីរសមាជិកក្រុមប្រឹក្សារដ្ឋរបស់ខ្លួនច្រាំពីររូប។ ប្រធានក្រុមប្រឹក្សារដ្ឋ គឺជាប្រមុខរដ្ឋ។ ក្រុមប្រឹក្សារដ្ឋមានសមាជិកច្រាំពីររូប ដែលដឹកនាំការងាររវាងសម័យប្រជុំនៃរដ្ឋសភា។

ការពឹងផ្អែកលើជំនួយ និងជំនាញការបរទេស ៖ រដ្ឋបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាខិតខំប្រមូលមន្ត្រីចាស់ៗ វិស្វករ សាស្ត្រាចារ្យ និងនិស្សិត ដែលសេសសល់ពីស្លាប់ ដើម្បីចូលរួមក្នុងការកសាងប្រទេសជាតិ។ ក៏ប៉ុន្តែ កម្ពុជាខ្វះអ្នកចេះដឹងច្រើន ដោយសារបញ្ហាវិន្តមួយចំនួនដែលនៅសេសសល់បានចាកចេញទៅរស់នៅបរទេស។ ដូច្នេះហើយ តាមសំណូមពររបស់កម្ពុជា វៀតណាមបានបញ្ជូនជំនាញការមកធ្វើការនៅក្នុងគ្រប់ក្រសួង-ស្ថាប័ន ក្នុងជួរកងទ័ព និងនៅតាមខេត្ត។ ពីឆ្នាំ១៩៧៩ដល់ ១៩៨២ លោក ឡេ ដឹកថូ ត្រូវបានតែងតាំងជាអគ្គទីប្រឹក្សានៃរណសិរ្សរំដោះជាតិកម្ពុជា ហើយទទួលខុសត្រូវចំពោះការសម្របសម្រួលការងារទីប្រឹក្សាទាំងអស់។ វត្តមាននៃជំនាញការវៀតណាមនៅបន្តរហូតដល់ឆ្នាំ ១៩៨៩ ហើយត្រូវដកចេញមុនការដកកងទ័ពវៀតណាមមួយឆ្នាំ។ កម្ពុជាបានចុះសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការជាមួយប្រទេសវៀតណាម ដែលជាមូលដ្ឋានច្បាប់នៃកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ។ កម្ពុជាបានចុះហត្ថលេខាផងដែរលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការជាមួយជាមួយសហភាពសូវៀត និងប្រទេសប្លុកលោកខាងកើត។ ជំនាញការសូវៀតត្រូវបានបញ្ជូនមកជួយក្នុងវិស័យសិក្សាធិការ ជាពិសេសក្នុងការស្តារ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឡើងវិញនូវវិទ្យាស្ថានមិត្តភាពកម្ពុជា-សូវៀត ដែលត្រូវបានដាក់ឱ្យដំណើរការឡើងវិញនៅឆ្នាំ១៩៨១ និងនៅសាកលវិទ្យាល័យកសិកម្មចំការដូង។ វិទ្យាស្ថានទាំងពីរនេះបានជួយបណ្តុះបណ្តាលអ្នកឯកទេសជាន់ខ្ពស់ និងអ្នកឯកទេសមធ្យម ក្នុងវិស័យសំណង់ អគ្គិសនី កសិកម្ម ជាវាសាស្ត្រ។ល។ ម្យ៉ាងវិញទៀត ជំនួបណ្តិតមកពីប្រទេសគុយបាក៏បានមកជួយបំពេញការងារនៅតាមមន្ទីរពេទ្យផងដែរ។

ការទទួលស្គាល់ជាអន្តរជាតិ ៖ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ មានតែប្រទេសសង្គមនិយម និងប្រទេសមួយចំនួនតូចប៉ុណ្ណោះ ដែលទទួលស្គាល់សាធារណរដ្ឋប្រជាមានិតកម្ពុជា និងមានទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាម ឡាវ សហភាពសូវៀត ប្រទេសសង្គមនិយមនៅអឺរ៉ុបខាងកើត ឥណ្ឌា និងប្រទេសតតិយលោកមួយចំនួនទៀត។ ក្រៅពីនេះមានអង្គការមនុស្សធម៌អន្តរជាតិមួយចំនួន ដូចជាកាកបាទក្រហមអន្តរជាតិ និងគណៈកម្មការអូឡាំពិកអន្តរជាតិ។

ខ-ការកសាងឡើងសេដ្ឋកិច្ចជាតិឡើងវិញ

ជំនួយសង្គ្រោះពីការអត់ឃ្លាន ៖ នៅឆ្នាំ១៩៧៩ ក្រោយថ្ងៃរំដោះ ប្រជាជនកម្ពុជាប្រឈមមុខនឹងគ្រោះអត់ឃ្លាន ដោយប្រជាជនកម្ពុជារាប់លាននាក់មានសភាពស្គមស្គាំងស្វេកស្វាំងដោយខ្វះអាហារ។ ប្រទេសជាមិត្ត ដែលក្នុងនោះមាន សហភាពសូវៀត វៀតណាម ប៊ុលហ្គារី ឡាវ និងអង្គការអន្តរជាតិមួយចំនួនបានផ្តល់ជំនួយជាស្បៀងអាហារចំនួន៦០៣ ០០០ តោន។ ស្បៀងទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ទប់ទល់នឹងតម្រូវការរហូតដល់រដូវច្រូតកាត់ថ្មីនៅខែ វិច្ឆិកា និងធ្នូ ឆ្នាំ១៩៧៩។

គោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ៖ ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជាបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍជាតិដូចតទៅ ៖ (១) ធ្វើប្រក្រតីភាវូបនីយកម្មនូវជីវភាពរបស់ប្រជាជន (២) រៀបចំចាត់តាំង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិស័យកសិកម្មឡើងវិញ ដោយរដ្ឋមិនយកពន្ធកសិកម្ម (៣) ស្តារសេដ្ឋកិច្ច គ្រួសារ ស្តារនិងពង្រីកវិស័យឧស្សាហកម្ម និងសិប្បកម្ម និង (៤) ពង្រីកខឿនអប់រំ និងវប្បធម៌។ រដ្ឋាភិបាលបានកសាង និងពង្រឹងអង្គការចាត់តាំង និងក្របខ័ណ្ឌរដ្ឋ រណសិរ្ស និងអង្គការមហាជន ដោយកំណត់នូវតួនាទីការកិច្ច និងរបៀបរបបធ្វើការងាររបស់អង្គការតាមថ្នាក់នីមួយៗ សំដៅពង្រឹងការទទួលខុសត្រូវរឿងៗខ្លួន។ នៅឆ្នាំ១៩៨៥ មហាសន្និបាតលើកទី៥របស់បក្សបានអនុម័តកម្មវិធីស្តារ និងផែនការសេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំ លើកទី ១ (១៩៨៦-១៩៩០) សំដៅលើកកម្ពស់វិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម និងអនុវត្តនូវគោលយោបាយ ដែលបានដាក់ចេញ។ បណ្តាអង្គការបក្ស និងរដ្ឋអំណាចគ្រប់លំដាប់ថ្នាក់ត្រូវចុះទៅពង្រឹងតាមមូលដ្ឋាន និងបម្រើប្រជាជនឱ្យបានដិតដល់តាមសមត្ថភាព និងគុណធម៌របស់ខ្លួន។

ការបង្កើតធនាគារជាតិនៃប្រជាជនកម្ពុជា ៖ ក្រុមប្រឹក្សាប្រជាជនបដិវត្តបានចេញអនុក្រឹត្យស្តីពីការបង្កើតធនាគារជាតិនៃប្រជាជនកម្ពុជា ហើយនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ គណៈរដ្ឋមន្ត្រីបានប្រកាសអំពីគោលការណ៍បោះផ្សាយក្រដាសប្រាក់រៀល។ នៅខែកញ្ញា ឆ្នាំ១៩៨០ ធនាគារជាតិបានបោះផ្សាយក្រដាសប្រាក់ដែលមានសាច់ប្រាក់ចំនួន៦២០ លានរៀល ដើម្បីបម្រើដល់សេដ្ឋកិច្ចជាតិ។

គោលនយោបាយក្នុងវិស័យអប់រំ ៖ នៅថ្ងៃទី៦៧ ខែតុលា ឆ្នាំ១៩៧៩ ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជាបានចេញសេចក្តីសម្រេចស្តីពីការងារអប់រំ និងសិក្សាធិការ ៖ (១) ប្រមូលផ្តុំសាមគ្គី អប់រំ បំពាក់បំប៉ននយោបាយ និងប្រើប្រាស់ជូរបញ្ជាវន្ត សាស្ត្រាចារ្យ និងគ្រូបង្រៀនដែលនៅសេសសល់ (៦) បំផុសចលនាលុបបំបាត់គ្រោះមិនចេះអក្សរ (៣) ស្តារ និងអភិវឌ្ឍសាលារៀនកម្រិតទី១ និងទាក់ទាញសិស្សចូលរៀន និង (៤) ស្តារ និងអភិវឌ្ឍជាជំហានៗ ការអប់រំកម្រិតមហាវិទ្យាល័យ និងមធ្យមសិក្សាបច្ចេកទេស។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ-ការប្រយុទ្ធប្រឆាំងនឹងការវិលត្រលប់នៃរបបប៉ុល ពត

ការបន្តឱ្យមានវត្តមានកងទ័ពស្ម័គ្រចិត្តវៀតណាម ៖ បន្ទាប់ពីថ្ងៃរំដោះ ៧ មករា កងកម្លាំងប្រដាប់អាវុធកម្ពុជាមានតិចតួចស្តួចស្តើងប៉ុណ្ណោះ។ មានតែទីក្រុងភ្នំពេញទេ ដែលមានកម្លាំងយោធាខ្មែរចំនួន១កងពលតូច។ នៅតាមខេត្តនីមួយៗមានកងកម្លាំងប្រដាប់អាវុធកម្ពុជាត្រឹមតែពី១ទៅ២ វរៈសេនាតូចប៉ុណ្ណោះ។ ដូច្នេះហើយ ដើម្បីប្រឆាំងនឹងការវិលត្រលប់មកកាន់អំណាចរបស់ពួកប៉ុល ពត សាធារណរដ្ឋប្រជាមានិតកម្ពុជាបានចុះសន្ធិសញ្ញាសន្តិភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៩ ដើម្បីរក្សាទុកកងទ័ពស្ម័គ្រចិត្តវៀតណាមបន្តទៀតនៅកម្ពុជា។

ការបង្កើតរដ្ឋាភិបាលត្រីភាគី ៖ មេដឹកនាំខ្មែរក្រហម និងកងទ័ពដែលនៅសេសសល់បានរត់ទៅជ្រកនៅតាមព្រំដែនកម្ពុជា-ថៃ។ បន្ទាប់ពីការដួលរលំនៃរបបប៉ុល ពត ប្រជាជនខ្មែរភាគច្រើនបានភៀសខ្លួនទៅប្រទេសថៃ ដើម្បីទៅរស់នៅប្រទេសទីបី។ បញ្ហាវិបត្តិមួយចំនួន ដែលនៅសេសសល់ពីរបបប៉ុល ពតបានធក់យកឱកាសនេះ ដើម្បីទៅរស់នៅបារាំង និងសហរដ្ឋអាមេរិក និងប្រទេសផ្សេងទៀតដែលទទួលយកជនភៀសខ្លួន។ ជំរំជនភៀសខ្លួនត្រូវបានបង្កើតឡើង ក្រោមការគ្រប់គ្រងនៃចលនាតស៊ូបីសំខាន់ៗ ៖ (១) ជំរំដែលគ្រប់គ្រងដោយចលនា FUNCINPEC (Front uni national pour un Cambodge indépendant, neutre, pacifique et coopératif) បង្កើតឡើងនៅឆ្នាំ ១៩៨១ ដោយសម្តេច នរោត្តម សីហនុ (២) ជំរំរបស់រណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ (KPNLF) ដែលបង្កើតឡើងនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៩ និងដឹកនាំដោយសម្តេចសឺន សាន និង ជំរំដែលគ្រប់គ្រងដោយពួកខ្មែរក្រហម។ ដោយមានការជួយជ្រោមជ្រែងពីប្រទេសអាស៊ាន ដែលភ័យខ្លាចលទ្ធិកុម្មុយនីស្តរាលដាលទៅប្រទេសផ្សេងទៀត និងដោយមានជំនួយហិរញ្ញវត្ថុ និងយោធាពីប្រទេសចិន និងប្រទេស

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

លោកសេរី (ជាពិសេសសហរដ្ឋអាមេរិក) នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨២ រដ្ឋាភិបាលចម្រុះត្រីភាគីកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើងនៅ Kuala Lumpur និងដែលមានទីតាំងនៅតាមជំរំតាមព្រំប្រទល់កម្ពុជា-ថៃ ហើយដែលអនុញ្ញាតឱ្យពួកខ្មែរក្រហមនៅបន្តកាន់កាប់អាសនៈកម្ពុជានៅអង្គការសហប្រជាជាតិ។ មានតែពួកខ្មែរក្រហមទេ ដែលមានកងទ័ពច្រើនជាងគេ មានប្រសិទ្ធភាពជាងគេ និងទទួលជំនួយយោធា និងហិរញ្ញវត្ថុបានច្រើនពីប្រទេសមហាអំណាច និងពីប្រទេសក្នុងតំបន់។

សង្គ្រាមឥណ្ឌូចិនលើកទី៣ ៖ បន្ទាប់ពីបានរំដោះផុតពីនឹមប៉ុល ពត សង្គ្រាមនៅតែបន្តរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលគាំទ្រដោយវៀតណាម សហភាពសូវៀត និងប្រទេសអឺរ៉ុបខាងកើត និងរដ្ឋាភិបាលត្រីភាគីកម្ពុជាប្រជាធិបតេយ្យ ដែលគាំទ្រដោយចិន ប្រទេសអាស៊ាន និងប្រទេសលោកខាងលិច។ សម្រាប់ប្រជាជនកម្ពុជានៅក្នុងប្រទេស សង្គ្រាមឥណ្ឌូចិនលើកទី៣ គឺជាសង្គ្រាមប្រឆាំងការវិលត្រលប់មកវិញនៃរបបប្រល័យពូជសាសន៍ប៉ុល ពត។ សម្រាប់ប្រទេសអាស៊ាន សង្គ្រាមឥណ្ឌូចិនលើកទី៣ គឺជាការប្រយុទ្ធប្រឆាំងការគំរាមកំហែងនៃលទ្ធិកុម្មុយនីស្ត ជាពិសេសលទ្ធភាពដែលវៀតណាមអាចនាំចេញបដិវត្តន៍សង្គមនិយមទៅកាន់ប្រទេសផ្សេងទៀតនៅអាស៊ាន។ ប្រទេសអាស៊ានចាត់ទុកការផ្តួលរំលំរបបប៉ុល ពត ជាការឈ្លានពានវៀតណាមប្រឆាំងប្រទេសអធិបតេយ្យ។ ប្រទេសអាស៊ានមានការព្រួយបារម្ភ ចំពោះការគំរាមកំហែងរបស់វៀតណាមមកលើប្រទេសក្នុងតំបន់។ សម្រាប់ប្រទេសចិន សង្គ្រាមឥណ្ឌូចិនលើកទី៣ គឺជាការប្រយុទ្ធប្រឆាំងការរាតទីនិយមរបស់សហភាពសូវៀត។ សម្រាប់ប្រទេសលោកខាងលិច សង្គ្រាមឥណ្ឌូចិនលើកទី៣ គឺជាការប្រយុទ្ធប្រឆាំងការរាលដាលនៃលទ្ធិកុម្មុយនិស្តនៅក្នុងពិភពលោក។

ទំនាក់ទំនងរវាងវៀតណាម និងចិនត្រូវបានកាត់ផ្តាច់ជាបណ្តើរៗ បន្ទាប់ពីចិនបានបញ្ជូនកងទ័ពទៅកាន់កាប់ទីប្រជុំកោះមួយចំនួន ដែលមាន

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជម្លោះជាមួយវៀតណាមខាងត្បូងនៅឆ្នាំ១៩៧៤។ បន្ទាប់ពីមានជម្លោះជាមួយ
ខ្មែរក្រហម វៀតណាមចាប់ផ្តើមដាកចេញពីចិន ហើយទៅពង្រឹងទំនាក់
ទំនងជាមួយសហភាពសូវៀត ជាពិសេសបន្ទាប់ពីចិនកាត់បន្តយជំនួយនៅ
ឆ្នាំ១៩៧៧។ នៅខែមិថុនា ឆ្នាំ១៩៧៨ វៀតណាមបានចូលជាសមាជិកនៃ
ក្រុមប្រឹក្សាឧបត្ថម្ភទៅវិញទៅមកខាងផ្នែកសេដ្ឋកិច្ច (COMECON) ដែល
ស្ថិតក្រោមការគ្រប់គ្រងរបស់សហភាពសូវៀត។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៨
វៀតណាមបានចុះហត្ថលេខាជាមួយសហភាពសូវៀត លើសន្ធិសញ្ញាមិត្ត
ភាពនិងសហប្រតិបត្តិការ ដើម្បីធានានូវការផ្តល់ជំនួយយោធាសូវៀតទៅ
ឱ្យវៀតណាម មុននឹងបញ្ជូនកងទ័ពស្ម័គ្រចិត្ត ដើម្បីមកជួយរំដោះកម្ពុជា
ឱ្យរួចផុតពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។
ចាប់ពីពេលនោះមក វៀតណាមបានដាកទៅរកសហភាពសូវៀត និងប្តូក
ប៉ាសូវី ដើម្បីទទួលបានខ្នងបង្អែក។ នៅខែកុម្ភៈ ឆ្នាំ១៩៧៩ ចិនបានវាយចូល
ខេត្តវៀតណាមភាគជើង ដើម្បី«ផ្តល់ដំបូន្មានដល់វៀតណាម» ហើយបាន
ដកទ័ពចេញវិញមួយខែក្រោយមក។

ការវាយកម្ទេចបញ្ជាការដ្ឋានរបស់ខ្មែរក្រហម ៖ ក្នុងគោលដៅពង្រឹង
សន្តិសុខនៅទូទាំងប្រទេស កងទ័ពជាតិកម្ពុជា ដោយមានការគាំទ្រពីកង
ទ័ពវៀតណាមបានបើកយុទ្ធនាការវាយកម្ទេច អគ្គសេនាធិការដ្ឋានរបស់
ខ្មែរក្រហមនៅអមលាំង ក្នុងខេត្តកំពង់ស្ពឺ បញ្ជាការដ្ឋានរបស់ប៉ុល ពត នៅ
តាសាញ់ និងទីតាំងខ្មែរក្រហមនៅតាមដែនសមុទ្រក្នុងខេត្តកោះកុង ខេត្ត
តាកែវ និងកំពត (ខែមីនា ឆ្នាំ ១៩៧៩)។ នៅរដូវប្រាំងឆ្នាំ១៩៨៦-៨៩ កង
កម្លាំងប្រដាប់អាវុធនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបើកយុទ្ធនាការ
យោធា ដើម្បីពង្រឹងសន្តិសុខនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដោយ
ជោគជ័យ។

កម្ពុជាបែកចែកជាពីរ ៖ ចាប់ពីឆ្នាំ១៩៨៦មក កម្ពុជាបានបែងចែក
ជាពីរ ៖ (១) សាធារណរដ្ឋប្រជាមានិតកម្ពុជា គាំទ្រដោយវៀតណាម

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សហភាពសូវៀត និងបក្សលោកខាងកើត និង (២) រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យដែលគាំទ្រដោយប្រទេសអាស៊ានចិននិងសហរដ្ឋអាមេរិក និងទទួលស្គាល់ដោយសហគមន៍អន្តរជាតិ។ អាសនៈកម្ពុជានៅអង្គការសហប្រជាជាតិត្រូវបានកាន់កាប់ដោយខ្មែរក្រហម។ នៅក្នុងប្រទេស កម្លាំងខ្មែរក្រហមនៅបន្តធ្វើទុក្ខបុកម្នេញប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង។ ពួកខ្មែរក្រហមធ្វើប្រតិបត្តិការជាក្រុមតូចៗ តាមបែបសង្គ្រាមឈ្លប ជាពិសេសនៅតាមតំបន់ព្រំដែនទន្លេសាប។

ក្នុងន័យនេះ ការកិច្ចរបស់រដ្ឋាភិបាលថ្មីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាគឺមានពីរសំខាន់ ៖ (១) ការកសាងជាតិឡើងវិញក្នុងគ្រប់វិស័យ និងការពង្រឹងសន្តិសុខ ការកសាងសន្តិភាព និងការប្រយុទ្ធតស៊ូប្រឆាំងនឹងការវិលត្រលប់នៃរបបប៉ុល ពត។

២-ការស្តារនិងកសាងជាតិឡើងវិញលើគ្រប់វិស័យ

វិស័យសាសនា ៖ មួយក្នុងចំណោមសកម្មភាពផ្លូវការដ៏សំខាន់នៃ ស.ប.ក.គឺការស្តារការកាន់ព្រះពុទ្ធសាសនាឡើងវិញជាសាសនារបស់រដ្ឋរបស់កម្ពុជា និងវត្តអារាមត្រូវបានបើកជាថ្មីបន្តិចម្តងៗដើម្បីផ្តល់ជាជម្រកដល់ព្រះសង្ឃ និងដើម្បីបន្តផ្លូវដាក់ស្តែងនៃជីវិតសាសនាតាមបែបប្រពៃណី។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៩ ព្រះសង្ឃចំណាស់ៗប្រាំពីរអង្គត្រូវបានបំបួសជាផ្លូវការឡើងវិញនៅវត្តឧណ្ណាលោម ភ្នំពេញ និងព្រះសង្ឃអស់ទាំងនេះបានបង្កើតឡើងវិញនូវសង្ឃកម្ពុជារវាងឆ្នាំ១៩៧៩ និង១៩៨១។ ពួកលោកបានចាប់ផ្តើមកសាងសហគមន៍ព្រះសង្ឃឡើងវិញនៅភ្នំពេញ និងក្រោយមកនៅតាមខេត្តនានា ដោយការបំបួសសង្ឃដែលមានកិត្តិនាមដែលធ្លាប់ជាពួកព្រឹទ្ធសង្ឃកាលពីមុនៗ។ យ៉ាងណាមិញ នយោបាយនៅពេលនោះគឺមិនឱ្យបំបួសលោកនេនក្មេងៗឡើយ ដោយសារខ្វះកម្លាំងពលកម្មក្នុងការបង្កបង្កើនផល។ បន្ទាប់មក ពុទ្ធបរិស័ទចាប់ផ្តើមការងារជួសជុលវត្ត

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

អារាមចំនួន៧០០សិន ក្នុងចំណោមវត្តប្រមាណ៣៦០០វត្ត ដែលត្រូវបានកម្ទេច ឬបំផ្លាញទាំងស្រុងដោយខ្មែរក្រហម។ នៅពាក់កណ្តាលឆ្នាំ១៩៨០ ពិធីបុណ្យព្រះពុទ្ធសាសនាតាមបែបប្រពៃណីបានចាប់ផ្តើមប្រារព្ធធ្វើឡើងវិញ។

គោលនយោបាយសេដ្ឋកិច្ច ៖ ចាប់ពីដើមទសវត្សរ៍ទី៨០រហូតដល់ឆ្នាំ១៩៩១ សេដ្ឋកិច្ចកម្ពុជាត្រូវបានរៀបចំបែបសេដ្ឋកិច្ចផែនការ រហូតដល់មានកំណែទម្រង់គោលនយោបាយ ដើម្បីជំរុញការអភិវឌ្ឍន៍វិស័យឯកជនដែលបានចាប់ផ្តើមក្នុងឆ្នាំ១៩៨៩ និង១៩៩០ បានបើកទូលាយសេដ្ឋកិច្ចតាមរយៈការរំលាយចោលការត្រួតពិនិត្យតម្លៃ និងការជំរុញការអភិវឌ្ឍវិស័យឯកជន រួមទាំងការវិនិយោគក្រៅប្រទេស។ គោលនយោបាយសេដ្ឋកិច្ចរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា គឺការកសាងខឿនសេដ្ឋកិច្ចផែនការដែលស្ថិតនៅក្នុងដំណាក់កាលអន្តរកាលឆ្ពោះទៅកាន់សេដ្ឋកិច្ចសង្គមនិយម ៖ (១) ការបង្កើតក្រុមសាមគ្គីបង្កបង្កើនផល (២) ការលើកកម្ពស់ពោងចក្រ និងសហគ្រាសរដ្ឋក្នុងវិស័យឧស្សាហកម្ម (៣) តួនាទីផ្តាច់មុខរបស់រដ្ឋក្នុងផ្នែកពាណិជ្ជកម្មក្រៅប្រទេស (៤) កម្មសិទ្ធិរដ្ឋលើដីធ្លី និងមធ្យោបាយផលិតកម្ម (៥) ការអនុញ្ញាតឱ្យមានផ្នែកឯកជនក្នុងវិស័យណា ដែលរដ្ឋនៅមិនទាន់ធ្វើបាន។

ក្រុមសាមគ្គីបង្កបង្កើនផល ៖ ក្រោយថ្ងៃរំដោះ ប្រជាជនកម្ពុជាខ្វះសព្វខ្វះគ្រប់ ហើយមេគ្រួសារជាងពាក់កណ្តាលជាស្ត្រីមេម៉ាយ។ ដោយសារខ្វះសត្វពាហនៈ និងកម្លាំងពលកម្មគោលនយោបាយកសិកម្មរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺការបង្កើតក្រុមសាមគ្គី ដែលក្រុមនីមួយៗមានសមាជិកពី១០ទៅ២០គ្រួសារ។ ក្រុមសាមគ្គីបង្កបង្កើនផលត្រូវបានគេបែងចែកជាបីប្រភេទ ដោយអាស្រ័យលើកម្រិតនៃទំហំកម្លាំងពលកម្ម និងអាស្រ័យលើមធ្យោបាយផលិតកម្មកសិកម្ម ៖

(១) ក្រុមសាមគ្គីប្រភេទទី១ គឺជាក្រុមដែលមានទំហំសមាជិកពល

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កម្មច្រើនជាងគេ ហើយដីស្រែចម្ការសម្រាប់ប្រកបរបរកសិកម្ម ស្ថិតនៅជាកម្មសិទ្ធិរួមគ្នា និងការប្រើប្រាស់រួមៗ ទន្ទឹមនឹងនេះ ការដាំដុះដំណាំស្រូវក្នុងរដូវកាល ក៏ដូចជាការក្តររាស់ដី ការសាបព្រោះ ការដាំដុះ ការប្រមូលផលស្រូវ ការដឹកជញ្ជូនផលស្រូវចេញពីស្រែចម្ការ គឺដំណើរការឡើងដោយសមាជិកនៃគ្រួសារកសិករ ក្នុងលក្ខណៈជាការងាររួមគ្នា។ ពួកគេអាចធ្វើសេចក្តីសម្រេចផ្សេងៗ តាមរយៈអង្គប្រជុំរួមក្នុងក្រុម ជាពិសេសលើកិច្ចការសំខាន់ៗ និងការបែងចែកកោគផលស្រូវរបស់ពួកគេ។ ជាក់ស្តែង ការងាររួមនេះមិនសូវមានប្រសិទ្ធភាពទេ ដោយសារតែគ្មានការលើកទឹកចិត្តឱ្យសមាជិកម្នាក់ៗខិតខំប្រឹងប្រែងបំពេញការងារ។

(២) ក្រុមសាមគ្គីប្រភេទទី២ គឺជាទម្រង់ផលិតកម្មកសិកម្ម ដែលផ្អែកលើមូលដ្ឋាននៃប្រព័ន្ធប្រវាស់ដៃគ្នា ដែលធ្លាប់មានជាប្រពៃណីរបស់ប្រជាកសិករខ្មែរតាំងពីយូរលង់ណាស់មកហើយ។ ក.ស.ប ប្រភេទទី២នេះត្រូវបានគេបង្កើតឡើងដោយធ្វើការបង្រួបបង្រួមគ្នាប្រមាណពី១០ទៅ១៧គ្រួសារក្នុងមួយក្រុម។ ហើយបែងចែកជាក្រុមតូចៗបន្តទៀត គឺពី៣ទៅ៥គ្រួសារក្នុងមួយក្រុម។ ដែលក្រុមនីមួយៗត្រូវបានទទួលដីប្រើប្រាស់ពីមួយទៅបីឆ្នាំ។ បន្ទាប់ពីក្រុមកសិករបានបំពេញកិច្ចការធ្ងន់ៗរួមគ្នារួចមក ដូចជាការជាស់ដី ការក្តររាស់ដី ការសាបសំណាបជាដើមរួចរាល់ហើយ ក្រោយមកទៀត ដីស្រែទាំងនោះត្រូវបានបែងចែកទៅឱ្យគ្រួសារផ្សេងៗគ្នា ដែលគ្រួសារនីមួយៗ ត្រូវតែធ្វើការចាត់ចែងការដាំដុះបន្តដោយខ្លួនឯង រួមមានការដកសំណាប ការស្មូនស្រូវ ការថែទាំ និងការច្រូតកាត់ប្រមូលផលជាដើម។ ចំពោះការបែងចែកដីធ្លីសម្រាប់គ្រួសារនីមួយៗវិញបានធ្វើឡើងជារៀងរាល់ឆ្នាំដោយធ្វើយ៉ាងណាឱ្យមានភាពយុត្តិធម៌ ដែលអាស្រ័យលើគុណភាពដីធ្លី និងទំហំគ្រួសារផងដែរ ក៏ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់នោះស្ថិតនៅត្រង់ថា បន្ទាប់ពីពួកគេបានបំពេញការងារសំខាន់ៗ ជាមួយគ្នារួចមកដូចជា ការក្តររាស់ដី ឬការសាបសំណាបជាដើម ដែលសម្រាប់កិច្ចការងារ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បន្ទាប់ទៀតនោះ គឺប្រគល់ឱ្យទៅក្រុមតូចៗ (ពី៣ទៅ៥គ្រួសារ) សម្រាប់ធ្វើការគ្រប់គ្រងបន្ត តែមិនមែនទៅឱ្យគ្រួសារនីមួយៗនោះទេ។ ជាងនេះទៀត សម្រាប់ការដាំដុះបន្ត ត្រូវបានគេបែងចែកជាពីរលក្ខណៈពោលគឺ សម្រាប់លក្ខណៈទី១ សំដៅលើគ្រួសារកសិករ ដែលមានទំហំពី៣ទៅ៥គ្រួសារនោះ ពួកគេអាចធ្វើការរួមគ្នាតែម្តងក៏បាន រីឯសម្រាប់លក្ខណៈទី២ គេអាចអភិវឌ្ឍជាលក្ខណៈគ្រួសារ ឬក៏ករណីខ្លះទៀត ក៏អាចធ្វើការរួមគ្នាដោយអន្ទើក៏សឹងមាន។ ដូច្នេះ ទម្រង់អង្គការផលិតកម្ម ក.ស.ប ប្រភេទទី២ មានលក្ខណៈបែបផែនផលិតកម្មប្រមូលផ្តុំ ឬជាទម្រង់ចម្រុះ។

(៣) ក្រុមសាមគ្គីប្រភេទទី៣ គឺជាទម្រង់ផលិតកម្មមួយប្រភេទផ្សេងទៀតនៃការអភិវឌ្ឍ សេដ្ឋកិច្ចកសិកម្ម ដែលដីធ្លីកសិកម្មត្រូវបានបែងចែករវាងគ្រួសារនៃសមាជិកក្រុមទាំងអស់ ហើយការងារដាំដុះដំណាំស្រូវត្រូវបានអនុវត្តន៍ឡើងដោយក្រុមគ្រួសារនីមួយៗវៀងៗខ្លួន។ ការបែងចែកដីធ្លីរវាងគ្រួសារនីមួយៗបានកំណត់ឡើងតាមគោលការណ៍ស្មើភាពគ្នា ដោយផ្អែកលើគុណភាពដីកសិកម្ម ទំហំគ្រួសារ និងបរិមាណពលកម្មដែលត្រូវបំពេញការងារ។ ដោយហេតុថា សមាជិកគ្រួសារកសិករនៃ ក.ស.ប របស់ប្រភេទទី៣ ដែលមានកម្លាំងអូសទាញជាសត្វពាហនៈក្នុងចំនួនច្រើនផ្សេងៗគ្នា ដូច្នេះគេអាចប្រើប្រាស់ការជួលសត្វពាហនៈជាលក្ខណៈឯកជនទៅឱ្យគ្រួសារផ្សេងទៀតក៏បាន។ ក្នុងស្ថានភាពបែបនេះ បានទាំមកនូវការកើតមានឡើងនូវទម្រង់លក្ខណៈនៃការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ជុំវិញទំនាក់ទំនងនៃការជួលសត្វគោ ឬក្របី តាមរយៈការផ្តល់សត្វពាហនៈជាលក្ខណៈកម្ចីឥណទាន ដែលមានការរីកចម្រើនផងដែរនាសម័យនោះ។ គួរបញ្ជាក់ដែរថា ក្នុងចំណោមសមាជិកគ្រួសារកសិករនៃក.ស.ប ប្រភេទទី៣ក៏កើតមាននូវទម្រង់បែបប្រវាស់ដៃគ្នាសុទ្ធសាធ និងការជួលសត្វពាហនៈបន្តែមឧទាហរណ៍ ៖ ម្ចាស់គោក្របីអាចជួលសត្វពាហនៈរបស់ខ្លួនទៅឱ្យក្រុមគ្រួសារណាដែលខ្វះខាតកម្លាំងអូសទាញ ហើយម្ចាស់គោក្របីខ្លួនឯងក៏

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

អាចទៅជួយក្តួរអស់ ឬបំពេញកិច្ចការស្រែចម្ការផ្សេងៗទៀតឱ្យអ្នកជួលដែលក្រោយមកត្រូវសងដែលបានជួលគោ ឬក្របីពីគេនោះ ត្រូវមកបំពេញការងារសងជំនួសវិញ ក្នុងតម្លៃពលកម្មដូចគ្នាដែលគេបានជួយដល់ខ្លួន។ អាជ្ញាធរចាត់ទុកថា ក្រុមសាមគ្គីបង្កបង្កើនផលប្រភេទទី៣ គឺជាការធ្វើសហករណ៍កម្រិតទាបជាងគេ ថ្វីត្បិតតែជាក់ស្តែង ប្រជាកសិករមានការលើកទឹកចិត្ត ដើម្បីបំពេញការងារនៅក្នុងសហករណ៍ប្រភេទនេះ។

ការបង្កើតសហគ្រាសរដ្ឋ ៖ ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ៖ តាមទ្រឹស្តីអង្គភាពរដ្ឋមានសិទ្ធិផ្តាច់មុខក្នុងការធ្វើពាណិជ្ជកម្មក្រៅប្រទេស។ ដោយនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ កម្ពុជាស្ថិតនៅក្នុងការហ៊ុមព័ទ្ធសេដ្ឋកិច្ចពីបស្ចិមប្រទេស សាធារណរដ្ឋប្រជាមានិតកម្ពុជាមានទំនាក់ទំនងពាណិជ្ជកម្មផ្លូវការ តែជាមួយវៀតណាម សហភាពសូវៀត និងប្រទេសបូកខាងកើតតែប៉ុណ្ណោះ។ កម្ពុជានាំចូលប្រេងឥន្ធនៈ ទំនិញប្រើប្រាស់ និងគ្រឿងចក្រពីសហភាពសូវៀត និងនាំចេញវិញនូវកៅស៊ូ និងកសិផលមួយចំនួនតូចប៉ុណ្ណោះ។ អតុល្យភាពរវាងការនាំចូល និងការនាំចេញ គឺជាបំណុល ដែលកម្ពុជាជំពាក់ប្រទេសដៃគូទាំងនោះ។ និយាយដោយខ្លី គឺកម្ពុជាត្រូវពឹងផ្អែកទាំងស្រុងលើជំនួយពីបរទេសជាពិសេសពីសហភាពសូវៀត។ ក៏ប៉ុន្តែ ពាណិជ្ជកម្មក្នុងប្រទេសមានលក្ខណៈសេរី ដោយអ្នកលក់ និងអ្នកទិញអាចលក់ដូរផលិតផលគ្រប់ប្រភេទលើទីផ្សារ។ ទំនិញទាំងនេះពួកគេនាំចូលតាមរយៈការរត់ពន្ធពីប្រទេសថៃ និងពីសិង្ហបុរី។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ពាណិជ្ជកម្មក្រៅប្រទេស ៖ គួរបញ្ជាក់ដែរថា ទម្រង់គោលនៃទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសរវាងប្រទេសកម្ពុជាជាមួយនឹងសហភាពសូវៀត និងបណ្តាប្រទេសអឺរ៉ុបខាងកើត គឺមានការពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្មក្រៅប្រទេស។ ជាងនេះទៀត ទំហំបម្វាស់ប្តូរទំនិញក្រៅប្រទេសជាមួយនឹងប្រទេសទាំងអស់នោះ មានការកើនឡើងលើសពី២ដងទៅទៀតនៅចន្លោះឆ្នាំ១៩៨០ដល់ឆ្នាំ១៩៨៩ ដែលមានទំហំរហូតដល់ទៅ១៥៦,៣៤ លានរូប្ល។ ក៏ប៉ុន្តែ កំណើនដ៏ធាប់រហ័សនេះបានកើតឡើងដោយសារតែកំណើននៃបម្វាស់ប្តូរទំនិញជាមួយនឹងសហភាពសូវៀត ដែលមានទំហំប្រមាណជា៩១,៣២%ដល់៩៥,៥% ធៀបទៅនឹងបម្វាស់ប្តូរទំនិញជាមួយបណ្តាក្រុមប្រទេសទាំងនេះ។ តាមរយៈខ្លឹមសារនេះ យើងពិនិត្យឃើញថា សហភាពសូវៀត គឺជាដៃគូពាណិជ្ជកម្មដ៏ធំបំផុតក្នុងចំណោមប្រទេសទាំងអស់ខាងលើនេះ។ ហើយបន្ទាប់ពីសហភាពសូវៀត ក៏មានប្រទេសជាបន្តបន្ទាប់ទៀតគឺ ប៉ូឡូញ ឆេកូស្លូវ៉ាគី ប៊ុលហ្គារី និងប្រទេសហុងគ្រីផងដែរ។

ចំពោះចំណាត់ថ្នាក់លេខមួយផ្នែកទំនិញនាំចូលពីសហភាពសូវៀតមកកាន់ប្រទេសកម្ពុជាយើងគឺ គ្រឿងម៉ាស៊ីន និងបរិក្ខារផ្សេងៗទៀត។ ក្នុងឆ្នាំ១៩៨០ ការនាំចូលទំនិញពីស.ស.ស.សស្ទើរតែទាំងអស់ គឺជាគ្រឿងម៉ាស៊ីន បរិក្ខារនានា និងមធ្យោបាយដឹកជញ្ជូន។ នៅឆ្នាំបន្តបន្ទាប់ទៀតក៏មានការកើនឡើង ផងដែរនូវវិស័យដទៃៗទៀត។ ដូចជានៅឆ្នាំ១៩៨៩ វិស័យទាំងនោះបានកើនឡើងដល់៦៧,៧%នៃទំហំនាំចូលសរុប ដែលមានតម្លៃជាទឹកប្រាក់ប្រមាណជា៦១,៣លានរូប្ល។ ការនាំចូលនេះបានគ្របដណ្តប់រហូតដល់ទៅប្រមាណ៦០%នៃតម្រូវការក្នុងស្រុក។ ហើយដោយសារតែ ការផ្តត់ផ្គង់ទំនិញឧស្សាហកម្មពីសហភាពសូវៀត គឺបានធ្វើឱ្យរោងចក្រ និងសហគ្រាសជាច្រើននៅកម្ពុជា ដែលកន្ទង់មកឆ្ងាប់បានបំផ្ទិចបំផ្ទាញដោយរបបប៉ុល ពតត្រូវបានស្តារឱ្យដំណើរការឡើងវិញ។ ម្យ៉ាងទៀត ការផ្តត់ផ្គង់នេះបានបង្កលក្ខណៈដល់ការស្តារវិស័យផងដែរ នូវវិស័យហេដ្ឋា

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយ៉ាងធាប់រហ័ស ក្នុងនោះមាន កំពង់ផែសមុទ្រនៅក្រុងកំពង់សោម កំពង់ផែថ្មទន្លេបួនមុខនៅក្រុងភ្នំពេញ ផ្លូវ អយស្ម័យយាន និងផ្លូវថ្នល់។ យើងគួរកត់សម្គាល់ផងដែរអំពីតួនាទីនៃ ការផ្តត់ផ្គង់ទំនិញពីសហភាពសូវៀតក្នុងការស្តារ និងអភិវឌ្ឍនីវិស័យឧស្សា-ហកម្មជាមពលក្នុងប្រទេសកម្ពុជា។

ចំណាត់ថ្នាក់ទីពីរបានទៅលើវិស័យនាំចូលប្រេងឥន្ធនៈ ដែលផ្តោត ទៅលើប្រេង និងផលិតផលតេលសិលា (ផលិតផលប្រេងកាត) ដែលមាន ការកើនឡើងដល់ទៅពីរដងក្នុងឆ្នាំ១៩៨៩ធៀបនឹងឆ្នាំ១៩៨១ ពោលគឺ ក្នុងទំហំរហូតដល់ទៅ៣១,២លានរូប្ល មានន័យថា ២៤,៣១%នៃទំហំទំនិញ នាំចូលសរុបពីសហភាពសូវៀតក្នុងឆ្នាំនោះដែរ។ ការនាំចូលប្រេង និង ផលិតផលតេលសិលាពីសហភាពសូវៀត គឺបានគ្របដណ្តប់ស្ទើរតែ៩៥% នៃតម្រូវការទំនិញដ៏ចាំបាច់ទាំងអស់នេះ។ ហើយមកដល់ឆ្នាំ១៩៩០ យើង ឃើញថាសហភាពសូវៀតបានធ្វើការផ្តត់ផ្គង់ទំនិញដល់ប្រទេសកម្ពុជា ប្រមាណ២០០លានតោនជាប្រេងឥន្ធនៈ និងផលិតផលតេលសិលា ដែល បំពេញដល់តម្រូវការក្នុងស្រុក មិនត្រឹមតែនៅក្នុងវិស័យសេដ្ឋកិច្ចជាតិ ប៉ុណ្ណោះទេ ក៏ប៉ុន្តែ សម្រាប់បំពេញតម្រូវការក្នុងវិស័យយោធាថែមទៀតផង ពោលគឺ ក្នុងនោះមានតែ៤០%ទៅ៥០% ឬប្រមាណជា៧០ទៅ៨០ពាន់ តោននៃផលិតផលតេលសិលា ដែលសម្រាប់ការបម្រើដល់វិស័យស៊ីវិល។ ក្នុងស្ថានភាពនៃការបញ្ចប់សកម្មភាពលើវិស័យយោធានៅក្នុងប្រទេសយើង ទើបអាចបង្កើនធនធានទាំងអស់នេះ សម្រាប់ការអភិវឌ្ឍដល់វិស័យសេដ្ឋ-កិច្ចទៅបាន។

និនភាពពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជាទាសម័យកាលនោះមាន ស្ថានភាពធ្ងន់ធ្ងរណាស់ ដូចជានៅឆ្នាំ១៩៨៦ ការនាំចេញមានទំហំតែ៨,៨% ប៉ុណ្ណោះធៀបទៅនឹងការនាំចូលទំនិញ ហើយបើគិតជាមធ្យមនៅចន្លោះ ឆ្នាំ១៩៨១-១៩៨៧ ផលធៀបរវាងទំនាក់ទំនងការនាំចេញ-ការនាំចូល គឺ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទទួលបានតែ១៦,៦%តែប៉ុណ្ណោះ។ ជាក់ស្តែង សម្រាប់ឆ្នាំ១៩៨០-១៩៨៩ តុល្យភាពជញ្ជីងពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាមានចរិតលក្ខណៈក្នុងស្ថានភាពអសកម្មភាព ដែលក្នុងចន្លោះឆ្នាំខាងលើនេះ ទិន្នភាពវិស័យពាណិជ្ជកម្មអន្តរជាតិ មានចំនួនរហូតដល់៥១០លានរៀល។ ចំពោះទិន្នភាពពាណិជ្ជកម្មនេះ ត្រូវបានធ្វើហិរញ្ញប្បទាន ដោយឥណទានរបស់ប្រទេសជាដៃគូពាណិជ្ជកម្មរបស់ខ្លួន ជាពិសេសប្រទេសសហភាពសូវៀត។ ម្យ៉ាងវិញទៀត ពួកពាណិជ្ជករឯកជនក៏បានរួមចំណែកជួយសង្គ្រោះចំពោះទិន្នភាពពាណិជ្ជកម្មក្រៅប្រទេសដោយប្រយោលផងដែរ តាមរយៈការផ្ទេរដុំមាស និងរូបិយប័ណ្ណបម្រុងពីបរទេសចូលក្នុងស្រុក។ ក្នុងលក្ខណៈតុល្យភាពពាណិជ្ជកម្មដោយប្រយោលបែបនេះ បានធ្វើឱ្យមានតម្រូវការនូវរូបិយប័ណ្ណ និងសាច់មាសនៅក្នុងប្រទេស ដែលទីបំផុតបានទាមទារនូវការធ្លាក់ចុះតម្លៃប្រាក់រៀលជាប្រចាំ។

ការហ៊ុមព័ទ្ធសេដ្ឋកិច្ចកម្ពុជា ដោយប្រទេសអាស៊ាននិងប្រទេសលោកខាងលិច បានធ្វើឱ្យកម្ពុជាមិនអាចងើបឡើងដោយស្រួលពីរបបខ្មែរក្រហមឡើយ។ ទំនាក់ទំនងសេដ្ឋកិច្ចពាណិជ្ជកម្មជាផ្លូវការជាមួយប្រទេសសមាជិកអាស៊ាន ជាក់ស្តែង គឺគ្មានទោះទេ។ ក៏ប៉ុន្តែ ប្រទេសថៃឡង់ដ៍ និងសិង្ហបុរីគឺបានប្រកាន់យកនូវគោលជំហរមុខពីរ។ ក្នុងផលប្រយោជន៍សេដ្ឋកិច្ចរបស់ខ្លួន ប្រទេសទាំងពីរនេះបានពង្រីកការអភិវឌ្ឍពាណិជ្ជកម្ម រហូតដល់លំដាប់ក្រុមហ៊ុនឯកជន។ លើយបម្វាស់ប្តូរទំនិញជាមួយប្រទេសថៃឡង់ដ៍គឺមានការរីកលូតលាស់យ៉ាងផុសផុល។ ជាក់ស្តែង ក្នុងឆ្នាំ១៩៨០ បម្វាស់ប្តូរទំនិញជាមួយនឹងប្រទេសនេះ មានទំហំប្រហែលជា១០លានបាត (៣៩១ពាន់ដុល្លារ) ក្នុងរយៈពេលមួយខែ។ ដោយគិតទាំងទំនិញរត់ពន្ធគឺមានន័យថា ៤,៦៩លានដុល្លារក្នុងមួយឆ្នាំ។ បើតាមការវាយតម្លៃរបស់យើង តួលេខនេះអាចកើនឡើងចំនួន៦ដង ធៀបនឹងឆ្នាំ១៩៨៥។ សម្រាប់ការនាំចេញទំនិញរបស់កម្ពុជាវិញ គឺមានតម្លៃប្រហែលជាមួយភាគប្រាំនៃ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទំហំបម្វាស់ប្តូរទំនិញសរុប។ ចំណែកឯភាគីប្រទេសថៃបាននាំចេញទំនិញជាច្រើនប្រភេទចូលមកក្នុងប្រទេសកម្ពុជា ផ្តើមចេញពីម្ហូបអាហារគ្រប់មុខ គ្រឿងទេសរហូតដល់យានជំនិះ។ រីឯខាងភាគីកម្ពុជាវិញក៏បាននាំចេញទៅប្រទេសថៃវិញនូវផលិតផលឈើប្រណីត ត្បូងថ្មមានតម្លៃ ត្រីដៀត ត្រីឆ្តើ គ្រឿងសង្ហារឹមធ្វើពីឫស្សីនិងស្ពាន់ ជ័រកៅស៊ូ ព្រមទាំងវត្ថុបុរាណផងដែរ។ គួរបញ្ជាក់ដែរថា ការវិភាគអំពីទំនាក់ទំនងវិស័យពាណិជ្ជកម្មក្រៅប្រទេសទាំងអស់នេះគឺមានសភាពស្មុគស្មាញបំផុត ដោយសារតែមូលហេតុកង្វះទិន្នន័យស្ថិតក្នុងស្រុក។

ចំពោះស្ថានភាពពាណិជ្ជកម្មខាងលើនេះ មានការផ្លាស់ប្តូរយ៉ាងគំហុកចាប់ផ្តើមពីឆ្នាំ១៩៨៩ ដែលអាចពន្យល់បានថា ស្ថានភាពបែបនេះបណ្តាលមកពីមូលហេតុនៃការកើនឡើងនៃចរន្តដំណោះស្រាយបញ្ហានយោបាយកម្ពុជាតាមរយៈការចរចា និងការចាប់ផ្តើមអនុវត្តគោលនយោបាយសេរីភាវូបនីយកម្មសេដ្ឋកិច្ចរបស់រដ្ឋាភិបាលហ៊ុន សែន ក្រោយពីបានធ្វើកំណែទម្រង់គោលនយោបាយ ក្នុងគោលដៅលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ស្របជាមួយគ្នានេះ ការចូលកាន់កាប់អំណាចនៃរដ្ឋាភិបាលថ្មីរបស់ប្រទេសថៃ ក្រោមការដឹកនាំរបស់លោក ធាត់ថៃ ឈុនហាវ៉ាន់ បានប្រកាន់យកនូវគោលនយោបាយ«កែប្រែឥណ្ឌូចិនពីទីលានប្រយុទ្ធទៅជាទីផ្សារ»។ និន្នាការនេះបានធ្វើឱ្យវិនិយោគិនថៃចាប់ផ្តើមចូលមកយកផលរ៉ែត្បូងថ្មមានតម្លៃ យកផលព្រៃឈើ និងធ្វើទំនើបកម្មសហគ្រាសឧស្សាហកម្ម។

ក្រៅពីប្រទេសថៃឡង់ដ៍ និងប្រទេសសិង្ហបុរី យើងសង្កេតឃើញថាប្រទេសកម្ពុជាមានទំនាក់ទំនងផ្នែកពាណិជ្ជកម្មជាមួយនឹងប្រទេសឥណ្ឌា ហុងកុង និងតៃវ៉ាន់ផងដែរ។ ក៏ប៉ុន្តែ ទំហំពាណិជ្ជកម្មមានទ្រង់ទ្រាយតូចបើប្រៀបធៀបទៅនឹងទំហំទំនាក់ទំនងពាណិជ្ជកម្មក្រៅប្រទេសទាំងមូល។ នៅសម័យនោះ ប្រទេសកម្ពុជាបាននាំចេញផលិតផលកសិកម្មមួយចំនួនទៅកាន់ប្រទេសទាំងអស់ខាងលើនេះ ហើយបាននាំចូលគ្រឿងរបស់របរ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រើប្រាស់ផ្សេងៗ គ្រឿងបរិក្ខារអគ្គិសនីនិងអេឡិកត្រូនិក និងសម្ភារសំណង់មកវិញ។

ហេតុដូចនេះ ការអនុវត្តគោលនយោបាយបើកចំហលើវិស័យសេដ្ឋកិច្ចក្រៅប្រទេសបានទាំមកនូវការពង្រឹងស្ថានភាពនយោបាយក្រៅប្រទេសរបស់រដ្ឋកម្ពុជាលើឆាកអន្តរជាតិ និងការបង្កើនទំនុកចិត្តទៅលើរដ្ឋាភិបាលសម័យនោះ។ នៅខែសីហា ឆ្នាំ១៩៩០ រដ្ឋាភិបាលរបស់សហរដ្ឋអាមេរិកក៏បានចេញសេចក្តីប្រកាសចំពោះការត្រៀមជាស្រេចក្នុងការចរចាជាមួយនឹងរដ្ឋាភិបាលហ៊ុន សែន និងការផ្តល់ជំនួយសេដ្ឋកិច្ច។

ការស្តារឡើងវិញវិស័យអប់រំ ៖ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៩២) ដែលដឹកនាំបន្ត ក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យប្រឈមនឹងការខ្វះខាតទាំងស្រុងក្នុងវិស័យអប់រំដូចជា ៖ គ្រូបង្រៀន សម្ភារសិក្សា និងអគារសិក្សាជាដើម។ ការកសាងប្រព័ន្ធអប់រំនៅកម្ពុជានៅពេលនោះត្រូវបានបែងចែកជាបីដំណាក់កាល ៖

ទីមួយ-នៅចន្លោះឆ្នាំ១៩៧៩-១៩៨៥ ប្រព័ន្ធអប់រំចំណេះទូទៅមានរយៈពេល១០ឆ្នាំត្រូវបានអនុវត្តទៅតាមប្រព័ន្ធ៤-៣-៣។ គឺរយៈពេល៤ឆ្នាំនៅបឋមសិក្សា (ថ្នាក់ទី១-៤) ៣ឆ្នាំនៅមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៥-៧) និង៣ឆ្នាំនៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី៨-១០)។

ទីពីរ-នៅចន្លោះឆ្នាំ១៩៨៦-១៩៩៥ ប្រព័ន្ធអប់រំចំណេះទូទៅត្រូវបានបង្កើនរហូតដល់១១ឆ្នាំ ដោយអនុលោមតាមប្រព័ន្ធ៥-៣-៣។

ទីបី-ចាប់តាំងពីឆ្នាំ១៩៩៦មក ប្រព័ន្ធអប់រំរយៈពេល១២ឆ្នាំត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីសម្រេចទិសដៅនៃការបង្កើនម៉ោងបង្រៀន និងពង្រឹងការសិក្សារបស់សិស្ស។

កិច្ចខិតខំប្រឹងប្រែងក្នុងការស្តារ និងកសាងប្រព័ន្ធអប់រំឡើងវិញបានចាប់ផ្តើមនៅខែមីនា-មេសា ឆ្នាំ១៩៧៩ ដោយមានការជ្រើសរើសបុគ្គលិកអប់រំដោយលោក ចាន់ វ៉ែន អតីតរដ្ឋមន្ត្រីនៃក្រសួងអប់រំនាពេលនោះ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដោយក្រសួងអប់រំជាតិត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ៦ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៨០។ ដូច្នេះ ការកសាងប្រព័ន្ធអប់រំឡើងវិញដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងអំឡុងពេលឆ្នាំ១៩៧៩-១៩៩២ ត្រូវចាប់ផ្តើមពីចំណុចសូន្យ។

ការបង្រៀនបានចាប់ផ្តើមឡើងវិញនៅឆ្នាំ១៩៧៩ ក្នុងស្ថានភាពខ្វះខាតសព្វគ្រប់បែបយ៉ាងនៅក្នុងសាលារៀនដែលនៅសេសសល់ពីការបំផ្លិចបំផ្លាញ និងក្នុងថ្នាក់រៀនបណ្តោះអាសន្នប្រក់ស្បឹកស្មៅត ស្បូវ ឬរៀនក្រោមដើមឈើ។ មន្ត្រីរាជការស៊ីវិល និងគ្រូបង្រៀន ដែលរួចផុតពីសេចក្តីស្លាប់បានបង្ហាញពីទឹកចិត្តលះបង់សព្វគ្រប់បែបយ៉ាង រហូតដល់ត្រូវបង្រៀនសូម្បីតែនៅពេលយប់។ គ្រូបង្រៀនដែលនៅសេសសល់ខ្លះបានចាកចេញពីកម្ពុជា ដើម្បីកៀសខ្លួនទៅនៅបរទេស ខ្លះទៀតក៏មកធ្វើជាគ្រូបង្រៀនវិញ ឬក៏ធ្វើការងារក្នុងក្រសួង-ស្ថាប័នផ្សេងទៀត។ ទោះបីជាយ៉ាងនេះក៏ដោយ ក្នុងឆ្នាំសិក្សា១៩៧៩-១៩៨០ គេឃើញមានគ្រូបង្រៀនចំនួន១៣ ៦០០នាក់ ដែលបានបង្រៀនសិស្សចំនួន៨៦៤ ០០០នាក់ (៨៣%នៃចំនួនសិស្សសរុបបានចូលរៀនថ្នាក់ទី១)។

ការបណ្តុះបណ្តាលគ្រូ ៖ ប្រព័ន្ធបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនត្រូវបានបង្កើតឡើងវិញ។ បញ្ហាជាអាទិភាពធំបំផុត គឺការបណ្តុះបណ្តាលគ្រូបង្រៀន និងអ្នកគ្រប់គ្រងអប់រំនៅគ្រប់កម្រិតទាំងអស់។ បន្ទាប់ពីឆ្នាំ១៩៧៩ក្លាម ក្រសួងអប់រំទទួលយកអ្នកណាក៏ដោយ ឱ្យតែស្មគ្រូចិត្តមកបង្រៀន ទោះបីជាពួកគេគ្មានគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីក្លាយជាគ្រូបង្រៀនក៏ដោយ។ «វគ្គបណ្តុះបណ្តាលខ្លី»ត្រូវបានរៀបចំឡើងក្នុងគោលដៅបណ្តុះបណ្តាលនិស្សិត និងអ្នកចេះដឹងដែលនៅសេសសល់មួយចំនួនដែលមានបំណងចង់ក្លាយជាគ្រូបង្រៀន។ បេក្ខជនទាំងនោះភាគច្រើនមានការសិក្សាមិនលើសពីថ្នាក់បឋមសិក្សាឡើយ។ វគ្គសិក្សាមានរយៈពេលពីមួយសប្តាហ៍ទៅបួនខែ។ បេក្ខជនដែលមានការសិក្សាត្រឹមតែរយៈពេលបី

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឆ្នាំនៅបឋមសិក្សា បានទទួលការបណ្តុះបណ្តាលរយៈពេលមួយឆ្នាំដើម្បីក្លាយជាគ្រូបង្រៀនបឋមសិក្សា។ ពាក្យស្លោករបស់ក្រសួងអប់រំនៅទសវត្សរ៍ឆ្នាំ៨០ គឺ ៖ «អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ» ហើយ«ទៅរៀន និងទៅបង្រៀន គឺស្នេហាជាតិ»។ សាលាគរុកោសល្យបានបើកទ្វារក្នុងឆ្នាំ១៩៧៩ ដើម្បីបំប៉ន និងបណ្តុះបណ្តាលគ្រូ។ ជាលទ្ធផល នៅចន្លោះឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៣ គ្រូបង្រៀនចំនួន៣៦ ០០០ នាក់បានទទួលការបណ្តុះបណ្តាល ឬធ្វើវិក្រឹតការដើម្បីការអប់រំនៅបឋមសិក្សា ដោយរួមបញ្ចូលទាំងគ្រូចំនួន៦ ៣៧៨នាក់ ដែលទទួលបានការបណ្តុះបណ្តាល ដើម្បីបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ និងគ្រូចំនួន៤៦៣នាក់ សម្រាប់ការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

វិស័យឧត្តមសិក្សា ៖ ចាប់តាំងពីទសវត្សរ៍ទី៦០មកម្ល៉េះ សហភាពសូវៀតបានផ្តល់ជំនួយដល់កម្ពុជាក្នុងការបណ្តុះបណ្តាលអ្នកបច្ចេកទេស។ នៅឆ្នាំ១៩៦៤ សហភាពសូវៀតបានសាងសង់ និងប្រគល់ជូនដល់ប្រជាជនកម្ពុជានូវវិទ្យាស្ថានបច្ចេកវិទ្យាជាន់ខ្ពស់មិត្តភាពកម្ពុជា-សូវៀត ដែលក្នុងនោះមានមហាវិទ្យាល័យចំនួន៥ ហើយមាននិស្សិតប្រមាណជាងមួយពាន់នាក់សិក្សា។ វិទ្យាស្ថានបានបណ្តុះបណ្តាលអ្នកបច្ចេកទេស សម្រាប់វិស័យឧស្សាហកម្ម កសិកម្ម និងវិស័យសំណង់។ ក្រោយថ្ងៃរំដោះ វិទ្យាស្ថានបច្ចេកវិទ្យាជាន់ខ្ពស់មិត្តភាពកម្ពុជា-សូវៀតបានចាប់ដំណើរការឡើងវិញ តាំងពីខែកញ្ញា ឆ្នាំ១៩៨១។ ក្នុងវិទ្យាស្ថាន ក៏មានបង្រៀនថ្នាក់ត្រៀមបម្រុង ដែលនៅទីនោះ និស្សិតបានសិក្សាជាភាសារុស្សី ហើយនិងមានមហាវិទ្យាល័យ៥ទៀតគឺ មហាវិទ្យាល័យដែលបណ្តុះបណ្តាលវិស្វករសំណង់ វិស្វកររ៉ាមសាស្ត្រ វិស្វករអគ្គិសនី វិស្វករអ៊ែ (កូគព្ភសាស្ត្រ) និងវិស្វករគីមីជាដើម។ ការអប់រំត្រូវបានដឹកនាំបង្រៀនដោយសាស្ត្រាចារ្យសូវៀត។ ក្នុងឆ្នាំ១៩៩០ សាស្ត្រាចារ្យមួយចំនួនត្រូវបានជំនួស ដោយសាស្ត្រាចារ្យខ្មែរ។ ក្នុងឆ្នាំ១៩៩៦ ក្នុងវិទ្យាស្ថានគឺមាននិស្សិតខ្មែរកំពុងសិក្សាចំនួន៨៣៦នាក់ មាន

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សាស្ត្រាចារ្យសូវៀត៨៣នាក់ សាស្ត្រាចារ្យខ្មែរ១២៨នាក់ ដោយរាប់ទាំងអ្នកជំនួយការ និងបុគ្គលិកផងដែរ។

ក្នុងឆ្នាំ១៩៨៥ វិទ្យាស្ថានកសិកម្មភ្នំពេញត្រូវបានស្តារឡើងវិញរួចរាល់ ដោយមាន៤មហាវិទ្យាល័យគឺ មហាវិទ្យាល័យកសិកម្មគីមី បសុវប្បកម្ម វក្ខវប្បកម្ម និងគ្រឿងយន្តកសិកម្ម។ ការសិក្សាបានប្រព្រឹត្តទៅជាភាសារុស្សី ដែលមានសាស្ត្រាចារ្យសូវៀត និងសាស្ត្រាចារ្យខ្មែរយើងជាអ្នកបណ្តុះបណ្តាល។

ការបណ្តុះបណ្តាលវិជ្ជាជីវៈ ៖ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការផ្នែកឥណទាន នៅថ្ងៃ១៤ ខែវិច្ឆិកា ឆ្នាំ១៩៨០ មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជាជាមួយសហភាពសូវៀតក្នុងការផ្តល់ប្រាក់កម្ចីក្នុងទំហំ៥,៥លានរូប្ល ដើម្បីស្តារមជ្ឈមណ្ឌលវិជ្ជាជីវៈ«ទឹកថ្ល»។ ក្នុងខែកុម្ភៈ ឆ្នាំ១៩៨១ មានការចាប់ផ្តើមដំណើរការមជ្ឈមណ្ឌលវិជ្ជាជីវៈខាងលើនេះ ដែលជាមជ្ឈមណ្ឌលវិជ្ជាជីវៈបច្ចេកទេសធំជាងគេបំផុត ក្នុងប្រទេសកម្ពុជា ហើយបានកសាងនូវកម្លាំងកម្មករជំនាញចំនួន ១៤មុខវិជ្ជា។ រវាងឆ្នាំ១៩៨១ដល់ឆ្នាំ១៩៨៦ នៅទីនេះបានបណ្តុះបណ្តាលកម្មករជំនាញចំនួន៦៥១នាក់។ ក្នុងមជ្ឈមណ្ឌលបានបង្រៀនដោយសាស្ត្រាចារ្យសូវៀត១០នាក់ និងសាស្ត្រាចារ្យខ្មែរ៨៩នាក់។

ការបណ្តុះបណ្តាលធនធានមនុស្សនៅបរទេស ៖ សហភាពសូវៀតនិងប្រទេសអឺរ៉ុបខាងកើតបានផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជារាប់ពាន់នាក់ឱ្យទៅសិក្សានៅបរទេស កម្រិតឧត្តមសិក្សា មជ្ឈមសិក្សាបច្ចេកទេស និងកម្មករជំនាញ។ នៅឆ្នាំ១៩៧៩-១៩៩១ និស្សិតកម្ពុជាប្រមាណជាង៦៥០០នាក់ ត្រូវបានបញ្ជូនទៅសិក្សានៅគ្រឹះស្ថានអប់រំកម្រិតមជ្ឈមនិងកម្រិតឧត្តមសិក្សានៅសហភាពសូវៀត (៤៤១៤នាក់) ប៊ុលហ្គារី (១៥៩នាក់) ឆេកូស្លូវ៉ាគី (៣២៦នាក់) អាឡឺម៉ាញ (១៣២៧នាក់) ហុងគ្រី (១៩៥នាក់) ប៉ូឡូញ (៩២នាក់) និងប្រទេសវៀតណាម។ សហភាពសូវៀតបាន

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ផ្តល់ជំនួយច្រើនជាងគេដល់រដ្ឋកម្ពុជាលើវិស័យបណ្តុះបណ្តាលអ្នកឯកទេស។

៣-ការប្រយុទ្ធតស៊ូប្រឆាំងនឹងការវិលត្រលប់នៃរបបប៉ុល ពត

ការជាក់ទណ្ឌកម្មសេដ្ឋកិច្ច ៖ ប្រទេសកម្ពុជាទទួលរងការជាក់ទណ្ឌកម្មសេដ្ឋកិច្ច ក្រោយពីការរលំរលាយរបបខ្មែរក្រហម។ ប្រទេសនេះពុំអាចប្រើប្រាស់គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិបានទេ។ ចំណែក រូបិយវត្ថុរបស់ខ្លួនក៏មិនអាចដូរបានដែរ។ ដោយសារមានជំនួយពីសហភាពសូវៀត វៀតណាម និងប្រទេសជនៃទៀតនៃប្លុកសូវៀត ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលបស្ចិមប្រទេសប្រហែល១៥ ទើបអាចបង្កើនសក្តានុពលឱ្យសាធារណរដ្ឋប្រជាមានិតកម្ពុជាចាប់ផ្តើមស្តារបានសេដ្ឋកិច្ច និងសង្គមឡើងវិញបាន។ ទោះជាមានកិច្ចខិតខំប្រឹងប្រែងយ៉ាងនេះក្តី ក៏គេពុំមានលទ្ធភាពបំពេញចន្លោះប្រហោងដ៏មហិមានៃកង្វះធនធានមនុស្ស ដែលបានបាត់បង់ក្នុងរបបខ្មែរក្រហមនោះបានដែរ។ អាទិភាពដំបូងបំផុតក្នុងការអភិវឌ្ឍគឺផ្តល់ការបណ្តុះបណ្តាល។ ការបង្កើតសាធារណរដ្ឋ ប្រជាមានិតកម្ពុជានៅឆ្នាំ១៩៧៩ស្តែងឱ្យឃើញដំណាក់កាលថ្មីមួយ ក្នុងការស្តារនីតិសម្បទា និងការស្តាបនាប្រទេសឡើងវិញលើគ្រប់វិស័យ។

សង្គ្រាមក្នុងស្រុកនៅបន្ត ៖ ទោះបីជារបបខ្មែរក្រហមផុតរលត់ ក្នុងឆ្នាំ១៩៧៩ យ៉ាងណាក្តី ក៏សង្គ្រាមស៊ីវិលនៅតែអូសបន្លាយបន្តទៀត។ បន្ទាប់ពីមានជំនួបហូរហែរនៅទីក្រុងប៉ារីសរួចមក នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ រដ្ឋាភិបាលចំនួន១៨ ព្រមទាំងភាគីកម្ពុជាទាំងបួនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយគ្រប់ជ្រុងជ្រោយខាងផ្នែកនយោបាយនៃវិបាកកម្ពុជា ដោយមានប្រទេសបារាំងជាអ្នកសម្របសម្រួលកិច្ចព្រមព្រៀងនេះ។ ប៉ុន្តែ ទោះបីមានកិច្ចព្រមព្រៀងក្រោយមកមានការបោះឆ្នោតជាសាកលនៅឆ្នាំ១៩៩៣យ៉ាងណាក្តី ក៏កោលាហលនៅតែបន្តកើតមាន។ លក្ខខណ្ឌតម្រូវដំបូងៗសម្រាប់ការអភិវឌ្ឍពិតប្រាកដ នៅមិនទាន់បាន

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្កើតឱ្យមាននៅឡើយ។ បរិយាកាសអសន្តិសុខនៅមានពាសពេញផ្ទៃប្រទេស។ ដោយសារគោលនយោបាយ"ឈ្នះ-ឈ្នះ" ដើម្បីការផ្សះផ្សាជាតិនៅឆ្នាំ១៩៩៧ ដែលផ្តួចផ្តើមឡើងដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទីបញ្ចប់របបខ្មែរក្រហមត្រូវបានបញ្ចប់ និងអង្គការយោធា និងនយោបាយនៃរបបនេះក៏ត្រូវបានរំលាយចោល។

ប៉ុន្តែ ប្រទេសកម្ពុជាទទួលរងគ្រោះយ៉ាងធ្ងន់ដោយសារសង្គ្រាម និងការនៅឯកោពីសហគមន៍អន្តរជាតិ។ ពិសេសជាងគេ ការខូតខាតផ្នែកសង្គមមានទំហំធំធេងណាស់។ នៅដើមទសវត្សរ៍ទី៩០ ប្រទេសកម្ពុជាមានអត្រាមរណភាពទារកកម្រិតខ្ពស់ជាងគេនៅលើពិភពលោក។ បើប្រៀបធៀបគ្នាទៅនឹងប្រទេសអាហ្វ្រិក និងឥណ្ឌា អត្រាមរណភាពចំពោះស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលសម្រាលទារកនៅកម្ពុជា មានចំនួនលើសគេទ្វេដង។ មិនតែប៉ុណ្ណោះ ប្រទេសកម្ពុជាមានអត្រាជនពិការខ្ពស់ជាងគេ និងករណីជំងឺរបេងច្រើនជាងគេនៅលើពិភពលោកផងដែរ។ ប្រជាជនជនបទតែ១៦%ប៉ុណ្ណោះមានទឹកស្អាតប្រើប្រាស់។ នៅកន្លែងខ្វះនៅជនបទ ចំនួនអ្នកចុះឈ្មោះចូលរៀនមានស្ទើរមិនដល់៣០%ផង។

ដើម្បីលើកកម្ពស់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពផ្នែកវិនិយោគខាងកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដោយផ្តោតជាពិសេសលើការដឹកជញ្ជូន និងទូរគមនាគមន៍ ថាមពលអគ្គិសនី ការអភិវឌ្ឍធនធានមនុស្ស សកម្មភាពអតិពលកម្ម ព្រមទាំងផលិតផលពោងចក្រសម្រាប់នាំចេញ និងទេសចរណ៍។ គោលនយោបាយនេះមានគោលបំណងបង្កើតមូលដ្ឋានគ្រឹះដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំពូក១៣
រដ្ឋកម្ពុជា និងដំណើរការស្វែងរកសន្តិភាពនៅកម្ពុជា (១៩៨៩-១៩៩២)

១-ការរកដំណោះស្រាយបញ្ហាកម្ពុជា ដោយសន្តិវិធី

មូលហេតុអ្វីបានជាចាំបាច់រកដំណោះស្រាយបញ្ហាកម្ពុជាដោយសន្តិវិធី?

មតិមួយចំនួនចាត់ទុកសង្គ្រាមនៅឥណ្ឌូចិនលើកទី៣ថា ជា«សង្គ្រាមដែលភាគីកម្ពុជាទាំង៤ ច្បាំងគ្នាជំនួសការប្រណាំងប្រជែងរវាងមហាអំណាចក្នុងពិភពលោក» (Proxy wars) ជាពិសេសរវាងចិន និងសហភាពសូវៀត និងរវៀងសហភាពសូវៀត និងសហរដ្ឋអាមេរិក។ «បញ្ហាកម្ពុជា»បានក្លាយជារបៀបវារៈនៃការប្រជុំក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ ចលនាមិនចូលបក្សសម្ព័ន្ធ និងវេទិកាអន្តរជាតិដទៃទៀត។

កត្តាខាងក្នុង ៖ សង្គ្រាមក្នុងស្រុករវាងភាគីកម្ពុជាដែលផ្ទុះឡើងនៅឆ្នាំ១៩៧០ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចសីហនុ បានបន្តជិតម្ភៃឆ្នាំ និងរបបប្រល័យពូជសាសន៍ ប៉ុល ពត បានធ្វើឱ្យជនជាតិកម្ពុជាជិត៦លាន អ្នកបាត់បង់ជីវិត ជនជាតិកម្ពុជារាប់សែននាក់ក្លាក់ខ្លួនពិការ និងក្លាយជាកុមារកំព្រា។ ជីវភាពរបស់ប្រជាជនរស់កាន់តែវេទនា និងដុនដាបទៅ។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម ជាពិសេសផ្លូវថ្នល់ ស្ពាន សាលារៀន

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

មន្ទីរពេទ្យកាន់តែដុនដាបទៅៗ ភាគីកម្ពុជាទាំងអស់ លើកលែងតែពួកខ្មែរក្រហមយល់ថា ស្ថានភាពនេះគឺជាស្ថានភាពគ្មានអ្នកឈ្នះ និងគ្មានអ្នកចាញ់ដែរ ហើយមានតែការចរចាប៉ុណ្ណោះ ទើបអាចរកដំណោះស្រាយទាំងស្រុងលើបញ្ហាកម្ពុជាបាន។

កត្តាខាងក្រៅ ៖ សង្គ្រាមត្រជាក់ជំរុញសហភាពសូវៀត ឱ្យប្រណាំងប្រជែងជាមួយសហរដ្ឋអាមេរិក ដែលចងសម្ព័ន្ធភាពយុទ្ធសាស្ត្រជាមួយចិន នៅក្នុងទំនាក់ទំនងត្រីកោណដ៏ស្មុគស្មាញនេះ។ ចាប់តាំងពីការធ្វើកំណែទម្រង់សេដ្ឋកិច្ច និងនយោបាយផ្ទៃក្នុងនៃសហភាពសូវៀត លោក Michail Gobatchev បានចាប់ផ្តើមចរចាជាមួយលោក Ronald Reagan ដើម្បីកាត់បន្ថយគ្រឿងសព្វាវុធ និងជាមួយនឹងថ្នាក់ដឹកនាំចិន ដើម្បីដោះស្រាយបញ្ហាព្រំដែន និងធ្វើប្រក្រតីភាវូបនីយកម្មនៃទំនាក់ទំនងសូវៀត និងចិន។

កំណែទម្រង់សេដ្ឋកិច្ច និងការកែប្រែនយោបាយក្រៅប្រទេសនៅសហភាពសូវៀត ការកែលម្អទំនាក់ទំនងរវាងសហភាពសូវៀតជាមួយនឹងសហរដ្ឋអាមេរិក និងប្រក្រតីភាវូបនីយកម្មនៃទំនាក់ទំនងរវាងសហភាពសូវៀត និងចិនបានជំរុញឱ្យភាគីកម្ពុជាខិតខំស្វែងរកដំណោះស្រាយនយោបាយលើបញ្ហាកម្ពុជា។ ដំណោះស្រាយបញ្ហាកម្ពុជាបានក្លាយជាលក្ខខណ្ឌនៃប្រក្រតីភាវូបនីយកម្ម ក្នុងទំនាក់ទំនងរវាងសហភាពសូវៀត និងចិន ហើយក៏ជាបញ្ហាមួយនៅក្នុងប្រក្រតីភាវូបនីយកម្ម ក្នុងទំនាក់ទំនងរវាងវៀតណាម និងសហរដ្ឋអាមេរិកផងដែរ។

នៅក្នុងតំបន់ វៀតណាមបានចាប់ផ្តើមចរចា ដើម្បីធ្វើប្រក្រតីភាវូបនីយកម្មជាមួយសហរដ្ឋអាមេរិក។ ម្យ៉ាងវិញទៀត ប្រទេសអាស៊ានបានដាក់ចេញនូវសេចក្តីផ្តួចផ្តើមជាច្រើនសំដៅរកដំណោះស្រាយនយោបាយលើបញ្ហាកម្ពុជា។ បញ្ហាកម្ពុជាត្រូវបានក្លាយជាប្រធានបទនៃការពិភាក្សានៅក្នុងកិច្ចប្រជុំអាស៊ាននៅគ្រប់កម្រិតទាំងអស់ ជាពិសេសនៅក្នុងកិច្ចប្រជុំអង្គការសហប្រជាជាតិ និងចលនាមិនចូលបក្សសម្ព័ន្ធ។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កំណែទម្រង់សេដ្ឋកិច្ចនៅចិន និងនៅសហភាពសូវៀត ៖ នៅឆ្នាំ ១៩៧៨ លោក តេង ស៊ាវពីង បានឡើងកាន់អំណាចជាអគ្គលេខាបក្សកុម្មុយនិស្តចិន។ លោកបានប្រកាសធ្វើកំណែទម្រង់សេដ្ឋកិច្ចចិន ដោយបង្កើតនូវសេដ្ឋកិច្ចទីផ្សារសង្គមនិយម ៖ (១) បង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅទីក្រុង Shenzhen ជិតហុងកុង ដើម្បីទាក់ទាញវិនិយោគពីបរទេស (២) អនុញ្ញាតឱ្យប្រជាជនចិនបង្កើតក្រុមហ៊ុនឯកជន និងធ្វើកសិកម្មជាលក្ខណៈជន (៣) បង្កើតទីផ្សារសេរីសម្រាប់លក់ផលិតផលតាមថ្លៃទីផ្សារ ព្រមព្រៀងរវាងអ្នកទិញ និងអ្នកលក់ ស្របទៅតាមយន្តការនៃទីផ្សារសេរី (៤) រក្សារបបនយោបាយគ្រប់គ្រងដោយបក្សកុម្មុយនីស្តដដែល។ លោកបានបញ្ជូននិស្សិតចិនឱ្យទៅរៀននៅបរទេស ជាពិសេស នៅសហរដ្ឋអាមេរិក និងអឺរ៉ុប ក្នុងគោលដៅអភិវឌ្ឍធនធានមនុស្ស និងទទួលយកនូវចំណេះដឹង និងបច្ចេកវិទ្យាថ្មី។ ៦០ឆ្នាំក្រោយមក ចិនបានក្លាយជាមហាអំណាចសេដ្ឋកិច្ចទី២លើសកលលោក។ នៅឆ្នាំ១៩៨៥ អគ្គលេខាបក្សកុម្មុយនីស្តសូវៀត Gorbachev បានចាប់ផ្តើមធ្វើកំណែទម្រង់សេដ្ឋកិច្ច និងនយោបាយ (Perestroika) ទាំងការបើកទូលាយ (Glasnost)។ កំណែទម្រង់នៅសហភាពសូវៀតនេះធ្វើឱ្យមានការបែកបាក់គ្នាក្នុងបក្ស និងនាំឱ្យសហភាពដួលរលំទៅជាសាធារណរដ្ឋឯករាជ្យ។

ប្រទេសមហាអំណាចចរចាកាត់បន្ថយការប្រឈមមុខដាក់គ្នា ៖ វិបត្តិសេដ្ឋកិច្ចរបស់សហភាពសូវៀត និងប្រទេសសង្គមនិយមនៅអឺរ៉ុបខាងកើតបានជំរុញឱ្យមេដឹកនាំសូវៀត និងសហរដ្ឋអាមេរិកជួបគ្នាជាច្រើនលើកច្រើនសាចាប់ពីឆ្នាំ១៩៨៧ ដើម្បីបញ្ឈប់ការរត់ប្រណាំងសព្វាវុធ និងដាក់ចេញនូវគោលនយោបាយចរចាបញ្ចប់សង្គ្រាមត្រជាក់ និងបញ្ចប់សង្គ្រាមនៅតាមប្រទេសតតិយលោក (Proxy wars) រវាងកាតីគាំទ្រដោយសហភាពសូវៀត និងកាតីគាំទ្រដោយសហរដ្ឋអាមេរិក។ ទន្ទឹមនឹងនេះ នៅកម្រិតពិភពលោក ជំនួបកំពូលផ្សេងទៀតបានប្រព្រឹត្តទៅ ដើម្បីធ្វើប្រក្រតីភាវូប-

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នីយកម្មក្នុងទំនាក់ទំនងអន្តរជាតិរវាងប្រទេស ដូចជារវាងសហភាពសូវៀត និងចិន។ នៅកម្រិតតំបន់ ជំនួបនៅទីក្រុងហូជីមិញរវាងឥណ្ឌូណេស៊ីតំណាងឱ្យអាស៊ាន និងវៀតណាមតំណាងឱ្យឥណ្ឌូចិន បានប្រព្រឹត្តទៅនៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ១៩៨៧ សំដៅដោះស្រាយបញ្ហាកម្ពុជា កាត់បន្ថយការប្រឈមមុខជាក់គ្នា និងពង្រឹងសន្តិភាព និងស្ថិរភាពនៅក្នុងតំបន់។

ការដួលរលំរបបកុម្មុយនីស្តនៅអឺរ៉ុប ៖ បន្ទាប់ពីមានកំណែទម្រង់សេដ្ឋកិច្ច និងនយោបាយនៅសហភាពសូវៀត នៅឆ្នាំ១៩៨៩ ប្រទេសហុងគ្រីបានបើកចំហព្រំដែនជាមួយអូទ្រីស ហើយក្នុងខែវិច្ឆិកា ឆ្នាំ១៩៨៩ ហ្វូងយុវជនអាឡឺម៉ង់ខាងកើតបានសម្រុកឆ្លងកំពែងប៊ែរឡាំងទៅកាន់ប្រទេសអាឡឺម៉ង់លិច ហើយធ្វើឱ្យរបងប៊ែរឡាំងដួលរលំ។ នៅឆ្នាំ១៩៩០ ប្រទេសអាឡឺម៉ង់ទាំងពីរបានរួបរួមគ្នាឡើងវិញ។ នៅឆ្នាំ១៩៩១ ក្រោយពីរដ្ឋប្រហារមិនបានសម្រេច លោក Gorbachev បានលាលែងពីតំណែង ហើយផ្ទេរអំណាចទៅឱ្យលោក Yeltsin វិញ។ សហភាពសូវៀតបានបែក-បាក់ជាដុំៗ ហើយក្លាយជារដ្ឋឯករាជ្យ។

២-របត់នយោបាយក្នុងប្រទេស ដើម្បីបង្រួបបង្រួមជាតិ

គោលនយោបាយបង្រួបបង្រួមជាតិ ៖ នៅថ្ងៃទី៦៧ ខែសីហា ឆ្នាំ ១៩៨៧ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានដាក់ចេញគោលនយោបាយបង្រួបបង្រួមជាតិ៦ចំណុច ក្នុងគោលដៅត្រៀមចរចាជាមួយសម្តេចនរោត្តម សីហនុ ដើម្បី ៖ (១) បង្រួបបង្រួមជាតិ (២) ដោយឈរលើមូលដ្ឋាននៃការទប់ស្កាត់ការវិលត្រលប់មកវិញនៃរបបប៉ុល ពត និង(៣) ការពារនូវសមិទ្ធផលដែលសម្រេចបានកន្លងមក។

កំណែទម្រង់នយោបាយនិងសេដ្ឋកិច្ច ៖ ពីថ្ងៃទី៤ដល់១៦ ខែមេសា ឆ្នាំ១៩៨៩ សន្និបាតកម្មាភិបាលទូទាំងប្រទេសលើកទី២បានអនុម័តគោល-នយោបាយត្រប់ត្រង់ និងប្រើប្រាស់ដីធ្លី គោលនយោបាយដឹកជញ្ជូន

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឯកជន គោលនយោបាយចំពោះកសិករ គោលនយោបាយចំពោះផលិតកម្ម-អាជីវកម្មកសិកម្មតាមរបៀបប្រពៃណី គោលនយោបាយចំពោះឧស្សាហកម្មធុនតូច និងសិប្បកម្ម។ គោលនយោបាយទាំងនេះសំដៅកែលម្អការគ្រប់គ្រងសេដ្ឋកិច្ចកម្ពុជា បង្កលក្ខណៈសម្បត្តិឱ្យគ្រប់សមាសភាពសេដ្ឋកិច្ចធ្វើសកម្មភាព លើកទឹកចិត្តសេដ្ឋកិច្ចឯកជនឱ្យចូលរួមកសាងសេដ្ឋកិច្ចជាតិ ទាក់ទាញការវិនិយោគពីបរទេស ជំរុញការកសាងខឿនសេដ្ឋកិច្ចទីផ្សារលើកស្ទួយជីវភាពប្រជាជន កសាងសង្គមមានយុត្តិធម៌ ប្រជាធិបតេយ្យ និងវឌ្ឍនភាព។

ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងការបង្កើតរដ្ឋកម្ពុជា ៖ កំណែទម្រង់រដ្ឋដ៏ធំមួយ ក្រោមការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នៅថ្ងៃ២៩ ខែមេសា ឆ្នាំ១៩៨៩។ ចំណុចសំខាន់ៗនៃវិសោធកម្មរដ្ឋធម្មនុញ្ញនេះមានដូចតទៅ ៖ (១) ការផ្លាស់ប្តូរឈ្មោះប្រទេសពីសាធារណរដ្ឋប្រជាមានិតកម្ពុជាទៅជារដ្ឋកម្ពុជា ដែលបង្ហាញពីឆន្ទៈងាកទៅរកឈ្មោះដើមរបស់កម្ពុជាមុនពេលមានរដ្ឋប្រហារឆ្នាំ ១៩៧០ (២) ការប្រកាសដកខ្លួនចេញពីរបបសង្គមនិយម (៣) ការទទួលស្គាល់កម្មសិទ្ធិឯកជន និងរបបទីផ្សារសេរី (៤) ទទួលស្គាល់ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ (៥) ការផ្លាស់ប្តូរទង់ជាតិ ភ្លេងជាតិ (៦) ការលុបចោលច្បាប់ប្រហារជីវិត។ នៅក្នុងនយោបាយក្រៅប្រទេស រដ្ឋធម្មនុញ្ញថ្មីបានចែងថាកម្ពុជាគឺជារដ្ឋអព្យាក្រឹត (ក្នុងទំនាក់ទំនងអន្តរជាតិ) និងមិនចូលបក្សសម្ព័ន្ធ។ វិសោធនកម្មរដ្ឋធម្មនុញ្ញនេះមានគោលដៅជំរុញការចរចាដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជាដោយសន្តិវិធី។

ការបង្កើតឱ្យមានកម្មសិទ្ធិឯកជន និងទីផ្សារសេរី ៖ ដើម្បីត្រៀមចរចារកសន្តិភាព លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានរៀបចំកំណែទម្រង់សេដ្ឋកិច្ចក្នុងគោលដៅធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ច និងបង្កើតមូលដ្ឋានសម្រាប់សេដ្ឋកិច្ចទីផ្សារ ដោយងាកចេញពីម៉ូដែលសេដ្ឋកិច្ចសង្គមនិយម

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាពិសេសការបង្កើតឱ្យមានកម្មសិទ្ធិឯកជនលើដីធ្លី និងអចលនទ្រព្យ ការទាក់ទាញវិនិយោគទុនពីបរទេស និងបង្កើតឱ្យមានក្រុមហ៊ុនរដ្ឋចម្រុះឯកជន និងក្រុមហ៊ុនឯកជន។

ការទាក់ទាញវិនិយោគពីបរទេស ៖ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ច្បាប់ស្តីពីការវិនិយោគបរទេសត្រូវបានអនុម័ត ដែលបានក្លាយជាចំណុចរបត់ថ្មីមួយនៃគោលនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជា។ ច្បាប់នេះមានគោលដៅលើកទឹកចិត្តចំពោះវិនិយោគទុនបរទេស ក្រុមហ៊ុន និងអ្នកវិនិយោគទាំងឡាយណា ដែលមានបំណងចង់មកដាក់ទុនវិនិយោគក្នុងប្រទេសកម្ពុជា ក្នុងគោលដៅជំរុញល្បឿនការអភិវឌ្ឍសេដ្ឋកិច្ច។ ប្រទេសកម្ពុជាបានចាប់ផ្តើមកាត់បន្ថយតួនាទីរដ្ឋ ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច ដោយជំនួសដោយយន្តការសេដ្ឋកិច្ចទីផ្សារ តាមរយៈការធ្វើឯកជនភាវូបនីយកម្ម សហគ្រាសរដ្ឋ បើកឱកាសឱ្យក្រុមហ៊ុនឯកជន ពង្រីកសកម្មភាពក្នុងពាណិជ្ជកម្មអន្តរជាតិ។

ច្បាប់ស្តីពីការវិនិយោគបរទេស ឆ្នាំ១៩៩៩ អនុញ្ញាតឱ្យមានការបើកជាក្រុមហ៊ុនបរទេស ការរួបរួមពីពាណិជ្ជករបរទេស និងអាណិកជនខ្មែរដែលរស់នៅបរទេសឱ្យចូលមកកម្ពុជាដោយសេរីមកចូលរួមកសាងសេដ្ឋកិច្ចកម្ពុជា។ ច្បាប់ថ្មីនេះបានកំណត់ទម្រង់នៃកិច្ចសហប្រតិបត្តិការជាបីសណ្ឋាន ជាមួយនឹងក្រុមហ៊ុនបរទេសដូចខាងក្រោមនេះ ៖ (១) ការបង្កើតជាសហគ្រាសសហកម្មសិទ្ធិ (ចម្រុះ) (២) ការបង្កើតជាសហគ្រាសដោយប្រើប្រាស់មូលធនបរទេសសុទ្ធ និង (៣) កិច្ចសហប្រតិបត្តិការកិច្ចព្រមព្រៀង។ ដៃគូបរទេសត្រូវដាក់ទុនមិនតិចជាង៣០%នៃទំហំវិនិយោគសរុប ប៉ុន្តែគេអាចពង្រីកទំហំភាគហ៊ុនបន្ថែមដោយគ្មានកំហិតណាមួយ។ ភាគទុនិកបរទេសមានសិទ្ធិក្នុងការរៀបចំក្បាលម៉ាស៊ីនគ្រប់គ្រងសហគ្រាសរបស់ខ្លួន ឬក៏អញ្ជើញអ្នកជំនាញបរទេស ឬអ្នកបច្ចេកទេសឱ្យចូលមកជួយរៀបចំចាត់ចែងអាជីវកម្មរបស់ខ្លួន។ ក្រៅពីនោះ ច្បាប់ក៏បានចែងអំពីទម្រង់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៃការវិនិយោគ ដូចជាការវិនិយោគជារូបិយប័ណ្ណសុទ្ធ ឬក៏ជាសម្ភារផលិតកម្ម។ ដៃគូបរទេសត្រូវតែប្រើប្រាស់សាច់ប្រាក់ជារូបិយប័ណ្ណដុល្លារ និងប្រើប្រាស់នូវគ្រឿងបរិក្ខារផលិតកម្ម គ្រឿងសំណង់ ស៊ីម៉ងត៍ និងផ្សេងៗទៀត ដោយធ្វើការនាំចូលតាមរយៈច្បាប់ជាអាជ្ញាប័ណ្ណ និងបង់ពន្ធប៉ាតង់ត្រឹមត្រូវ។

សហគ្រាសវិនិយោគអាចទទួលការអនុគ្រោះពន្ធយ៉ាងច្រើន ឬក៏លើកលែងពន្ធទាំងស្រុង ក្នុងចំរវេលាពីរឆ្នាំរហូតដល់សហគ្រាសចាប់ផ្តើមទទួលបានប្រាក់ចំណេញ។ ក្នុងករណីពិសេស រយៈពេលអនុគ្រោះពន្ធអាចបន្តថែមពីរឆ្នាំបន្តទៀត។ វិនិយោគិនបរទេសអាចធ្វើការបណ្តាក់ទុនវិនិយោគរបស់ខ្លួនលើគ្រប់វិស័យសេដ្ឋកិច្ចទាំងអស់ ដែលគេមានបំណង។ ដៃគូវិនិយោគិនបរទេស មានសិទ្ធិក្នុងការផ្ទេរប្រាក់ចំណេញទៅក្រៅប្រទេស ដោយត្រូវជាប់ពន្ធប្រាក់ចំណេញតែពី៥%ទៅ១០%ប៉ុណ្ណោះ។ បុគ្គលិកបរទេសក៏អាចផ្ទេរប្រាក់បៀវត្សរបស់ខ្លួនទៅក្រៅប្រទេសដោយគ្មានការបង់ពន្ធក្រោយពេលគេបានបង់ពន្ធលើប្រាក់ចំណូលរួចរាល់ ស្របតាមច្បាប់របស់ប្រទេសកម្ពុជា។

ការហូរចូលវិនិយោគពីបរទេស ៖ បន្ទាប់ពីការអនុម័តច្បាប់វិនិយោគនេះមក នៅឆ្នាំ១៩៩៩ មានក្រុមហ៊ុនបរទេសជាច្រើនបានមកវិនិយោគទុននៅកម្ពុជា។ ក្រុមហ៊ុនជប៉ុនឈ្មោះ អូកាដា ឌូហ្គិនកូ បានធ្វើការសាង់សង់រោងចក្រអារឈើ ដើម្បីនាំចេញ។ អណិកជនខ្មែរនៅបរទេសក៏បានចុះកិច្ចសន្យាស្តីអំពីការជួសជុលសណ្ឋាគារ«កាំបូឌីយ៉ាណា» ក្នុងទំហំទឹកប្រាក់ចំនួន ១០លានដុល្លារ។ ទំហំវិនិយោគបរទេសនៅកម្ពុជានៅឆ្នាំ១៩៩០បានកើនឡើងពី០ដល់៣៥លានដុល្លារអាមេរិក ដែលក្នុងនោះ ទំហំចំណែករបស់ប្រទេសជប៉ុនមានប្រហែល៧%នៃការវិនិយោគបរទេសសរុប។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

៣-ដំណើរការចរចាដើម្បីដោះស្រាយបញ្ហាកម្ពុជា

ជំនួបចរចាកសន្តិភាពនៅកម្ពុជា

កត្តាផ្ទៃក្នុងប្រទេស និងដំណោះស្រាយរវាងខ្មែរ និងខ្មែរ គឺជាគន្លឹះនៃការបញ្ចប់សង្គ្រាមផ្ទៃក្នុង ដែលអូសបន្លាយអស់ជាច្រើនទសវត្សរ៍មកហើយ។

លោកស្រី ពុង ឈីវកេក ដែលជាភរិយារបស់អ្នកការទូតបារាំងចូលនិវត្តន៍បានជួបជាមួយលោក ហ៊ុន សែន នៅប្រទេសអង់ហ្គោឡា ហើយបានផ្តួចផ្តើមរៀបចំឱ្យមានជំនួបដំបូងៗរវាងសម្តេចសីហនុ និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅតំបន់ Fère-en-Tardenois នៃប្រទេសបារាំង កាលពីឆ្នាំ១៩៨៧។ លោកស្រី ពុង ឈីវកេក និងស្វាមីដើរតួនាទីជា«ប្រអប់សំបុត្រ» សម្រាប់ទំនាក់ទំនងរវាងសម្តេចសីហនុ និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ នៅខែឧសភា ឆ្នាំ១៩៨៧ សម្តេចសីហនុបានលាលែងពីប្រមុខរដ្ឋាភិបាលត្រីភាគី ដើម្បីព្រះអង្គមានសេរីភាពទូលំទូលាយ ក្នុងការចរចាជាមួយសម្តេចហ៊ុន សែន។ ជាការឆ្លើយតប នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ ១៩៨៧ សាធារណរដ្ឋប្រជាមានិតកម្ពុជាបានដាក់ចេញនយោបាយបង្រួបបង្រួមជាតិ ដោយបើកផ្លូវចរចាជាមួយភាគីខ្មែរផ្សេងទៀត លើកលែងតែជាមួយភាគីខ្មែរក្រហម។ សម្តេចសីហនុ និងសម្តេចហ៊ុន សែនបានជួបចរចាគ្នាជាច្រើនលើក មុននឹងសម្រេចបាននូវដំណោះស្រាយចុងក្រោយ ៖

- ជំនួបសីហនុ-ហ៊ុន សែន លើកទី១ ៖ នៅ Fère-en-Tardenois ប្រទេសបារាំង នៅថ្ងៃទី២-៤ ខែធ្នូ ឆ្នាំ១៩៨៧។ លោក ហ៊ុន សែនបានស្នើបញ្ហាដូចតទៅ ៖ (១) ជម្លោះនៅកម្ពុជាចាំបាច់ត្រូវដោះស្រាយតាមផ្លូវនយោបាយ (២) បញ្ហាកម្ពុជាចាំបាច់ត្រូវដោះស្រាយដោយកម្ពុជាខ្លួនឯងតាមរយៈការចរចារវាងភាគីខ្មែរដែលមានជម្លោះ ដើម្បីបញ្ចប់សង្គ្រាមបង្ហូរឈាមនាំដល់ការបង្រួបបង្រួមជាតិ សន្តិភាព ប្រជាធិបតេយ្យ ឯករាជ្យ អធិបតេយ្យភាព អព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធរបស់កម្ពុជា (៣) ភាគីទាំងពីរស្រុះស្រួលគ្នាអនុវត្តការបង្រួបបង្រួមជាតិ ក៏ប៉ុន្តែ មិនត្រូវឱ្យរបប

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប៉ុល ពត ឬរបបលន់ នល់វិលត្រលប់មកវិញឡើយ (៦) កងទ័ពវៀតណាម ត្រូវដកឱ្យអស់ពីកម្ពុជា នៅឆ្នាំ១៩៩០ ក៏ប៉ុន្តែ ប្រសិនបើមានដំណោះស្រាយ នយោបាយ កងទ័ពវៀតណាមអាចនឹងដកអស់នៅឆ្នាំ១៩៨៨ ឬ១៩៨៩ (៥) សន្និសីទអន្តរជាតិត្រូវរៀបចំឡើង ដើម្បីជានាទូវកិច្ចព្រមព្រាងរវាង ភាគីខ្មែរ (៦) ប្រទេសជិតខាងត្រូវទទួលស្គាល់ព្រំដែនកម្ពុជា តាមរយៈ កិច្ចព្រមព្រៀងព្រំដែនដែលមានស្រាប់ (៧) ក្រោយការដកទ័ពវៀតណាម អស់ពីកម្ពុជា ត្រូវចាត់តាំងការបោះឆ្នោត ដោយមានអ្នកសង្កេតការណ៍ បរទេស ដើម្បីជ្រើសតាំងរដ្ឋសភា និងបង្កើតរដ្ឋាភិបាលចម្រុះដែលមាន ភាគីទាំង៤ចូលរួម (៧) មាតុភូមិនិវត្តន៍នៃជនភៀសខ្លួន។ ជំនួបសីហនុ-ហ៊ុន សែន លើកទី១បានចេញសេចក្តីថ្លែងការណ៍បួនចំណុច ៖ ផ្តោតលើ ការដកកងទ័ពវៀតណាមចេញពីកម្ពុជា និងការកសាងកម្ពុជា ដែលសេរី ឯករាជ្យ អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ និងសន្តិភាព។

-ជំនួបសីហនុ-ហ៊ុន សែន លើកទី២ ៖ នៅ Saint Germain-en-Laye ប្រទេសបារាំង នៅខែមករា ឆ្នាំ១៩៨៨ បានពិភាក្សាលើ ៖ (១) ប្រតិទិន ដកកងទ័ពវៀតណាម (២) បញ្ហាកម្លាំងប្រដាប់អាវុធខ្មែរក្រហម (៣) ការបង្កើតរដ្ឋាភិបាលចម្រុះ (៤) របបនយោបាយអនាគតរបស់កម្ពុជា (៥) ការធានា និងការត្រួតពិនិត្យអន្តរជាតិ។

ពាក់ព័ន្ធនឹងការដកកងទ័ពវៀតណាម ៖ សម្តេចសីហនុទាមទារដក កងទ័ពវៀតណាម ក្នុងឆ្នាំ១៩៨៨ យឺតបំផុត១៩៨៩ ទោះបីបណ្តាភាគី កម្ពុជាមានការព្រមព្រៀង ឬមិនព្រម ហើយមិនទទួលពិភាក្សាប្រតិទិន ដកកងទ័ពវៀតណាម ក្នុងក្របខ័ណ្ឌនៃដំណោះស្រាយនយោបាយមួយទេ ហើយបដិសេធការផ្សារភ្ជាប់បញ្ហាដកទ័ពជាមួយការកម្ចាត់កម្លាំងប្រដាប់ អាវុធរបស់ប៉ុល ពត។ លោក ហ៊ុន សែន បានដាក់ប្រតិទិនដកកងទ័ពវៀត-ណាមក្នុងរង្វង់៦ខែ ដែលត្រូវដំណើរការក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀង ដែលផ្សារភ្ជាប់ជាមួយការរំលាយចោលកម្លាំងយោធារបស់ខ្មែរក្រហម និង

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការបញ្ចប់ការជ្រៀតជ្រែកប្រើប្រាស់ទឹកដីប្រទេសក្រៅប្រទាំងកម្ពុជា។

ពាក់ព័ន្ធនឹងរដ្ឋាភិបាលចម្រុះ ៖ សម្តេចសីហនុលើកឡើងថា ភាគីផ្សេងទៀតនឹងមិនទទួលការកម្ចាត់កងកម្លាំងប្រដាប់អាវុធរបស់ប៉ុល ពត ហើយក៏នឹងមិនទទួលការបញ្ជូនកម្លាំងរក្សាសន្តិសុខអន្តរជាតិមកកម្ពុជា។ ដូច្នេះ ចាំបាច់ត្រូវបង្កើតរដ្ឋាភិបាលចម្រុះដែលមានសមាសភាព៤។ ប្រសិនមានការគំរាមកំហែងពីខាងកម្លាំងប្រដាប់អាវុធខ្មែរក្រហម កងទ័ពសីហនុនឹងសហការជាមួយកងទ័ពហ៊ុន សែនដើម្បីប្រទាំង។ សម្តេចស្នើបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នមួយ ដើម្បីរៀបចំការបោះឆ្នោត ដែលមានសីហនុធ្វើជាប្រមុខ និងហ៊ុន សែន ធ្វើជានាយករដ្ឋមន្ត្រី ប្រសិនបើភាគីផ្សេងទៀតមិនចូលរួម។ តែសម្តេចសីហនុក្សាជំហរទាមទារលុបបំបាត់សាធារណរដ្ឋប្រជាមានិតកម្ពុជា មុននឹងចូលរួមក្នុងរដ្ឋាភិបាលបណ្តោះអាសន្ន។ ចំណែកឯរបបសង្គមវិញ គួរត្រូវពិនិត្យនៅសន្និសីទអន្តរជាតិ។

ពាក់ព័ន្ធនឹងសន្និសីទអន្តរជាតិ ៖ សម្តេចសីហនុមានមតិថា ព្រះអង្គយល់ព្រមជាមួយឥណ្ឌូនេស៊ីចាត់តាំងតុមូលនៅហ្សាកាតាជាមួយនឹងការចូលរួមរបស់ហ៊ុន សែន, សីហនុ និងវៀង គីថាច់ ឬតុមូលទំហំមធ្យមជាមួយនឹងការចូលរួមបើកទូលាយជាមួយវៀតណាម ឡាវ បណ្តាភាគីកម្ពុជា អាស៊ាន ចិន ជប៉ុន ឥណ្ឌា និងអូស្ត្រាលី។

ភាគីទាំងពីរមិនបានឯកភាពគ្នាលើ ៖ (១) កាលបរិច្ឆេទដកកងទ័ពវៀតណាមចេញពីកម្ពុជា និង (២) ការបង្កើតរដ្ឋាភិបាលចម្រុះបណ្តោះអាសន្ន។ ជំនួបលើកទី២នេះមិនបានឯកភាពលើកាលបរិច្ឆេទច្បាស់លាស់នៃការដកកងទ័ពវៀតណាមឡើយ។ លោក ហ៊ុន សែនបានបដិសេធសំណើរំលាយចោលរចនាសម្ព័ន្ធសាធារណរដ្ឋប្រជាមានិតកម្ពុជា និងទាមទារឱ្យរៀបចំការបោះឆ្នោតក្នុងក្របខ័ណ្ឌរដ្ឋបាលនៅនឹងកន្លែង។

នៅក្នុងជំនួបលើកទី២នេះ ភាគីទាំងពីរបានឯកភាពគ្នាលើ ៖ (១) របបនយោបាយ កម្ពុជាត្រូវសម្រេចដោយប្រជាជនកម្ពុជា ដែលស្តែងចេញ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

តាមការបោះឆ្នោតជាសាកល (២) បណ្តាលក្នុងការណ៍ឯករាជ្យ អព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ មានន័យថាមិនចូលរួមក្នុងសម្ព័ន្ធយោធាណាមួយ គ្មានមូលដ្ឋានយោធាបរទេស គ្មានកងទ័ពបរទេសលើទឹកដីកម្ពុជា (៣) សន្ធិសីទអន្តរជាតិនិងការត្រួតពិនិត្យអន្តរជាតិ (៤) បញ្ចប់សង្គ្រាមប៉ាកកា។ ពិតមែនតែជំនួបនេះមិនបានចេញសេចក្តីថ្លែងការណ៍រួម ប៉ុន្តែមិនមែនជាការបរាជ័យទេ។ ភាគីទាំងពីរបានព្រមព្រៀងបន្តជួបទៀត ហើយបានត្រៀមរហូតដល់លើកទី៥។

- ជំនួបហ៊ុន សែន-ឆាត់ជៃ ឈុនហាវ៉ាន់ (Chatichai Choonhavan) នៅបាងកក នៅថ្ងៃទី២៥-២៧ ខែកុម្ភៈ ឆ្នាំ១៩៨៨ បានជួយដល់ការរកដំណោះស្រាយបញ្ហាកម្ពុជា ជាពិសេស ដោយសារប្រទេសថៃ គឺជាអ្នកផ្តល់មូលដ្ឋានសឹកដល់ភាគីកម្ពុជា។ នាយករដ្ឋមន្ត្រីឈុនហាវ៉ាន់បានបង្ហាញពីគោលបំណងក្នុងការប្រែក្លាយតំបន់ឥណ្ឌូចិនពីសមរភូមិទៅជាទីផ្សារ។

- កិច្ចប្រជុំក្រៅផ្លូវការនៅចាកាតាទី១ (Jarkarta Informal Meeting-JIM-1) ៖ បានប្រព្រឹត្តនៅ Bogor ឥណ្ឌូនេស៊ី នៅថ្ងៃទី២៥-២៨ ខែកក្កដា ឆ្នាំ១៩៨៨។

ជំនួបដំណាក់កាលទី១ ៖ ប្រព្រឹត្តទៅរវាងភាគីខ្មែរបដិបក្ខនៅថ្ងៃទី ២៥ ខែកក្កដា ដើម្បីពិភាក្សាលើទិដ្ឋភាពអន្តរជាតិនៃបញ្ហាកម្ពុជា ដោយមានការចូលរួមចតុភាគី ៖ ហ៊ុន សែន, ខៀវ សំផន, រណឫទ្ធិ (តំណាងសម្តេចសីហនុ) និងសឺន សាន។ លោក ហ៊ុន សែន បានស្នើ៧ចំណុច ៖ (១) កសាងកម្ពុជាមួយសន្តិភាព ឯករាជ្យ ប្រជាធិបតេយ្យ មានអធិបតេយ្យភាព អព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ (២) ដោះស្រាយទិដ្ឋភាពអន្តរជាតិនៃបញ្ហាកម្ពុជា តាមរយៈការដកកងទ័ពវៀតណាមចេញពីកម្ពុជាឱ្យអស់នៅខែធ្នូ ឆ្នាំ១៩៨៩ ហើយបើយឺតបំផុតនៅត្រីមាសទី១ ឆ្នាំ១៩៩០ ដែលត្រូវផ្សារភ្ជាប់ទៅនឹងការបញ្ចប់ការផ្តល់ជំនួយ និងផ្តល់ដីឱ្យភាគីខ្មែរឯទៀត និងបញ្ចប់ការជ្រៀតជ្រែកពីសំណាក់ប្រទេសក្រៅចូលកិច្ចការផ្ទៃក្នុងរបស់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កម្ពុជា (៣) បញ្ហាផ្ទៃក្នុងកម្ពុជា (រដ្ឋាភិបាលចម្រុះ ការបោះឆ្នោត របប នយោបាយ រដ្ឋធម្មនុញ្ញថ្មី) ត្រូវដោះស្រាយដោយភាគីកម្ពុជាលើមូលដ្ឋាន នៃការបង្រួបបង្រួមជាតិ និងការកម្ចាត់ចោលមេដឹកនាំ និងកងកម្លាំងប្រដាប់ អាវុធរបស់ខ្មែរក្រហម (៤) រក្សាស្ថានភាពបច្ចុប្បន្នរហូតដល់ការបញ្ចប់ ការបោះឆ្នោតជ្រើសរើសសភា ការអនុម័តរដ្ឋធម្មនុញ្ញ និងការបង្កើតរដ្ឋ ភិបាលថ្មី (ភាគីទាំងអស់ត្រូវផ្តល់សម្បទានឱ្យគ្នាទៅវិញទៅមក ដោយមិន ត្រូវឱ្យភាគីណាមួយធ្វើសម្បទានជាឯកតោភាគីឡើយ។ ការរំលាយសាជា-ណារដ្ឋប្រជាមានិតកម្ពុជាមិនអាចធ្វើបានឡើយ។ កម្លាំងទ័ពត្រូវស្ថិតនៅ កន្លែងដដែល ដោយមានការត្រួតពិនិត្យអន្តរជាតិ) (៥) បង្កើតក្រុមប្រឹក្សា បង្រួបបង្រួមជាតិ ដោយមានសម្តេចសីហនុ ជាប្រធាន ដើម្បីអនុវត្តកិច្ច ព្រមព្រៀង (ត្រូវមានអនុគណៈកម្មការដើម្បីគ្រប់គ្រងផ្នែកយោធា និង រៀបចំការបោះឆ្នោត) (៦) បង្កើតគណៈកម្មការត្រួតពិនិត្យអន្តរជាតិ ដើម្បី ពិនិត្យមើលការអនុវត្តកិច្ចព្រមព្រៀង (៧) រៀបចំសន្និសីទអន្តរជាតិដោយ មានការចូលរួមពីប្រទេសឥណ្ឌូចិន អាស៊ាន សហភាពសូវៀត ចិន អាមេរិក បារាំង អគ្គលេខាអង្គការសហប្រជាជាតិ ប្រទេសដែលចូលរួមវិភាគទាន ដល់សន្តិភាព និងចលនាមិនចូលបក្សសម្ព័ន្ធ។

ជំនួបដំណាក់កាលទី២ ៖ បានពិភាក្សាលើក្របខ័ណ្ឌសម្រាប់កិច្ច ពិភាក្សារកដំណោះស្រាយទូលំទូលាយ និងយុត្តិធម៌ ដោយមានការចូលរួម ពីភាគីខ្មែរទាំង៤ជាមួយនឹងប្រទេសអាស៊ាន៦ (ប្រ៊ុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ) ឡាវ និងវៀតណាម។ នៅក្នុងខែ មិថុនា ឆ្នាំ១៩៨៨ សូវៀត និងចិនឯកភាពលើដំណោះស្រាយនយោបាយ លើបញ្ហាកម្ពុជា។ កិច្ចប្រជុំក្រៅផ្លូវការនៅចាកាតា គឺជាចំណុចប្រមូលផ្តុំនៃ ការផ្តួចផ្តើមគំនិតខាងផ្នែកការទូតរបស់អាស៊ាន ហើយដែលភាគីខ្មែរទាំង ៤ព្រមចូលរួម។ ការសម្រេចរបស់កិច្ចប្រជុំបង្ហាញឱ្យឃើញថា ៖ (១) គ្រប់ ភាគីទាំងអស់បានព្រមព្រៀងគ្នាពីភាពចាំបាច់ ដើម្បីរកដំណោះស្រាយ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នយោបាយអំពីបញ្ហាកម្ពុជា និងដើម្បីរួមចំណែកក្នុងការបង្កើតសន្តិភាព និងស្ថិរភាពនៅអាស៊ីអាគ្នេយ៍ (៦) បង្កើតក្រុមការងារ ដើម្បីពិនិត្យអំពីទិដ្ឋភាពជាក់លាក់ដោយឡែកនៃបញ្ហាកម្ពុជា ហើយត្រូវផ្តល់អនុសាសន៍សម្រាប់ការជួបគ្នាពេលខាងមុខទៀត (៣) មានទិន្នាការផ្សារភ្ជាប់ការដកកងទ័ពវៀតណាមចេញពីកម្ពុជា ទៅនឹងការមិនវិលត្រលប់មកវិញនៃរបបប៉ុល ពត (៤) មេដឹកនាំខ្មែរក្រហមបានបដិសេធរាល់សំណើទាំងអស់សម្រាប់ដំណោះស្រាយបញ្ហាកម្ពុជាតាមផ្លូវនយោបាយ ជាពិសេសការបង្កើតក្រុមប្រឹក្សាបង្រួបបង្រួមជាតិ (៥) ភាគីភ្នំពេញមិនជំទាស់នឹងការចូលរួមខាងផ្នែកនយោបាយរបស់ពួកខ្មែរក្រហម ក្នុងដំណោះស្រាយបញ្ហាកម្ពុជាទេ តែប្រឆាំងនឹងការរក្សាទុកអង្គការយោធារបស់ខ្មែរក្រហម ដើម្បីជាមធ្យោបាយសម្រាប់ដណ្តើមអំណាច។ ចំណុចដែលគ្មានការឯកភាព គឺកាលបរិច្ឆេទនៃការដកកងទ័ពវៀតណាម ការរំលាយរដ្ឋបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ការរំលាយកងទ័ពខ្មែរក្រហម និងតួនាទីនៃកងទ័ពថែរក្សាសន្តិភាពអន្តរជាតិ។

ដោយសារស្ថានភាពសេដ្ឋកិច្ចក្នុងស្រុកកាន់តែលំបាកទៅ និងការខិតជិតគ្នានៃទំនាក់ទំនងសូវៀត-ចិន និងសូវៀត-អាមេរិក វៀតណាមប្រកាសក្នុងខែ ឧសភាថានឹងដកទ័ពចំនួន៥០ ០០០ នាក់ចេញពីកម្ពុជាក្នុងខែមិថុនា និងខែធ្នូ ឆ្នាំ១៩៨៨ ហើយទ័ពនៅសេសសល់នឹងត្រូវដកនៅចុងឆ្នាំ១៩៩០។

- ជំនួបសីហនុ-ហ៊ុន សែនលើកទី៣ ៖ និងជំនួបកំពូលត្រីភាគីសីហនុ-ហ៊ុន សែន-សឺន សាន នៅ Fère-en-Tardenois ប្រទេសបារាំង នៅថ្ងៃទី៦-៨ ខែវិច្ឆិកា ឆ្នាំ១៩៨៨ ឯកភាពលើ ៖ (១) សន្និសីទអន្តរជាតិ ៖ ភាគីទាំង ៣ ឯកភាពឱ្យមានសន្និសីទអន្តរជាតិមួយក្រៅក្របខ័ណ្ឌអង្គការសហប្រជាជាតិ (២) គណៈកម្មាធិការការងារ ៖ ភាគីទាំង៣ ឯកភាពបង្កើតគណៈកម្មាធិការនេះឡើង ដែលមានតំណាងភាគីទាំងបីចូលរួម និងបើកចំហដល់តំណាងខ្មែរក្រហម ដោយយកអតីតស្ថានទូតកម្ពុជានៅ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ប្រទេសជាកំណ ជាទីកន្លែងប្រជុំ។

ជំនួបមិនទាន់មានការឯកភាពលើ ៖ (១) ការផ្សារភ្ជាប់ការដកទ័ព ជាមួយការបញ្ឈប់ជំនួយពីខាងក្រៅ (២) ប្រតិទិននៃការដកកងទ័ពវៀតណាម (៣) អនាគតរដ្ឋអំណាច និងកងទ័ពនៅកម្ពុជាដោយភាគីពីរទៀតទាមទាររំសាយសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ ដោយបង្កើតរដ្ឋាភិបាលចតុភាគីបណ្តោះអាសន្ន ហើយពួកប៉ុល ពតមានតួនាទីទាំងនយោបាយ ទាំងយោធា (ភាគីភ្នំពេញបដិសេធ) (៤) ផ្សារភ្ជាប់បញ្ហាសិទ្ធិមនុស្ស ទៅនឹងបញ្ហាប្រល័យពូជសាសន៍។

- កិច្ចប្រជុំក្រៅផ្លូវការនៅចាកាតាទី២ (Jarkarta Informal Meeting-JIM-2) ៖ បានប្រព្រឹត្តនៅឥណ្ឌូនេស៊ី នៅថ្ងៃទី១៩-២១ ខែកុម្ភៈ ឆ្នាំ១៩៨៩។ មុនប្រជុំថ្នាក់រដ្ឋមន្ត្រី ភាគីទាំងអស់បានប្រជុំក្រុមការងារលើកទី២ ដើម្បីផ្ទាស់ប្តូរមតិក្នុងគោលដៅកាត់បន្ថយការខ្វែងគំនិត និងបើកទូលាយចំណុចឯកភាពស្តីពីវិធានការជាក់ស្តែងក្នុងការអនុវត្តបញ្ហាគន្លឹះនៃដំណោះស្រាយបញ្ហាកម្ពុជា។ ប្រទេសអាស៊ានមិនចង់ពិភាក្សាជាក់ស្តែងពីបញ្ហាដកកងទ័ពវៀតណាម និងការទប់ស្កាត់ការវិលត្រលប់នៃរបបប៉ុល ពត។ ភាគីភ្នំពេញចង់ឱ្យហ្សឺម២ពង្រីក និងធ្វើឱ្យជាក់ស្តែងបញ្ហាគន្លឹះ២ ៖ (១)ការទប់ស្កាត់ការវិលត្រលប់របស់ពួកប៉ុល ពត និង(២)ការដកកងទ័ពវៀតណាម។ ភ្នំពេញបានស្នើទូរវិធានការជាក់ស្តែង ដើម្បីទប់ស្កាត់ការវិលត្រលប់នៃរបបប៉ុលពត និងដើម្បីដោះស្រាយទិដ្ឋភាពអន្តរជាតិនៃបញ្ហាកម្ពុជា។ ប្រទេសអាស៊ានបានឯកភាពលើ ៖ ការផ្សារភ្ជាប់ជាមួយគ្នាក្នុងទិដ្ឋភាពអន្តរជាតិនៃបញ្ហាកម្ពុជានូវ (i) ការដកកងទ័ពវៀតណាម (ii) ការទប់ស្កាត់ការវិលត្រលប់មកវិញនៃរបបប្រល័យពូជសាសន៍ និង (iii) ការពារកំណមិនឱ្យសង្គ្រាមកើតឡើងជាថ្មី ដោយបញ្ឈប់ការធ្វើអន្តរាគមន៍បរទេស និងជំនួយយោធាបរទេសដល់ភាគីកម្ពុជាទាំងអស់។ ក៏ប៉ុន្តែ អាស៊ានមិនព្រមពិភាក្សាពីបញ្ហាជាក់ស្តែងឡើយ។ សន្និសីទបានផ្តាកបណ្តោះអាសន្ន ដើម្បីឱ្យភាគី

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កម្ពុជាដោះស្រាយទិដ្ឋភាពផ្ទៃក្នុងកម្ពុជា ហើយរាយការណ៍លទ្ធផលឱ្យ ប្រធានសន្និសីទក្នុងរយៈពេល៦ខែ។ ជំនួបនេះប្រព្រឹត្តទៅក្នុងបរិបទនៃ ការដកកងទ័ព រុស្ស៊ីចេញអស់ពីអាហ្វហ្គានីស្ថាននៅក្នុងខែកុម្ភៈ ឆ្នាំ១៩៨៩។

- នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៨៩ កម្ពុជា និងវៀតណាមបានប្រកាស ដកកងទ័ពចេញពីកម្ពុជា នៅចុងខែកញ្ញា ឆ្នាំ១៩៨៩។ ការដកកងទ័ព វៀតណាមអស់ទាំងស្រុងពីកម្ពុជានៅឆ្នាំ១៩៨៩បានបើកសកពជថ្មីនៅក្នុង ដំណើរការស្វែងរកសន្តិភាពនៅកម្ពុជា។ ជាការពិត កងទ័ពខ្មែរក្រហមបាន ឆ្លៀតយកឱកាសនេះ ដើម្បីពង្រីកទឹកដីដែលខ្លួនគ្រប់គ្រង ជាពិសេសនៅ តំបន់ប៉ៃលិន ហើយបានលក់ធនធានត្បូង និងព្រៃឈើ ដើម្បីយកថវិកា សម្រាប់បន្តសង្គ្រាមនៅកម្ពុជា។ ការប្រកាសដកទ័ពនេះក៏ជាការត្រៀមជំនួប កំពូលចិន-សូវៀតលើកទី១ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៥-១៨ ខែឧសភា ឆ្នាំ១៩៨៩ផងដែរ។

- ជំនួបសីហនុ-ហ៊ុន សែន លើកទី៤ ៖ នៅ Jarkarta ឥណ្ឌូនេស៊ីនៅ ថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៨៩។ នៅក្នុងជំនួបនេះមានការពិភាក្សាលើរដ្ឋ ធម្មនុញ្ញថ្មី ដើម្បីផ្តល់កម្មសិទ្ធិឯកជនលើដីធ្លី ការបង្កើតសេដ្ឋកិច្ចទីផ្សារ និង ការទាក់ទាញការវិនិយោគទុនពីបរទេស ដើម្បីលើកស្ទួយជីវភាពប្រជាជន នៅកម្ពុជា ការដូរឈ្មោះប្រទេសទៅជារដ្ឋកម្ពុជា និងការផ្លាស់ប្តូរទង់ជាតិថ្មី ការអនុម័តរបបនយោបាយពហុបក្ស ដែលរដ្ឋាភិបាលភ្នំពេញបានអនុម័ត នៅក្នុងខែមេសា ឆ្នាំ១៩៨៩។ កាគីភ្នំពេញបានលើកឡើង ៖ (១) រូបមន្តទី១ គឺការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់កម្ពុជា ដែលមានប្រធានមួយ និងអនុប្រធាន មួយ ឬច្រើន ដោយរក្សាទុករដ្ឋាភិបាលទាំងពីរឱ្យនៅចាំផ្ទះ និងចាត់ចែង ជីវភាពសេដ្ឋកិច្ច (២) រូបមន្តទី២គឺ បន្ទាប់ពីការដកកងទ័ពវៀតណាមចេញ ពីកម្ពុជាអស់ រដ្ឋកម្ពុជានឹងយាងសម្តេចសីហនុទៅធ្វើប្រមុខរដ្ឋកម្ពុជា បើក ទូលាយរដ្ឋាភិបាល ចាត់តាំងរៀបចំការបោះឆ្នោត ដោយមានកាគីពីរទៀត អាចចូលរួមបាន។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- ជំនួបសីហនុ-ហ៊ុន សែន លើកទី៥ ៖ នៅ La Celle Saint Cloud ប្រទេសបារាំង ថ្ងៃទី២៤-២៥ ខែកក្កដា ឆ្នាំ១៩៨៩។ ជំនួបនេះមិនបានលទ្ធផលទេ ដោយសារតែភាគីកម្ពុជាដកថយពីជំហរដែលខ្លួនប្រកាន់យកនៅក្នុងជំនួបហ្សឺម១ និងហ្សឺម២ ហើយប្រកាន់ជំហរយ៉ាងរឹងមាំលែងទន់ភ្លន់ទៀត ដោយសារតែមានប្រទេសមហាអំណាចមួយបានជាក់សំពាធលើភាគីខ្មែរ។

- សន្និសីទទីក្រុងប៉ារីសស្តីពីកម្ពុជា (PICC) នៅថ្ងៃទី២៨-៣០ ខែសីហា ឆ្នាំ១៩៨៩ នៅប្រទេសបារាំង ដោយមានការចូលរួមពីភាគីកម្ពុជាទាំង៤ ប្រទេសអាស៊ានទាំង៦ សមាជិកអចិន្ត្រៃយ៍ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិទាំង៥ វៀតណាម ឡាវ អូស្ត្រាលី កាណាដា ឥណ្ឌា និងហ្សឺមបាវ៉ែ តំណាងចលនាមិនចូលបក្សសម្ព័ន្ធ និងតំណាងអគ្គលេខា UN ដែលមានបារាំង និងឥណ្ឌូនេស៊ី ជាសហប្រធាន។ សន្និសីទនេះមិនបានជោគជ័យ តែបានបង្កើតយន្តការដោះស្រាយបញ្ហាកម្ពុជាគ្រប់ជ្រុងជ្រោយ ដោយបង្កើតគណៈកម្មការ៤ ៖ (១) គណៈកម្មការត្រួតពិនិត្យ (២) គណៈកម្មការជាតិអន្តរជាតិ (៣) គណៈកម្មការជនភៀសខ្លួន និងសាងសង់ឡើងវិញ និង (៤) គណៈកម្មការពិសេសស្តីពីការបង្រួបបង្រួមជាតិ។ គណៈកម្មការទាំងនេះដឹកនាំដោយសហប្រធាន។ បន្ទាប់ពីការដកកងទ័ពវៀតណាមអស់ពីកម្ពុជា នៅចុងខែកញ្ញា ឆ្នាំ១៩៨៩ កងទ័ពខ្មែរក្រហមបានវាយចូលមកកាន់កាប់តំបន់ប៉ៃលិន និងតំបន់មួយចំនួន តែកងទ័ពរដ្ឋកម្ពុជាអាចទប់ទល់ជាមួយនឹងទ័ពខ្មែរក្រហមបាន ដោយរក្សាបាននូវសន្តិភាព និងសន្តិសុខក្នុងប្រទេស។ ក៏ប៉ុន្តែ សន្និសីទនេះនៅមិនទាន់ដោះស្រាយបញ្ហាមួយចំនួននៅឡើយ។

ចំណុចដែលមានការឯកភាពគ្នាគឺ ៖ (១) ដំណោះស្រាយនយោបាយរួមនៃបញ្ហាកម្ពុជា (២) ការដកកងទ័ពវៀតណាម ការបញ្ឈប់ជំនួយបរទេស ការបង្ការសង្គ្រាមក្នុងស្រុក និងការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួន (៣)

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

រដ្ឋកម្ពុជាឯករាជ្យ សន្តិភាព អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ និងមានទំនាក់-ទំនងជាមួយប្រទេសទាំងអស់ (៤) ដំណោះស្រាយកិច្ចការផ្ទៃក្នុងដោយភាគីកម្ពុជាខ្លួនឯង របបនយោបាយត្រូវសម្រេចដោយប្រជាជន តាមរយៈការបោះឆ្នោត (៥) ការជានាអន្តរជាតិចំពោះឯករាជ្យភាព និងអព្យាក្រឹតភាពរបស់កម្ពុជា (៦) ការត្រួតពិនិត្យអន្តរជាតិលើការអនុវត្តកិច្ចព្រមព្រៀង និង (៧) ជំនួយអន្តរជាតិដើម្បីកសាងប្រទេសឡើងវិញ។

ចំណុចដែលមិនទាន់មានការឯកភាពគ្នាគឺ ៖ (១) ការប្រកាន់ជំហរចំពោះរបបប្រល័យពូជសាសន៍ (៦) បញ្ហាដែលត្រូវដោះស្រាយនៅក្នុងដំណាក់កាលអន្តរកាល (៣) តួនាទីរបស់អង្គការសហប្រជាជាតិ ក្នុងយន្តការត្រួតពិនិត្យ (៤) បញ្ហាអាណិកជនវៀតណាម និងបរទេស។

ដើម្បីទម្លុះភាពទាល់ច្រក និងជាក់សម្ពាធលើភាគីរដ្ឋាភិបាលចម្រុះរាជរដ្ឋាភិបាលថៃបានប្រកាសថានឹងដូរជំហរលើបញ្ហាកម្ពុជា ប្រសិនភាគីខ្មែរនៅបន្តរឹងរូសទៀត។ ដើម្បីត្រៀមរៀបចំការបោះឆ្នោត អូស្ត្រាលីបានដាក់ចេញសេចក្តីផ្តួចផ្តើមគំនិតឱ្យអង្គការសហប្រជាជាតិចូលរួមក្នុងការគ្រប់គ្រងកម្ពុជា ក្នុងដំណាក់កាលអន្តរកាល និងឱ្យកងទ័ពសហប្រជាជាតិត្រួតពិនិត្យកិច្ចឈប់បាញ់គ្នា និងការបញ្ឈប់ជំនួយយោធាពីបរទេស ក្នុងគោលដៅបង្កើតបរិយាកាសនយោបាយអព្យាក្រឹត សម្រាប់ការបោះឆ្នោតសេរី និងយុត្តធម៌នៅកម្ពុជា។

- កិច្ចប្រជុំកំពូលរវាងរដ្ឋាភិបាលកម្ពុជាទាំងពីរ ៖ នៅ Tokyo ប្រទេសជប៉ុន ថ្ងៃទី៤-៥ ខែមិថុនា ឆ្នាំ១៩៩០។ ជប៉ុនបានរៀបចំកិច្ចប្រជុំនេះឡើងរវាងរដ្ឋាភិបាលបដិបក្ខទាំងពីរ (មិនមែនរវាងភាគីកម្ពុជាទាំង៤ទេ) ហើយអង្គប្រជុំ ដែលផ្តួចផ្តើមដោយជប៉ុន និងប្រទេសថៃបានសម្រេចដូចតទៅ ៖ (១) បង្កើតក្របខ័ណ្ឌដំណោះស្រាយរួម ដែលចេញពីការឈប់បាញ់គ្នា (៦) ការផ្សារភ្ជាប់សកម្មភាពយោធាទៅនឹងសម័យប្រជុំទី១នៃក្រុមប្រឹក្សាជាតិ (៣) ការប្រកាសតំបន់អង្គរជាតំបន់គ្មានការប្រទូស្តរាយខាងយោធា។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កាគីភ្នំពេញបានស្នើសុំកាគីជប៉ុនជួយដល់បញ្ហាធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួន និងជួយដល់បញ្ហាអតិវក្ស និងជួសជុលអគ្គីរ។

- កិច្ចប្រជុំសមាជិកអចិន្ត្រៃយ៍ទាំង៥នៃក្រុមប្រឹក្សាសន្តិសុខ អសប (Perm5) ដែលប្រព្រឹត្តនៅប៉ារីស នៅថ្ងៃទី១៥-១៦ ខែមករា ឆ្នាំ១៩៩០ បានឯកភាពគ្នាលើចំណុចខាងក្រោម ៖ (១) ដំណោះស្រាយរួមដោយសន្តិវិធីតាមរយៈការដកទ័ពបរទេស ដោយមានការត្រួតពិនិត្យ ការឈប់បាញ់ និងការបញ្ឈប់ជំនួយយោធាបរទេស (២) សិទ្ធិស្វ័យសម្រេចរបស់ប្រជាជនកម្ពុជា តាមរយៈការបោះឆ្នោតសេរី (៣) តួនាទីរបស់អង្គការសហប្រជាជាតិក្នុងដំណោះស្រាយកម្ពុជា (៤) ការជំរុញការងារការទូតឆ្ពោះទៅរកដំណោះស្រាយ (៥) ការដកទ័ពបរទេសទាំងស្រុង ដោយមានការត្រួតពិនិត្យដោយអង្គការសហប្រជាជាតិ (៦) បន្តកិច្ចសន្ទនារវាងភាគីកម្ពុជា (៧) វត្តមានអង្គការសហប្រជាជាតិ ក្នុងការជានាសន្តិសុខផ្ទៃក្នុង (៨) តែងតាំងតំណាងពិសេសអង្គការសហប្រជាជាតិនៅកម្ពុជា ដើម្បីរៀបចំការបោះឆ្នោត (៩) ការផ្តល់ជំនួយហិរញ្ញវត្ថុដល់ប្រតិបត្តិការអង្គការសហប្រជាជាតិ (១០) ការបោះឆ្នោតក្រោមការគ្រប់គ្រងផ្ទាល់របស់អង្គការសហប្រជាជាតិ (១១) ការបង្កើតបរិយាកាសនយោបាយអព្យាក្រឹតសម្រាប់ការបោះឆ្នោត (១២) ការគោរពលទ្ធផលការបោះឆ្នោតដោយសមាជិកអចិន្ត្រៃយ៍ទាំង៥ (១៣) សិទ្ធិ និងសេរីភាពរបស់ជនជាតិកម្ពុជាក្នុងការបោះឆ្នោត (១៤) ការបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដើម្បីតំណាងអធិបតេយ្យភាពកម្ពុជា (១៥) ដោះស្រាយបញ្ហាអធិបតេយ្យភាពកម្ពុជា ដោយមានការយល់ព្រមពីភាគីកម្ពុជា (១៦) ការកោះប្រជុំជាថ្មីនៃសន្និសីទទីក្រុងប៉ារីស ក្នុងពេលវេលាចាំបាច់។

- កិច្ចប្រជុំឧត្តមក្រុមប្រឹក្សាជាតិ (SNC) ដែលប្រព្រឹត្តនៅប៉ាតាយ៉ា នៅថ្ងៃទី២៤-២៦ ខែមិថុនា ឆ្នាំ១៩៩១ សម្តេចសីហនុ និងលោកហ៊ុន សែន បានព្រមព្រៀងអនុម័តក្របខ័ណ្ឌដំណោះស្រាយបញ្ហាកម្ពុជា ដែលរៀបចំ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឡើងដោយសមាជិកអចិន្ត្រៃយ៍ទាំង៥ ដោយផ្តល់តួនាទីឱ្យអង្គការសហប្រជាជាតិ ក្នុងការរៀបចំការបោះឆ្នោត។ សម្តេចសីហនុស្នើថា ព្រះអង្គនឹងត្រូវបានតែងតាំងជាប្រធាន SNC ហើយលោកហ៊ុន សែន ជាអនុប្រធាននៃ SNC។ កិច្ចប្រជុំ SNC លើកទី២ នៅប៉ាតាយ៉ា នៅថ្ងៃទី២៦-២៩ ខែមិថុនា ឆ្នាំ១៩៩១ បានដោះស្រាយបញ្ហាដែលនៅសេសសល់ ហើយជាលទ្ធផល SNC ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១។

៤-ការសម្រេចបានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស

- នៅក្នុងសន្និសីទទី២ក្រុងប៉ារីសស្តីពីកម្ពុជា (PICC) ភាគីកម្ពុជាទាំង ៤ និងប្រតិភូអន្តរជាតិទាំងអស់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីដំណោះស្រាយនយោបាយនៃបញ្ហាកម្ពុជា នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដោយមានការចូលរួមត្រួតពិនិត្យពីអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC)។

- នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ សម្តេចនរោត្តម សីហនុបានយាងត្រលប់មកកម្ពុជាវិញ ក្នុងព្រះរាជឋានៈជាព្រះប្រធាន SNC បន្ទាប់ពីព្រះអង្គត្រូវបាននិរទេសខ្លួនអស់រយៈពេល២១ឆ្នាំមក។

កំណែទម្រង់ដើម្បីរកដំណោះស្រាយបញ្ចប់សង្គ្រាមនៅកម្ពុជា

ទិដ្ឋភាពខាងក្រៅ ៖ ដើម្បីដោះស្រាយបញ្ហាកម្ពុជា ចាំបាច់ត្រូវដកកងទ័ព និងជំនាញការវៀតណាមចេញពីកម្ពុជា ដើម្បីកាត់បន្ថយកង្វល់របស់ប្រទេសអាស៊ាន ដែលមិនចង់ឃើញលទ្ធិកុម្មុយនីស្តរាលដាលទៅប្រទេសផ្សេងទៀត។ ម្យ៉ាងវិញទៀត ការដកកងទ័ពវៀតណាមចេញពីកម្ពុជា គឺមានគោលដៅពិនិត្យឡើងវិញនូវតុល្យភាពកម្លាំង ទាំងនៅក្នុងតំបន់រវាងចិន និងសហភាពសូវៀត (នេះគឺជាលក្ខណៈនៃការធ្វើប្រក្រតីភាវូបនីយកម្មនៃទំនាក់ទំនងរវាងចិន និងសហភាពសូវៀត) និងរវាងមហា

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

អំណាចបរមាណូទាំងពីរ គឺសហភាពសូវៀត និងសហរដ្ឋអាមេរិក។

ទិដ្ឋភាពខាងក្នុង ៖ ដើម្បីដោះស្រាយបញ្ហាកម្ពុជា ភាគីខ្មែរទាំងអស់ត្រូវព្រមព្រៀងគ្នាពីរបបនយោបាយ (ការគ្រប់គ្រងបែបរាជានិយម ឬសាធារណរដ្ឋ) គោលនយោបាយសេដ្ឋកិច្ច និងសង្គម (សេដ្ឋកិច្ចទីផ្សារ ឬសេដ្ឋកិច្ចផែនការ) ការកសាងកងទ័ព និងការកសាងរដ្ឋបាលសាធារណៈ។ ក្នុងន័យនេះ មានតែការបង្កើតឡើងវិញនូវរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ការបង្កើតរបបនយោបាយពហុបក្ស ការធ្វើសមាហរណកម្មកងកម្លាំងប្រដាប់អាវុធ និងរដ្ឋបាលសាធារណៈ ការធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួន និងការរៀបចំបោះឆ្នោត ដើម្បីឱ្យប្រជាជនកម្ពុជា ជាអ្នកសម្រេចជោគវាសនាប្រទេស ទើបកម្ពុជាអាចរកច្រកចេញពីផ្លូវទាល់នេះបាន។

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ មានគោលដៅដោះស្រាយជម្លោះប្រដាប់អាវុធនៅកម្ពុជាដោយសន្តិវិធី។ ខ្ឹមសារសំខាន់ៗនៃកិច្ចព្រមព្រៀងនេះ រួមមាន ៖ (១) វត្ថុបំណងនៃកិច្ចព្រមព្រៀងនេះ គឺជាដំណាក់កាលអន្តរកាល ដែលចាប់ផ្តើមនៅពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ហើយត្រូវបញ្ចប់វិញ នៅពេលដែលសភាធម្មនុញ្ញ ដែលត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតដ៏ត្រឹមត្រូវ និងយុត្តិធម៌អនុម័តរដ្ឋធម្មនុញ្ញ ហើយបន្ទាប់មកបានប្រែក្លាយខ្លួនទៅជាសភានីតិបញ្ញត្តិ និងបន្ទាប់ពីរាជរដ្ឋាភិបាលត្រូវបានបង្កើត (គោលការណ៍គោរពអធិបតេយ្យភាព) (២) ការបង្កើតអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ ដែលហៅកាត់ថាអ៊ិនតាក់ ដែលមានផ្នែកយោធា និងផ្នែកស៊ីវិល ស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់អគ្គលេខាអង្គការសហប្រជាជាតិ ក្នុងការរៀបចំការបោះឆ្នោត (៣) ការបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC) ដែលជាប្រភពអំណាចតែមួយគត់ និងតំណាងឱ្យអធិបតេយ្យភាព ឯកភាព និងឯកភាពជាតិកម្ពុជាក្នុងដំណាក់កាលអន្តរកាល (៤) ដើម្បីធានានូវបរិយាកាសអព្យាក្រឹត អ៊ិនតាក់ត្រូវត្រួតពិនិត្យកិច្ចការ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រសួងការបរទេស ក្រសួងការពារជាតិ ក្រសួងហិរញ្ញវត្ថុ ក្រសួងសន្តិសុខជាតិ និងក្រសួងឃោសនាការ (៥) ការត្រួតពិនិត្យមើលការដកកងទ័ពបរទេសចេញពីកម្ពុជា (៦) ការឈប់បាញ់គ្នា និងការបញ្ឈប់ជំនួយយោធាពីក្រៅប្រទេស (ការហាមពង្រាយនិងចល័តទ័ព ដែលពង្រីកតំបន់ត្រួតត្រា) (៧) ការរៀបចំការបោះឆ្នោត (៨) ការគោរពសិទ្ធិមនុស្ស (៩) ការបញ្ជូនជនភៀសខ្លួនមកកាន់កម្ពុជាវិញ (១០) ការដោះលែងឈ្លើយសឹក និង (១១) ការកំណត់គោលការណ៍នៃរដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជា (រួមមានដូចជាគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាជន និងគោលការណ៍នីតិរដ្ឋជាដើម)។

ហត្ថលេខីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសមាន១៨ ប្រទេស និងភាគីកម្ពុជា៖ (រដ្ឋកម្ពុជា ហ៊ុនសុិនបុិច រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និងខ្មែរក្រហម)។ ប្រទេសហត្ថលេខីទាំងនោះរួមមាន ៖ (១) សមាជិកអចិន្ត្រៃយ៍ក្រុមប្រឹក្សាសន្តិសុខអ.ស.ប. (៥ប្រទេស) ៖ អាមេរិក អង់គ្លេស បារាំង (សហប្រជានសន្និសីទ) ចិន និងសហភាពសូវៀត (២) ប្រទេសនៅអាស៊ីអាគ្នេយ៍ (៨ប្រទេស) ៖ឥណ្ឌូណេស៊ី (សហប្រជានសន្និសីទ) វៀតណាម, ឡាវ ថៃ សិង្ហបុរី ម៉ាឡេស៊ី ហ្វីលីពីន និងប្រ៊ុយណេ (៣) ក្រុមប្រទេសមិនចូលបក្សសម្ព័ន្ធ តំណាងដោយយូហ្គោស្លាវី និង (៤) ឥណ្ឌា ជប៉ុន កាណាដា និងអូស្ត្រាលី។

៥-កម្ពុជាក្នុងដំណាក់កាលអន្តរកាលក្រោមការដឹកនាំរបស់អ៊ុនតាក់

ក-ការអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស

ការរួបរួមគ្នាក្រោមដំបូល SNC ៖ ភាគីខ្មែរទាំងបួនបានបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC) ដែលជាប្រភពអំណាចតែមួយគត់ និងតំណាងឱ្យអធិបតេយ្យភាព ឯកភាព្យ និងឯកភាពជាតិកម្ពុជាក្នុងដំណាក់កាលអន្តរកាល។ ថ្វីត្បិតតែភាគីទាំងបួនបានរួបរួមគ្នាមែន តែនៅមិនទាន់មានឯកភាព

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ផ្នែកក្នុងនៅឡើយទេ។ ការប្រយុទ្ធលើសមរភូមិយោធា និងលើសមរភូមិនយោបាយ នៅតែបន្ត។

ការចាប់ផ្តើមថ្មី ៖ បន្ទាប់ពីមានកិច្ចប្រជុំនៅប៉ាតាយ៉ា រួចមក សម្តេចសីហនុបានយាងមកកម្ពុជាវិញ នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ ដែលជាថ្ងៃដែលកម្ពុជាទទួលបានឯករាជ្យពីបារាំង ដែលបង្ហាញពីជោគជ័យរបស់សម្តេចហ៊ុន សែន ក្នុងការធ្វើកំណែទម្រង់នយោបាយ សេដ្ឋកិច្ច និងសង្គម ដើម្បីតម្រូវតាមស្ថានភាព និងដើម្បីបញ្ឈប់សង្គ្រាម និងបានដាក់សម្ពាធបន្ថែមដល់ភាគីខ្មែរក្រហមឱ្យទទួលយកដំណោះស្រាយនយោបាយ។ មានតែភាគីខ្មែរក្រហមមួយគត់ ដែលមានកម្លាំងយោធាខ្លាំងក្លា ដែលទទួលបានផលប្រយោជន៍តិចជាងគេពីដំណោះស្រាយនយោបាយ ពីព្រោះគេដឹងច្បាស់ថា ប្រជាជនកម្ពុជាពិតជានឹងមិនបោះឆ្នោតគាំទ្រពួកខ្មែរក្រហមឡើយ។

មាតុភូមិនិវត្តន៍នៃជនភៀសខ្លួន ៖ ប្រជាជនខ្មែរប្រមាណជាង៦សែននាក់ ដែលរស់នៅប្រទេសថៃ ត្រូវបានធ្វើមាតុភូមិនិវត្តន៍មករស់នៅតាមស្រុកភូមិរបស់ពួកគេវិញ លើកលែងតែប្រជាជន ដែលស្ថិតនៅក្នុងជំរំខ្មែរក្រហមប្រមាណជា១សែននាក់បានចូលមកនៅតាមតំបន់ដែលខ្មែរក្រហមកាន់កាប់តាមព្រំដែនកម្ពុជា-ថៃ។ ប្រជាជនភាគច្រើន ដែលរស់នៅក្នុងជំរំគ្រប់គ្រងដោយចលនាមិនមែនកុម្មុយនីស្ត (FUNCINPEC និង KPNLF) បានមករស់នៅតាមខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប ហើយខ្លះទៀតបានមករស់នៅទីក្រុងភ្នំពេញ។

ស្ថានភាពសេដ្ឋកិច្ចយ៉ាប់យឺន ៖ ជំនួយ ដែលរដ្ឋកម្ពុជាធ្លាប់ទទួលពីសហភាពសូវៀតត្រូវបានកាត់ផ្តាច់។ រដ្ឋកម្ពុជាត្រូវបង្ខំចិត្តធ្វើឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ ដើម្បីរកចំណូលចូលថវិការដ្ឋ។ ការហូរចូលនៃជនភៀសខ្លួនរាប់សែននាក់បានធ្វើឱ្យតម្រូវការទំនិញសព្វសារពើកើនឡើង តែការផ្គត់ផ្គង់នៅមានកំហិត ដោយសារតែស្ថានភាពនយោបាយនៅផុយ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ស្រួយ ហើយវិនិយោគិនភាគច្រើននៅចាំមើលលទ្ធផលនៃការបោះឆ្នោតសិន។ ការហូរចូលប្រាក់ដុល្លារយ៉ាងលឿន និងការបោះពុម្ពក្រដាសប្រាក់ដើម្បីបំពេញតម្រូវការថវិកាជាតិ បានធ្វើឱ្យអត្រាអតិផរណាឡើងដល់រាប់រយភាគរយ។ ប្រជាជនបាត់ជំនឿលើរូបិយវត្ថុជាតិ ហើយដំណើរការដុល្លារភាវូបនីយកម្មក៏ចាប់ផ្តើម។ មន្ត្រីរាជការ កងទ័ព និងកងនគរបាលបើកប្រាក់បៀវត្សដ៏តិចតួចរបស់ខ្លួនមិនទៀងពេល។

ខ្មែរក្រហមដកថយពីកិច្ចព្រមព្រៀង ៖ នៅខែឧសភា ឆ្នាំ១៩៩២ នៅពេលដែលកងទ័ពអ៊ុនតាក់ចាប់ផ្តើមអនុវត្តផែនការរំសាយកងទ័ព និងដាក់កងទ័ពចំនួន៧០%ឱ្យនៅក្នុងបន្ទាយសុវត្ថិភាព ខ្មែរក្រហមបានជំទាស់មិនព្រមដាក់អាវុធចុះ និងរំសាយកងទ័ព ដោយឈរលើមូលហេតុ២យ៉ាង ៖ (១) កងទ័ពវៀតណាមនៅតែមានវត្តមាននៅកម្ពុជាដដែល ដូច្នេះខ្មែរក្រហមត្រូវពន្យាពេលដាក់អាវុធចុះ (២) ភាគីរដ្ឋកម្ពុជានៅបន្តគ្រប់គ្រងរដ្ឋបាលនៅនឹងកន្លែង ដែលបង្ហាញថាអ៊ុនតាក់មិនបានបង្កើតលក្ខខណ្ឌអំណោយផលល្អ សម្រាប់ខ្មែរក្រហមចូលរួមក្នុងការបោះឆ្នោតឡើយ។ ក្នុងន័យនេះ ខ្មែរក្រហមបានទាមទារបង្កើតរដ្ឋបាល៤ភាគី ជំនួសរដ្ឋបាលនៅនឹងកន្លែងតាមគំរូ SNC ខុសពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស តែត្រូវភាគីរដ្ឋកម្ពុជាបដិសេធ។ ខ្មែរក្រហមក៏ដកខ្លួនចេញពី SNC និងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ហើយចាប់ផ្តើមបន្តសង្គ្រាមវាតទីកដី នៅតាមតំបន់ដែលពីពេលមុនកាន់កាប់ដោយកងទ័ពវៀតណាម។ មានតែកងទ័ពនៃរដ្ឋកម្ពុជាទេ ដែលអាចទប់ទល់ជាមួយខ្មែរក្រហមបាន។ ម្យ៉ាងវិញទៀត ខ្មែរក្រហមនៅមានប្រភពហិរញ្ញប្បទានយ៉ាងសំខាន់ បន្ទាប់ពីជំនួយបរទេសត្រូវបានកាត់ផ្តាច់ គឺការកាប់ឈើ និងការធ្វើអាជីវកម្មរ៉ែត្បូង ដើម្បីយកថវិកាទៅបម្រើឱ្យការបន្តសង្គ្រាមនៅកម្ពុជា។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ខ-ការរៀបចំការបោះឆ្នោតដោយអ៊ុនតាក់

ការបង្កើតរដ្ឋបាលអ៊ុនតាក់ ៖ មុនទីបង្កើតអ៊ុនតាក់ អង្គការសហប្រជាជាតិបានបញ្ជូនបេសកកម្មនាំមុខ ដែលមានឈ្មោះថា យូណាមិច ដើម្បីត្រៀមរៀបចំទទួលប្រតិបត្តិការកសាងសន្តិភាពដ៏ធំមួយនេះ ហើយដែលចំណាយថវិកាអស់ជាង២៣ពាន់លានដុល្លារ។ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ១៩៩២ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានអនុម័តលើផែនការបង្កើតអ៊ុនតាក់ ដែលមានកងទ័ពចំនួន១៥ ៩០០នាក់ ប៉ូលិស៣ ៦០០នាក់ និងមន្ត្រីស៊ីវិលចំនួន១ ០២០នាក់។ នៅខែមីនា ឆ្នាំ១៩៩២ អ៊ុនតាក់ ដែលមានលោក Yasushi Akashi ជាតំណាងអគ្គលេខាអង្គការសហប្រជាជាតិ និងឧត្តមសេនីឯក John Sanderson ជាមេបញ្ជាការកងទ័ពអ៊ុនតាក់ បានមកដល់កម្ពុជា។ នៅតាមខេត្ត មានប្រធានរដ្ឋបាលអ៊ុនតាក់ជាអ្នកត្រួតពិនិត្យរដ្ឋបាលនៅទីឯកន្លែង។ អ៊ុនតាក់ក៏ដាក់តំណាងរបស់ខ្លួននៅតាមក្រសួងសំខាន់ៗផងដែរ ដូចជាក្រសួងការបរទេស ក្រសួងការពារជាតិ ក្រសួងសន្តិសុខជាតិ និងក្រសួងហិរញ្ញវត្ថុ។ ច្បាប់បោះឆ្នោតរបស់អ៊ុនតាក់ត្រូវបានអនុម័ត ហើយស្ថានីយវិទ្យុអ៊ុនតាក់ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ឱកាសដល់គណបក្សនយោបាយ ក្នុងការធ្វើការឃោសនាបោះឆ្នោត។

លទ្ធផលនៃការបោះឆ្នោត ៖ ការបោះឆ្នោតបានប្រព្រឹត្តទៅពីថ្ងៃទី ២៣ដល់២៨ ខែឧសភា ឆ្នាំ១៩៩៣ ដោយមានប្រជាជនកម្ពុជាចំនួន៩០% ចូលរួមបោះឆ្នោត។ គណបក្ស FUNCINPEC ទទួលបាន៥៨អាសនៈ គណបក្សប្រជាជនទទួលបាន៥១អាសនៈ គណបក្សសេរីនិយមព្រះពុទ្ធសាសនាទទួលបាន១០អាសនៈ និងគណបក្សម៉ូលីណាកាទទួលបាន១ អាសនៈ។

ការចាប់ផ្តើមនៃការបញ្ចប់សង្គ្រាម ៖ ដើម្បីបញ្ចប់សង្គ្រាមចាំបាច់ទាមទារឱ្យមានកត្តាខាងក្រៅ និងកត្តាខាងក្នុង។

កត្តាខាងក្រៅ គឺជាការគាំទ្ររបស់សហគមន៍អន្តរជាតិ ជាពិសេស

ប្រទេសសមាជិកក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ មហាអំណាចក្នុងតំបន់ និងប្រទេសជិតខាង។

កត្តាខាងក្នុង គឺជាដំណោះស្រាយបញ្ហារវាងខ្មែរ និងខ្មែរ។ ទោះបីជាមានការជួយគាំទ្រពីខាងក្រៅក៏ប៉ុន្តែ កត្តាសម្រេច គឺជាកត្តាខាងក្នុង ដែលជាការព្រមព្រៀងគ្នារវាងភាគីខ្មែរទាំងអស់ ដែលច្បាំងគ្នា។ អ្នកដឹកនាំនយោបាយខ្មែរពីរូប ដែលដើរតួនាទីសំខាន់បំផុត ក្នុងដំណើរការធ្វើឱ្យមានសន្តិភាពឡើងវិញនៅកម្ពុជា គឺសម្តេចសីហនុ និងសម្តេចហ៊ុន សែន។ សម្តេចហ៊ុន សែនបានដឹកនាំរដ្ឋកម្ពុជា ដើម្បីប្រឆាំងការវិលត្រលប់មកវិញនៃរបបប្រល័យពូជសាសន៍ប៉ុល ពត និងជានាចូលរួមរបស់គណបក្សប្រជាជនកម្ពុជា នៅក្នុងដំណើរការចរចាសន្តិភាព និងការកសាងប្រទេសឡើងវិញនៅក្នុងស្ថានភាពជំលំបាក។ សម្តេចសីហនុ គឺជាមគ្គុទ្ទេសក៍ ដែលបានបង្ហាញពីការឈ្វាសវៃខាងផ្នែកនយោបាយ ក្នុងការសម្រុះសម្រួលរវាងគណបក្សនយោបាយធំៗទាំងពីរ តាមរយៈការផ្តួចផ្តើមគំនិតបង្កើតរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី១ ដែលមានន្យាករដ្ឋមន្ត្រីពីរ ៖ នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ បន្ទាប់ពីរដ្ឋកម្ពុជាមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត។

ថ្វីត្បិតតែអ៊ុនតាក់មិនអាចនាំមកនូវសន្តិភាពទាំងស្រុងបាន តែអ៊ុនតាក់បានកាត់បន្ថយជម្លោះកម្ពុជាឱ្យនៅតូចជាងមុន។ ប្រតិបត្តិការអ៊ុនតាក់បានដោះស្រាយទិដ្ឋភាពអន្តរជាតិនៃបញ្ហាកម្ពុជា និងបានបង្កើតលក្ខខណ្ឌអំណោយផលខាងក្នុង សម្រាប់ការកសាងប្រទេសកម្ពុជាឡើងវិញ តាមរយៈការរៀបចំប្រព័ន្ធនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាលថ្មីមួយ ដែលឈានទៅរកដំណោះស្រាយទាំងស្រុង នៅពេលដែលខ្មែរក្រហមអាចទទួលយកបាននូវដំណោះស្រាយដោយសន្តិវិធីនេះ។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំពូក១៤
ការបង្កើត
ព្រះរាជាណាចក្រកម្ពុជា
ទី២ (១៩៩៣-២០០៤)

១-ការបង្កើតឡើងវិញនៃរបបរាជានិយមនៅកម្ពុជា

ក-ការរៀបចំស្ថាប័នរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ

ការអភិសេកសម្តេចសីហនុជាព្រះមហាក្សត្រ ៖ បន្ទាប់ពីការបង្កើតសភាធម្មនុញ្ញក្រោយការបោះឆ្នោតឆ្នាំ១៩៩៣រួចមក បក្សទាំង៥បីដែលមានអាសនៈនៅក្នុងសភាបានតាក់តែងរដ្ឋធម្មនុញ្ញមួយ ដែលធ្វើបញ្ចាំងពីធន្ធៈក្នុងការបង្កើតឡើងវិញនូវរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ហើយសម្តេចសីហនុត្រូវបានអភិសេកឡើងគ្រងរាជបល្ល័ង្កឡើងវិញនៅឆ្នាំ១៩៩៣ ហើយកម្ពុជាបានក្លាយទៅជា ព្រះរាជាណាចក្រកម្ពុជាទី២។

ការបង្កើតរដ្ឋសភានីតិបញ្ញត្តិ ៖ បន្ទាប់ពីការបង្កើតសភាធម្មនុញ្ញក្រោយការបោះឆ្នោតឆ្នាំ១៩៩៣រួចមក បក្សទាំង៥បីដែលមានអាសនៈនៅក្នុងសភាបានតាក់តែងរដ្ឋធម្មនុញ្ញមួយ ដែលធ្វើបញ្ចាំងពីធន្ធៈក្នុងការបង្កើតឡើងវិញនូវរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ការកសាងប្រព័ន្ធនយោបាយពហុបក្ស សេដ្ឋកិច្ចទីផ្សារសេរី។ ក្រោយពីរដ្ឋសភាធម្មនុញ្ញបានអនុម័ត

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

លើរដ្ឋធម្មនុញ្ញថ្មីរួចមក រដ្ឋសភាធម្មនុញ្ញបានប្រែក្លាយទៅជារដ្ឋសភានីតិបញ្ញត្តិ ហើយអាណត្តិរបស់អ៊ុនតាក់ត្រូវបានបញ្ចប់។ អ៊ុនតាក់ក៏បានដកចេញពីកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជានៃព្រះរាជាណាចក្រកម្ពុជាទី៦ត្រូវបានបង្កើតឡើង។

ការបង្កើតរាជរដ្ឋាភិបាល ៖ ជម្លោះកម្ពុជា គឺជាជម្លោះស្មុគ្រស្មាញមិនអាចបញ្ចប់ងាយៗទេ។ ក៏ប៉ុន្តែ ស្ថានភាពនៅកម្ពុជានៅមានលក្ខណៈល្អប្រសើរជាងបណ្តាប្រទេសឯទៀត ហើយភាគីកម្ពុជាចេះសម្របសម្រួលគ្នាបាន។ កោសិកាសង្គមកម្ពុជានៅផុយស្រួយនៅឡើយ ការឯកភាពជាតិនៅមានកម្រិត ដែលតាមការឱ្យមានការផ្សះផ្សារជាតិ ការយោគយល់គ្នានិងការសម្រុះសម្រួលឱ្យគ្នាទៅវិញទៅមក។ ដោយមានការសម្រុះសម្រួលពីសម្តេចសីហនុ រដ្ឋាភិបាលចម្រុះមួយរវាងគណបក្សហ៊ុនស៊ុនប៊ិច និងគណបក្សប្រជាជនត្រូវបានបង្កើតឡើង ដោយមានសហនាយករដ្ឋមន្ត្រី ៖ សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ជានាយករដ្ឋមន្ត្រីទី១ និងសម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីទី២។ ក្រសួងសំខាន់ៗ ដូចជាក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃដឹកនាំដោយសហរដ្ឋមន្ត្រីនៃគណបក្សហ៊ុនស៊ុនប៊ិច និងគណបក្សប្រជាជន។

ខ-សមាហរណកម្មរដ្ឋបាលសាធារណៈ

បន្ទាប់ពីការបង្កើតរាជរដ្ឋាភិបាលនីតិកាលទី១រួចមក ភាគីទាំងបីបានធ្វើសមាហរណកម្មនៃរដ្ឋបាលសាធារណៈរបស់ខ្លួនឱ្យទៅជារដ្ឋបាលឯកភាពតែមួយ។ វិធានការនេះបានធ្វើឱ្យរដ្ឋបាលនៅតាមក្រសួង និងតាមខេត្តឡើងប៉ោងខ្លាំងលើសតម្រូវការជាក់ស្តែង។ អាណត្តិទី១ គឺជាអាណត្តិបង្រួបបង្រួមជាតិ ដោយសារខ្មែរដែលរស់នៅក្នុងស្រុក និងខ្មែរដែលរស់នៅបរទេសបានចាប់ដៃគ្នាធ្វើការប្រកួតប្រជែងគ្នាដោយមិនប្រើអាវុធ។ រាជរដ្ឋាភិបាលចម្រុះដំណើរការជាមួយគ្នាបានបីឆ្នាំ។ ជម្លោះរវាងគណបក្ស

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ហ៊ុនសុិនបុិច និងគណបក្សប្រជាជនបានផ្ទុះឡើង នៅពេលដែលគណបក្ស
ទាំងពីរប្រកួតប្រជែងគ្នា ក្នុងការទាក់ទាញពួកខ្មែរក្រហមឱ្យចុះចូលជាមួយ
រាជរដ្ឋាភិបាលកម្ពុជា។

២-នយោបាយឈ្នះ-ឈ្នះរបស់សម្តេចហ៊ុន សែន ដើម្បីកសាង សន្តិភាពឡើងវិញនៅកម្ពុជា

ក-ការដាក់ចេញនយោបាយឈ្នះ-ឈ្នះ

សង្គ្រាមស្បែកខ្វា ៖ ក្រោយពីអ៊ិនតាក់បានដកទ័ពចេញពីកម្ពុជា
សន្តិភាពនៅមិនទាន់មានពេញលេញនៅឡើយ។ ក្នុងឆ្នាំ១៩៩៦ ខ្មែរក្រហម
បានដកខ្លួនចេញពីដំណើរការស្វែងរកសន្តិភាព និងបានធ្វើពហិការមិន
ព្រមចូលរួមការបោះឆ្នោត នៅឆ្នាំ១៩៩៣ ដោយពួកគេយកលេសថា រដ្ឋ
កម្ពុជានៅបន្តគ្រប់គ្រងរដ្ឋបាលនៅទឹងកន្លែង។ ប្រជាជនដែលរស់នៅក្នុង
តំបន់ខ្មែរក្រហមកាន់កាប់មិនបានចូលរួមក្នុងការបោះឆ្នោតទេ។ បន្ទាប់ពី
អ៊ិនតាក់បានដកចេញពីកម្ពុជា សង្គ្រាមស្បែកខ្វានៅបន្តនៅក្នុងតំបន់ ដែល
ខ្មែរក្រហមកាន់កាប់ នៅក្នុងខេត្តកំពង់ស្ពឺ កំពត កោះកុង ពោធិ៍សាត់
បាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងព្រះវិហារ។ ទឹកដី
កម្ពុជាបន្តបែងចែកជាពីរ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល
ពីរ ៖ រាជរដ្ឋាភិបាលកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ។ ការប្រយុទ្ធនៅ
តែបន្តទៀត នៅក្នុងតំបន់ព្រំដែនកម្ពុជា-ថៃ។ ការចរចារវាងរាជរដ្ឋាភិបាល
កម្ពុជា (សម្តេចជា ស៊ីម ព្រះអគ្គមហាសេនាតេជោ រណឫទ្ធិ និងសម្តេចហ៊ុន សែន)
និងខ្មែរក្រហម (លោក ខៀវ សំផន) ដែលប្រព្រឹត្តទៅនៅទីក្រុងព្យុងយ៉ាង
កូរ៉េខាងជើង ក្រោមអធិបតីភាពរបស់សម្តេចនរោត្តម សីហនុទទួលបរាជ័យ។
រាជរដ្ឋាភិបាលកម្ពុជាបានស្នើច្បាប់ ដើម្បីដាក់ក្រុមខ្មែរក្រហមឱ្យនៅក្រៅច្បាប់
ក្នុងឆ្នាំ១៩៩៤ ដើម្បីដាក់សម្ពាធពួកគេឱ្យចុះចូលជាមួយរាជរដ្ឋាភិបាល
កម្ពុជា។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការដាក់ចេញនយោបាយឈ្នះ-ឈ្នះ ៖ សម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីទី២នៃរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវនយោបាយឈ្នះ-ឈ្នះ ក្នុងគោលដៅបញ្ចប់សង្គ្រាមនៅកម្ពុជា ដោយយល់ឃើញថាសង្គ្រាមនៅកម្ពុជាមិនអាចបញ្ចប់ដោយចុងកាំភ្លើងបានឡើយ។ កងទ័ពខ្មែរក្រហមនៅមានប្រើនកងពល ចំណែកឯកងយោធពលខេមរភូមិន្ទនៅទិសខាងលិចមានតែពីរកងពលប៉ុណ្ណោះ គឺកងពលលេខ៤ និងកងពលលេខ៦។ គោលនយោបាយឈ្នះ-ឈ្នះមានសមាសភាគ៣សំខាន់ គឺ៖ (១) ការជានាអាយុជីវិត និងរូបកាយដល់អតីតបងប្អូនខ្មែរក្រហម (ការមិនចាប់ចង មិនពិសអើង និងធ្វើទុក្ខបុកម្នេញអ្វីទាំងអស់) (២) ការជានាអាជីព និងមុខរបរ (ការរក្សាស្ថានភាពដើមរបស់កងទ័ព ពោលគឺ រក្សារចនាសម្ព័ន្ធចាត់តាំងនៃកងទ័ព និងរដ្ឋបាលខ្មែរក្រហម ដោយគ្មានការរុះរើ និងការធ្វើសមាហរណកម្មនៃកងកម្លាំងប្រដាប់អាវុធខ្មែរក្រហម ចូលក្នុងកងយោធពលខេមរៈភូមិន្ទ ដោយគ្រាន់តែប្តូរឯកសណ្ឋានកងទ័ពពីខោអាវខ្មែរក្រហមទៅឯកសណ្ឋានកងយោធពលខេមរភូមិន្ទ និងធ្វើសមាហរណកម្មនៃរដ្ឋបាលខ្មែរក្រហម ចូលក្នុងរចនាសម្ព័ន្ធរដ្ឋបាលនៃរាជរដ្ឋាភិបាលកម្ពុជា) និង (៣) ការជានាកម្មសិទ្ធិ ចលនទ្រព្យ និងអចលនទ្រព្យ (ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ម៉ាឡៃ ទទួលបាននូវសម្បទានដីចំនួនពី៥ទៅ១០ហិកតាក្នុងមួយគ្រួសារ)។

ខ-ការរំលាយចោលអង្គការចាត់តាំងយោធា និងនយោបាយរបស់ខ្មែរក្រហម

ការចុះចូលរបស់មេខ្មែរក្រហមនៅតំបន់ភ្នំឱ៉ាល់ ៖ នៅក្នុងខែកុម្ភៈឆ្នាំ១៩៩៦ លោក កែវ ពង្ស ដែលជាមេខ្មែរក្រហមក្នុងតំបន់ភ្នំឱ៉ាល់ ខេត្តកំពង់ស្ពឺ បានចុះចូលជាមួយសម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីទី២នៃរាជរដ្ឋាភិបាលកម្ពុជា។ ដោយអនុវត្តតាមគោលនយោបាយឈ្នះ-ឈ្នះ កង

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កម្លាំងប្រដាប់អាវុធខ្មែរក្រហម និងប្រជាពលរដ្ឋ ដែលរស់នៅក្នុងខេត្ត កំពង់ស្ពឺ និងផ្នែកខ្លះនៃខេត្តពោធិ៍សាត់ ខេត្តព្រះសីហនុ ខេត្តតាកែវ និង កំពតបានចូលមករួមរស់ជាមួយរាជរដ្ឋាភិបាលកម្ពុជា។

ការបះបោរនៃប្រធានកងពលនៅប៉ៃលិន និងម៉ាឡៃ ៖ ចាប់ពីខែ មិថុនា ឆ្នាំ១៩៩៦ លោក អ៊ី ឈាន ប្រធានកងពលខ្មែរក្រហមលេខ៤១៥ និងលោក សុខ កាព ប្រធានកងពលខ្មែរក្រហមលេខ៤៥០ នៅតំបន់ម៉ាឡៃ បានចុះចូលជាមួយសម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីទី២នៃរាជរដ្ឋាភិបាល កម្ពុជា។ នៅដើមឆ្នាំ១៩៩៧ ខ្មែរក្រហមនៅតំបន់ផ្លូវជាតិលេខ៥ និងនៅ តាមតំបន់បឹងទន្លេសាបបានចុះចូលជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។ លោក អៀង សារី ដែលជាមេដឹកនាំខ្មែរក្រហមមួយរូប ត្រូវបានប្រើប្រាស់ ជាឧត្រសម្រាប់ចលនានេះចុះចូលជាមួយរាជរដ្ឋាភិបាល (លោក អ៊ី ឈាន ធ្លាប់ធ្វើជានីរសារបស់លោក អៀង សារី)។ ដូច្នេះហើយសម្តេច ហ៊ុន សែន បានស្នើសុំសម្តេចសីហនុឡាយព្រះរាជហត្ថលេខាលើព្រះរាជក្រឹត្យលើក លែងទោសលោក អៀង សារី បន្ទាប់ពីរដ្ឋសភាពអនុម័តយល់ព្រមតាម សំឡេង៦ភាគ៣។ បន្ទាប់មក កងពលខ្មែរក្រហមនៅតាមតំបន់ផ្សេង។ ទៀត ដូចជានៅកំពត កំពង់ស្ពឺ កោះកុង ពោធិ៍សាត់ សៀមរាប បន្ទាយ មានជ័យ ឧត្តរមានជ័យ និងព្រះវិហារបានចុះចូលជាមួយសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២នៃរាជរដ្ឋាភិបាលកម្ពុជា។

ខ្មែរក្រហមបាត់បង់នូវការគាំទ្រពីខាងក្រៅ ៖ បន្ទាប់ពីការបង្កើត ព្រះរាជាណាចក្រកម្ពុជាទី២នៅក្នុងឆ្នាំ១៩៩៣ មហាអំណាចដែលធ្លាប់ តែគាំទ្រខ្មែរក្រហម និងផ្តល់ការឧបត្ថម្ភហិរញ្ញវត្ថុ និងគ្រឿងយុទ្ធោបករណ៍ ដល់ខ្មែរក្រហម បានឈប់ផ្តល់ការគាំទ្រដល់ពួកគេ។ ជាពិសេស ប្រទេស ដែលធ្លាប់តែផ្តល់ទឹកដីឱ្យខ្មែរក្រហមបង្កើតជំរំ និងមូលដ្ឋានសឹក និងមាន ទំនាក់ទំនងពាណិជ្ជកម្មជាមួយពួកគេក៏ដាក់សម្ពាធទៅលើពួកខ្មែរក្រហម ដោយបញ្ឈប់រាល់សកម្មភាពជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់កម្ពុជា។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការបែកបាក់ផ្ទៃក្នុងក្បាលម៉ាស៊ីនដឹកនាំខ្មែរក្រហម ៖ ខ្មែរក្រហមបន្តធ្វើសង្គ្រាមតាមតំបន់ស្បែកខ្វាជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ក្នុងបរិបទនៃសង្គ្រាមឈូប រចនាសម្ព័ន្ធដឹកនាំខ្មែរក្រហមដំណើរការ តាមគោលការណ៍ស្វ័យភាពតាមតំបន់។ ដូច្នេះចលនាចុះចូលនៃមេកងពលខ្មែរក្រហមតាមតំបន់បានធ្វើឱ្យមេខ្មែរក្រហមលែងទុកចិត្តគ្នា បែកបាក់សាមគ្គីផ្ទៃក្នុង និងធ្វើឱ្យក្បាលម៉ាស៊ីនដឹកនាំខ្មែរក្រហមមានការរន្ធោះរន្ធើរ។ ការចុះចូលរបស់លោក អៀង សារី នៅឆ្នាំ១៩៩៦ ធ្វើឱ្យមេដឹកនាំខ្មែរក្រហមបែកបាក់គ្នា និងលែងទុកចិត្តគ្នា។ ក្នុងឆ្នាំ១៩៩៧ ប៉ុល ពតបានបញ្ជាឱ្យសម្លាប់លោក សុន សេន ទាំងគ្រួសារ។ ដោយសារហឿងនេះ តាម៉ុកក៏ចាប់ប៉ុល ពតមកកាត់ទោសនៅអន្ទង់វែង។ បន្ទាប់មក តាម៉ុកក៏ផ្ចាច់ខ្លួន ដើម្បីបង្កើតតំបន់ស្វយ័តនៅអន្ទង់វែង។

ការចុះចូលរបស់មេដឹកនាំខ្មែរក្រហម ៖ ស្ថិតនៅក្នុងភាពឯកោ ដោយបាត់បង់ការគាំទ្រពីខាងក្រៅ និងការគាំទ្រខាងក្នុងប្រទេស នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ មេដឹកនាំប្រវត្តិសាស្ត្ររបស់ខ្មែរក្រហមបានយល់ព្រមចូលជួបសម្តេចហ៊ុន សែន ដែលទើបនឹងត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីអាណត្តិទី២។ លោក ខៀវ សំផន ប្រធានរដ្ឋ និងជានាយករដ្ឋមន្ត្រី លោក នួន ជា ប្រធានរដ្ឋសភា និងគណៈរដ្ឋមន្ត្រីនៃរដ្ឋាភិបាលខ្មែរក្រហមបានចុះចូលជាមួយសម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនីតិកាលទី២ នៅឯនិវេសនដ្ឋានរបស់សម្តេចនៅឯទីក្រុងតាខ្មៅ។ ជំនួបនេះបានផ្តើសារសំខាន់ៗចំនួន៣គឺ ៖ (១) កម្លាំងខ្មែរក្រហមដែលនៅសេសសល់ត្រូវបញ្ឈប់ការប្រយុទ្ធ និងត្រូវចុះចូលមករួមរស់ ជាមួយរាជរដ្ឋាភិបាល (២) ជម្រាបជូនប្រជាជនកម្ពុជាថា សង្គ្រាម៣ទសវត្សរ៍ត្រូវបានបញ្ចប់ទាំងស្រុង និង (៣) ជុរជន និងវិនិយោគិនអាចមកវិនិយោគនៅកម្ពុជា ហើយភ្ញៀវទេសចរអាចមកទស្សនាកម្ពុជាបានហើយ។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

៣-ការកាត់ទោសមេដឹកនាំខ្មែរក្រហម និងការបិទទំព័រប្រវត្តិសាស្ត្រខ្មៅងងឹត

ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ការបង្កើតតុលាការកូនកាត់ ៖ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ ២០០៣ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ដោយមានសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាជាជនជាតិខ្មែរ និងជាបរទេស។

សំណុំរឿងតុលាការ

សំណុំរឿង០០១ ៖ កាំង ហ្គេកអ៊ាវ ហៅឌុច អតីតប្រធានមន្ទីរស២១ ជាជនជាប់ចោទក្នុងសំណុំរឿង០០១។ អង្គជំនុំជម្រះសាលាដំបូងរកឃើញថាឌុចមានពិរុទ្ធភាពពីបទ ៖ (១)ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត) (២) ការបំពានបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ លើឧក្រិដ្ឋកម្មមួយចំនួនដូចជា ៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌។ល។ អង្គជំនុំជម្រះសាលាដំបូងបានកាត់ទោសឱ្យគាត់ជាប់ពន្ធនាគារយៈពេល ៣៥ឆ្នាំ និងបានបន្ថយទោសជាប់ពន្ធនាគារយៈពេល៣០ឆ្នាំ។

សំណុំរឿង០០២ ៖ អតីតមេដឹកនាំខ្មែរក្រហមពីរនាក់កំពុងស្ថិតនៅក្នុងដំណាក់កាលជំនុំជម្រះនៃសំណុំរឿង០០២៖ (១) នួន ជា អតីតប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និង (២) ខៀវ សំផន អតីតប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ជនជាប់ចោទទាំងពីរត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

និងអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និងវៀតណាម។ ជនជាប់ចោទពីរនាក់ផ្សេងទៀតគឺ អៀង សារី និងប្រពន្ធរបស់គាត់ អៀង ធីរិទ្ធ ក៏ជាផ្នែកមួយនៃសំណុំរឿង០០២ផងដែរ។ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងអៀង សារីត្រូវបានបញ្ចប់នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ក្រោយពីគាត់បានស្លាប់នៅថ្ងៃដដែលនេះ។ អៀង ធីរិទ្ធត្រូវបានបញ្ជូនទៅជំនុំជម្រះ ប៉ុន្តែក្រោយមកត្រូវបានរកឃើញថា ពុំមានសមត្ថភាពចូលរួមក្នុងការជំនុំជម្រះបានទេ ដោយសារតែជំងឺវង្វេងស្មារតី។ នួន ជា និងខៀវ សំផនត្រូវបានតុលាការរកឃើញថា មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

សំណុំរឿង០០៣ ៖ មាស មុត និងស៊ូ ម៉ែត ត្រូវបានគេដាក់ឈ្មោះថាជាជនសង្ស័យក្នុងសំណុំរឿង០០៣។ ការស៊ើបអង្កេតរបស់តុលាការប្រឆាំងលោក ស៊ូ ម៉ែតត្រូវបានបញ្ចប់នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ បន្ទាប់ពីគាត់បានស្លាប់។ លោក មាស មុត ត្រូវបានចោទប្រកាន់ដោយកំប៉ាំងមុខនៅក្នុងខែមីនា ឆ្នាំ២០១៥។ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ចប់ការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ប្រឆាំងនឹងមាស មុត។ មាស មុតជាសមាជិកគណៈមជ្ឈិមលេខាធិការវង លេខាកងពល ១៦៤ (រាប់បញ្ចូលទាំងកងទ័ពជើងទឹក) លេខាស្វយ័តកំពង់សោម។

សំណុំរឿង០០៤ ៖ នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាបញ្ជូនរឿងឱ្យស៊ើបសួរចំនួន៦ទៅសហចៅក្រមស៊ើបអង្កេតស្នើសុំឱ្យបើកការស៊ើបអង្កេតលើឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងជនសង្ស័យចំនួនប្រាំរូបទៀត។ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់លោក យឹម ទិត្យ នៅក្នុងសំណុំរឿង ០០៤។ យឹម ទិត្យ គឺជាបុគ្គលមានអំណាចម្នាក់នៅកូមិកាគនិរតី ដោយបានឡើងពីអនុលេខាស្រុកគិរីវង់ដល់លេខាស្រុក និងបន្ទាប់មកទៀតបានឡើងជាអនុលេខា និងលេខាតំបន់១៣។ គាត់បានត្រួតត្រាបណ្តាស្រុក

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នានាដែលមានមន្ទីរសន្តិសុខ និងទីតាំងសម្ងាប់មនុស្សជាច្រើនស្ថិតនៅក្នុងនោះ។ សហព្រះរាជអាជ្ញាជាតិប្រកាន់ជំហរថា យឹម ទិត្យ មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់អ.វ.ត.កឡើយ ដោយគាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យឡើយ។

នៅថ្ងៃទី៣ ខែមីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ដោយកំពាំងមុខនៅក្នុងសំណុំរឿង០០៤។ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចេញការពិចារណារបស់ខ្លួនលើពាក្យបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដែលបានសម្រេចលើកលែងការចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម លើបទល្មើសព្រហ្មទណ្ឌនានាដោយមូលហេតុមិនមានយុត្តាធិការបុគ្គល។ អ៊ឹម ចែម ជាលេខាស្រុកព្រះនេត្រព្រះ និងអនុលេខាតំបន់៥នៃកូមិកាគពាយ័ព្យ។

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់អោ អាន នៅក្នុងសំណុំរឿង០០៤ពីបទឧក្រិដ្ឋកម្ម ៖ (១) អំពើប្រល័យពូជសាសន៍លើជនជាតិចាម (២) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្តទៅនៅភូមិភាគកណ្តាល (ឧត្តរចាស់) ជាពិសេសនៅកន្លែងសម្ងាប់មនុស្សគោគព្រីង នៅមន្ទីរសន្តិសុខវត្តអូរត្រកួន និងកន្លែងដទៃទៀតនៅខេត្តកំពង់ចាម។ អោ អានជាអនុលេខាភូមិភាគកណ្តាល និងជាលេខាតំបន់៦១។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំពូក១៥
ការបើកសកម្មភាពថ្មី និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា

១-ការសម្រេចបាននូវសុខសន្តិភាពទូទាំងប្រទេស

លក្ខខណ្ឌសម្រាប់ការអភិវឌ្ឍនៅមិនទាន់មាន ៖ ក្នុងឆ្នាំ១៩៩៣-១៩៩៧ រាជរដ្ឋាភិបាលកម្ពុជានៅពុំទាន់អាចនាំមកនូវលក្ខខណ្ឌនយោបាយនិងសន្តិសុខ ដែលចាំបាច់សម្រាប់ឱ្យមានរដ្ឋាភិបាលបង្រួបបង្រួម និងមានស្ថិរភាពមួយនៅឡើយទេ។ កម្លាំងយោធាខ្មែរក្រហមនៅតែជាកម្លាំងសំខាន់មួយ ដែលជាការគំរាមកំហែងយ៉ាងខ្លាំងមួយដល់សន្តិសុខរបស់ប្រទេស ចំណែករចនាសម្ព័ន្ធសង្គមរបស់ប្រទេសនៅមានភាពផុយស្រួយនៅឡើយ។ លើសពីនេះទៅទៀត ទោះបីជារាជរដ្ឋាភិបាលខិតខំយ៉ាងណាក៏ដោយ ក៏កំណើនសេដ្ឋកិច្ចសម្រេចបានយ៉ាងទាប ក្នុងឆ្នាំ១៩៩៧-១៩៩៨ ដោយសារតែព្រឹត្តិការណ៍នយោបាយក្នុងស្រុក និងវិបត្តិហិរញ្ញវត្ថុនៅអាស៊ី ដែលផ្ទុះឡើងនៅក្នុងឆ្នាំ១៩៩៧។

ការបញ្ចប់ទាំងស្រុងការបែងចែកទឹកដី ៖ ក្រោយពីអនុវត្ត«នយោបាយឈ្នះ-ឈ្នះ» ដែលដាក់ចេញដោយសម្តេចហ៊ុន សែន បានដោយជោគជ័យ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ក្នុងឆ្នាំ១៩៨៨រួចមក រាជរដ្ឋាភិបាលកម្ពុជាអាចរំលាយចោលអង្គការចាត់តាំងយោធា និងនយោបាយរបស់ខ្មែរក្រហម និងនាំមកនូវការស្តារបានឡើងវិញនូវសុខសន្តិភាពទូទាំងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការបង្រួបបង្រួមនយោបាយរបស់ប្រទេស។ សង្គ្រាម និងជម្លោះប្រដាប់អាវុធផ្ទៃក្នុងត្រូវបានបញ្ចប់ទាំងស្រុង។ ប្រទេសកម្ពុជាត្រូវបានរួបរួមគ្នាជាលើកទី១ក្រោយពីការបែកបាក់គ្នាអស់ជាច្រើនសតវត្សមកហើយ។ នៅលើទឹកដីកម្ពុជាជានិច្ចជាកាលតែងតែមានកងកម្លាំងប្រដាប់អាវុធ ដែលធ្វើទុក្ខបុកម្នេញដល់ប្រជាពលរដ្ឋ ដែលរស់នៅតាមតំបន់ជាច់ស្រយាល។ ជាពិសេសមុនឆ្នាំ១៩៧០ ថ្វីត្បិតតែទឹកដីខ្មែរភាគច្រើនលើសលប់ កាន់កាប់ដោយរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមក៏ដោយ ក៏តំបន់ជាយដែន និងជាច់ស្រយាលខ្លះត្រូវបានកាន់កាប់ដោយខ្មែរក្រហម ដែលមានការគាំទ្រដោយកងទ័ពវៀតណាមខាងជើង តំបន់នៅជាប់ព្រំដែនថៃត្រូវបានកាន់កាប់ដោយពួកឧទ្ទាមខ្មែរខៀវ ហើយតំបន់នៅជាប់ព្រំដែនវៀតណាម ត្រូវបានកាន់កាប់ដោយពួកឧទ្ទាមខ្មែរស ដោយមានការឧបត្ថម្ភគាំទ្រពីបរទេស។ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចសីហនុ នៅខែមីនា ឆ្នាំ១៩៧០ ទឹកដីកម្ពុជាទាំងមូលត្រូវបានបែងចែកជាពីរគឺ ៖ តំបន់ដែលរដ្ឋាភិបាលលន់ នល់គ្រប់គ្រង និងតំបន់រំដោះក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហម។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ទឹកដីកម្ពុជាត្រូវបានបែកចែកជាតំបន់ត្រួតត្រា៤គឺ តំបន់ដែលកាន់កាប់ដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា និងតំបន់បីទៀតគ្រប់គ្រងដោយភាគីនៃរដ្ឋាភិបាលត្រីភាគីគឺ តំបន់ត្រួតត្រាដោយ FUNCINPEC តំបន់ត្រួតត្រាដោយ KPNLF និងតំបន់ត្រួតត្រាដោយពួកខ្មែរក្រហម។ ក្រោយពីការបោះឆ្នោតខែកក្កដា ឆ្នាំ១៩៩៣ កម្ពុជាត្រូវបានបែកចែកជាពីរគឺ តំបន់ដែលគ្រប់គ្រងដោយរាជរដ្ឋាភិបាលកម្ពុជា និងតំបន់ដែលត្រួតត្រាដោយកងទ័ពខ្មែរក្រហម។ ដូច្នេះ «នយោបាយឈ្នះ-ឈ្នះ» បាននាំមកនូវការបង្រួបបង្រួមទឹកដី និងជាតិកម្ពុជាឱ្យវេញត្រចាញ់ជាឆ្នងមួយ។ រដ្ឋាភិបាល

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

អាចបោះជំហានពង្រឹងស្មារតីនៃការបង្រួបបង្រួមនិងផ្សះផ្សាជាតិ។

ការផ្សះផ្សាជាតិ ៖ ការអនុវត្ត«នយោបាយឈ្នះ-ឈ្នះ» បាននាំមកនូវការផ្សះផ្សាជំពៅកម្ពុជា ដែលបំផ្ទាញកោសិកាជាតិអស់រយៈពេលជាង បីទសវត្សរ៍បុងក្រោយនេះ។ ក្រោយរបបប៉ុល ពត ជនជាតិកម្ពុជាកើតជំងឺភ័យខ្លាច មិនទុកចិត្តគ្នា លាបពណ៌គ្នា ដែលធ្វើឱ្យមូលធនសង្គមខ្មែរបាត់-បង់។ ការបែកបាក់ជាតិ គឺជាផលវិបាកដ៏ធំ ដែលរារាំងកម្ពុជាមិនអាចដើរទៅមុខយ៉ាងស្ទាហាប់បាន។

ការផ្ទុះអាវុធនៅទីក្រុងភ្នំពេញនៅឆ្នាំ១៩៩៧ ៖ ការចុះចូលនៃមេដឹកនាំកងពលខ្មែរក្រហមជាមួយសម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីទី២នៃរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតនូវការប្រណាំងប្រជែងរវាងគណបក្សទាំងពីរក្នុងរាជរដ្ឋាភិបាលកម្ពុជាគឺ គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊ុនស៊ីនប៉ិច។ កងទ័ពដែលស្មោះត្រង់នឹងសម្តេចនរោត្តម រណឫទ្ធិបាននាំយកកម្លាំងខ្មែរក្រហមចូលក្នុងទីក្រុងភ្នំពេញ ហើយការប្រណាំងប្រជែងនេះបានក្លាយទៅជាជម្លោះប្រដាប់អាវុធ នៅថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ នៅកណ្តាលក្រុងភ្នំពេញ។

២-ការឡើងសោយរាជ្យរបស់ព្រះករុណា នរោត្តម សីហមុនី

ដើម្បីជៀសវាងវិបត្តិរាជបល្ល័ង្ក ដែលតែងតែកើតឡើងមិនចេះឈប់ឈរនៅក្នុងប្រវត្តិសាស្ត្រខ្មែរ សម្តេចសីហនុបានប្រកាសនៅឆ្នាំ២០០៤ថាព្រះអង្គនឹងដាក់រាជ្យ។ តាមរដ្ឋធម្មនុញ្ញ ដើម្បីអាចក្លាយជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបាន មានតែសមាជិកនៃរាជវង្សានុវង្សខ្មែរ ដែលជាព្រះរាជបច្ចាញាតិនៃព្រះមហាក្សត្រអង្គដួង ឬព្រះមហាក្សត្រនរោត្តម ឬព្រះមហាក្សត្រសីសុវត្ថិ។

ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ត្រូវបានក្រុមប្រឹក្សារាជសម្បត្តិជ្រើសតាំងជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

កម្ពុជាបន្តពីព្រះបិតា កាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៤។ ព្រះរាជពិធីរាជាភិសេកព្រះអង្គជាផ្លូវការត្រូវបានប្រារព្ធឡើងនៅក្នុងព្រះបរមរាជវាំងក្រុងភ្នំពេញ នាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤។

ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ទ្រង់ចូលទិវង្គតនៅថ្ងៃចន្ទ ទី១៥ ខែតុលា ឆ្នាំ២០១២។ ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ជាព្រះមហាវីរក្សត្រដ៏មានឥទ្ធិពលរបស់កម្ពុជា ចាប់ពីឆ្នាំ១៩៥៣ដល់២០០៤។ ព្រះអង្គត្រូវបានប្រសិទ្ធិនាមជាផ្លូវការជាមួយគោរម្យងារ ព្រះករុណា ព្រះបាទ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ។ ហ្វូងមនុស្សបានប្រមូលផ្តុំគ្នាលើផ្លូវនានានៅភ្នំពេញដើម្បីធ្វើការលាព្រះសីហនុជាចុងក្រោយ ពេលដែលព្រះសពរបស់ព្រះអង្គត្រូវបានដឹកទូទាំងទីក្រុង។

៣-យុទ្ធសាស្ត្រអភិវឌ្ឍកម្ពុជាក្នុងគ្រប់វិស័យ

ក្រោយការបោះឆ្នោតនៅខែកក្កដា ឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តយុទ្ធសាស្ត្រត្រីកោណ ដែលមានទិសដៅជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា។

មុំទីមួយនៃ"ត្រីកោណ" ៖ គឺការទាំសុខសន្តិភាព និងស្ថិរភាពមកវិញ និងការរក្សាបាននូវសន្តិសុខសម្រាប់ប្រទេស និងប្រជាជនខ្លួន ឥឡូវជាការពិត ចំណុចនេះរដ្ឋាភិបាលធ្វើបានសម្រេចហើយ។

មុំទីពីរនៃ"ត្រីកោណ" ៖ ដែលផ្តោតលើ សមាហរណកម្ម ប្រទេសកម្ពុជាចូលក្នុងតំបន់ និងប្រក្រតីភាវូបនីយកម្មនៃទំនាក់ទំនងរបស់ខ្លួនជាមួយសហគមន៍អន្តរជាតិ ក៏បានសម្រេចដោយជោគជ័យផងដែរ។

ការកាន់កាប់ឡើងវិញអាសនៈនៅអង្គការសហប្រជាជាតិ ៖ ប្រទេសកម្ពុជាបានទទួលអាសនៈរបស់ខ្លួននៅឯអង្គការសហប្រជាជាតិមកវិញ ដែលអាសនៈនេះបានបាត់បង់កាលពីក្រោយការ ប្រឈមគ្នាខាងប្រដាប់អាវុធ នៅខែកក្កដា ឆ្នាំ១៩៩៧។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

សមាហរណកម្មកម្ពុជាទៅក្នុងតំបន់ ៖ ក្នុងខែមេសា ឆ្នាំ ១៩៩៩ កម្ពុជា បានក្លាយជាសមាជិកទីដប់នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)។ មូលហេតុដែលកម្ពុជាចូលជាសមាជិកអាស៊ានគឺ ៖ (១) អាស៊ានអនុវត្ត គោលការណ៍មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង (២) ស្មារតីសហគមន៍ ៖ ការសម្រេចចិត្តដោយកុងសង់ស៊ីស (៣) ផលប្រយោជន៍សេដ្ឋកិច្ច និង សង្គម (៤) អាស៊ាន គឺជាច្រកការទូតរបស់កម្ពុជា និង (៥) អាស៊ានក៏ជា កត្តាជានាទូវការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា ជាពិសេសការជានាបាន នូវសុខសន្តិភាពទាំងនៅក្នុងប្រទេស ទាំងនៅក្នុងតំបន់។

កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៅក្នុងអាស៊ានបានទាំឆ្ពោះទៅរកការ បង្កើតតំបន់ពាណិជ្ជកម្មសេរី។ កម្ពុជាក៏ជាផ្នែកមួយនៃមហាអនុតំបន់មេគង្គ (GMS)។ សកម្មភាពកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់របស់កម្ពុជាឥឡូវនេះ រួមមាន ក្រុមតំបន់ថ្មីដែលសំដៅទៅលើ"អាស៊ាន+៣" ដែលនៅក្នុងក្រុម នេះរួមមានចិន ជប៉ុន និងកូរ៉ែខាងត្បូងក៏ដូចជាវេទិកាតំបន់អាស៊ាន (ARF) ដែលការពិភាក្សាផ្តោតទៅលើបញ្ហាសន្តិសុខតំបន់។ នៅក្នុងឆ្នាំ២០០៤ កម្ពុជា បានក្លាយទៅជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ហើយ បានចាប់ផ្តើមចូលរួមនៅក្នុងកិច្ចប្រជុំផ្សេងៗរួមមានកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM)។

ក្នុងនាមជាប្រទេសសមាជិកថ្មីមួយ កម្ពុជាអាចទទួលបានអត្ថប្រ-យោជន៍ពីគំនិតផ្តួចផ្តើមមួយចំនួនដែលបង្កើតឡើងដោយដៃគូ ដែលមាន ការអភិវឌ្ឍជាងសម្រាប់ប្រទេសជាសមាជិកថ្មី និងប្រទេសជាសមាជិក ដែលមានការអភិវឌ្ឍតិចតួចរបស់អាស៊ានរួមមានប្រព័ន្ធអនុគ្រោះសមា-ហរណកម្មអាស៊ាន (AISP) (៣៦៩មុខ)។ កិច្ចព្រមព្រៀងក្របខ័ណ្ឌដទៃ ទៀតជាមួយនឹងដៃគូអាស៊ានក៏បាននាំមកនូវផលប្រយោជន៍សម្រាប់កម្ពុជា ដែលក្នុងចំណោមផលប្រយោជន៍ទាំងអស់នេះរួមមាន ពន្ធគយអនុគ្រោះ និងពិសេស (SPT) ជាមួយនឹងប្រទេសចិន (២៩៧មុខ) ប្រព័ន្ធអនុគ្រោះ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ពន្ធទូទៅ (GSP) ជាមួយប្រទេសជប៉ុន (៦៦មុខ) និងសាធារណរដ្ឋកូរ៉ៃ (៣៨មុខ)។

នៅពេលដែលកម្ពុជាបានក្លាយជាសមាជិកអាស៊ានកម្ពុជាបានក្លាយជាផ្នែកមួយនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA)។ វិសាលភាពរបស់កិច្ចព្រមព្រៀងគ្របដណ្តប់ទៅលើផលិតផលដែលបានកំណត់ដោយឈរលើតាមផ្នែកជាមួយនឹងបរិមាណតម្លៃបន្ថែមជាក់លាក់ហើយមានប្រកពក្នុងតំបន់ពាណិជ្ជកម្មសេរី។ ការបង្កើតតំបន់ពាណិជ្ជកម្មសេរីគឺជាបញ្ហាប្រឈមទីមួយរបស់កម្ពុជានៅក្នុងដំណើរដ៏វែងឆ្ងាយ ក្នុងការធ្វើសមាហរណកម្មជាមួយនឹងអាស៊ាន។

យន្តការគន្ធីះដើម្បីអនុវត្ត AFTA គឺអនុគ្រោះពន្ធគយរួម។ នៅក្រោមកិច្ចព្រមព្រៀងនេះប្រទេសជាសមាជិកបានឯកភាពកាត់បន្ថយពន្ធគយទៅលើទំនិញដែលនាំចូលពីប្រទេសអាស៊ានដទៃទៀតនៅក្នុងអត្រាពី០ និង ៥% នៅក្នុងកាលកំណត់១៥ឆ្នាំ។ គំនិតផ្តួចផ្តើមគន្ធីះខ្លះដែលបង្កើតឡើងដោយអាស៊ានរួមមាន"កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន-ចិនលើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ" "កិច្ចព្រមព្រៀងដៃគូសេដ្ឋកិច្ចទូលំទូលាយអាស៊ាន-ជប៉ុន" "កិច្ចព្រមព្រៀងក្របខ័ណ្ឌឥណ្ឌា-អាស៊ានស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ" តំបន់ពាណិជ្ជកម្មសេរីរវាងអាស៊ាននិងសាធារណរដ្ឋកូរ៉ៃ ហើយនឹងតំបន់ពាណិជ្ជកម្មសេរី AFTA-CER (ទំនាក់ទំនងសេដ្ឋកិច្ចជិតស្និទជាមួយនឹងអូស្ត្រាលី និងណូវែលហ្សេឡង់)។ ការបង្កើនការវិនិយោគផលិតកម្មនិងការប្រើប្រាស់ដែលបានមកពីកត្តាទាំងអស់នេះនឹងផ្តល់ផលប្រយោជន៍ដល់កម្ពុជាថែមទៀតក្នុងនាមជាសមាជិកអាស៊ាន។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

៤-សមិទ្ធផលនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជានៅក្នុងឆ្នាំ ១៩៩៩-២០១៨

កំណែទម្រង់ ៖ មុំទីបីនៃ«យុទ្ធសាស្ត្រត្រីកោណ»របស់រដ្ឋាភិបាលកម្ពុជា គឺការជំរុញការអភិវឌ្ឍសង្គមសេដ្ឋកិច្ច តាមរយៈកម្មវិធីកំណែទម្រង់ទូលំទូលាយ ដែលពាក់ព័ន្ធនឹងកំណែទម្រង់សាធារណៈ វិមជ្ឈការ ការកាត់បន្ថយចំនួនកងទ័ព កំណែទម្រង់ច្បាប់និងតុលាការ សមភាពយេនឌ័រ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការលុបបំបាត់អំពើពុករលួយ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។

ការអភិវឌ្ឍសេដ្ឋកិច្ច ៖ យើងអាចបែងចែកការវិវត្តសេដ្ឋកិច្ចកម្ពុជាជាដំណាក់កាលសំខាន់ៗដូចតទៅ ៖ (១) ដំណាក់កាលស្ដារឡើងវិញ ពីឆ្នាំ១៩៧៩-១៩៨៨ (២) ដំណាក់កាលអន្តរកាល ពីឆ្នាំ១៩៨៩-១៩៩២ (៣) ដំណាក់កាលនៃការស្ដារបនាឡើងវិញ ពីឆ្នាំ១៩៩៣-១៩៩៨ និង (៤) ដំណាក់កាលអភិវឌ្ឍន៍ចាប់ផ្ដើមពីឆ្នាំ១៩៩៩មក។ សេដ្ឋកិច្ចកម្ពុជាកើនឡើងជាលំដាប់ ក្នុងដំណាក់ទាំងបួននេះ ៖

ឆ្នាំ១៩៧៩-១៩៨៨ ៖ កម្ពុជាត្រូវចាប់ផ្ដើមកសាងប្រទេសពីបាតដៃទទេ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមរួចមក។ នៅក្នុងដំណាក់កាលស្ដារឡើងវិញ ពីឆ្នាំ១៩៧៩-១៩៩០ ប្រទេសកម្ពុជាត្រូវប្រឈមនឹងផលវិបាកនៃការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច។ អត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំកើនឡើងមិនលើស៣,៤%ក្នុង១៩៨៨-១៩៩១ ទោះបីជាកំណើនមធ្យមប្រចាំឆ្នាំក្នុងវិស័យពោធិចក្រកើនឡើងដល់៦,៣%ក៏ដោយ។

ឆ្នាំ១៩៨៩-១៩៩២ ៖ គឺជាដំណាក់កាលអន្តរកាល ដើម្បីបង្កើតមូលដ្ឋានសេដ្ឋកិច្ចទីផ្សារ ដូចជាការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៨៩ ដើម្បីទទួលស្គាល់នូវកម្មសិទ្ធិឯកជន ឯកជនភាវូបនីយកម្មនៃសហគ្រាសរដ្ឋ ការរំលាយចោលនូវក្រុមសាមគ្គីបង្កបង្កើនផលក្នុងវិស័យកសិកម្ម និងការរៀបចំការបោះឆ្នោតសេរី ពហុបក្ស ដើម្បីបង្កើតឡើងនូវមូលដ្ឋានគ្រឹះ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នៃលទ្ធិប្រជាធិបតេយ្យជាដើម។

ឆ្នាំ១៩៩៣-១៩៩៨ ៖ គឺជាដំណាក់កាលពង្រឹងមូលដ្ឋានសេដ្ឋកិច្ច ទីផ្សារ និងការកសាងឡើងវិញ តាមរយៈការអនុវត្តនូវកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈលើកទីមួយ ក្នុងគោលដៅពង្រឹងមូលដ្ឋាននៃការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ការរៀបចំប្រព័ន្ធថវិកាជាតិ និងប្រព័ន្ធប្រមូលពន្ធប្រមូលផ្តុំនៅរដ្ឋបាលកណ្តាល និងការរៀបចំក្របខ័ណ្ឌគតិយុត្តិសម្រាប់សហគ្រាសសាធារណៈ និងឯកជន។ នៅក្នុងដំណាក់កាលនេះ កម្ពុជាសម្រេចបានអត្រាមធ្យមប្រចាំឆ្នាំ៦,៣% ទោះបីជាមានវិបល្លាស ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុនៅអាស៊ីនៅឆ្នាំ១៩៩៧-១៩៩៨យ៉ាងណាក្តី។

ឆ្នាំ១៩៩៩-បច្ចុប្បន្ន ៖ គឺជាដំណាក់កាលអភិវឌ្ឍន៍ ដែលចាប់ផ្តើមពីការអនុវត្ត«យុទ្ធសាស្ត្រត្រីកោណ» ដើម្បីពង្រឹងសុខសន្តិភាព និងធ្វើសមាហរណកម្មចូលក្នុងតំបន់ និងពិភពលោក។ ការចោះឡោតនៅឆ្នាំ១៩៩៨ បានបង្កើតនូវលក្ខខណ្ឌចាំបាច់នានាសម្រាប់បង្កើតស្ថិរភាពនយោបាយនៅក្នុងប្រទេស និងអាចឱ្យរដ្ឋាភិបាលផ្តោតលើការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច។ ចាប់ពីឆ្នាំ២០០៤មក គឺជាដំណាក់កាលអនុវត្ត«យុទ្ធសាស្ត្រចតុកោណ» ដោយផ្តោតជាសំខាន់លើការពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់ប្រព័ន្ធធនាគារ និងការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ជាពិសេសការកសាងឡើងវិញនៃប្រព័ន្ធផ្លូវជាតិ។ ដំណាក់កាលនេះ គឺជាដំណាក់កាលហក់ឡើងនៃសេដ្ឋកិច្ចកម្ពុជា និងការអនុវត្តកំណែទម្រង់ដំណាក់កាលទី២ ជាពិសេសការអនុវត្តនូវយុទ្ធសាស្ត្រចតុកោណ ការចាប់ផ្តើមអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទីមួយ និងការកសាងនូវប្រព័ន្ធផ្លូវខេត្ត និងផ្លូវលំ។ នៅក្នុងដំណាក់កាលនេះ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនខ្ពស់ និងការវិនិយោគទុនកើនឡើង ការគ្រប់គ្រងរូបិយវត្ថុ និងសារពើពន្ធបានប្រសើរជាងមុន ដែលជាលទ្ធផលនាំឱ្យមានអតិផរណាទាប និងទុន

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បម្រុងអត្រាប្តូរប្រាក់ខ្ពាំង លំហូរចូលនៃការផ្ទេរប្រាក់ពីបរទេសផ្ទៀងការ និង មូលធនឯកជនច្រើនជាងមុន និងការអភិវឌ្ឍវិស័យឯកជនបានលឿន។ កម្ពុជាទទួលបាននូវជំនួយពីក្រៅប្រទេសយ៉ាងច្រើនសន្ធឹកសន្ធាប់ សម្រាប់ការអភិវឌ្ឍប្រទេសជាតិ។

យុទ្ធសាស្ត្រចតុកោណ ៖ នៅឆ្នាំ២០០៣ ប្រទេសកម្ពុជាបានដើរដល់ចំណុចផ្លូវប្រសព្វមួយនៅចុងអាណត្តិនយោបាយទី៤របស់រដ្ឋាភិបាល។ ក្រោយការបោះឆ្នោតឆ្នាំ២០០៣ ប្រទេសកម្ពុជាពិតជាចង់ធ្វើដំណើរឱ្យបានលឿនលើវិថីនៃទំនើបភាវូបនីយកម្ម។ នៅពេលចាប់ផ្តើមពិធីបើកកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែនជាក់ចេញនូវ«យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា»។ ចំណុចស្នូលនៃយុទ្ធសាស្ត្រនេះគឺអភិបាលកិច្ចល្អ។ ជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រនេះ គឺអាស្រ័យលើការបង្កើតនូវបរិយាកាសអំណោយផលមួយក្នុង ផ្នែកសំខាន់ៗទាំងបួន ៖ (១) សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម (២) ភាពជាដៃគូសម្រាប់ការអភិវឌ្ឍ ជាពិសេសភាពជាដៃគូជាមួយវិស័យឯកជន សហគមន៍ម្ចាស់ជំនួយ និងសង្គមស៊ីវិល (៣) ស្ថិរភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង (៤) សមាហរណកម្មកម្ពុជាចូលទៅក្នុងតំបន់ និងពិភពលោក។

មុំទាំងបួននៃចតុកោណដែល ផ្តោតលើកំណែទម្រង់មាន ៖ (១) ការលុបបំបាត់អំពើពុករលួយ (២) កំណែទម្រង់ច្បាប់ និងតុលាការ (៣) កំណែទម្រង់រដ្ឋបាលសាធារណៈ រួមទាំងវិមជ្ឈការ និងសហវិមជ្ឈការ និង (៤) កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ជាពិសេសការកាត់រំសាយទ័ព។ ចុងក្រោយ មុំទាំងបួននៃចតុកោណសម្រាប់ការបង្កើតកំណើនគឺ ៖ (១) ការជំរុញវិស័យកសិកម្ម (២) ការអភិវឌ្ឍវិស័យឯកជន និងការបង្កើតការងារ (៣) ការស្តារនីតិសម្បទា និងការស្តាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ និង (៤) ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជារួម ថ្វីត្បិតតែមូលដ្ឋានសេដ្ឋកិច្ចកម្ពុជាត្រូវបានពង្រឹងចាប់តាំងពីឆ្នាំ១៩៩៣ តាមរយៈការបង្កើតឡើងនូវរាជរដ្ឋាភិបាលនីតិកាលទីមួយ ការអភិវឌ្ឍសេដ្ឋកិច្ចពិតប្រាកដទើបតែចាប់ផ្តើមនៅក្នុងឆ្នាំ១៩៩៩ប៉ុណ្ណោះ ដោយកម្ពុជាបានធ្វើសមាហរណកម្មបន្តនូវតំបន់ផ្សេងៗដែលពីពេលមុនស្ថិតនៅក្នុងការត្រួតត្រារបស់ពួកខ្មែរក្រហម និងការកសាងឡើងវិញនូវបណ្តាញផ្លូវ ដើម្បីផ្សារភ្ជាប់សេដ្ឋកិច្ចកម្ពុជាឱ្យក្លាយទៅជាសរីរាង្គតែមួយ។ នៅផ្នែកខាងក្រោមនេះ យើងនឹងវិភាគពីការផ្លាស់ប្តូរចនាសម្ព័ន្ធនៃសេដ្ឋកិច្ចកម្ពុជានៅក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ដោយផ្តោតជាសំខាន់លើដំណាក់កាលមួយទសវត្សរ៍ចុងក្រោយនៃកំណើនសេដ្ឋកិច្ច។

ក-សេដ្ឋកិច្ចកម្ពុជា

ចាប់តាំងពីឆ្នាំ១៩៩៦មកដល់ឆ្នាំ២០១៨ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនខ្ពស់ប្រកបដោយចីរភាព ដោយមានកំណើនសេដ្ឋកិច្ចជាមធ្យម៧% ក្នុងមួយឆ្នាំ ហើយកម្ពុជាជាប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ជាងគេក្នុងចំណោមប្រទេសចំនួន១០លើសកលលោក។ សេដ្ឋកិច្ចកម្ពុជាមានមូលដ្ឋានសំខាន់ៗដូចជា ៖ វិស័យកសិកម្ម ឧស្សាហកម្មកាត់ដេរ វិស័យសំណង់ និងវិស័យទេសចរណ៍។

កសិកម្ម ៖ វិស័យកសិកម្មនៅតែជាវិស័យចម្បងនៃសេដ្ឋកិច្ចកម្ពុជា និងជាប្រភពនៃការបង្កើតការងារនៅកម្ពុជា។ នៅឆ្នាំ២០១៨ កសិកម្មមានចំណែកស្មើនឹង៣០%នៃផលិតផលសរុបក្នុងស្រុក និងបង្កើតការងារសម្រាប់ប្រជាពលរដ្ឋកម្ពុជាចំនួន៤០%។ វិស័យកសិកម្មសំខាន់ៗមាន ដំណាំស្រូវ កៅស៊ូ ពោត សណ្តែក លូ ដំឡូងមី ម្រេច ស្វាយចន្ទី ដំណាំហូបផ្លែ និងដំណាំបន្លែ។ លក្ខណៈសំខាន់នៃវិស័យកសិកម្មក្នុងឆ្នាំ២០១៨ គឺការប្រើប្រាស់គ្រឿងយន្តកសិកម្មជំនួសសត្វពាហនៈ ការកាត់បន្ថយចំនួនកម្លាំងពលកម្មក្នុងវិស័យកសិកម្ម ដើម្បីរំដោះកម្លាំងពលកម្មឱ្យទៅធ្វើការនៅក្នុងវិស័យ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កាត់ដេរវិញ។ ក្នុងន័យនេះ វិស័យកសិកម្មក្នុងពេលអនាគតនឹងលែងបង្កើតទីកន្លែងការងារដ៏ច្រើនលើសលប់ ដូចពេលមុនទៀតហើយ។

ឧស្សាហកម្ម ៖ នៅកម្ពុជាមានសហគ្រាសប្រមាណជាកន្លះលានដែលដំណើរការក្នុងគ្រប់វិស័យ ដែលភាគច្រើន គឺជាសហគ្រាសមីក្រូ និងសហគ្រាសតូច និងមធ្យម។ នៅឆ្នាំ២០១៨ នៅកម្ពុជាមានរោងចក្រឧស្សាហកម្មទាំងអស់ចំនួនប្រមាណជា១៥០០ ដែលក្នុងនោះរោងចក្រកាត់ដេរមានចំនួន១០០០ ដែលបង្កើតការងារធ្វើដល់កម្មករជិត១លាននាក់ ដែលក្នុងនោះមានស្ត្រីប្រមាណជាជិត៩០%។ ក្រៅពីរោងចក្រកាត់ដេរ គេឃើញមានរោងចក្រផលិតអាហារ កេសជ្ជៈ ថ្នាំ ថ្នាស្ងិច និងឧស្សាហកម្មគីមីជាដើម។ កម្ពុជានាំចេញផលិតផលកាត់ដេរចំនួន៧ពាន់លានដុល្លារ ដែលមានចំណែកស្មើនឹង៨០%នៃការនាំចេញទំនិញសរុប។

ទេសចរណ៍ ៖ ទេសចរណ៍ជាវិស័យដ៏សំខាន់សម្រាប់សេដ្ឋកិច្ចកម្ពុជា។ នៅកម្ពុជាមានរមណីយដ្ឋានទេសចរណ៍វប្បធម៌ និងធម្មជាតិជាច្រើនឥតគណនា។ នៅឆ្នាំ២០១៨ មានភ្ញៀវទេសចរចំនួន៦លាននាក់មកទស្សនាកម្ពុជា ហើយបង្កើតការងារធ្វើបានរហូតដល់ជិតកន្លះលាននាក់។

ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ៖ កម្ពុជាសម្រេចបានវឌ្ឍនភាពសេដ្ឋកិច្ចគួរជាទីមោទនក្នុងរយៈពេល២ទសវត្សរ៍កន្លងទៅ ជាមួយនឹងកំណើនផលិតផលសរុបក្នុងស្រុកពិត (ផសស) ជាមធ្យមប្រចាំឆ្នាំប្រមាណជា៧,៨%ក្នុងរវាងឆ្នាំ១៩៩៨ដល់២០១៨។ ផលិតផលសរុបក្នុងស្រុកបានកើនឡើងជិតប្រាំបីដងពី៣,១ពាន់លានដុល្លារអាមេរិកនៅក្នុងឆ្នាំ១៩៩៨ដល់២៦,៥ពាន់លានដុល្លារនៅក្នុងឆ្នាំ២០១៨។ ជាមួយគ្នានេះដែរ ចំណូលប្រជាជនម្នាក់ៗបានកើនឡើងជាងប្រាំមួយដងពី២៥៣ដុល្លារអាមេរិកក្នុងមួយឆ្នាំ នៅក្នុងឆ្នាំ១៩៩៨ដល់១ ៥៥៥ដុល្លារអាមេរិកក្នុងមួយឆ្នាំ នៅក្នុងឆ្នាំ២០១៨។ ក្រៅពីកំណើនសេដ្ឋកិច្ចខ្ពស់ រាជរដ្ឋាភិបាលកម្ពុជាក៏ទទួលបានជោគជ័យក្នុងការគ្រប់គ្រងអតិផរណាឱ្យស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ពោល

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គឺពីអត្រា១៤,៧%ក្នុងឆ្នាំ១៩៩៨ មកត្រឹម២,៩%ក្នុងឆ្នាំ២០១៨។ ទន្ទឹមនេះ អត្រាភាពក្រីក្របានថយចុះជាបន្តបន្ទាប់ពី៥៣,២%មកត្រឹម១៣,៥%។ កម្ពុជាក៏បានពង្រីកមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួនគួរឱ្យកត់សម្គាល់។ ក្នុងនោះ ការនាំចេញសរុបបានកើនឡើង១៦ដងពី៨០០លានដុល្លារអាមេរិកក្នុងឆ្នាំ ១៩៩៨ដល់១២ ៧៦៨លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៨។ ជាលទ្ធផល ទុនបម្រុងអន្តរជាតិបានកើនឡើងពី៣៩០លានដុល្លារអាមេរិកក្នុងឆ្នាំ១៩៩៨ ដល់១០ ០៥២លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៨។ ក្រៅពីនេះ ចំណូលជាតិសរុបបានកើនឡើងពី២៧លានដុល្លារអាមេរិកក្នុងឆ្នាំ១៩៩៨រហូតដល់៤ ៧៣២លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៨។

ជំនួយសម្រាប់ការអភិវឌ្ឍប្រទេស ៖ ហិរញ្ញប្បទានខាងក្រៅ ជាពិសេសជំនួយអភិវឌ្ឍន៍ផ្លូវការបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតមូលដ្ឋានគ្រឹះ សម្រាប់កំណើនសេដ្ឋកិច្ចកម្ពុជា។ ជំនួយអភិវឌ្ឍន៍ផ្លូវការរួមមាន ជំនួយឥតសំណង ឥណទាន និងជំនួយបច្ចេកទេសបានកើតឡើងពី ៥០០លានដុល្លារក្នុងឆ្នាំ១៩៩៣ដល់៧០០លានដុល្លារក្នុងឆ្នាំ២០០៨ និងដល់ប្រមាណ១៥០០លានដុល្លារក្នុងឆ្នាំ២០១៨។ អ្នកដែលផ្តល់ជំនួយសំខាន់ៗ មាន អង្គការសហប្រជាជាតិ ធនាគារអភិវឌ្ឍអាស៊ី ធនាគារពិភពលោក អង្គការរូបិយវត្ថុអន្តរជាតិ ជប៉ុន សហភាពអឺរ៉ុប ចិន បែលហ្សិក ជាណឺម៉ាក ហ្វាំងឡង់ បារាំង សហរដ្ឋអាមេរិក អាឡឺម៉ង់ ហុល្លង់ អេស្ប៉ាញ ស៊ុយអែត ចក្រភពអង់គ្លេស អូស្ត្រាលី កាណាដា ណូវ៉ែលហស្សេឡង់ ន័រវែស សាធារណរដ្ឋកូរ៉េ ស្វីស អង្គការក្រៅរដ្ឋាភិបាល និងប្រទេសដទៃទៀត។

ការកសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ៖ ក្រោយពីសង្គ្រាមស៊ីវិល ដែលបានអូសបន្លាយអស់រយៈពេលជាងបីទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានទទួលសន្តិភាពចាប់តាំងពីឆ្នាំ១៩៩៨ និងបាននិងកំពុងស្ថាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច និងរចនាសម្ព័ន្ធជាមូលដ្ឋានរបស់សង្គម និងកំពុងផ្តល់លទ្ធភាពឱ្យប្រទេសអាចបង្កើនទិសនៃជនជាន និងកម្លាំងរបស់

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្លួនឆ្ពោះទៅរកទិសដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព និងស្មើភាពគ្នា។ សមិទ្ធិរបស់ប្រទេសក្នុងរយៈពេលម្ភៃឆ្នាំចុងក្រោយនេះ (១៩៩៨-២០១៨) បង្ហាញនូវអ្វីដែលប្រជាជនកម្ពុជាមានលទ្ធភាពធ្វើបាន នៅពេលដែលខ្លួនយកទេពកោសល្យ និងគំនិតច្នៃប្រឌិតរបស់ខ្លួនមកប្រើប្រាស់ដើម្បីបុព្វហេតុសន្តិភាព។ ឥឡូវនេះ ប្រទេសកម្ពុជាបានដាក់មករកគន្លងដ៏ត្រឹមត្រូវ ដើម្បីទទួលបានភាពជាប្រទេសនាំមុខគេមួយក្នុងចំណោមសហគមន៍ប្រជាជាតិ។

រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពមួយ ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ជាពិសេសផ្លូវថ្នល់ និងស្ពានដែលជាមូលដ្ឋានគ្រឹះសំខាន់នៃសេដ្ឋកិច្ចជាតិ សម្រាប់បង្កើតបណ្តាញប្រតិបត្តិការផ្លូវថ្នល់ទូលំទូលាយ ដែលអាចឱ្យកម្ពុជាជំរុញសកម្មភាពសេដ្ឋកិច្ច និងទេសចរណ៍ សម្របសម្រួលចរាចរទំនិញនិងសេវា លើកស្ទួយការវិនិយោគក្នុងស្រុក និងពីក្រៅប្រទេស និងពង្រីកសក្តានុពលនៃសេដ្ឋកិច្ចជនបទ។ ការកាត់បន្ថយថ្លៃដឹកជញ្ជូននឹងជំរុញការវិនិយោគពាណិជ្ជកម្ម ឯកជន និងការងារធ្វើ។

ការអភិវឌ្ឍវិស័យអប់រំ ៖ បន្ទាប់ពីសម្រេចបាននូវសន្តិភាពពេញលេញទូទាំងប្រទេស រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដោយកាត់បន្ថយចំណាយលើវិស័យយោធា និងសន្តិសុខ ដើម្បីបង្កើនចំណាយលើវិស័យសង្គមកិច្ច ជាពិសេសវិស័យអប់រំ និងសុខាភិបាល។ វិស័យអប់រំសម្រេចបាននូវសមិទ្ធផលយ៉ាងធំធេងក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ពីឆ្នាំ១៩៩៨ដល់ឆ្នាំ២០១៨ ជាអាទិ៍ ៖ (១) ចំនួនសាលារៀនបានកើនឡើងពី ៧ ០០០ហួតដល់១៣ ០០០សាលា (២) ចំនួនសិស្សបានកើនឡើងពី២លាននាក់ដល់៣លាននាក់ (៣) អត្រាសិស្សចូលរៀនកម្រិតមត្តេយ្យសិក្សាបានកើនឡើងចំនួន៦០%ពី៧%ដល់៦៧% (៤) អត្រាសិស្សចូលរៀនកម្រិតបឋមសិក្សាបានកើនឡើងចំនួន២០%ពី៧៨%ដល់៩៨% គឺសិស្សមានចំនួនជាង២លាននាក់ក្នុងឆ្នាំ២០១៨

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

(ម) អត្រាសិស្សចូលរៀនកម្រិតអនុវិទ្យាល័យបានកើនឡើងចំនួន៤០% ពី១៧%ដល់ម៧% គឺមានចំនួនជាង៥សែននាក់ក្នុងឆ្នាំ២០១៨ (៦) អត្រាសិស្សចូលរៀនកម្រិតវិទ្យាល័យបានកើនឡើងចំនួន២០%ពី៧%ដល់២៧% គឺមានចំនួនជិត៣សែននាក់ក្នុងឆ្នាំ២០១៨ និង (៧) អត្រានិស្សិតចូលរៀនកម្រិតឧត្តមសិក្សាបានកើនឡើងចំនួន១៤%ពី១%ស្មើនឹង៩ពាន់នាក់ដល់ ១ម%ស្មើនឹងជាង៦សែននាក់ក្នុងឆ្នាំ២០១៨។

ការកាត់បន្ថយភាពក្រីក្រ ៖ ការកាត់បន្ថយភាពក្រីក្រ តម្រូវឱ្យមានវិធានការសមស្របទាំងឡាយដូចជា (ក) គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលនឹងបង្កើនប្រាក់ចំណូល ក្នុងមធ្យោបាយដែលមានសមធម៌និងប្រាក់ចំណូលតាមរយៈការចំណាយសាធារណៈដែលលម្អៀងទៅអ្នកក្រ (ខ) រក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង (គ) ការបង្កើត និងអនុវត្តន៍គោលនយោបាយសមស្របសម្រាប់វិស័យនីមួយៗ រួមទាំងការបង្កើនការវិនិយោគខាងសុខាភិបាល និងអប់រំ ការដោះស្រាយបញ្ហាយេនឌ័រ ការអភិវឌ្ឍរបស់ជនជាតិដើមភាគតិច កំណែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព និងកិច្ចការពារបរិស្ថាន។

ខ-កំណែទម្រង់វិស័យអប់រំ

ធ្វើយតបនឹងបញ្ហាប្រឈមសកល ដែលរួមមាន ការប្រែប្រួលអាកាសជាតុ អំពើភេរវកម្ម ឆ្លងដែន ក៏ដូចជាការឈានមកដល់បដិវត្តឧស្សាហកម្មជំនាន់ទី៤ នៅខែកញ្ញា ឆ្នាំ២០១៣ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវកំណែទម្រង់អប់រំ ដោយផ្តោតលើអាទិភាព៨ចំណុចក្នុងគោលដៅធ្វើយតបទៅនឹងបញ្ហាប្រឈមនានា ក៏ដូចជាតម្រូវការធ្វើឱ្យគោលនយោបាយអប់រំធ្វើយតបទៅនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ បន្ទាប់ពីបានធ្វើកំណែទម្រង់ការប្រឡងថ្នាក់ទី១២លើកទី១មក ក្នុងខែមីនាឆ្នាំ២០១៩ ក្រសួងបានដាក់ចេញនូវ«ចក្ខុវិស័យកំណែទម្រង់អប់រំ» ដែល

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឈរលើសសរស្តម្ភ ៥ រួមមាន ៖ (១) ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (២) អធិការកិច្ចសាលារៀន (៣) ការវាយតម្លៃការសិក្សារបស់សិស្ស (៤) ការពិនិត្យឡើងវិញកម្មវិធីសិក្សា និង (៥) កំណែទម្រង់ឧត្តមសិក្សា។

ជាការពិតណាស់ កម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការទទួលបានការអប់រំ សម្រាប់ទាំងអស់គ្នា ដែលអត្រានៃការសិក្សាកម្រិតបឋមសិក្សាស្មើនឹង៩៨ភាគរយ នៅឆ្នាំ២០១៧ បើប្រៀបធៀបទៅនឹងឆ្នាំ១៩៩៨ ដែលមានតែ៨៧ភាគរយប៉ុណ្ណោះ។ សមិទ្ធផលនេះអាចសម្រេចបាន លុះត្រាតែប្រទេសមានសន្តិភាព មានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំខ្ពស់ ៧% និងបង្កើនការវិនិយោគក្នុងវិស័យអប់រំ។ ថវិកាអប់រំបានកើនឡើងជិត ៣ដងពី១៦ភាគរយនៃថវិកាចរន្តសរុប ឬប្រមាណ២៨២លានដុល្លារ ក្នុងឆ្នាំ២០១៣ទៅដល់១៨% ឬប្រមាណ៨០០លានដុល្លារក្នុងឆ្នាំ២០១៨ ហើយនឹងកើនឡើងដល់ជាង២០% នៅឆ្នាំ២០២០។ បន្ថែមពីនេះ កម្ពុជាទទួលបានថវិកាប្រមាណ៣០លានដុល្លារពីដៃគូអភិវឌ្ឍក្នុងមួយឆ្នាំ។

បញ្ហាប្រឈមចម្បងៗដែលប្រព័ន្ធអប់រំនៅកម្ពុជាកំពុងតែប្រឈមគឺ ៖ ធនធានមនុស្សខុសជំនាញពីតម្រូវការទីផ្សារ គុណភាពអប់រំនៅមានកម្រិតទាប ការអនុវត្តកម្មវិធីសិក្សាស្ថិតក្រោមស្តង់ដា គុណភាពរបស់គ្រូបង្រៀននៅមានកម្រិត ហេដ្ឋារចនាសម្ព័ន្ធសាលារៀននៅខ្វះខាត កង្វះការប្រើប្រាស់សម្ភារ បច្ចេកវិទ្យាព័ត៌មាននិងមធ្យោបាយក្នុងការបង្រៀននិងរៀន ទំនាក់ទំនងរវាងគោលនយោបាយ ការបណ្តុះបណ្តាលគ្រូបង្រៀន សាលារៀន និងថ្នាក់រៀនស្ថិតនៅក្នុងសតវត្សរ៍ទី២០នៅឡើយ។

ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់កម្ពុជា ក្នុងការសម្រេចបាននូវស្ថានភាពប្រទេស មានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០ ការដោះស្រាយបញ្ហាធនធានមនុស្សខុសជំនាញ និងការធ្វើពិពិធកម្មនៃកំណើនឧស្សាហកម្ម ក្រសួងអប់រំបានចាប់ផ្តើមធ្វើកំណែទម្រង់វិស័យអប់រំ

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដើម្បីផ្តល់ការអប់រំប្រកបដោយគុណភាពនិងមូលដ្ឋានគ្រឹះជំនាញដល់យុវវ័យ ដើម្បីឱ្យពួកគេអាចចាប់យកអនាគត និងដើម្បីឱ្យយុវជនជំនាន់ក្រោយមានលក្ខណៈសម្បត្តិល្អ ទទួលបាននូវចំណេះដឹង ជំនាញទន់និងបំណិនជីវិត ការប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍសហគមន៍ និងការអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីក្លាយជាពលរដ្ឋសកល ចេះឱ្យតម្លៃលើវប្បធម៌សម្បុរណ៍បៃប និងគោរពតម្លៃមនុស្ស និងធ្វើឱ្យពិភពលោកល្អប្រសើរជាងមុន។

ដើម្បីកែលម្អបន្ថែមទៀតនូវកំណែទម្រង់ការគ្រប់គ្រងអប់រំ ឆ្ពោះទៅលើកកម្ពស់ភាពជា ពលរដ្ឋប្រកបដោយគុណភាពនៅកម្ពុជា កំណែទម្រង់វិស័យអប់រំផ្តោតលើសមាសភាគទាំង៦នៃការគ្រប់គ្រងអប់រំដូចជា ៖ (១) កំណែទម្រង់ការគ្រប់គ្រងទូទៅនិងរដ្ឋបាល (២) ការគ្រប់គ្រងរដ្ឋបាលសិក្សា (៣) ការគ្រប់គ្រងហិរញ្ញវត្ថុ និង (៤) ការគ្រប់គ្រងធនធានមនុស្ស ក្នុងគោលដៅលើកកម្ពស់ភាពជាពលរដ្ឋប្រកបដោយគុណភាព សម្រាប់សតវត្សរ៍ទី២១។

កំណែទម្រង់ការគ្រប់គ្រងអប់រំ រួមមាន សមាសភាគសំខាន់បួន ៖

(១) កំណែទម្រង់ការគ្រប់គ្រងទូទៅនិងគ្រប់គ្រងរដ្ឋបាល ៖ (i) គោលនយោបាយអប់រំនិងផែនការយុទ្ធសាស្ត្រ (ii) ការគ្រប់គ្រងតាមសាលារៀន (iii) ការចូលរួមរបស់សហគមន៍ ក្នុងការគ្រប់គ្រងសាលារៀន។

(២) កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលសិក្សា ៖ (i) ការបញ្ចូលការអប់រំ ពលរដ្ឋប្រកប ដោយគុណភាពក្នុងកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល (ii) ការកែលម្អការរៀននិងបង្រៀន ដោយផ្តោតលើវិធីសាស្ត្របង្រៀន (iii) ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងអធិការកិច្ចសាលារៀន។

(៣) កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុអប់រំ ៖ (i) ការវិភាជថវិកាធ្វើយតបទៅនឹងគោលនយោបាយអប់រំ (ii) ស្ថិយភាពហិរញ្ញវត្ថុ និងគណនេយ្យភាពសាលារៀន (iii) សវនកម្ម ថវិកាអប់រំ។

(៤) កំណែទម្រង់ការគ្រប់គ្រងបុគ្គលិក ៖ (i) ការបង្កើនគុណវឌ្ឍិគ្រូ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្រៀន (ii) ការងារ វិក្រឹត្យការគ្រូបង្រៀន និង (iii) ការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន។

គោលបំណងនៃកំណែទម្រង់ការគ្រប់គ្រងអប់រំ គឺអភិវឌ្ឍសិស្សប្រកបដោយគុណភាពខ្ពស់ និងមានលក្ខណៈសម្បត្តិដូចខាងក្រោម ៖

(១) ភាពជាពលរដ្ឋកម្ពុជាប្រកបដោយគុណភាព ៖ (i) ផ្នែកសេដ្ឋកិច្ច (ក) ចំណេះដឹងនិងជំនាញវិជ្ជី (ខ) ជំនាញទន់និងបំណិនជីវិត (ii) សង្គម-នយោបាយ (ក) ការគោរពច្បាប់និងសណ្តាប់ធ្នាប់សង្គម (ខ) ការអភិវឌ្ឍសហគមន៍ និងការអភិវឌ្ឍប្រកបដោយចីរភាព (គ) ការចូលរួមក្នុងសកម្មភាពនយោបាយ

(២) ភាពជាពលរដ្ឋសកលប្រកបដោយគុណភាព ៖ (i) ផ្នែកសេដ្ឋកិច្ច (ក) ការយល់ដឹងពីបញ្ហាសកលលោក (ខ) ការគោរពចំពោះ ភាពខុសគ្នានិងតម្លៃមនុស្ស (ii) ផ្នែកសង្គម-នយោបាយ (ក) ការធ្វើឱ្យពិភពលោកប្រសើរជាងមុន (ខ) ការទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន។

ក្នុងវិស័យអប់រំ កម្ពុជាផ្តល់អាទិភាពទៅលើអនុវិស័យដូចតទៅ ៖

ការយកចិត្តទុកដាក់ដល់ការអប់រំកុមារតូច ៖ ការអប់រំកុមារតូចផ្តល់នូវមូលដ្ឋានគ្រឹះ ទាំងចំណេះដឹងនិងកាយសម្បទា ការរៀនសូត្រពេញមួយជីវិត និងជំនាញក្នុងសតវត្សទី២១ ដូចជាការគិតត្រិះរិះ ការដោះស្រាយបញ្ហា ដែលនឹងត្រូវបានអភិវឌ្ឍនៅតាមក្រោយ។

ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន ៖ គ្រូបង្រៀននឹងមានសមត្ថភាពវិជ្ជាជីវៈ ការលើកទឹកចិត្ត និងការគាំទ្រ ព្រមទាំងត្រូវបានបំពាក់បំប៉នដោយចំណេះគ្រប់គ្រាន់ ក៏ដូចជាជំនាញគរុកោសល្យ និងមានចំណងចំណូលចិត្តក្នុងការបង្រៀននិងទឹកចិត្តស្រលាញ់សិស្សានុសិស្ស។ ស្ថានភាពនៃវិជ្ជាជីវៈជាគ្រូបង្រៀននឹងត្រូវបានលើកកម្ពស់ ដូច្នេះវាអាចទាក់ទាញ និងរក្សាបាននូវជនជាន់មនុស្សដែលមានសមត្ថភាពនិងមានការលើកទឹកចិត្តខ្ពស់។ គ្រូបង្រៀននឹងក្លាយជាអ្នកសម្របសម្រួលក្នុងការរៀនសូត្រ ដែល

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

បង្កើតឱកាសរៀនសូត្រសម្រាប់មនុស្សគ្រប់រូបតាមរយៈការប្រើវិធីសាស្ត្របង្រៀនតាមបែបអន្តរកម្ម និងតាមបែបសហការ។ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួនពីរត្រូវបានដំឡើងទៅជាវិទ្យាស្ថានគរុកោសល្យ ដើម្បីធ្វើការបង្កើនគុណវុឌ្ឍិគ្រូបង្រៀន។

ការយកចិត្តទុកដាក់ដល់ការគ្រប់គ្រងតាមសាលារៀន ៖ សាលារៀនត្រូវមានស្វ័យភាព និងទទួលខុសត្រូវចំពោះលទ្ធផលនៃការសិក្សាប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។ សាលារៀននីមួយៗត្រូវមានគ្រូបង្រៀនមានសមត្ថភាព និងមានការលើកទឹកចិត្តសាលារៀន និងដឹកនាំដោយអ្នកដឹកនាំដែលមានចក្ខុវិស័យវែងឆ្ងាយ ព្រមទាំងមានបរិស្ថានបង្រៀន និងការបង្រៀនដែលមានគុណភាពខ្ពស់ សុវត្ថិភាព ជាសុកភាព ធ្វើយតបនឹងយេនឌ័រ បរិយាបន្ន និងបំពាក់បរិក្ខារបច្ចេកវិទ្យា។ បន្ទប់រៀននៅកម្ពុជានឹងត្រូវបានផ្លាស់ប្តូរបន្តិចម្តងៗ និងបំពាក់ទៅដោយឆន្ទានអប់រំនិងបច្ចេកវិទ្យា ហើយផ្តល់នូវបរិយាកាសសិក្សា ដែលមានការរៀបចំប្រកបដោយសុវត្ថិភាព និងអំណោយផលសម្រាប់ទាំងអស់គ្នា។

ការយកចិត្តទុកដាក់លើកត្តាសមធម៌ ៖ ក្រសួងអប់រំបានបញ្ចូលសាលារៀនពីរភាសាសហគមន៍ សម្រាប់កុមារជនជាតិដើមភាគតិចចំនួន ៧០ទៅជាសាលារៀនសាធារណៈ ដើម្បីទទួលបានថវិកាបន្ថែម និងផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជាង១ម៉ឺននាក់ ដើម្បីឱ្យពួកគេអាចទៅសាលារៀន។

ការយកចិត្តទុកដាក់លើការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ៖ ក្រសួងនឹងបន្តបណ្តុះបណ្តាលគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រស្តីពីការប្រើប្រាស់បច្ចេកវិទ្យា និងមន្ទីរពិសោធន៍សម្រាប់ការបង្រៀននិងរៀន។ ស្របជាមួយនឹងការបង្រៀនសិស្សឱ្យអនុវត្តចំណេះដឹង ផ្នែកវិទ្យាសាស្ត្ររបស់ពួកគេ។

ការយកចិត្តទុកដាក់លើការផ្តល់ជំនាញទន់និងសហគ្រិនភាព ៖

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំនាញទន់អាចនឹងត្រូវ បានបង្រៀនដោយធ្វើការកែលម្អវិធីសាស្ត្របង្រៀន និងការអប់រំសហគ្រិនភាពនឹងត្រូវបញ្ចូលទៅក្នុងកម្មវិធីសិក្សាដើម្បីយុវជន ឱ្យបង្កើតការងារដោយខ្លួនឯង។

ការយកចិត្តទុកដាក់លើការអប់រំភាពជាពលរដ្ឋប្រកបដោយគុណភាព សម្រាប់ប្រទេសជាតិ និងសកល ៖ ក្រសួងកំពុងដាក់បញ្ចូលតម្លៃសីលធម៌ ល្អ គុណតម្លៃជាតិ ភាពជាពលរដ្ឋសកល ទៅក្នុងកម្មវិធីសិក្សានិងថ្នាក់រៀន និងការផ្តល់ប្រឹក្សាអាជីព។

ការយកចិត្តទុកដាក់លើតម្រូវការរបស់សិស្ស ៖ ក្រសួងលើកទឹកចិត្ត ដល់សិស្ស និស្សិតឱ្យបង្កើតក្លឹបសិក្សា ដើម្បីសិក្សានិងរៀនពីគ្នាទៅវិញ ទៅមក។

ការយកចិត្តទុកដាក់លើការសិក្សាពេញមួយជីវិតនិងយុវជន ៖ ក្រសួង បន្តយុទ្ធនាការអក្ខរកម្មនិងការរៀនតាមបែបអេឡិចត្រូនិចសម្រាប់យុវវ័យ និងមនុស្សពេញវ័យនៅក្រៅសាលារៀន។

ការយកចិត្តទុកដាក់លើកុមារក្រៅសាលា ៖ ក្រសួងបន្តផ្តល់នូវកម្ម វិធីសិក្សាពន្លឿន និងកម្មវិធីស្ពានចម្ងងសម្រាប់កុមារលើសអាយុ កម្មវិធី ចូលរៀនឡើងវិញ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់យុវជនក្រៅ សាលា។

ការយកចិត្តទុកដាក់លើសុខភាពសិក្សា ៖ ក្រសួងបន្តកសាងបង្គន់ និងសម្ភារអនាម័យនៅតាមសាលារៀន។

ការយកចិត្តទុកដាក់លើសិស្សដែលមានតម្រូវការពិសេស ៖ ក្រសួង បានបង្កើតវិទ្យាស្ថានជាតិអប់រំពិសេសសម្រាប់សិស្សគ ថ្លង់ និងពិការភ្នែក ហើយក្រសួង បានទទួលយកការងារនេះបន្ត ដែលកន្លងមកបានអនុវត្ត ដោយអង្គការមិនមែនរដ្ឋាភិបាល។ ក្រសួងបានដាក់បញ្ចូលនូវសេចក្តី ត្រូវ ការពិសេសទៅក្នុងការគំរូបង្ហ័សាលារៀន។

ការយកចិត្តទុកដាក់លើការត្រួតពិនិត្យនិងវាយតម្លៃ ៖ ក្រសួងត្រូវ

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពិនិត្យឡើងវិញនូវការប្រមូលទិន្នន័យឱ្យស្របនឹងគោលដៅអភិវឌ្ឍដោយ ចីរភាព កសាងសមត្ថភាពសាលារៀនដើម្បីផ្តល់ទិន្នន័យទាន់ពេលវេលា និងមានភាពពាក់ព័ន្ធ។

ការយកចិត្តទុកដាក់លើសាលារៀនជំនាន់ថ្មី ៖ ក្រសួងបានបង្កើតសាលារៀនជំនាន់ថ្មីប្រមាណជា១០កន្លែង ដើម្បីសាកល្បងកំណែទម្រង់ការអប់រំទូលំទូលាយរបស់យើង។ គុណភាពអប់រំនៅសាលារៀនជំនាន់ថ្មីមានភាពល្អប្រសើរជាងមុន ហើយសិស្សានុសិស្សត្រូវបានបំពាក់ដោយជំនាញវិជ្ជិជំនាញទន់ ជាពិសេស គំនិតផ្តួចផ្តើមថ្មី ការគិតត្រិះរិះ និងការដោះស្រាយបញ្ហា។ សាលារៀនចំនួន១៥០បន្ថែមទៀតត្រូវបានជ្រើសរើស ដើម្បីបង្កើតសាលារៀនគំរូប្រភេទទីពីរ។

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឯកសារយោង

ភាសាខ្មែរ

ក្រសួងអប់រំជាតិ (១៩៧២). ប្រវត្តិវិទ្យា, ថ្នាក់ទី២. ភាគ ១, គណៈកម្មាធិការជាតិអចិន្ត្រៃយ៍ខេមរយោនកម្ម. ភ្នំពេញ

ក្រសួងអប់រំ យុវជន និងកីឡា (២០១១). ប្រវត្តិវិទ្យា, ថ្នាក់ទី១២. គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ភ្នំពេញ

កែវ បាភ្នំ (២០១៦). កាលប្រវត្តិសកម្មភាពសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្នុងបុព្វហេតុបម្រើជាតិ និងប្រជាជន. ភាគទីមួយ ១៩៧៩-១៩៨១

ដេវិឌ ឆាណ្ឌលឺរ (២០០០). ប្រវត្តិសាស្ត្រខ្មែរ. ចេញផ្សាយលើកទី២, ភ្នំពេញ: Westview Press

នួន ឈឿន (១៩៧១). ដំណើរឆ្ពោះទៅទិសខាងលិច និងឥណ្ហចិនក្នុងឆ្នាំ ២០០០. រោងពុម្ពសិន មុយ, ភ្នំពេញ

ឌី ខាំបូលី (២០១០). ប្រវត្តិសាស្ត្រកម្ពុជាប្រជាជិបតេយ្យ. ភ្នំពេញ: មណ្ឌលឯកសារកម្ពុជា

តូច ឈួន (១៩៩៦). បាត់ដំបងសម័យលោកម្ចាស់. មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ

ប៊ុណ្ណា ចន្ទម៉ុល (១៩៧៣). ចរិតខ្មែរ. ភ្នំពេញ

លាង ហាប់អាន (១៩៦៩). ព្រះបាទសម្តេចព្រះអង្គដួង. ភ្នំពេញ: បណ្ណាគារ អឹង ហ៊ុន

រស់ ចន្ទ្រាបុត្រ (២០០៧). ព្រះស្តេចកន. ភ្នំពេញ: បណ្ណាគារ អង្គរ

វ៉ង់ សុជាភ័ (២០១០). *សិលាចារឹកនៃប្រទេសកម្ពុជាសម័យមុនអង្គរ* (pre-angkor inscriptions of cambodia 1). *ភ្នំពេញ: គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ*

វ៉ាន់ឌី កាអុន (២០០៨). *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា: ពីសម័យអាណានិគមបារាំងមកដល់បច្ចុប្បន្នកាល. ភាគទី១ ភាគទី២ និង ភាគទី៣*

វ៉ាន់ឌី កាអុន (២០១២). *សុបិន និង ការពិត. ភាគទី១ និង ភាគទី២*

ហម ឆាយលី (២០១១). *សិលាចារឹកកម្ពុជា (Inscriptions du cambodge: anthologie epigraphies anciennes du cambodge). ភ្នំពេញ: គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ*

ហ៊ិន សែន (undated). *១៣ ទសវត្សរ៍នៃដំណើរកម្ពុជា. ភ្នំពេញ: ការផ្សាយរបស់កាសែត ប្រជាជន*

អាដេម៉ារ ឌ្យូក្លែរ (១៩១៦). *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់ពីសតវត្សទី១ នៃគ្រិស្តសករាជរហូតមក. ភ្នំពេញ: គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ*

អ៊ិត សារិន (១៩៧៣). *ស្រណោះព្រលឹងខ្មែរ. ភ្នំពេញ*

ភាសាបរទេស

Ang Cheng Guan *(2013). Singapore, ASEAN and the Cambodian Conflict 1978-1991.* NUS Press: Singapore.

Armstrong, John (1964). Sihanouk Speaks: *Cambodia's Chief of State explains his controversial policies.* Walker and Company: New York.

Becker, Elizabeth. (1986) When the war was over: *Cambodia and the Khmer Rouge revolution*, New York: PublicAffairs.

Bernard F. Colonel (1933). *À l'école des diplomats: La Perte et le Retour d'Angkor.* Éditions de la Bibliothèque nationale du Cambodge.

Burchett, Wilfred (1970). *La seconde guerre d'Indochine: Cambodge et*

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

Laos 1970. Paris: Seuil.

Burgess, John (2010). *Stories in Stone: The Sdok Kok Thom Inscriptions and the Enigma of Khmer History*. Bangkok: River Books.

Caldwell, Malcolm and Lek, Tan (1973). *Cambodia in the Southeast Asian War*. Monthly Review Press: New York.

Chanda, Nayan (1986). Brother Enemy: *The War After the War. A History of Indochina Since the Fall of Saigon*. New York: Collier Books.

Chandler, David. (1991). T*he Land and People of Cambodia*, Harper Collins Publishers: New York.

Chandler, David (1991). *The Tragedy of Cambodian History: Politics, War, and Revolution since 1945*. Chiang Mai: Silkworm Books.

Chandler, David. (1999). *Voice from S-21: Terror and History in Pol Pot's Secret Prison* Silkworm Books, Thailand.

Chandler, David P. (2000) Brother Number One: *A Political Biography of Pol Pot*. Silkworm Books, Thailand.

Chandler, David. (2008). *A History of Cambodia* (Westview Publishers: Boulder Colorado, 2008).

Clymer, Kenton. (2007). Troubled Relations: *The United States and Cambodia Since 1870*. Northern Illinois University Press.

Chovelon, Bernadette et Bernard (1997). *Doudart de Lagrée: Marin, diplomate*, explorateur. Presses Universitaires de Grenoble: Grenoble.

Coe, Michael and Evans, Damian (2018). *Angkor and the Khmer Civilization*. Second Edition. Thames & Hudson: London.

Coedès, George (1964). *Les États Hindouisés d'Indochine et d'Indonésie*. Nouvelle edition revue et mise à jour. Paris: Editions E. De Boccard.

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

Coggan, Philip. (2018). *An Illustrated History of Cambodia.* Oxford: John Beaufoy Publishing.

Corrèze, Françoise et Forest, Alain (1984). *Le Cambodge à Deux Voix.* L'Harmattan: Paris.

Curtis, Grant (1990). Cambodia: *A Country Profile. A Report Prepared for the Swedish International Development Authority.* Stockholm.

Dryfus, Paul (2000). Pol Pot: *Le bourreau du Cambodge.* Paris: Stock.

Dumarçay, Jacques and Smithies, Michael (1995). *Cultural Sites of Burma, Thailand, and Cambodia.* Kuala Lumpur: Oxford University Press.

Dupaigne, Bernard (2016). *Les maîtres du fer et du feu dans le royaume d'Angkor.* Paris: CNRS Éditions.

Epinal, Guillaume (2013). Cambodge: *Du Funan au Chenla: 1.000 ans d'histoire monétaire. Avec la collaboration de Jean-Daniel Gardère.* Phnom Penh: A National Bank of Cambodia Publication.

Fielding, Leslie (2008). *Before the Killing Fields: Witness to Cambodia and the Vietnam War.* London-New York: I.B. Tauris.

Forest, Alain. (1980). Le Cambodge et la colonization française: *Histoire d'une colonization sans heurts (1897-1920).* L'Harmattan: Paris.

Forest, Alain. (2012). Histoire religieuse du Cambodge: *Un royaume d'enchantement.* Paris: les Indes savants.

François, Im (2006). *La question cambodgienne dans les relations internationals de 1979 à 1993.* Paris: L'Harmattan.

Frings, Viviane (1997). Le socialism et le paysan cambodgien: *La politique agricole de la République Populaire du Kampuchea et l'État du Cambodge.* Paris: L'Harmattan.

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Giteau, M. (1957). *Histoire du Cambodge.* Paris: Didier. Bangkok: Silkworm Books.

Gottesman, Evan (2004). Cambodia after the Khmer Rouge: *Inside the Politics of Nation Building.*

Gouvernement Royal du Cambodge (1953). *Livre Jaune sur les Revendications de l'Indépendance du Cambodge.*

Hansen, Anne Ruth. (2007). *How to Behave: Buddhism and Modernity in Colonial Cambodia, 1860-1930.* Bangkok: Silkworm Books.

Harris, Ian (2005). Cambodian Buddhim: *History and Practice.* Silkworm Books.

Heder, Steve (2004). Cambodian Communism and the Vietnamese Model. Volume 1: *Imitation and Independence, 1930-1975.* White Lotus Press: Bangkok.

Héduy, Philippe (2015). Histoire de l'Indochine: *La perle de l'empire, 1624-1953.* Paris: Soukha Éditions.

Heng Samrin (2018). The People's Struggle: *Cambodia Reborn.* Singapore: Editions Didier Millet.

Higham, Charles. (2014). Early Mainlan Southeast Asia: *From First Humans to Angkor.* Bangkok: River Books.

Ishizawa, Yoshiaki (2012). *Challenging the Mystery of the Angkor Empire.* Sophia University Press.

Jackson, D. Karl (eds.) (1989). Cambodia 1975-1978: *Rendezvous with Death.* Princeton University Press: New Jersey.

Jeldres, Julio (2003). *The Royal House of Cambodia. Phnom Penh*: JSRC Printing House.

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Jennar, Raoul Marc (1994). Les Constitutions du Cambodge. Textes rassemblés et présentés Par Raoul M. Jennar. Documentation française: Paris.

Jennar, Raoul Marc (1995). *Chroniques cambodgiennes, 1990-1994.* Paris: L'Harmattan.

Jennar, Raoul Marc (1995). *Les clés du Cambodge. Maisonneuve & Larose.*

Kiernan, Ben. (1995). How Pol Pot Came to Power: *Collonialism, Nationalism, and Communism in Cambodia, 1930-1975.* Second Edition. Yale University Press: New Haven & London.

Kiernan, Ben. (2008). Genocide and Resistance in Southeast Asia: *Documentation, Denial & Justice in Cambodia & East Timor. Transaction Publishers: New Brunswick (U.S.A.) and London (U.K.).*

Kiernan, Ben. (2008). The Pol Pot Regime: *Race, Power and Genocide in Cambodia under the Khmer Rouge, 1975-79.* Third Edition. Yale University Press: New Haven and London.

Khin Sok (1988). Chroniques Royales du Cambodge (*De Baña Yat à la prise de Lanvaek*) (de 1417 à 1595). Paris: EFEO.

Khin Sok (1991). *Le Cambodge entre le Siam et le Viêtnam (de 1775 à 1860).* Paris: EFEO.

Khin Sok (1991). L'Annexation du Cambodge par les Viêtnamiens au XIXe Siècle: D'après les deux poèmes du Vénérable Bâtum Baramey Pich. Paris: Éditions You-Feng.

Khoo, James (eds.). (2003). *Art and Archeology of Fu Nan: Pre-Khmer Kingdom of the Lower Mekong Valley.* Orchid Press: Bangkok.

Krassem, Maha Bidur. (1984). *Inscriptions modernes d'Angkor.* Paris:

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

CEDORECK. Nouvelle preface de Saveros Pou.

Lê Thành Khôi. (2001). *Éducation et Civilisations: Genèse du monde contemporain.* UNESCO, Paris: Bruno Leprince Éditeur.

Leclere, Adhémard (1974). Histoire du Cambodge: *Depuis le Ier Siècle de Notre Ère. D'après les inscriptions lapidaires, les annals chinoises et annamites et les documents européens des six derniers siècles.* Phnom Penh: Nokor Thom Editeur.

Ly Sok-Kheang (2017). Reconciliation Process in Cambodia: *1979-2007. Before the Khmer Rouge Tribunal.* Documentation Center of Cambodia: Phnom Penh.

Luden-Roze, Dominique (2005). Cambodge: *Vers de Nouvelles Tragédies?* L'Harmattan: Paris.

Martin, Marie Alexandrine (1989). *Le Mal Cambodgien.* Paris: Hachette.

McGloin, Frank (1882). Norodom, King of Cambodia: *A Romance of the East.* New York: A. Appleton and Company.

Mak Phoeun (1981). *Chroniques Royales du Cambodge (de 1594 à 1677).* Paris: EFEO.

Mak Phoeun (1995). *Histoire du Cambodge de la fin du XVIe siècle au début du XVIIIe.* Paris: EFEO.

Marston, John and Guthrie, Elizabeth (2004). *Hisotry, Buddhism, and New Religious Movements in Cambodia.* Silkworm Books: Bangkok.

Mehta, Harish and Julie. (1999). Hun Sen: *Strongman of Cambodia.* Singapore: Graham Brash.

Meyer, Charles (1971). *Derrière le sourire khmer.* Paris: Plon.

Meyer, Charles (1996). *Les Français en Indochine, 1860-1910.* Paris: Hachette.

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Migozzi, Jacques (1973). *Cambodge: faits et problems de population.* Paris: CNRS.

Mikaelian, Grégory (2009). *La Royauté d'Oudong: Réformes des institutions et crise du pouvoir dans le royaume khmer du XVIIe siècle.* Paris: PUPS.

Montagnon, Pierre (2004). *France-Indochine: Un siècle de vie commune (1858-1954).* Pygmalion: Paris.

Morice, Jean (1977). Cambodge: *Du sourire à l'horreur.* Éditions France-empire: Paris.

Mouhot, Henri (1999). *Voyage dans les Royaumes de Siam, de Cambodge, de Laos et autres parties centrales de l'Indochine.* Éditions Olizane: Genève.

Mysliwiec, Eva (1988). Les dessous d'une impasse: *L'isolement international du Kampuchea.* Oxfam Belgique.

Norén-Nilsson, Astrid (2016). *Cambodia's Second Kingdom: Nation, Imagination and Democracy.* SEAP, Ithaca, New York.

Norodom Arunrasmy & Jeldres, Julio (2012). *A Life Dedicated to Cambodia.* Phnom Penh: JSRC Printing House.

Norodom Sihanouk, (sans date). *Le Roi Norodom Ier.*

Norodom Sihanouk (1972). L'Indochine vue de Pékin: *Entretiens avec Jean Lacouture.* Paris: Seuil.

Norodom Sihanouk (1973). My War with the CIA: *The Memoirs of Prince Norodom Sihanouk as Related to Wilfred Burchett.* Penguin Books.

Norodom Sihanouk (1979). *Chroniques de guerre et d'espoir.* Paris: Hachette/Stock.

Norodom Sihanouk (1981). *Souvenirs doux et amers.* Paris: Hachette.

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Norodom Sihanouk (1986). *Prisonnier des Khmers Rouges.* Paris: Hachette.

Norodom Sihanouk (2005). Shadow over Angkor. Volume One: *Memoirs of His Majesty King Norodom Sihanouk of Cambodia.* Phnom Penh: 3DGraphics Publishing.

Osborne, Milton (1973). *Politics and Power in Cambodia.* Longman.

Osborne, Milton (1994). Norodom Sihanouk: *Prince of Light, Prince of Darkness.* Silkworms Book: Bangkok.

Osborne, Milton (2016). Southeast Asia: *An Introductory History.* 12th Edition. Allen & Unwin: Sydney.

Peou, Sorpong (1997). Conflict Neutralization in the Cambodian War: *From Battlefield to Ballot-Box.* Oxford University Press: Kuala Lumpur.

Peschoux, Christophe (1992). *Les "Nouveaux" Khmers Rouges, 1979-1992.* Paris: L'Harmattan.

Pin, Yathay (1980). L'utopie meutrière: *Un rescapé du genocide cambodgien témoigne.* Paris: Robert Laffont.

Pomonti, Jean-Claude et Thion, Serge (1971). Des courtisans aux partisans: *La crise cambodgienne.* Gallimard: Paris.

Ponchaud, François (1998). Cambodge: *Année zero.* Paris: Editions Kailash.

Porée, Guy and Maspero, Éveline (1938). *Moeurs et Coutumes des Khmèrs.* Payot: Paris.

Pou Sothirak, Wade, Geoff and Hong Mark (Eds.) (2012). Cambodia: *Progress and Challenges since 1991.* ISEAS: Singapore.

Prud'homme, Rémy (1969). *L'économie du Cambodge.* Paris: Presse

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

universitaire de France.

Regaud, Nicolas (1971). Le Cambodge dans la tourmente: *Le troisième conflit indochinois, 1978-1991*. Paris: L'Harmattan.

Roberts, David (2001). Political Transition in Cambodia: Power, Elitism and Democracy. Curzon.

Ros, Chantrabot (2000). Cambodge: *La Répétition de l'histoire (De 1991 aux élections de juillet 1998)*. Paris: Éditions You-Feng.

Ros, Chantrabot (2017). *The Khmer Republic, 1970-1975*. Phnom Penh: CamEd Business School. Translated and annotated by Michelle Vachon.

De San Antonio, Gabriel Quiroga (2009). *Les Derniers Conquistadores: La Non-Conquête du Cambodge (Brève et véridique relation des évènements du Cambodge)*. Traduit de l'espagnol par Antoine Cabaton. Toulouse: Anacharsis.

SarDesai, D.R. (2013). *Southeast Asia: past and present*, Westview Press.

Shawcross, William (1984). The Quality of Mercy: *Cambodia, Holocaust, and Modern Conscience*. Simon and Schuster: New York.

Shawcross, William (2002). Sideshow: *Kissinger, Nixon, and the Destruction of Cambodia*. Revised Edition. Cooper Square Press.

Sher, Sacha (2004). Le Kampuchéa des "Khmers rouges": *Essai de comprehension d'une tentation de revolution*. Paris: L'Harmattan.

Short, Philip. (2004) Pol Pot: *The History of a Nightmare*. John Murray Publishers, London, UK.

Slocomb, Margaret (2003). The People's Republic of Kampuchea, 1979-1989: *The Revolution after Pol Pot*. Bangkok: Silkworm Books.

Slocomb, Margaret (2010). *An Economic History of Cambodia in the Twentieth Century*. NUS Press: Singapore.

Sola, Richard (1994). Le Cambodge: *Espoir, Désillusions et Amertume*. Paris: Sudestasie.

Sliwinski, Marek (1995). Le Génocide Khmer Rouge: Une Analyse Démographique Paris: L'Harmattan.

Strangio, Sebastian (2014). Hun Sen's Cambodia. Yale University Press.

Thion, Serge (1981). *Khmers rouges! Matériaux pour l'histoire du communism au Cambodge*. Paris: J.-E. Hallier/ Albin Michel.

Thierry, Solange (1996). *Les Khmers*. Paris: Editions Kailash.

Thiounn, Okna Veang (2006). *Voyage du Roi Sisowath en France*. Traduit du khmer, présenté et annoté par Olivier de Bernon. Mercure de France.

Tong, André (1972). Sihanouk: *la fin des illusions*. Éditions de la Table Ronde.

Tranet, Michel (1981). *L'origine de la civilization et de la religiosité khmères*.

Tully, John. (2002). *France on the Mekong: A History of the Protectorate in Cambodia, 1863-1953*. University Press of America: New York.

Tully, John. (2006). A Short History of Cambodia: *From empire to survival*. Silkworms Book: Bangkok.

Van der Kraan, Alfons (2009). Murder and Mayhem in Seventeenth-Century Cambodia: *Anthony van Diemen vs. King Ramadhipati I*. Silkworm Book: Bangkok.

Vickery, Michael. (2005). *Cambodia: 1975-1982*. Silkworm Books, Thailand.

fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

Wetterhahn, Ralph (2001). The Last Battle: *The Mayaguez Indicent and the End of the Vietnam War*. Plume: New York.

Widyono, Benny (2008). Dancing in Shadows: *Sihanouk, the Khmer Rouge, and the United Nations in Cambodia*. Rowman & Littlefield Publishers.

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ក្នុងនីតិកាលទី៦នៃរាជរដ្ឋាភិបាលកម្ពុជា។

លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នៅឆ្នាំ១៩៨៨ និងបណ្ឌិតនៅឆ្នាំ១៩៩១ ផ្នែកសេដ្ឋកិច្ចអន្តរជាតិពីវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិក្រុងម៉ូស្គូ ព្រមទាំងសញ្ញាបត្រជាន់ខ្ពស់ផ្នែកធានាភ័ប់រង៉ពីវិទ្យាស្ថានធានាភ័ប់រង៉(CII) ប្រទេសអង់គ្លេស និងវិទ្យាស្ថានធានាភ័ប់រង៉ម៉ាឡេស៊ី (MII)។ នៅឆ្នាំ២០១២ លោកបណ្ឌិតទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រអន្តរជាតិពីសាកលវិទ្យាល័យកូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅកម្ពុជា និងពីសាកលវិទ្យាល័យLyon II នៃសាធារណរដ្ឋបារាំង ព្រមទាំងទទួលបានវិញ្ញាបនបត្រផ្នែកនីតិសមុទ្រពីបណ្ឌិត្យសភា Rhodes ផ្នែកនីតិសាស្ត្រ និងគោលនយោបាយសមុទ្រ។ នៅឆ្នាំ២០១៨ លោកបណ្ឌិតទទួលបានសញ្ញាបត្របណ្ឌិតផ្នែកអប់រំពីសាកលវិទ្យាល័យចូឡាឡុងកន។

លោកបណ្ឌិតធ្លាប់បានបម្រើការងារក្នុងបេសកកម្មការទូត និងក្នុងវិទ្យាស្ថានស្រាវជ្រាវ ជាអ្នកវិភាគនយោបាយ និងសេដ្ឋកិច្ច។ ចាប់តាំងពីឆ្នាំ១៩៩៩មក លោកបណ្ឌិតបានចូលបម្រើការងារក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទទួលបន្ទុកការងារសំខាន់ៗរួមមាន អ្នកសម្របសម្រួលការងារស្រាវជ្រាវនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងជាអនុប្រធានទី១នៃនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ។ បន្ទាប់មក ក្នុងឆ្នាំ២០០១ លោកបណ្ឌិតបានត្រូវតែងតាំងជាអគ្គលេខាធិការងទទួលបន្ទុកគោលនយោបាយរួមមាន គោលនយោបាយ

សេដ្ឋកិច្ច សារពើពន្ធ ហិរញ្ញវត្ថុ កិច្ចការអាស៊ាន ឧស្សាហកម្មហិរញ្ញវត្ថុ ការវិភាគសេដ្ឋកិច្ច និងទទួលបន្ទុកក្នុងការសម្របសម្រួលជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។

ពីឆ្នាំ២០០៤ដល់ឆ្នាំ២០១០ លោកបណ្ឌិតត្រូវបានតែងតាំងជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លោកបណ្ឌិតធ្លាប់ចូលរួមកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ានបួកបី ពីឆ្នាំ២០០០ដល់២០១០។ ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៣ លោកត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងតួនាទីនេះ លោកធ្លាប់ធ្វើជាតំណាងប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាល G20 ក្នុងឋានៈដែលប្រទេសកម្ពុជាជាប្រធានអាស៊ាន នៅឆ្នាំ២០១៦។ លោកបណ្ឌិតក៏បម្រើការងារជាអ្នកសម្របសម្រួលកិច្ចពិភាក្សាគោលនយោបាយរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយធនាអភិវឌ្ឍន៍អាស៊ី(ADB) មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។

ក្នុងតំណែងជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ដែលជាស្ថាប័នខាងផ្នែកគោលនយោបាយសេដ្ឋកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា លោកបណ្ឌិតបានសរសេរឯកសារគោលនយោបាយជាច្រើន និងបានអមដំណើរ សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្និសិទអន្តរជាតិ ដូចជាមហាសន្និបាតអង្គការសហប្រជាជាតិ ចលនាមិនចូលបក្សសម្ព័ន្ធ កិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងវេទិការអន្តរជាតិជាច្រើនទៀត។

លោកបណ្ឌិតបាននិពន្ធសៀវភៅជាច្រើនក្បាល ជាភាសាខ្មែរ អង់គ្លេស និងបារាំង ស្តីអំពីការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា និងហិរញ្ញវត្ថុសាធារណៈ ហើយស្នាដៃចុងក្រោយ ត្រូវបានចំណងជើងថា «Cambodian Economy:

Charting the Course for a Bright Future» ត្រូវបានជ្រើសរើសបោះ-ពុម្ពផ្សាយ ដោយវិទ្យាស្ថានសិក្សាអាស៊ីអាគ្នេយ៍(ISEAS) នៃប្រទេសសិង្ហបុរី។ ស្នាដៃចុងក្រោយរបស់លោក គឺ «វិភាគទានៃការសិក្សាអក្សរសិល្ប៍ខ្មែរក្នុងការលើកកម្ពស់អំណាននៅកម្ពុជា»។

ស្នាដៃរបស់អ្នកនិពន្ធ

១- L'Économie du Cambodge : La lutte pour le développement, 2005

២- Essais économiques, 2007

៣- Les finances publiques du Cambodge, 2007

៤- Cambodia: Recent Macroeconomic and Financial Sector Development, 2008

៥- Three Essays on Macroeconomic Management of Cambodia, 2008

៦- Introduction to Insurance, 2008

៧- ម៉ាក្រូសេដ្ឋកិច្ច - ឆ្នាំ២០០៩

៨- Public Finance in Cambodia, 2009

៩- ហិរញ្ញវត្ថុសាធារណៈ - ឆ្នាំ២០០៩

១០- ប្រាសាទព្រះវិហារ - ឆ្នាំ២០០៩

១១- Cambodian Economy: Chartering the Course of a Brighter Future. A Survey of Progress, Problems and Prospects, 2009

១២- L'économie du Cambodge: Nouvelles frontières du développement socio-économique, 2010

១៣- Regards sur le différend maritime khméro-thaïlandais à la lumière de la jurisprudence internationale, 2012

១៤- ទស្សនាទានស្តីពីវិវាទព្រំដែនសមុទ្រវាង‌កម្ពុជា និង‌ថៃ‌ឡង់ដ៍ ក្នុង‌បរិបទ‌នៃ‌យុត្តិការអន្តរជាតិ - ឆ្នាំ២០១៣

១៥- សេដ្ឋកិច្ចកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង ៖ វឌ្ឍនភាព

បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត - ឆ្នាំ២០១៥

១៦- កំណែទម្រង់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ៖
មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព - ឆ្នាំ២០១៦

១៧- គោលនយោបាយទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃប្រទេសកម្ពុជា
នាសម័យទំនើបនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា(ទសវត្សរ៍
ឆ្នាំ១៩៨០) - ឆ្នាំ២០១៧

១៨- នីតិអន្តរជាតិសេដ្ឋកិច្ច - ឆ្នាំ២០១៧

១៩- Series of Lectures in Public International Law, 2018

២០- សិក្ខាសង្ខេបស្តីពីទស្សនវិជ្ជា - ឆ្នាំ២០១៨

២១- Droit International Économique, 2018

២២- Education Reform in Cambodia, 2018

២៣-វិភាគទានៃការសិក្សាអក្សរសិល្ប៍ខ្មែរក្នុងការលើកកម្ពស់អំណាន
នៅកម្ពុជា - ឆ្នាំ២០១៩